# អដ្ឋកថា ព្រះសុត្តន្តបិដក

## សុមង្គលវិលាសិនី

## ចតុត្ថភាគ

## ភាគ ១៧

ពុទ្ធសករាជ ២៥៥៣

# អដ្ឋកថា ទីឃនិកាយ ចតុត្ថភាគ

## នៃព្រះសុត្តន្តបិដក

### មហាវគ្គវណ្ណនា

### ភាគ ១៧

ឈ្មោះ

# សុមង្គលវិលាសិនី

ពុទ្ធសករាជ ២៥៥៣

អធិប្បាយ

មហាសុទស្សន-ជនវសភ-មហាគោវិន្ទ-មហាសមយ-សក្កបញ្ហ-មហាសតិប្បដ្ឋាន-បាយាសិរាជញ្ញ

A

# Signes et accents:



B

# ស្រះពេញតួ
## Voyelles:

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | អ | អា | ឥ | ឦ | ឧ | ឩ | ឯ | ឱ |
| រូម Romain | a | .ā | i | ī | u | ū | e | o |
| សៀម Siamois | อ | อา | อิ | อี | อุ | อู | เอ | โอ |
| លាវ Laotien | ອະ | ອາ | ອິ | ອີ | ອຸ | ອູ | ເອ | ໂອ |
| លង្កា Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា Birman | အ | အာ | ဣ | ဤ | ဥ | ဦ | ဧ | ဩ |

## ព្យញ្ជនៈ

## *Consonnes:*

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង |
| ឡូប Romain | *k* | *kh* | *g* | *gh* | *ṅ* |
| សៀម Siamois | ก | ข | ค | ฆ | ง |
| លាវ Laotien | ກ | ຂ | ຄ | ຆ | ງ |
| លង្កា Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា Birman | က | ခ | ဂ | ဃ | င |

D


Cambodgien
Romain
c ch j jh ñ
Siamois
Laotien
Cinghalais
Birman

# E

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ដ | ឋ | ឌ | ឍ | ណ |
| រ៉ូម Romain | *ṭ* | *ṭh* | *ḍ* | *ḍh* | *ṇ* |
| សៀម Siamois | ฏ | ฐ | ฑ | ฒ | ณ |
| លាវ Laotien | ຏ | ຐ | ຑ | ຒ | ຓ |
| សិង្ហល Cinghalais | ට | ඨ | ඩ | ඪ | ණ |
| ភូមា Birman | ဋ | ဌ | ဍ | ဎ | ဏ |

# F

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ត្ត | ថ្ថ | ទ្ទ | ធ្ធ | ន្ន |
| បារាំង Français | *t* | *th* | *d* | *dh* | *n* |
| សៀម Siamois | ต | ถ | ท | ธ | น |
| លាវ Laotien | ຕ | ຖ | ດ | ທ | ນ |
| សិង្ហល Cinghalais | ත | ථ | ද | ධ | න |
| ភូមា Birman | တ | ထ | ဒ | ဓ | န |

G

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ប | ផ | ព | ភ | ម |
| [illegible] Romain | *p* | *ph* | *b* | *bh* | *m* |
| សៀម Siamois | ป | ผ | พ | ภ | ม |
| លាវ Laotien | ປ | ຜ | [illegible] | [illegible] | ມ |
| លង្កា Cinghalais | ප | ඵ | බ | භ | ම |
| ភូមា Birman | ပ | ဖ | ဗ | ဘ | မ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ខ្មែរ CAMBODGIEN | យ្យ | ្រ | ល្ល | វ្វ | ស្ស | ហ្ហ | ឡ | ំ | ។ |
| Romain | y | r | l | v | s | h | ḷ | ṃ | ./. |
| សៀម Siamois | ย | ร | ล | ว | ส | ห | ฬ | ํ | ฯ |
| លាវ Laotien | ຍ | ຣ | ລ | ວ | ສ | ຫ | ຬ | ໍ | ຯ |
| លង្កា Cinghalais | ය | ර | ල | ව | ස | හ | ළ | ං | । |
| ភូមា Birman | ယ | ရ | လ | ဝ | သ | ဟ | ဠ | ံ | ။ |

# ពាក្យផ្ដើម

*ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖*

***សុត្ត*** *បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើម ។*

***គេយ្យ*** *បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។*

***វេយ្យាករណ*** *គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមាន គាថា និងពុទ្ធវចនៈ ដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។*

***គាថា*** *គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។*

***ឧទាន*** *គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។*

*ឥតិវុត្តក គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។*

***ជាតក*** *គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។*

***អព្ភូតធម៌*** *គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។*

*វេទល្ល* គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស់ ព្រមទាំងបាននូវសេចក្តីរីករាយ និងសួរជាបន្ត ៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្តែងថា ៖

**ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម**

**ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត**

**មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល**

**បណ្ឌិតគប្បីដឹងបាន ។**

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្តីពិតក្នុងរឿងនោះ ៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេង ៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្វាសក្នុងវិធីសម្តែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគ មាន ៣ ប្រការ គឺ ៖

**១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង** ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

**២ ទ្រង់សម្តែងធម៌មានហេតុផល** ដែលអ្នកស្តាប់អាចពិចារណាឃើញតាម

សេចក្ដីពិតបាន ។

**៣ ទ្រង់សម្ដែងធម៌ដ៏អស្ចារ្យ** គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្ដែងនូវព្រះធម៌ដល់ បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថាការបានស្ដាប់នូវពុទ្ធោវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្ដែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្ដាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្ដីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិផ្សេង ៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធ-វចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដកនូវសេចក្ដីដែលលំបាកយល់ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្ដីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

**១ ព្រះសូត្រ** គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ ***សុត្តានុលោម*** គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយសេចក្តីដែលលំបាកក្នុងព្រះត្រៃបិដក ។

៣ ***អាចរិយវាទ*** វាទៈរបស់អាចារ្យផ្សេង ៗ តាំងអំពីថ្នាក់ដីកា អនុដីកា និងបុញ្ញាចារ្យជំនាន់ក្រោយ ៗ ។

៤ ***អត្តនោមតិ*** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្តែងធម៌ក្នុងព្រះពុទ្ធ-សាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាមអាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯង ដោយច្រើន ទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានឆន្ទៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមកហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹងក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មា-សម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះឱកាសដែលយល់ខុស និយាយខុស បដិបត្តិខុស ។ ព្រះត្រៃបិដក ប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដក

ពុទ្ធសាសនិកជនដែលល្អប្រកាន់ថា ធ្វើមិនបានដូចគ្នា ដូច្នោះ ។

សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ
របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ
សេចក្ដីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់
ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

សេចក្តីសង្ខេបថា ក្នុងទីបំផុតនៃការសម្តែងយមកប្បាដិហារ្យ ព្រះមានព្រះភាគជាម្ចាស់ ស្តេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្មកថាដល់ទេវបរិស័ទ លុះទ្រង់សម្តែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅ ពួកភិក្ខុវជ្ជីបុត្រសម្តែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះ ធម៌-វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្លាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន ឬ មិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវ យ៉ាងណាប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បីខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្ដាប់វត្ថុ ១០ ប្រការនោះហើយបានកាន់យកព្រះចៅអសោករាជដែលជា ព្រះឱរសរបស់ ព្រះចៅសុសុនាគៈធ្វើជាសម្ចាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសីរៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ គ្រាបានពួកដែលជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះម៉្យាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយគោកុលិកៈ ។ អាចរិយវាទដទៃទៀតឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងរវាងនិកាយពហុលិយៈនោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈដោយប្រការដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បាន

បានជាប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិសាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្ដាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និងធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពីត្រកូលអាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយ-សង្កន្តិកៈទាំងឡាយបែកគ្នាហើយ និកាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះ កើតឡើងហើយ ព្រោះបែកចេញមកពីថេរវាទយ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយវាទ ១១ និកាយនេះ រួមទាំងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្ដី ត្រកូលអាចារ្យ ១៨ ក្ដី ជាឈ្មោះរបស់និកាយ ដែលពោលមកហើយទាំងនោះឯង ។ម្យ៉ាងទៀត បណ្ដានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទបណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

## តារាងសម្ដែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្តេញចេញហើយ បានពួកដទៃទៀត ទើបផ្តើមតាំងជាគណាចារ្យថ្មី ។

( ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា **ព្រះពុទ្ធឃោសាចារ្យ** បានប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ព្រះភិក្ខុមាននាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង ( គម្ពីរអដ្ឋសាលិនី ) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យនោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះ ពុទ្ធឃោសៈតែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការរកសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធឃោសាចារ្យជាអ្នកស្រុកជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ពុទ្ធគយាដែនមគធៈ ជិតស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធ-សាសនា បានសិក្សាសិល្បសាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅកាន់ទីផ្សេង ៗ ក្នុងជម្ពូទ្វីប បានឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នកមានសតិបញ្ញាច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃ ៗ មិនអាចឆ្លើយដោះស្រាយបញ្ហាព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហាដែលសមណព្រាហ្មណ៍ និង

បណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះបោះសំឡេងខ្ទរខ្ទារ គ្របសង្កត់រហូតសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធគយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេចបដិសម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេង ៗ ក្នុងគម្ពីរត្រៃវេទដែលខ្លួននៅមានការសង្ស័យមិនយល់ ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះ ៗ ព្រាហ្មណ៍កំលោះ ឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថា **ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថាព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនាបករណ៍ឈ្មោះ **ញាណោទ័យ** ទុកក្នុងវត្ត ហើយផ្តើមរចនាគម្ពីរអដ្ឋកថា ឈ្មោះអដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈ បានឃើញអដ្ឋកថា

ដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលី ព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កា-ទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយមានព្រះ សារីបុត្ត ( ឈ្មោះដូចអគ្គសាវក ) ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុក ជាភាសាសីហឡៈ សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើល អដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និង សេចក្ដីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះ ហើយ ព្រះពុទ្ធឃោសៈ ក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធ-ទត្តត្ថេរៈ ដែលបាននិមន្តជ្រួសជ្រប់គ្នានៅកណ្ដាលសមុទ្រ បានសន្ទនាគ្នា និង ប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅរហូតដល់ កំពង់ផែក្រុងលង្កា សម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថា មហានាម មាននាមដទៃទៀតថា ( សិរិនិវាស ) ខ្វះ ( សិរិកុថៈ ) ខ្វះ ( សិរិកូដ្ឋៈ ) ខ្វះ ពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុង មហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្ដាប់ អដ្ឋកថាជាភាសាសីហឡៈ និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថា ជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិ អំពីសង្ឃ

ដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធ: ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរ:ជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោករចនាសិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបានរចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្តីយ៉ាងល្អប្រសើរ រហូតដល់ព្រះសង្ឃលង្កាទទួលស្គាល់នូវសេចក្តីជំនាញរបស់លោក តាមប្រវត្តិបាននិយាយថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតាបានបណ្តាលឲ្យគម្ពីរដែលរចនាស្រេចហើយ បាត់ទៅ ព្រះពុទ្ធឃោសៈក៏បានរចនាជាថ្មីម្តងទៀត ទេវតាក៏បណ្តាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្តងទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញវេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរប្រៀបធៀបគ្នាហើយ មិនមានការខុសគ្នាទាំងដោយព្រះគម្ពីរ ឬអក្ខរ: ឬដោយបទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុងឬ ដោយថេរវាទ ឬដោយព្រះបាលី ទាំងឡាយក្នុងកន្លែងណាមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បីសម្តែងសេចក្តីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការ ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញសេចក្តីអស្ចារ្យ នាំគ្នាត្រេកអរ កោតសរសើរ សោមនស្ស សាធុការ បានប្រកាសថា លោកអង្គនេះជាព្រះមេត្តេយ្យពោធិសត្វ ពិតប្រាកដ និងបានអនុមតិ

ឲ្យលោកប្រែគម្ពីរ ពីភាសាសីហឡ:មកជាភាសាមគធ: ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្តាប់កិត្តិគុណរបស់លោក ស្តេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ ហើយនមស្ការព្រះពុទ្ធឃោស:និមន្តឲ្យគង់នៅក្នុងប្រាសាទមួយ ឈ្មោះ **បធានឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡ:ជាអដ្ឋកថាព្រះត្រៃបិដកភាសាមគធ: ។

អដ្ឋកថាក្នុងភាសាសីហឡ:ពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរិយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា

ព្រះមហិន្ទត្ថេរ:នាំមកពីជម្ពូទ្វីប ហើយរចនាទុកជាភាសាសីហឡ:ឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ ( ផ្ទះទឹក ) ដែលក្នុងភាសាសីហឡ:ហៅថា បច្ចរិយ: ឈ្មោះថា **បច្ចរិយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទ:ដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរ:ជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡ: ដែលព្រះពុទ្ធឃោស:បានប្រែមកជាអដ្ឋ-

កថាព្រះត្រៃបិដកជាភាសាមគធៈ មានច្រើនជាងពាក់កណ្ដាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលបញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលនៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្ដីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបោរាណាចារ្យយ៉ាងសំខាន់ក្រៃ-លែងរបស់លោក ។

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុផាត

ឧបាសក ក្អាត ហ៊ាន

ឧបាសក ទុំ ទួន

ឧបាសក ជឹម ជំនិត

ឧបាសក សន ម៉ារឌី

ឧបាសក អុឹម រ៉ៃយ៉ា

ឧបាសក សំ ឆាយ

ឧបាសិកា ហាយ សារ៉ាត់

ឧបាសិកា យស សម្បត្តិ

ឧបាសក នាក់ ម៉ៅ

ឧបាសក ហុក សឹងហួត

ឧបាសក កើត ទិត្យ

ឧបាសក ហាយ ចំរើន

ឧបាសក សុក្រ ហ៊ត

ឧបាសិកា ថាប់ លឿម

ឧបាសិកា ប៊ុត សុម៉ាលី

ឧបាសិកា ពូ ហ៊ាង

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

## ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

| | | |
|---|---|---|
| ព្រះភិក្ខុអគ្គទិន្នោ | នូវ ប៉ូរ៉ា | ប្រធានអាស្រម |
| ព្រះភិក្ខុចិត្តរក្ខិតោ | សំ សម្បត្តិ | ធម្មាចារ្យ |
| ព្រះភិក្ខុវរធម្មោ | ផុត តៅ | ធម្មាចារ្យ |
| ព្រះភិក្ខុសារញ្ញាណោ | ស សត្ថា | ធម្មាចារ្យ |

ព្រះភិក្ខុកល្យាណធម្មោ យឿន កល្យាណ វិនយាចារ្យ

ព្រះភិក្ខុបវរធម្មោ អ៊ុល សុធា សមណសិស្ស សាលាសតិប្បដ្ឋាន

សាមណេរ កោវិទោ ឡោះ សូវៀត សមណសិស្ស សាលាសតិប្បដ្ឋាន

## ផ្នែកឧបាសក

| | |
|---|---|
| ឧបាសក ក្អាត ហ៊ន | ឧបាសក ហាយ ចំរើន |
| ឧបាសក សន ម៉ារឌី | ឧបាសក អ៊ឹម រ៉ៃយ៉ា |
| ឧបាសក ទុំ ទូន | ឧបាសក ហុក សឹងហួត |

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់ ៥.០០០ ព្រះវស្សា ។

យើងខ្ញុំជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះ ៖-

ឧទ្ទិសថ្វាយ និងគោរពជូន:

-ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

-មាតាបិតានៃយើងខ្ញុំទាំងអស់គ្នា

-លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

-លោកគ្រូធម្មបណ្ឌិត រស់ សុផាត

-សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

-សព្វសត្វទាំងអស់ក្នុងត្រៃភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះបានស្មើ ៗ គ្នា

សូមអនុមោទនា !.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌

| ឈ្មោះធម៌ | ទំព័រ |
| --- | --- |
| **អដ្ឋកថា មហាសុទស្សនសូត្រ ទី ៤** | |
| ពោលអំពី កុសាវតីរាជធានី | ១ |
| ពោលអំពី ចក្ករតន៍ | ៤ |
| ពោលអំពី ដំរីរតន៍ | ២០ |
| ពោលអំពី សេះរតន៍ | ២២ |
| ពោលអំពី មណីរតន៍ | ២៤ |
| ពោលអំពី ស្ត្រីរតន៍ | ២៥ |
| ពោលអំពី គហបតីរតន៍ | ២៨ |
| ពោលអំពី បរិនាយករតន៍ | ២៩ |
| ពោលអំពី ឫទ្ធិ ៤ យ៉ាង | ៣០ |
| ពោលអំពី ធម្មប្រាសាទបោក្ខរណី | ៣១ |
| **ទុតិយភាណវារៈ** | |
| ពោលអំពី ឧទានរបស់ព្រះបាទមហាសុទស្សនៈ | ៣៧ |
| ពោលអំពី ព្រះនាងសុភទ្ទាទេវី | ៤៣ |
| បច្ឆិមជាតិរបស់ព្រះបាទមហាសុទស្សនៈ | ៤៤ |
| **អដ្ឋកថា ជនវសភសូត្រ ទី ៥** | |
| ទ្រង់ព្យាករណ៍កំណើតបញ្ញា និងគតិ និងបុណ្យ | ៥០ |
| ពោលអំពី សេចក្តីត្រិះរិះរបស់ព្រះអានន្ទ | ៥១ |
| ពោលអំពី ជនវសភយក្ស | ៥៣ |
| ពោលអំពី សនង្កុមារព្រហ្ម | ៥៦ |

ពោលអំពី អានិសង្សនៃការបម្រើនឥទ្ធិបាទ ៦០
ពោលអំពី ការបាននូវឱកាសទី ១ ៦៥
ពោលអំពី ការបាននូវឱកាសទី ២-ទី ៣ ៦៦
ពោលអំពី សតិប្បដ្ឋាន ៤ ៦៩
ពោលអំពី ធម្មគុណ ៦៩
ពោលអំពី ការជំណាលប្រាប់គ្នាតៗ ៧២

## អដ្ឋកថា មហាគោវិន្ទសូត្រ ទី ៦

មហារាជទាំង ៤ ៧៣
ការពោលចចាររបស់ពួកទេវតាពួកខ្លះ ៩៩
ការនិម្មិតអត្តភាព ...... ១០២
រឿងព្រះរេណុរាជបុត្រ ១០៦
កិត្តិសព្ទរបស់មហាគោវិន្ទព្រាហ្មណ៍ ១១០
ការឆ្លើយឆ្លងជាមួយសនង្កុមារព្រហ្ម ១១៣
ការសួរអំពីដំណើរទៅកាន់ព្រហ្មលោក ១១៦
ការពោលអំពីក្លិនពុល ១១៧
ពោលអំពី ការលាក្សត្រទាំង ៦ អង្គ ១២៥
ការអង្វររបស់ក្សត្រទាំង ៦ អង្គ ...... ១២៧

## អដ្ឋកថា មហាសមយសូត្រ ទី ៧

-------------------- ១៣៤
គាថានីមួយៗ នៃទេវតាជាន់សុទ្ធាវាស ១៥២
នាម និងគោត្តរបស់ពួកទេវតា ១៦៣
ពាក្យរបស់មារ ១៨២

## អដ្ឋកថា សក្កបញ្ហាសូត្រ ទី ៨


----------------- ១៩២

គាថារបស់បញ្ចសិខគន្ធព្វទេវបុត្ត ២០១

រឿងបញ្ចសិខគន្ធព្វទេវបុត្ត ២០៧

ការត្រិះរិះរបស់ទេវានមិន្ទ ២១០

គោបិកាសក្យធីតា ២១៩

ព្រហ្មមានព្រះភាគទ្រង់ត្រិះរិះ ២២៤

ប្រស្នាព្រះឥន្ទ ព្រះមានព្រះភាគទ្រង់ព្យាករណ៍ ២៤៦

ព្រះមានព្រះភាគទ្រង់ព្យាករណ៍បញ្ហា ១៤ ប្រការ ២៩៥

ការនិយាយអំពីសមណព្រាហ្មណ៍ដទៃ ២៩៧

សង្គ្រាមទេវតា និងអសុរ ២៩៨

អំណាចប្រយោជន៍ ៦ ប្រការ ២៩៩


## អដ្ឋកថា សតិប្បដ្ឋានសូត្រ ទី ៩


ឧទ្ទេសវារៈ ៣០៤

រឿងសត្វសោក ៣០៦

អធិប្បាយសេចក្តីលំដាប់បទ ៣០៨

ធម្មសាកច្ឆារបស់ព្រះមហាថេរៈ ៣១២

អធិប្បាយមគ្គ ៣១៥

ទុក្ខរបស់ព្រះតិស្សត្ថេរ ៣១៩

ទុក្ខរបស់ភិក្ខុ ៣០ រូប ៣២០

ទុក្ខរបស់ព្រះបីតិមល្លត្ថេរ ៣២២

រឿងទោមនស្សរបស់ស្តេចសក្កៈ ៣២៤

រឿងទោមនស្សរបស់សុព្រហ្មទេវបុត្ត ៣២៥

| | |
|---|---|
| អធិប្បាយ សតិប្បដ្ឋាន | ៣៣២ |
| បាលីវិគត្ត | ៣៥១ |
| ឧទ្ទេសវារៈនៃវេទនាចិត្តធម្មានុបស្សនា | ៣៥៤ |
| និទ្ទេសវារៈកាយានុបស្សនាសតិប្បដ្ឋាន | ៣៥៨ |
| អានាបានបព្វៈ | ៣៥៩ |
| សេនាសនៈសមគួរ ...... | ៣៦២ |
| កំណត់ខ្យល់អស្សាសបស្សាសៈ | ៣៦៤ |
| អានាបានស្សតិ ជាអរិយសច្ចៈ ៤ | ៣៦៩ |
| ឥរិយាបថបព្វៈ | ៣៧១ |
| ឥរិយាបថខាងក្នុង ខាងក្រៅ | ៣៧៥ |
| សតិកំណត់ឥរិយាបថ ជាអរិយសច្ចៈ | ៣៧៦ |
| សម្បជញ្ញបព្វៈ | ៣៧៧ |
| បដិកូលមនសិការបព្វៈ | ៣៧៩ |
| ធាតុមនសិការបព្វៈ | ៣៨១ |
| នវសីវថិកាបព្វៈ | ៣៨៤ |
| កាយប្រាសចាកអាយុ កម្តៅ វិញ្ញាណ | ៣៨៦ |
| វេទនានុបស្សនាសតិប្បដ្ឋាន | ៣៩២ |
| វេទនាជាអរូបកម្មដ្ឋាន | ៣៩៥ |
| វេទនាជាសាមិសៈ និងនិរាមិសៈ | ៣៩៧ |
| វេទនាក្នុង វេទនាក្រៅ | ៣៩៨ |
| ចិត្តានុបស្សនាសតិប្បដ្ឋាន | ៤០០ |
| ចិត្តក្នុង ចិត្តក្រៅ | ៤០២ |
| ធម្មានុបស្សនាសតិប្បដ្ឋាន | ៤០៤ |
| នីវរណបព្វៈ , ហេតុកើតកាមច្ឆន្ទៈ | ៤០៥ |
| ហេតុកើតព្យាបាទៈ , ហេតុលះព្យាបាទៈ | ៤១០ |
| ហេតុកើតថីនមិទ្ធៈ | ៤១២ |
| ហេតុកើតឧទ្ធច្ចកុក្កុច្ចៈ | ៤១៥ |

| | |
|---|---|
| ហេតុកើតវិចិកិច្ឆា | ៤១៨ |
| សតិកំណត់នីវរណៈ ជាអរិយសច្ចៈ ៤ | ៤២១ |
| ខន្ធបព្វៈ | ៤២២ |
| សតិកំណត់ខន្ធ ៥ ជាអរិយសច្ចៈ ៤ | ៤២៣ |
| អាយតនបព្វៈ | ៤២៥ |
| ហេតុកើតសំយោជនៈ | ៤២៦ |
| សតិកំណត់អាយតនៈ ជាអរិយសច្ចៈ ៤ | ៤២៩ |
| ពោជ្ឈង្គបព្វៈ | ៤៣០ |
| ធម៌ជាហេតុកើតសតិសម្ពោជ្ឈង្គៈ | ៤៣១ |
| ធម៌ជាហេតុកើតធម្មវិចយសម្ពោជ្ឈង្គៈ | ៤៣៣ |
| វីរិយសម្ពោជ្ឈង្គៈ | ៤៣៩ |
| ការពិចារណាឃើញភ័យក្នុងអបាយ | ៤៤០ |
| ការឃើញអានិសង្ស | ៤៤១ |
| ការពិចារណាវិថីនៃដំណើរ | ៤៤២ |
| ការគោរពកោតក្រែងក្នុងបិណ្ឌបាត | ៤៤២ |
| រឿងព្រះមហាមិត្តត្ថេរ | ៤៤៣ |
| ការពិចារណានូវទ្រព្យមត៌កជាធំ | ៤៤៦ |
| ការពិចារណា ព្រះសាស្តាជាធំ | ៤៤៧ |
| ការពិចារណា ជាតិជាធំ | ៤៤៨ |
| ការពិចារណា សព្រហ្មចារីជាធំ | ៤៤៨ |
| ការបង្អោនចិត្តទៅក្នុងវីរិយសម្ពោជ្ឈង្គៈ | ៤៤៩ |
| បីតិសម្ពោជ្ឈង្គៈ | ៤៤៩ |
| បស្សទ្ធិសម្ពោជ្ឈង្គៈ | ៤៥២ |
| សមាធិសម្ពោជ្ឈង្គៈ | ៤៥៥ |
| អធិប្បាយធម៌ ១១ ប្រការ | ៤៥៦ |
| ឧបេក្ខាសម្ពោជ្ឈង្គៈ | ៤៥៩ |
| អធិប្បាយធម៌ ៥ ប្រការ | ៤៦០ |

| | |
|---|---|
| សតិកំណត់ពោជ្ឈង្គៈ ជាអរិយសច្ចៈ | ៤៦៣ |
| សច្ចបព្វៈ | ៤៦៤ |
| អធិប្បាយបទភាជនៈ , ជាតិ | ៤៦៥ |
| ជរា | ៤៦៦ |
| មរណៈ | ៤៦៨ |
| សោកៈ , បរិទេវៈ | ៤៧០ |
| ទុក្ខៈ , ទោមនស្សៈ , ឧបាយាសៈ | ៤៧១ |
| ការមិនបានតាមសេចក្ដីប្រាថ្នាជាទុក្ខ | ៤៧២ |
| សមុទយអរិយសច្ចៈ | ៤៧៣ |
| ទុក្ខនិរោធអរិយសច្ចៈ | ៤៧៦ |
| ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ | ៤៧៩ |
| សម្មាសង្កប្បៈ , សម្មាវាចា | ៤៨២ |
| សម្មាកម្មន្តៈ , សម្មាអាជីវៈ | ៤៨៣ |
| សម្មាវាយាមៈ | ៤៨៤ |
| សម្មាសតិ , សម្មាសមាធិ | ៤៨៦ |
| សតិកំណត់សច្ចៈ ៤ ជាអរិយសច្ចៈ | ៤៨៩ |
| សរុបសេចក្ដី | ៤៩០ |
| អានិសង្ស | ៤៩១ |


## អដ្ឋកថា ចាយាសិរាជញ្ញសូត្រ ទី ១០


| | |
|---|---|
| ប្រវត្តិព្រះកុមារកស្សបៈ | ៤៩៤ |
| រឿង ព្រះគវម្បតិ | ៥១០ |

# សុមង្គលវិលាសិនី

## អដ្ឋកថា ទីឃនិកាយ

## មហាវគ្គវណ្ណនា

## ភាគ ១៧

## អដ្ឋកថា មហាសុទស្សនសូត្រ ទី៤

### ពោលអំពី កុសាវតីរាជធានី

[១] *មហាសុទស្សនសូត្រមានពាក្យផ្ដើមថា ខ្ញុំបានស្ដាប់មកហើយយ៉ាងនេះ ។*

*ការពណ៌នាតាមលំដាប់បទ ក្នុងមហាសុទស្សនសូត្រនោះ មានដូច្នេះ ៖*

*ក្នុងពាក្យថា* ***យកកែវគ្រប់យ៉ាង មកសាងលើគ្នា*** *នោះ ឥដ្ឋមួយដុំធ្វើដោយមាស , មួយដុំធ្វើដោយប្រាក់ , មួយដុំធ្វើដោយកែវពិទូរ្យ , មួយដុំធ្វើដោយកែវផលិក , មួយដុំធ្វើដោយកែវទទឹម , មួយដុំធ្វើដោយកែវមរកត , មួយដុំធ្វើដោយកែវគ្រប់យ៉ាង ។ កំពែងនេះ នៅខាងក្នុងកំពែងទាំងអស់ ខ្ពស់ប្រមាណ ៦០ ហត្ថ ។ តែព្រះថេរៈពួកមួយពោលថា*

នគរនេះ កាលគេឈរខាងក្រៅក្រឡេកមើល ក៏ទីងមានសណ្ឋានមូល ព្រោះដូច្នោះ កំពែងដែលនៅខាងក្រៅទាំងអស់ ទើបកម្ពស់ ៦០ ហត្ថ កំពែងដ៏សេស ទើបទាបដោយលំដាប់ ។ ពួកខ្លះពោលថា នគរនេះ កាលគេឈរមើលពីខាងក្រៅ ក៏ទីងមានសណ្ឋានមូល ព្រោះដូច្នោះ កំពែងក្នុងទីបំផុត ទើបខ្ពស់ ៦០ ហត្ថ កំពែងដ៏សេស ទើបទាបតាមលំដាប់ ។ ពួកខ្លះពោលថា នគរនេះ កាលគេឈរនៅខាងក្នុង និងខាងក្រៅក្រឡេកមើល ក៏ទីងមានសណ្ឋានមូល ព្រោះដូច្នោះ លោកពោលកំពែងខាងក្នុង ទើបខ្ពស់ ៦០ ហត្ថ ។ កំពែងខាងក្នុង ៣ កន្លែង និងខាងក្រៅ ៣ កន្លែង ទើបទាបដោយលំដាប់ ។

បទថា ឯកសិកា គឺ សសរខឿន ។ បទថា តិបោរិសង្គា សេចក្តីថា ៣ ជួរបុរស រួមគ្នាជា ១៥ ហត្ថ ។ ក៏សសរខឿនទាំងនោះ តាំងនៅយ៉ាងណា ។ ដោយខាងក្រៅព្រះនគរ ជិតស្នាបទ្វារធំ តែមួយកន្លែងមានសសរខឿន ១ ដើមៗ , ជិតស្នាបទ្វារតូច តែមួយកន្លែង មានសសរខឿន ១ ដើមៗ , ចន្លោះទ្វារធំ និងទ្វារតូច មួយកន្លែង ៣ ដើម ។

បណ្តាដើមត្នោតដែលធ្វើដោយរតនៈទាំងអស់ ក្នុងជួរត្នោតទាំងឡាយ ត្នោតមួយដើមធ្វើដោយមាស ព្រោះដូច្នោះ គប្បីជ្រាបលក្ខណៈ

ដែលពោលហើយក្នុងកំពែងនោះឯង ។ សូម្បីក្នុងស្ទឹក និងផ្ទៃទាំងឡាយ ក៏មានន័យដូចគ្នា ។ ក៏ដូរគ្នោតទាំងនោះ កម្ពស់ ៨០ហត្ថ តាំងនៅក្នុងចន្លោះកំពែង មួយកន្លែង ១ ដូរ ក្នុងផ្ទៃដីរាបស្មើ ដែលចាក់រោយដោយខ្សាច់ ។ បទថា វគ្គូ បានដល់ ឈ្មោសវៃ ។ បទថា រជនីយោ សេចក្ដីថា គួរត្រេកអរ ។ បទថា កមនីយោ សេចក្ដីថា កាលស្ដាប់សូម្បីអស់មួយថ្ងៃ ក៏មិនទៀយណាយ ។ បទថា មទនីយោ ប្រែថា ធ្វើឲ្យកើតជក់ចិត្តដល់បុគ្គល ។ បទថា បញ្ចង្គិកស្ស សេចក្ដីថា ប្រកបដោយ អង្គ ៥ ប្រការ គឺ **អាតដ: វិតដ: អាតដវិតដ: សុសិរ: ឃន:** ។ ក្នុងអង្គ ៥ ប្រការនោះ គ្រឿងប្រគំ ដែលពាសស្បែកមុខតែម្ខាង ក្នុងបណ្ដាស្គរជាដើម ដែលពាសដោយស្បែក ឈ្មោះថា **អាតដ:** , គ្រឿងប្រគំដែលពាសទាំង ២ ខាង ឈ្មោះថា **វិតដ:** , គ្រឿងប្រគំដែលពាសទាំងអស់ ឈ្មោះថា **អាតដវិតដ:** ។ ប៉ី និងស័ង្ខជាដើម ឈ្មោះថា **សុសិរ:** ។ កណ្ដឹងជាដើម ឈ្មោះថា **ឃន:** ។ បទថា សុវិនីតស្ស សេចក្ដីថា សន្ទឹងល្អហើយ ហើយធ្វើឲ្យធូរជាដើម ។ បទថា សុប្បដិតាឡិតស្ស សេចក្ដីថា វាយធៀបល្អហើយ ដើម្បីឲ្យដឹងថា ល្មមហើយ ។ បទថា កុសលេហិ សមន្នាហតស្ស សេចក្ដីថា ប្រគំដោយអ្នកស្ទាត់ជំនាញ ដែលអាចលេង

ក្មេងបាន ។ បទថា ធុត្តា គឺ អ្នកលេងក្បាល់ ។ បទថា សោណ្ឌា សេចក្តីថា អ្នកលេងសុរា ។ អ្នកលេងសុរាទាំងនោះឯង ឈ្មោះថា អ្នកផឹក ដោយការផឹករឿយៗ ។ បទថា បរិចារេសុំ ប្រែថា លើកដៃជើងតាមចង្វាក់រាំលេង ។

## ពោលអំពីចក្ករតន៍

[២] បទថា សីសន្ហាតស្ស ប្រែថា ទ្រង់កក់ដោយទឹកក្លិនក្រអូបសព្វព្រះសិរសា ។

បទថា ឧបោសថិកស្ស សេចក្តីថា ទ្រង់សមាទានអដ្ឋង្គឧបោសថ ។ បទថា ឧបរិបាសាទវរគតស្ស សេចក្តីថា ស្តេចឡើងកាន់ប្រាសាទដ៏ប្រសើរ ទ្រង់សោយព្រះក្រយាហារហើយ ស្តេចចូលទៅកាន់បន្ទប់សិរីខាងលើ គឺលើផែនដីធំនៃព្រះប្រាសាទដ៏ប្រសើរ ហើយទ្រង់រឭកដល់សីល ។ បានឮថា គ្រានោះ ព្រះរាជាទ្រង់ដោះស្រាយបញ្ហាទាំងសែន តាំងពីព្រឹកព្រលឹម ហើយទ្រង់ថ្វាយមហាទាន ទ្រង់ជម្រះព្រះសិរសា ដោយទឹកក្រអូប ១៦ ឆ្នាំង សោយព្រះក្រយាហារព្រឹក ទ្រង់ដណ្តប់ស្បៃដ៏បរិសុទ្ធិ ប្រថាប់អង្គុយសមាធិក្នុងបន្ទប់ផ្ទំ លើប្រាសាទដ៏ប្រសើរ ទ្រង់រឭកដល់ហេតុនៃបុណ្យ

ដែលសម្រេចដោយទាន ទមៈ និងសញ្ញមៈរបស់ព្រះអង្គ ។ នេះជាធម្មតា របស់ស្តេចចក្រពត្តិទាំងពួង ។ កាលស្តេចចក្រពត្តិទាំងនោះ ទ្រង់រក្សា ដល់សីលយ៉ាងនោះ ចក្ករតនៈដែលជាទិព្វ ដូចជាដុំកែវមណីពណ៌ខៀវ ដែលមានសមុដ្ឋានអំពីបុញ្ញកម្ម បច្ច័យ និងរដូវ ដូចពោលហើយ រមែង ប្រាកដដូចផ្ទៃទឹកសមុទ្រ នាទិសបស្ចិមត្រូវលេកបក់ចេញ ដូចអាកាស ដែលប្រដាប់ប្រដាហើយ ដូច្នោះ ។ ចក្ករតនៈនោះ បានប្រាកដដល់ ព្រះបាទមហាសុទស្សនចក្រពត្តិរាជ ដូច្នោះ ។

ចក្ករតនៈនេះ លោកពោលថា ជាទិព្វ ព្រោះប្រកបដោយអានុភាព ដែលជាទិព្វ ។ ចក្ករតនៈមានកាំទាំងពាន់ ទើបឈ្មោះថា សហស្សារំ ។ ព្រមទាំងខ្នងកង់ ព្រមទាំងដុំ ទើបឈ្មោះថា សនេមិកំ សនាភិកំ ។ បរិបូរណ៍ដោយអាការទាំងពួង ទើបឈ្មោះថា សព្វាការបរិបូរំ ។

ចក្រក្នុងមហាសុទស្សនសូត្រនោះផង ជារតនៈផង ព្រោះអត្ថថា ឲ្យ កើតសេចក្តីត្រេកអរ ព្រោះដូច្នោះ ទើបឈ្មោះថា ចក្ករតនៈ ។ ក៏ចក្ក-រតនៈលោកពោលថា សនាភិកំ ដោយដុំណា ដុំនោះ ធ្វើដោយកែវមណី ពណ៌ខៀវ ។ ក៏ផ្ទៃកកណ្តាលនៃដុំ ដែលធ្វើដោយប្រាក់ រុងរោចន៍ដូច ប្រៀតប្រៀតដោយរបៀបធ្មេញដ៏សស្និទ្ធ ។ ស្រោបដោយផែនប្រាក់ ទាំង

ខាងក្រៅ និងខាងក្នុង ទាំងពីរ ដូចមណ្ឌលនៃព្រះច័ន្ទ ដែលមានចំណុច ក្នុងកណ្តាល ដូច្នោះ ។ ក៏ក្បូរក្បាច់ដែលឆ្លាក់ក្នុងទីដ៏សមគួរ ក្នុងផែន ស្រោបដុំ និងកាំនោះ ប្រាកដថា ចាត់ចែកទុកយ៉ាងល្អ ។ សេចក្តីបរិបូរណ៍ ដោយអាការទាំងពួងនៃដុំ នៃចក្ករតន៍ ត្រឹមតែប៉ុណ្ណេះមុន ។ ចក្ករតន៍ នោះ លោកពោលថា សហស្សារំ ដោយកាំពួកណា កាំទាំងនោះ ធ្វើដោយ រតនៈ ៧ ប្រការ ដល់ព្រមដោយពន្លឺ ដូចរស្មីនៃព្រះអាទិត្យ ដូច្នោះ ។ អាការ មានក្បាច់ក្បូរដោយដុំកែវនៃកាំសូម្បីទាំងនេះ ប្រាកដជាចក្រ បែង ចែកាយ៉ាងល្អ ។ នេះជាសេចក្តីសម្បូរណ៍ដោយអាការទាំងពួង របស់កាំ នៃចក្ករតន៍នោះ ។ មួ៉ាងទៀត ចក្ករតន៍នោះ លោកពោលថា សនេមិកំ ដោយខ្នងកង់ណា កង់នោះ ធ្វើដោយកែវប្រវាឡក្រហម បរិសុទ្ធិស្និទ្ធ ដូច ជាចំអកដល់សិរីនៃក្រុមរស្មីព្រះអាទិត្យស្រទន់ៗ ដូច្នោះ ។ ក៏ក្នុងទី.តនៃ កង់នោះ ក្បាច់ដែលឆ្លាក់មានសិរីជាដុំស ក្រហម បរិសុទ្ធល្អ ដេរដាស់ ដោយជម្ពូនុទពណ៌ក្រហម ប្រាកដជាការចាត់ចែកទុកយ៉ាងល្អ ។ នេះគឺ សេចក្តីបរិបូរណ៍ដោយអាការទាំងពួងនៃកង់ចក្ករតន៍នោះ ។ ក៏ក្នុងចន្លោះ កាំទាំង ១០ នៃចក្ករតន៍នោះ ក្នុងខាងខ្នងនៃបរិវេណកង់ មានដុំកែវប្រវាឡ ចាប់ខ្យល់ ឆ្លាក់ជាក្បាល ខាងក្នុងដូចដុំផ្សែង ដូច្នោះ ។

ចក្ករតន៍ណាដែលត្រូវខ្យល់ហើយ មានសំឡេងពីរោះ ទាក់ទាញចិត្ត បបួលឲ្យស្ដាប់ ឲ្យរំភើបដូចសំឡេងតន្ត្រីដែលប្រកបដោយអង្គ ៥ ដែលលេងក្មេងដោយអ្នកជំនាញល្អហើយដូច្នោះ ក៏ចក្ករតន៍នោះ ក្នុងខាងលើនៃដងកែវប្រវាឡ មានឆត្រសទាំងពីរខាង មានជួរក្បាច់ផ្កាមាស រួមគ្នាជាពីរជួរ ខាងក្នុងដុំ និងកាំសូម្បីទាំងពីរ ស្រោបកង់ដ៏ល្អ ព្រមដោយដងកែវប្រវាឡ ១០០ ទ្រទ្រង់ឆត្រសរាប់រយ មានជួរក្បាច់ផ្កាមាស ដែលរួមប្រជុំ ២០០ យ៉ាងនេះជាបរិវារ មានមុខសីហៈពីរ មានកម្រងកែវមុក្ដាប្រមាណប៉ុនដើមត្នោត ២ កួង ដែលស្អាតល្អ ដូចពន្លឺព្រះចន្ទពេញវង់ដេរដាស់ដោយសំពត់កម្ពលពណ៌ក្រហម ប្រៀបដូចដួងព្រះអាទិត្យមានកំដៅស្រទន់ នឹងសភាពល្អលួះដែលផ្សាយខ្វេខ្វាយក្នុងអាកាស និងទន្ទេគន្ធាដូច្នោះ បន្ទាន់រំយោល មានវង់ចក្ក ៣ ព្រមនឹងចក្ករតន៍ ប្រាកដដូចជាវិលក្នុងអាកាស ព្រមគ្នាដូច្នោះ នេះសេចក្ដីបរិសុទ្ធិគ្រប់យ៉ាង ដោយប្រការទាំងពួងនៃចក្ករតន៍នោះ ។

ក៏ចក្ករតន៍នេះ សម្បូរណ៍ដោយអាការទាំងពួងដូច្នេះ ដូចគ្នានឹងក្រុមមនុស្សបរិភោគអាហារត្រជាក់តាមប្រក្រតី អង្គុយលើអាសនៈដែលក្រាលត្រង់ទ្វារស្រុករៀងៗ ខ្លួនសន្ទនាគ្នា ក្មេងៗ កំពុងលេងក្នុងទីផ្លូវបែកជា ៤

ជាដើម ក្នុងអាកាសមិនខ្ពស់ពេកមិនទាបពេក ប្រមាណចុងឈើ ឲ្យស្វាង ស្វៃ ដូចឲ្យបានឮសំឡេងសត្វទាំងឡាយ នូវសំឡេងដ៏ពីរោះដែលស្តាប់បានតាំងពីចុងមែកឈើ ដល់ ១២ យោជន៍ ធ្វើឲ្យនេត្រាមើលឃើញនូវពណ៌ដែលរុងរឿងដោយពន្លឺផ្សេងៗ ដល់មួយយោជន៍ ដូចជាឃោសនានូវបុញ្ញានុភាពនៃស្តេចចក្រពត្តិ ត្រឡប់មកកាន់រាជធានី ។ លំដាប់នោះដោយការស្តាប់សំឡេងចក្ររតន៍នុ៎ះឯង ពពួកមនុស្សដែលក្រឡេកមើលទិសខាងកើត មានការផ្តោតចិត្តថា នេះជាសំឡេងរបស់អ្នកណា មកអំពីទីណាហ្ន៎ ខ្លះក៏ពោលប្រាប់គ្នាថា លោកដ៏ចម្រើនគួរអស្ចារ្យណាស់ ពីកាលមុន ព្រះចន្ទពេញវង់រះត្រឹមតែមួយដួង តែថ្ងៃនេះ ដូចម្តេច ? ទើបរះឡើង ២ ដួង ក៏នោះជាព្រះចន្ទពេញវង់មួយគូ ដូចរាជហង្សមួយគូ ប្រដាប់ក្នុងផ្ទៃអាកាស ដូចគ្នានឹងកាលមុន ។ អ្នកដទៃក៏ពោលនឹងអ្នកនោះថា និយាយអ្វីសម្លាញ់ លោកធ្លាប់ឃើញព្រះចន្ទ ២ ដួង រះឡើងព្រមគ្នាពីកាលណា នោះជាវង់រស្មីព្រះអាទិត្យមិនមែនឬ ។ អ្នកដទៃញញឹម ហើយពោលនឹងអ្នកនោះថា លោកឯងឆ្កួតឬ ព្រះអាទិត្យលិចហើយមិនមែនឬ ព្រះអាទិត្យនោះនឹងរះឡើងតាមព្រះចន្ទពេញវង់នេះ ដូចម្តេច នោះជាវិមានរបស់អ្នកមានបុណ្យណាម្នាក់ ដែលរុងរោចន៍ដោយពន្លឺរតនៈ ពិតប្រាកដ ។ មនុស្ស

សម្បីទាំងអស់នោះ មិនជឿពាក្យគ្នា ក៏ពោលនឹងអ្នកពួកដទៃយ៉ាងនេះថា លោកដ៏ចម្រើន និយាយច្រើនអ្វីម្ល៉េះ នេះមិនមែនព្រះចន្ទពេញវង់ មិនមែនព្រះអាទិត្យ មិនមែនវិមានរបស់ទេវតា និងមិនមែនសិរីសម្បត្តិរបស់ពួកទេវតា តែជាចក្ករតន៍មួយ យ៉ាងពិតប្រាកដ ។ កាលជនទាំងនោះសន្ទនាគ្នាយ៉ាងនេះហើយ ចក្ករតន៍នោះ ក៏លះបង់ចេញនូវមណ្ឌលនៃព្រះចន្ទបែរត្រង់ឆ្ពោះរាជធានី ។

តពីនោះ ប្រសិនបើនិយាយថា ចក្ករតន៍នេះ កើតដល់អ្នកណាហ្ន៎ ក៏នឹងមានអ្នកនិយាយថា ចក្ករតន៍នោះ មិនកើតដល់អ្នកណាដទៃ តែកើតដល់ព្រះបាទមហាចក្រពត្តិ ដែលមានព្រះបារមីបរិបូររបស់ពួកយើង មិនមែនឬ ។ លំដាប់នោះ មហាជននោះ និងជនដទៃៗ ទាំងអស់ក៏ដាប់តាមចក្ករតន៍នោះឯង ។ ចក្ករតន៍សម្បីនោះ ដូចប្រាថ្នានឹងឲ្យដឹងដល់ការៈប្រព្រឹត្តទៅនៃខ្លួន ដើម្បីប្រយោជន៍ដល់ស្តេចចក្រពត្តិ វិលក្បែរៗ ព្រះនគរ កម្ពស់ប្រមាណកំពែងដល់ ៧ គ្រា ធ្វើប្រទក្សិណព្រះនគររបស់ស្តេចចក្រពត្តិហើយប្រតិស្ថានទៅត្រង់ទីសីហបញ្ជរផ្នែកទិសខាងជើង ខាងក្នុងរាជធានី ប្រាកដដូចឲ្យមហាជនសប្បាយដល់ការបូជា ដោយគ្រឿងក្រអូប និងផ្កាឈើជាដើមដូច្នោះ ។ ក៏កាលចក្ករតន៍នោះ តាំងនៅយ៉ាងនេះហើយ ក៏នឹងមាន

ព្រះរាជា ព្រះអង្គអ្នកប្រាថ្នានឹងទតព្រះនេត្រមើលចក្ករតន៍ ដែលមានពន្លឺធ្វើឲ្យខាងក្នុងប្រាសាទភ្លឺស្វាងស្វៃ ដោយពន្លឺរតនៈចំរុះពណ៌ ដែលផ្សាយចេញមកតាមចន្លោះបហោងផ្សេងៗ ។ សូម្បីប្រជាជន ដែលមកជាមួយព្រះរាជានោះ ក៏ប្រារព្ធដល់ពាក្យគួរស្រឡាញ់នៃចក្ករតន៍នោះ ទើបប្រកាសសេចក្តីនោះ ។

លំដាប់នោះ ព្រះរាជាទ្រង់មានព្រះសរីរៈផូរផង់ដោយព្រះបីតិ និងបាមោជ្ជៈជាកម្លាំង ទ្រង់លើកសមាធិ ស្តេចក្រោកឡើងចាកព្រះរាជាសនៈស្តេចទៅជិតសីហបញ្ជរ ទ្រង់ឃើញចក្ករតន៍នោះ ទ្រង់ព្រះតម្រិះថា ក៏ចក្ករតន៍នោះ យើងបានស្តាប់ហើយ ដូច្នេះជាដើម ។ ចក្ករតន៍នោះទាំងអស់ បានជាយ៉ាងនោះ ដល់ព្រះបាទមហាសុទស្សនចក្រពត្តិរាជ ។ ដោយហេតុនោះ លោកទើបពោលថា រញ្ញោ មហាសុទស្សនស្ស ។បេ។ អស្សំ នុខោ អហំ រាជា ចក្កវត្តិ ក្នុងបទនោះមានអត្ថថា **ព្រះរាជាព្រះអង្គនោះជាស្តេចចក្រពត្តិ** ។ សួរថា ជាស្តេចចក្រពត្តិ ដោយហេតុមានប្រមាណប៉ុនណា ។

ព្រះមានព្រះភាគ គ្រាចក្ករតន៍ស្ទុះឡើងទៅកាន់អាកាស សូម្បីត្រឹមតែមួយអង្គុលី ពីរអង្គុលី ទ្រង់សម្តែងកិច្ចនឹងគប្បីធ្វើ ដើម្បីញ៉ាំង

ចក្ររតន៍នោះឲ្យប្រព្រឹត្តទៅ ក្នុងកាលឥឡូវនេះ ទើបត្រាស់ថា អជទោ អានន្ទ ជាដើម ។

ក្នុងបទទាំងនោះ បទថា ឧដ្ឋាយាសនា សេចក្តីថា ស្តេចក្រោកចាកព្រះរាជាសនៈ ដែលប្រថាប់ហើយ ស្តេចមកជិតចក្ករតន៍ ។ បទថា សុវណ្ណ-ភិង្គារំ គហេត្វា សេចក្តីថា ទ្រង់លើកព្រះសុវណ្ណភិង្គារមានទម្ងន់ ដូចប្រមោយដំរី ។

បទថា អន្វទេវ រាជា មហាសុទស្សនោ សទ្ធិំ ចតុរង្គិនិយា សេ-នាយ សេចក្តីថា ក៏ព្រះបាទមហាសុទស្សនចក្រពត្តិរាជនោះ ទ្រង់ព្រះនាមថា ចក្រពត្តិមួយរំពេច ទន្ទឹមនឹងចក្ករតន៍ហោះឡើងកាន់វេហាស៍ ដូចនឹងស្តេចចក្រពត្តិទាំងឡាយ ទ្រង់ជ្រួចទឹកហើយត្រាស់ថា សូមចក្ករតន៍ ចូរអភិជិតចក្រភព ។ ក៏គ្រាចក្ករតន៍ប្រព្រឹត្តទៅហើយ ស្តេចចក្រពត្តិ ស្តេចជាប់តាមចក្ករតន៍នោះ ស្តេចទៅកាន់យានដ៏ប្រសើរ ហើយហោះឡើងកាន់វេហាស៍ ។ លំដាប់នោះ បរិជន និងអន្តោជនរបស់ព្រះរាជានោះ កាន់ឆត្រ និងផ្លិតជាដើម តពីនោះ ពួកឧបរាជ និងសេនាបតី ព្រមទាំងពលកម្លាំង ប្រដាប់ដោយអាវក្រោះជាដើម រុងរឿងដោយពន្លឺអាភរណៈផ្សេង ៗ តាក់តែងដោយទង់បដាដែលស្អាតល្អ ហោះឡើងកាន់វេហាស៍

ហែហមព្រះរាជា ។ ក៏បណ្ដាកេរីរាជយុទ្ធ ក៏ឲ្យវាយត្រាច់ទៅតាមថ្នល់ក្នុងព្រះនគរ ដើម្បីសង្គ្រោះជនថា ម្នាលអ្នកទាំងឡាយ ចក្ររតន៍បានកើតឡើងដល់ព្រះរាជារបស់ពួកយើងហើយ អ្នកទាំងឡាយចូរតុបតែង ប្រដាប់ខ្លួនតាមសមគួរដល់ទ្រព្យរៀង ៗ ខ្លួន ហើយមកប្រជុំ ។ និងសូម្បីមហាជនលះបង់កិច្ចទាំងពួងតាមប្រក្រតី ដោយសំឡេងចក្ររតន៍នោះឯង កាន់គ្រឿងក្រអូប និងផ្កាឈើជាដើម ប្រជុំគ្នាហើយ ។ មហាជនសូម្បីទាំងអស់នោះហោះឡើងកាន់វេហាស ហែហមព្រះរាជានោះឯង ។ ក៏មហាជនណាៗបំណងនឹងទៅជាមួយព្រះរាជា មហាជននោះៗ ក៏ទៅកាន់អាកាស ។ បរិស័ទមានទំហំប្រមាណ ១២ យោជន៍យ៉ាងនេះ ។ ក្នុងបរិស័ទនោះ សូម្បីតែម្នាក់ និងមានសរីរៈបែកបាក់ ឬសំពត់ប្រលាក់ មិនមាន ។ ពិតណាស់ស្ដេចចក្រពត្តិ ទ្រង់មានរាជបរិវារដ៏ស្អាត ។ ដែលឈ្មោះថា បរិស័ទរបស់ស្ដេចចក្រពត្តិហោះបានដូចវិទ្យាធរ ប្រៀបដូចជាកែវមណី ពាសពេញក្នុងផ្ទៃអាកាសពណ៌ខៀវ ។ បរិស័ទ សូម្បីរបស់ព្រះបាទមហាសុទស្សនចក្រពត្តិរាជ ក៏ដូច្នោះដែរ ។ ដោយហេតុនោះ ទើបលោកពោលថា អន្វេវ រាជា មហាសុទស្សនោ សទ្ធឹ ចតុរង្គិនិយា សេនាយ ។

ក៏ចក្ររតន៍នោះ រមែងហោះទៅលើក្នុងអាកាស លើចុងឈើ ដោយ

មិនខ្ពស់ពេក មិនទាបពេក ដូចអ្នកត្រូវការផ្លែផ្កា និងវល្លិនៃដើមឈើ ក៏អាចបេះផ្លែផ្កាទាំងនោះបានដោយងាយ និងដូចបុគ្គលឈរលើផែនដី ក៏អាចនឹងសង្កេតដឹងថា នោះព្រះរាជា នោះឧបរាជ នោះសេនាបតី ។ ក៏ក្នុងបណ្តាឥរិយាបថ មានឈរជាដើម អ្នកណាត្រូវការឥរិយាបថណា អ្នកនោះ ក៏ប្រព្រឹត្តទៅដោយឥរិយាបថនោះបាន ។ ក៏ក្នុងទីនេះអ្នកខ្វល់ខ្វាយក្នុងសិល្បៈ មានចិត្រកម្មជាដើម កាលធ្វើកិច្ចរៀងៗ ខ្លួនទៅ កិច្ចទាំងពួងរបស់ជនទាំងនោះ ក៏រមែងសម្រេចក្នុងអាកាសនោះ ដូចក្នុងផែនដី ។ ចក្ររតន៍នោះ នាំបរិស័ទស្តេចចក្រពត្តិទៅដោយអាការយ៉ាងនេះ និងលះភ្នំព្រះសុមេរុផ្លូវខាងឆ្វេង ទៅកាន់បុព្វវិទេហប្រទេស ប្រមាណ ៨ ពាន់យោជន៍ ក្នុងចំណែកខាងលើនៃមហាសមុទ្រ ។ ក្នុងទីនោះ ភូមិភាគណាផ្នែកទទឹងដោយជុំវិញបាន ១២ យោជន៍ គួរដល់ការនៅអាស្រ័យរបស់បរិស័ទ ១៦ យោជន៍ មានអាហារ គ្រឿងឧបករណ៍រកបានងាយ សម្បូរដោយម្លប់ និងទឹក មានភាគផែនដីស្មើស្អាត គួររីករាយ ចក្ករតន៍នោះតាំងនៅមិនញាប់ញ័រ ក្នុងចំណែកខាងលើនៃភូមិភាគនោះៗ លំដាប់នោះដោយសញ្ញាណនោះ មហាជននោះ ក៏ចុះធ្វើកិច្ចទាំងពួង មានការងូត និងបរិភោគជាដើម តាមសេចក្តីពេញចិត្ត សម្រេចការនៅ ។ ចក្ករតន៍ទាំង

ពួនរមែងមានសភាពយ៉ាងនោះ សូម្បីរបស់ព្រះបាទមហាសុទស្សនចក្រពត្តិក៏ដូច្នោះ ដោយហេតុនោះ លោកទើបពោលថា **ម្នាលអានន្ទ ចក្ករតន៍ប្រតិស្ឋាននៅក្នុងប្រទេសណា ព្រះបាទមហាសុទស្សនចក្រពត្តិ ក៏ស្ដេចចូលទៅប្រថាប់នៅក្នុងប្រទេសនោះ ព្រមទាំងចតុរង្គសេនា ។**

គ្រាស្ដេចចក្រពត្តិ ប្រថាប់នៅយ៉ាងនេះហើយ ព្រះរាជាទាំងឡាយក្នុងប្រទេសនោះ សូម្បីបានស្ដាប់ហើយថា ចក្រមកហើយ ក៏រមែងមិនប្រជុំកម្លាំងដើម្បីត្រៀមច្បាំង ។ ព្រោះក្នុងចន្លោះឧប្បត្តិឡើងនៃចក្ករតន៍ធម្មតាសត្វដែលនឹងព្យាយាមលើកអាវុធតតាំងចំពោះព្រះរាជានោះ ដោយសម្គាល់ថា ជាសត្រូវមិនមានឡើយ ។ នេះជាអានុភាពនៃចក្ករតន៍ ។ ក៏ពួកសត្រូវដ៏សេសរបស់ព្រះរាជានោះ រមែងចូលដល់ការទូន្មាន ដោយអានុភាពនៃចក្រ ។ ធម្មតាការទូន្មានសត្រូវ ជានាទីរបស់ព្រះរាជាអ្នកជាធំនៃមនុស្ស ដោយហេតុនោះ ទើបលោកពោលដល់ចក្ររបស់ព្រះរាជានោះ ។ ព្រោះដូច្នោះ ព្រះរាជាសូម្បីទាំងអស់នោះ ទ្រង់កាន់បណ្ណាការដ៏សមគួរដល់រាជសិរីសម្បត្តិរៀងៗ ខ្លួន ស្ដេចចូលគាល់ព្រះរាជានោះ ទ្រង់បន្អោនព្រះសិរសា ធ្វើការបូជាព្រះបាទនៃព្រះរាជានោះ ដោយអភិសេកនៃរស្មីកែវមណីព្រះមោលីរបស់ខ្លួន ដល់នូវការទទួលព្រះរាជានោះ ដោយ

ព្រះវចនៈថា បពិត្រព្រះមហារាជ សូមព្រះអង្គស្តេចមក ដូច្នេះជាដើម ។ ព្រះរាជាទាំងឡាយ ក៏បានធ្វើយ៉ាងនោះ ដល់ព្រះបាទមហាសុទស្សនចក្រពត្តិរាជ ដូចគ្នា ។ ដោយហេតុនោះ ទើបលោកពោលថា យេ ខោ បនានន្ទ បុរត្ថិមាយ ទិសាយ ។បេ។ អនុសាស មហារាជ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា ស្វាគតំ ប្រែថា ស្តេចមកល្អហើយ ។ លោកពោលថា ក៏គ្រាព្រះរាជាមួយអង្គស្តេចមក រាជសត្រូវក៏សោកសៅ គ្រាស្តេចទៅ ក៏ទ្រង់រីករាយ គ្រាព្រះរាជាអង្គខ្លះស្តេចមក រាជសត្រូវក៏ទ្រង់រីករាយ គ្រាស្តេចទៅ ក៏ទ្រង់សោកសៅ ព្រះអង្គក៏ជាដូច្នោះ ទ្រង់ស្តេចមកក៏រីករាយ ស្តេចទៅក៏សោកសៅ ព្រោះដូច្នោះ ការស្តេចមករបស់ព្រះអង្គ ទើបជាការដែលស្តេចមកដោយល្អ ។ ក៏គ្រាពោលយ៉ាងនេះហើយ ព្រះចៅចក្រពត្តិនឹងមិនត្រាស់ថា លោកទាំងឡាយ ចូរនាំពលីដ៏សមគួរ មានប្រមាណប៉ុណ្ណេះឲ្យដល់យើងខ្លះ នឹងមិនកាត់យកភោគៈរបស់ព្រះរាជាអង្គដទៃ ទ្រង់ព្រះរាជទានដល់ព្រះរាជាអង្គដទៃខ្លះ តែនឹងទ្រង់ផ្តើមពាក្យថា បាណោ ន ហន្តព្វោ ជាដើមឡើង ពោលដោយបញ្ញាដែលសមគួរដល់កាលដែលព្រះអង្គជាធម្មរាជា ទ្រង់សម្តែងព្រះធម៌ដោយព្រះវចនៈដែលជាទីស្រឡាញ់ ដែលទន់ភ្លន់ផ្អែមល្ហែម ដោយន័យជាអាទិ៍ថា ម្នាលអ្នក

ទាំងឡាយ លោកចូរមើល ដែលឈ្មោះថា ការសម្លាប់សត្វនោះ ដែលសេពហើយ ចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីនរក ទ្រង់ព្រះរាជទានព្រះឱវាទមានជាអាទិ៍ថា កុំគប្បីសម្លាប់សត្វ ដូច្នេះ ។ សូម្បីព្រះបាទមហាសុទស្សនចក្រពត្តិ ក៏ទ្រង់ធ្វើយ៉ាងនេះដូចគ្នា ។ ដោយហេតុនោះ ទើបលោកពោលថា ព្រះបាទមហាសុទស្សនចក្រពត្តិ ត្រាស់យ៉ាងនេះថា លោកមិនគប្បីសម្លាប់សត្វ ។ល។ និងលោកគប្បីបរិភោគតាមសមគួរ ។

សួរថា ក៏ព្រះរាជាសូម្បីទាំងអស់ ទ្រង់កាន់យកព្រះឱវាទនេះរបស់ព្រះរាជាឬទេ ។ ឆ្លើយថា ព្រះរាជាសូម្បីទាំងអស់ មិនទាន់កាន់យកព្រះឱវាទសូម្បីរបស់ព្រះពុទ្ធ នឹងកាន់យកព្រះឱវាទរបស់ព្រះរាជាបាន យ៉ាងណា ។ ព្រោះដូច្នោះ ព្រះរាជាពួកណា ទ្រង់ជាបណ្ឌិត ឆ្លាតឈ្លាស មានបញ្ញា ព្រះរាជាទាំងនោះ ក៏ទ្រង់កាន់យក ។ តែព្រះរាជាទាំងអស់ ទ្រង់តាមស្តេច ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ថា យេ ខោ បនានន្ទ ដូច្នេះជាដើម ។

លំដាប់នោះ ចក្ករតន៍នោះ លុះព្រះរាជាឲ្យព្រះឱវាទដល់អ្នកបុព្វ-វិទេហៈយ៉ាងនេះហើយ ក៏ស្ទុះឡើងទៅកាន់វេហាស៍ ព្រមទាំងកម្លាំងរបស់

ចក្រពត្តិ ដែលបានទទួលទានអាហារព្រឹកស្រេចហើយ ក៏យាងចូលកាន់សមុទ្រផ្នែកខាងបុរត្ថិមទិស កន្ទង់លោកដ៏ធំទូលាយ ដូចនាគរាជបានក្លិនពស់ហើយបើកពពារដូច្នោះ ហោះហើរលើទឹកមហាសមុទ្រប្រមាណមួយយោជន៍ តាំងនៅខាងក្នុងមហាសមុទ្រប្រៀបដូចជាកែវពិទូរ្យ ដូច្នោះ ។ និងក្នុងខណៈនោះ រតន៍ច្រើនប្រភេទរាយពាសពេញក្នុងផ្ទៃមហាសមុទ្រ ដូចប្រាថ្នានឹងឃើញបុណ្យសិរីរបស់ព្រះរាជាព្រះអង្គនោះ មកពីទីនោះៗ ពេញប្រទេសនោះៗ លំដាប់នោះបរិស័ទនៃព្រះរាជានោះ ឃើញផ្ទៃមហាសមុទ្រពោរពេញដោយរតន៍ច្រើនប្រភេទនោះ លំដាប់នោះ បរិស័ទនៃព្រះរាជានោះ ឃើញផ្ទៃមហាសមុទ្រពោរពេញដោយរតន៍ច្រើនប្រភេទនោះ ក៏កាន់យកដោយកម្សន្ដជាដើម តាមចិត្ត ។ ក៏កាលបរិស័ទបានកាន់យករតន៍តាមពេញចិត្ត ចក្ករតន៍នោះ ក៏ត្រឡប់ ។ ក៏កាលចក្ករតន៍នោះត្រឡប់ បរិស័ទមិនបានទៅ ព្រះរាជានៅក្នុងកណ្ដាលនៃចក្ករតន៍ ។ កង់ចក្ករតន៍ ក៏វិលជក់ដោយជុំវិញៗ ស្ទុះទៅញែកអាកាសនោះ ដូចប៉ះខ្ទប់ផ្ទៃទឹកសមុទ្រ និងដូចគ្រប់សង្កត់ដោយចក្ករតន៍សិរី ចូលទៅមួយជួរនិរន្តរ ។ ស្ដេចចក្រពត្តិទ្រង់ឈ្នះបុព្វវិទេហប្រទេស ដែលមានមហាសមុទ្រផ្នែកទិសខាងកើតជាព្រំដែនយ៉ាងនេះហើយ ទ្រង់ប្រាថ្នានឹងឈ្នះជម្ពូទ្វីប ដែលមានសមុទ្រផ្នែកទិស

ត្បូងជាព្រំដែន ស្ដេចទ្រង់បែរចំពោះសមុទ្រផ្នែកទិសខាងត្បូង តាមផ្លូវដែលចក្ករតន៍នាំទៅ ។ សូម្បីព្រះបាទមហាសុទស្សនចក្រពត្តិ ក៏ស្ដេចទៅដូច្នោះដែរ ។ ដោយហេតុនោះ ទើបលោកពោលថា **ម្នាលអានន្ទ លំដាប់នោះឯង ចក្ករតន៍នោះ ចូលទៅកាន់សមុទ្រទិសខាងកើត ត្រឡប់ទៅទិសខាងត្បូង** ដូច្នេះ ។

ក៏កាលចក្ករតន៍នោះ ប្រព្រឹត្តទៅយ៉ាងនេះ ពាក្យថា វិធីត្រឡប់ ការស្នាក់នៅនៃសេនា ការយាងមកនៃព្រះអរិរាជ ការព្រះរាជទានអនុ-សាសនីដល់ពួកព្រះអរិរាជនោះៗ ការចូលទៅកាន់សមុទ្រផ្នែកទិសខាងត្បូង ការឡើងទៅលើសមុទ្រ ការកាន់យករតនច្រើនប្រភេទទាំងអស់ គប្បីជ្រាបដោយន័យមុននោះឯង ។ ក៏ទ្រង់ឈ្នះជម្ពូទ្វីប ប្រមាណមួយម៉ឺនយោជន៍នោះហើយ ត្រឡប់អំពីសមុទ្រទិសខាងត្បូង ស្ដេចទៅដោយន័យពោលហើយក្នុងបទមុន ដើម្បីឈ្នះអមរគោយាន មាន ៧ ពាន់យោជន៍ ជាប្រមាណ ទ្រង់ឈ្នះអមរគោយាននោះ ដែលមានសមុទ្រជាព្រំដែនយ៉ាងនោះ ស្ដេចចូលទៅអំពីសមុទ្រទិសខាងលិច ស្ដេចទៅយ៉ាងនោះ ដើម្បីឈ្នះឧត្តរកុរុ ដែលមាន ៨ ពាន់យោជន៍ ជាប្រមាណ ទ្រង់ឈ្នះឧត្តរកុរុនោះ ដែលមានសមុទ្រជាព្រំដែនដូចគ្នា ហើយស្ដេចត្រឡប់អំពីសមុទ្រទិសខាងជើង ។

ព្រះចៅចក្រពត្តិ ទ្រង់សម្រេចភាពជាអ្នកធំក្រៃលែងនៃប្រថពី ដែលមានមហាសមុទ្រទាំងបួនជាព្រំដែន ដោយប្រការដូច្នេះ ។

ព្រះរាជាព្រះអង្គនោះ ទ្រង់ឈ្នះដ៏វិសេស ដោយការឈ្នះហើយយ៉ាងនេះ មានបរិស័ទដើម្បីសម្ដែងដល់សិរីរាជសម្បត្តិរបស់ព្រះអង្គ ទ្រង់ងើយមើលផ្ទៃអាកាសខាងលើ ទ្រង់ក្រឡេកមើលមហាទ្វីបបួន ដែលមានកោះតូចៗ ប្រមាណ ៥០០ ជាបរិវារ ដូចស្រះកើតឡើងឯងទាំងបួន ដែលវិចិត្រដោយព្រៃបទុម ឧប្បល កុមុទ និងបុណ្ឌរិក ដែលរីកខ្វាយល្អហើយ ដូច្នោះស្ដេចត្រឡប់ទៅកាន់រាជធានី របស់ព្រះអង្គតាមលំដាប់ តាមផ្លូវដែលចក្ករតន៍សម្ដែងហើយនោះឯង ។ លំដាប់នោះ ចក្ករតន៍នោះ ក៏តាំងនៅដូចនៅខាងក្នុងទ្វារនៃបុរី ដ៏ស្រស់ល្អដូច្នោះ ។ ក៏កាលចក្ករតន៍នោះប្រតិ-ស្ឋានយ៉ាងនេះហើយ កិច្ចដែលនឹងគប្បីធ្វើខ្លះ ដោយគប់ភ្លើង ឬដោយប្រទីបខាងក្នុងរាជបុរី ក៏មិនមាន ។ ពន្លឺនៃចក្ករតន៍នោះ រមែងកម្ចាត់ភាពងងឹតនៃរាត្រី ។ តែបុគ្គលពួកណា ត្រូវការភាពងងឹត ភាពងងឹតនោះ ក៏រមែងមានដល់បុគ្គលទាំងនោះ ។ ចក្ករតន៍នោះ ទាំងអស់មានហើយយ៉ាងនេះដល់ព្រះបាទមហាសុទស្សនចក្រពត្តិ ។ ដោយហេតុនោះ ទើបលោកពោលថា ឧក្កិណាសមុទ្ទំ អជ្ឈោគាហេត្វា ។បេ។ ឯវរូបំ ចក្ករតនំ

ចាតុរហោសិ ។

## ពោលអំពីដំរីរតន៍

[៣] អាមាត្រទាំងឡាយ របស់ស្តេចចក្រពត្តិអ្នកមានចក្ករតន៍ប្រាកដយ៉ាងនេះ ក៏ឲ្យធ្វើទីនៅរបស់ដំរីមង្គល ប្រក្រតីឲ្យជាភូមិភាគស្មើ បរិសុទ្ធិស្អាត ព្រោះព្រំដោយក្លិនសុរភី មានចន្ទន៍ក្រហមជាដើម តាក់តែងឲ្យស្អាតល្អ ដូចវិមានទេព ខាងក្រោមពាសពេញដោយផ្កាសុរភី ផ្កាកុសុមដែលមានពណ៌វិចិត្រ ខាងលើ មានពិតានប្រដាប់ដោយក្បាច់ផ្កា ដែលគួរពេញចិត្ត រួមខាងក្នុងដួងផ្កាយមាស ហើយទូលថា បពិត្រសម្មតិទេព សូមព្រះអង្គចូរព្រះតម្រិះ ការមកនៃហត្ថីរតន៍ មានសភាពបែបនេះ ។ ព្រះរាជានោះ ក៏ទ្រង់ថ្វាយមហាទាន ដោយន័យដែលពោលហើយ ក្នុងកាលមុន និងទ្រង់សមាទានសីល ហើយប្រថាប់អង្គុយរឭកដល់បុញ្ញសម្បត្តិនោះ ។ លំដាប់នោះ ដំរីប្រសើរដែលអានុភាពនៃបុណ្យរបស់ព្រះរាជានោះដាស់តឿនហើយ ដូចនឹងគ្របសង្កត់សក្ការៈពិសេសនោះ មកអំពីត្រកូលឆទ្ទន្ត ឬអំពីត្រកូលឧបោសថ មានសរីរៈពណ៌ស ផុតពីតាក់តែងការដេរក និងមាត់ មានពណ៌ក្រហមដូចមណ្ឌលនៃព្រះអាទិត្យស្រទន់ៗ មានការប្រតិស្ឋាន ៧ ប្រការ មានរូបរាងអវយវៈតូចធំតាំងទុកយ៉ាងល្អ មានដោះ

ក្រចក និងចុងប្រមោយក្រហម អាចហោះបាន ដូចយោគីអ្នកមានឫទ្ធិ រូបរាងធំស ដូចបរិវេណដែលជ្រលក់ដោយលំអិតនៃមនោសិលា មកឈរ ក្នុងប្រទេសនោះ ។ ដំរីនោះ មកពីត្រកូលដំរីឆទ្ទន្ត រមែងតូចជាងដំរីទាំង អស់ ។ ដំរីដែលមកអំពីត្រកូលដំរីឧបោសថ រមែងធំជាងដំរីទាំងពួង ។ តែក្នុងបាលី មានមកថា នាគរាជឈ្មោះ **ឧបោសថ** ដូច្នេះ ។ លោកពោល ទុកក្នុងអដ្ឋកថាទាំងឡាយថា ដែលឈ្មោះថា **ដំរីនាគរាជ** មិនសមគួរដល់ នរណាៗ ជាដំរីតូចជាងដំរីទាំងអស់ រមែងមកដូច្នេះ ។ ដំរីនេះ រមែងមក ដល់ស្តេចចក្រពត្តិ ដែលមានវត្តនៃចក្រពត្តិ ទ្រង់ត្រិះរិះដោយន័យពោល ហើយនោះឯង ។ ក៏ដំរីនាគរាជ មកកាន់រោងដំរីមង្គលជាប្រក្រតីខ្លួនឯង មិនកម្ចាត់ដំរីមង្គល ឈរនៅក្នុងទីនោះ ។ ដោយហេតុនោះ ទើបលោក ពោលថា ឫុន ចបរំ អានន្ទ ។បេ។ នាគរាជ ដូច្នេះ ។

ក៏បុគ្គលទាំងឡាយមានអ្នកចិញ្ចឹមដំរីជាដើម ឃើញហត្ថីរតនៈដែល ប្រាកដយ៉ាងនោះហើយ រីករាយសប្បាយចិត្តប្រញាប់ទៅទូលដល់ព្រះរាជា ។ ព្រះរាជាប្រញាប់ស្តេចមកមើល ហត្ថីរតន៍នោះ ទ្រង់មានព្រះរាជហឫទ័យ ថ្លាថ្លៃផង់ ទ្រង់គិតថា ហត្ថីយានប្រសើរហ្ន៎ សមគួរនាំចូលហ្វឹកហាត់ ដូច្នេះ ។ ទ្រង់លាព្រះហស្ត លំដាប់នោះ ដំរីនោះ ដូចដំរីមេដោះ រំសាយត្រចៀក

សម្តេងសំឡេងស្រែក ចូលទៅគាល់ព្រះរាជា ។ ព្រះរាជាទ្រង់ប្រាថ្នានឹងស្តេចឡើងប្រថាប់ដំរីនោះ ។ លំដាប់នោះ បរិជនរបស់ព្រះរាជានោះដឹងព្រះរាជបំណង ធ្វើទង់មាស គ្រឿងប្រដាប់មាស គ្របដោយសំណាញ់មាស នាំចូលទៅរកហត្ថីរតនៈនោះ ។ ព្រះរាជាមិនឲ្យដំរីនោះអង្គុយស្តេចឡើងជណ្តើរដែលធ្វើដោយរតនៈ ៧ ប្រការ មានព្រះរាជហឫទ័យបង្អោនទៅក្នុងអាកាស ។ ព្រមដោយចិត្តុប្បាទរបស់ព្រះរាជានោះ ហត្ថិ-នាគរាជនោះ ក៏អណ្តែតឡើងកាន់ផ្ទៃអាកាស ដ៏រុងរឿងដោយពន្លឺកែវឥន្ទនិលនិងកែវមណី ដូចរាជហង្សដូច្នោះ ។ តពីនោះ បរិស័ទរបស់ព្រះរាជាទាំងអស់ ក៏ហោះឡើង ដោយន័យដែលពោលហើយក្នុងចក្កចារិកានោះឯង ។ ព្រះរាជាព្រមជាមួយបរិស័ទ ឡើងមើលប្រថពីទាំងអស់ ក៏ត្រឡប់រាជធានីខាងក្នុងអាហារព្រឹក ដោយប្រការដូច្នេះ ។ ហត្ថីរតនៈរបស់ព្រះបាទមហាសុទស្សនចក្រពត្តិរាជ ក៏ជាយ៉ាងនោះ ។ ដោយហេតុនោះ ទើបលោកពោលថា ឥស្សា រញ្ញោ ។បេ។ ធាតុរហោសិ ដូច្នេះ ។

## ពោលអំពី អស្សរតនៈ

[៤] ក៏អាមាត្រទាំងឡាយ របស់ស្តេចចក្រពត្តិ ដែលមានហត្ថីរតនៈ

ប្រាកដយ៉ាងនេះហើយ ឲ្យធ្វើ និងប្រដាប់រោងសេះមង្គលតាមប្រក្រតី ឲ្យមានផ្ទៃដីស្អាត រាបស្មើ ញ៉ាំងព្រះឧស្សាហ៍ឲ្យកើតឡើងដល់ព្រះរាជា ដើម្បីទ្រង់គិតការមកនៃសេះនោះ ដោយន័យមុននោះឯង ។ ព្រះរាជានោះ ទ្រង់មានសក្ការៈបង្អោនក្នុងទាន ដែលទ្រង់ធ្វើហើយដោយន័យមុននោះឯង ទ្រង់សមាទានសីល និងវត្ត ប្រថាប់អង្គុយសប្បាយលើផ្ទៃប្រាសាទ ទ្រង់រឭកដល់បុញ្ញសម្បត្តិ ។ លំដាប់នោះ អស្សរាជ ឈ្មោះថា **វលាហក** មកពីត្រកូលសេះសិន្ធព ដែលអានុភាពនៃបុណ្យរបស់ព្រះរាជានោះ ដាស់តឿនហើយ មានសិរីនៃដុំពពកសក្នុងសរទកាលដែលត្រូវផ្ទេកបន្ទោរ មានជើងក្រហម មានក្រចកជើងក្រហម មានរូបរាងរឹងមាំបរិសុទ្ធិស្និទ្ធ ដូចជាដុំរស្មីនៃព្រះចន្ទ មានសីសៈខ្មៅ ព្រោះដល់ព្រមដោយសក់ត្រង់មូលល្អិត ពណ៌ស ដូចស្មៅយាប្លង ដែលសម្រេចដោយល្អតាំងទុកហើយ អាចហោះបានមកនៅក្នុងរោងនោះ ។ ក៏អស្សរាជនោះ មកហើយដល់ព្រះបាទមហាសុទស្សនចក្រពត្តិ ដូចហត្ថីរតន៍ដូច្នោះ ។ បទទាំងពួងដ៏សេស គប្បីជ្រាបដោយន័យពោលហើយ ក្នុងហត្ថីរតន៍នុ៎ះឯង ។ ព្រះមានព្រះភាគ ទ្រង់សំដៅដល់ អស្សរតនៈនោះ ទើបត្រាស់ថា បុន ចបរំ ដូច្នេះជាដើម ។

## ពោលអំពី មណីរតន៍

[៩] ក៏មណីរតនៈមកពីវេបុលបព៌ត ប្រវែងបួនហត្ថ មានទ្រង់ទ្រាយស្រស់ល្អ ប្រដាប់ដោយមាស និងបទុមទាំងពីរ មានត្រួបកជាមុក្តា ដ៏បរិសុទ្ធិ ដុះចេញចេញចាកជុំទាំងពីរ ក្នុងទីបំផុតទាំងពីរខាង មានមណី ៨៤.០០០ ជាបរិវារ ហាក់ដូចជាផ្សាយទៅខ្ទប់នឹងសិរីនៃព្រះចន្ទពេញវង់ ដែលពួកផ្កាយហែហមជុំវិញ មកដល់ស្តេចចក្រពត្តិ អ្នកមានអស្សរតន៍ប្រាកដហើយយ៉ាងនេះ ។ កាលមណីរតនៈនោះ មកហើយយ៉ាងនេះ ដែលបុគ្គលទុកដាក់ក្នុងសំណាញ់មុក្តា លើកឡើងកាន់អាកាសប្រមាណ ៦០ ហត្ថ ត្រឹមចុងឫស្សី ពន្លឺនឹងផ្សាយទៅកាន់ឱកាស ប្រមាណមួយយោជន៍ដោយជុំវិញ ដែលជាហេតុឲ្យឱកាសនោះទាំងអស់ កើតពន្លឺដូចក្នុងវេលាអរុណរះដូច្នោះ ។ តពីនោះ អ្នកស្រែក៏ប្រកបកសិកម្ម ឈ្មួញក៏ប្រកបការជួញដូរ អ្នកសិល្បៈនោះៗ ក៏ប្រកបការងារនោះៗ សម្គាល់ថា ជាពេលថ្ងៃ ។ មណីរតនៈនោះ បានមានហើយយ៉ាងនោះ សូម្បីដល់ព្រះបាទមហាសុទ-ស្សនចក្រពត្តិនោះឯង ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា បុន ចបរំ អានន្ទ ។បេ។ មណិរតនំ បាតុរហោសិ ដូច្នេះ ។

## ពោលអំពី ស្រ្តីរតន៍

[៦] *ឥត្ថីរតនៈ មានការណ៍ពិសេស ប្រាកដដល់ស្តេចចក្រពត្តិ ទ្រង់មានសុខវិស័យពិសេស មានមណីរតន៍ប្រាកដហើយយ៉ាងនេះ ។ ក៏ព្រះញាតិទាំងឡាយ រមែងនាំឥត្ថីរតន៍នោះ មកអំពីមទ្ទរាជត្រកូល មកជាអគ្គមហេសីរបស់ស្តេចចក្រពត្តិនោះ ។ ឬមកពីឧត្តរកុរុប្រទេស ដោយបុញ្ញានុភាព ។ ក៏សម្បត្តិនៃឥត្ថីរតន៍នោះ ដ៏សេសមកហើយក្នុងបាលីនោះឯង ដោយន័យមានជាអាទិ៍ថា ម្នាលអានន្ទ ប្រការមួយទៀត ឥត្ថីរតន៍ដែលមានរូបស្អាតបំផុត គួរមើល ប្រាកដហើយដល់ព្រះបាទមហាសុទ-ស្សនចក្រពត្តិរាជ ។ ក្នុងបណ្តាសម្បត្តិនោះ ឈ្មោះថា អភិរូបា ព្រោះឥត្ថីរតន៍នោះ មានរូបស្អាតល្អ បរិបូរណ៌ដោយទ្រង់ទ្រាយ ។ និងឈ្មោះថា ទស្សនីយា ព្រោះកាលមើលក៏ត្រូវភ្នែក សូម្បីត្រូវលើកធុរកិច្ចយ៉ាងដទៃ សម្លឹងមើល ។ ឈ្មោះថា បាសាទិកា ព្រោះកាលមើល ក៏ញ៉ាំងចិត្តឲ្យជ្រះថ្លា ដោយអំណាចសោមនស្ស ។ បទថា បរមាយ សេចក្តីថា ឧត្តម ព្រោះនាំមកនូវសេចក្តីជ្រះថ្លាយ៉ាងនេះ ។ បទថា វណ្ណបោក្ខរតាយ សេចក្តីថា ព្រោះវណ្ណៈល្អ ។ បទថា សមន្នាគតា សេចក្តីថា ចូលដល់ហើយ ។ ប្រការមួយទៀត ឈ្មោះថា អភិរូបា ព្រោះមិនខ្ពស់ពេក មិន*

ទាបពេក ។ ឈ្មោះថា ឧស្សន្និយា ព្រោះមិនស្គមពេក មិនធាត់ពេក ។ ឈ្មោះថា ចាសាធិកា ព្រោះមិនខ្មៅពេក មិនសពេក ។ ឈ្មោះថា បរ-មាយ វណ្ណបោក្ខរតាយ សមន្នាគតា ព្រោះឈានកន្លងវណ្ណៈមនុស្ស តែមិនដល់វណ្ណៈទិព្វ ។ ពិតណាស់ ពន្លឺវណ្ណៈរបស់ពួកមនុស្ស រមែងមិនភ្លឺចេញមកខាងក្រៅ ។ តែរបស់ទេពទាំងឡាយ រមែងភ្លឺចេញទៅសូម្បីឆ្ងាយ ។ ចំណែកពន្លឺសរីរៈនៃឥត្ថីរតន៍នោះ រមែងញ៉ាំងប្រទេសប្រមាណ ១២ ហត្ថ ឲ្យភ្លឺបាន ។ ក៏ក្នុងបណ្តាសម្បត្តិមានមិនខ្ពស់ពេកជាដើម របស់ឥត្ថីរតន៍នោះ លោកពោលអារោហសម្បត្តិ ដោយគូទីមួយ ពោលបរិ-ណាសម្បត្តិ ដោយគូទីពីរ ពោលវណ្ណសម្បត្តិ ដោយគូទីបី ពោលនូវកាយវិបត្តិ ដោយអាការវិបត្តិ ៦ ប្រការនោះ ។ ពោលកាយសម្បត្តិ ដោយបទនេះថា អតិក្កន្តា មានុសវណ្ណំ ។ បទថា តូលបិចុនោ វា កប្បាសបិចុនោ វា សេចក្តីថា ដូចសំឡីគ ឬសំឡីកប្បាស នៃកាយសម្ផស្ស ដែលយកទៅដាក់លើដុំទឹកដោះថ្លា និងបែកចេញជា ៧ ចំណែក ។ បទថា សីតេ សេចក្តីថា អប់កំដៅ ក្នុងកាលព្រះរាជាត្រជាក់ ។ បទថា ឧណ្ហេ សេចក្តីថា ត្រជាក់ ក្នុងវេលាដែលព្រះរាជាក្តៅ ។ បទថា ចន្ទនគន្ធោ សេចក្តីថា ក្លិនច័ន្ទក្រហមដែលប្រកបដោយជាតិបួនប្រភេទ នៅថ្មីកិនល្អិត

ល្អអស់កាលនិច្ច រមែងស្ងួតអស់អំពីកាយ ។ បទថា ឧប្បលគន្ធោ សេចក្តីថា ក្លិនក្រអូបយ៉ាងក្រៃលែងនៃនីលុប្បលរីក ខណៈនោះរមែងផ្សាយចេញពីមាត់ វេលាក្អក ឬនិយាយ ។ ក៏ទ្រង់សម្តែងអាចារៈដែលសមគួរនៃសរីរសម្បត្តិ ប្រកបដោយសម្ផស្សសម្បត្តិ និងគន្ធសម្បត្តិយ៉ាងនេះ ទើបត្រាស់ថា តំ ខោ បន ជាដើម ។ ក្នុងអាចារៈនោះ ឥត្ថីរតន៍ឃើញព្រះរាជាហើយ ក្រោកឡើងចាកអាសនៈទីអង្គុយមុន ដូចអ្នកត្រូវភ្លើងឆេះ ព្រោះដូច្នោះ ទើបឈ្មោះថា បុព្វុដ្ឋាយិនី លុះព្រះរាជានោះប្រថាប់អង្គុយហើយ ឥត្ថីរតន៍ធ្វើកិច្ច មានបក់ដោយផ្លិតស្លឹកត្នោតជាដើម ដល់ព្រះរាជានោះ ហើយទើបសម្រាក គឺ អង្គុយក្រោយ ព្រោះដូច្នោះ ទើបឈ្មោះថា បច្ឆានិបាតិនិ ។ ឥត្ថីរតន៍ រមែងទូលខ្វាយក្នុងកិច្ចដែលគប្បីធ្វើ ដោយវាចាថា បពិត្រទេវៈ ខ្ញុំម្ចាស់នឹងធ្វើអ្វីដល់ព្រះអង្គ ព្រោះដូច្នោះ ទើបឈ្មោះថា កឹការប្បដិស្សាវិនី ។ ឥត្ថីរតន៍ រមែងប្រព្រឹត្ត រមែងធ្វើវត្តដែលពេញព្រះរាជហឫទ័យរបស់ព្រះរាជាប៉ុណ្ណោះ ព្រោះដូច្នោះ ទើបឈ្មោះថា មនាបចារិនី ។ ឥត្ថីរតន៍ រមែងពោលពាក្យដែលគួរស្រឡាញ់ ដល់ព្រះរាជាប៉ុណ្ណោះ ព្រោះដូច្នោះ ទើបឈ្មោះថា បិយវាទិនី ។ ឥឡូវនេះ ព្រះមានព្រះភាគ ទើបត្រាស់ថា តំ ខោ បន ជាដើម ដើម្បីទ្រង់សម្តែងថា

អាចារៈរបស់ឥត្ថីរតន៍នេះ បរិសុទ្ធិតែម្យ៉ាង ដោយមិនមានសាថេយ្យៈឡើយ ។ បណ្ដាបទទាំងនោះ បទថា នោ អតិចារី សេចក្ដីថា មិនប្រព្រឹត្តកន្លង ។ លោកពោលថា ឥត្ថីរតន៍ មិនប្រាថ្នាបុរសដទៃ សូម្បីដោយចិត្តក្រៅអំពីព្រះរាជា ។ ក្នុងបទនោះ អាចារៈទាំងឡាយណា របស់ឥត្ថីរតន៍នោះ លោកពោលថា អភិរូបា ជាដើម ក្នុងខាងដើម និងពោលថា បុព្វុដ្ឋាយិនិ ក្នុងទីបំផុត អាចារៈទាំងនោះ ជាគុណដោយប្រក្រតីយ៉ាងនេះឯង ។ ក៏សម្បត្តិជាដើមថា អតិក្កន្តា មានុសវណ្ណំ គប្បីជ្រាបថា កើតឡើងហើយ ដោយអានុភាពកម្មចាស់ តាំងពីចក្ករតន៍ប្រាកដឡើង ព្រោះអាស្រ័យបុណ្យរបស់ស្ដេចចក្រពត្តិ ។ ឬសម្បត្តិថា អភិរូបតា ជាដើម កើតបរិបូរណ៍ដោយអាការទាំងពួង តាំងពីចក្ករតន៍ប្រាកដហើយ ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា ឯវរូបំ ឥត្ថីរតនំ បាតុរហោសិ ដូច្នេះ ។

## ពោលអំពី គហបតិរតន៍

[៧] ក៏គហបតីរតន៍ ដើម្បីឲ្យកិច្ចទាំងឡាយ ដែលគប្បីធ្វើដោយទ្រព្យ ប្រព្រឹត្តទៅដោយសប្បាយ រមែងប្រាកដដល់ស្ដេចចក្រពត្តិ អ្នក

មានឥត្ថីរតន៍ ប្រាកដហើយយ៉ាងនេះ ។ គហបតីនោះ ដោយប្រក្រតីមានភោគៈច្រើន កើតក្នុងត្រកូលមានភោគៈច្រើន ចម្រើនដោយគំនរទ្រព្យរបស់ព្រះរាជា ជាសេដ្ឋីគហបតី ។ ក៏ទិព្វចក្ខុដែលជាហេតុឃើញរណ្តៅទ្រព្យខាងក្នុងមួយយោជន៍ សូម្បីខាងក្នុងប្រថពី ដែលកើតពីផលកម្ម សង្គ្រោះដោយអនុភាពចក្ករតន៍ រមែងប្រាកដដល់គហបតីរតន៍នោះ គហបតីរតន៍នោះ ឃើញសម្បត្តិនោះហើយ សប្បាយចិត្ត ទៅបវារណាព្រះរាជាដោយទ្រព្យ ទទួលធ្វើកិច្ចទាំងឡាយ ដែលនឹងគប្បីធ្វើដោយទ្រព្យទាំងអស់ឲ្យសម្រេច ។ គហបតីរតន៍ សូម្បីរបស់ព្រះបាទមហាសុទស្សនចក្រពត្តិ ក៏ញុំាងកិច្ចដែលគប្បីធ្វើដោយទ្រព្យ ឲ្យសម្រេចយ៉ាងនោះ ដូចគ្នា ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា បុន ចបរំ អានន្ទ ។បេ។ ឯវរូបំ គហបតិរតនំ ចាតុរហោសិ ដូច្នេះ ។

## ពោលអំពី បរិនាយករតន៍

[៨] ក៏បរិនាយករតន៍ ដែលអាចចាត់ចែងសព្វកិច្ច រមែងប្រាកដដល់ស្តេចចក្រពត្តិ ដែលមានគហបតីរតន៍ ប្រាកដហើយយ៉ាងនេះ ។ បរិនាយករតន៍នោះ ជាព្រះរាជឱរសអង្គធំរបស់ព្រះរាជនោះឯង ។ ដោយ

ប្រក្រតី បរិនាយករតន៍នោះ ជាបណ្ឌិត ឈ្លាសវៃ មានបញ្ញាអាស្រ័យបុញ្ញានុភាពរបស់ព្រះរាជា រមែងចូលដល់ញាណ ដឹងចិត្តបុគ្គលដទៃដោយអានុភាពនៃកម្មរបស់ខ្លួន ដែលជាហេតុឲ្យដឹងវារៈចិត្តនៃបរិស័ទ ប្រមាណ ១២ យោជន៍ អាចកំណត់ដឹងហិតៈប្រយោជន៍ និងអហិតៈប្រយោជន៍ ដល់ព្រះរាជាបាន ។ បរិនាយករតន៍សូម្បីនោះ ឃើញអានុភាពរបស់ខ្លួននោះ សប្បាយចិត្ត បវារណាព្រះរាជាដោយការបរិហារកិច្ចទាំងអស់ ។ បរិនាយករតន៍ បវារណាសូម្បីព្រះបាទមហាសុទស្សនចក្រពត្តិយ៉ាងនោះ ដូចគ្នា ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា បុន ចបរំ អានន្ទ ។បេ។ បរិណាយករតនំ បាតុរហោសិ ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា ថបេតព្វំ ថបេតុំ សេចក្តីថា ដើម្បីតាំងនៅក្នុងឋានន្តរៈនោះៗ ។

## ពោលអំពី ឫទ្ធិ ៤ យ៉ាង

[៩-១០-១១-១២] បទថា សមវេបាកិនិយា សេចក្តីថា ដែលកើតពីផលកម្មដែលស្មើ ។ បទថា គហណិយា សេចក្តីថា ដោយតេជោធាតុដែលកើតពីកម្ម ។ ក្នុងបទនេះ អាហារ ត្រឹមតែថា សោយហើយរបស់ព្រះបាទមហាសុទស្សនចក្រពត្តិ រមែងរលួយ ឬរមែងតាំងនៅយ៉ាងនោះ

ដូចកត្តដែលសោយ ដល់ព្រមដោយតេជោធាតុ ដែលកើតពីវិបាកដ៏ស្មើ ស្មើទាំងពីរនោះ ។ ក៏សេចក្តីពេញព្រះរាជហឫទ័យក្នុងព្រះក្រយាហារ ក្នុងកាលនៃកត្ត រមែងកើតឡើងដល់ព្រះបាទមហាសុទស្សនចក្រពត្តិណា ព្រះបាទមហាសុទស្សនចក្រពត្តិរាជនេះ ទ្រង់ដល់ព្រមដោយតេជោធាតុដែលកើតពីវិបាកដ៏ស្មើ ដូច្នេះ ។

## ពោលអំពី ធម្មប្រាសាទនិងបោក្ខរណី

[១៣] បទថា មាបេសិ ខោ សេចក្តីថា ទ្រង់ឲ្យវាយស្គរប្រកាសក្នុងព្រះនគរ ទ្រង់ឲ្យពពួកជនធ្វើការកសាង ។ ក៏ស្រះបោក្ខរណី ៨៤,០០០ កន្លែង ក៏ផុសឡើងព្រមនឹងការកើតឡើងនៃព្រះរាជតម្រិះ របស់ព្រះរាជា ។ បទថា មាបេសិ ខោ នោះ ព្រះមានព្រះភាគ ត្រាស់សំដៅដល់ស្រះបោក្ខរណីទាំងនោះ ។ បទថា ទ្វីហិ វេទិកាហិ សេចក្តីថា ហោមព័ទ្ធដោយជុំឥដ្ឋមួយ ក្នុងទីបំផុតនៃឥដ្ឋទាំងឡាយ ហោមព័ទ្ធដោយជុំឥដ្ឋមួយ ក្នុងទីបំផុតនៃការកំណត់បរិវេណ ។

បទថា ឯវរូបំ អហោសិ សេចក្តីថា បានមានហើយព្រោះអ្វី ។

បានឮថា ក្នុងថ្ងៃមួយ មហាបុរសសម្ដឹងមើលមហាជនទៅងូត និង

ផឹក គិតថា ជនទាំងនេះរមែងទៅដោយភេទមនុស្សឆ្កួត បើគប្បីមានផ្កាឈើប្រដាប់ក្នុងស្រះនោះ ដល់ជនទាំងនោះ ក៏នឹងជាការល្អ លំដាប់នោះ ព្រះបាទមហាសុទស្សនចក្រពត្តិនោះ បានមានព្រះរាជតម្រិះ ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា សព្វោតុកំ សេចក្តីថា ព្រះបាទមហាសុទស្សនចក្រពត្តិទ្រង់ត្រិះរិះថា ធម្មតាផ្កាឈើ រមែងរីកក្នុងរដូវតែមួយប៉ុណ្ណោះ ក៏យើងនឹងធ្វើឲ្យផ្កាឈើនឹងរីកក្នុងគ្រប់រដូវ ។ បទថា រោបាបេសិ សេចក្តីថា ទ្រង់ឲ្យនាំពូជឧបុលប្រភេទនានាជាដើម អំពីទីនោះៗ ទ្រង់ឲ្យដាំ ។ ផ្កាឈើទាំងអស់ ក៏សម្រេចព្រមជាមួយការកើតឡើងនៃព្រះរាជតម្រិះរបស់ព្រះបាទមហាសុទស្សនចក្រពត្តិនោះ ។ មនុស្សលោកយល់ថា ផ្កាឈើនោះ ព្រះរាជាទ្រង់ឲ្យដាំ ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា រោបាបេសិ ដូច្នេះ ។ តាំងពីនោះមក មហាជនបានប្រដាប់ផ្កាឈើដែលកើតអំពីទឹក និងកើតអំពីលើគោកនានប្បការ ដូចលេងនក្ខត្តឫក្ស ដូច្នោះ ។

លំដាប់នោះ ព្រះរាជា ទ្រង់មានព្រះរាជបំណងនឹងធ្វើជនឲ្យដល់ព្រមដោយសេចក្តីសុខក្រៃលែងជាងនោះ ទើបទ្រង់គិតចាត់រកសេចក្តីសុខដល់ជន ដោយបទថា យន្នហាំ ឥមាសំ ចោក្ខរណីនំ តីរេ ជាដើម ហើយ

ទ្រង់ធ្វើកិច្ចទាំងពួង ។ ក្នុងបណ្ដាបទទាំងនោះ បទថា ន្ហាបេសុំ សេចក្ដីថា អ្នកដទៃជម្រះរាងកាយ អ្នកដទៃប្រកបលំអិតទាំងឡាយ អ្នកដទៃនាំទឹកមកឲ្យដល់អ្នកងូតទឹកត្រង់មាត់ស្រះបោក្ខរណី អ្នកដទៃទទួលសំពត់ និងឲ្យសំពត់ ។ បទថា បដ្ឋបេសិ សេចក្ដីថា ទ្រង់តាំងយ៉ាងណា ។ ទ្រង់តាំងរាជការ ប្រដាប់ដ៏សមគួរដល់ស្ត្រី និងបុរសទាំងឡាយ ទ្រង់តាំងត្រឹមតែស្ត្រីប៉ុណ្ណោះ ដោយអំណាចបម្រើក្នុងទីនោះៗ ទ្រង់តាំងកិច្ចទាំងអស់ដ៏សេសដោយអំណាចការបរិច្ចាគ ទ្រង់ឲ្យវាយស្គរប្រកាសថា ព្រះបាទមហាសុទ-ស្សនចក្រពត្តិទ្រង់ថ្វាយទាន អ្នកទាំងឡាយចូរបរិភោគទាននោះ ។

មហាជនមកកាន់មាត់ស្រះបោក្ខរណី ងូតទឹក ផ្លាស់សំពត់ លាបស្រឡាបដោយរបស់ក្រអូបផ្សេងៗ ប្រដាប់ខ្លួនដ៏វិចិត្រ ទៅរោងទាន ស៊ីនិងផឹកវត្ថុតាមត្រូវការ ក្នុងបណ្ដាយាគូ ភត្ត និងទំពារស៊ីច្រើនប្រការ និងគ្រឿងផឹក ៨ យ៉ាង ស្លៀកដណ្ដប់សំពត់កប្បាសសាច់ល្អិតទន់ល្មៃ មានពណ៌ផ្សេងៗ សោយសម្បត្តិ លះបុគ្គលដែលមានរបស់ដូច្នោះទៅ ។ អ្នកដែលមិនមានរបស់ដូច្នោះ កាន់យកហើយអំពីនោះទៅ ។ បុគ្គលដែលអង្គុយលើដំរី សេះ និងយានជាដើម ត្រាច់ទៅបន្តិចៗ មិនត្រូវការ ក៏ចេញទៅ ត្រូវការក៏កាន់យកទៅ ។ ត្រូវការក៏ទទួលទៅ ។ បុគ្គលដែល

ជេកក្នុងទីជេកដ៏ប្រសើរ សោយសម្បត្តិហើយ មិនត្រូវការក៏ចេញទៅ ។ អ្នកប្រដាប់ខ្លួនដោយគ្រឿងរតនៈ ៧ ប្រការ សោយសម្បត្តិហើយ មិនត្រូវការក៏ចេញទៅ ត្រូវការក៏ទទួលយកទៅ ។ ទានសូម្បីនោះ ព្រះបាទមហាសុទស្សនចក្រពត្តិ ទ្រង់ក្រោកឡើងហើយ ក៏ទ្រង់ថ្វាយ ។ ការងារយ៉ាងដទៃរបស់មនុស្សជម្ពូទ្វីបទាំងឡាយមិនមាន ។ មនុស្សជម្ពូទ្វីប ទៅបរិភោគទានរបស់ព្រះរាជាប៉ុណ្ណោះ ។

[១៤] លំដាប់នោះ ព្រាហ្មណ៍គហបតីទាំងឡាយគិតថា ព្រះរាជានេះ កាលនឹងថ្វាយទានបែបនេះ ក៏ទ្រង់មិនឲ្យនាំអ្វីមកថា អ្នកទាំងឡាយចូរឲ្យស្រូវអង្ករជាដើម ឬឲ្យទឹកដោះជាដើមដល់យើង ក៏ការណ៍នោះមិនសមគួរនឹងនៅស្ងៀមព្រងើយ ដោយថា ព្រះរាជារបស់ពួកយើង ទ្រង់មិនឲ្យនាំមក ។ ព្រាហ្មណ៍គហបតីទាំងនោះ ក៏រួបរួមទ្រព្យសម្បត្តិចំនួនច្រើន នាំទៅទូលថ្វាយដល់ព្រះរាជា ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ថា អថខោ អានន្ទ ព្រាហ្មណគហបតិកា ដូច្នេះ ជាដើម ។

បទថា ឯវំ សមចិន្តេសុំ សេចក្តីថា គិតរឿយៗ យ៉ាងនេះ ព្រោះហេតុអ្វី ។ ព្រោះព្រាហ្មណ៍គហបតីទាំងឡាយ គិតរឿយ ៗ យ៉ាងនេះថា អ្នកខ្លះនាំទ្រព្យសម្បត្តិអំពីផ្ទះតិច អ្នកខ្លះនាំមកច្រើន កាលទ្រព្យសម្បត្តិ

កំពុងរួបរួម សូម្បីសំឡេងគឹកកង ក៏គប្បីកើតឡើងថា ហេតុដូចម្តេចលោក ប៉ុណ្ណោះនាំទ្រព្យសម្បត្តិអំពីផ្ទះល្អ យើងនាំមកពីផ្ទះមិនល្អ ហេតុដូចម្តេច លោកប៉ុណ្ណោះនាំទ្រព្យសម្បត្តិអំពីផ្ទះច្រើន យើងមិនច្រើន ដូច្នេះ សំឡេង គឹកកងនោះ កុំគប្បីកើតឡើងឡើយ ។

**[១៥]** បទថា ឯហិ ត្វំ សម្ម សេចក្តីថា ម្នាលអ្នកមានយស លោក ចូរមក ។ បទថា ធម្មំ នាម ចាសាទំ សេចក្តីថា លើកឡើងហើយទ្រង់ តាំងឈ្មោះ ប្រាសាទ ។ ក៏វិស្សកម្មទេវបុត្រក្រាបទូលថា បពិត្រព្រះអង្គ ជាសម្មតិទេព ប្រាសាទនឹងធំប៉ុនណា គ្រាត្រាស់ថា ប្រាសាទនោះ ប្រវែង មួយយោជន៍ ទទឹងកន្លះយោជន៍ សាងដោយរតនៈទាំងពួងទូលទទួលព្រះ តម្រាស់ព្រះរាជាថា ចូរសម្រេចដូច្នោះ តាមព្រះតម្រាស់របស់ព្រះអង្គចុះ លំដាប់នោះ ទូលឲ្យព្រះធម្មរាជាទ្រង់ទទួលជ្រាបហើយ ក៏ធ្វើឲ្យសម្រេច ។

ក្នុងបទទាំងនោះ បទថា ឯវំ ភន្តេ ត្វាតិ ខោ អានន្ទ សេចក្តីថា ម្នាលព្រះអានន្ទ (វិស្សកម្មទេវបុត្រ ទូលទទួលហើយ) ថា ព្រះតម្រាស់ របស់ព្រះអង្គយ៉ាងនេះ ។ បទថា បដិស្សុណិត្វា សេចក្តីថា ទទួលជ្រាប ហើយ គឺ ក្រាបទូលហើយ ។ បទថា តុណ្ហីភាវេន សេចក្តីថា ព្រះបាទ មហាសុទស្សនចក្រពត្តិទ្រង់បំណងថា យើងនឹងមានឱកាសធ្វើការបដិបត្តិ

សមណធម៌ ទ្រង់ទទួលដោយការស្ងៀម ។

បទថា សារមយោ សេចក្ដីថា សម្រេចដោយខ្លឹមច័ន្ទ ។

[១៦] ក្នុងបទថា ទ្វីហិ វេទិកាហិ នោះ វេទិមួយមានក្នុងកំពូលឧណ្ហិស្សវេទិមួយ មានក្នុងទីបំផុតកំណត់ខាងក្រោម ។ បទថា ទុក្ខនិក្ខោ ហោសិ សេចក្ដីថា ឃើញបានលំបាក គឺ ឃើញបានលំបាក ព្រោះសម្បត្តិនៃពន្លឺ ។ បទថា មុសតិ គឺ នាំទៅឲ្យសម្រេច គឺ មិនឲ្យតាំងនៅ ដោយសភាពជានិច្ច ។ បទថា ឧបវិទ្ធេ សេចក្ដីថា រឹងមាំ គឺ នៅឆ្ងាយ ព្រោះប្រាសចាកពពក ។ បទថា ទេវេ សេចក្ដីថា ក្នុងអាកាស ។ បទថា មាបេសិ ខោ សេចក្ដីថា វិស្សកម្មទេវបុត្រមិនធ្វើយ៉ាងនេះថា យើងនឹងសាងស្រះបោក្ខរណីក្នុងទីនេះ លោកទាំងឡាយ ចូរទម្លាយផ្ទះរបស់លោកដូច្នេះ ហើយសាង ។ ក៏ស្រះបោក្ខរណីបែបនោះ បានផុសឡើងហើយដោយអំណាចនៃចិត្តុប្បាទ របស់ព្រះបាទមហាសុទស្សនចក្រពត្តិនោះ ។ បទថា តេ សក្កាមេហិ សេចក្ដីថា ទ្រង់ចិញ្ចឹមសមណៈទាំងឡាយ ដោយវត្ថុដែលត្រូវការទាំងពួង គឺ ដោយសមណបរិក្ខារ ទ្រង់ចិញ្ចឹមព្រាហ្មណ៍ទាំងឡាយដោយព្រាហ្មណបរិក្ខារ ។

" ចប់ បឋមភាណវារវណ្ណនា "

## ទុតិយភាណវារៈ

### ពោលអំពី ឧទានរបស់ព្រះចៅមហាសុទស្សនៈ

[១៧] *បទថា* មហិទ្ធិកោ *សេចក្ដីថា ទ្រង់ដល់ព្រមដោយឥទ្ធិច្រើន ពោលគឺ សេចក្ដីសម្រេចនៃស្រះបោក្ខរណីចំនួន ៨៤,០០០ ស្រះ ដោយអំណាចនៃចិត្តប្បាទប៉ុណ្ណោះ ។ បទថា* មហានុភាវោ *សេចក្ដីថា ដល់ព្រមដោយអានុភាពធំ ព្រោះកម្មដែលគប្បីសោយទាំងនោះ មានច្រើន ។ បទថា* សេយ្យថីទំ *សេចក្ដីថា ជានិបាត ។ អត្ថនៃនិបាតនោះថា កម្ម ៣ ប្រការ ដូចម្ដេច ? ។ បទថា* ទានស្ស *បានដល់ បរិច្ចាគសម្បត្តិ ។ បទថា* ទមស្ស *សេចក្ដីថា បញ្ញាមកថា ទមៈ ក្នុងអាឡវកសូត្រ ។ ក្នុងបទនេះ យើងទូន្មានខ្លួនឯង រក្សាឧបោសថកម្ម ។ បទថា* សញ្ញមស្ស *បានដល់ សីល ។ ក៏គប្បីជ្រាបបុព្វយោគរបស់ព្រះរាជា ដែលតាំងនៅក្នុងសីលនេះ ដូច្នេះ ។*

*បានឮថា ក្នុងកាលមុន ព្រះរាជាទ្រង់សម្ភពក្នុងត្រកូលគហបតី ។ សម័យនោះ ព្រះថេរៈមួយរូបក្នុងសាសនារបស់ព្រះពុទ្ធកស្សបៈ ទ្រង់នៅមានព្រះជន្ម ចាំវស្សាក្នុងព្រៃ ។ ព្រះពោធិសត្វ ចូលព្រៃដោយការងារ*

របស់ខ្លួន ឃើញព្រះថេរៈហើយ ចូលទៅគាល់ថ្វាយបង្គំ បានក្រឡេក មើលទីអង្គុយ និងទីចង្ក្រមជាដើម របស់ព្រះថេរៈ ទើបសួរថា បពិត្រ លោកដ៏ចម្រើន លោកម្ចាស់នៅក្នុងទីនោះឬ ។ បានស្តាប់ថា យ៉ាងនោះ ឧបាសក ទើបគិតថា សមគួរដល់ការសាងបណ្ណសាលាថ្វាយលោកម្ចាស់ ក្នុងទីនេះ ហើយផ្អាកការងាររបស់ខ្លួន ជញ្ជូនទព្វសំភារៈ ធ្វើបណ្ណសាលា លាប បូកជញ្ជាំងដោយដីស្អិត ភ្ជាប់ទ្វារ ធ្វើបង្អែកអង្គុយ ហើយអង្គុយ ក្នុងទីសមគួរម្ខាង ដោយគិតថា ព្រះថេរនឹងធ្វើការបរិភោគ ឬទេហ្ន៎ ។

ព្រះថេរៈមកពីខាងក្នុងស្រុក ចូលទៅកាន់បណ្ណសាលាហើយ អង្គុយ ត្រង់ទីបង្អែក ។ សូម្បីឧបាសកមកហើយ សំពះអង្គុយក្នុងទីជិត សួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន បណ្ណសាលានៅជាសប្បាយទេ ។ សប្បាយ សមគួរដល់បព្វជិត ។ លោកនឹងនៅទីនេះឬ ។ យ៉ាងនោះ ឧបាសក ។ ឧបាសកនោះដឹងថា ព្រះថេរៈនឹងនៅដោយអាការទទួល ក៏ទូលឲ្យព្រះថេរៈ ជ្រាបថា លោកម្ចាស់គប្បីទៅកាន់ទ្វារផ្ទះរបស់ខ្ញុំជានិច្ចចុះ ហើយទូល ប្រាប់ថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ចូរឲ្យពរមួយ ដល់ ខ្ញុំចុះ ។ ម្នាលឧបាសក បព្វជិតឈានកន្លងហើយ ។ បពិត្រលោកម្ចាស់ ដ៏ចម្រើន ជាពរដែលគួរនឹងមិនមានទោស ។ ឧបាសកចូរប្រាប់ ។ បពិត្រ

លោកម្ចាស់ដ៏ចម្រើន មនុស្សទាំងឡាយ ក្នុងទីជាទីនៅប្រចាំ រមែងប្រាថ្នាការមកក្នុងមង្គល ឬអមង្គល រមែងក្រោធដល់ព្រះថេរៈអ្នកមិនមក ព្រោះដូច្នោះ លោកម្ចាស់សូមប្បីទៅកាន់ទីនិមន្តដទៃហើយ ចូលទៅកាន់ផ្ទះរបស់ខ្ញុំហើយ គប្បីធ្វើភត្តកិច្ច ។ ព្រះថេរៈ ក៏ទទួលហើយ ។

ព្រះពោធិសត្វនោះ ក្រាលកន្ទេលក្នុងសាលា រៀបចំគ្រែ តាំង ធ្វើបង្អែក រៀបចំកន្ទេលជូតជើង ជីកស្រះ ធ្វើទីចង្រ្កមចាក់វាយដោយខ្សាច់ កាលឃើញសត្វមកទម្លាយជញ្ជាំង ធ្វើជីស្អិតឲ្យជ្លាក់ ក៏ស្រះបន្ទា ឃើញសត្វចុះស្រះធ្វើទឹកធ្វើឲ្យល្អក់ ក៏ធ្វើជណ្តើរខាងក្នុង ព័ទ្ធរបងបន្ទាខាងក្រៅ ដាំជួរត្នោតខាងក្នុងរបង កាលឃើញសត្វធ្វើកន្ទេលក្នុងទីមហាចង្រ្កមឲ្យស្មោកគ្រោក ក៏ធ្វើរបងព័ទ្ធទីចង្រ្កម ដាំជួរត្នោតក្នុងរបងខាងក្នុង ញុំាងអាវាសឲ្យសម្រេចយ៉ាងនេះ ថ្វាយត្រៃចីវរ បិណ្ឌបាត ថ្នាំ ភាជនៈបរិភោគ ក្អមទឹកកន្ត្រៃ កាំបិតកាត់ក្រចក ម្ជុល ឈើប្រត់ ស្បែកជើង ពាងទឹក ឆត្រគប់ភ្លើង ឈើខ្វេះអាចម៍ត្រចៀក បាត្រ ស្មោកបាត្រ សំពត់តម្រងទឹក ទីត្រងទឹក ក៏ឬវត្ថុ ដែលបព្វជិតគួរបរិភោគដទៃចំពោះព្រះថេរៈ ឈ្មោះថាបរិក្ខារ ដែលព្រះពោធិសត្វមិនថ្វាយដល់ព្រះថេរៈមិនមាន ។ ព្រះពោធិ-សត្វនោះ រក្សាសីល រក្សាឧបោសថ ទំនុកបម្រុងព្រះថេរៈរហូតអស់ជីវិត ។

ព្រះថេរៈនៅក្នុងអាវាសនោះឯង សម្រេចព្រះអរហត្តហើយនិព្វាន ។ ចំណែក ព្រះពោធិសត្វ ធ្វើបុណ្យរហូតអស់អាយុ ហើយទៅកើតក្នុងទេវលោក ចុតិអំពីទេវលោកនោះ មកកាន់មនុស្សលោក កើតជាព្រះបាទមហាសុទស្សនចក្រពត្តិ ក្នុងរាជធានី ឈ្មោះថា **កុសាវតី** ។

**បុណ្យសូម្បីដែលមិនធំក្រៃលែង បានធ្វើហើយក្នុងសាសនា**

**របស់លោកយ៉ាងនេះ មហាវិបាក ទើបមាន ព្រោះដូច្នោះ**

**អ្នកមានបញ្ញា គប្បីធ្វើបុណ្យនោះ ។**

បទថា មហាវិយូហំ សេចក្តីថា មហាកូដាគារដែលធ្វើដោយប្រាក់ ។ ទ្រង់ព្រះបំណងនឹងប្រថាប់នៅក្នុងកូដាគារនោះ ទើបបានស្តេចទៅ ។ បទថា ឋត្វាវសា កាមវិតក្កា សេចក្តីថា ព្រះបាទមហាសុទស្សនចក្រពត្តិ ទ្រង់គ្រប សង្កត់វិតក្កទាំងបីត្រង់ទ្វារកូដាគារនោះឯង យ៉ាងនេះថា ៖

ម្នាលកាមវិតក្ក អ្នកគប្បីត្រឡប់ត្រឹមតែប៉ុណ្ណេះ ខាងមុខអំពីនេះទៅ អ្នកមិនមានទីនៅ នេះឈ្មោះថា **ឈានាគារ** ឈានាគារនេះ មិនមែនទីនៅរួមជាមួយអ្នកឡើយ ។

ក្នុងពាក្យថា **បឋមជ្ឈានំ** ជាដើម ឈ្មោះថា កសិណបរិកម្មកិច្ចរមែងមិនមានដទៃទៀត កាលមានសេចក្តីត្រូវការនីលកសិណ នីលមណី

ក៏រមែងមាន កាលមានសេចក្តីត្រូវការដោយបិតកសិណ សុវណ្ណៈក៏រមែងមាន កាលមានសេចក្តីត្រូវការដោយលោហិតកសិណ រត្តមណីក៏រមែងមាន កាលមានសេចក្តីត្រូវការដោយឱទាតកសិណ វជ្ជៈក៏រមែងមាន លោកបញ្ញត្តិកសិណក្នុងឋានៈដែលក្រឡេកមើលហើយ យ៉ាងនេះ ។

[១៨] ក្នុងបទថា មេត្តាសហគតេន ជាដើម ពាក្យដែលនឹងគប្បីពោលសូម្បីទាំងអស់ បានពោលហើយក្នុងវិសុទ្ធិមគ្គនោះឯង ។ លោកពោលឈានបួន អប្បមញ្ញាបួន ក្នុងបាលីដោយប្រការដូច្នេះ ។ ក៏មហាបុរសញុំាងសមាបត្តិ ៨ អភិញ្ញា ៥ ឲ្យកើតហើយចូលសមាបត្តិ ដោយអាការ ១៤ ដោយអំណាចអនុលោម បដិលោមជាអាទិ៍ ឲ្យប្រព្រឹត្តទៅ ដោយសេចក្តីសុខក្នុងសមាបត្តិនោះឯង ដូចភមរៈចូលសម្បុកឃ្មុំ រស់នៅដោយមធុរស ដូច្នោះ ។

[១៩] ពាក្យថា **កុសាវតីរាជធានី** សេចក្តីថា កុសាវតីរាជធានីជាប្រមុខ គឺ ជាធំនៃព្រះនគរទាំងនោះ ។ បទថា ភត្តាភិហារោ សេចក្តីថា ភត្តដែលនឹងគប្បីនាំទៅចំពោះ ។

[២០] បទថា វស្សសតស្ស វស្សសតស្ស សេចក្តីថា លោកគិតយ៉ាងនេះ ព្រោះហេតុអ្វី ។ ព្រោះរំខានដោយសំឡេងនៃបុគ្គលទាំងនោះ ។

ក៏លោកពោលថា "សំឡេង ជាបន្លារបស់អ្នកចូលសមាបត្តិ" ព្រោះដូច្នោះ មហាបុរសទើបរំខានដោយសំឡេង ។ បើដូច្នោះ ហេតុដូចម្តេច ទើបមិនប្រាប់ថា ពួកលោកចូរកុំមក ។ ឥឡូវនេះ ព្រះរាជាមិនឃើញ ព្រោះដូច្នោះ ទើបមិនពោលថា នឹងមិនបានវត្តជានិច្ច វត្តនោះ របស់ជនទាំងនោះ ចូរកុំដាច់ទៅ ។

បទថា ឯតទហោសិ សេចក្តីថា ការគិតនោះ បានមានហើយ ក្នុងកាលណា ។ ក្នុងថ្ងៃកាលកិរិយារបស់ព្រះរាជា ។ បានឮថា ក្នុងកាលនោះ ទេវតាទាំងឡាយគិតថា ព្រះរាជាចូរកុំទ្រង់ធ្វើកាលកិរិយាយ៉ាងអនាថា ចូរមានបុត្រធីតាទាំងឡាយ មកស្រែកយំហែហមក្នុងការធ្វើកាលកិរិយាចុះ ។ លំដាប់នោះ ក៏នឹកដល់ព្រះទេវី ញ៉ាំងចិត្តនៃព្រះទេវីឲ្យកើតឡើងយ៉ាងនេះ ។ បទថា ឋិតានិ វត្ថានិ សេចក្តីថា បានឮថា សំពត់លឿងទាំងនោះ ជាទីពេញព្រះរាជហឫទ័យរបស់ព្រះរាជាដោយប្រក្រតី ព្រោះដូច្នោះ ព្រះនាងសុភទ្ទាទេវី ទើបត្រាស់ថា នាងទាំងឡាយចូរដណ្តប់សំពត់លឿង ។ បទថា ឯត្ថេវ ទេវ តិដ្ឋ សេចក្តីថា ឈ្មោះថា ឈានាគារនេះ មិនមែនស្ថានទីនៅរួមជាមួយលោកទាំងឡាយ តែឈ្មោះថា ជាស្ថានទីដែលបានសេចក្តីត្រេកអរក្នុងឈាន លោកកុំចូលមកក្នុងទីនេះ ។

## ពោលអំពី ព្រះនាងសុភទ្ទាទេវី

[២១] បទថា ឯតទវោច សេចក្តីថា ធម្មតាសត្វទាំងឡាយក្នុងលោក រមែងរុងរឿងក្រៃលែងក្នុងកាលសម័យជិតស្លាប់ ដោយហេតុនោះព្រះនាងទេវីនោះ ទ្រង់ឃើញសភាពនៃព្រះរាជាទ្រង់មានព្រះឥន្ទ្រិយថ្លាផូរផង់ ទើបមានព្រះតម្រាស់យ៉ាងនោះ ។

តពីនោះ ព្រះនាងទេវីទ្រង់មិនប្រាថ្នាកាលកិរិយារបស់ព្រះរាជាថា សូមកាលកិរិយាកុំមានចំពោះព្រះរាជា ត្រាស់ដល់គុណសម្បត្តិ របស់ព្រះរាជានោះ ទ្រង់គិតថា យើងនឹងធ្វើអាការឲ្យទ្រង់មានព្រះជន្មនៅ ទើបទូលថា ឥមានិ តេ ទេវ ជាដើម ។

ក្នុងបទទាំងនោះ បទថា ឆន្ទំ ជនេហិ សេចក្តីថា ចូរទ្រង់ញ៉ាំងសេចក្តីស្រឡាញ់ឲ្យកើតឡើង គឺ ចូរទ្រង់ធ្វើបីតិ ។ បទថា ជីវិតេ បេក្ខំ អបេក្ខ សេចក្តីថា ព្រះអង្គចូរទ្រង់ធ្វើសេចក្តីអាល័យ គឺ សេចក្តីប្រាថ្នាក្នុងជីវិត ។ បទថា ឯវំ ខោ មំ ត្វំ ទេវិ សេចក្តីថា កាលព្រះនាងទេវីសម្គាល់ព្រះរាជាថា ព្រះរាជានេះ ជាបណ្ឌិត ទើបទូលថា បពិត្រទេវៈ នាងខ្ញុំម្ចាស់ជាស្រី រមែងមិនដឹងនូវពាក្យដែលគួរដល់បណ្ឌិត នាងខ្ញុំម្ចាស់នឹងពោលយ៉ាងណា មហារាជ ព្រះបាទមហាសុទស្សនចក្រពត្តិ ទើបត្រាស់

ថា ឃរំ ខោ មំ ត្វំ នេវិ សមុទាចារ ដូច្នេះ ។ បទថា គរហិតា សេចក្ដីថា សាបេក្ខកាលកិរិយា ដែលព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះសាវក និងបព្វជិត ពួកដទៃអ្នកជាពហុស្សូតតិះដៀលហើយ ។ ព្រោះហេតុអ្វី ។ ព្រោះកាល-កិរិយា ដែលមានសេចក្ដីហួងហែងជាហេតុ ឲ្យកើតជាយក្ខ សុនខ ពពែ គោ ក្របី កណ្ដុរ មាន់ និងសត្វបក្សីជាដើម ក្នុងផ្ទះរបស់ខ្លួនប៉ុណ្ណោះ ។

[២២] បទថា អជខោ អានន្ទ សេចក្ដីថា ព្រះនាងទេវី ទៅក្នុងទីដ៏សមគួរម្ខាង ហើយទ្រង់ព្រះកន្សែង ទ្រង់ជូតព្រះអស្សុជល ទើបត្រាស់ដូច្នោះ ។ បទថា កហាបតិស្ស វា សេចក្ដីថា ហេតុដូចម្ដេច ព្រះមាន-ព្រះភាគ ទើបត្រាស់ ។ បានឮថា សម្បត្តិដ៏ច្រើន រមែងមានដល់ជនទាំងនោះ ដូចមានដល់បុត្ររបស់សោណសេដ្ឋីជាដើម ដូច្នោះ ។ បានឮថា ថាសនៃភត្តមួយរបស់សោណសេដ្ឋីបុត្រ មានតម្លៃពីរសែន កាលជនទាំងនោះបរិភោគភត្តដូច្នោះ មួយភ្លែតក៏កើតសេចក្ដីស្រវឹងក្នុងភត្ត ធ្វើឲ្យលំបាកចិត្ត ព្រោះភត្ត ដោយប្រការដូច្នេះ ។

## បច្ឆិមជាតិរបស់ព្រះបាទមហាសុទស្សនៈ

[២៣-២៤] បទថា យំ តេន សមយេន អជ្ឈាវសាមិ សេចក្ដីថា

នគរដែលយើងរស់នៅ មានត្រឹមនគរតែមួយប៉ុណ្ណោះ ។ បុត្រធីតាជាដើម និងទាសមនុស្សទាំងឡាយ នៅក្នុងនគរដ៏សេស ។ សូម្បីក្នុងប្រាសាទ និងកូដាគារទាំងឡាយ ក៏មានន័យដូចគ្នា ។

ក្នុងបល្ល័ង្កជាដើម ក៏ទ្រង់ប្រើបល្ល័ង្កតែមួយប៉ុណ្ណោះ ។ បល្ល័ង្កដ៏សេស ជារបស់ប្រើសម្រាប់បុត្រជាដើម ។ សូម្បីក្នុងស្ត្រីទាំងឡាយ ស្ត្រីតែម្នាក់ប៉ុណ្ណោះ ទំនុកបម្រុង ស្ត្រីដ៏សេសត្រឹមតែជាបរិវារ ។ បទថា បរិទហាមិ សេចក្តីថា យើងស្លៀកសំពត់គូតែមួយប៉ុណ្ណោះ ។ សំពត់គូដ៏សេស រមែងមានដល់បុរស ១៦ សែន ៨០ ពាន់នាក់ ដែលសូមត្រាច់ទៅ ។ បទថា ភុញ្ជាមិ សម្តែងថា យើងបរិភោគបាយត្រឹមតែមួយនាឡីដោយបត្ថៈជាប្រមាណដ៏សេស បានដល់ បុរស ៨ សែន ៤០ ពាន់ ដែលសូមត្រាច់ទៅ ។ ពិតណាស់ សម្រាប់មួយ ល្មមដល់ជន ១០ នាក់ ។ បានឮថា ព្រះនគរ ៨៤,០០០ កន្លែង ប្រាសាទមួយពាន់ខ្នង និងកូដាគារមួយពាន់ កើតឡើងព្រោះផលបុណ្យ ហូរមកអំពីបណ្ណសាលាមួយខ្នង ។ បល្ល័ង្ក ៨៤.០០០ កើតឡើង ដោយផលបុណ្យហូរមកអំពីគ្រែ ដែលថ្វាយ ដើម្បីប្រយោជន៍ដល់ការដេក ។ ដំរី ៨៤.០០០ សេះ ១.០០០ រថ ១.០០០ កើតឡើងដោយផលបុណ្យដែលហូរមកអំពីតាំង ដែលថ្វាយដើម្បី

ប្រយោជន៍ដល់ការអន្ទ្ឋ័យ ។ កែវមណី ៨៤.០០០ កើតឡើងដោយផល បុណ្យដែលហូរមកអំពីប្រទីបមួយ ។ ស្រះបោក្ខរណី ៨៤.០០០ កើតឡើងដោយផលបុណ្យដែលហូរមកអំពីស្រះបោក្ខរណីមួយ ។ ស្ត្រី ៨៤.០០០ នាក់ បុត្រ ១.០០០ នាក់ គហបតី ១,០០០ នាក់ កើតឡើងដោយផលបុណ្យដែលហូរមកអំពីការថ្វាយបរិភោគភាជនៈ បាត្រ ស្មោកបាត្រ ធម្មក្រក សំពត់ត្រងទឹក ធ្នាំងទឹក កន្ត្រៃ កាំបិតកាត់ក្រចក ម្ជុល សោរ ឈើខ្វៈ អាចម៍ត្រចៀក សំពត់ជូតជើង ស្បែកជើង ឆ័ត្រ និងឈើប្រត់ ។ មេគោយកទឹកដោះ ៨៤.០០០ ក្បាល កើតឡើងដោយផលបុណ្យដែលហូរមកអំពីទានគោរស ។ សំពត់ ៨៤,០០០ កោដិផាប់ កើតឡើងដោយផលបុណ្យដែលហូរមកអំពីទានសំពត់ស្លៀក សំពត់ដណ្តប់ ។ សម្រាប់ដាក់ព្រះក្រយាហារ ៨៤,០០០ សម្រាប់ គប្បីជ្រាបថា កើតឡើងដោយផលបុណ្យដែលហូរមកអំពីទានភោជនា ។ ព្រះមានព្រះភាគ ត្រាស់ដល់សម្បត្តិរបស់ព្រះបាទមហាសុទស្សនចក្រពត្តិ តាំងអំពីដើម ដោយពិស្តារដូច្នេះហើយ កាលនឹងទ្រង់សម្តែងសម្បត្តិនោះទាំងអស់ ដូចសម្តែងពេងលេងធូលីដល់ក្មេងទាំងឡាយ ផ្ទំលើព្រះទែនជាទីរលត់ខន្ធបរិនិព្វាន ហើយត្រាស់ថា ម្នាលអានន្ទ អ្នកចូរមើល ដូច្នេះជាអាទិ៍ ។

ក្នុងបទទាំងនោះ បទថា វិបរិណតា សេចក្តីថា ដល់នូវសេចក្តីប្រែប្រួល ដូចប្រទីបរលត់ ដោយលះប្រក្រតីទៅ ដូច្នោះ ។ បទថា ឯវំ អនិច្ចាខោ អានន្ទ សង្ខារា សេចក្តីថា ឈ្មោះថា មិនទៀង ព្រោះអត្ថថាមានហើយ ត្រឡប់ជាមិនមានយ៉ាងនេះ ។ បុរសចងបង្អោនក្នុងដើមឈើចម្បាកម្ពស់ ១០០ ហត្ថ ឡើង ហើយកាន់យកផ្កាឈើចម្បា ស្រាយបង្អោនចុះមកយ៉ាងណា ព្រះមានព្រះភាគ ក៏ដូច្នោះដែរ ទ្រង់លើកនូវសម្បត្តិរបស់ស្តេចមហាសុទស្សនចក្រពត្តិ ខ្ពស់ដល់សែនកោដិឆ្នាំមិនមែនតិច ដូចចងបង្អោន ទ្រង់កាន់យកអនិច្ចលក្ខណៈ ដែលតាំងនៅក្នុងទីបំផុតនៃសម្បត្តិឈានចុះ ដូចស្រាយបង្អោន ដោយប្រការដូច្នេះ ។ ដោយហេតុនោះ ក្នុងកាលមុន ព្រះបាទវសភៈ ទ្រង់ស្តាប់ព្រះសូត្រនេះ ដែលព្រះទីឃ-ភាណត្ថេរ ស្វាធ្យាយក្នុងអម្ពលដ្ឋិកា នាទិសខាងកើតនៃលោហៈប្រាសាទ ហើយទ្រង់គិតថា លោកម្ចាស់របស់យើងពោលអ្វីក្នុងទីនេះ លោកម្ចាស់ពោលចំពោះសម្បត្តិក្នុងឋានៈដែលខ្ញុំបានស៊ី បានផឹកប៉ុណ្ណោះ ទ្រង់ដាក់ព្រះហស្តឆ្វេងផ្គុំដោយព្រះហស្តស្តាំថា លោកមានចក្ខុដោយចក្ខុ ៥ ប្រការ ឃើញសូត្រនេះហើយពោលយ៉ាងនេះ ក្នុងកាលដែលព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ សង្ខារទាំងឡាយមិនទៀងយ៉ាងនេះឯង ។ ទ្រង់មាន

ព្រះហឫទ័យត្រេកអរថា សាធុ សាធុ ទ្រង់ឲ្យសាធុការ ។

បទថា ឯវំ អធុវា សេចក្ដីថា ប្រាសចាកសេចក្ដីពិតប្រាកដ ដូចលេកទឹកជាដើមយ៉ាងនេះ ។ បទថា ឯវំ អនស្សាសិកា សេចក្ដីថា ប្រាសចាកខ្យល់អស្សាសៈដូចទឹកដែលផឹកហើយ និងដូចបបោសអង្អែលព្រះច័ន្ទក្នុងការយល់សប្ដិ ដូច្នោះ ។ បទថា សរីរំ និក្ខិបេយ្យ សេចក្ដីថា បោលសាកសព ។ ឥឡូវនេះ ព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ ការបោលឬការបដិបត្តិសរីរៈដទៃ រមែងមិនមានដល់ព្រះតថាគត ។ ក៏កាលត្រាស់យ៉ាងនេះហើយ ទើបត្រាស់ហៅព្រះថេរៈទៀតថា ធម្មតាអានុភាពនៃស្ដេចចក្រពត្តិ រមែងអន្តរធានក្នុងថ្ងៃទី ៧ បន្ទាប់ពីការបួស ។ ចំណែកសម្បត្តិទាំងអស់នេះ គឺ កំពែងរតនៈ ៧ ជាន់ ត្នោតរតនៈ ស្រះបោក្ខរណី ៨៤.០០០ ធម្មបសាទ ធម្មបោក្ខរណី ចក្ករតន៍ អន្តរធានហើយក្នុងថ្ងៃ ទី ៧ ចាប់ពីកាលកិរិយានៃព្រះបាទមហាសុទស្សនចក្រពត្តិ ។ ក្នុងដំរីជាដើមក៏ធម្មតាយ៉ាងនេះ ។ ដែលអស់អាយុក្ខ័យ ក៏ធ្វើកាលកិរិយាទៅ ។ គ្រាអាយុនៅសល់ ហត្ថីរតនៈ ក៏ទៅកាន់ត្រកូលឧបោសថ អស្សរតនៈ ក៏ទៅកាន់ត្រកូលវលាហកៈ មណីរតនៈ ក៏ទៅកាន់វេបុល្លបព៌ត ប៉ុណ្ណោះឯង ។ អនុភាពនៃឥត្ថីរតន៍ រមែងអន្តរធានទៅ ។ ចក្ខុរបស់គហបតីរតន៍ ក៏នឹង

*ត្រឡប់ជាប្រក្រតី ។ ការខ្វល់ខ្វាយរបស់បរិនាយករតន៍ ក៏រមែងវិនាស ។*

*បទថា ឥធមហោជ ភគវា សេចក្តីថា ព្រះមានព្រះភាគ បានត្រាស់បទនេះទាំងអស់ដែលមកហើយ និងមិនមានមកហើយក្នុងព្រះបាលី ។ បទដ៏សេសមានសេចក្តីងាយទាំងអស់ ដូច្នេះ ។*

" ចប់ អដ្ឋកថា មហាសុទស្សនសូត្រទី ៤ "

# អដ្ឋកថា ជនវសភសូត្រ ទី ៥

[២៥] ជនវសភសូត្រ មានពាក្យផ្តើមថា ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ ការពណ៌នាបទមិនងាយយល់ក្នុងជនវសភសូត្រ ដូច្នេះ ៖

បទថា បរិតោ បរិតោ ជនបទេសុ សេចក្តីថា ក្នុងជនបទជិតខាង ។ បទថា បរិចារកេ សេចក្តីថា អ្នកទំនុកបម្រុងព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ។ បទថា ឧប្បត្តីសុ សេចក្តីថា ក្នុងការឧប្បត្តិនៃញាណគតិ និងបុណ្យ ។ បទថា កាសីកោសលេសុ សេចក្តីថា ក្នុងដែនកាសី និងកោសល ។ អធិប្បាយថា ក្នុងកាសីរដ្ឋ និងកោសលរដ្ឋ ។ ក្នុងបទទាំងពួង ក៏មានន័យដូចគ្នា ។ តែទ្រង់មិនព្យាករណ៍ក្នុងរដ្ឋទាំង ៦ គឺ អង្គៈ មគធៈ យោនកៈ កម្ពោជៈ អស្សកៈ និងអវន្តី ។ ក៏ទ្រង់ព្យាករណ៍ក្នុងជនបទ ១០ មុន នៃមហាជនបទ ១៦ នេះ ។

## ទ្រង់ព្យាករក្នុងកំណើតនៃបញ្ញា និងគតិ និងបុណ្យ

[២៦] បទថា នាទិកិយា សេចក្តីថា អ្នកស្រុកនាទិកៈ ។ បទថា តេន ច សេចក្តីថា ជាព្រះអនាគាមី ជាដើមនោះ ។ បទថា សុត្វា សេចក្តីថា បានស្តាប់ព្យាករណ៍បញ្ហារបស់ព្រះមានព្រះភាគ ទ្រង់កំណត់

ដោយព្រះសព្វញ្ញុតញ្ញាណព្យាករណ៍ហើយ ក៏នឹងដល់ទីបំផុត ក្នុងភាពជាព្រះអនាគាមីជាដើម របស់ជនទាំងនោះ ក៏នឹងមានចិត្តជារបស់ខ្លួន ភាពជាព្រះអនាគាមីជាដើមនោះ ។ តែក្នុងអដ្ឋកថា លោកពោលថា បទថា តេន គឺ អ្នកស្រុកនាទិកៈទាំងនោះ ។ ពិតហើយ **ន** អក្សរ ក្នុងអត្ថនោះ ត្រឹមតែជានិបាត ។

## ពោលអំពី សេចក្តីត្រិះរិះរបស់ព្រះអានន្ទ

[**២៧**] បទថា ភគវន្តំ កិត្តយមានរូបោ សេចក្តីថា ព្រះបាទពិម្ពិសារ ទ្រង់បរិកម្មយ៉ាងនេះថា ឱហ្ន៎ព្រះពុទ្ធ ឱហ្ន៎ព្រះធម៌ ឱហ្ន៎ព្រះសង្ឃ ឱហ្ន៎ព្រះធម៌ដែលត្រាស់ល្អ សុគតហើយ ។ បទថា ពហុជនោ បសីទេយ្យ សេចក្តីថា ជនច្រើនដល់សេចក្តីជ្រះថ្លាយ៉ាងនេះថា បិតា មាតា បងប្រុស បងស្រី បុត្រ ធីតា សម្លាញ់ របស់ពួកយើង ពួកយើងធ្លាប់ស៊ីរួម ដេករួមនឹងលោក ពួកយើងនឹងធ្វើវត្ថុដែលគួរពេញចិត្តយ៉ាងនេះ និងដល់លោកនោះ បានឮថា លោកនោះ ជាអនាគាមី សកទាគាមី សោតាបន្ន ឱហ្ន៎ជាការប្រសើរ ឱហ្ន៎ជាការប្រពៃ ។

[**២៨**] បទថា គតឹ គឺ ញាណគតិ ។ បទថា អភិសម្បរាយំ

សេចក្ដីថា មានញាណប្រព្រឹត្តទៅខាងមុខ ។ បទថា អទ្ទសា ខោ សេចក្ដីថា បានឃើញជនប្រមាណប៉ុនណា ។ ប្រមាណ ២,៤០០,០០០ នាក់ ។

## ការចូលទៅគាល់ព្រះមានព្រះភាគនៃព្រះអានន្ទ

[២៩] បទថា ឧបសន្តបតិស្សោ សេចក្ដីថា ទ្រង់មានទស្សនស្ងប់ហើយ ។ បទថា ភាតិរិវ សេចក្ដីថា ស្រស់បស់ក្រៃលែង គឺ រុងរឿងក្រៃលែង ។ បទថា ឥន្ទ្រិយានំ សេចក្ដីថា ព្រះឥន្ទ្រិយដែលមានព្រះហឫទ័យជាគម្រប់ ៦ ។ បទថា អទ្ទសំ ខោ អហំ អានន្ទ សេចក្ដីថា ព្រះមានព្រះភាគត្រាស់ថា តថាគតបានឃើញអ្នកមគធៈ ដែលទំនុកបម្រុង មិនមែនចំនួន ១០ ចំនួន ២០ ចំនួនមួយរយ ចំនួនមួយពាន់ តែចំនួនមិនតិចជាង ២,៤០០,០០០ នាក់ ។ តែជនមានប្រមាណប៉ុណ្ណោះ ឃើញតថាគតហើយ អាស្រ័យតថាគត ផុតពីទុក្ខហើយ សោមនស្សមានកម្លាំងកើតឡើងហើយ ចិត្តជ្រះថ្លា ព្រោះចិត្តជ្រះថ្លា លោហិតដែលមានចិត្តជាសមុដ្ឋានក៏ថ្លាផូរផង់ ព្រោះលោហិតថ្លាផូរផង់ ឥន្ទ្រិយទាំងឡាយដែលមានមនៈជាគម្រប់ ៦ ក៏ថ្លាផូរផង់ គ្រាត្រាស់ដូច្នេះហើយ ទើបត្រាស់ថា អថខោ អានន្ទ ជាដើម ។

ព្រះបាទពិម្ពិសារព្រះអង្គនោះ ទ្រង់ស្ដាប់ព្រះធម្មកថារបស់សម្ដេច

ព្រះមានព្រះភាគក្នុងទីនោះ ជាធំនៃជនមួយសែន និងក្រៃលែងដោយ ១០ ពាន់ សម្រេចជាព្រះសោតាបន្ន ព្រោះដូច្នោះ ព្រះអង្គ ទើបមានព្រះនាមថា **ជនវសភៈ** ។

## ពោលអំពី ជនវសភយក្ស

[៣០-៣១] បទថា ឥតោ សត្ត សេចក្តីថា ចុតិចាកទេវលោកនេះ ៧ ដង ។ បទថា តតោ សត សេចក្តីថា ចុតិអំពីមនុស្សលោកនោះ ៧ ដង ។ បទថា សំសរាមិ ចតុទ្ទស សេចក្តីថា តាមលំដាប់ខន្ធទាំងអស់ ១៤ ដង ។ បទថា និវាសមភិជានិ សេចក្តីថា យើងដឹងនិវាសដោយអំណាចនៃជាតិ ។ បទថា យត្ថ មេ វុសិតំ បុរេ សេចក្តីថា យើងចូលដល់ភាពជាសម្លាញ់នៃវេស្សវណក្នុងទេវលោក និងជារាជាក្នុងមនុស្សលោកហើយ ក្នុងកាលមុនអត្តភាពនេះ និងព្រោះបាននៅយ៉ាងនេះហើយ ឥឡូវនេះ បានជាសោតាបន្ន ធ្វើបុណ្យច្រើនក្នុងវត្ថុទាំង ៣ សូម្បីអាចកើតក្នុងទីខ្ពស់ ដោយអានុភាពនៃបុណ្យនោះ ទើបបានកើតហើយក្នុងទីនេះឯង ព្រោះកម្លាំងនៃសេចក្តីប្រាថ្នាក្នុងទីនៅរហូតអស់កាលយូរ ។

ដោយបទថា អាសា ច បន មេ សន្តិដ្ឋតិ នេះ លោកសម្តែងថា

យើងមិនប្រមាទថា យើងជាសោតាបន្ន ញ៉ាំងកាលឲ្យកន្លងហើយ ក៏យើងបានចម្រើនវិបស្សនា ដើម្បីប្រយោជន៍ដល់ព្រះសកទាគាមី ហើយមានសេចក្តីសន្សឹមថា យើងនឹងសម្រេចក្នុងថ្ងៃនេះៗ ។ បទថា យធគ្គេ សេចក្តីថា លោកពោលបំណាំងដល់ថ្ងៃសម្រេចព្រះសោតាបន្នក្នុងបឋមទស្សន៍ ត្រង់សួនលដ្ឋិវ័ន ។ បទថា តធគ្គេ អហំ ភន្តេ ទីឃរត្តំ អវិនិចាតោ អវិនិចាតំ សញ្ជានាមិ សេចក្តីថា បពិត្រលោកដ៏ចម្រើន ខ្ញុំបានធ្វើថ្ងៃនោះជាដើមហេតុមិនធ្លាក់ចុះជាវេលាយូរ នោះបាន ១៤ អត្តភាពមុន បានចាំធម៌ ដែលមិនញ៉ាំងខ្លួនឲ្យធ្លាក់ចុះ ដែលសម្រេចហើយដោយអំណាចសោតាបត្តិមគ្គ នៅត្រង់សួនលដ្ឋិវ័ន ។ បទថា អនច្ឆរិយំ សេចក្តីថា អស្ចារ្យរឿយៗ ។ កាលយើងទៅដោយករណីយកិច្ចយ៉ាងណាមួយ បានឃើញព្រះមានព្រះភាគ ក្នុងចន្លោះផ្លូវ ជាការអស្ចារ្យដែលគិតដល់រឿយៗ និងធម៌ដែលយើងបានស្តាប់ចំពោះព្រះភក្ត្ររបស់ព្រះមានព្រះភាគ ត្រាស់ក្នុងបរិស័ទរបស់មហារាជ-វេស្សវ័ណនោះ សូម្បីសេចក្តីនេះ ក៏ជាការអស្ចារ្យ ។ បទថា ទ្វេ បច្ចយា សេចក្តីថា ការឃើញក្នុងចន្លោះផ្លូវ និងការប្រាថ្នាប្រាប់ធម៌ដែលបានស្តាប់ចំពោះមុខវេស្សវ័ណមហារាជ ។ បទថា សន្និបតិតា សេចក្តីថា ប្រជុំព្រោះហេតុអ្វី ។ បានឮថា ទេវតាទាំងនោះ ប្រជុំដោយហេតុ ៤ ប្រការ គឺ

ដើម្បីសង្គ្រោះថ្ងៃវស្សូបនាយិកា ដើម្បីសង្គ្រោះថ្ងៃបវារណា ដើម្បីស្ដាប់ធម៌ ដើម្បីលេងបារិចត្តកីឡា ។ ក្នុងហេតុការណ៍ទាំងនោះ ក្នុងថ្ងៃអាសាឡ្ហបុណ្ណមី ពួក ទេវតាក្នុងទេវលោកទាំងពីរ ប្រជុំក្នុងទេវសភាឈ្មោះ **សុធម្មា** ថា ស្អែក នេះជាថ្ងៃវស្សូបនាយិកា ហើយប្រឹក្សាគ្នាថា ក្នុងវិហារឯណោះ មានភិក្ខុ ចូលវស្សាមួយរូប ក្នុងវិហារឯណោះ មានភិក្ខុចូលវស្សា ២ រូប ៣ រូប ៤ រូប ៥ រូប ១០ រូប ២០ រូប ៣០ រូប ៤០ រូប ៥០ រូប ១០០ រូប ១,០០០ រូប អ្នកទាំងឡាយ ចូរធ្វើការរក្សាអារាម ក្នុងទីនោះៗ ឲ្យល្អ ។ ការសង្គ្រោះវស្សូបនាយិកា ពួកទេវតាបានធ្វើហើយដូច្នេះ ។ សូម្បីក្នុងកាលនោះ ពួកទេវតាបានប្រជុំហើយ ដោយការណ៍នោះឯង ។ បទថា ឥធំ តេសំ ហោតិ អាសនស្មឹ សេចក្ដីថា អាសនៈនេះជារបស់មហារាជទាំងបួនប៉ុណ្ណោះ ។

[៣២] គ្រាមហារាជទាំងនោះ បានអង្គុយយ៉ាងនេះហើយ តមកខាងក្រោយ អាសនៈទើបមានដល់យើង ។ បទថា យេនត្ថេន សេចក្ដីថា ដោយប្រយោជន៍នៃវស្សូបនាយិកាណា ។ បទថា តំ អត្ថំ ចិន្តយិត្វា សេចក្ដីថា គិតការរក្សាព្រះភិក្ខុសង្ឃដែលនៅព្រៃនោះ ហើយប្រឹក្សានឹងមហារាជទាំងបួនថា អ្នកទាំងឡាយ ចូរចាត់ចែងរក្សាព្រះភិក្ខុសង្ឃអ្នកនៅ

ក្នុងព្រៃនោះៗ ។ បទថា វុត្តចនាបិ តំ សេចក្តីថា ទេវបុត្រ ៣៣ អង្គ រមែងពោលចេញឈ្មោះថា **មឃាភជ** ។ ទេវបុត្រ ៣៣ អង្គ រមែងហៅយ៉ាងនោះ ។ មឃាភជក្រៅនេះ ក៏ភយឈ្មោះបន្តបន្ទាប់ចុះមក ។ ក៏បទថា តំ សូម្បីក្នុងបទទាំងពីរត្រឹមតែជានិបាតប៉ុណ្ណោះ ។ បទថា អបក្កន្តា គឺ មិនចៀសចេញទៅ ។

[៣៣] បទថា ឧឡារោ គឺ ទូលំទូលាយ ធំ ។ បទថា ទេវានុភាវំ សេចក្តីថា ពន្លឺនៃសំពត់ គ្រឿងប្រដាប់ វិមាន និងសរីរៈរបស់ទេវតាទាំងពួង រមែងផ្សាយទៅចម្ងាយ ១២ យោជន៍ ចំណែកពន្លឺនៃសរីរៈរបស់ទេវតាអ្នកមានបុណ្យច្រើនផ្សាយទៅចម្ងាយ ១០០ យោជន៍ ឈានកន្លងនូវទេវានុភាពនោះ ។ បទថា ព្រហ្មុនោ ហេតំ បុព្វនិមិត្តំ សេចក្តីថា លោកសម្តែងថា ពន្លឺអរុណជាបុព្វង្គមៈ ជាបុព្វនិមិត្តនៃព្រះអាទិត្យឧទ័យយ៉ាងណា នោះជាបុព្វនិមិត្ត សូម្បីនៃព្រហ្មដូច្នោះដែរ ។

## ពោលអំពី ព្រហ្មឈ្មោះសនង្កុមារ

[៣៤-៣៥] បទថា អនភិសម្ភវនិយោ សេចក្តីថា មិនគប្បីដល់ ។ សេចក្តីថា ពួកទេវតាជាន់តាវត្តិង្ស រមែងមិនឃើញព្រហ្មនោះ ។ បទថា

ចក្ខុបថស្មឹ សេចក្តីថា ក្នុងចក្ខុបសាទ ឬគន្លងចក្ខុ ។ វណ្ណៈនោះ មិនគប្បីឃើញ ឬមិនគប្បីដល់ក្នុងគន្លងចក្ខុរបស់ទេវតាទាំងឡាយ ។ បទថា ឆាភិភវតិ សេចក្តីថា បានពោលហើយ ។ ពិតហើយ ទេវតាជាន់ទាបរមែងអាចឃើញអត្តភាពដែលសាងយ៉ាងបរិបូណ៌ របស់ទេវតាជាន់ខ្ពស់ៗ ។ បទថា វេឧប្បជិលាភំ សេចក្តីថា ត្រឡប់បានសេចក្តីត្រេកអរ ។ បទថា អធុនាភិសិត្តោ រជ្ជេន សេចក្តីថា ទ្រង់អភិសេកដោយសម្បត្តិ ។ ក៏អត្ថនេះ គប្បីសម្តែងរឿងទុដ្ឋគាមណីអភ័យ ។

បានឮថា ព្រះបាទទុដ្ឋគាមណីអភ័យនោះ ទ្រង់ឈ្នះក្សត្រិយ៍ទមិឡដល់ ៣២ ព្រះអង្គ ទ្រង់អភិសេកក្នុងក្រុងអនុរាធបុរី ដោយព្រះហឫទ័យសោមនស្សត្រេកអរ តែមិនបានដេកលក់ ត្រាស់ប្រាប់ភិក្ខុសង្ឃថា បពិត្រលោកម្ចាស់ តាំងពីនោះមក ខ្ញុំម្ចាស់មិនបានដេកលក់ឡើយ ។ ភិក្ខុសង្ឃទូលថា បពិត្រមហារាជ បើដូច្នោះ សូមព្រះអង្គទ្រង់អធិដ្ឋានព្រះឧបោសថ-សីលក្នុងថ្ងៃនេះ ព្រះអង្គក៏ទ្រង់អធិដ្ឋានព្រះឧបោសថសីលហើយ ។ ព្រះសង្ឃត្ថេរ ទៅប្រាប់ភិក្ខុដែលរៀនព្រះអភិធម្ម ៨ រូប ថា សូមឲ្យលោកស្វាធ្យាយចិត្តយមកៈ ។ ភិក្ខុទាំងនោះទៅហើយ ទូលថា បពិត្រមហារាជ សូមព្រះអង្គទ្រង់ផ្ទុំចុះ ហើយផ្តើមស្វាធ្យាយ ។ ព្រះរាជាទ្រង់ស្តាប់ការ

ស្វាធ្យាយ ក៏ទ្រង់ផ្ទុំលក់ទៅ ។ ព្រះថេរៈទាំងឡាយគិតថា កុំដាស់ព្រះរាជាហើយចៀសទៅ ក្នុងថ្ងៃទីពីរ ព្រះរាជាទ្រង់ភ្ញាក់ឡើង ពេលព្រះអាទិត្យឧទ័យ កាលទ្រង់មិនឃើញព្រះថេរៈ ទើបត្រាស់សួរថា លោកម្ចាស់ទៅណា ។ ទ្រង់បានទទួលពាក្យក្រាបទូលថា ព្រះថេរៈដឹងថា ព្រះអង្គទ្រង់ផ្ទុំលក់ហើយ ទើបទៅ ។ ព្រះរាជាត្រាស់ថា លោកម្ចាស់ រមែងដឹងសូម្បីភេសជ្ជៈ គឺ សេចក្ដីលក់ដរាបណា ឈ្មោះថា ភេសជ្ជៈ គឺ សេចក្ដីមិនដឹងរបស់ក្មេងទាំងឡាយ រមែងមិនមានដល់លោកម្ចាស់របស់យើងដរាបនោះ ។

បទថា បញ្ចសិខោ សេចក្ដីថា ដូចគ្នានឹងបញ្ចសិខគន្ធព្វ ។ បានឮថា ពួកទេវបុត្រទាំងអស់ បាននិម្មិតអត្តភាពរបស់បញ្ចសិខគន្ធព្វទេវបុត្រ ព្រោះហេតុនោះ សូម្បីព្រហ្មក៏បាននិម្មិតអត្តភាព ដូច្នោះ ឲ្យប្រាកដហើយដូចគ្នា ។ បទថា បល្លង្កេន និសីទិ សេចក្ដីថា អង្គុយបម្រើនសមាធិ ។

[៣៦-៣៧] បទថា វិសដ្ឋោ សេចក្ដីថា ល្អិតទន់ល្អ គឺ មិនរឹង ។ បទថា វិញ្ញេយ្យោ សេចក្ដីថា ឲ្យដឹងប្រយោជន៍ ។ បទថា មញ្ជុ គឺ ទន់ក្ងន់មូលក្ងំ ។ បទថា សវនិយោ គឺ គួរស្ដាប់ បានដល់ ពីរោះត្រចៀក ។ បទថា ពិន្ទុ សេចក្ដីថា ជុំតែមួយ ។ បទថា អវិសារី សេចក្ដីថា ល្អស្អាត

មិនបែក ។ បទថា គម្ភីរោ សេចក្តីថា ជ្រៅ កើតតាំងពីមូលនាភី ។ មិនបានកើតប៉ះខ្ទប់ត្រឹមតែអណ្តាត ធ្មេញ បបូរមាត់ ឬពិតាន ។ សេចក្តីថា សំឡេងដែលកើតត្រឹមនេះ ទើងមិនទន់ភ្លន់ និងមិនឮទៅឆ្ងាយ ។ បទថា និន្នាទី សេចក្តីថា គឹកកងដូចសំឡេង គម្រាមរបស់មហាមេឃ និងសំឡេងសម្ភោរ ។ មួយទៀត បទក្រោយៗ ក្នុងទីនេះ គប្បីជ្រាបថា ជាប្រយោជន៍របស់បទមុន ៗ ។ បទថា យថាបរិសំ សេចក្តីថា ឲ្យបរិស័ទដឹងទូទៅ ។ សំឡេងនៃព្រហ្មនោះ រមែងតាំងនៅខាងក្នុងបរិស័ទប៉ុណ្ណោះ រមែងមិនឮចេញទៅខាងក្រៅ ។

បទថា យេ ហិ កេចិ ជាដើម ប្រាប់ ដើម្បីសម្តែងការបដិបត្តិ ដើម្បីប្រយោជន៍ដល់ជនច្រើន ។ បទថា សរណំ គតា សេចក្តីថា លោកមិនពោលសំដៅអ្នកដល់សរណៈតាមមានតាមបាន តែពោលសំដៅដល់សរណៈដែលដល់មិនខុស ។ បទថា គន្ធព្វកាយំ បរិបូរេតិ សេចក្តីថា បន្ថែមគណៈនៃគន្ធព្វទេវតាឲ្យបរិបូរ ។ លោកពោលថា ទេវលោក ៦ ជាន់ ចាប់ផ្តើមតាំងពីកាលដែលព្រះសាស្តារបស់ពួកយើង បានឧប្បត្តិក្នុងលោកហើយកើតមិនមានចន្លោះ ដូចនាឡិដែលពេញបរិបូណ៌ និងដូចព្រៃសរ ព្រៃបបុស ទើបឈ្មោះថា មារិសា ។

## ពោលអំពីអានិសង្សនៃការចម្រើនឥទ្ធិបាទ

[៣៨] បទថា យាវ សុប្បញ្ញត្តាបិ មេ តេន ភគវតា សេចក្តីថា ព្រះមានព្រះភាគជាសាស្តារបស់យើង ទ្រង់បញ្ញត្តិល្អហើយ គឺ ត្រាស់ល្អហើយ ។ ក្នុងបទថា **ឥទ្ធិបាទា** នោះ គប្បីជ្រាបថា **ឥទ្ធិ** ដោយអត្ថថា សម្រេច គប្បីជ្រាបថា **បាទ** ដោយអត្ថថា ជាទីតាំង ។ បទថា ឥទ្ធិពហុលីកតាយ សេចក្តីថា ព្រោះឥទ្ធិមានគ្រប់គ្រាន់ ។ បទថា ឥទ្ធិវិសេវិតាយ សេចក្តីថា ព្រោះមានឥទ្ធិជាពិសេស លោកពោលថា ចិណ្ណវសិតាយ ដោយអំណាចសេពរឿយៗ ។ បទថា ឥទ្ធិវិកុព្វនតាយ សេចក្តីថា ព្រោះការចម្រើនឥទ្ធិរឿយៗ ដើម្បីប្រយោជន៍ដែលនឹងសម្តែងធ្វើ ដោយប្រការផ្សេងៗ ។ ក្នុងបទថា ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ជាដើម មានអត្ថដូច្នេះ ។ សមាធិដែលមានឆន្ទៈជាហេតុ ឬមានឆន្ទៈជាគោល ឈ្មោះថា ឆន្ទសមាធិ ។ ពាក្យថា **ឆន្ទសមាធិ** នោះ ជាឈ្មោះនៃសមាធិដែលបានមកព្រោះធ្វើឆន្ទៈ ដែលមានសេចក្តីប្រាថ្នានឹងធ្វើជាធំ ។ សង្ខារដែលជាបធាន ឈ្មោះថា បធានសង្ខារ ។ ពាក្យថា **បធានសង្ខារា** នោះ ជាឈ្មោះរបស់សម្មប្បធាន វីរិយៈដែលញុំាងកិច្ច ៤ ប្រការឲ្យសម្រេច ។ បទថា សមន្នាគតំ សេចក្តីថា ចូលដល់ហើយដោយឆន្ទសមាធិ និងបធានសង្ខារ ។

បទថា **ឥទ្ធិបាទំ** សេចក្ដីថា កងនៃចិត្តដ៏សេស ឬចេតសិកជាបាទ ដោយអត្ថថា តាំងមាំនៃឆន្ទសមាធិ និងបធានសង្ខារ ដែលប្រកបព្រមដោយអភិញ្ញាចិត្ត ដែលរាប់ថា **ឥទ្ធិ** ដោយបរិយាយថា សម្រេច ឬដោយបរិយាយនេះថា ជាហេតុឲ្យសត្វទាំងឡាយសម្រេច ដោយអត្ថថា **សម្រេច** គឺជាអ្នកសម្រេចហើយ បរិបូរណ៍ហើយ ដល់ទីបំផុតហើយ ។ ព្រោះពាក្យថា **ឥទ្ធិបាទ** លោកពោលថា វេទនាខន្ធនៃសេចក្ដីពិតណា ។ល។ វិញ្ញាណក្ខន្ធ ។ គប្បីជ្រាបអត្ថ សូម្បីក្នុងបទដ៏សេសដោយន័យនេះ ។ ព្រោះសមាធិដែលធ្វើឆន្ទៈជាធំ ទើបបានមក លោកហៅថា **ឆន្ទសមាធិ** យ៉ាងណា សមាធិដែលធ្វើវីរិយ ចិត្ត វិមំសា ជាធំបានមក ហៅថា **វិមំសាសមាធិ** ដូច្នោះ ។

មួយទៀត គប្បីជ្រាបអត្ថក្នុងពាក្យនេះថា **បាទ** ក្នុងចំណែកខាងដើមថា ឧបចារឈានជាបាទ បឋមឈានជាឥទ្ធិ បឋមឈានជាបាទ ទុតិយជ្ឈានជាឥទ្ធិ ជាឥទ្ធិក្នុងចំណែកចុង ។ ក៏ឥទ្ធិបាទកថា លោកពោលទុកហើយក្នុងវិសុទ្ធិមគ្គ និងក្នុងវិភង្គអដ្ឋកថា ដោយពិស្ដារ ។ តែកេចិអាចារ្យពោលថា ឥទ្ធិដែលសម្រេចហើយ ជាឥទ្ធិដែលនៅមិនសម្រេច ។ ដើម្បីប្រយោជន៍នៃការនិយាយដល់វាទៈនៃកេចិអាចារ្យពួកនោះ ឈ្មោះថា **ឧត្តរចូឡិកវារ** មកហើយក្នុងអភិធម្មថា ឥទ្ធិបាទ ៤ គឺ ឆន្ទិទ្ធិបាទ វីរិយិទ្ធិ-

បាទ ចិត្តិទ្ធិបាទ វិមំសិទ្ធិបាទ ក្នុងឥទ្ធិបាទទាំង ៤ នោះ ឆន្ទិទ្ធិបាទ ដូចម្តេច ? ភិក្ខុក្នុងសាសនានេះ ក្នុងសម័យណាចម្រើនលោកុត្តរឈាន ដែលជាគ្រឿងចេញចាកទុក្ខ ដែលជាអបចយគាមី ដើម្បីលះទិដ្ឋិ ដើម្បីសម្រេចបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ល។ ចូលដល់បឋមឈាន ដែលជាទុក្ខាបដិបទា ទន្ធាភិញ្ញា ក្នុងសម័យនោះ ធម្មឆន្ទៈណា ឈ្មោះថា ឆន្ទៈ ព្រោះបានធ្វើឆន្ទៈហើយ ឈ្មោះថា កុសល ព្រោះប្រាថ្នានឹងធ្វើ នេះហៅថា **ឆន្ទិទ្ធិបាទ** ធម៌ដ៏សេសសម្បយុត្តដោយឆន្ទិទ្ធិបាទ ។ ក៏ធម៌ទាំងនេះ មកហើយដោយអំណាចនៃលោកុត្តរៈ ។

ក្នុងទីនេះ ព្រះរដ្ឋបាលត្រូវធ្វើឆន្ទៈឲ្យជាធុរៈ ញុំាងលោកុត្តរធម៌ឲ្យកើតឡើង ព្រះសោណត្រូវធ្វើវីរិយៈឲ្យជាធុរៈ ព្រះសម្ភូតត្រូវធ្វើចិត្តឲ្យជាធុរៈ ព្រះមោឃរាជដ៏មានអាយុធ្វើវិមំសាឲ្យជាធុរៈ ញុំាងលោកុត្តរធម៌ឲ្យកើតឡើង ។ ក្នុងសេចក្តីនេះ ឧបមាដូចបុត្រអាមាត្រទាំង ៤ នាក់ ប្រាថ្នាឋានន្តរៈ ចូលទៅអាស្រ័យព្រះរាជា ម្នាក់កើតសេចក្តីពេញចិត្តក្នុងការទំនុកបម្រុង ដឹងអធ្យាស្រ័យ និងសេចក្តីពេញព្រះទ័យរបស់ព្រះរាជា ចាំបម្រើទាំងពេលថ្ងៃ និងពេលយប់ ញុំាងព្រះរាជាឲ្យពេញព្រះរាជហឫទ័យ ហើយបានឋានន្តរៈ យ៉ាងណា គប្បីជ្រាបភិក្ខុដែលញុំាងលោកុត្តរធម៌ឲ្យកើត

ឡើង ដោយឆន្ទធុរៈ ដូច្នោះ ។ ចំណែកម្នាក់ទៀត គិតថា នរណានឹងអាច ដើម្បីទំនុកបម្រុងរាល់ៗ ថ្ងៃបាន កាលកិច្ចការកើតឡើង យើងនឹងញ៉ាំង ព្រះរាជាឲ្យពេញព្រះទ័យ ដោយសេចក្តីព្យាយាម កាលបច្ចន្តជនបទកើត ចលាចល ត្រូវព្រះរាជាបញ្ជូនទៅបង្ក្រាបសត្រូវដោយសេចក្តីព្យាយាម បាន នូវឋានន្តរៈ យ៉ាងណា ភិក្ខុនោះ ឲ្យលោកុត្តរធម៌កើតឡើងដោយវីរិយ-ធុរៈ គប្បីជ្រាបដូច្នោះ ។ ម្នាក់ទៀតគិតថា សូម្បីការបទំនុកម្រុងរាល់ថ្ងៃៗ ជាភារៈធ្ងន់ ដូចកូនសរមុតត្រូវទ្រូង យើងនឹងញ៉ាំងព្រះរាជាឲ្យពេញព្រះទ័យ ដោយអំណាចមន្ត ទើបញ៉ាំងព្រះរាជាឲ្យពេញព្រះហឫទ័យ ដោយការរាយ មន្ត ព្រោះវិជ្ជាភូមិសាស្រ្តបានសិក្សាមកហើយ ក៏ដល់ឋានន្តរៈ យ៉ាងណា ភិក្ខុនោះ អ្នកញ៉ាំងលោកុត្តរធម៌ឲ្យកើតឡើងដោយចិត្តធុរៈ គប្បីជ្រាប ដូច្នោះ ។ បុត្រអាមាត្យម្នាក់ទៀតគិតថា ឈ្មោះថា ព្រះរាជា រមែងព្រះ-រាជទានឋានន្តរៈ ដល់អ្នកដែលដល់ព្រមដោយជាតិ ដោយការទំនុកបម្រុង ជាដើម ទាំងនេះ កាលទ្រង់ព្រះរាជាទានដល់បុគ្គល បែបនោះ ៗ ក៏ទ្រង់ ព្រះរាជទានដល់យើង អាស្រ័យជាតិសម្បទាតែម្យ៉ាង ក៏ដល់នូវឋានន្តរៈ យ៉ាងណា ភិក្ខុនោះ អាស្រ័យវិមំសាដ៏បរិសុទ្ធិ ញ៉ាំងលោកុត្តរធម៌កើត ឡើង ដោយវិមំសាធុរៈ គប្បីជ្រាបដូច្នោះ ។

បទថា អនេកវិហិតំ សេចក្ដីថា វិធីមិនមែនមួយ ។ បទថា ឥទ្ធិវិធំ សេចក្ដីថា ចំណែករបស់ឥទ្ធិ ។

[៣៩] បទថា សុខស្សាធិគមាយ សេចក្ដីថា ដើម្បីសម្រេចដល់ឈានសុខ មគ្គសុខ និងផលសុខ ។

[៤០] បទថា សំសដ្ឋា សេចក្ដីថា ចិត្តសម្បយុត្ត ។ បទថា អរិយធម្មំ សេចក្ដីថា ធម៌ដែលព្រះអរិយៈ ព្រះមានព្រះភាគ គឺ ព្រះពុទ្ធទ្រង់សម្ដែងហើយ ។ បទថា សុណាតិ សេចក្ដីថា ធម៌ដែលភិក្ខុ និងភិក្ខុនីជាដើម សម្ដែងចំពោះព្រះភក្ត្រព្រះសាស្ដា ឈ្មោះថា ស្ដាប់ហើយ ។ បទថា យោនិសោមនសិករោតិ សេចក្ដីថា ធ្វើទុកក្នុងចិត្តដោយឧបាយ ដោយគន្លង ដោយហេតុការណ៍ ដោយអំណាចជាដើមថា មិនទៀង ។ អធិប្បាយថា ភិក្ខុប្រារព្ធកម្ម ដោយការធ្វើទុកក្នុងចិត្តដោយប្រពៃ ដែលលោកពោលយ៉ាងនេះថា ឈ្មោះថា យោនិសោមនសិការ គឺ ការធ្វើទុកក្នុងចិត្តដោយឧបាយ ការធ្វើទុកក្នុងចិត្តដោយគន្លង ឬការរឭក ការចងការប្រុងប្រមនៃចិត្ត ការធ្វើទុកក្នុងចិត្ត ដោយអនុលោមសច្ចៈ ក្នុងសភាពមិនទៀង ថាមិនទៀង ក្នុងសភាពមិនស្អាត ថាមិនស្អាត ក្នុងទុក្ខ ថាទុក្ខ ក្នុងភាពជាអនត្តា ថាជាអនត្តា នេះហៅថា **យោនិសោមនសិការ** ។ បទថា

អសំសដ្ឋោ សេចក្តីថា មិនស្និទស្នាលជាមួយនឹងវត្ថុកាមខ្លះ កិលេសកាមខ្លះ ។ បទថា ឧប្បជ្ជតិ សុខំ សេចក្តីថា បឋមជ្ឈានសុខរមែងកើតឡើង ។ បទថា សុខា ភិយ្យោ សោមនស្សំ សេចក្តីថា សោមនស្សដទៃៗ ព្រោះឈានសុខជាបច្ច័យ រមែងកើតឡើងដល់អ្នកចេញចាកសមាបត្តិ ។ បទថា បមុទា គឺ បីតិ ដែលមានកម្លាំងតិចជាងអាការរបស់តុដ្ឋិ ។ ពាក្យថា ចាមោជ្ជំ គឺ បីតិ និងសោមនស្សមានកម្លាំង ។ បទថា បឋមោ ឱកាសាធិគមោ សេចក្តីថា បឋមជ្ឈាន គ្របសង្កត់នីវរណៈ ៥ កាន់យក ឱកាសរបស់ខ្លួនហើយ តាំងនៅ ព្រោះដូច្នោះ លោកទើបពោលថា បឋមោ ឱកា-សាធិគមោ ( ការសម្រេចឱកាសគ្រាដំបូង ) ។

## ពោលអំពី ការបានឆ្លូវឱកាសទី ៣

[៤១] ក្នុងបទថា ឱឡារិកា នោះ កាយសង្ខារ និងវចីសង្ខារនៅគ្រោតគ្រាត ចិត្តសសង្ខារ នឹងគ្រោតគ្រាតយ៉ាងណា ។ ព្រោះចិត្តសង្ខារមិនទាន់លះ ។ ក៏កាយសង្ខារ រមែងលះដោយចតុត្ថជ្ឈាន ។ វចីសង្ខារលះដោយទុតិយជ្ឈាន ។ ចិត្តសង្ខារ លះដោយនិរោធសមាបត្តិ ។ គ្រាកាយសង្ខារ និងវចីសង្ខារសូម្បីលះហើយ ចិត្តសង្ខារទាំងឡាយនោះ ក៏

តាំងនៅដោយប្រការដូច្នេះ ទើបជាឱឡារិកៈ ព្រោះលះមិនទាន់បាន ដោយប្រកាន់កាយសង្ខារ វចីសង្ខារ ដែលលះបានហើយ ។ បទថា សុខំ សេចក្តីថា ផលសមាបត្តិសុខ ដែលកើតពីចតុត្ថជ្ឈាន ដែលកើតដល់អ្នកចេញចាកនិរោធ ។ បទថា សុខា ភិយ្យោ សោមនស្សំ សេចក្តីថា សោមនស្សដទៃៗ មានដល់អ្នកចេញហើយអំពីផលសមាបត្តិ ។ បទថា ឧត្តិយោ ឱកាសាធិគមោ សេចក្តីថា ចតុត្ថជ្ឈានគ្របសង្កត់សុខទុក្ខ កាន់យកឱកាសខ្លួនហើយតាំងនៅ ព្រោះដូច្នោះ ទើបលោកពោលថា ឧត្តិយោ ឱកាសាធិ-គមោ ។ ចំណែកទុតិយជ្ឈាន និងតតិយជ្ឈាន លោកកាន់យកហើយក្នុងចតុត្ថជ្ឈាននោះ ព្រោះដូច្នោះ ទើបលោកមិនពោលឲ្យផ្សេងទៀត ។

## ពោលអំពី ការចាបនូវឱកាសទី ២-៣

[៤២] ក្នុងបទថា ឥធំ កុសលំ ជាដើម មានអត្ថាធិប្បាយ ដូច្នេះ ។ កុសលកម្មបថ ១០ ឈ្មោះថា កុសល ។ បទថា អកុសលំ បានដល់អកុសលកម្មបថ ១០ ។ សូម្បីគ្រប់សាវជ្ជៈជាដើម គប្បីជ្រាបដោយអំណាចនៃអកុសលកម្មបថទាំង ១០ នោះឯង ។ ក៏កម្មទាំងអស់នោះឯង ជាកណ្ហៈ សុក្កៈ និងសប្បដិភាគ ទើបឈ្មោះថា កណ្ហសុក្កសប្បដិភាគំ ។

ក៏និព្វានប៉ុណ្ណោះ **ជាអប្បដិភាគ** ។ បទថា អវិជ្ជា បហិយតិ សេចក្ដីថា អវិជ្ជា ដែលបិទបាំងវដ្ដៈ រមែងលះបាន ។ បទថា វិជ្ជា ឧប្បជ្ជតិ សេចក្ដីថា អរហត្តមគ្គវិជ្ជា រមែងកើតឡើង ។ បទថា សុខំ គឺ សុខដែលកើតពីអរហត្តមគ្គ និងផល ។ បទថា សុខា ភិយ្យោ សោមនស្សំ សេចក្ដីថា សោមនស្សដទៃៗ របស់ដែលអ្នកចេញចាកអំពីសមាបត្តិហើយ ។ បទថា តតិយោ ឱកាសាធិគមោ សេចក្ដីថា អរហត្តមគ្គ គ្របសង្កត់កិលេសទាំងអស់ កាន់យកឱកាសខ្លួនហើយតាំងនៅ ព្រោះដូច្នោះ ទើបលោកពោលថា តតិយោ ឱកាសធិគមោ ។ ចំណែកមគ្គដ៏សេស កាលអរហត្តមគ្គកាន់យកហើយ ក៏ប្រមូលចូលគ្នាបាន ទើបមិនពោលឲ្យផ្សេងគ្នា ។

ចំណែកឱកាសាធិគមៈ ៣ ប្រការនេះ គប្បីពោលយ៉ាងពិស្ដារដោយអំណាចអារម្មណ៍ ៣៨ ប្រការ ។ ដូចម្ដេច ។ លោកកំណត់អារម្មណ៍ទាំងអស់ដោយអំណាចឧបចារៈ និងអប្បនា ដោយន័យដែលពោលហើយក្នុងវិសុទ្ធិមគ្គនោះឯង ពោលដល់បឋមជ្ឈានក្នុងឋានៈ ២៤ ប្រការ ថា បឋមោ ឱកាសាធិគមោ ។ លោកកំណត់ទុតិយជ្ឈាន និងតតិយជ្ឈានក្នុងឋានៈ ១៣ ប្រការ និងចតុត្ថជ្ឈាន ក្នុងឋានៈ ១៥ ប្រការ ឲ្យដល់និរោធសមាបត្តិពោលថា ទុតិយោ ឱកាសាធិគមោ ។ ចំណែកឧបចារ-

ជ្ឈាន ១០ ប្រការ ជាបទដ្ឋាននៃមគ្គ រួមចូលនឹងឱកាសាធិគមទី ៣ ។ ម្យ៉ាងទៀត គប្បីពោលសូម្បីដោយអំណាចសិក្ខាយ៉ាងនេះ ក្នុងសិក្ខា ៣ ប្រការ អធិសីលសិក្ខា រួមចូលជាមួយបឋមឱកាសាធិគមៈ , អធិចិត្តសិក្ខា រួមចូលជាមួយទុតិយឱកាសាធិគមៈ , អធិប្បញ្ញាសិក្ខា រួមចូលជាមួយតតិយឱកាសាធិគមៈ ។ សូម្បីក្នុងសាមញ្ញផល លោកពោលដោយអំណាចនៃសាមញ្ញផលសូត្រ យ៉ាងនេះថា តាំងពីចូឡសីល ដរាបដល់បឋមជ្ឈាន ជាឱកាសាធិគមៈទី ១ , តាំងពីទុតិយជ្ឈាន ដរាបដល់នេវ-សញ្ញានាសញ្ញាយតនៈ ជាឱកាសាធិគមៈទី ២ , តាំងពីវិបស្សនា ដរាបដល់អរហត្ត ជាឱកាសាធិគមៈទី ៣ ។ ចំណែកក្នុងបិដក ៣ ប្រការ គប្បីពោលសូម្បីដោយអំណាចបិដកយ៉ាងនេះថា វិន័យបិដក រួមចូលជាមួយបឋមឱកាសាធិគមៈ , សុត្តន្តបិដក រួមចូលជាមួយទុតិយឱកាសា-ធិគមៈ , អភិធម្មបិដក រួមចូលជាមួយតតិយឱកាសាធិគមៈ ។

បានឮថា ព្រះមហាថេរៈក្នុងកាលមុន រមែងតាំងព្រះសូត្រនេះប៉ុណ្ណោះក្នុងថ្ងៃវស្សូបនាយិកា ។ ព្រោះហេតុអ្វី ។ ព្រោះពួកយើងនឹងចែកបិដក ៣ ហើយពោល ។ ព្រោះកាលរួមព្រះត្រៃបិដក ហើយពោល ព្រះសូត្រក៏ពោលបានលំបាក ព្រោះដូច្នោះ នរណាៗ ក៏មិនអាចពោលបាន ។ សូត្រនេះ

ដែលចែកព្រះត្រៃបិដក ហើយពោល ក៏នឹងពោលបាននាយ ។

## ពោលអំពី សតិប្បដ្ឋាន ៤

[៤៣] បទថា កុសលស្សាធិគមាយ សេចក្តីថា ដើម្បីប្រយោជន៍សម្រេចមគ្គកុសល និងផលកុសល ។ ពិតហើយ ទាំងពីរយ៉ាងនោះឈ្មោះថា ជាកុសល ដោយអត្ថថា មិនមានទោស ឬដោយអត្ថថា ក្សេម ។ បទថា តត្ថ សម្មា សមាធិយតិ សេចក្តីថា ភិក្ខុតាំងមាំដោយប្រពៃក្នុងកាយខាងក្នុងនោះ ក៏នឹងជាឯកគ្គតាចិត្ត ។ បទថា ពហិទ្ធា បរកាយេ ញាណ–ទស្សនំ អភិនិព្វត្តេតិ សេចក្តីថា បញ្ជូនញាណចំពោះកាយបុគ្គលដទៃក្រៅអំពីកាយខ្លួន ។ ក្នុងបទទាំងពួងក៏មានន័យនេះ ។ គប្បីជ្រាប សតិដែលកំណត់កាយជាដើម ដោយបទថា សតិមា ក្នុងបទទាំងពួង ។ គប្បីជ្រាបថា កាយជាដើម ដែលកំណត់ហើយ ដោយបទថា **លោកេ** ក៏សតិប្បដ្ឋាន ៤ នោះ គប្បីជ្រាបថា លោកពោលលាយដោយលោកិយៈនិងលោកុត្តរៈ ។

## ពោលអំពី ធម្មគុណ

[៤៤-៤៥] បរិក្ខារ ក្នុងបទនេះថា សមាធិបរិក្ខារា មាន ៣ យ៉ាង ។

គ្រឿងប្រដាប់ក្នុងបទនេះថា រថមានសីលជាគ្រឿងពាស មានឈានជាភ្លៅ មានវីរិយៈជាកង់ ឈ្មោះថា **បរិក្ខារ** ។ **បរិវារ** ក្នុងបទនេះថា ចោមរោម ល្អហើយដោយនគរបរិក្ខារ ៧ ប្រការ ឈ្មោះថា **បរិក្ខារ** ។ **សម្ភារៈ** ក្នុងបទនេះថា គិលានបច្ចយជីវិតបរិក្ខារា ឈ្មោះថា **បរិក្ខារ** ។ ក៏ក្នុងទីនេះ លោកពោលថា សមាធិបរិក្ខារ ៧ ប្រការ ដោយអំណាចបរិវារ និង បរិក្ខារ ។ បរិវារិក ឈ្មោះថា បរិក្ខារ ។ បទថា អយំ វុច្ចតិ ភោ អរិយោ សម្មាសមាធិ សេចក្តីថា នេះហៅថា សម្មាសមាធិដ៏ប្រសើរ ដែលចោម រោមដោយអង្គ ៧ ដូចចក្រពត្តិចោមរោមដោយរតនៈ ៧ ប្រការ ដូច្នោះ ។ បទថា សឧបនិសោ ឥតិបិ សេចក្តីថា លោកហៅថា សឧបនិស្ស័យ សូម្បីដោយប្រការនេះ ។ បទថា សបរិវារោ យេវ បានពោលហើយ ។ បទថា សម្មាទិដ្ឋិស្ស សេចក្តីថា អ្នកតាំងនៅក្នុងសម្មាទិដ្ឋិ ។ បទថា សម្មាសង្កប្បោ បហោតិ សេចក្តីថា សម្មាសង្កប្បៈ រមែងប្រព្រឹត្តទៅ ។ ក្នុងបទទាំងពួងក៏មានន័យដូចគ្នា ។

ក៏អត្ថនេះ គប្បីជ្រាបដោយអំណាចមគ្គខ្លះ ដោយអំណាចផលខ្លះ ។ យ៉ាងណា ។ មគ្គសម្មាសង្កប្បៈ រមែងមានដល់កិច្ចដែលតាំងនៅក្នុងមគ្គ សម្មាទិដ្ឋិ ។ល។ និងមគ្គវិមុត្តិ រមែងមានដល់កិច្ចដែលតាំងនៅក្នុងមគ្គ-

ញ្ញាណ ម្យ៉ាងទៀត ផលសម្មាសង្កប្បៈ រមែងមានដល់ភិក្ខុដែលតាំងនៅក្នុងផលសម្មាទិដ្ឋិ ។បេ។ និងផលវិមុត្តិ រមែងមានដល់ភិក្ខុដែលតាំងនៅក្នុងផលសម្មាញាណ ។ បទថា ស្វាក្ខាតោ ជាដើម លោកពណ៌នាហើយក្នុងវិសុទ្ធិមគ្គ ។ បទថា អបារុតា សេចក្ដីថា បើកហើយ ។ បទថា អមតស្ស សេចក្ដីថា និព្វាន ។ បទថា ទ្វារា សេចក្ដីថា ផ្លូវចូល ។ បទថា អវេច្ចប្បសាទេន សេចក្ដីថា សេចក្ដីជ្រះថ្លាមិនកម្រើក ។ បទថា ធម្មេ វិនីតា សេចក្ដីថា ពិតប្រាកដហើយដោយធម្មនិយាម ។ បទថា អថាយំ ឥតរា បជា សេចក្ដីថា លោកពោលសំដៅដល់ព្រះអនាគាមី ។ បទថា អនាគាមិនោ អត្ថិ លោកពោលហើយ ។ បទថា បុញ្ញភាគា សេចក្ដីថា កើតហើយដោយចំណែកនៃបុណ្យ ។ បទថា ឱត្តប្បំ សេចក្ដីថា មានចិត្តខ្មាចក្រែង ។ បើដូច្នោះ **មុសា** គប្បីមានក្នុងកាលណា ព្រោះដូច្នោះយើងមិនអាចរាប់ដោយភ័យមុសាវាទបាន តែមិនបានសម្ដែងថា កម្លាំងរាប់របស់យើងមិនមាន ។ សនង្កុមារព្រហ្ម សាកសួរវេស្សវណ ដោយបទនេះថា តំ កឹ មញ្ញតិ ភវំ ។ តែសនង្កុមារព្រហ្មនោះ មិនមានលទ្ធិថា ព្រះសាស្ដាដូចនោះ មិនមាន ឬនឹងមិនមាន ។ ពិតហើយ ក្នុងអភិសម័យរបស់ព្រះពុទ្ធទាំងឡាយ មិនមានពិសេស ។

## ពោលអំពីការដំណាលប្រាប់គ្នា ៗ គ្នា

[៤៦] *បទថា សយំបរិសាយ សេចក្តីថា ក្នុងបរិស័ទរបស់ខ្លួន ។*

*បទថា តយិទំ ព្រហ្មចរិយំ សេចក្តីថា ត្រៃសិក្ខាទាំងអស់នេះ គឺព្រហ្មចារ្យ ។ បទដ៏សេសឯទៀតទាំងអស់ ។ ចំណែកបទទាំងនេះ ដែលព្រះធម្មសង្គាហកត្ថេរទាំងឡាយ បានតាំងទុកហើយ ដូច្នេះ ។*

" ចប់អដ្ឋកថា ជនវសភសូត្រ ទី៥ "

# អដ្ឋកថា មហាគោវិន្ទសូត្រ ទី ៦

## មហារាជទាំង ៤

[៤៧] មហាគោវិន្ទសូត្រ មានពាក្យផ្ដើមថា ។ តទៅនេះជាពាក្យពណ៌នា បទដែលនៅមិនងាយយល់ក្នុងមហាគោវិន្ទសូត្រនោះ ។ ពាក្យថា បញ្ចសិខ សេចក្ដីថា មានជុក ៥ គឺ មានសក់ ៥ កញ្ចុំ ។ ដំណាលមកថា បញ្ចសិខៈ បុត្តគន្ធព្វនោះ ក្នុងវេលាធ្វើកម្មដែលជាបុណ្យ ក្នុងអត្តភាពជាជាមនុស្សកម្លោះ ។ ក្នុងកាលនៅក្មេងទុកជុក ៥ កញ្ចុំ ជាប្រធានចិញ្ចឹមគោ នាំពួកក្មេងៗ ពួកដទៃ នាំគ្នាធ្វើសាលាក្នុងទីដែលមានផ្លូវបែកជាបួន ជីកស្រះឈូក ធ្វើស្ពាន ពង្រាបផ្លូវរដិបរដុបឲ្យរាប ជញ្ជូនឈើមកធ្វើក្ដៅ និងឈើសឹកក្លៅរបស់យានទាំងឡាយ តែងតែធ្វើបុណ្យបែបនេះ ដូចដែលពោលមកហើយ ក៏ស្លាប់ទាំងដែលនៅជាកម្លោះ ។ រាងកាយរបស់គេនោះ ជារាងកាយដែលគួរស្រឡាញ់ គួរប្រាថ្នា គួរពេញចិត្ត ។ កាលគេស្លាប់ហើយ ក៏ទៅកើតក្នុងទេវលោកជាន់ចាតុម្មហារាជិកា មានអាយុ ៩ លានឆ្នាំ ។ រាងកាយរបស់គេដូចជាកងមាស មានទំហំបីគាវុត ។ គេប្រដាប់ គ្រឿងប្រដាប់ប្រមាណ ៦០ រទេះ ប្រោះព្រំរបស់ក្រអូបប្រមាណ

៩ ឆ្នាំង ស្លៀកដណ្តប់សម្ពត់ទិព្វពណ៌ក្រហម ប្រដាប់ផ្កាកណ្ណិកាមាស ក្រហម មាន ៥ កញ្ចុំ បណ្តានទៅខាងក្រោយ ត្រាច់ទៅទំនងដូចក្មេង ៥ ជុកនោះឯង ។ ពួកទេវតាទើបជ្រាបទូលថា បញ្ចសិខៈ ដូច្នេះឯង ។

បទថា **កាលរាត្រីកន្លងទៅហើយ** គឺ រាត្រីឈានកន្លងទៅហើយ គឺ អស់ទៅហើយ ។ មានន័យថា កន្លងទៅហើយដោយចំណែកមួយ ។ ពាក្យថា **មានរស្មីល្អស្អាតក្រៃលែង** គឺ មានរស្មី គួរស្រឡាញ់ គួរប្រាថ្នា គួរពេញចិត្តយ៉ាងក្រៃលែង ។ សូម្បីដោយប្រក្រតី ទេវបុត្រនោះ ក៏មាន រស្មី ( ពណ៌សម្បុរ ) គួរប្រាថ្នា តែកាលបើតុបតែងហើយ ក៏ក្រៃលែង ជាងអ្នកមានពណ៌សម្បុរ គួរប្រាថ្នាក្រៃលែងថែមទៀត ។ ពាក្យថា **ជាទូទៅ ដល់** គឺ ដោយជុំវិញមិនមានសល់ ។ **កេវល** សព្ទ ក្នុងទីនេះ ប្រែថា មិនមានសល់ ដូចក្នុងពាក្យនេះថា បរិបូណ៌ដោយអស់ជើង ។ **កប្ប** សព្ទ ប្រែថា ដោយជុំវិញ ដូចក្នុងពាក្យនេះថា ញុំាងព្រះជេតពនដោយជុំវិញ យ៉ាងអស់ជើង ។ ពាក្យថា **បំភ្លឺឲ្យភ្លឺ** គឺ ផ្សាយទៅដោយពន្លឺ ។ មាន ន័យថា ធ្វើឲ្យជាពន្លឺតែម្យ៉ាង ឲ្យជាប្រទីបតែមួយ ដូចព្រះចន្ទ និងព្រះ អាទិត្យ ។

ពាក្យថា ទីសុធម្មាសភា គឺ សភាដែលកើត ព្រោះផលនៃដើម

កណ្ណិកាដែលជំទន់ ៗ នឹងកែវរបស់ស្ត្រីឈ្មោះ សុធម្មា ។ ដូចបានឮមកថា ផ្ទៃដីរបស់សុធម្មាសភានោះ សម្រេចដោយកែវផលឹក ស្នៀតគន្លឹះទ្វារយកកែវមណីមកធ្វើ សសរសម្រេចដោយមាស វត្ថុភ្ជាប់សសរ និងកុណ្ឌីធ្វើអំពីប្រាក់ រូបសត្វកាចយកកែវប្រវាឡមកធ្វើ បន្ទន់ ពិតាន និងស៊ុមបន្ថួចយកកែវ ៧ ប្រភេទ មកសាង ក្បៀងប្រើជុំឥដ្ឋពណ៌កែវឥន្ទនិល ដំបូលយកមាសមកធ្វើ ដោម (កំពូលប្រាសាទ) ធ្វើដោយប្រាក់ ផ្ទៃកបណ្តោយ និងផ្ទៃកទទឹង ម្ខាង ៣០០ យោជន៍ ដោយបរិវេណជុំវិញក្នុង ៩០០ យោជន៍ ដោយចំណែកខ្ពស់ ៥០០ យោជន៍ ។ សុធម្មាសភា មានសភាពបែបនេះ ។

ក្នុងបទជាដើមថា ***ស្តេចធតរដ្ឋ*** គប្បីជ្រាបថា ស្តេចធតរដ្ឋ ជារាជានៃគន្ធព្វ ដែលមានពួកទេវតាអ្នកបម្រើមួយសែនកោដិហែហមហើយ ឲ្យកាន់យកបន្ទះក្តាធំ ដែលធ្វើដោយមាសមួយសែនកោដិ និងលំពែងមាស ហើយបែរព្រះភក្ត្រទៅទិសខាងលិច យកពួកទេវតាក្នុងទេវលោកទាំងពីរទុកខាងមុខ ហើយប្រថាប់អង្គុយផ្ទៃកទិសខាងកើត ។

***ស្តេចវិរូឡ្ហក*** ជារាជានៃកុម្ភណ្ឌ ដែលមានពួកទេវតាពួកកុម្ភណ្ឌមួយសែនកោដិហែហមហើយ ឲ្យកាន់យកបន្ទះក្តាធំ ដែលធ្វើដោយប្រាក់

មួយសែនកោដិ និងលំពែងមាស ហើយបែរព្រះភ័ក្ត្រទៅទិសខាងជើង យកពួកទេវតាក្នុងទេវលោកទាំងពីរទុកខាងមុខ ហើយប្រថាប់អង្គុយផ្ទែកទិសខាងត្បូង ។

**ស្តេចវិរូបក្ខ** ជាកជាំនៃនាគ មានពួកនាគមួយសែនកោដិហែហមឲ្យកាន់ យកបន្ទះក្តាធំ សម្រេចដោយមណីសែនកោដិ និងលំពែងមាស ហើយបែរព្រះភ័ក្ត្រទៅទិសខាងកើត យកពួកទេវតាក្នុងទេវលោកទាំងពីរទុកខាងមុខ ហើយប្រថាប់អង្គុយផ្ទែកទិសខាងលិច ។

**ស្តេចវេស្សវណ** ជាកជាំនៃយក្ខ មានពួកយក្ខមួយសែនកោដិហែ-ហម ឲ្យកាន់យកបន្ទះក្តាធំ ដែលធ្វើដោយកែវប្រវាឡមួយសែនកោដិ និងលំពែងមាស បែរព្រះភ័ក្ត្រទៅទិសខាងត្បូង យកពួកទេវតាក្នុងទេវលោកទាំងពីរទុកខាងមុខ ហើយប្រថាប់អង្គុយផ្ទែកទិសខាងជើង ។

បទថា **និងខាងក្រោយជាអាសនៈរបស់ពួកយើង** គឺ ឱកាសសម្រាប់អង្គុយរបស់ពួកយើង រមែងដល់ផ្ទែកខាងក្រោយរបស់លោកទាំង ៤ អង្គនោះ តពីនោះ ពួកយើងនឹងចូលក៏មិនបាន ឬនឹងមើលក៏មិនបាន ។

ក្នុងករណីនេះ លោកពោលហេតុការប្រជុំគ្នា ៤ យ៉ាងទុកមុន ។ ក្នុងហេតុទាំង ៤ យ៉ាងនោះ ការប្រមូលចុះក្នុងថ្ងៃចូលវស្សា លោកអធិប្បាយ

ទុកឲ្យធំទូលាយហើយ ។ ពិតហើយ ហេតុក្នុងថ្ងៃចូលវស្សា យ៉ាងណា ភិក្ខុទាំងឡាយប្រជុំគ្នាក្នុងថ្ងៃពេញបូណ៌មី ក្នុងថ្ងៃមហាបវារណា ប្រឹក្សាគ្នាថា ថ្ងៃនេះពួកយើងនឹងទៅណា ហើយបវារណាក្នុងសម្នាក់អ្នកណា ដូច្នោះ ។ ក្នុងទីប្រជុំនោះ ស្តេចសក្កៈជាធំលើពួកទេវតា ដោយច្រើន ទ្រង់នឹងបវារណា ក្នុងបិយង្គុទីបព្រះមហាវិហារនុ៎ះឯង ។ ពួកទេវតាដ៏សេស ក៏កាន់យក ផ្កាឈើទិព្វ ដូចជាផ្កាបារិឆត្តជាដើម និងលំអិតចន្ទន៍ទិព្វ ហើយទៅកាន់ ដែលពេញចិត្តរៀងៗ ខ្លួន ហើយបវារណាគ្នា ។ បែបនេះឈ្មោះថា រមែង ប្រជុំគ្នា ដើម្បីប្រយោជន៍ដល់ការសង្គ្រោះបវារណា ។

ក៏ក្នុងទេវលោក មានវល្លិ៍ឈ្មោះ អាសាវតី ។ ពួកទេវតាគិតថា វល្លិ៍នោះនឹងចេញផ្កា ទើបទៅកាន់ទីនោះ រក្សារហូតដល់អស់ពាន់ឆ្នាំ កាល ដើមបារិច្ឆត្តកំពុងចេញផ្កា ពួកទេវតាទៅកាន់ទីនោះ រក្សារហូតដល់អស់ មួយឆ្នាំ ។ ទេវតាទាំងនោះ នាំគ្នាសប្បាយចិត្ត តាំងពីដើមឈើនោះមាន ស្លឹកលឿងជាដើមទៅ ។ ដូចដែលព្រះមានព្រះភាគ ត្រាស់ថា ម្នាលភិក្ខុ ទាំងឡាយ ក្នុងសម័យណា ដើមរលួសផ្អុងជាបារិច្ឆត្តកព្រឹក្ស របស់ពួក ទេវតាជាន់តាវត្តិង្ស មានស្លឹកលឿង ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ ពួកទេវតាជាន់តាវត្តិង្ស ក៏នាំគ្នាត្រេកអរថា ឥឡូវនេះ ដើមរលួសផ្អុង

ជាបារិច្ឆត្តកព្រឹក្ស មានស្លឹកលឿង មិនយូរទេនឹងជ្រុះស្លឹកលឿងអស់ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ដើមរលួសផ្អុងជាបារិច្ឆត្តកព្រឹក្ស របស់ពួកទេវតាជាន់វត្តិង្ស ជ្រុះស្លឹកលឿងអស់ហើយ ផ្តើមជាដុំផ្កា ផ្តើមចេញផ្កា ជាផ្កាក្រពុំ ជាផ្ការីក ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ ពួកទេវតាជាន់តាវត្តិង្ស ក៏នាំគ្នាត្រេកអរថា ឥឡូវនេះ ដើមរលួសផ្អុងជាបារិច្ឆត្តកព្រឹក្ស មានផ្ការីក មិនយូរទេ នឹងមានផ្ការីកស្គុះស្គាយទាំងអស់ ។ ម្នាលភិក្ខុទាំងឡាយ រស្មីបានគ្របដណ្តប់ទៅ ៥០ យោជន៍ ដោយជុំវិញដើមបារិច្ឆត្ត គឺ ដើមរលួសផ្អុង ដែលមានផ្ការីកស្គុះស្គាយ ក្លិនផ្សាយទៅតាមខ្យល់ ១០០ យោជន៍ ។ នេះជាអានុភាពនៃដើមបារិច្ឆត្ត គឺ ដើមរលួសផ្អុង ។

កាលដើមបារិច្ឆត្តកៈរីកហើយ កិច្ចដោយការដាក់បង្អោង កិច្ចដោយការយកទំពក់ថ្កក់យកមក ឬកិច្ចដោយការយកប្រអប់ទៅទទួល ដើម្បីនាំយកផ្កាឈើមកមិនមាន ។ ខ្យល់ដែលធ្វើនាទីផ្តាច់ តាំងឡើងហើយ ក៏ផ្តាច់ផ្កាឈើអំពីទង ខ្យល់ដែលធ្វើនាទីទទួល ក៏ទទួលទុក ខ្យល់ដែលធ្វើនាទីត្រងបញ្ជូន ក៏បញ្ជូនចូលទៅកាន់សុធម្មាទេវសភា ។ ខ្យល់ដែលធ្វើនាទីបោស ក៏បោសយកផ្កាឈើចាស់ចោល ។ ខ្យល់ដែលធ្វើនាទីក្រាល

ក៏ចាត់ចែងក្រាលត្របកផ្កា និងកេសរ ។ ទីត្រង់កណ្ដាល មានធម្មាសនៈ មានបល្ល័ង្កកែវ កម្ពស់ ១ យោជន៍ មានស្វេតឆត្រកម្ពស់ ៣ យោជន៍ ការពារអំពីខាងលើ ។ បន្ទាប់អំពីបល្ល័ង្កនោះ ក៏ក្រាលអាសនៈស្ដេចសក្កទេវរាជ ។ បន្ទាប់ពីនោះមក ក៏ជាអាសនៈរបស់ទេវបុត្រ ៣៣ អង្គទៀត ។ បន្ទាប់ពីនោះមក ក៏ជាអាសនៈរបស់ទេវបុត្រអ្នកមានសក្ដិធំ ៗ ពួកដទៃ ។ សម្រាប់ពួកទេវតាដទៃ ក៏ប្រើត្របកផ្កាឈើជាអាសនៈ ។ ពួកទេវតាចូលកាន់ទេវសភាហើយអង្គុយ ។ លម្អងផ្កាឈើ ហុយទៅទល់នឹងត្របកខាងលើ ហើយធ្លាក់មក ធ្វើឲ្យអត្តភាពប្រមាណបីគាវុតរបស់ទេវតាទាំងឡាយ ដូចលាបខ្លួនដោយទឹកល័ក្ខ ។ ពួកទេវតាទាំងនោះលេងកីឡានោះ ៤ ខែ ទើបចប់ ។ ពួកទេវតា រមែងប្រជុំគ្នាដើម្បីប្រយោជន៍ដល់ការសោយបារិច្ឆត្តកៈកីឡា ដោយប្រការដូច្នេះ ។

ក៏ក្នុងទេវលោក ទេវតាឃោសនាការស្ដាប់ធម៌ជំមួយខែ ៨ ថ្ងៃ ។ ក្នុងថ្ងៃទាំង ៨ នោះ សនង្កុមារមហាព្រហ្ម ស្ដេចសក្កៈទេវរាជ ភិក្ខុជាធម្មកថិក ឬមិនដូច្នោះ ក៏ទេវបុត្រធម្មកថិកអង្គណាមួយ ពោលធម្មកថាក្នុងសុធម្មាទេវសភា ។ ក្នុងថ្ងៃ ៨ កេច របស់បក្ខ ពួកអាមាត្យរបស់មហារាជទាំង ៤ អង្គ , ក្នុងថ្ងៃ ១៤ កេច ឱរសទាំងឡាយ , ក្នុងថ្ងៃ

១៥ កេច មហារាជទាំង ៤ អង្គ ស្ដេចចេញទៅ ទ្រង់កាន់ក្រាំងមាស និង ជាតិហិង្គុលក៍ ត្រាច់ទៅតាមគាមនិគម និងរាជធានីទាំងឡាយ ។ ព្រះអង្គ ទ្រង់កត់ត្រាទុក ដោយជាតិហិង្គុលក៍លើក្រាំងមាសថា ស្រ្តី ឬបុរស ឈ្មោះ ឯណោះ ដល់ព្រះពុទ្ធជាសរណៈ ដល់ធម៌ជាសរណៈ ដល់ព្រះសង្ឃជា សរណៈ ។ រក្សាសីល ៥ ធ្វើឧបោសថ ៨ ដង ក្នុងខែ បំពេញការ ទំនុកបម្រុងមាតា ការទំនុកបម្រុងបិតា ធ្វើការបូជាដោយផ្កាឧប្បល ១០០ ក្ដាប់ បូជាដោយជិតគ្នា ផ្កាឈើក្នុងទីឯណោះ តាំងប្រទីប ១,០០០ ដួង ធ្វើការស្ដាប់ធម៌ មិនជាវេលាសាងឆត្រវេទី មុទ្ទិវេទី កុច្ឆិវេទី បល្ល័ង្កសិង្ហ ជណ្ដើរសិង្ហ បំពេញសុចរិត ៣ ប្រការ ប្រព្រឹត្តមុតមាំក្នុងកុសលកម្មបថ ១០ ប្រការ ហើយនាំមកប្រគល់ឲ្យដល់ដៃរបស់បញ្ចសិខៈ ។ បញ្ចសិខៈ ក៏ឲ្យដល់ដៃរបស់មាតលី ។ សារថីមាតលី ក៏ថ្វាយចំពោះស្ដេចសក្កទេវ-រាជ ។ កាលមនុស្សធ្វើបុណ្យមានមិនច្រើន ក្រាំងបញ្ជីក៏ស្ដើង ។ ពេល ពួកទេវតាបានឃើញបញ្ជីនោះប៉ុណ្ណោះ ក៏តូចចិត្តថា សម្លាញ់អើយ មហាជន ប្រមាទពិតហ្ន៎ អបាយ ៤ នឹងពេញ ទេវលោក ៦ នឹងទទេ ។ តែបើ បញ្ជីក្រាស់ កាលពួកទេវតាបានឃើញប៉ុណ្ណោះ ក៏នាំគ្នាសប្បាយចិត្តថា ឱសម្លាញ់អើយ មហាជន មិនបានប្រមាទ អបាយ ៤ នឹងទទេ ទេវលោក

៦ នឹងពេញ ពួកយើងនឹងបានហែហមអ្នកមានបុណ្យធំ ដែលបានធ្វើបុណ្យទុកក្នុងព្រះពុទ្ធសាសនា ហើយមកលេងនក្សត្រជាមួយគ្នា ។ ស្តេចសក្កទេវរាជ ទ្រង់កាន់បញ្ជីនោះហើយ ក៏ទ្រង់ប្រៀនប្រដៅ ។ ជាប្រក្រតីកាលស្តេចសក្កទេវរាជនោះ កំពុងត្រាស់ ព្រះសូរសេង បានឮទៅ ១២ យោជន៍ ។ កាលត្រាស់ដោយព្រះសូរសេងខ្លាំង ព្រះសូរសេង ក៏គ្របដណ្តប់ទេវនគរអស់ទាំងម៉ឺនយោជន៍ ហើយតាំងនៅ ។ ដូចពោលមកនេះ ទេវតាទាំងឡាយ រមែងប្រជុំគ្នាដើម្បីប្រយោជន៍ស្តាប់ធម៌ ។ ក៏ក្នុងទីនេះ គប្បីជ្រាបថា ពួក ទេវតាប្រជុំគ្នាដើម្បីប្រយោជន៍បវារណាសង្គ្រោះ ។

[៤៨] ពាក្យថា **នមស្ការព្រះតថាគតហើយ** មានន័យថា នមស្ការព្រះតថាគត ដោយហេតុ ៩ យ៉ាង ។ សេចក្តីរបស់បាទគាថា ថា **ភាវៈនៃព្រះធម៌ ជាធម៌ល្អជាដើម** គឺ ភាវៈនៃព្រះធម៌ ដែលផ្សេងដោយធម៌ ដែលព្រះមានព្រះភាគ ត្រាស់ទុកល្អហើយជាដើម ជាធម៌ល្អ និងការបដិបត្តិល្អ ដែលផ្សេងដោយការបដិបត្តិត្រង់ជាដើម របស់ព្រះសង្ឃ ។

[៤៩] ពាក្យថា **តាមសេចក្តីពិត** គឺ តាមពិត តាមភាវៈរបស់ខ្លួន ។ ពាក្យថា **វណ្ណៈ** សំដៅយកព្រះគុណ ។ ពាក្យថា **ការពោលឡើងហើយ** មានន័យថា និយាយហើយ ។

ពាក្យថា **បដិបត្តិដើម្បីប្រយោជន៍ដល់ជនច្រើន** គឺ បដិបត្តិយ៉ាងណា សូម្បីកាលទ្រង់របូរួមធម៌ ៨ ប្រការ ទៀបព្រះបាទរបស់ព្រះទីបង្ករ ហើយបំពេញព្រះអភិនិហារ ឈ្មោះថា ទ្រង់បដិបត្តិដើម្បីប្រយោជន៍ដល់ជនច្រើន ។ សូម្បីកាលទ្រង់បំពេញព្រះបារមី ១០ ទស ទាំងនេះ គឺ ទានបារមី សីលបារមី នេក្ខម្មបារមី បញ្ញាបារមី វីរិយបារមី ខន្តិបារមី សច្ចបារមី អធិដ្ឋានបារមី មេត្តាបារមី ឧបេក្ខាបារមី អស់វេលា ៤ អសង្ខេយ្យក្រៃលែងដោយសែនកប្ប ក៏ឈ្មោះថា ទ្រង់បដិបត្តិដើម្បីប្រយោជន៍ដល់ជនច្រើន ។ ក្នុងកាលជាតាបសកានយកមាំក្នុងខន្តិ (ខន្តិវាទី) ក្នុងកាលជាចូឡធម្មបាលកុមារ ក្នុងកាលជាស្តេចដំរីឆទ្ទន្ត ក្នុងកាលជាស្តេចនាគភូរិទត្ត ចម្បេយ្យៈ និងសង្ខបាល និងក្នុងកាលជាមហាកបិ សូម្បីទ្រង់ធ្វើការងារដែលធ្វើបានលំបាកដូច្នោះ ក៏ឈ្មោះថា ទ្រង់បដិបត្តិដើម្បីជាប្រយោជន៍ដល់ជនច្រើន ។ សូម្បីកាលទ្រង់មានអត្តភាពជាព្រះវេស្សន្តរ ទ្រង់ឲ្យទានធំមួយប្រភេទមួយរយ រួម ៧ ប្រភេទ ធ្វើឲ្យផែនដីញ័រក្នុង ៧ ស្ថាន ហើយទ្រង់ប្រកាន់យកកំពូលព្រះបារមី ក៏ឈ្មោះថា ទ្រង់បដិបត្តិដើម្បីប្រយោជន៍ដល់ជនច្រើន ។ សូម្បីក្នុងអត្តភាពបន្ទាប់អំពីជាព្រះវេស្សន្តរនោះ ស្តេចតាំងនៅក្នុងតុសិតបុរីរហូតដល់អស់ព្រះជន្មាយុ ក៏

ឈ្មោះថា ទ្រង់បដិបត្តិដើម្បីប្រយោជន៍ដល់ជនច្រើន ។ ព្រះអង្គទ្រង់ឃើញបុព្វនិមិត្ត ៥ យ៉ាងក្នុងតុសិតបុរីនោះ អ្នកដែលពួកទេវតាក្នុងម៉ឺនចក្រវាឡអង្វរហើយ ទ្រង់ត្រួតមើលមហាវិលោកនៈ ៥ ប្រការហើយប្រទានបដិញ្ញាណ ដើម្បីប្រយោជន៍ដល់ការសង្គ្រោះពួកទេវតា ហើយទ្រង់ចុតិចាកតុសិតបុរី សូម្បីទ្រង់កាន់បដិសន្ធិក្នុងព្រះគភ៌មាតា ក៏ឈ្មោះថា ទ្រង់បដិបត្តិដើម្បីប្រយោជន៍ដល់ជនពួកច្រើន ។ ទ្រង់នៅក្នុងព្រះគភ៌ព្រះមាតារហូតដល់អស់ ១០ ខែ ហើយប្រសូតិចាកព្រះគភ៌ព្រះមាតា នៅត្រង់ព្រៃលុម្ពិនីក្តី ទ្រង់គ្រប់គ្រងផ្ទះអស់ ២៩ វស្សា ស្តេចចេញមហាភិនេស្ក្រម៍ទ្រង់ព្រះផ្នួសនៅត្រង់មាត់ប្រាំងស្ទឹងអនោមាក្តី ទ្រង់ធ្វើព្រះអង្គឲ្យលំបាកដោយសេចក្តីព្យាយាមដ៏ធំក្រៃលែង ៦ ឆ្នាំ ហើយ ស្តេចឡើងកាន់ពោធិ-បល្ល័ង្ក ហើយទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណក្តី ទ្រង់ញុំាងព្រះឥរិយាបថឲ្យប្រព្រឹត្តទៅត្រង់គល់ពោធិព្រឹក្ស រហូត ៧ សប្តាហ៍ក្តី ស្តេចអាស្រ័យព្រៃឥសិបតនៈ ហើយទ្រង់បន្លិលធម្មចក្រដ៏កំពូលក្តី ទ្រង់ធ្វើយមកប្បា-ដិហារ្យក្តី ស្តេចចុះចាកពីទេវលោកក្តី ទ្រង់ជាព្រះពុទ្ធហើយ ស្តេចតាំងនៅសែសិបប្រាំវស្សាក្តី ទ្រង់ដាក់ព្រះជន្មាយុសង្ខារក្តី ស្តេចបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ចន្លោះគូនៃដើមសាលៈក្តី ក៏ឈ្មោះថា ទ្រង់បដិបត្តិ

ដើម្បីប្រយោជន៍ដល់ជនពួកច្រើន ។ គប្បីជ្រាបថា ទ្រង់បដិបត្តិដើម្បីប្រយោជន៍ដល់ជនពួកច្រើន រហូតដល់អស់វេលា ដែលព្រះធាតុរបស់ព្រះអង្គ សូម្បីប៉ុនគ្រាប់ស្ពៃតាំងនៅ ។ បទដ៏សេស ក៏ជាពាក្យប្រើជំនួសបទថា ទ្រង់បដិបត្តិដើម្បីប្រយោជន៍ដល់ជនពួកច្រើន នេះទាំងអស់ ។ ក្នុងបទទាំងនោះ បទក្រោយ ជាពាក្យវិសេសក្តីរបស់បទមុន ។

ក្នុងច្រើនបទថា **ក្នុងចំណែកអតីត យើងសម្លឹងមើលមិនឃើញឡើយ និងក្នុងពេលនេះ ក៏សម្លឹងមើលមិនឃើញ** មានន័យថា សូម្បីក្នុងអតីត យើងក៏សម្លឹងមើលមិនឃើញ ក្នុងអនាគតក៏សម្លឹងមើលមិនឃើញបុគ្គលដទៃក្រៅពីព្រះពុទ្ធ សូម្បីក្នុងឥឡូវនេះ ក៏មើលមិនឃើញ ព្រោះមិនមានសាស្តាដទៃឡើយ ក្រៅពីព្រះដ៏មានព្រះភាគ ព្រះអង្គនោះ ។ សូម្បីក្នុងអដ្ឋកថា លោកក៏ពិចារណាថា ព្រះពុទ្ធទាំងឡាយទាំងដែលកន្លងហើយ និងដែលមិនទាន់មកដល់ ក៏ដូចព្រះសាស្តារបស់ពួកយើងនោះឯង ហើយស្តេចសក្កៈត្រាស់ធ្វើអ្វី ហើយពោលថា ក្នុងឥឡូវនេះ ព្រះសាស្តា ទ្រង់បដិបត្តិដើម្បីប្រយោជន៍ដល់ជនពួកច្រើន ក្រៅអំពីព្រះសាស្តារបស់ពួកយើងហើយ ក៏មិនមានអ្នកណាដទៃ ព្រោះដូច្នោះ ស្តេចសក្កៈ ទើបត្រាស់ថា យើងសម្លឹងមើលមិនឃើញ ។ ក៏ក្នុងបទនេះ យ៉ាងណា សូម្បីក្នុងបទ

ពួកជនទៃក្រៅពីនេះ ក៏គប្បីជ្រាបថា មានសេចក្តីតែម្យ៉ាងដូចគ្នានេះ ដូច្នោះ ។

ពាក្យទាំងឡាយ មានពាក្យថា ធម៌ដែលព្រះអង្គត្រាស់ទុកល្អហើយជាដើម និងពាក្យទាំងឡាយជាដើមថា នេះជាកុសល មានសេចក្តីដូចបានពោលទុកហើយទាំងនោះ ។

ពីរបទថា **ទឹកនៃទន្លេគង្គា និងទឹកទន្លេយមុនា** សេចក្តីថា ទឹកក្នុងទីរួមនៃទន្លេគង្គា និងទន្លេយមុនា រមែងចូលគ្នា លាយគ្នាបាន ទាំងដោយពណ៌ ដោយក្លិន ដោយរស គឺ រមែងដូចគ្នាទុះឯង ដូចមាសដែលកាច់បំបាក់ត្រង់កណ្តាល មិនមែនផ្សេងគ្នា ដូចវេលាដែលលាយចូលគ្នានឹងទឹករបស់មហាសមុទ្រ ។ បដិបទាដើម្បីនិព្វានដែលបរិសុទ្ធិ ទើបបរិសុទ្ធិ ។ ពិតហើយ បុគ្គលធ្វើការងារ មានវេជ្ជកម្មជាដើម ក្នុងវេលាជាកម្មោះ ត្រាច់ទៅក្នុងអគោចរ ក៏មិនអាចឃើញនិព្វាន ក្នុងកាលដែលចាស់បាន ។ ការបដិបត្តិ ដែលឲ្យដល់ព្រះនិព្វាន គប្បីជាការបដិបត្តិដែលបរិសុទ្ធិពិត ៗ ប្រៀបដូចអាកាស ។ ពិតដូច្នោះ ការបដិបត្តិរបស់ភិក្ខុ ដែលឆ្ពោះទៅកាន់ព្រះនិព្វាន គួរនឹងប្រៀបផ្ទឹមដោយអាកាស មិនជាប់ទាក់ក្នុងត្រកូល ឬក្នុងពួកគណៈ ដូចផ្លូវដំណើរ ដែលជាទីត្រូវការប្រាថ្នាក្នុងអាកាស របស់ព្រះចន្ទ និងព្រះអាទិត្យ ដែលកំពុងចរក្នុងអាកាសដ៏បរិសុទ្ធិ មិនមានអ្វី

ជាប់ ដូច្នោះ ។ ក៏ឯការបដិបត្តិនេះ គឺ ដូច្នោះឯង ព្រះមានព្រះភាគ ទ្រង់បញ្ញត្តិ ត្រាស់ គឺ ទ្រង់សម្តែងទុកហើយ ។ ព្រោះហេតុនោះ ស្តេចសក្កៈ ទើបត្រាស់ថា ទាំងព្រះនិព្វាន ទាំងការបដិបត្តិ រមែងចូលគ្នាបាន ដូច្នេះ ។

បទថា **ការបដិបត្តិទាំងឡាយ** គឺ របស់អ្នកតាំងនៅក្នុងបដិបត្តិ ។ បទថា **អ្នកមាន (ការនៅ) ទីនៅ** គឺ អ្នកមានការនៅរួចហើយ ។ បទថា **អ្នកមានបុគ្គលទាំងនេះ ជាសំឡាញ់ដែលខ្លួនបានហើយ** សេចក្តីថា ឈ្មោះថាសម្លាញ់ ព្រោះទៅជាមួយគ្នានឹងបុគ្គលទាំងនេះ ក្នុងទីនោះ ៗ ។ ក៏ពាក្យថា អ្នកមិនមានអ្នកណាជាទីពីរ មិនមានសម្លាញ់ មិនមានអ្នកណាប្រៀបផ្ទឹម នេះ ស្តេចសក្កៈត្រាស់ដោយអត្ថថា មិនមានអ្នកណាដូច ព្រះមាន-ព្រះភាគព្រះអង្គនោះ ។ ពាក្យថា **ទ្រង់មិនជាប់** គឺ សំដៅសេចក្តីថា សូម្បីត្រង់កណ្តាលបុគ្គលទាំងនេះ ក៏ទ្រង់នៅដោយផលសមាបត្តិ គឺ ដោយព្រះទ័យហើយ ទ្រង់មិនជាប់ក្នុងបុគ្គលទាំងនោះ ទ្រង់តាមប្រកបក្នុងភាពជាបុគ្គលតែម្នាក់ឯង ដែលមកត្រេកអរ ហើយ ។

ច្រើនបទថា **ក៏លាភរបស់ព្រះមានព្រះភាគព្រះអង្គនោះ សម្រេចក្រៃលែងហើយ** គឺ លាភដែលធំក្រៃលែង កើតឡើងហើយ ដល់ព្រះមាន-

ព្រះភាគ ព្រះអង្គនោះ ។ កើតឡើងហើយតាំងអំពីកាលណា ? កើតឡើងហើយដល់ព្រះអង្គ តាំងអំពីទ្រង់សម្រេចអភិសម្ពោធិហើយ ទ្រង់កន្លង ៧ សប្តាហ៍ ស្តេចបង្វិលធម្មចក្រនៅឥសិបតនៈ ទ្រង់ធ្វើការទូន្មានទេវតា និងមនុស្សដោយលំដាប់ ទ្រង់ឲ្យជដិល ៣ នាក់ បួស ស្តេចយាងកាន់ក្រុងរាជគ្រឹះ និងទ្រង់ទូន្មានព្រះបាទពិម្ពិសារ ដូចលោកពោលទុកថា ក៏ដោយសម័យនោះ ព្រះមានព្រះភាគ ទ្រង់ជាបុគ្គលដែលជនធ្វើសក្ការៈហើយ ធ្វើសេចក្តីគោរពហើយ រាប់អានហើយ បូជាហើយ នមស្ការហើយ ទ្រង់ជាបុគ្គលមានលាភ ដោយចីវរ បិណ្ឌបាត សេនាសនៈ និងបរិក្ខារ គឺ ថ្នាំដែលជាបច្ច័យសម្រាប់អ្នកជម្ងឺ លាភសក្ការៈកើតឡើងមក ដូចអន្លង់ទឹកធំជោរជន់ហើយ ព្រោះផលបុណ្យដ៏ច្រើន សូម្បីក្នុង ៤ អសង្ខេយ្យក្រៃលែងដោយសែនកប្ប ។

បានឮមកថា ក្នុងក្រុងរាជគ្រឹះ ក្រុងសាវត្ថី ក្រុងសាកេត ក្រុងកោសម្ពី ក្រុងពារាណសី ឈ្មោះថា **បដិបាដិកត្ត** ( កត្តដែលឲ្យតាមលំដាប់ ) កើតឡើងហើយដល់ព្រះមានព្រះភាគ ។ ក្នុងក្រុងទាំងនោះម្នាក់ៗ ចុះក្នុងបញ្ជីទុកថា ខ្ញុំនឹងលះបង់ទ្រព្យមួយរយថ្វាយទាន ហើយក៏ភ្ជាប់ទុកត្រង់ទ្វារវិហារ , អ្នកខ្លះ ខ្ញុំពីររយ , ខ្ញុំ ៥ រយ , អ្នកខ្លះ ខ្ញុំមួយ

ពាន់ , អ្នកខ្លះ ខ្ញុំពីរពាន់ , អ្នកខ្លះ ខ្ញុំ ៥ , ១០ , ២០ , ៥០ , អ្នកខ្លះ ខ្ញុំមួយសែន , អ្នកខ្លះ ខ្ញុំនឹងលះបង់ទ្រព្យ ២ សែន ថ្វាយទាន សរសេរដូច្នេះហើយ ក៏ភ្ជាប់ទុកត្រង់ទ្វារវិហារ ។ មហាជនគិតថា បានឱកាសខ្ញុំនឹងថ្វាយ ហើយក៏ផ្ទុកពេញរទេះ ជាប់តាមភិក្ខុ ដែលកំពុងត្រាច់ទៅកាន់ជនបទ ។ ដូចដែលលោកពោលទុកថា "សម័យនោះឯង ពួកមនុស្សអ្នកជនបទ បានផ្ទុកអំបិលខ្លះ ប្រេងខ្លះ អង្ករខ្លះ ខាទនីយៈខ្លះ ដ៏ច្រើនដាក់ក្នុងរទេះទាំងឡាយ ហើយក៏ជាប់ទៅតាមក្រោយព្រះមានព្រះភាគ ដោយគិតថា យើងនឹងធ្វើភត្តក្នុងទីដែលយើងបានលំដាប់ សូម្បីវៀងដទៃ ៗ ជាច្រើន ទាំងក្នុងខន្ធកៈ ទាំងក្នុងព្រះវិន័យ ដូចដែលពោលមកនេះ ក៏គប្បីជ្រាប ។ ក៏ឯលាភនោះដល់កំពូលហើយ ក្នុងអសទិសទាន ។

បានឮមកថា សម័យមួយ កាលព្រះមានព្រះភាគ ស្ដេចត្រាច់ចារិកតាមជនបទហើយ ទ្រង់មកដល់ព្រះជេតពន ព្រះរាជាទ្រង់និមន្តថ្វាយទាន ។ ក្នុងថ្ងៃទីពីរ ពួកអ្នកក្រុងថ្វាយ ។ ព្រះរាជាទ្រង់ថ្វាយក្រៃលែងជាងទានរបស់ពួកអ្នកក្រុងទាំងនោះទៀត ពួកអ្នកក្រុងក៏ថ្វាយ ក្រៃលែងជាងទានរបស់ព្រះអង្គ ដូច្នេះ កាលកន្លងទៅច្រើនថ្ងៃ ព្រះរាជាទ្រង់ព្រះត្រិះរិះថា ពួកអ្នកក្រុងទាំងនេះ នាំគ្នាធ្វើក្រៃលែងឡើង ៗ រាល់ៗ ថ្ងៃ នឹង

មានពាក្យរិះគន់ថា អើ ! ពួកអ្នកក្រុងឈ្មុះព្រះរាជាអ្នកជំក្នុងផែនដីបាន ។ ពេលនោះ ព្រះនាងមល្លិកា បានក្រាបទូលឧបាយចំពោះព្រះអង្គ ។

ព្រះអង្គ ត្រាស់បង្គាប់ឲ្យយកក្តារឈើសាលៈប្រភេទល្អ មកសាងបាពំ ហើយឲ្យយកផ្កាឧប្បលខៀវមកប្រក់ ត្រាស់បង្គាប់ឲ្យក្រាលទីអង្គុយ ៥០០ កន្លែង ផ្នែកខាងក្រោយទីអង្គុយ មានដំរីឈរ ៥០០ ក្នុងដំរីមួយៗ បាំងស្វេតច័ត្រដល់ភិក្ខុមួយរូប ។ ចន្លោះទីអង្គុយពីមួយទៅមួយ មានធីតាក្សត្រិយ៍មួយអង្គៗ តុបតែងកាយដោយគ្រឿងស្អិតស្អាង កិនគ្រឿងក្រអូបដែលកើតពីឈើបួនប្រភេទ ។ ធីតាក្សត្រិយ៍អង្គដទៃ ក៏ដាក់គ្រឿងក្រអូបដែលកិនស្រេចហើយ ក្នុងស្នូកសម្រាប់ដាក់របស់ក្រអូប ក្នុងទីត្រង់កណ្តាល ។ ធីតាក្សត្រិយ៍មួយអង្គទៀត ក៏កាន់ឧប្បលខៀវ និងគ្រឿងក្រអូបនោះ ។ ដោយប្រការដូច្នេះ ភិក្ខុតែមួយរូប ៗ ក៏មានធីតាក្សត្រិយ៍ ៣ ៗ អង្គ ជាបរិវារ ។ ស្ត្រីម្នាក់ទៀត ដែលតែង គ្រឿងស្អិតស្អាងសព្វគ្រប់ កាន់ផ្ចិតស្លឹកត្នោត ស្ត្រីដទៃយកតម្រងទឹក ស្រីដទៃនាំយកទឹកពីបាត្រ ។ ចំណែកព្រះមានព្រះភាគ មានរបស់បួនយ៉ាង កាត់ថ្លៃមិនបាន ។ របស់បួនយ៉ាងដែលកាត់ថ្លៃមិនបានទាំងនេះ គឺ ទីដូតព្រះបាទ ទីទ្រទ្របស់ ក្តារបង្អែកមណីជើងឆត្រ ។ ទេយ្យធម៌សម្រាប់ភិក្ខុថ្មីក្នុងសង្ឃ មានតម្លៃមួយសែន ។

ក៏ឯក្នុងការថ្វាយទាននោះ ព្រះអង្គុលិមាលត្ថេរ បានជាភិក្ខុថ្មីក្នុងសង្ឃ ។ ជិតទីអង្គុយរបស់លោក ដំរីដែលនាំមកហើយ មិនអាចចូលជិតលោកបាន ។ លំដាប់នោះ អ្នកចាត់ចែងការងារក្រាបទូលព្រះរាជា ព្រះរាជាត្រាស់បង្គាប់ថា ពួកលោកចូរនាំយកដំរីដទៃមក ។ ដំរីដែលនាំមកហើយ នាំមកហើយក៏មិនអាចឡើយ ។ ព្រះរាជាត្រាស់ថា មិនមានដំរីដទៃទេឬ ។ អ្នកចាត់ចែងការងារក្រាបទូលថា នៅមានដំរីកាច តែនាំមកមិនបាន ។ ព្រះរាជាទូលសួរព្រះមានព្រះភាគថា ភិក្ខុអង្គណាជាភិក្ខុថ្មីក្នុងសង្ឃ ព្រះមានព្រះ-ភាគត្រាស់ថា អង្គុលិមាល មហាបពិត្រ ព្រោះដូច្នោះ សូមឲ្យអ្នកចាត់ចែងការងារនាំយកដំរីកាចមកតាំងទុកចុះ មហាបពិត្រ ពួកអ្នកចាត់ចែងការងារគាត់តែងដំរីកាចហើយ ក៏នាំមក ។ ដោយតេជះរបស់ព្រះថេរៈ ដំរីនោះ សូម្បីត្រឹមតែថា ខ្យល់ចុងប្រមុះ ក៏ធ្វើមិនបាន ។ ព្រះរាជាទ្រង់បានថ្វាយទានជាប់តគ្នាប្រាំពីរថ្ងៃ ដោយប្រការដូច្នេះ ។ ក្នុងថ្ងៃទី ៧ ព្រះរាជាទ្រង់ថ្វាយបង្គំហើយ ក្រាបទូលព្រះទសពលថា បពិត្រព្រះមានព្រះភាគ សូមព្រះអង្គប្រោសមេត្តាសម្តែងធម៌ដល់ខ្ញុំព្រះអង្គចុះ ។

ក៏ឯក្នុងបរិស័ទនោះ មានអាមាត្រ ២ នាក់ គឺ កាឡៈ និងជុណ្ហៈ ។ កាឡៈគិតថា សម្បត្តិរបស់រាជត្រកូលនឹងវិនាស ពួកបុគ្គលមានប្រមាណ

ប៉ុណ្ណោះ នឹងធ្វើអ្វី ស៊ីហើយទៅវត្ត ហើយក៏នឹងដេកប៉ុណ្ណោះឯង តែរាជបុរស មួយនាក់បានវត្តនេះ នឹងមិនធ្វើឬ ឱ ! សម្បត្តិរបស់ព្រះរាជានឹងវិនាស ។ ជុណ្ហៈគិតថា ដែលឈ្មោះថា ភាពជាព្រះរាជានេះ ធំក្រៃលែង បុគ្គលដទៃ ណាហ្ន៎ នឹងធ្វើវត្តនេះបាន ដែលឈ្មោះថា ព្រះរាជា គឺ អ្នកដែលតាំង នៅក្នុងភាពជាព្រះរាជា ហើយទ្រង់នឹងឲ្យទានបែបនោះ មិនបានឬ កាល ព្រះមានព្រះភាគ ទ្រង់ត្រួតមើលអធ្យាស្រ័យរបស់បរិស័ទ ក៏ទ្រង់ជ្រាប អធ្យាស្រ័យរបស់អ្នកទាំងពីរនោះ ទើបទ្រង់ព្រះតម្រិះថា ប្រសិនបើតថាគត នឹងសម្តែងធម៌តាមអធ្យាស្រ័យរបស់ជុណ្ហៈក្នុងថ្ងៃនេះ សីសៈរបស់កាឡៈ នឹងបែកជា ៧ ចំរៀក តថាគតបំពេញបារមី ក៏ដោយសេចក្តីអាណិតសត្វ សូម្បីក្នុងថ្ងៃដទៃ កាលតថាគតសម្តែងធម៌ ជុណ្ហៈ ក៏គង់នឹងសម្រេចរហូត ដល់អស់មគ្គផល គ្រានេះតថាគតឃើញដល់កាឡៈ ហើយបានត្រាស់គាថា បួនបាទប៉ុណ្ណោះ ដល់ព្រះរាជាថា ៖

> **ពួកបុគ្គលកំណាញ់ នឹងទៅកាន់ទេវលោកមិនបាន ពួក បុគ្គលល្ងង់ នឹងមិនសរសើរទានឡើយ ចំណែកអ្នកប្រាជ្ញ តែងអនុមោទនាទាន ព្រោះហេតុនោះឯង គេទើបមាន សេចក្តីសុខក្នុងលោកខាងមុខ ។**

ព្រះរាជា ទ្រង់មិនពេញព្រះរាជហឫទ័យថា យើងថ្វាយទានយ៉ាងធំសម្បើម តែព្រះសាស្តា ទ្រង់សម្តែងធម៌ដល់យើងតែបន្តិចបន្តួច យើងមិនអាចចាប់ព្រះហឫទ័យរបស់ព្រះទសពលបាន កាលសោយព្រះក្រយាហារព្រឹកស្រេចហើយ ស្តេចក៏យាងទៅកាន់វត្ត ថ្វាយបង្គំព្រះមានព្រះភាគហើយ ក៏ទូលសួរថា ព្រះអង្គ ខ្ញុំម្ចាស់ថ្វាយទានដ៏ធំសម្បើម តែព្រះអង្គទ្រង់ធ្វើអនុមោទនាដល់ខ្ញុំព្រះអង្គមិនច្រើន ខ្ញុំព្រះអង្គមានកំហុសអ្វីឬ ព្រះអង្គ ។ មហាបពិត្រ ព្រះអង្គទ្រង់មិនមានខុសអ្វី តែបរិស័ទមិនស្អាត ព្រោះដូច្នោះតថាគតទើបមិនសម្តែងធម៌ ។ ព្រោះហេតុណា ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ថា បរិស័ទមិនស្អាត ។ ព្រះសាស្តាត្រាស់ប្រាប់បរិវិតក្ករបស់អាមាត្រ ។ ព្រះរាជាត្រាស់សួរកាឡះថា យ៉ាងនោះឬ បា! កាឡះ ។ យ៉ាងនោះមែន មហារាជ ។ ព្រះរាជាត្រាស់ថា កាលយើងឲ្យទ្រព្យរបស់យើង អ្នកនឹងក្តៅក្រហាយដូចម្តេច យើងមិនអាចមើលអ្នកបាន ពួកអ្នកចូរដេញគេចេញ ពីព្រំដែនយើង ។ តពីនោះ ត្រាស់បង្គាប់ហៅជុណ្ហៈមកសួរថា ន័យថា បា! គិតយ៉ាងនោះឬ ។ យ៉ាងនោះឯង ព្រះអង្គ ។ ព្រះរាជាត្រាស់ថា ចូរតាមចិត្តអ្នកចុះ អ្នកចូរនិមន្តភិក្ខុ ៥០០ រូប មកអង្គុយលើទីអង្គុយ ដែលក្រាលទុកក្នុងបារាំនុ៎ះឯង ហើយឲ្យធីតាក្សត្រិយ៍ទាំង

នោះឯង ហែហម យកទ្រព្យពីព្រះរាជវាំងមកថ្វាយទានប្រាំពីរថ្ងៃ ដូចដែលយើងថ្វាយចុះ គេបានធ្វើយ៉ាងនោះហើយ ។ លុះថ្វាយសម្រេចហើយ ក្នុងថ្ងៃទី ៧ ក៏ក្រាបទូលថា បពិត្រព្រះមានព្រះភាគ សូមព្រះអង្គមេត្តាប្រោសសម្តែងធម៌ដល់ខ្ញុំព្រះអង្គចុះ ។ ព្រះសាស្តាទ្រង់ធ្វើការអនុមោទនាទានសូម្បីទាំងពីរឲ្យដូចគ្នា ដូចទ្រង់ធ្វើទន្លេធំពីរខ្សែ ឲ្យពេញដោយអន្លង់ទឹកតែមួយ ទ្រង់សម្តែងព្រះធម៌ទេសនាកណ្ឌធំ ។ កាលទ្រង់ទេសនាចប់ជុណ្ហៈ ក៏បានជាព្រះសោតាបន្ន ។ ព្រះរាជាទ្រង់ជ្រះថ្លា ទ្រង់ថ្វាយសំពត់ឈ្មោះបាវាយចំពោះព្រះទសពល ។ គប្បីជ្រាបថា ក៏លាភសម្រេចក្រៃលែងចំពោះព្រះមានព្រះភាគព្រះអង្គនោះឯង ដោយអាការយ៉ាងនេះ ។

បទថា **ព្រះកិត្តិសព្ទសម្រេចយ៉ាងក្រៃលែង** គឺ ការសរសើរដល់ព្រះកិត្តិគុណ ។ សូម្បីព្រះកិត្តិសព្ទនោះ ក៏សម្រេចយ៉ាងក្រៃលែង ចំពោះព្រះមានព្រះភាគ តាំងពីទ្រង់បង្វិលធម្មចក្ក ។ ពិតយ៉ាងនោះ តាំងពីនោះមក ពួកក្សត្រក៏និយាយដល់ព្រះកិត្តិសព្ទរបស់ព្រះមានព្រះភាគ ដល់ពួកព្រាហ្មណ៍ ពួកគហបតី ពួកនាគ ពួកគ្រុឌ ពួកគន្ធព្វ ពួកទេវតាពួកព្រហ្ម បុគ្គលដទៃក៏ពោលដល់ព្រះកិត្តិសព្ទ ហើយសរសើរដោយពាក្យជាដើមថា សូម្បីព្រោះហេតុនេះ ព្រះមានព្រះភាគព្រះអង្គនោះ សូម្បីពួក

តិរិយឲ្យទ្រព្យមួយពាន់ដល់វរោជៈ ហើយបញ្ជូនទៅថា លោកចូរពោល ទោសព្រះសមណគោតម ។ គេទទួលទ្រព្យមួយពាន់ហើយ ក៏ពិចារណា មើលព្រះទសពល តាំងពីព្រះបាទទល់នឹងចុងព្រះកេសា ទោសត្រឹមតែ មួយលិក្ខា (លិក្ខា មាត្រា ទម្ងន់ស្មើនឹង ១២៩៦ អណូ) ក៏មិនឃើញមាន ទើបគិតថា អ្នកដែលបែរត្រឡប់មាត់និយាយដល់ទោស ក្នុងអត្តភាពដែល រកទោសមិនបាន ដែលពោរពេញទៅដោយមហាបុរិសលក្ខណៈ ៣២ ប្រការ ប្រដាប់ដោយអនុព្យញ្ជនៈ ៨០ យ៉ាង ហែហមទៅដោយរស្មីមួយព្យាម ដូចបារិឆត្តកៈដែលរីក ដូចផ្ទៃមេឃដែលរុងរឿងដោយពួកផ្កាយ និងនន្ទវ័ន ដែលស្រស់ល្អទៅដោយផ្កាឈើវិចិត្រ ដូច្នេះ ក្បាលត្រូវបែកជា ៧ ចំរៀក ឧបាយដែលនឹងពោលតិះដៀល ក៏មិនមាន យើងនឹងពោលសរសើរប៉ុណ្ណោះ ដូច្នេះហើយ ក៏ពោលសរសើរតែម្យ៉ាង តាំងពីផ្ទៃព្រះបាទដរាបដល់ចុង ព្រះកេសា ដោយពាក្យជាងពាន់បទ ។ ក៏ឈ្មោះថា **កិត្តិសព្ទ** នោះ ដល់ កំពូលក្នុងរឿងយមកបាដិហារ្យ ព្រះកិត្តិសព្ទសម្រេចយ៉ាងក្រៃលែង ដូច ពោលមក ដោយប្រការដូច្នេះ ។

បទថា **សូម្បីពួកក្សត្រដទៃ** សេចក្តីថា សូម្បីមនុស្សជាដើម ទាំង អស់ គឺ ពួកព្រាហ្មណ៍ ពួកវេស្សៈ ពួកសុទ្រៈ ពួកនាគ ពួកគ្រុឌ ពួក

*អសុរ ពួកទេវតា ពួកព្រហ្ម សុទ្ធតែជាអ្នកស្រឡាញ់ រីករាយពេញចិត្ត ទាំងអស់គ្នា ។*

*បទថា* ***ក៏ទ្រង់ប្រាសចាកសេចក្តីស្រវឹង*** *គឺ ទ្រង់មិនមែនជាបុគ្គល ស្រវឹង ប្រមាទថា ពួកជនមានប្រមាណប៉ុណ្ណេះ ជាអ្នកស្រឡាញ់តថាគត ហើយសោយព្រះក្រយាហារ ដោយការលេងជាដើម ការពិត ព្រះមានព្រះ-ភាគព្រះអង្គនោះ ទ្រង់ប្រាសចាកសេចក្តីស្រវឹង សោយព្រះក្រយាហារ ។ បទថា* ***មានប្រក្រតីត្រាស់យ៉ាងណា*** *សេចក្តីថា ត្រាស់ពាក្យណាដោយ ព្រះវាចា ព្រះករណីយកិច្ចតាមផ្លូវព្រះកាយរបស់ព្រះអង្គ ក៏ស្របតាម ព្រះវាចានោះពិត ៗ និងព្រះករណីយកិច្ច ដែលទ្រង់ធ្វើដោយព្រះកាយ ព្រះករណីយកិច្ចផ្លូវព្រះវាចារបស់ព្រះអង្គ ក៏ស្របតាមព្រះកាយដោយពិត ព្រះកាយមិនឈានកន្លងព្រះវាចា ឬព្រះវាចា ក៏មិនឈានកន្លងព្រះកាយ ព្រះវាចាសមនឹងព្រះកាយ និងព្រះកាយក៏សមនឹងព្រះវាចា ។ ដូចសេចក្តី ថា ៖*

***ខាងត្បូងជាជ្រូក ខាងស្តាំជាពពែ ដោយសំឡេង***

***ជាគោ ដោយស្នែងជាគោចាស់ ដូច្នេះ ។***

*យក្ខជ្រូកនេះ កាលឃើញហ្វូងជ្រូក ក៏សម្តែងផ្នែកខាងត្បូងដូច*

ជ្រូក ហើយក៏ចាប់ជ្រូកទាំងនោះស៊ី គ្រាឃើញហ្វូងពពែ ក៏សម្តែងផ្នែកខាងស្តាំដូចពពែនោះ ហើយក៏ចាប់ពពែទាំងនោះស៊ី គ្រាឃើញហ្វូងកូនកែះ ក៏ស្រែកជាសំឡេងស្រែករបស់កូនកែះ ហើយក៏ចាប់កូនកែះទាំងនោះស៊ី ពេលឃើញហ្វូងគោ ក៏និម្មិតឲ្យដូចហ្វូងគោទាំងនោះ មើលពីចម្ងាយក៏ឃើញដូចគោដោយប្រការដូច្នេះ ក៏ចាប់គោទាំងនោះ ដែលចូលមកជិតស៊ី យ៉ាងណា និងដូចក្អែក ក្នុងកាកជាតកទ្រទ្រង់ធម៌ ដែលពួកសត្វសួរក៏ប្រាប់ថា ខ្ញុំជាក្អែកហាមាត់ស៊ីខ្យល់ ឈរដោយជើងតែម្ខាងប៉ុណ្ណោះ ព្រោះខ្លាចជាន់សត្វស្លាប់ ព្រោះដូច្នោះ សូម្បីពួកអ្នក ។

សូមចូរប្រព្រឹត្តធម៌ សូមសេចក្តីចម្រើនចូរមានដល់ពួកលោក ញាតិទាំងឡាយ សូមពួកលោកចូរប្រព្រឹត្តធម៌ អ្នកប្រព្រឹត្តធម៌ជាប្រក្រតី រមែងនៅជាសុខ ទាំងក្នុងលោកនេះ និងក្នុងលោកមុខ ហើយធ្វើឲ្យពួកបក្សីស្ងាប់ចិត្ត តពីនោះ ក៏ស៊ីពួកបក្សីដែលមកដល់សេចក្តីស្ងាប់ចិត្តយ៉ាងនេះថា ៖

**បក្សីមួយនេះល្អពិតហ្ន៎ បក្សីមួយនេះទ្រទ្រង់ធម៌យ៉ាង**
**ក្រៃលែង យកជើងតែម្ខាងឈរ ស្រែកថា ធម៌ ធម៌ ។**

វាចារបស់យក្ខជ្រូក និងក្អែកទាំងនោះ មិនសមនឹងកាយ និងកាយ

ក៏មិនសមនឹងវាចា យ៉ាងណា របស់ព្រះមានព្រះភាគ មិនដូច្នោះទេ លោកសម្តែងថា ព្រោះព្រះវាចារបស់ព្រះមានព្រះភាគសមនឹងព្រះកាយ និងព្រះកាយក៏សមនឹងព្រះវាចា ដោយពិតប្រាកដ ដូច្នេះ ។

ឈ្មោះថា **ទ្រង់កន្លងសេចក្តីសង្ស័យបាន** ព្រោះព្រះអង្គទ្រង់កន្លងគឺ ទ្រង់ឆ្លងសេចក្តីសង្ស័យបានហើយ ។ ឈ្មោះថា **ទ្រង់ប្រាសចាកសួរថា យ៉ាងណា ៗ** ព្រោះព្រះអង្គប្រាសចាកការសួរយ៉ាងណា ៗ បែបនេះថា នេះជាអ្វី នេះជាអ្វី ។ ពិតហើយ ព្រះសាស្តាមិនដូចមនុស្សចំនួនច្រើន ដែលនៅមានសេចក្តីសង្ស័យថា ដើមឈើនេះ ឈ្មោះដើមអ្វី តំបន់នេះ ( ឈ្មោះតំបន់អ្វី ) ស្រុក ( ឬខេត្ត ) នេះ ( ឈ្មោះស្រុក ឬខេត្តអ្វី ) ដែននេះឈ្មោះដែនអ្វី ហេតុដូចម្តេច ដើមឈើនេះ ទើបមានដើមត្រង់ ដើមឈើនេះមានដើមវៀច ហេតុដូចម្តេច ទើបមានបន្ទា ខ្លះដើមត្រង់ ខ្លះដើមវៀច ខ្លះផ្កាក្លិនក្រអូប ខ្លះផ្កាក្លិនស្អុយ ខ្លះផ្លែផ្អែម ខ្លះផ្លែមិនផ្អែម ។ ពិតយ៉ាងនោះ ព្រះសាស្តាទ្រង់ជ្រាបថា ព្រោះធាតុទាំងនេះក្រាស់ សូម្បីវត្ថុនេះទើបយ៉ាងនេះ ទើបទ្រង់ជាអ្នកប្រាសចាកការសួរយ៉ាងណា ៗ ដោយពិត ។ម្យ៉ាងទៀត ចំពោះព្រះពុទ្ធជាម្ចាស់ ក៏ទ្រង់មិនដូចអ្នកដែលបានឈានទី ១ ជាដើម មានសេចក្តីសង្ស័យក្នុងឈានទី ២ ជាដើម និងសូម្បីព្រះ-

បច្ចេកពុទ្ធ ក៏នៅមានសេចក្តីសង្ស័យ ដោយអំណាចវោហារដោយពិត ព្រោះមិនទាន់មានការដល់ព្រមតាមសេចក្តីជាពិតដោយសព្វញ្ញុតញ្ញាណ ស្តេចសក្កៈ ទើបលោកទ្រង់សម្តែងថា ព្រះមានព្រះភាគព្រះអង្គនោះ ទ្រង់ប្រាសចាកការសួរថា យ៉ាងណា ៗ ក្នុងវត្ថុគ្រប់យ៉ាង ដូច្នេះ ។

បទថា **ចប់ការគិតហើយ** គឺ ព្រះសាស្តារបស់យើង មិនដូចមនុស្សពួកខ្លះ ដែលការគិត គឺ ពេញមនោរថអស់ត្រឹមតែសីល ខ្លះត្រឹមតែវិបស្សនា ខ្លះត្រឹមតែបឋមជ្ឈាន ។បេ។ ខ្លះត្រឹមតែនេវសញ្ញានាសញ្ញា-សមាបត្តិ ខ្លះត្រឹមតែភាពជាសោតាបន្ន ។បេ។ ខ្លះត្រឹមតែអរហត្តមគ្គ ខ្លះត្រឹមតែសាវកបារមីញាណ ខ្លះត្រឹមតែបច្ចេកពោធិញាណ ។ ស្តេចសក្កៈទ្រង់បញ្ជាក់ថា ចំណែកព្រះសាស្តារបស់យើង ទ្រង់បញ្ចប់សេចក្តីត្រិះរិះដោយសព្វញ្ញុតញ្ញាណ ។ បទថា អជ្ឈាសយំ អាទិព្រហ្មចរិយំ ជាបឋមា-វិភត្តិចុះក្នុងអត្ថនៃតតិយាវិភត្តិ ។ អធិប្បាយថា ទ្រង់ឆ្លងសេចក្តីសង្ស័យបាន ទ្រង់ប្រាសចាកការសួរថា យ៉ាងណាៗ ទ្រង់ដល់ទីបំផុតហើយនៃសេចក្តីត្រិះរិះ ដោយបដិបត្តិដែលជាខាងដើមព្រហ្មចរិយៈ ដែលជាទីអាស្រ័យយ៉ាងក្រៃលែង គឺ ជាទីអាស្រ័យដ៏ខ្ពស់បំផុត និងដោយអរិយមគ្គ ដែលជាព្រហ្មចរិយៈចាស់ ។ សួម្បីសេចក្តីដែលព្រះមានព្រះភាគ ទ្រង់បញ្ចប់

សេចក្ដីត្រិះរិះហើយ ឈ្មោះថា សម្រេចហើយដោយអរិយមគ្គនុ៎ះឯង ព្រោះព្រះបាលីថា ត្រាស់ដឹងសច្ចៈទាំងឡាយ ដោយព្រះអង្គឯង ក្នុងវត្ថុដែលទ្រង់មិនបានស្ដាប់មកអំពីមុន និងទ្រង់សម្រេចភាព ជាអ្នកត្រាស់ដឹងគ្រប់យ៉ាងក្នុងវត្ថុទាំងនោះ និងទ្រង់សម្រេចភាព ជាអ្នកស្ទាត់ជំនាញក្នុងធម៌ដែលជាកម្លាំងទាំងឡាយ ។

## ការពោលចចារបស់ទេវតាពួកខ្លះ

[៥០-៥៣] បទថា **ដូចជាព្រះមានព្រះភាគនោះឯង** គឺ ព្រះមានព្រះភាគនុ៎ះឯង យ៉ាងណា ។ បុគ្គលទាំងឡាយប្រាថ្នានិយាយថា ឱហ្ន៎ ! ព្រះជិនៈបួនព្រះអង្គ គប្បីត្រាច់ចារិកសម្ដែងធម៌ក្នុងទិសទាំងបួន លើផែនដីជម្ពូទ្វីបតែមួយ ។ តមកបុគ្គលពួកដទៃ ប្រាថ្នាការស្ដេចយាង ទៅជាមួយគ្នាក្នុងបរិមណ្ឌល ក៏ពោលថា **ព្រះសម្មាសម្ពុទ្ធ ៣ ព្រះអង្គ** ។ បុគ្គលមួយពួកទៀតគិតថា ការបំពេញព្រះបារមីជាបដល់គ្រប់ ១០ ទសៈ ហើយត្រាស់ជាព្រះពុទ្ធ ៤ ឬ ៣ ព្រះអង្គ មកហើយ លំបាកនឹងបាន តែបើព្រះពុទ្ធមួយព្រះអង្គ គប្បីប្រថាប់ប្រចាំសម្ដែងធម៌ ព្រះសម្មាសម្ពុទ្ធមួយព្រះអង្គ ស្ដេចយាងទៅ សូម្បីដូច្នេះ ជម្ពូទ្វីប ក៏នឹងគប្បីស្រស់ល្អ និង

គប្បីសម្រេចហិតសុខដ៏ច្រើនដោយពិត ទើបពោលថា ឱហ្ន៎ ! លោកអ្នកនិរទុក្ខទាំងឡាយ ដូច្នេះជាដើម ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា នេះមិនមែនឋានៈ នេះមិនមែនឱកាស ដូចតទៅនេះ ៖

ពាក្យទាំងពីរនេះ គឺ **ឋាន អវកាស** ជាឈ្មោះរបស់ហេតុនុ៎ះឯង ។ ពិតណាស់ ការណ៍ (ហេតុ) ឈ្មោះថា **ឋាន** ព្រោះផល រមែងតាំងនៅក្នុងទីនោះ ព្រោះផល ជារបស់ប្រព្រឹត្តទៅជាប់ទាក់ទងនឹងហេតុនោះ និងហេតុនោះ ក៏ដូចជាឱកាស ទើបឈ្មោះថា **អវកាស** ព្រោះផលនោះ វៀរឱកាសនោះចេញ មិនមានក្នុងទីដទៃ ។ បទថា យំ ជាបឋមាវិភត្តិចុះក្នុងអត្ថតតិយាវិភត្តិ ។ មានពាក្យដែលស្តេចសក្កៈ ទ្រង់អធិប្បាយទុកដូច្នេះថា ក្នុងលោកធាតុមួយ ព្រះពុទ្ធពីរព្រះអង្គ ទ្រង់គប្បីកើតឡើងព្រមគ្នាដោយហេតុណា ហេតុនោះមិនមាន ។ មយ៉ាងទៀត ចក្រវាឡមួយប៉ុណ្ណោះ ឈ្មោះថា លោកធាតុមួយ ក្នុងគាថានេះថា ៖

**ព្រះចន្ទ និងព្រះអាទិត្យគោចរបំភ្លឺទិស ឲ្យភ្លឺ មានប្រមាណ**
**ត្រឹមណា លោកទាំងពាន់ ក៏កំណត់ត្រឹមនោះ ដោយអំណាច**
**របស់ព្រះអង្គ ប្រព្រឹត្តទៅបានក្នុងពាន់លោកនោះ ។**

ពាន់ចក្រវាឡ ឈ្មោះថា មួយលោកធាតុ ក្នុងអនាគតស្ថានថា **ពាន់លោកធាតុ បានញាប់ញ័រហើយ** ចក្រវាឡ ឈ្មោះថា មួយលោកធាតុ ក្នុងទីមកថា អានន្ទ កាលតថាគតត្រូវការបន្លឺសំឡេងឲ្យតិសហស្សីលោក-ធាតុ មហាសហស្សីលោកធាតុ ដឹងក៏បាន និងផ្សាយរស្មីទៅក៏បាន ។ ម៉ឺនចក្រវាឡ ឈ្មោះថា លោកធាតុ ក្នុងទីមកថា **និងម៉ឺនលោកធាតុនេះ** ។ ព្រះមានព្រះភាគនោះ ទ្រង់សំដៅដល់ ម៉ឺនលោកធាតុនោះ ត្រាស់ថា **ក្នុងមលោកធាតុមួយ** ដូច្នេះ ។ ក៏ត្រឹមប៉ុណ្ណេះ ឈ្មោះថា **ជាតិខេត្ត** ។ សូម្បីក្នុងជាតិខេត្តនោះ វៀរលែងតែប្រទេសចំណែកកណ្ដាលនៃជម្ពូទ្វីប ក្នុងចក្រវាឡនេះចេញហើយ ក្នុងប្រទេសដទៃ ព្រះពុទ្ធទាំងឡាយទ្រង់មិនបានកើតឡើងឡើយ ក៏ផុតពីជាតិខេត្តទៅ មិនប្រាកដថា មានការកើតឡើងនៃព្រះពុទ្ធទាំងឡាយឡើយ ។

បទថា **ដោយប្រយោជន៍ណា** គឺ ដោយប្រយោជន៍នៃបវារណា សង្គ្រោះណា ។

[៥៤] បទថា **ដោយវណ្ណ និងយសនោះឯង** សេចក្ដីថា ដោយគ្រឿងតែងខ្លួន និងបរិវារ និងដោយបុញ្ញសិរី ។

[៥៦] **សាធុ** សព្ទប្រព្រឹត្តទៅក្នុងសេចក្ដីជ្រះថ្លា ក្នុងបទនេះថា

សាធុ មហាព្រហ្ម ។ បទថា **ពិចារណាហើយត្រេកអរ** គឺ ដឹងហើយ ទើបត្រេកអរ ។

## ការនិម្មិតអត្តភាពដ៏ច្រើនលើសលប់នៃសនង្កុមារព្រហ្ម

[**៥៧**] នរណា ៗ មិនអាចកំណត់ថា ប៉ុណ្ណេះ ហើយពោលបានថា ព្រះមានព្រះភាគព្រះអង្គនោះ ទ្រង់មានព្រះបញ្ញាដ៏ធំក្រៃលែងមកយូរពីត្រឹមណាមក ការពិត ព្រះមានព្រះភាគរបស់យើងព្រះអង្គនោះ ទ្រង់មានព្រះបញ្ញាដ៏ធំក្រៃលែងមកយូរ គឺ យូរណាស់មកហើយ ព្រោះដូច្នោះ ពួកលោកនឹងសម្គាល់យ៉ាងណា ពេលនោះ សនង្កុមារព្រហ្ម មានសេចក្តីប្រាថ្នានឹងដោះស្រាយបញ្ហានោះដោយខ្លួនឯងតែម្តង ទើបពោលថា លោកអ្នកនិរទុក្ខទាំងឡាយ មិនគួរអស្ចារ្យឡើយ ប្រការដែលព្រះមានព្រះភាគ ព្រះអង្គនោះ ទ្រង់បំពេញព្រះបារមី ទម្លាយកំពូលមារទាំងបី ត្រង់ពោធិបល្ល័ង្កទ្រង់មានព្រះញាណមិនទូទៅ ដែលទ្រង់ជាក់ច្បាស់អស់ហើយ គប្បីក្លាយជាអ្នកមានព្រះបញ្ញាធំក្រៃលែង ឥឡូវនេះ អស្ចារ្យអ្វីក្នុងប្រការនេះ ។ តែ សម្លាញ់អើយ ខ្ញុំនឹងប្រាប់ពួកលោកដល់ភាពដែលព្រះអង្គតាំងនៅក្នុងប្រទេសញ្ញាណនៃព្រះពោធិញ្ញាណ ដែលនៅមិនទាន់ចាស់ក្លា ក៏ទ្រង់មាន

ព្រះបញ្ញាធំក្រៃលែងពិត ៗ សូម្បីក្នុងវេលាដែលទ្រង់នៅមានរាគៈជាដើម កាលទ្រង់នាំយកហេតុការណ៍ ដែលត្រូវកពបិទបាំងមកសម្តែង ទើបត្រាស់ពាក្យជាដើមថា ភូតបុព្វំ ភោ ដូច្នេះ ។

ពាក្យថា បុរោហិតោ គឺ ទីប្រឹក្សាសម្រាប់ទូន្មានកិច្ចគ្រប់យ៉ាង ។ បទថា គោវិន្ទ គឺ បានទទួលអភិសេក ដោយការអភិសេកឲ្យជាធំក្នុងផែនដី ។ ក៏ដោយប្រក្រតី គេមានឈ្មោះដទៃៗ ។ តាំងពីវេលាបានទទួលអភិសេកហើយ ក៏ដល់ការរាប់ថា **គោវិន្ទៈ** ។ ពាក្យថា **ជោតិបាល** គឺ ឈ្មោះថា ជោតិបាល ព្រោះរុងរឿង និងព្រោះរក្សា ។

បានឮមកថា ក្នុងថ្ងៃដែលជោតិបាលកើតនោះ អាវុធគ្រប់ប្រភេទក៏ឆេះឡើង ។ សូម្បីព្រះរាជា កាលទ្រង់ឃើញពន្លឺមង្គលាវុធរបស់ព្រះអង្គឆេះសន្ធោសន្ធៅ ក្នុងវេលាជិតភ្លឺ ក៏ទ្រង់តក់ស្លុត ហើយប្រថាប់ឈរ ។ គោវិន្ទ ទៅគាល់ព្រះរាជាតាំងពីព្រឹកព្រលឹម ក្រាបទូលសួរការផ្ទំជាសុខ ។ ព្រះរាជាត្រាស់ឆ្លើយថា លោកអាចារ្យ ខ្ញុំដេកជាសុខបានអំពីណា ហើយក៏ទ្រង់ប្រាប់ហេតុនោះ ។ មហារាជ ទ្រង់កុំខ្លាចឡើយ កូនប្រុសខ្ញុំព្រះអង្គកើតហើយ ដោយអានុភាពរបស់គេ អាវុធទាំងឡាយ ក៏ឆេះទូទៅទាំងព្រះនគរ ។ ព្រះរាជាទ្រង់គិតថា កុមារនេះ នឹងគប្បីជាសត្រូវដល់យើង

ឬហ្ន៎ ហើយក៏ទ្រង់តក់ស្លុតថែមទៀត ។ កាលទ្រង់ត្រូវទូលសួរថា មហារាជ ព្រះអង្គទ្រង់គិតអ្វី ? ក៏ត្រាស់ប្រាប់សេចក្តីនោះ ។ ទីនោះ គោវិន្ទបាន ក្រាបទូលព្រះអង្គថា មហារាជ ទ្រង់កុំខ្វាចឡើយ កុមារនេះ នឹងមិនប្រទូស-រ៉ាយចំពោះព្រះអង្គ តែថា ក្នុងជម្ពូទ្វីបទាំងអស់ នឹងមិនមានអ្នកណាមាន បញ្ញាស្មើគេ សេចក្តីសង្ស័យរបស់មហាជននឹងដាច់អស់ ព្រោះពាក្យរបស់ កូនប្រុសរបស់ខ្ញុំព្រះអង្គ និងគេនឹងទូន្មានកិច្ចគ្រប់យ៉ាងចំពោះព្រះអង្គ ហើយ ក៏លួងលោមព្រះរាជា ។ ព្រះរាជាទ្រង់ពេញព្រះទ័យ ត្រាស់ថា ចូរឲ្យតម្លៃ ទឹកដោះដល់កុមារ ហើយព្រះរាជទានទ្រព្យមួយពាន់ ត្រាស់បង្គាប់ថា ចូរ សម្តែងកុមារនោះដល់យើងក្នុងវេលាដែលកុមារនោះធំ ។ កុមាររមែងធំធាត់ ដោយលំដាប់ ។ ព្រោះកុមារនោះ ជាអ្នករុងរឿង និងជាអ្នកអាចក្នុងការ រក្សា ឪពុកម្តាយទើបតាំងឈ្មោះថា **ជោតិបាល** ។ ព្រោះហេតុនោះ ទើប លោកពោលថា ជោតិបាល ព្រោះសេចក្តីរុងរឿង និងព្រោះការរក្សាដូច្នេះ ។

បទថា **លះបាន់ដោយប្រពៃ** គឺ បានលះបង់ដោយប្រពៃ ។ ឬបទ ថា បានលះបង់ដោយប្រពៃនេះឯង ជាបាឋៈ ។ បទថា **ជាអ្នកអាចឃើញ និងពិចារណាសេចក្តី** គឺ ព្រោះជាអ្នកអាច អាចហ៊ាន ជាអ្នកឃើញសេចក្តី ទើបឈ្មោះថា ជាអ្នកអាចឃើញសេចក្តី ឈ្មោះថា ជាអ្នកអាចឃើញ និង

ពិចារណាសេចក្តី ព្រោះរមែងពិចារណាសេចក្តីនោះ ។ ដោយបទថា **ដែលជាតិបាលនោះឯង គប្បីទូន្មាន** លោកសម្តែងថា សូម្បីព្រះរាជានោះ ក៏ទ្រង់សួរជោតិបាលនុ៎ះឯងហើយ ទើបទ្រង់គ្រប់គ្រង ។ បទថា **សូមសេចក្តីចម្រើន ចូរមានដល់ជោតិបាលដ៏ចម្រើន** សេចក្តីថា ភាពនៃសេចក្តីចម្រើន ការសម្រេចគុណវិសេស សេចក្តីល្អ និងមហាមង្គលទាំងអស់ ចូរមានដល់ជោតិបាលដ៏ចម្រើន ។

បទថា **ពាក្យនាំឲ្យកើតសេចក្តីរីករាយ** គឺ ចប់ពាក្យបដិសណ្ឋារៈដែលជាគ្រឿងបន្ទោបង់នូវសោក ជាប់ទាក់ទងនឹងសេចក្តីស្លាប់ ដោយន័យជាដើមថា កុំឡើយ មហារាជ ទ្រង់កុំគិតឡើយ នេះជារបស់ពិតសម្រាប់សព្វសត្វ ។ បទថា **ជោតិបាលដ៏ចម្រើន កុំឲ្យយើងវិនាសចាកពាក្យទូន្មាន** សេចក្តីថា កុំឲ្យវិនាសចាកពាក្យទូន្មាន ។ អធិប្បាយថា កាលត្រូវសូមអង្វរថា ចូរទូន្មាន ក៏កុំបោះបង់ចោលពួកយើងពីពាក្យទូន្មាន ដោយនិយាយថា ខ្ញុំនឹងមិនទូន្មាន ។ បទថា **ចាត់ចែង** គឺ ចាត់ចែង តែងតាំង ។

បទថា **ពួកមនុស្សពោលយ៉ាងនេះ** សេចក្តីថា កាលពួកមនុស្សឃើញ ជោតិបាលនោះ មានបញ្ញាច្រើនជាងឪពុក ទូន្មានកិច្ចគ្រប់ប្រភេទ ចាត់ចែងការងារគ្រប់យ៉ាង ក៏មានចិត្តត្រេកអរ ពោលយ៉ាងនេះថា **លោក**

**ដ៏ចម្រើន គោវិន្ទព្រាហ្មណ៍ហ្ន៎ លោកដ៏ចម្រើន មហាគោវិន្ទព្រាហ្មណ៍ហ្ន៎** មានពាក្យដែលលោកអធិប្បាយយ៉ាងនេះថា អើហ្ន៎ គោវិន្ទព្រាហ្មណ៍នោះ ជាបិតារបស់បុគ្គលនេះ ចំណែកបុគ្គលនេះ ជាមហាគោវិន្ទព្រាហ្មណ៍ ។

## រឿងព្រះរេណុរាជបុត្រ

[៥៨] បទថា **ក្សត្រ ៦ អង្គនោះ អំពីណា** គឺ ក្សត្រ ៦ អង្គ ដែលលោកពោលថា សម្លាញ់ទាំងនោះណា ។ ដំណាលមកថា ក្សត្រទាំងនោះ រួមព្រះបិតានឹងព្រះរាជបុត្តរេណុ ទ្រង់ជាប្អូន ព្រោះដូច្នោះ មហាគោវិន្ទ ទើបគិតថា ព្រះរាជបុត្តរេណុនេះ ទ្រង់បានទទួលអភិសេកហើយ នឹងបែងចែក ឬមិនបែងចែករាជសម្បត្តិដល់ក្សត្រិយ៍ទាំង ៦ អង្គនោះ ឬយ៉ាងណា ? យើងត្រូវបញ្ជូនក្សត្រទាំងនោះ ទៅកាន់សម្នាក់របស់ព្រះរាជបុត្តរេណុ ដោយប្រញាប់ ហើយធ្វើឲ្យព្រះរាជបុត្តរេណុ ទ្រង់ទទួលពាក្យនោះឲ្យបាន ទើបចូលគាល់ក្សត្រិយ៍ទាំង ៦ អង្គនោះ ដល់ទីប្រថាប់ ។ បទថា **អ្នកបម្រើការព្រះរាជា** បានដល់ ពួកអ្នករាជការ គឺ ពួកអាមាត្រ ។ បទថា **កាមទាំងឡាយជាទីតាំងនៃសេចក្ដីស្រវឹង** មានន័យថា កាមទាំងឡាយ ធ្វើឲ្យស្រវឹង ធ្វើឲ្យប្រមាទ អធិប្បាយថា កាលបើវេលាកន្លងទៅ ៗ ព្រះបាទ

វេណុនេះ មិនអាចស្ងប់ស្ងៀមបានដើម្បីតាមរឿងជល់ ។ ព្រោះដូច្នោះ លោក ដ៏ចម្រើនទាំងឡាយចូរមក គឺ ចូរធ្វើដំណើរមក ។ បទថា **លោក ខ្ញុំនៅចាំបាន** គឺ គេថា គ្រានោះ ជាវេលាដែលពួកអ្នកត្រូវនិយាយការពិតជល់គ្នា ព្រោះដូច្នោះ ព្រះបាទវេណុ ទើបមិនត្រាស់ពាក្យមិនពិតថា យើងនិយាយក្នុងកាលណា នរណាបានឃើញ នរណាបានឮ ( តែ ) ត្រាស់ថា ម្នាលអ្នកដ៏ចម្រើន យើងនៅចាំបាន ។

បទថា **ពាក្យដែលគួរីកកាយ** គឺ ពាក្យទទួលបែបនេះថា មហារាជ កាលព្រះរាជា ស្តេចសុគតហើយ ព្រះអង្គទ្រង់កុំគិតអ្វី នេះជាវត្ថុពិតរបស់សព្វសត្វ សង្ខារទាំងឡាយជាយ៉ាងនេះ ។ បទថា **មានមុខដូចជាមុខរទេះ** គឺ តម្កល់ទុកនូវដែនទាំង ៦ ជាផ្លូវរទេះ ។ ព្រះរាជាតែមួយអង្គ មានរាជសម្បត្តិបីរយយោជន៍ ប្រទេសដែលជាទីរួមនៃរាជសម្បត្តិរបស់ព្រះបាទវេណុ ១០ គាវុត ។ ក៏រាជសម្បត្តិរបស់ព្រះបាទវេណុ នៅត្រង់កណ្តាល ដូចជាពិតាន ។ ហេតុដូចម្តេច ទើបតាំងទុកយ៉ាងនេះ ក្សត្រទាំងឡាយ កាលមកគាល់ព្រះរាជាពេលខ្លះ ទ្រង់មិនបៀតបៀនរាជសម្បត្តិរបស់ក្សត្រអង្គដទៃ ទ្រង់មក និងទៅដោយប្រទេសរៀងៗ ខ្លួន ប៉ុណ្ណោះ ព្រោះកាលទ្រង់ធ្លាក់ចុះកាន់រាជសម្បត្តិរបស់អង្គដទៃ ហើយត្រាស់ថា ពួកលោកចូរ

ឲ្យអាហារ ចូរឲ្យគោ ពួកមនុស្សក៏នឹងលើកទោស ព្រះរាជាទាំងនេះ ស្តេច មិនទៅផ្លូវព្រំដែនរបស់ខ្លួន ទ្រង់រមែងធ្វើការបៀតបៀនពួកយើង ។ តែ កាលស្តេចទៅផ្លូវព្រំដែនរបស់ខ្លួន ពួកមនុស្ស ក៏រមែងមិនសម្គាល់ការ បៀតបៀនថា ព្រះរាជអង្គនេះ នឹងត្រូវបានវត្ថុនេះ និងវត្ថុនេះ ពីសម្នាក់ របស់ពួកយើងតែម្យ៉ាង ។ មហាគោវិន្ទ រឭកដល់សេចក្តីនេះ ទើបតាំង ទុកយ៉ាងនេះថា កាលពួកព្រះរាជាទ្រង់រីករាយព្រមព្រៀងគ្នា ចូរគ្រប់គ្រង រាជសម្បត្តិឲ្យយឺនយូរចុះ ដូច្នេះ ។

[៥៩] នគរ ៧ កន្លែងនេះ គឺ ទន្តបុរៈនៃដែនកលិង្គ បោតនៈនៃ ដែនអស្សកៈ មាហិស្សតីនៃដែនអវន្តី រោរុកៈនៃដែនសោចិរៈ មិថិលា នៃដែនវិទេហៈ និងសាងចម្បាក្នុងដែនអង្គៈ និងពារាណសីនៃដែនកាសី ទាំងនេះ គោវិន្ទសាងទុកហើយ ដែលមហាគោវិន្ទនុ៎ះឯង សាងទុកដើម្បី ប្រយោជន៍ ដល់ព្រះរាជា ព្រះនាមទាំងនេះគឺ ៖

[៦១] សត្តភូ ព្រហ្មទត្ត វេស្សភូ ព្រមទាំងភរតៈ រេណុ និងពីរ ធតរដ្ឋៈ ទាំង ៧ អង្គនេះ បានជាអ្នកទទួលភារៈក្នុងគ្រានោះ ជាព្រះនាម នៃព្រះរាជាទាំង ៧ ព្រះអង្គទាំងនោះ ។ ពិតហើយ ក្នុង ៧ ព្រះអង្គ ទាំងនោះ បានដល់អង្គទាំងនេះ គឺ សត្តភូ ១ ព្រហ្មទត្ត ១ វេស្សភូ ១

*ព្រមទាំងវេស្សភូនោះឯង គឺ ករតៈ ១ វេណុ ១ ចំណែកធតរដ្ឋៈ មានពីរព្រះអង្គ ។ បទថា ទាំង ៧ អង្គទ្រង់មានការៈ គឺ ទ្រង់ជាអ្នកមានព្រះការៈបានដល់ ទ្រង់ជាមហារាជក្នុងផែនដីជម្ពូទ្វីប ។*

" ចប់ ការពណ៌នា ក្នុងបឋមភាណវារៈ "

## កិត្តិសព្ទដ៏ពីរោះរបស់មហាគោវិន្ទព្រាហ្មណ៍

[៦២] បទថា **ចូលទៅរក** គឺ ព្រះរាជាទាំង ៧ ព្រះអង្គ ទ្រង់ព្រះតម្រិះថា ឥស្សរិយសម្បត្តិនេះ សម្រេចហើយដល់ពួកយើង មិនមែនដោយអានុភាពនៃអ្នកដទៃ តែដោយអានុភាពរបស់មហាគោវិន្ទ មហាគោវិន្ទបានធ្វើឲ្យពួកយើងទាំង ៧ អង្គ ព្រមព្រៀងគ្នា តែងតាំងពួកយើងក្នុងផែនដីជម្ពូទ្វីប ឯពួកយើងមិនងាយនឹងធ្វើការតបស្នងដល់មហាគោវិន្ទដែលជាបុព្វការី មហាគោវិន្ទនេះឯង ចូរប្រៀនប្រដៅពួកយើង សូម្បីទាំង ៧ នាក់ ពួកយើងនឹងឲ្យមហាគោវិន្ទនេះឯង ជាមេទ័ព និងជាទីប្រឹក្សា កាលបើដូច្នេះ ពួកយើងគង់នឹងមានសេចក្តីចម្រើនពិត ហើយក៏ចូលទៅរក ។ ចំណែកមហាគោវិន្ទក៏គិតថា យើងបានធ្វើឲ្យព្រះរាជាទាំងនេះ ស្ម័គ្រស្មោះនឹងគ្នាហើយ ។ ប្រសិនបើ ព្រះរាជាទាំងនេះ នឹងមានអ្នកដទៃជាមេទ័ព និងជាទីប្រឹក្សា អំពីនោះ ព្រះរាជាទាំងនេះ ក៏នឹងទ្រង់កាន់ពាក្យរបស់មេទ័ព និងទីប្រឹក្សារៀងៗ ខ្លួន ហើយបែកគ្នា យើងនឹងព្រមទទួល ទាំងតំណែងមេទ័ព និងតំណែងទីប្រឹក្សារបស់ព្រះរាជាទាំងនេះ ហើយទូលថា យ៉ាងនោះព្រះអង្គ ។

បទថា **និងព្រាហ្មណ៍មហាសាល ៧ នាក់** គឺ មហាគោវិន្ទគិតថា

យើងនឹងគប្បីនៅចំពោះព្រះភ័ក្ត្រ ឬមិននៅក៏ដោយ ក្នុងទីគ្រប់កន្លែង ព្រះរាជាទាំងនេះ ទ្រង់នឹងបដិបត្តិមុខនាទី ដោយប្រការដែលយើងនឹងមិននៅចំពោះព្រះភ័ក្ត្របាន ហើយក៏តែងតាំងជំនួសទីប្រឹក្សាទុក ៧ នាក់ លោកសំដៅយកទីប្រឹក្សា ៧ នាក់នោះ ទើបពោលពាក្យនេះថា និងព្រាហ្មណ៍មហាសាល ៧ នាក់ ដូច្នេះ ។ ឈ្មោះថា **អ្នកងូត** ព្រោះងូតទឹកមួយថ្ងៃបីដង ឬងូតទឹកក្នុងពេលល្ងាច និងពេលព្រឹករាល់ថ្ងៃ ឬឈ្មោះថា **ងូតហើយ** ព្រោះចប់ការប្រព្រឹត្តវត្ត ។ ឈ្មោះថា អ្នកងូត តាំងពីនោះ ពួកព្រាហ្មណ៍មិនស៊ី មិនផឹក រួមនឹងពួកព្រាហ្មណ៍ផងគ្នា ។

បទថា **ផ្សាយទៅ** គឺ ល្បីឡើងទៅខ្ពស់ក្រៃលែង ដំណាលមកថា គ្រានោះ ពាក្យនេះឯងប្រព្រឹត្តទៅហើយដល់មនុស្សទាំងឡាយ ក្នុងទីដែលអង្គុយហើយ ( ក្នុងទីអង្គុយគ្រប់កន្លែង ) ថា មនុស្សយើង កាលបានប្រឹក្សាជាមួយព្រហ្មហើយ ក៏នឹងទូន្មានបានអស់ទាំងជម្ពូទ្វីប ។ បទថា **តែយើងមិនបានឡើយ** សេចក្ដីថា បានឮថា មហាបុរស គិតថា គុណដែលមិនមានពិតនេះ កើតដល់យើងហើយ ក៏ការកើតគុណឡើង មិនមែនរបស់ធ្ងន់ធ្ងរអ្វី តែការរក្សាគុណដែលកើតឡើងហើយនុ៎ះឯង ជារបស់ធ្ងន់ ។ មួយ៉ាងទៀត ទាំងដែលយើងមិនបានគិត មិនបានប្រឹក្សាធ្វើ គុណនេះក៏កើត

ឡើងហើយ ក៏កាលយើងគិតហើយ ប្រឹក្សាហើយទើបធ្វើ គុណក៏នឹងធំទូលាយក្រៃលែងពិត ហើយក៏ស្វែងរកឧបាយក្នុងការឃើញព្រហ្ម កាលបានឃើញព្រហ្មនោះហើយ ក៏ត្រិះរិះដល់សេចក្តីនេះជាដើមថា ក៏ប្រការនេះយើងបានស្តាប់មកហើយ ដូច្នេះ ។ បទថា **ចូលគាល់ព្រះបាទរេណុដល់ទីប្រថាប់** សេចក្តីថា មហាគោវិន្ទគិតថា សេចក្តីត្រូវការដើម្បីនឹងគាល់ ឬសេចក្តីត្រូវការដើម្បីនឹងសន្ទនាគ្នាក្នុងវាំងនោះ មិនមានឡើយ ព្រោះយើងកាត់សេចក្តីកង្វល់បានហើយ នឹងនៅជាសប្បាយ ដូច្នេះ ទើបចូលគាល់ដើម្បីកាត់សេចក្តីកង្វល់ឲ្យអស់ ។ គ្រប់កន្លែងក៏ន័យនេះ ។ បទថា **ពួកដែលដូចគ្នា** គឺ ស្មើមានវណ្ណៈស្មើគ្នា មានជាតិស្មើគ្នា ។

បទថា **ឲ្យសាងសណ្ឋាគារថ្មី** គឺ ឲ្យសាងទីនៅយ៉ាងវិចិត្រ យកដើមបបុសមកជាំព័ទ្ធខាងក្រៅ មានទីសម្រាកពេលយប់ ទីសម្រាកពេលថ្ងៃនិងទីចង្ក្រម បរិបូរណ៌សមគួរសម្រាប់នៅក្នុងរដូវភ្លៀង ៤ ខែ ។ បទថា **សម្លឹងករុណាឈាន** គឺ សម្លឹងឈានទាំងពួកបី និងពួកបួននៃករុណា ។ ក៏ក្នុងបទថា **សម្លឹងករុណាឈាន** នេះ ដោយមុខ គឺ ករុណា ក៏ជាការថាព្រហ្មវិហារដ៏សេសទៀតបីប្រការ លោកកាន់យកហើយនោះឯង ។ បទថា **សេចក្តីអផ្សុក សេចក្តីអន្ទះអន្ទែង** សេចក្តីថា កាលនៅក្នុងភូមិឈាន មិន

ថា សេចក្ដីអផ្សុក ព្រោះសេចក្ដីមិនត្រេកអរ ឬសេចក្ដីអន្ទះអន្ទែង ព្រោះសេចក្ដីខ្វាច រមែងមិនមាន , តែសេចក្ដីត្រូវការឲ្យព្រហ្មមក សេចក្ដីប្រាថ្នាឲ្យព្រហ្មមក បានមានហើយ ។ សេចក្ដីភ័យខ្លាច ព្រោះចិត្តតក់ស្លុតនុ៎ះឯង ហៅថា សេចក្ដីភ័យខ្លាច ។

## ការនិយាយឆ្លើយឆ្លងជាមួយសនង្កុមារព្រហ្ម

[៦៣-៦៤] បទថា **មិនដឹង** គឺ មិនជ្រាប ។ បទថា **ធ្វើយ៉ាងណាពួកយើងទើបនឹងស្គាល់លោក** សេចក្ដីថា ពួកយើងនឹងស្គាល់លោកថាអ្វី ។ អធិប្បាយថា ពួកយើងនឹងចាំលោកដោយអាការអ្វី ក្នុងអាការជាដើមថា បុគ្គលនេះនៅទីណា ឈ្មោះអ្វី គោត្រអ្វី ។ ពាក្យថា **បុគ្គលទាំងឡាយស្គាល់ខ្ញុំថាជាកុមារ** សេចក្ដីថា ជនទាំងឡាយស្គាល់ខ្ញុំនុ៎ះឯងថា ជាកុមារ ថាជាប្រុសកម្លោះ ។ បទថា **ក្នុងព្រហ្មលោក** គឺ ក្នុងលោកដ៏ប្រសើរបំផុត ។ បទថា **ជារបស់ចាស់** គឺ ជារបស់យូរលង់ ជារបស់យូរអង្វែង ។ ព្រហ្មរមែងសម្ដែងថា ខ្ញុំនោះជាកុមារចាស់ ឈ្មោះសនង្កុមារព្រហ្ម ។ បទថា **គោវិន្ទ លោកចូរដឹងយ៉ាងនេះ** សេចក្ដីថា គោវិន្ទបណ្ឌិត លោកកចូរដឹងខ្ញុំយ៉ាងនេះ គឺ ចូរចាំខ្ញុំទុកយ៉ាងនេះ ។

របស់ដែលគប្បីបង្អោនទៅដើម្បីភ្ញៀវ ហៅថា របស់ទទួលភ្ញៀវ ក្នុងគាថានេះថា ៖

**ទឹអគ្ឃ ទឹក ប្រេងសម្រាប់លាបជើង និងទឹកឃ្មុំយ៉ាងល្អ សម្រាប់ទទួលព្រហ្ម (មានហើយ) ខ្ញុំសូមទទួលលោក ដ៏ចម្រើន សូមលោកដ៏ចម្រើន ចូរទទួលរបស់មានតម្លៃ របស់ខ្ញុំ ។**

មានពាក្យដែលលោកអធិប្បាយទុកដោយបទថា **របស់ទទួលភ្ញៀវ** នុ៎ះឯងថា នេះទឹអគ្ឃដែលក្រាលទុកហើយ សូមអញ្ជើញអគ្ឃលើទឹអគ្ឃនេះ នេះទឹកបរិសុទ្ធិ អញ្ជើញផឹកទឹក អញ្ជើញលាងជើងពីទឹកនេះ នេះប្រេងលាបជើង ដែលយកប្រេងមកផ្សំដើម្បីប្រយោជន៍ដល់ជើង អញ្ជើញលាបជើងដោយប្រេងនេះ ។ បទនេះថា **ទឹស្អាក់នៅយ៉ាងល្អ** គឺ ព្រហ្មចរិយៈរបស់ព្រះពោធិសត្វ មិនដូចគ្នានឹងព្រហ្មចរិយៈរបស់ពួកអ្នកដទៃទេ ព្រះពោធិសត្វនោះ មិនធ្វើការសន្សំដោយគិតថា នេះសម្រាប់ស្អែកនេះ នេះសម្រាប់ថ្ងៃទីបី ក៏បន្ទៃដែលលាយដោយទឹក មានរសផ្អែម មិនប្រៃ មិនបានចំអិន មិនជូរ (មានហើយ) ព្រះពោធិសត្វនោះ ទ្រង់សំដៅយកទឹកឃ្មុំនោះ កាលនឹងពោលថា អញ្ជើញតកទឹកឃ្មុំនេះទៅបរិភោគ ទើប

ពោលពាក្យជាដើមថា **ខ្ញុំសូម សួរលោកចម្រើន** ទាក់ទងនឹងរបស់ទទួលភ្ញៀវ ៗ របស់ទទួលភ្ញៀវទាំងអស់នេះ មានទុកសម្រាប់ព្រហ្ម ខ្ញុំសូមសួររបស់ទទួលភ្ញៀវទាំងនោះនឹងលោកដ៏ចម្រើន លោកដ៏ចម្រើន ចូរធ្វើរបស់ទទួលភ្ញៀវរបស់ខ្ញុំ គឺ លោកដ៏ចម្រើន ចូរទទួលរបស់ទទួលភ្ញៀវនេះរបស់ខ្ញុំ ដែលជាអ្នកសួរហើយយ៉ាងនេះ ៗ

ក៏មហាគោវិន្ទនេះ មិនជ្រាបឬថា ព្រហ្មមិនបរិភោគ សូម្បីតែវត្ថុណាមួយអំពីវត្ថុនេះ ៗ មិនមែនមិនជ្រាប ទាំងដែលជ្រាបហើយ ក៏សួរដោយប្រាថ្នាវត្ថុជាសំខាន់ថា ឈ្មោះថា ភ្ញៀវ ដែលមកកាន់សម្នាក់របស់ខ្លួន ជាអ្នកដែលត្រូវការសួរ ៗ ទីនោះឯង ព្រហ្មក៏ពិចារណាមើលថា បណ្ឌិតដឹងថា យើងមិនមានការបរិភោគហើយ ទើបសួរឬហ្ន៎ ឬថា តាំងនៅក្នុងសេចក្ដីល្ងង់លោមហើយ ទើបសួរ ជ្រាបថា តាំងនៅក្នុងវត្ថុជាសំខាន់ ទើបសួរ ទើបគិតថា ឥឡូវនេះ យើងគួរទទួល ទើបពោលថា គោវិន្ទ យើងនឹងទទួលរបស់ទទួលភ្ញៀវ ដែលលោកពោលដល់ ៗ ( មានពាក្យដែលមហាព្រហ្មអធិប្បាយថា ) គោវិន្ទ ពាក្យដែលលោកពោលជាដើមថា នេះទីអគ្ឃយក្រាលទុកហើយ សូមអញ្ជើញអគ្ឃយលើទីអគ្ឃយនេះ ក្នុងវត្ថុទាំងនេះ យើងនោះឯងឈ្មោះថា ជាអ្នកអគ្ឃយហើយលើទីអគ្ឃយ

ឈ្មោះថា ជាអ្នកផឹកទឹកហើយ សូម្បីជើងយើង ក៏ឈ្មោះថា លាងហើយ ឈ្មោះថា លាបប្រេងហើយ ឈ្មោះថា បរិភោគទឹកឃ្មុំហើយ តាំងពីវេលាដែលយើងទទួលរបស់ដែលលោកឲ្យ លោកនិយាយដល់វត្ថុណា វត្ថុនោះយើងបានទទួលរៀបរយស្រេចហើយ ព្រោះហេតុនោះ លោកពោលទើបថា គោវិន្ទ យើងសូមទទួលរបស់ទទួលភ្ញៀវដែលពោលដល់នោះ ។ ក៏គ្រាទទួលរបស់ទទួលភ្ញៀវហើយ កាលនឹងធ្វើឱកាសនៃបញ្ហា មហាព្រហ្ម ទើបពោលពាក្យជាដើមថា **ដើម្បីប្រយោជន៍ដ៏ចម្រើនក្នុងបច្ចុប្បន្ន** ដូច្នេះ ។

## ការសួរអំពីដំណើរទៅកាន់ព្រហ្មលោក

[៦៥-៦៦] បទថា ( **ខ្ញុំ** ) **ជាអ្នកមានសេចក្តីសង្ស័យ** ( សូមសួរលោក ) **អ្នកមិនសង្ស័យ** ( ក្នុងបញ្ហា ) **ដែលគប្បីធ្វើឲ្យអ្នកដទៃយល់** សេចក្តីថា ខ្ញុំនៅមានសេចក្តីសង្ស័យ (សូមសួរ) លោកដ៏ចម្រើន ដែលមិនមានសេចក្តីសង្ស័យក្នុងបញ្ហា ដែលគប្បីធ្វើឲ្យអ្នកដទៃយល់ ដែលប្រាកដដល់អ្នកដទៃ ព្រោះសេចក្តីដែលត្រូវអ្នកដទៃសាងឡើងមកឯង ។ ពាក្យថា **លះភាពជារបស់យើង** គឺ លះតណ្ហាដែលជាគ្រឿងឲ្យប្រកាន់ថា នេះរបស់អញ នេះរបស់អញ ។ ពាក្យថា **ក្នុងពួកមនុស្ស** គឺ ក្នុងពួកសត្វ ។

អធិប្បាយថា មនុស្សបុគ្គល យើងលះភាពជារបស់យើងហើយ ។ ពាក្យថា **ជាអ្នកឯកោ** គឺ តែម្នាក់ឯង ។ មានន័យថា ឈរម្នាក់ឯង អង្គុយម្នាក់ឯង ។ ក៏ក្នុងសេចក្ដីនេះ មានខ្លឹមសាររបស់ពាក្យថា ដែលឈ្មោះថា **ឯកោ** ព្រោះជាបុគ្គលតែឯង លេចឡើង គឺ ប្រព្រឹត្តទៅ ។ ដែលឈ្មោះថា ជាបុគ្គលឯកោ ព្រោះជាបុគ្គលដូច្នោះ ។ ពាក្យថា **បង្អោនទៅក្នុងសេចក្ដីអាណិត** គឺ បង្អោនទៅក្នុងឈាន ដែលប្រកបដោយសេចក្ដីអាណិត មានន័យថា ធ្វើឲ្យឈាននោះកើតឡើង ។ ពាក្យថា **មិនមានក្លិនស្អុយ** គឺ ប្រាសចាកក្លិនស្អុយ ។ ពាក្យថា **តាំងនៅក្នុងទីនេះ** គឺ តាំងនៅក្នុងធម៌ទាំងនេះ ។ ពាក្យថា **និងកំពុងសិក្សាហើយ** គឺ កំពុងសិក្សាក្នុងធម៌ទាំងនេះ ។ នេះជាសេចក្ដីសង្ខេបក្នុងរឿងនេះ ។ ចំណែកសេចក្ដីពិស្ដារ មហាគោវិន្ទ និងព្រហ្ម បានពោលទុកខាងលើរួចហើយ ។

## ការពោលអំពីក្លិនពុល

[៦៧] បណ្ដាបទទាំងនោះ បទថា **មិនដឹងវត្ថុទាំងនេះ** មានសេចក្ដីថា ខ្ញុំមិនដឹង មិនស្គាល់ក្លិនពុលទាំងនេះ ។ បទថា ធីរ: លោកចូរពោលក្នុងទីនេះ សេចក្ដីថា **ធីរ:** គឺ អ្នកប្រាជ្ញ ព្រោះហេតុនោះ លោកចូរពោល

គឺ ចូរប្រាប់ខ្ញុំក្នុងទីនេះ ។ ពាក្យថា **ពួកសត្វត្រូវអ្វីរួបរឹតទុក ទើបមានក្លិនស្អុយផ្សាយទៅ** សេចក្ដីថា សត្វត្រូវគ្រឿងបិទបាំង គឺ កិលេសដូចម្ដេច ? រួបរឹតទុក ទើបជះក្លិនស្អុយទៅ ពាក្យថា **អបាយសត្វ** បានដល់សត្វចូលដែលចូលដល់អបាយ ។ បទថា **បិទព្រហ្មលោក** គឺ ឈ្មោះថាបិទព្រហ្មលោកហើយ ព្រោះព្រហ្មលោករបស់គេត្រូវគ្របទុក គឺ ត្រូវបិទហើយ ។ មហាគោវិន្ទ សួរថា ពួកសត្វត្រូវកិលេសអ្វីរួបរឹត គឺ បិទបានដល់ បិទបាំងផ្លូវព្រហ្មលោកហ្ន៎ មហាព្រហ្មឆ្លើយថា សេចក្ដីក្រោធការនិយាយកុហក ការបញ្ឆោតបន្លំ ការប្រទូសរ៉ាយជាដើម សេចក្ដីក្រោធមានការឆេវឆាវជាលក្ខណៈ ការបញ្ឆោតបន្លំ មានការសម្ដែងវត្ថុដែលដូចគ្នាហើយលលួងយកជាលក្ខណៈ និងការប្រទូសរ៉ាយ មានការទំលាយមិត្តជាលក្ខណៈ ។ ពាក្យថា **សេចក្ដីកំណាញ់ ការមើលងាយ សេចក្ដីច្រណែន** សេចក្ដីថា សេចក្ដីកំណាញ់ មានសេចក្ដីបិទបាំង និងសេចក្ដីស្វិតស្វាញជាលក្ខណៈ ការមើលងាយ មានការជាន់ឈ្លីហើយមើលងាយមើលថោកជាលក្ខណៈ និងសេចក្ដីច្រណែន មានសេចក្ដីអស់ទៅនៃសម្បត្តិអ្នកដទៃជាលក្ខណៈ ។ ពាក្យថា **សេចក្ដីកំណាញ់ ការមើលងាយ ការច្រណែន** សេចក្ដីថា សេចក្ដីកំណាញ់ មានភាពរឹងត្អឹង និងស្វិតស្វាញ ជាលក្ខណៈ ,

ការមើលងាយ មានការបន្ទាបបន្ថោក ជាលក្ខណៈ , ការច្រណែន មានការអស់ទៅនៃសម្បត្តិអ្នកដទៃ ជាលក្ខណៈ , បទថា **សេចក្តីប្រាថ្នា ការចង់បានផ្អែកៗ និងការបៀតបៀនអ្នកដទៃ** សេចក្តីថា សេចក្តីប្រាថ្នា មានការចង់បាន ជាលក្ខណៈ , ការហួងហែង មានសេចក្តីកំណាញ់ ជាលក្ខណៈ , និងបៀតបៀនអ្នកដទៃ មានការធ្វើឲ្យលំបាក ជាលក្ខណៈ ។ បទថា **ការចង់បាន ការប្រទូសរ៉ាយ ការស្រវឹង និងការវង្វេង** គឺ ការប្រាថ្នាចង់បាន មានលោភៈជាលក្ខណៈ , ការប្រទូសរ៉ាយ មានសេចក្តីកាចជាលក្ខណៈ , ការស្រវឹង មានការវង្វេងភ្លេចជាលក្ខណៈ និងការវង្វេង មានការវង្វេងភ្លេចស្មារតីជាលក្ខណៈ ។ បទថា **អ្នកប្រកបក្នុងធម៌ទាំងនេះ មិនមែនជាអ្នកមិនមានក្លិនអាក្រក់** សេចក្តីថា ពួកសត្វដែលប្រកបក្នុងកិលេសទាំង ១៤ ប្រការនេះ មិនមែនជាអ្នកមិនមានក្លិនអាក្រក់ ។ មហាព្រហ្មពោលថា ជាអ្នកមានក្លិនអាក្រក់ មានក្លិនសាកសព មានក្លិនស្អុយពិតៗ ។ បទថា **សត្វអបាយបិទព្រហ្មលោកហើយ** មហាព្រហ្ម រមែងសម្តែងថា ក៏ពួកសត្វនេះ ជាសត្វអបាយ និងជាអ្នកបិទផ្លូវព្រហ្មលោក ។ ក៏អ្នកពោលសូត្រនេះ គប្បីពោលឲ្យជាក់ច្បាស់បាន ដោយអាមគន្ធសូត្រ សូម្បីអាមគន្ធសូត្រ ក៏គប្បីពោលឲ្យជាក់ច្បាស់បាន ដោយសូត្រនេះ ។

[៦៨] បទថា **កូនគួរខ្មីមទាំងនោះ មិនគប្បីញាំញីបានងាយ** សេចក្តីថា កូនស្ងួយទាំងនោះ មិនមែនជាវត្ថុដែលនឹងគប្បីញាំញីចេញបានដោយងាយ គឺ មិនមែនជាវត្ថុ ដែលនឹងគប្បីញាំញីចេញបានស្រួល គឺ មិនមែនជាវត្ថុដែលនឹងគប្បីលះបង់បានងាយៗ ។ មានន័យថា លះបង់លំបាក គឺ លំបាកនឹងលះ ។ បទថា **គោវិន្ទដ៏ចម្រើន ចូរសម្គាល់កាលដើម្បីវត្ថុណា ក្នុងពេលនេះ** សេចក្តីថា គោវិន្ទដ៏ចម្រើន រមែងសម្គាល់វេលាដើម្បីការបួសណា ការបួសនេះឯងចូរសម្រេច ។ កាលបើដូច្នោះ ការមកក្នុងសម្នាក់របស់លោក សូម្បីយើង ក៏ជាការមកដោយល្អ ។ ពាក្យក្នុងផ្លូវធម៌ដែលពោលហើយ ក៏ជាការពោលល្អហើយ គោវិន្ទ ! លោកជាបុរសដ៏កំពូលក្នុងជម្ពូទ្វីបទាំងអស់ ជាមនុស្សក្មេង នៅក្នុងបឋមវ័យ ឈ្មោះថា ការលះភាពជាសិរីនៃសម្បត្តិដ៏ធំយ៉ាងនេះហើយ ការបួសរបស់លោកនេះ ជាការជាំក្រៃលែងដូចគ្នានឹងដំរីកូនក្រអូប (ដំរីបានកូនដំរីញី) ហើយកាត់គ្រឿងឈាម គឺ (ច្រវាក់) ដែក ទៅបាន ដូច្នោះ ។ គ្រាធ្វើការងារ គឺ ភាពមុតមាំដល់មហាបុរសថា ការបួសនេះ ឈ្មោះថា ជាព្រះពុទ្ធភាវៈ ដូច្នេះហើយ ព្រហ្មសនង្កុមារក៏ទៅកាន់ព្រហ្មលោកដូចដើម ។ សូម្បីមហាបុរសក៏គិតថា ការដែលយើងចេញចាកទីនេះឯងបួស មិនសមគួរ យើងរមែង

ប្រៀនប្រដៅអត្ថដល់រាជត្រកូល ព្រោះដូច្នោះ យើងនឹងក្រាបទូលចំពោះព្រះរាជា បើព្រះអង្គទ្រង់ផ្នួសដែរ ក៏ជាការល្អ បើទ្រង់មិនផ្នួស យើងនឹងវៀរលែងពីតំណែងទីប្រឹក្សាស្រេចហើយ ទើបបួស ដូច្នេះ ហើយទើបចូលគាល់ព្រះរាជា ។ ព្រោះហេតុនោះ លោកទើបពោលថា លោក គ្រានោះឯង មហាគោវិន្ទ ។បេ។ ខ្ញុំព្រះអង្គមិនត្រេកអរក្នុងភាពជាទីប្រឹក្សាដូច្នេះ ។

[៦៩] បណ្តាបទទាំងនោះ បទថា **សូមព្រះអង្គចូរទ្រង់ជ្រាបដោយរាជសម្បត្តិ** សេចក្តីថា ព្រះអង្គនុ៎ះឯង ចូរទ្រង់ជ្រាបចំពោះ (ទទួលខុសត្រូវ) ដោយរាជសម្បត្តិ របស់ព្រះអង្គ ។ បទថា **ខ្ញុំព្រះអង្គ មិនត្រេកអរក្នុងភាពជាទីប្រឹក្សា** សេចក្តីថា ខ្ញុំព្រះអង្គ រកត្រេកអរក្នុងភាពជាទីប្រឹក្សាក៏ទេ ខ្ញុំព្រះអង្គ នឿយណាយហើយ សូមព្រះអង្គ ចូរទ្រង់ជ្រាបបុរោហិតអ្នកទូន្មានដទៃចុះ ខ្ញុំព្រះអង្គមិនត្រេកអរក្នុងភាពជាទីប្រឹក្សា ។ លំដាប់នោះព្រះរាជាទ្រង់ព្រះតម្រិះថា ភោគៈក្នុងផ្ទះរបស់ព្រាហ្មណ៍អ្នកពួនសម្ងំបួនខែគង់នឹងតិចពិត ទើបទ្រង់អញ្ជើញដោយទ្រព្យ ត្រាស់ថា បើលោកនៅខ្វះដោយកាមទាំងឡាយ ខ្ញុំនឹងថែមឲ្យលោកដរាបពេញ ហើយទ្រង់ព្រះតម្រិះទៀតថា កាលព្រាហ្មណ៍នេះនៅម្នាក់ឯង ត្រូវនរណា ៗ បៀតបៀនឬហ្ន៎

ទើបត្រាស់សួរថា ៖

**ខ្ញុំនឹងការពារ អ្នកដែលនឹងបៀតបៀនលោក**

**ខ្ញុំជាមេទ័ពផែនដី លោកជាឪពុក ខ្ញុំជាកូន**

**គោវិន្ទ សូមលោកកុំលះបង់ពួកខ្ញុំឡើយ ។**

សេចក្ដីនៃគាថានេះថា ខ្ញុំនឹងការពារអ្នកដែលនឹងបៀតបៀនលោក សូមតែម្យ៉ាង ត្រឹមតែឲ្យលោកប្រាប់ថា អ្នកឯណោះ ខ្ញុំនឹងជ្រាបវត្ថុដែលគប្បីធ្វើក្នុងករណីនោះ ។ បទថា **ខ្ញុំជាមេទ័ពនៃផែនដី** សេចក្ដីថា ម្យ៉ាងទៀត ខ្ញុំជាម្ចាស់ផែនដី ខ្ញុំនោះនឹងឲ្យលោកប៉ុណ្ណោះ គ្រប់គ្រងរាជសម្បត្តិនេះ ។ បទថា **លោកជាបិតា ខ្ញុំជាកូន** សេចក្ដីថា លោកកតាំងនៅក្នុងតំណែងឪពុក ខ្ញុំក្នុងតំណែងកូន ចិត្តរបស់ខ្ញុំត្រូវលោកនាំយកទៅហើយ គោវិន្ទ ! សូមលោកកុំលះបង់ខ្ញុំចោល បាឋៈថា លោកចូរឲ្យប្រព្រឹត្តទៅតាមដែលលោកត្រូវការចុះ ចំណែកខ្ញុំ ព្រមតាមចិត្តរបស់លោកតែម្យ៉ាងនឹងស៊ីអាហារដែលលោកឲ្យ មានដៃកាន់ដាវ និងខែលបម្រើលោក ឬបររថឲ្យលោក ម្នាលគោវិន្ទៈ ! លោកកុំលះបង់ខ្ញុំឡើយ ដូច្នេះក៏មាន ។ សេចក្ដីរបស់ពាក្យនោះថា លោកចូរតាំងនៅក្នុងតំណែងជាឪពុក ខ្ញុំនឹងតាំងនៅក្នុងតំណែងជាកូន គោវិន្ទៈ ! លោកកុំចោល គឺ កុំលះបង់ខ្ញុំទៅ

ឡើយ ។

គ្រានោះ កាលមហាបុរសនឹងសម្ដែងវត្ថុដែលព្រះរាជាទ្រង់គិត មិនមានក្នុងខ្លួន ទើបពោលថា ៖

**ការជំពាក់ដោយកាមរបស់ខ្ញុំមិនមាន និងការបៀត**

**បៀនក៏មិនមានដល់ខ្ញុំ ព្រោះខ្ញុំស្ដាប់ពាក្យរបស់**

**អមនុស្ស ទើបមិនត្រេកអរក្នុងការគ្រប់គ្រងផ្ទះ ។**

ក្នុងបទទាំងនោះ បទថា **របស់ខ្ញុំព្រះអង្គមិនមានទេ** សេចក្ដីថា មិនមានដល់ខ្ញុំ ។ បទថា **ក្នុងផ្ទះ** គឺ នៅផ្ទះ ។

លំដាប់នោះ ព្រះរាជទ្រង់ត្រាស់សួរមហាគោវិន្ទនោះថា ៖

**អមនុស្សមានវណ្ណយ៉ាងណា បានពោលសេចក្ដីអ្វី**

**នឹងលោក ដែលលោកបានស្ដាប់ហើយ កលះបង់**

**ផ្ទះរបស់ពួកយើង និងពួកខ្ញុំទាំងអស់ទៅ ។**

បណ្ដាបទទាំងនោះ បទថា **លះបង់ផ្ទះរបស់ពួកយើង និងពួកខ្ញុំទាំងអស់ទៅ** សេចក្ដីថា ព្រះរាជា កាលនឹងទ្រង់ធ្វើព្រះរាជវាំងរបស់ព្រះអង្គដោយអំណាចរួមយកទាំងស្រុកព្រាហ្មណ៍ ដែលសម្បូរណ៍ដោយសម្បត្តិ ទើបត្រាស់ថា ដែលលោកបានស្ដាប់ហើយ ក៏បោលផ្ទះរបស់ពួកយើងខ្ញុំ

និងអ្នកជម្ពូទ្វីបទាំងអស់ គឺ មិនមានសល់ ។

លំដាប់នោះ កាលមហាបុរសក្រាបទូលចំពោះព្រះរាជាអង្គនោះ ទើបពោលពាក្យជាដើមថា កាលខ្ញុំចូលទៅនៅគ្រាដំបូង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចូលទៅនៅ** សេចក្តីថា ចូលទៅដល់ភាពជាបុគ្គលតែម្នាក់ឯង ហើយនៅ ។ បទថា **ខ្ញុំជាអ្នកត្រូវការបូជា** សេចក្តីថា ខ្ញុំព្រះអង្គជាអ្នកប្រាថ្នាដើម្បីសែនទេវតា ។ បទថា **ភ្លើងដែលយកស្បូវមកបន្ថែម បានដុតបំភ្លឺហើយ** គឺ សេចក្តីក្នុងប្រការនេះថា ខ្ញុំឈរគិតយ៉ាងនេះថា ភ្លើងដែលយកស្បូវមកថែមហើយ ដាក់ទឹកដោះថ្លា ទឹកដោះជូរ និងទឹកឃ្មុំជាដើមចូលទៅ កាន់តែឆេះសន្ធោសន្ធៅ ហើយកាលបង្កាត់ភ្លើងឲ្យឆេះសន្ធោសន្ធៅយ៉ាងនោះស្រេចហើយ ខ្ញុំនឹងឲ្យទានដល់មហាជន ។ បទថា **មនុស្សចាស់ៗ** បានដល់ សនង្កុមារព្រហ្ម ។ តអំពីនោះ សូម្បីព្រះរាជាអង្គនោះឯង ក៏ទ្រង់ជាអ្នកប្រាថ្នានឹងបួស ទើបត្រាស់ពាក្យជាដើមថា ខ្ញុំជឿ ។

បណ្តាបទទាំងនោះ បទថា **ហេតុអ្វី លោកទើបប្រព្រឹត្តយ៉ាងដទៃ** សេចក្តីថា លោកនឹង ប្រព្រឹត្តដោយប្រការដទៃបានយ៉ាងណា ។ បទថា **ពួកយើងប្រព្រឹត្តតាមលោក** សេចក្តីថា យើងទាំងនោះនឹងប្រព្រឹត្តតាម គឺ

នឹងបួសតាមលោកនោះឯង ។ បាលីថា **នឹងទៅតាម** ដូច្នេះក៏មាន សេចក្តីរបស់បាលីនោះថា នឹងប្រព្រឹត្តតាម ។ បទថា **មិនថ្មី** គឺ មិនមានការអ្វីមិនជំទាស់ ។ បទថា **ក្នុងអនុសាសន៍របស់គោវិន្ទ** គឺ ក្នុងពាក្យទូន្មានរបស់គោវិន្ទ ព្រះរាជាត្រាស់ថា ពួកយើងនឹងធ្វើគោវិន្ទដ៏ចម្រើននោះឯង ឲ្យជាគ្រូ ហើយប្រព្រឹត្តតាម ។

## ពោលអំពី ការលាក្សត្រទាំង ៦ អង្គ

[៧០] បទថា **ចូលគាល់ក្សត្រ ៦ ព្រះអង្គ ដល់ទីប្រថាប់** សេចក្តីថា គោវិន្ទគាំទ្រព្រះបាទរេណុថា ល្អហើយមហារាជ ! កិច្ចការដ៏ធំក្រៃលែង ដែលមហារាជទ្រង់ប្រាថ្នាដើម្បីនឹងទ្រង់ព្រះផ្នួស មកលះបង់រាជសិរីដ៏ធំក្រៃលែងយ៉ាងនេះ ក្នុងកាលពួកសត្វសម្លាប់ឪពុកខ្លះ ម្តាយខ្លះ បងប្អូនប្រុសខ្លះ បងប្អូនស្រីជាដើមខ្លះ កាន់យករាជសម្បត្តិ ទ្រង់ធ្វើហើយ ធ្វើឧស្សាហ៍របស់ព្រះអង្គឲ្យរឹងមាំហើយ ទើបចូលគាល់ ។ បទថា **ទ្រង់គិតព្រមគ្នាយ៉ាងនេះ** សេចក្តីថា ក្សត្រ ៦ ព្រះអង្គ ទ្រង់សម្គាល់ថា ពេលខ្លះភោគៈទាំងឡាយរបស់ព្រាហ្មណ៍សាបសូន្យហើយក៏បាន ទើបទ្រង់គិតព្រមគ្នា ដោយន័យដែលព្រះរាជាទ្រង់គិតនុ៎ះឯង ។

បទថា **ពួកយើងគប្បីសិក្សាដោយទព្យ** សេចក្តីថា ពួកយើងគប្បីជួយដល់ គឺ គប្បីសង្គ្រោះ ។ បទថា **ចូរៀនាំមកប៉ុណ្ណោះ** សេចក្តីថា គប្បីឲ្យនាំយក គឺ គប្បីឲ្យកាន់យកប៉ុណ្ណោះ ។ មានពាក្យដែលលោកពោលទុកថា លោកគប្បីកាន់យកស្មើចំនួនដែលលោកត្រូវការ ។ បទថា សម្បត្តិរបស់លោកដ៏ចម្រើនទាំងឡាយ ក៏យ៉ាងនោះ សេចក្តីថា សម្បត្តិកើតជារបស់ត្រឹមតែល្មមហើយ ព្រោះលោកទាំងឡាយធ្វើ លោកដ៏ចម្រើនទាំងឡាយឲ្យជាបច្ច័យហើយនោះឯង ។

[៧១] បទថា **ប្រសិនបើពួកលោកលះកាមទាំងឡាយបាន** សេចក្តីថា ប្រសិនបើពួកលោកទាំងឡាយលះវត្ថុកាម និងកិលេសកាមបាន ។ បទថា **ក្នុងកាមទាំងឡាយណា ដែលបថុជ្ជនជាប់ជំពាក់ហើយ** គឺ ទាក់ជាប់ហើយ ក្នុងកាមទាំងឡាយណា ។ បទថា **ពួកលោកចូរប្រារព្ធ ចូរជាអ្នកមុតមាំ** គឺ កាលបើដូច្នេះ សូមឲ្យពួកលោកប្រារព្ធសេចក្តីព្យាយាមអធិដ្ឋានការតស៊ូពុះពារ ចូរជាអ្នករឹងមាំ ។ បទថា **ជាអ្នកតម្កល់មាំក្នុងកម្លាំង គឺ សេចក្តីអត់ធន់** គឺ គោវិន្ទ បណ្ដុះសេចក្តីឧស្សាហ៍ឲ្យកើតដល់ព្រះរាជាទាំងឡាយថា សូមឲ្យពួកព្រះអង្គ ចូរជាអ្នកដល់ព្រមដោយកម្លាំង គឺ សេចក្តីអត់ធន់ ។ បទថា **នុ៎ះ ជាផ្លូវត្រង់** សេចក្តីថា ផ្លូវនៃឈាន

ដែលប្រកបដោយសេចក្តីអាណិតនោះ ឈ្មោះថា ជាផ្លូវត្រង់ ។ បទថា **ទុំះ ជាផ្លូវដ៏កំពូល** សេចក្តីថា ទុំះឯង ឈ្មោះថា ជាផ្លូវខ្ពស់បំផុត ដែលមិនមានផ្លូវដទៃដូច ដើម្បីការចូលដល់ព្រហ្មលោក ។ បទថា **ព្រះសទ្ធម្ម ដែលពួកសប្បុរសរក្សាហើយ** សេចក្តីថា ឈ្មោះថា ព្រះធម៌នោះឯង ឈ្មោះថា ជាធម៌ដែលព្រះពុទ្ធទាំងឡាយ ព្រះបច្ចេកពុទ្ធ និងព្រះសាវក ឈ្មោះថា ជាសប្បុរសរក្សាហើយ ។ គោវិន្ទ រមែងធ្វើពាក្យឲ្យជាកម្មវិធីមាំពិតៗ ដើម្បីប្រយោជន៍ការមិនត្រឡប់នៃព្រះរាជាទាំងនោះ សូម្បីដោយការពណ៌នាឈានដែលប្រកបដោយករុណា ដោយប្រការដូច្នេះ ។

## ការអង្វរមហាគោវិន្ទព្រាហ្មណ៍នៃក្សត្រទាំង ៦ អង្គ

[៧២] បទថា **លោក! នរណានឹងដឹង (គតិ) របស់ជីវិតទាំងឡាយ** សេចក្តីថា លោក ! ដែលឈ្មោះថា ជីវិត ក៏ដូចគ្នានឹងពពុះទឹក ដូចតំណក់ទឹកសន្សើមនៅចុងស្មៅ មានការបែកធ្លាយក្នុងកាលឆាប់ជាធម្មតា នរណានឹងដឹងគតិរបស់ជីវិតនោះបានថា វានឹងបែកធ្លាយក្នុងខណៈណា ។ បទថា **កពមុខ ចាំបាច់ត្រូវទៅ** សេចក្តីថា ក៏លោកមុខជារបស់ដែលត្រូវទៅពិតប្រាកដនោះឯង ព្រោះដូច្នោះ កុលបុត្រអ្នកជាបណ្ឌិតគប្បីដឹងដោយបញ្ញា

ក្នុងរឿងនោះ អធិប្បាយថា **បញ្ញា** លោកហៅថា សេចក្ដីដឹង ត្រូវប្រឹក្សា ត្រូវយល់ ត្រូវពិនិត្យពិចារណាដោយបញ្ញានោះ ។ ឬពាក្យថា មន្តាយ នោះ ជាសត្តមីវិភត្តិចុះក្នុងអត្ថតតិយាវិភត្តិ ។ បទថា **ត្រូវបង្អោនចុះទៅដោយសេចក្ដីដឹង** សេចក្ដីថា ត្រូវដឹងដោយសេចក្ដីដឹង ។ អធិប្បាយថា ត្រូវយល់ ដោយសេចក្ដីដឹង ។ ត្រូវដឹងអ្វី ត្រូវដឹងនូវជីវិតដែលដឹងបាន លំបាក និងលោកខាងមុខជាទីត្រូវតែទៅពិតប្រាកដ ។ ក៏កាលដឹងហើយ ក៏ត្រូវកាត់សេចក្ដីវល់គ្រប់យ៉ាងហើយធ្វើកុសល ត្រូវប្រព្រឹត្តព្រហ្មចារ្យ ។ ព្រោះអ្វី ព្រោះអ្នកកើតហើយមិនស្លាប់ រមែងមិនមាន ។

បទថា **មានសក្តិតូច និងមានលាភតិច** គឺថា ( ព្រះបាទរេណុ ត្រាស់ថា ) លោកដ៏ចម្រើន ដែលឈ្មោះថាការបួស រមែងមានយសតូច ព្រោះអ្នកបៀតបៀនហើយបៀតបៀនទៀត ដល់អ្នកដែលលះបង់រាជសម្បត្តិ ហើយបួសតាំងពីវេលាដែលបួសហើយ រមែងនិយាយធ្វើឲ្យទន់ខ្សោយ និង គ្មានទីពឹង និងឈ្មោះថា មានលាភតិច ព្រោះសូម្បីដើរទៅរហូតទូទាំងស្រុក ក៏រកអាហារលេបបានលំបាកទុំឯង ចំណែកភាពជាព្រាហ្មណ៍នេះ ឈ្មោះថា **មានសក្តិធំ** ព្រោះភាពជាអ្នកមានយសធំ និងឈ្មោះថា **មានលាភច្រើន** ព្រោះភាពជាអ្នកសម្បូរណ៍ដោយលាភ និងសក្ការៈដែលច្រើន ។ ក្នុងឥឡូវ

នេះ លោកដ៏ចម្រើន ដែលជាទីប្រឹក្សាថ្នាក់ខ្ពស់ទូទាំងជម្ពូទ្វីប គ្រប់កន្លែងរមែងបានពីទីអន្តុយដ៏ប្រសើរ ទឹកដ៏ប្រសើរ អាហារដ៏កំពូល ក្លិនដ៏កំពូលផ្កាឈើដ៏ប្រសើរ ។ បទថា **ចូរជាព្រះរាជានៃព្រះរាជាទាំងឡាយ** សេចក្តីថាលោក ! ខ្ញុំព្រះអង្គ ឥឡូវនេះ ដូចជាស្តេចចក្រពត្តិ ក្នុងចំណោមពួកព្រះរាជា ។ បទថា **ដូចព្រហ្មក្នុងពពួកព្រាហ្មណ៍** សេចក្តីថា ដូចជាមហាព្រហ្ម ក្នុងចំណោមនៃព្រាហ្មណ៍ប្រក្រតីទាំងឡាយ ។ បទថា **ដូចទេវតាក្នុងពួកគហបតី** សេចក្តីថា ឯខ្ញុំព្រះអង្គ ប្រៀបដូចជាសក្កៈទេវរាជក្នុងចំណោមពួកគហបតីទាំងឡាយដ៏សេស ។

បទថា **និងពួកភរិយាដែលមានជាតិ និងវណ្ណៈស្មើគ្នា** សេចក្តីថាពួកភរិយាដែលមានជាតិ និងវណ្ណៈដូចគ្នា ៤០ នាក់ ប៉ុណ្ណោះ តែពួកស្ត្រីបំរើទៀតក្នុងវ័យទាំងបីរបស់គោវិន្ទ មានច្រើនទោះឯង ។

បទថា **ចារិក** សេចក្តីថា គោវិន្ទ ត្រាច់ទៅតាមតំបន់ និងគ្រប់ៗស្ថានទីដែលគេទៅ ក៏មានការប្រៀនប្រដៅ ដូចពាក្យប្រៀនប្រដៅរបស់ព្រះសម្ពុទ្ធ ។ ពួកអ្នកបានស្តាប់ថា ន័យថា មហាគោវិន្ទបណ្ឌិតកំពុងនឹងមក ក៏ឲ្យសាងបារាំទុកជាមុន តុបតែងលំអផ្លូវថ្នល់ ហើយក្រោកឡើងទទួលនាំមក ។ លាភ និងសក្ការៈ កើតឡើងដូចអន្លង់ទឹកធំ ហូរជោរ

ជន់ ៗ បទថា **ដល់ទីប្រឹក្សាទាំង ៧** គឺ ពីទីប្រឹក្សារបស់ព្រះរាជា ៧ ព្រះអង្គ ៗ ក្នុងគ្រានោះ ពួកមនុស្សរមែងពោលថា សូមសេចក្ដីចម្រើន ចូរមានដល់មហាគោវិន្ទព្រាហ្មណ៍ សូមសេចក្ដីចម្រើន ចូរមានដល់ទីប្រឹក្សារបស់ព្រះរាជាទាំង ៧ ដូចក្នុងឥឡូវនេះ កាលទុក្ខណា ៗ កើតក្នុងឋានៈបែបនេះ រមែងពោលថា សូមនមស្ការចំពោះព្រះពុទ្ធ ដូច្នោះ ដោយប្រការដូច្នេះ ៗ

ព្រហ្មវិហារមកហើយក្នុងបាលី ដោយន័យជាដើមថា **ទៅជាមួយគ្នានឹងសេចក្ដីស្រឡាញ់** ៗ ក៏ឯមហាបុរស ធ្វើសមាបត្តិ ៨ និងអភិញ្ញា៥ ឲ្យកើតហើយ ៗ បទថា **នឹងសម្ដែងផ្លូវនៃភាពជាសម្មាញ់ក្នុងព្រហ្មលោកដល់ពួកសាវក** សេចក្ដីថា ប្រាប់ផ្លូវដែលត្រូវនៅរួមគ្នាជាមួយនឹងព្រហ្ម ក្នុងព្រហ្មលោក ៗ បទថា **អស់ទាំងអស់** សេចក្ដីថា សាវកទាំងឡាយណាធ្វើសមាបត្តិ ៨ និងអភិញ្ញា ៥ ឲ្យកើតឡើងហើយ ៗ សាវកពួកណាមិនជ្រាបទូទៅដល់សាសនាទាំងអស់ ៗ សាវកពួកណា មិនដឹង មិនអាចឲ្យសូម្បីតែសមាបត្តិមួយ ក្នុងសមាបត្តិ ៨ កើតឡើង ៗ បទថា **មិនទទេ** គឺ មានផល ៗ បទថា **មិនសោះសូន្យ** គឺ មិនមែនទទេ ៗ បាលីថា **ប្រសព្វផលដែលថោកទាបជាងគេ** ដូច្នេះខ្វះ ៗ អធិប្បាយថា ប្រសព្វកាយគន្ធព្វ ៗ

បទថា **មានផល** គឺ ប្រព្រឹត្តទៅព្រមដោយផល ប្រព្រឹត្តទៅជាមួយដោយប្រយោជន៍ដ៏ច្រើន ដើម្បីការចូលដល់ទេវលោកដ៏សេស ។ បទថា **មានកម្រៃ** បានដល់ ប្រព្រឹត្តទៅជាមួយសេចក្តីចម្រើន ដើម្បីចូលដល់ព្រហ្មលោក ។

បទថា **យើងនៅរឭកបាន** សេចក្តីថា បញ្ចសិខៈ តថាគតនៅចាំបាន ។ បានឮមកថា ព្រោះបទនេះ ព្រះសូត្រនេះទើបក្លាយជាពុទ្ធភាសិត ។

បទថា **មិនមែនដើម្បីការនឿយណាយ** គឺ មិនមែនដើម្បីប្រយោជន៍ដល់សេចក្តីនឿយណាយក្នុងវដ្តៈ ។ បទថា **មិនមែនដើម្បីប្រាសចាកតម្រេក** គឺ មិនមែនដើម្បីប្រយោជន៍ដល់ការប្រាសចាកតម្រេកក្នុងវដ្តៈ ។ បទថា **មិនមែនដើម្បីការរលត់ ដោយមិនមានសល់** គឺ មិនមែនដើម្បីប្រយោជន៍ដល់ការរលត់វដ្តៈដោយមិនទៅសល់ ។ បទថា **មិនមែនដើម្បីស្ងប់រម្ងាប់** គឺ មិនមែនដើម្បីដល់ការចូលទៅស្ងប់រម្ងាប់វដ្តៈ ។ បទថា **មិនមែនការដឹងដ៏ក្រៃលែង** គឺ មិនមែនដើម្បីប្រយោជន៍ដល់ការដឹងវដ្តៈយ៉ាងក្រៃលែង ។ បទថា **មិនមែនដើម្បីការភ្ញាក់ព្រម** គឺ មិនមែនដើម្បីប្រយោជន៍ដល់ការភ្ញាក់ចាកវដ្តៈ ដោយប្រាសចាកទៅអំពីសេចក្តីលក់ក្នុងកិលេស ។ បទថា **មិនមែនដើម្បីព្រះនិព្វាន** គឺ មិនមែនដើម្បីប្រយោជន៍ដល់អមតមហា-

និព្វាន ។ បទថា **ដើម្បីការនឿយណាយដល់ទីបំផុត** គឺ ដើម្បីប្រយោជន៍ដល់សេចក្តីនឿយណាយក្នុងវដ្តៈ តែម្យ៉ាងប៉ុណ្ណោះ ។ ចំពោះក្នុងទីនេះ បទថា **ដើម្បីសេចក្តីនឿយណាយ** បានដល់ វិបស្សនា ។ បទថា **ដើម្បីប្រាសចាកតម្រេក** បានដល់ មគ្គ ។ បទថា **ដើម្បីរលត់ដោយមិនមានសល់ ដើម្បីការស្ងប់រម្ងាប់** បានដល់ ព្រះនិព្វាន ។ បទថា **ដើម្បីសេចក្តីដឹងដ៏ក្រៃលែង ដើម្បីការត្រាស់ដឹង** សំដៅយកមគ្គ ។ បទថា **ដើម្បីព្រះនិព្វាន** ក៏គឺ ព្រះនិព្វានទុះឯង ដោយប្រការដូច្នេះ ក៏គប្បីជ្រាបពាក្យដែលប្រាសចាកវដ្តៈយ៉ាងនេះថា លោកពោលវិបស្សនា ១ កន្លែង ពោលមគ្គ ៣ កន្លែង ពោលនិព្វាន ៣ កន្លែង ក៏ពាក្យប្រើជំនួសមគ្គក្តី ពាក្យប្រើជំនួសនិព្វានក្តី ទាំងអស់នេះ រមែងមានដោយទំនងនេះឯង ។ ពាក្យដែលនឹងគប្បីពោលក្នុងបទជាដើមថា សេចក្តីយល់ត្រូវ ក៏បានពោលហើយក្នុងសច្ចវណ្ណនា ក្នុងវិសុទ្ធិមគ្គ ។

បទថា **ពួកណាមិនមែនទាំងអស់** សេចក្តីថា ពួកកុលបុត្រណាមិនជ្រាប ដើម្បីនឹងបំពេញអរិយមគ្គទាំង ៤ ឬធ្វើឲ្យអរិយមគ្គ ៣ , ២ ឬ ១ កើតឡើង ។ បទថា **របស់កុលបុត្រទាំងឡាយនេះតែម្យ៉ាង** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់ញ៉ាំងធម៌ទេសនាឲ្យចប់ស្រេចដល់កំពូល គឺ អរហត្ត

*(ការបព្វជ្ជា) របស់ពួកកុលបុត្រអ្នកប្រព្រឹត្តព្រហ្មចរិយៈរឿយៗ មិនជារបស់ទទេ មានកម្រៃ ដូច្នេះ ។ បទថា* ***ថ្វាយបង្គំព្រះមានព្រះភាគ ហើយធ្វើប្រទក្សិណ*** *សេចក្ដីថា បញ្ចសិខទេវបុត្ររីករាយ ទទួលព្រះធម៌ទេសនារបស់ព្រះមានព្រះភាគហើយដោយចិត្ត អនុមោទនាសរសើរហើយដោយវាចា លើកផ្គងដៃធំដាក់លើសិរសា ចូលទៅក្នុងចន្លោះព្រះរស្មី ៦ ពណ៌របស់ព្រះទសពល ដូចអ្នកមុជចុះក្នុងទឹកលក្ខដ៏ថ្លា សំពះក្នុងទី ៤ កន្លែងហើយធ្វើប្រទក្សិណបីជុំ គោតសរសើរព្រះមានព្រះភាគបណ្ដើរ ក៏បាត់ភ្លាមអំពីព្រះភក្ត្រព្រះសាស្ដា បានមកកាន់ទេវលោករបស់ខ្លួនហើយ ដោយប្រការដូច្នេះឯង ។*

" ចប់ អដ្ឋកថា មហាគោវិន្ទសូត្រទី ៦ "

# អដ្ឋកថា មហាសមយសូត្រ ទី ៧

[៧៣] មហាសម័យសូត្រផ្ដើមឡើងថា **ខ្ញុំបានស្ដាប់មកយ៉ាងនេះ** ។ តទៅនេះ ជាការពណ៌នាតាមលំដាប់បទក្នុងមហាសមយសូត្រនោះ ។

បទថា **ក្នុងដែនរបស់ពួកអ្នកសក្យៈ** សេចក្ដីថា ជនបទមួយ ជាទីនៅនៃព្រះរាជកុមារដែលបានព្រះនាមថា សក្កៈ ព្រោះអាស្រ័យព្រះឧទានថា លោក ! ពួកក្មេងជាង ពូកែពិត តាមន័យនៃការកើតឡើងដែលពោលទុកក្នុងអម្ពដ្ឋសូត្រ ក៏ហៅថា សក្កៈទាំងឡាយ ក្នុងជនបទរបស់ពួកអ្នកសក្កៈនោះ ។ បទថា **ព្រៃធំ** គឺ ក្នុងព្រៃធំដែលកើតឯងមិនបានដាំទុក ជាប់តគ្នាពីហិមពាន្ត ។ បទថា **សុទ្ធតែជាព្រះអរហន្តទាំងអស់** គឺ អ្នកសម្រេចព្រះអរហន្ត ក្នុងថ្ងៃដែលត្រាស់ព្រះសូត្រនេះឯង ។ តទៅនេះជាលំដាប់ពាក្យ ៖

ដំណាលមកថា អ្នកសក្យៈ និងកោលិយៈ នាំគ្នាការពារទន្លេឈ្មោះរោហិណីក្នុងចន្លោះក្រុងកបិលកស្ថុ និងក្រុងកោលិយៈ ដោយខឿនតែមួយប៉ុណ្ណោះ ហើយសាបសំណាប ។ តមកក្នុងដើមខែ ៧ កាលសំណាបកំពុងស្វិតស្រពោន ពួកអ្នកធ្វើការរបស់អ្នកក្រុងទាំងពីរ ក៏ប្រជុំ

គ្នា ។ ក្នុងទីប្រជុំនោះ ពួកអ្នកក្រុងកោលិយៈនិយាយថា ទឹកនេះកាលត្រូវទាំងពីរចំណែកនាំយកទៅ (ប្រើ) ពួកលោកក៏នឹងមិនសម ពួកខ្ញុំក៏នឹងមិនសម តែភាពខ្វាំងក្លារបស់ពួកខ្ញុំនឹងសម្រេចដោយទឹក ត្រឹមតែមួយគ្រាប៉ុណ្ណោះ សូមឲ្យពួកលោក ចូរឲ្យទឹកដល់ពួកខ្ញុំចុះ អ្នកក្រុងកបិលភស្តុក៏និយាយថា កាលពួកលោកដាក់ស្រូវដកាបពេញជង្រុកហើយ ពួកខ្ញុំនឹងយកមាសក្រហម មណីខៀវ និងកហាបណៈខ្មៅ មានដៃកាន់កំប៉ុង និងថៃជាដើម ដើរទៅជិតទ្វារស្រុករបស់ពួកលោកក៏មិនបាន ពេលសំណាបរបស់ពួកខ្ញុំសម្រេចដោយទឹកក្នុងគ្រាតែមួយដូចគ្នា សូមឲ្យពួកលោក ចូរឲ្យទឹកនេះដល់ពួកខ្ញុំចុះ ពួកខ្ញុំឲ្យមិនបាន ។ ឯពួកខ្ញុំ ក៏ឲ្យមិនបាន ។ កាលឈ្លោះគ្នាជៀមដាមយ៉ាងនេះហើយ ម្នាក់ក៏ក្រោកទៅវាយម្នាក់ សូម្បីអ្នកនោះក៏វាយអ្នកដទៃ គ្រប់គ្នាក៏វាយតប់គ្នានិងគ្នា យ៉ាងនេះ ហើយក៏ឈ្លោះគ្នាជៀម-ដាម ដកាបជាប់ទាក់ទងទៅដល់ជាតិរបស់ពួករាជត្រកូល ដោយប្រការដូច្នេះ ។

ពួកអ្នកធ្វើការខាងកោលិយៈ និយាយថា ពួកលោកចូរនាំយកពួកអ្នកកបិល ដែលរួមសង្វាសនឹងបងប្អូនស្រីរបស់ខ្លួន ដូចគ្នានឹងពួកសុនខនិងចចកជាដើមទៅ ប្រគល់នូវដំរី សេះ និងខែល និងអាវុធ របស់ពួក

នោះ ក៏ធ្វើអ្វីពួកខ្ញុំមិនបាន ។ ពួកអ្នកធ្វើការខាងសក្យៈ ក៏និយាយថា ពួកលោកក៏ចូរនាំយកក្មេងកើតរោគឃ្លង់ ដែលជាពួកអនាថា រកគតិមិនបាន នៅក្រោមដើមក្រពៅ ដូចពួកតិរច្ឆានទៅ ប្រគល់ដំរី សេះ និងខែល និងអាវុធរបស់ពួកនោះ ក៏ធ្វើអ្វីពួកខ្ញុំមិនបានទេ ។ គ្រាពួកទាំងនោះត្រឡប់ទៅហើយ ក៏បានជ្រាបដល់ពួកអាមាត្រ ដែលជាប់ទាក់ទងនឹងការងារនោះ ។ ពួកអាមាត្រ ក៏ក្រាបទូលពួករាជត្រកូលនោះ តពីនោះពួកស្តេចសក្យៈក៏ថា ពួកយើងនឹងសម្តែងសេចក្តីក្លាហាន និងកម្លាំងរបស់ពួកអ្នករួមសង្វាសនឹងបងប្អូនស្រី ហើយក៏ត្រៀមលើកទ័ពទៅ ។ ចំណែកពួកស្តេចកោលិយៈ ក៏ថា ពួកយើងនឹងសម្តែងសេចក្តីក្លាហាន និងកម្លាំងរបស់ពួកអ្នកនៅក្រោមដើមក្រពៅ ហើយក៏ត្រៀមលើកទ័ពទៅ ។

ចំណែកព្រះមានព្រះភាគ កាលវេលាជិតភ្លឺនោះឯង ស្តេចចេញចាកមហាករុណាសមាបត្តិ កាលទ្រង់ពិចារណាលោក ទ្រង់បានឃើញពួកទាំងនេះ កំពុងត្រៀមលើកទ័ពទៅយ៉ាងនេះ លុះទ្រង់ឃើញហើយ ទ្រង់ក៏ពិចារណាថា កាលតថាគតទៅ ជម្លោះនេះនឹងស្ងប់ឬទេហ្ន៎ ទ្រង់បានធ្វើការសន្និដ្ឋានថា កាលតថាគតទៅទីនោះហើយ នឹងសម្តែងជាតកបីរឿង ដើម្បីរម្ងាប់ការឈ្លោះគ្នា តពីនោះការឈ្លោះគ្នាក៏នឹងស្ងប់ បន្ទាប់ពីនោះ

ដើម្បីប្រយោជន៍ការទូន្មានដល់សេចក្តីព្រមព្រៀងគ្នា តថាគតនឹងសម្តែងពីរជាតកទៀត ហើយសម្តែងដល់រឿងអត្តទណ្ឌសូត្រ កាលបើព្រះរាជាទាំងពីរបានស្តាប់ទេសនាហើយ នឹងឲ្យក្មេងក្នុងម្នាង ២៥០ នាក់ តថាគតនឹងឲ្យក្មេងទាំងនោះបួស ពេលនោះ ការប្រជុំធំក៏នឹងមាន ព្រោះហេតុនោះ ខណៈដែលពួកទាំងនេះ កំពុងត្រៀមលើកទ័ពចេញទៅ ទ្រង់មិនសំដៅយកនរណា ១ ព្រះអង្គឯង ស្តេចកាន់បាត្រ ចីវរ ទៅដល់បល្ល័ង្ក ប្រថាប់អង្គុយបញ្ចេញព្រះរស្មីមាន ៦ ពណ៌ កាត់ចន្លោះនៃកងទ័ពទាំងពីរ ។

ពេលអ្នកក្រុងកបិលពស្តុ បានឃើញព្រះមានព្រះភាគ យាងដល់ប៉ុណ្ណោះ ក៏គិតថា ព្រះសាស្តា ព្រះញាតិប្រសើររបស់ពួកយើងស្តេចមកហើយ ព្រះអង្គទ្រង់ជ្រាបការដែលពួកយើងឈ្លោះគ្នាឬហ្ន៎ ហើយគិតថាកាលព្រះមានព្រះភាគស្តេចមកហើយ ពួកយើងនឹងឲ្យសស្ត្រាដល់សរីរៈអ្នកដទៃ មិនបានដាច់ខាត ហើយក៏ចោលអាវុធ អង្គុយសំពះព្រះមាន-ព្រះភាគ ។ សូម្បីពួកអ្នកក្រុងកោលិយៈ ក៏គិតដូចគ្នាយ៉ាងនោះឯង នាំគ្នាចោលអាវុធ អង្គុយសំពះព្រះមានព្រះភាគ ។ កាលទ្រង់ជ្រាបហើយ ព្រះមានព្រះភាគ ក៏ត្រាស់សួរថា មហាបពិត្រ ! ពួកព្រះអង្គ ស្តេចមកធ្វើអ្វី ។ ពួកក្សត្រទាំងនោះក្រាបទូលថា បពិត្រ ព្រះមានព្រះភាគ ! ពួក

ខ្ញុំព្រះអង្គមកទីនេះ មិនមែនដើម្បីលេងកំពង់ទឹក មិនមែនដើម្បីលេងភ្នំ មិនមែនដើម្បីលេងទន្លេ មិនមែនដើម្បីសរសើរគ្នា តែមកច្បាំងគ្នា ។ មហាបពិត្រ ! ព្រោះអាស្រ័យអ្វី ព្រះអង្គទើបឈ្លោះគ្នា ។ ទឹក ព្រះអង្គ ។ ទឹកមានតម្លៃប៉ុនណា មហាបពិត្រ មានតម្លៃតិច ព្រះអង្គ ។ ឈ្មោះថាផែនដី មានតម្លៃប៉ុនណា មហាបពិត្រ រកតម្លៃមិនបានទេ ព្រះអង្គ ។ ឈ្មោះថា ពួកក្សត្រ មានតម្លៃប៉ុនណា មហាបពិត្រ ឈ្មោះថា ពួកក្សត្ររកតម្លៃមិនបាន ព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ថា មហាបពិត្រ ! ពួកព្រះអង្គអាស្រ័យទឹកដែលមានតម្លៃតិចហើយ មកធ្វើឲ្យពួកក្សត្រ ដែលរកតម្លៃមិនបាន វិនាសដើម្បីអ្វី ហើយត្រាស់ថា ក្នុងការឈ្លោះគ្នា មិនមានសេចក្ដីរីករាយ មហាបពិត្រទាំងឡាយ ! ដោយអំណាចការឈ្លោះគ្នា ការឈឺចាប់ផ្លូវចិត្ត ដែលរុក្ខទេវតាម្នាក់ ធ្វើពៀរក្នុងទីដែលមិនគួរប្រព្រឹត្តទៅបាន ហើយចងទុកជាមួយខ្លាឃ្មុំ បានជាប់តាមទៅរហូតដល់អស់នៃកប្បហើយត្រាស់ជាតក រឿងដើមពន្ទ្រ ។ តពីនោះត្រាស់ទៀតថា មហាបពិត្រទាំងឡាយ ! មិនគប្បីជាអ្នកភ្ញាក់ផ្អើល ព្រោះហ្វូងសត្វជើងបួន ក្នុងព្រៃហិមពាន្ត ដែលមានទទឹងរហូតបីពាន់យោជន៍ ភ្ញាក់ផ្អើល ព្រោះពាក្យនិយាយរបស់ទន្សាយមួយក្បាល បានស្ទុះទៅដរាបដល់សមុទ្រហ្លួង ព្រោះ

ដូច្នោះ មិនគប្បីជាអ្នកភ្ញាក់ផ្អើល ហើយត្រាស់ជាតករឿងផែនដីស្រុត តពីនោះត្រាស់ថា មហាបពិត្រទាំងឡាយ ! ពេលខ្លះ សូម្បីតែអ្នកដែលទន់ខ្សោយ ក៏ឃើញចំណុចខ្សោយរបស់អ្នកមានកម្លាំងច្រើនបាន ពេលខ្លះអ្នកមានកម្លាំងច្រើន ក៏ឃើញពិរុទ្ធរបស់អ្នកខ្សោយបាន ពិតយ៉ាងនោះសូម្បីតែសត្វរុយញី ក៏អាចសម្លាប់ដំរីបាន ហើយត្រាស់ជាតក រឿងសត្វចាបចៀបកប្បាស ។ កាលត្រាស់ជាតកទាំងបីរឿង ដើម្បីរម្ងាប់ការឈ្លោះគ្នាយ៉ាងនេះហើយ ដើម្បីប្រយោជន៍ការទូន្មានដល់សេចក្តីព្រមព្រៀងគ្នា ទើបបានត្រាស់ជាតកពីររឿង ( ទៀត ) ។ ត្រាស់យ៉ាងណា ត្រាស់ថាមហាបពិត្រទាំងឡាយ ! ក៏នរណាៗ មិនអាចនឹងឃើញចំណុចខ្សោយរបស់ពួកអ្នកព្រមព្រៀងគ្នាបាន ហើយត្រាស់រុក្ខធម្មជាតក ។ តពីនោះត្រាស់ថា មហាបពិត្រទាំងឡាយ នរណាៗ មិនអាចឃើញចំណុចខ្សោយរបស់ពួកអ្នកព្រមព្រៀងគ្នាបាន តែកាលពួកគេបានធ្វើការវិវាទគ្នានិងគ្នាកាលនោះ កូនព្រាន ក៏សម្លាប់គេទាំងនោះកាន់យកទៅ ដែលឈ្មោះថាសេចក្តីរីករាយ រមែងមិនមានក្នុងការវិវាទគ្នា ហើយត្រាស់ជាតករឿងសត្វក្រួច លុះត្រាស់ជាតកទាំង ៥ រឿងនេះ ស្រេចហើយ ចុងបញ្ចប់ទ្រង់ត្រាស់រឿងអត្តទណ្ឌសូត្រ ។

ព្រះរាជាទាំងឡាយទ្រង់ជ្រះថ្លា ត្រាស់ថា បើព្រះសាស្តាស្តេចមិនបានយាងមក ពួកយើងក៏នឹងសម្លាប់គ្នាឯងដោយដៃរបស់ខ្លួន ហើយធ្វើឲ្យទន្លេឈាមហូរទៅ ពួកយើងនឹងមិនគប្បីឃើញកូន និងបងប្អូនរបស់យើងត្រង់ទ្វារផ្ទះ ពួកយើងនឹងមិនបានមានសូម្បីតែអ្នកនាំសារឆ្លើយឆ្លងគ្នា ពួកយើងបានជីវិត ព្រោះអាស្រ័យព្រះសាស្តា ក៏បើព្រះសាស្តានឹងទ្រង់គ្រប់គ្រងផ្ទះ រាជសម្បត្តិក្នុងទ្វីបធំបួន ដែលមានទ្វីបតូចពីរពាន់ជាបរិវារ ក៏គង់នឹងបាននៅក្នុងកណ្តាប់ព្រះហស្តរបស់ព្រះអង្គ កូនៗ របស់ពួកយើងទាំងពាន់នាក់ជាង ក៏នឹងបានមាន និងតពីនោះ ព្រះអង្គក៏នឹងមានក្សត្រជាបរិវារហែហមទៅ តែព្រះអង្គមក ទ្រង់លះបង់សម្បត្តិនោះហើយ ទ្រង់ចេញទៅសម្រេចព្រះសម្ពោធិញ្ញាណហើយ ឥឡូវនេះ ក៏សូមឲ្យទ្រង់មានក្សត្រជាបរិវារត្រាច់ទៅ ដូច្នេះ ។ ក្សត្រទាំងពីរនគរ ក៏បានថ្វាយព្រះកុមារ ម្ខាង ២៥០ អង្គ ។ ព្រះមានព្រះភាគ ទ្រង់ឲ្យព្រះកុមារទាំងនោះបួសហើយ ក៏ស្តេចយាងទៅព្រៃធំ ព្រោះសេចក្តី ដែលលោកទាំងនោះគោរពយ៉ាងជូន់សេចក្តីមិនត្រេកអរ ទើបបានកើតដល់ពួកអ្នកដែលមិនបានបួសតាមសេចក្តីពេញចិត្តរបស់ខ្លួន ។ សូម្បីពួកភរិយាចាស់របស់អ្នកទាំងនោះ ក៏និយាយពាក្យជាដើមថា សូមឲ្យព្រះអយ្យបុត្តទាំងឡាយចូរសឹកចុះ ការគ្រប់គ្រង

ផុះ ទ្រង់នៅមិនបានឬ ហើយក៏បញ្ជូនដំណឹងទៅ ។ ពួកលោកក៏អផ្សុកក្រៃលែងឡើងទៀត ។ ព្រះមានព្រះភាគ ទ្រង់ពិចារណាហើយ ក៏ទ្រង់ជ្រាបសេចក្តីមិនត្រេកអររបស់ពួកអ្នកទាំងនោះ ទ្រង់គិតថា ពួកភិក្ខុទាំងនេះនៅរួមគ្នានឹងព្រះពុទ្ធដូចតថាគត ញុំាងសេចក្តីអផ្សុក ដូចម្តេច ? តថាគតនឹងពោលសរសើរស្រះតាវៅដល់ពួកអ្នក ហើយក៏ទ្រង់នាំទៅកាន់ទីនោះ ទ្រង់ព្រះចិន្តាថា តថាគតនឹងបន្ទោបង់សេចក្តីមិនត្រេកអរ ទើបទ្រង់ពោលគុណរបស់ស្រះតាវៅ ។ ពួកភិក្ខុទាំងនោះ ក៏ជាអ្នកចង់ឃើញស្រះនោះ ។ ព្រះមានព្រះភាគ ត្រាស់សួរថា ភិក្ខុទាំងឡាយ ! ពួកអ្នកចង់ឃើញស្រះតាវៅឬ ។ ពួកភិក្ខុក្រាបទូលថា ព្រះករុណាព្រះអង្គ ។ បើដូច្នោះមក ពួកយើងទៅ ។ បពិត្រព្រះមានព្រះភាគ ! ពួកខ្ញុំព្រះអង្គនឹងទៅកាន់ទីដែលទៅរបស់ពួកលោកអ្នកមានឫទ្ធិបានយ៉ាងណា ។ ពួកអ្នកប្រាថ្នាចង់ទៅស្រះនោះ តថាគតនឹងនាំទៅដោយអានុភាពរបស់តថាគត ។ ព្រះករុណាព្រះអង្គ ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់នាំភិក្ខុ ៥០០ រូប ហោះទៅក្នុងអាកាស ចុះត្រង់ទីជិតស្រះតាវៅ និងត្រាស់ចំពោះភិក្ខុទាំងនោះថា ភិក្ខុទាំងឡាយ ! ស្រះតាវៅនេះ អ្នកណាមិនស្គាល់ឈ្មោះពួកត្រី ចូរសួរ

តថាគត ។ ភិក្ខុទាំងនោះទូលសួរហើយ ។ ព្រះមានព្រះភាគ ក៏ត្រាស់ប្រាប់វត្ថុ ដែលភិក្ខុសួរហើយសួរទៀត ។ និងមិនមែនតែឈ្មោះពួកត្រីប៉ុណ្ណោះ ទ្រង់ឲ្យសួរដល់ឈ្មោះរបស់ដើមឈើទាំងឡាយ ក្នុងដងព្រៃនោះផង របស់សត្វជើងពីរ ជើងបួន និងសត្វត្រង់ជើងក្នុំផង ហើយទ្រង់ក៏ប្រាប់ ។

គ្រានោះ ស្តេចសត្វតាវៅ ចាប់សត្វបក្សីពីរក្បាល ត្រង់កំណាត់ឈើ ប្រើចំពុះខាំពាំទុក មានពួកសត្វចោមរោមពីមុខពីក្រោយទាំងពីរខាងកំពុងមក ។ កាលភិក្ខុបានឃើញសត្វនោះ ក៏ទូលសួរថា ព្រះអង្គ ! នោះជាស្តេចបក្សីរបស់សត្វទាំងនេះ ខ្ញុំព្រះករុណាទាំងឡាយយល់ថា ពួកបក្សីទាំងនេះ ជាបរិវាររបស់ស្តេចបក្សីនោះ ។ ភិក្ខុទាំងឡាយ ! ប្រការនោះ យ៉ាងនោះឯង សូម្បីនេះ ក៏ជាវង្សរបស់តថាគត ជាប្រពៃណីរបស់តថាគត ។ ព្រះអង្គ ! ពួកខ្ញុំព្រះអង្គនឹងមើលសត្វទាំងនេះ ត្រឹមតែម្តងក៏ពួកខ្ញុំព្រះអង្គចង់នឹងស្តាប់ ប្រការដែលព្រះមានព្រះភាគត្រាស់ថា សូម្បីនេះ ក៏ជាវង្សរបស់តថាគត ជាប្រពៃណីរបស់តថាគត ។ ចង់ស្តាប់ឬភិក្ខុទាំងឡាយ ។ ព្រះករុណា ព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ថា បើបើដូច្នោះ ចូរស្តាប់ ហើយក៏ត្រាស់ជាតករឿងសត្វតាវៅ ប្រដាប់ដោយគាថា

៣០០ ទ្រង់បន្ទោបង់សេចក្ដីមិនត្រេកអរ កាលចប់ទេសនា ភិក្ខុទាំងនោះ ក៏តាំងនៅក្នុងសោតាបត្តិផលគ្រប់រូប និងសូម្បីតែឫទ្ធិរបស់ភិក្ខុទាំងនោះ ក៏មកព្រមនឹងមគ្គនុ៎ះឯង ។ ព្រះមានព្រះភាគ ទ្រង់ត្រិះរិះថា សម្រាប់ភិក្ខុទាំងនេះត្រឹមតែប៉ុណ្ណេះសិនចុះ ហើយក៏ទ្រង់ហោះទៅក្នុងអាកាស ស្ដេចទៅកាន់ព្រៃជំនុ៎ះឯង ។ សូម្បីភិក្ខុទាំងនោះ វេលាទៅ ក៏ទៅដោយអំណាចរបស់ព្រះទសពល តែវេលាមកហែហមព្រះមានព្រះភាគ ចុះកាន់ក្នុងព្រៃជំមកដោយអំណាចរបស់ខ្លួនឯង ។

ព្រះមានព្រះភាគ ប្រថាប់លើទីអង្គុយដែលក្រាលទុកហើយ ត្រាស់ហៅភិក្ខុទាំងនោះ ហើយត្រាស់ថា ភិក្ខុទាំងឡាយ ចូរមកអង្គុយចុះ តថាគតនឹងប្រាប់កម្មដ្ឋាន ដើម្បីឲ្យពួកអ្នកលះកិលេស ដែលត្រូវលះដោយមគ្គបីខាងលើ ហើយក៏ទ្រង់ប្រាប់កម្មដ្ឋាន ។ ពួកភិក្ខុនាំគ្នាគិតថា ព្រះមានព្រះភាគទ្រង់ជ្រាបថា ពួកយើងមិនមានសេចក្ដីត្រេកអរ ទើបទ្រង់នាំទៅស្រះតាវៅ ទ្រង់បន្ទោបង់សេចក្ដីមិនត្រេកអរ ឥឡូវនេះ ទ្រង់បានប្រទានកម្មដ្ឋានសម្រាប់មគ្គទាំងបីក្នុងទីនេះដល់ពួកយើង ដែលសម្រេចសោតាបត្តិផលក្នុងទីនោះហើយ ឯពួកយើងមិនគួរឲ្យវេលាកន្លងហួស ដោយគិតថា ពួកយើងជាព្រះសោតាបន្នហើយ ពួកយើងគួរជាឧត្តមបុរស ភិក្ខុទាំងនោះ ទើបសំពះ

ព្រះបាទារបស់ព្រះទសពល ហើយក្រោកឡើងចាកទីអង្គុយ បែកគ្នាទៅអង្គុយក្នុងទីញកភ្នំ និងគល់ឈើ ។ ព្រះមានព្រះភាគ ទ្រង់ព្រះតម្រិះថា ភិក្ខុទាំងនេះ សូម្បីដោយប្រក្រតី ក៏មិនចោលការងារ និងចំពោះភិក្ខុដែលបានឧបាយ នឹងមិនមានហេតុនៃការនឿយហត់ និងកាលទៅតាំងវិបស្សនា ហើយក៏បានសម្រេចអរហត្ត ក៏នឹងនាំគ្នាមកកាន់សម្នាក់តថាគត ដោយគិតថា ពួកយើងនឹងក្រាបទូលគុណវិសេស ដែលយើងម្នាក់ៗ បានចំពោះហើយ កាលពួកភិក្ខុទាំងនោះមកហើយ ពួកទេវតាក្នុងមុឺនចក្រវាឡ ក៏នឹងប្រជុំគ្នាក្នុងចក្រវាឡមួយ ការប្រជុំធំក៏នឹងមាន តថាគតគួរអង្គុយក្នុងទីស្ងាត់ ។ លំដាប់នោះ ក៏ត្រាស់បង្គាប់ឲ្យក្រាលពុទ្ធាសនៈក្នុងទីដែលស្ងាត់ ហើយប្រថាប់គង់ ។

ព្រះថេរៈដែលទទួលកម្មដ្ឋានមុនគេ សម្រេចព្រះអរហត្តព្រមទាំងបដិសម្ភិទាទាំងឡាយហើយ ។ ជាបន្តបន្ទាប់ ភិក្ខុដទៃទៀតក៏ដូច្នេះ ក៏បានជាភិក្ខុទាំង ៥០០ រូប រីកាយដូចបទុមដែលរីកក្នុងស្រះបទុម ដូច្នោះ ។ ភិក្ខុដែលសម្រេចព្រះអរហត្តមុនគេបង្អស់ គិតថា យើងនឹងក្រាបទូលដល់ព្រះមានព្រះភាគ ទើបក្រោកចាកទីអង្គុយ បែរមុខទៅរកព្រះទសពល ។ មួយរូបទៀតក៏យ៉ាងនោះ មួយរូបទៀតក៏យ៉ាងនោះ ដូច្នេះ ក៏ពោលបានថា

ភិក្ខុទាំង ៥០០ រូប ជាបន្តបន្ទាប់គ្នា ដូចចូលកាន់រោងអាហារ ដូច្នោះ ។ ភិក្ខុដែលមកមុនគេ សំពះ និងក្រាលទីអង្គុយ ហើយអង្គុយក្នុងទីដ៏សមគួរមួយ ជាអ្នកប្រាថ្នានឹងក្រាបទូលនូវគុណពិសេស ដែលបានដោយចំពោះ គិតថា អ្នកដទៃណាមាន ឬមិនមានហ្ន៎ បែរសម្លឹងមើលផ្លូវមក បានឃើញសូម្បីមួយរូបហើយមួយរូបទៀត ។ ដោយប្រការដូច្នេះ ជាការពោលបានថា លោកទាំងអស់នោះ ក៏មកអង្គុយក្នុងទីសមគួរមួយ ហើយក៏គិតផ្សេងគ្នាថា អង្គនេះកំពុងធុញទ្រាន់ ទើបមិនប្រាប់ដល់អង្គនេះ អង្គនេះ ក៏កំពុងធុញទ្រាន់ ទើបមិនប្រាប់ដល់អង្គនេះ បានឮថា ចំពោះពួកអ្នកអស់អាសវៈហើយ រមែងមានអាការពីរយ៉ាងគឺ ៖

១ កើតសេចក្តីគិតថា មនុស្សលោកព្រមទាំងទេវតា នឹងគប្បីដឹងច្បាស់នូវគុណវិសេស ដែលយើងបានចំពោះហើយ ដោយឆាប់រហ័សឬ ។

២ មិនប្រាថ្នានឹងប្រាប់គុណដែលខ្លួនបានហើយ ដល់អ្នកដទៃ ដូចអ្នកដែលបានកំណប់ទ្រព្យ ដូច្នោះ ។

ក៏កាលត្រឹមតែថា វង្សរបស់ព្រះអរិយៈនោះធ្លាក់ចុះហើយ ព្រះចន្ទពេញវង់ ដែលរួចផុតពីការដែលធ្វើឲ្យសៅហ្មង គឺ អ័ព្ទ ទឹកសន្សើមផ្សែង ធូលី រាហូ ចាកផុតព្រំដែនភ្នំយុគន្ធរនាទិសខាងកើត ប្រកបដោយ

សិរីនៃកង់ប្រាក់ ដែលកំពុងវិលទៅ ហាក់បីដូចជាវង់ពន្លឺដ៏ធំ ដែលសម្រេចដោយប្រាក់ អណ្តែតឡើងបំភ្លឺក្នុងទិសខាងកើត ដើម្បីទស្សនៈដែលជាទីគួររីករាយរបស់លោក ប្រដាប់ដោយពុទ្ធប្បាទ ដំណើរបណ្តោយទៅតាមផ្លូវខ្យល់ ។ ព្រះមានព្រះភាគ ប្រថាប់នៅត្រង់ព្រៃធំ ជិតក្រុងកបិលភស្តុ ក្នុងដែននៃពួកអ្នកសក្កៈ ជាមួយពួកភិក្ខុចំនួនច្រើន គឺ ភិក្ខុមានចំនួន ៥០០ រូប គ្រប់រូបសុទ្ធតែជាព្រះអរហន្តក្នុងខណៈ គឺ ក្នុងដ៏ឆាប់ បានដល់ ក្នុងវេលាមួយភ្លែតបែបនេះ ដោយប្រការដូច្នេះ ។

ក្នុងទីប្រជុំនោះ ព្រះមានព្រះភាគ ទ្រង់កើតក្នុងវង្សព្រះបាទមហាសម្មត ពួកភិក្ខុទាំង ៥០០ រូបនោះ ក៏កើតក្នុងត្រកូលព្រះបាទមហាសម្មត ព្រះមានព្រះភាគ ទ្រង់កើតក្នុងព្រះគភ៌ក្សត្រ ភិក្ខុទាំងនោះ ក៏កើតក្នុងគភ៌ក្សត្រ ព្រះមានព្រះភាគ ទ្រង់ជាអ្នកបួស ភិក្ខុទាំងនោះ ក៏ជាអ្នកបួស ព្រះមានព្រះភាគ ទ្រង់លះបង់ស្វេតឆត្រ ទ្រង់លះបង់រាជសម្បត្តិជាស្តេចចក្រពត្តិដែលនៅក្នុងព្រះហស្ត ទ្រង់ព្រះផ្នួស ភិក្ខុទាំងនោះក៏លះបង់ស្វេតឆត្រ បោលរាជសម្បត្តិដែលនៅក្នុងដៃ ហើយបួស ។ សេចក្តីដូចពោលមកនេះ ទើបពោលបានថា ព្រះមានព្រះភាគ ទ្រង់បរិសុទ្ធិ ទ្រង់មានបរិវារដែលបរិសុទ្ធិ ក្នុងឱកាសដែលបរិសុទ្ធិ ក្នុងចំណែករាត្រីដ៏បរិសុទ្ធិ ទ្រង់

ប្រាសចាករាគៈ ទ្រង់មានបរិវារដែលប្រាសចាករាគៈ ទ្រង់ប្រាសចាកទោសៈ ទ្រង់មានបរិវារដែលប្រាសចាកទោសៈ ទ្រង់ប្រាសចាកមោហៈ ទ្រង់មានបរិវារដែលប្រាសចាកមោហៈ ទ្រង់មិនមានតណ្ហា ទ្រង់មានបរិវារដែលមិនមានតណ្ហា ទ្រង់មិនមានកិលេស ទ្រង់មានបរិវារដែលមិនមានកិលេស ទ្រង់ស្ងប់ ទ្រង់មានបរិវារដែលស្ងប់ ទ្រង់ហ្វឹកហាត់ហើយ ទ្រង់មានបរិវារដែលទូន្មានហើយ ទ្រង់រួចផុតហើយ ទ្រង់មានបរិវារដែលរួចផុតហើយ ទ្រង់រុងរឿងគ្មានអ្វីប្រៀបផ្ទឹម ដោយប្រការដូច្នេះ ។ នេះឈ្មោះថា ជាប្រភេទវណ្ណៈអាចនិយាយបានប៉ុនណា ក៏គប្បីនិយាយប៉ុណ្ណោះ ។ ដូចពោលមកនេះ ព្រះអានន្ទ សំដៅយកភិក្ខុទាំងនេះ ទើបពោលថា គឺ ភិក្ខុមានចំនួន ៥០០ រូប គ្រប់អង្គសុទ្ធតែជាព្រះអរហន្ត ។

បទថា **ដោយច្រើន** គឺ ច្រើនជាង ប្រជុំគ្នាហើយ ដែលតិចវៀរលែងតែទេវតាមិនមានសញ្ញា ទេវតាជាន់អរូបាវចរ និងទេវតាដែលចូលសមាបត្តិ មិនបានចូលប្រជុំ ។ តទៅនេះ ជាលំដាប់ការចូលប្រជុំក្នុងមហាសមយសូត្រនោះ ។

ដំណាលមកថា ពួកទេវតាដោយជុំវិញព្រៃធំញាប់ញ័រហើយ ធ្វើសំឡេងខ្លាំងៗ ថា មកចុះអ្នកដ៏ចម្រើនទាំងឡាយ ឈ្មោះថា ការឃើញ

ព្រះពុទ្ធមានឧបការៈច្រើន ការស្តាប់ព្រះធម៌មានឧបការៈច្រើន ការឃើញពួកភិក្ខុមានឧបការៈច្រើន មក មកចុះពួកយើង ហើយក៏នាំគ្នាមកនមស្ការព្រះមានព្រះភាគ និងពួកព្រះខីណាស្រពអ្នកសម្រេចព្រះអរហត្តក្នុងវេលាមួយរំពេចនោះ ហើយឈរក្នុងទីសមគួរមួយ ។ ដោយឧបាយនេះនោះឯងគប្បីជ្រាបថា ពួកទេវតាទាំងឡាយក្នុងសែនចក្រវាឡមកប្រជុំគ្នា ព្រោះស្តាប់សំឡេងទេវតាទាំងនោះ ដោយលំដាប់ គឺ ទេវតាដែលនៅក្នុងចក្រវាឡទាំងអស់ ដែលនៅក្នុងសកលជម្ពូទ្វីប បុព្វវិទេហទ្វីប អមរគោយានទ្វីបឧត្តរកុរុទ្វីប ក្នុងទ្វីបតូចពីរពាន់ គឺ ពួកទេវតាដែលអាស្រ័យនៅក្នុងព្រៃហិមពាន្តដែលមានទទឹងប្រមាណបីពាន់យោជន៍ ដោយស្តាប់សំឡេងទេវតាអ្នកអាស្រ័យនៅក្នុងទីកន្ទះគាវុត មួយគាវុត កន្ទះយោជន៍ មួយយោជន៍ដោយលំដាប់ តគ្នាទៅ ទេវតាក្នុងនគរ ១៨៩,០០០ នគរ ទេវតានៅត្រង់ទោណមុខ ៩,៩០០,០០០ កន្លែង ទេវតានៅត្រង់បដនៈ ៩៦ សែនកោដិនិងអាស្រ័យនៅត្រង់សមុទ្រ ៥៦ កន្លែង មកប្រជុំគ្នាហើយ អំពីនោះក៏ទេវតាក្នុងចក្រវាឡទីពីរ ទីបីជាដើម ក៏មកប្រជុំគ្នាដោយប្រការដូច្នេះ ។ ក៏មុឺនចក្រវាឡ លោកសំដៅយកថា ១០ លោកធាតុ ក្នុងទីនេះ ។ ហេតុនោះ លោកទើបពោលថា ទេវតាមកពី ១០ លោកធាតុ ដោយច្រើន

ជាអ្នកចូលរួមប្រជុំហើយ ។

ផ្ទៃចក្រវាឡទាំងអស់ ដរាបដល់ព្រហ្មលោក ពោរពេញទៅដោយពួកទេវតាដែលចូលប្រជុំយ៉ាងនោះ ដូចបំពង់ម្សៅដែលពេញទៅដោយម្សៅ ដាក់ទៅដរាបរកទីដាក់មិនបាន ។ ក្នុងផ្ទៃចក្រវាឡទាំងអស់នោះ គប្បីជ្រាបថា ដែលខ្ពស់ជាងគេ បានដល់ ផ្ទៃចក្រវាឡរបស់ព្រហ្មលោក ។ ដំណាលមកថា អ្នកឈរក្នុងព្រហ្មលោក យកដុំថ្មប៉ុនផ្ទះកំពូល ៧ ជាន់ ក្នុងលោហប្រាសាទ បោះចុះក្រោម បួនខែ ទើបដល់ផែនដី ។ ក្នុងឱកាសធំបែបនោះ មានទេវតាដរាបរកទីដាក់មិនបាន ដូចផ្កាឈើ ដែលអ្នកឈរខាងក្រោមបោះទៅ ឬដូចផ្សែងមិនមានផ្លូវដើម្បីហុយឡើងទៅខាងលើ ឬដូចគ្រាប់ស្ពៃដែលអ្នកឈរខាងលើ រោយទៅ មិនមានប្រហោងដើម្បីធ្លាក់ចុះក្រោម ដូច្នោះ ។ ក៏ការប្រថាប់គង់របស់ព្រះមានព្រះភាគ មិនចង្អៀតដល់ពួកទេវតា និងពួកព្រហ្មដែលមានសក្តិធំ ដែលមកហើយនោះៗ រមែងបានចន្លោះគ្រប់អង្គ ដូចការប្រថាប់អង្គុយរបស់ស្តេចចក្រពត្តិ រមែងជាទីមិនចង្អៀតដល់ពួកក្សត្រជាអ្នកធំ ដែលស្តេចមកហើយនោះៗ ទ្រង់ក៏ញ៉ាំងនូវចន្លោះក្នុងទីទុំះឯង ដូច្នោះ ។ អើក៏មានដំណាលមកថា ប្រទេសសូម្បីខ្នាតប៉ុនចុងរោមទ្រាយ តាមន័យដែលពោលទុក ក្នុងមហាបរិនិព្វានសូត្រ

ក្នុងទីជិតព្រះមានព្រះភាគទ្រង់ឯង ក៏នៅមានទេវតា ១០ អង្គខ្លះ ២០ អង្គខ្លះ និម្មិតរាងកាយតូចល្អិតឈរ ។ ខាងមុខទាំងអស់មានទេវតា ៦០ ៗ អង្គឈរហើយ ។

បទថា **ពួកជាន់សុទ្ធាវាស** គឺ ព្រហ្មសុទ្ធាវាស ។ ព្រហ្មលោក ៥ ជាន់ ដែលជាទីនៅរបស់ព្រះអនាគាមី និងព្រះខីណាស្រពអ្នកបរិសុទ្ធិ ឈ្មោះថា **សុទ្ធាវាស** ។ ពាក្យថា **ដែលមានពាក្យត្រិះរិះ** គឺ ដូចម្តេចទើបមាន ។ បានឮថា ក្នុងគ្រានោះ ពួកព្រហ្មទាំងនោះ ចូលសមាបត្តិហើយ ចេញតាមកំណត់ កាលសម្លឹងមើលទីនៅរបស់ព្រហ្ម ក៏បានឃើញទំនេរ ដូចរោងអាហារក្នុងវេលាក្រោយអាហារ ពេលនោះពិចារណាថា ពួកព្រហ្មទៅណា ក៏ជ្រាបថា ទៅទីកាន់ប្រជុំធំ គិតថា សមាគមនេះធំ ចំណែកពួកយើងវល់តែបង្អែបង្អង់ ក៏សម្រាប់ពួកអ្នកបង្អែបង្អង់នឹងរកឱកាសបានលំបាក ព្រោះដូច្នោះ កាលនឹងទៅ ពួកយើងកុំមានដៃទទេ ក៏តែងគាថាមួយអង្គមួយបទ ហើយសឹមទៅ ពួកយើងនឹងឲ្យព្រះមានព្រះភាគទ្រង់ជ្រាបថា ខ្ញុំនមកក្នុងសមាគមដូចគ្នាដោយគាថានោះ និងនឹងពោលព្រះកិត្តិគុណរបស់ព្រះទសពលផង ។ សេចក្តីត្រិះរិះយ៉ាងនេះ ទើបមាន ព្រោះការមានព្រហ្មទាំងនោះ ចេញចាកសមាបត្តិហើយ ពិចារណាដោយប្រការដូច្នេះ ។

បទថា **ប្រាកដចំពោះព្រះភក្ត្រព្រះមានព្រះភាគ** សេចក្តីថា លោកធ្វើព្រហ្ម ទាំងនោះ ឲ្យដូចធ្លាក់ចុះក្នុងទីចំពោះព្រះភ័ក្ត្រ ជិតព្រះមានព្រះភាគទុំះឯង ពោលទុកហើយក្នុងបាលី តែក្នុងទីនេះ មិនគប្បីយល់សេចក្តីយ៉ាងនេះ ឡើយ ។

ក៏ព្រហ្មទាំងនោះ ឋិតនៅក្នុងព្រហ្មលោក តែងគាថាស្រេចហើយ មួយអង្គចុះត្រង់កណ្តាប់ចក្រវាឡខាងកើត មួយអង្គចុះត្រង់កណ្តាប់ចក្រ-វាឡខាងត្បូង មួយអង្គចុះត្រង់កណ្តាប់ចក្រវាឡខាងលិច មួយអង្គចុះត្រង់ កណ្តាប់ចក្រវាឡខាងជើង ។ តពីនោះ ព្រហ្មដែលចុះត្រង់កណ្តាប់ចក្រ-វាឡខាងកើត ក៏ចូលនីលកសិណ បញ្ចេញនូវរស្មីពណ៌ខៀវ បីដូចជា ដណ្តប់ស្បែករំលេចដោយកែវមណី ហើយបង្ហាញខ្លួនដល់ទេវតាក្នុងម៉ឺន ចក្រវាឡឲ្យដឹងថា ខ្លួនមកហើយ ធម្មតាវិធីរបស់ព្រះពុទ្ធ មិនមាននរណា អាចនឹកនូងទៅបាន ព្រោះដូច្នោះ ទើបមកដោយវិធីរបស់ព្រះពុទ្ធ ដែល ប៉ះខ្ទប់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ឋិត (ឈរ) នៅក្នុងទីដ៏សមគួរ ក៏ពោលនូវគាថាដែលខ្លួនបានតែង ។ ព្រហ្មដែលចុះត្រង់កណ្តាប់ចក្រវាឡ ផ្នែកខាងត្បូង ក៏ចូលបីតកសិណ បញ្ចេញរស្មីមានពន្លឺដូចមាស ដូចជា ដណ្តប់សំពត់មាស បង្ហាញខ្លួនដល់ទេវតាក្នុងម៉ឺនចក្រវាឡឲ្យដឹងថា ខ្លួន

មកហើយឋិតនៅ ក្នុងទីនោះឯងដែរ ។ ព្រហ្មដែលចុះត្រង់កណ្តាលចក្រវាឡ ខាងលិច ចូលលោហិតកសិណ បញ្ចេញរស្មីក្រហម ដូចដណ្តប់សំពត់រោមសត្វប្រភេទល្អ ពណ៌ក្រហម បង្ហាញខ្លួនដល់ទេវតាក្នុងម៉ឺនចក្រវាឡ ឲ្យដឹងថា ខ្លួនមកហើយឋិតនៅ ដូច្នោះដែរ ។ ព្រហ្មដែលចុះត្រង់កណ្តាលចក្រវាឡផ្នែកខាងជើង ចូលឱទាតកសិណ បញ្ចេញរស្មីពណ៌ស បីដូចដណ្តប់សំពត់ផ្កាម្លិះ បង្ហាញខ្លួនដល់ទេវតាក្នុងម៉ឺនចក្រវាឡ ឲ្យដឹងថាខ្លួនមកហើយឋិតនៅ ដូច្នោះដែរ ។ តែក្នុងបាលី លោកពោលថា ៖

ព្រហ្មទាំងឡាយនោះ ប្រាកដក្នុងទីចំពោះព្រះភក្ត្រព្រះមានព្រះភាគថា គ្រានោះទេវតាទាំងនោះ ក៏ថ្វាយបង្គំព្រះមានព្រះភាគហើយ ឈរក្នុងទីដ៏សមគួរមួយ ដូច្នេះ ហើយបានពោលសេចក្តីប្រាកដខាងមុខ និងការអភិវាទ ហើយឈរក្នុងទីដ៏សមគួរមួយ ដូចគ្នា ក្នុងខណៈតែមួយ ដូច្នោះ ។

ការប្រាកដ និងការឈរបានមានតាមលំដាប់នេះ តែលោកធ្វើឲ្យព្រមគ្នា សម្តែងទុកហើយ ។ ចំណែកការពោលគាថាក្នុងបាលី លោកចែកពោលទុកជាផ្នែក ៗ តែម្យ៉ាង ។

## គាថានីមួយ ៗ នៃទេវតាជាន់សុទ្ធាវាស

[៧៤] ក្នុងបទទាំងនោះ បទថា **មហាសម័យ** ប្រែថា ការប្រជុំធំ ។ ព្រៃក្រាស ហៅថា **ព្រៃធំ** ព្រះមានព្រះភាគត្រាស់ថា ការប្រជុំធំ គឺ ការចូលប្រជុំព្រមគ្នាគ្រាធំ មានក្នុងថ្ងៃនេះនាព្រៃក្រាស់នេះ សូម្បីដោយបទទាំងពីរ ។ តពីនោះ ដើម្បីសម្ដែងពួកដែលចូលប្រជុំនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា **ពពួកទេពមកប្រជុំគ្នាហើយ** ។ ក្នុងបទថា **ពពួកទេព** នោះ គឺ ពួកទេវតា ។ បទថា **ពួកយើងជាអ្នកមកកាន់ប្រជុំនេះ** គឺ កាលបានឃើញពួកទេពមកប្រជុំគ្នាយ៉ាងនេះ សូម្បីពួកយើង ក៏មកកាន់ការប្រជុំធម៌នេះ ។ ព្រោះហេតុណា ព្រោះហេតុដើម្បីឃើញពួកបុគ្គលដែលមិនមាននរណាបៀតបៀនបានទុ៎ះឯង អធិប្បាយថា ពួកយើងមកដើម្បីសរសើរពួកបុគ្គលដែលមិនមានអ្នកណាបង្ក្រាបបាន នេះអ្នកបានឈ្មោះថា **ពិជិតសង្គ្រាម** ព្រោះជាបុគ្គលដែលមិនមាននរណាផ្ដាលផ្ដាញ់បាន ហើយញាំញីមារទាំងបីប្រភេទបានក្នុងថ្ងៃនេះ ទុ៎ះឯង ។ ក៏ព្រហ្មនោះ គ្រាពោលគាថានេះហើយ ក៏អភិវាទព្រះមានព្រះភាគ បានឈរត្រង់កណ្ដាប់ចក្រវាឡខាងកើត ។ តមកអន្ទុទីពីរ ក៏មកពោលតាមន័យដែលពោលហើយទុ៎ះឯង ។

[៧៥] ក្នុងបទថា **ភិក្ខុទាំងឡាយក្នុង.....នោះ** នោះបានដល់ ពួកភិក្ខុក្នុងទីប្រជុំនោះ ។ បទថា **តម្កល់មាំហើយ** គឺ ប្រកបដោយសមាធិ ។

បាទគាថាថា **បានធ្វើចិត្តរបស់ខ្លួនឲ្យត្រង់ហើយ** បានដល់ បាននាំចិត្តវៀចនិងចិត្តកោងចេញជាកបដល់អស់ ហើយធ្វើចិត្តរបស់ខ្លួនឲ្យត្រង់ ។ បាទគាថា ថា **ដូចជាសារថីកាន់ខ្សែ** សេចក្តីថា កាលពួកសេះសិន្ធពទៅយ៉ាងរៀបរយ សារថីដាក់ជន្លួញចុះ ហើយចាប់ខ្សែទាំងអស់ទុក មិនដាស់តឿនមិនបញ្ឈប់ តាំងនៅយ៉ាងណា ភិក្ខុទាំង ៥០០ នេះ ដល់ព្រមដោយភាពប្រសើយមានអង្គ ៦ ឃុំគ្រងទ្វារបានហើយ បណ្ឌិតរក្សាឥន្ទ្រិយទាំងឡាយទុកដូច្នោះ ព្រហ្មពោលថា បពិត្រព្រះមានព្រះភាគ ពួកខ្ញុំព្រះអង្គ ជាអ្នកមកទីនេះ ដើម្បីសរសើរភិក្ខុទាំងនេះ ។ ហើយព្រហ្មទាំងនោះ ក៏ទៅឈរតាមតំណែងរៀងខ្លួន ។ បន្ទាប់មក អង្គទីបី ក៏មកពោលតាមន័យដែលពោលហើយនុ៎ះឯង ។

[៧៦] ក្នុងបទទាំងនោះ បទថា **កាត់ដែកគោលបានហើយ** គឺ កាត់ដែកគោល បានដល់ រាគៈ ទោសៈ និងមោហៈ ។ បទថា **រនុក** បានដល់ រនុក គឺ រាគៈ ទោសៈ និងមោហៈនុ៎ះឯង ។ បទថា **សសរគោល** បានដល់ សសរគោល គឺ រាគៈ ទោសៈ និងមោហៈនុ៎ះឯង ។ បទថា **គាស់រំលើងសសរគោល** គឺ ពួកភិក្ខុឈ្មោះថា មិនញាប់ញ័រ ព្រោះមិនមានការញាប់ញ័រ គឺ តណ្ហាដកហើយ គឺ គាស់រំលើងសសរ

គោលបានហើយ ។ បទថា **លោកទាំងនោះត្រាច់ទៅ** គឺ ចារិកទៅដោយការមិនទើសទាក់នឹងនរណាៗ ក្នុងទិសទាំង ៤ ។ បទថា **បរិសុទ្ធិ** គឺ មិនមានអ្វីដែលចូលមកធ្វើឲ្យចិត្តចិត្តសៅហ្មង ។ បទថា **ប្រាសចាកមន្ទិល** គឺ មិនមានមន្ទិល ។ ពាក្យថា **ប្រាសចាកមន្ទិល** នេះ ក៏ជាពាក្យសម្រាប់ប្រើជំនួសពាក្យថា **បរិសុទ្ធ** នុ៎ះឯង ។ បទថា **មានភ្នែក** គឺ មានភ្នែកដោយភ្នែក ៥ ប្រភេទ ។ បទថា **ទូន្មានហើយយ៉ាងល្អ** គឺ ផ្លូវភ្នែកទូន្មានហើយ ផ្លូវត្រចៀក ផ្លូវច្រមុះ ផ្លូវអណ្តាត ផ្លូវកាយ ផ្លូវចិត្តក៏ទូន្មានហើយ ។ បទថា **នាគកំលោះ** គឺ នាគជំទង់ ៗ ។ ព្រហ្ម អធិប្បាយថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គជាអ្នកមកហើយ ដើម្បីសរសើរនាគជំទង់ដែលទូន្មានហើយដោយសេចក្តីព្យាយាម ជាគ្រឿងប្រកបដ៏កំពូលបែបនេះ ទាំងនេះ ។ សូម្បីព្រហ្មអង្គនោះ ក៏បានទៅឈរតាមតំណែងនុ៎ះឯង ។

[៧៧] បន្ទាប់មកអង្គទីបួន ក៏បានមកពោលតាមន័យដែលពោលហើយនុ៎ះឯង ។

បណ្តាបទទាំងនោះ បទថា **ដល់ហើយ** គឺ ដល់ហើយដោយការដល់សរណៈដែលមិនមានសេចក្តីសង្ស័យ ។ សូម្បីព្រហ្មអង្គនោះ ក៏បានទៅឈរតាមតំណែងនុ៎ះឯង ។

លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់បានត្រួតមើលតាំងពីផ្ទៃផែនដី ដរាបទល់នឹងកំណាត់កណ្ដាប់ចក្រវាឡ ពីកណ្ដាប់ចក្រវាឡដរាបទល់នឹងព្រហ្មលោក ទតឃើញការប្រជុំរបស់ទេវតាហើយ ទើបទ្រង់ព្រះតម្រិះថា សមាគមទេវតានេះធំ ។ ចំណែកពួកភិក្ខុមិនជ្រាបថា សមាគមទេវតានេះ ធំយ៉ាងនេះ ណ្ហើយចុះ តថាគតនឹងប្រាប់ពួកអ្នក កាលទ្រង់ត្រិះរិះយ៉ាងនោះស្រេចហើយ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុ ដោយប្រការដូច្នេះ ។ គប្បីពង្រីកសេចក្ដីឲ្យទូលាយទាំងអស់ ។

[៧៨] បណ្ដាពាក្យទាំងនោះ ពាក្យថា **មានប្រមាណ យ៉ាងក្រៃលែង** គឺ ឈ្មោះថា មានត្រឹមប៉ុណ្ណោះយ៉ាងក្រៃលែង ព្រោះប៉ុណ្ណោះជាប្រមាណយ៉ាងក្រៃលែង របស់ព្រះពុទ្ធទាំងនោះ ។ ព្រោះកាលឥឡូវនេះ មិនមានព្រះពុទ្ធទាំងឡាយ ទើបមិនត្រាស់ជាលើកទីបីថា "ម្នាលភិក្ខុទាំងឡាយ សូម្បីព្រះពុទ្ធជាម្ចាស់ទាំងនោះ ក្នុងកាលឥឡូវនេះ" ។ បទថា **ម្នាលភិក្ខុទាំងឡាយ តថាគតនឹងប្រាប់** សេចក្ដីថា សួរថា ហេតុដូចម្ដេចទើបត្រាស់ឆ្លើយថា ដើម្បីឲ្យជ្រាបការព្រមព្រៀងនៃចិត្តរបស់ពួកទេវតា បានឮថា ពួកទេវតានាំ គ្នាគិតថា ព្រះមានព្រះភាគទ្រង់នឹងពោលឈ្មោះ និងគោត្រតែពួកទេវតាថ្នាក់ធំប៉ុណ្ណោះ ឯពួកទេវតាថ្នាក់តូច ទ្រង់នឹងប្រាប់នៅក្នុង

សមាគមធំនេះ ដូចម្តេចបាន ។ ក្លាមនោះ ព្រះមានព្រះភាគទ្រង់ពិចារណាថា ទេវតាទាំងនេះគិតយ៉ាងណា ទ្រង់ជ្រាបវារៈចិត្តនោះ របស់ទេវតាទាំងនោះ ដូចសឹកដែចូលមាត់ហើយស្ទាបអន្លើលដូងចិត្ត និងដូចចាប់ចោរបានទាំងរបស់ ទើបទ្រង់ត្រិះរិះថា តថាគតនឹងពោលដល់ឈ្មោះ និងគោត្ររបស់ពួកទេវតាសូម្បីទាំងអស់ ទាំងថ្នាក់តូច និងថ្នាក់ធំ ដែលនាំគ្នាមកពីម៉ឺនចក្រវាឡ ។

ធម្មតាថា ព្រះពុទ្ធទាំងឡាយទ្រង់ជាអ្នកធំ ព្រះពុទ្ធទាំងនោះទ្រង់ជាសត្វពិសេស ទ្រង់ជ្រាបវត្ថុដែលមនុស្សលោកព្រមទាំងទេវតាបានឃើញបានឮ បានជ្រាប បានដឹងច្បាស់ បានដល់ បានស្វែងរក បានប្រើចិត្តអន្ទោលទៅតាម មិនថា វត្ថុណា ៗ ក្នុងទីណា ៗ នឹងជារូបារម្មណ៍ក្នុងរូបារម្មណ៍ដែលចែកដោយអំណាចរូប មានរូបពណ៌ខៀវជាដើម ឬអារម្មណ៍ មានសំឡេងជាដើម ដែលចែកទុកជាផ្នែក ៗ ក្នុងសទ្ទារម្មណ៍ជាដើម ដែលចែកដោយអំណាចសំឡេងស្គរជាដើម មានហើយ ដែលមកកាន់គន្លងចំពោះព្រះញាណរបស់ព្រះពុទ្ធទាំងនោះ ។ សមពិតដូចដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ វត្ថុណាដែលមនុស្សលោកព្រមទាំងទេវតា ។ល។ រួមទាំងទេវតា និងមនុស្ស បានឃើញ បានឮ បានជ្រាប បាន

ដឹងច្បាស់ បានដល់ បានស្វែងរក បានប្រើចិត្តអន្ទោលទៅតាម តថាគត ដឹងវត្ថុនោះ តថាគតឃើញវត្ថុនោះ តថាគតយល់វត្ថុនោះយ៉ាងជាក់ច្បាស់ ។ ព្រះមានព្រះភាគ ទ្រង់មានព្រះញាណមិនមានអ្វីមករារាំងបាន ក្នុងគ្រប់គ្រា គ្រប់កន្លែងយ៉ាងនេះ ទ្រង់បានធ្វើពួកទេវតាសូម្បីទាំងអស់នោះ ជាពីរពួក ដោយអំណាចភព្វ និងអភព្វ គឺ ពួកដែលជាអភព្វសត្វ ដែលពោលដោយន័យជាដើមថា ឬសត្វពួកណាដល់ព្រមដោយទំនប់ គឺ កម្ម សត្វពួកនោះនឹងដល់ការនៅរួមវិហារគ្នា ព្រះពុទ្ធទាំងឡាយ ក៏ទ្រង់មិនមើល , និងពួកភព្វសត្វដែលផ្ទុយគ្នានឹងពួកអភព្វសត្វនោះ សូម្បីនៅឆ្ងាយ ក៏ស្ដេចទ្រង់យាងទៅសង្គ្រោះ ។ ព្រោះដូច្នោះ សូម្បីក្នុងការប្រជុំរបស់ទេវតានោះ ព្រះមានព្រះភាគ ទ្រង់លះពួកដែលអភព្វ ( មិនសមគួរ ដោគអាក្រក់ ) ហើយរួបរួមយកតែពួកភព្វសត្វ កាលរួបរួមយកស្រេចហើយ ទ្រង់ក៏ចាត់ជា ៦ ពួក តាមអំណាចចរិតនុ៎ះឯងថា ពួករាគចរិតប៉ុណ្ណោះ ពួកទោសចរិតប៉ុណ្ណោះ ជាដើម ។

តមកក៏ទ្រង់ពិចារណាធម៌ទេសនា ដែលជាទីសប្បាយដល់ពួកចរិតទាំងនោះ ទ្រង់កំណត់ទេសនាថា ពួកទេវតារាគចរិត នឹងសម្ដែងសម្មាបរិព្វាជនីយសូត្រ (សូត្រពោលអំពីរឿងដែលគប្បីវៀរដោយប្រពៃ) និង

សម្ដែងកលហវិវាទសូត្រ (សូត្រជាប់ទាក់ទងនឹងរឿងឈ្លោះវិវាទ) ដល់ពួកទោសចរិត និងសម្ដែងមហាព្យូហសូត្រ (សូត្រពោលអំពីពួកធំ) ដល់ពួកមោហចរិត និងសម្ដែងចូឡព្យូហសូត្រ (សូត្រពោលអំពីពួកតូច) ដល់ពួកវិតក្កចរិត និងសម្ដែងតុវដ្តកបដិបទា (ការបដិបត្តិរបស់សត្វ) ដល់ពួកសទ្ធាចរិត និងសម្ដែងបុរាភេទសូត្រ (សូត្រពោលអំពីរឿងបែកក្នុងអនាគត) ដល់ពួកពុទ្ធិចរិត ហើយក៏ទ្រង់ដាក់ព្រះទ័យដល់បរិស័ទនោះទៀតថា បរិស័ទគប្បីដឹងដោយអធ្យាស្រ័យរបស់ខ្លួន ដោយអធ្យាស្រ័យរបស់អ្នកដទៃ ដោយការកើតរឿងឡើង ឬដោយអំណាចការសួរហ្ន៎ តពីនោះក៏ទ្រង់ជ្រាបថា បរិស័ទគប្បីដឹងដោយអំណាចការសួរ ហើយទ្រង់ព្រះតម្រិះថា នឹងមានអ្នកណា ឬមិនហ្ន៎ ដែលជាអ្នកកាន់យកអធ្យាស្រ័យរបស់ពួកទេវតា ហើយអាចសួរបញ្ហាដោយអំណាចចរិតបាន ទ្រង់ឃើញថា ក្នុងពួកភិក្ខុតាំង ៥០០ រូបនោះ សូម្បីតែមួយរូប ក៏នឹងមិនអាច ។ បន្ទាប់ពីនោះ ទ្រង់រួមយកព្រះមហាសាវក ៨០ រូប និងព្រះសាវកថ្នាក់កំពូល ២ រូប ក៏ទ្រង់ឃើញថា សូម្បីលោកទាំងនោះ ក៏នឹងមិនអាច ហើយទ្រង់រំពឹងថា បើគប្បីមានព្រះបច្ចេកពុទ្ធ ព្រះបច្ចេកពុទ្ធនឹងអាចឬទេហ្ន៎ ទ្រង់ជ្រាបថា សូម្បីព្រះបច្ចេកពុទ្ធ ក៏នឹងមិនអាច ទ្រង់សរុបថា ក្នុងបណ្ដាស្ដេច

សក្កៈ និងស្តេចសុយាមៈជាដើម នរណា ៗ ក៏មិនអាច ប្រសិនបើក្នុងលោកទាំងនោះ នរណា ៗ នឹងគប្បីអាច នឹងឲ្យសួរព្រះអង្គហើយនឹងគប្បីឆ្លើយបាន មិនមាន ។ តែសូម្បីក្នុងលោកទាំងនោះ នរណា ៗ ក៏មិនអាច ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់មានព្រះតម្រិះយ៉ាងនេះថា ព្រះពុទ្ធដូចតថាគតប៉ុណ្ណោះ ទើបអាច តើមានព្រះពុទ្ធអង្គដទៃក្នុងទីណាខ្លះទេ ហើយក៏ទ្រង់ផ្សាយព្រះញាណដែលមិនមានទីបំផុត ទៅក្នុងលោក-ធាតុ ដែលមិនមានទីបំផុត ទ្រង់ពិចារណា ក៏ទ្រង់មិនបានឃើញព្រះពុទ្ធអង្គដទៃ ។ ប្រការដែលទ្រង់មិនឃើញអ្នកណាស្មើព្រះអង្គក្នុងឥឡូវនេះនោះមិនគួរអស្ចារ្យឡើយ សូម្បីក្នុងថ្ងៃប្រសូតិ កាលទ្រង់មិនឃើញអ្នកណាស្មើព្រះអង្គ តាមន័យដែលពោលទុកក្នុងអដ្ឋកថា "ព្រហ្មជាលសូត្រ" ព្រះអង្គក៏បានបន្លឺសីហនាទ ដែលមិនមានអ្នកណានឹងគប្បីបដិបត្តិបានថា យើងជាកំពូលរបស់លោក ដូច្នេះ ។ កាលទ្រង់មិនឃើញអ្នកដទៃស្មើនឹងព្រះអង្គយ៉ាងនេះហើយ ក៏ទ្រង់គិតថា បើតថាគតគប្បីសួរ ហើយឆ្លើយដោយខ្លួនឯង សូម្បីយ៉ាងនេះ ទេវតាទាំងនេះ ក៏នឹងមិនអាចចាក់ធ្លុះបាន ប៉ុន្តែបើព្រះពុទ្ធអង្គដទៃទន្ទឹះឯងទ្រង់សួរ និងតថាគតឆ្លើយ ទើបនឹងជាវត្ថុគួរអស្ចារ្យ និងពួកទេវតាក៏នឹងអាចចាក់ធ្លុះបាន ដូច្នោះ តថាគតនឹងនិម្មិត

ព្រះពុទ្ធនិម្មិត ។ ហើយទ្រង់ចូលឈានដែលមានអភិញ្ញាជាបាទ គ្រាទ្រង់ចេញហើយ ក៏ទ្រង់បរិកម្មដោយកាមាវចរចិត្តទាំងឡាយថា សូមឲ្យការកាន់បាត្រ និងចីវរ ការមើលទៅមុខ និងមើលមកក្រោយ និងការបត់ចូល និងលាចេញ ចូរដូចតថាគតតែម៉្យាង ហើយក៏ទ្រង់អធិដ្ឋានដោយរូបាវចរចិត្ត ដូចទំលាយដួងច័ន្ទដែលកំពុងដំណើរជុំវិញភ្នំយុគន្ធរ តាមទិសខាងកើត ឲ្យចេញចាកវង់ ដូច្នោះ ។

គ្រាពួកទេវតាបានឃើញពុទ្ធនិម្មិតនោះ ក៏និយាយថា ម្នាលគ្នាយើងព្រះចន្ទដួងដទៃរះទៀតហើយឬហ្ន៎ ។ កាលព្រះពុទ្ធនិម្មិត ទ្រង់អណ្តែតចូលមកជិត ក៏និយាយថា មិនមែនព្រះចន្ទ តែជាព្រះអាទិត្យរះឡើងទេ កាលចូលជិតមកទៀត ក៏និយាយថា មិនមែនព្រះអាទិត្យ នោះជាវិមានទេវតា ។ កាលចូលជិតមកទៀត ក៏និយាយថា មិនមែនវិមានទេវតា នោះជាទេវ-បុត្រ ។ កាលចូលជិតមកទៀត ក៏និយាយថា មិនមែនទេវបុត្រ នោះជាមហាព្រហ្ម កាលចូលជិតមកទៀត ក៏និយាយថា មិនមែនជាមហាព្រហ្មតែជាព្រះពុទ្ធមួយអង្គទៀត ស្តេចយាងមក ដូច្នេះ ។ ក្នុងទីនោះពួកទេវតាបុថុជ្ជន ក៏នាំគ្នាគិតថា ព្រះពុទ្ធតែមួយអង្គ ទីប្រជុំទេវតាក៏ធំយ៉ាងនេះហើយ ពីរព្រះអង្គនឹងធំយ៉ាងណា (ចំណែក) ទេវតាអរិយៈ ក៏នាំគ្នាគិតថា

ក្នុងលោកធាតុតែមួយ មិនមានព្រះពុទ្ធពីរព្រះអង្គ ព្រះមានព្រះភាគនោះឯង ទ្រង់និម្មិតព្រះពុទ្ធអង្គដទៃមួយព្រះអង្គទៀត ដែលដូចនឹងព្រះអង្គពិតៗ ។

ខណៈដែលពួកទេវតាកំពុងឃើញព្រះពុទ្ធនិម្មិតនុ៎ះឯង ព្រះពុទ្ធនិម្មិតក៏ស្តេចមកដល់ ទ្រង់មិនសំពះព្រះទសពលឡើយ ធ្វើឲ្យដូច ៗ គ្នា ក្នុងទីចំពោះព្រះភ័ក្ត្រ ហើយក៏ប្រថាប់អង្គុយលើទីអង្គុយ ដែលនិម្មិតទុក ។ មហាបុរិសលក្ខណៈ ៣២ ប្រការ សូម្បីរបស់ព្រះមានព្រះភាគ សូម្បីរបស់ព្រះពុទ្ធនិម្មិត ក៏មាន ៣២ ប្រការដូចគ្នា ។ ព្រះរស្មី ៦ ពណ៌ ចេញចាកព្រះសរីរៈរបស់ព្រះមានព្រះភាគ សូម្បីរបស់ព្រះពុទ្ធនិម្មិតក៏ដូចគ្នា ។ ព្រះរស្មីចាកព្រះសរីរៈរបស់ព្រះមានព្រះភាគ ប៉ះខ្ទប់ព្រះកាយរបស់ព្រះពុទ្ធ-និម្មិត ព្រះរស្មីចាកព្រះសរីរៈរបស់ព្រះពុទ្ធនិម្មិត ក៏ប៉ះខ្ទប់ព្រះកាយព្រះមាន-ព្រះភាគ ។ រស្មីទាំងនោះ គប្បីចេញចាកព្រះសរីរៈរបស់ព្រះពុទ្ធទាំងពីរព្រះអង្គ ទៅទល់នឹងជាន់អកនិដ្ឋព្រហ្ម ត្រឡប់អំពីនោះ ក៏ចុះក្នុងទីបំផុតគ្រប់សិរសារបស់ពួកទេវតា ហើយតាំងនៅត្រង់កណ្តាប់មាត់ចក្រវាឡ ។ ផ្ទៃចក្រវាឡទាំងអស់រុងរឿង ដូចផ្ទះព្រះចេតិយ ដែលមានឈើផ្ទោងកោងហាក់ដូចជាស្រោបដោយប្រាក់ទុកហើយ ដូច្នោះ ។ ទេវតាក្នុងម៉ឺនចក្រវាឡរួមជាក្រុមក្នុងចក្រវាឡតែមួយ ចូលទៅតាំងនៅក្នុងចន្លោះព្រះរស្មី របស់

ព្រះពុទ្ធទាំងពីរព្រះអង្គ ។ កាលព្រះពុទ្ធនិម្មិតកំពុងប្រថាប់អង្គុយ នោះឯង សរសើរការលះកិលេសត្រង់ពោធិបល្ល័ង្ករបស់ព្រះទសពល ទើបត្រាស់គាថា ថា ៖

**ខ្ញុំសូមសួរនូវព្រះមុនី ដែលមានប្រាជ្ញាច្រើន អ្នកឆ្លងហើយ ដល់នូវត្រើយហើយ ត្រជាក់ស្និទ មានព្រះទ័យតាំងនៅមាំ ចេញចាកផ្ទះ ហើយបន្ទោបង់កាមទាំងឡាយ ។**

ភិក្ខុនោះ គប្បីត្រាច់ទៅក្នុងលោកដោយប្រពៃយ៉ាងណា ។

ព្រះសាស្តា គ្រាទ្រង់គិតថា តថាគតនឹងពោលដល់ឈ្មោះ និងគោត្ររបស់អ្នកដែលមកហើយ ៗ ដើម្បីឲ្យពួកទេវតាកើតភាពជាអ្នកមានចិត្តព្រមគ្នាមុន ទើបត្រាស់ពាក្យជាដើមថា **ម្នាលភិក្ខុទាំងឡាយ តថាគតនឹងត្រាស់ប្រាប់** ដូច្នេះ ។

## នាម និងគោត្ររបស់ពួកទេវតា

[**៧៩**] បណ្តាបទទាំងនោះ បទថា **តថាគតនឹងធ្វើសោលក:** គឺ ពាក្យដែលចងជាឆន្ទ គឺ នឹងឲ្យពួកពាក្យដែលនិយមហើយដោយបទអក្សរ

ប្រព្រឹត្តទៅ ។ បទថា **កុម្មទេវតាក្នុងទីណា ក៏អាស្រ័យទីនោះ** សេចក្តីថា ពួកទេវតាដែល នៅតាមផែនដីក្នុងទីណា ៗ ក៏អាស្រ័យទីនោះ ៗ ឯង ។ ព្រះមានព្រះភាគត្រាស់ប្រាប់ប្រភេទវណ្ណៈ ដល់ភិក្ខុទាំងនោះ ដោយបទជាដើមថា **ពួកដែលអាស្រ័យញកភ្នំ** ។ អធិប្បាយថា ភិក្ខុពួកណាអាស្រ័យរូងភ្នំ ។ បទថា **បញ្ជូនខ្លួនទៅហើយ** គឺ មានចិត្តដែលបញ្ជូនទៅហើយ ។ បទថា **តម្កល់មាំ** គឺ មិនរវើរវាយ ។ បទថា **ច្រើន** គឺ ជនច្រើន ។ បទថា **ដូចសីហៈពួនសម្ងំ** គឺ ចូលដល់ភាពជាអ្នកមានចិត្តតែមួយ ដូចសីហៈលាក់ខ្លួន ។ បទថា **គ្របសង្កត់ការព្រឺរោម** គឺ គ្របសង្កត់រោមដែលបះឡើង ហើយតាំងនៅ ។ មានពាក្យអធិប្បាយថា មិនមានការខ្លាច ។ បទថា **មានចិត្តផូរផង់ បរិសុទ្ធិ** គឺ ជាអ្នកមានចិត្តស្អាតបរិសុទ្ធ ។ បទថា **មានចិត្តជ្រះថ្លា មិនល្អក់** គឺ ថ្លាស្អាតមិនល្អក់ ។ បទថា **ទ្រង់ជ្រាបភិក្ខុច្រើនជាង ៥០០ រូប** គឺ ទ្រង់ដឹងភិក្ខុលើសពី ៥០០ រូប រួមទាំងព្រះសម្មាសម្ពុទ្ធផង ។ បទថា **ក្នុងព្រៃជិតក្រុងកបិលភស្តុ** គឺ ក្នុងដងព្រៃដែលកើតជិតក្រុងកបិលភស្តុ ។ បទថា **តពីនោះ ព្រះសាស្តាទើបត្រាស់ហៅ** គឺ ត្រាស់ហៅក្នុងគ្រានោះ ។ បទថា **ពួកសាវកដែលត្រេកអរក្នុងសាសនា** គឺ ឈ្មោះថា សាវក ព្រោះកើតក្នុងទីបំផុតការស្តាប់ព្រះធម៌-

ទេសនា របស់ព្រះអង្គ ឈ្មោះថា អ្នកត្រេកអរក្នុងសាសនា ព្រោះត្រេកអរក្នុងសាសនា គឺ សិក្ខា ៣ ។ ព្រះមានព្រះភាគ ទ្រង់ធ្វើពាក្យទាំងអស់នេះឲ្យដូចអ្នកជទៃពោល ត្រាស់ដោយព្រះតម្រាស់ថា តថាគតនឹងធ្វើពាក្យស្លោក ។ បទថា **ពួកទេពបែរមុខមកហើយ ភិក្ខុទាំងឡាយ ពួកអ្នកចូរដឹងទេពទាំងនោះចុះ** សេចក្ដីថា ព្រះមានព្រះភាគ ត្រាស់ដើម្បីប្រយោជន៍ដល់អភិនិហារនៃទិព្វចក្ខុញ្ញាណរបស់ភិក្ខុទាំងនោះថា ពួកអ្នកចូរស្គាល់ពួកទេវតាទាំងនោះ ដោយទិព្វចក្ខុ ដូច្នេះ ។

បទថា **ក៏ពួកភិក្ខុទាំងនោះ ស្ដាប់ព្រះពុទ្ធសាសន៍ហើយ បានធ្វើសេចក្ដីព្យាយាម** សេចក្ដីថា ក៏ភិក្ខុទាំងនោះ ស្ដាប់ពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគហើយ ភ្លាមនោះឯង ក៏បានធ្វើសេចក្ដីព្យាយាមដើម្បីប្រយោជន៍ដល់ទិព្វចក្ខុនោះ ។ ញាណ ក៏មានប្រាកដដល់ភិក្ខុទាំងនោះ ដែលគ្រាន់តែបានប្រារព្ធធ្វើសេចក្ដីព្យាយាមនុ៎ះឯង យ៉ាងនោះ ។ តើយ៉ាងណា គឺទិព្វចក្ខុញ្ញាណ ដែលជាគ្រឿងឃើញពួកអមនុស្សកើតឡើងហើយ ។ ទិព្វ-ចក្ខុញ្ញាណនោះ មិនមែនថា ពួកលោកទាំងនោះធ្វើបរិកម្មហើយ ឲ្យកើតឡើងក្នុងខណៈនោះ តែទិព្វចក្ខុញ្ញាណនោះ សម្រេចដោយមគ្គតែម្ដង ។ ឯហេតុត្រឹមតែអភិនិហារនៃទិព្វចក្ខុញ្ញាណ ដើម្បីឃើញអមនុស្សនោះប៉ុណ្ណោះ

បានធ្វើហើយ ។ សូម្បីព្រះសាស្តា ទ្រង់សំដៅយកប្រការនេះឯងថា ពួកអ្នកមានញាណ បើដូច្នោះ ពួកអ្នកចូរបង្អោនញាណទៅដឹង ហើយទើបត្រាស់ថា ភិក្ខុទាំងឡាយ ពួកអ្នកចូរស្គាល់ពួកទេវតាទាំងនោះ ។ បទថា **ភិក្ខុពួកខ្លះបានឃើញ ១០០** សេចក្តីថា ក្នុងភិក្ខុទាំងនោះ ភិក្ខុពួកខ្លះបានឃើញពួកអមនុស្ស ១០០ ។ បទថា **១.០០០ និង ៧** សេចក្តីថា ពួកខ្លះឃើញអមនុស្ស ១.០០០ ពួកខ្លះឃើញអមនុស្ស ៧ ម៉ឺន ។

បទថា **ពួកខ្លះមួយពាន់** សេចក្តីថា ពួកភិក្ខុខ្លះឃើញអមនុស្សមួយសែន ។ បទថា **ឃើញមិនមានទីបំផុត** សេចក្តីថា បានឃើញយ៉ាងធំ ។ អធិប្បាយថា បានឃើញអមនុស្សសូម្បីនឹងកំណត់ដោយអំណាចចំនួនរយ និងដោយអំណាចចំនួនពាន់ក៏មិនបាន ព្រោះហេតុអ្វី ព្រោះអមនុស្សបានផ្សាយពាសពេញក្នុងទិសទាំងពួង គឺ មានពាសពេញទីកន្លែង ។

បទថា **នឹងដឹងក្រៃលែងក្នុងវត្ថុទាំងអស់** គឺ ក្នុងភិក្ខុទាំងនោះ វត្ថុណាដែលបានឃើញ សូម្បីមួយរូប ក៏ដឹងវត្ថុនោះដែរ ។ បទថា **ទ្រង់មានចក្ខុ ទ្រង់ពិចារណាហើយ** គឺ ព្រះសាស្តាទ្រង់មានចក្ខុ ដោយចក្ខុទាំង ៥ យ៉ាង ទ្រង់ពិចារណាដោយប្រចក្ស ដូចអ្នកពិចារណាមើលក្រឡាបាតដៃដូច្នោះ ទើបត្រាស់ព្រះគាថា ដែលពោលមកកាលមុនថា **តអំពីនោះ ទើប**

**ត្រាស់ហៅ** ដើម្បីទ្រង់ត្រូវការប្រាប់ដល់ឈ្មោះ និងគោត្រ ។ ក្នុងបទនេះ មានសេចក្តីជាប់ទាក់ទងយ៉ាងនេះថា ពួកអ្នកចូរដឹង គឺ ចូរមើល បានដល់ ចូរសម្លឹងមើលពួកអមនុស្ស ដែលតថាគតនឹងប្រាប់ដល់ពួកអ្នក ។ បទថា **ដោយពាក្យទាំងឡាយ** គឺ ដោយពាក្យទាំងឡាយ ។ បទថា **ដោយលំដាប់** គឺ តាមលំដាប់ ។

បទថា **យក្សទាំងឡាយ ៧ ពាន់ ជាពួកទេពនៅតាមផែនដី អាស្រ័យក្រុងកបិលភស្តុ** គឺ ព្រះមានព្រះភាគត្រាស់ថា ពួកយក្ខ គឺ ពួកទេវតានៅតាមផែនដី អាស្រ័យក្រុងកបិលភស្តុ កើតក្នុងក្រុងកបិលភស្តុនោះមុន ។ បទថា **មានឫទ្ធិ** គឺ ប្រកបដោយឫទ្ធិទិព្វ ។ បទថា **មានសេចក្តីរុងរឿង** គឺ ដល់ព្រមដោយអានុភាព ។ បទថា **វណ្ណៈ** គឺ សម្បូរណ៍ដោយពណ៌សម្បុរ របស់រាងកាយ ។ បទថា **មានយស** គឺ សម្បូរណ៍ដោយបរិវារ ។ បទថា **ត្រេកអរ ឆ្ពោះមុខមក** គឺ មានចិត្តត្រេកអរមក ។ បទថា **កាន់ព្រៃជាទីប្រជុំនៃភិក្ខុទាំងឡាយ** គឺ មកដើម្បីត្រូវការមើលព្រៃធំនេះ គឺ សម្នាក់របស់ពួកភិក្ខុនេះ បានដល់ ដើម្បីត្រូវការមើលភិក្ខុទាំងឡាយ ។ម្យ៉ាងទៀត **ពួក** ហៅថា **ប្រជុំ** អធិប្បាយថា មកដើម្បីសរសើរពួកភិក្ខុ ដូច្នេះក៏បាន ។ បទថា **ពួកយក្សហេមវតៈ ៦ ពាន់ មានសម្បុរផ្សេងៗគ្នា** គឺ ពួកយក្ខដែល

កើតនៅនាភ្នំហេមវន្ត ៦ ពាន់ ពួកយក្ខសុម្បីទាំងអស់នោះ មានពណ៌ផ្សេង ៗ គ្នា ដោយពណ៌ខៀវជាដើម ។ បទថា **ពួកយក្សនៅភ្នំសាតាគិរី ៣ ពាន់** គឺ ពួកយក្ខដែលកើតនៅនា ភ្នំសាតាគិរី ៣.០០០ ។ បទថា **ពួកយក្សទាំងនោះ ១៦.០០០ ដោយប្រការដូច្នេះ** គឺ យក្ខសុម្បីទាំងអស់នេះ រួមគ្នាជា ១៦.០០០ ។ បទថា **វិស្សាវាមិត្ត ៥០០** គឺ ពួក យក្ខដែលកើតលើភ្នំវិស្សាវមិត្ត ៥០០ ។ បទថា **កុម្ភីរនាក្រុងរាជគ្រឹះ** គឺ យក្ខឈ្មោះកុម្ភីរ កើតក្នុងក្រុងរាជគ្រឹះ ។ បទថា **ភ្នំវេបុល្ល ជាទីនៅរបស់យក្សនោះ** អធិប្បាយថា ភ្នំវេបុល្ល: ជានិវេសន៍ គឺ ទីលំនៅរបស់យក្ខនោះ ។ បទថា **យក្សច្រើនជាងមួយសែន ចូលគាល់យក្ខឈ្មោះកុម្ភីរនោះ** គឺ យក្សច្រើនជាងមួយសែន ចូលគាល់យក្សឈ្មោះកុម្ភីរនោះ ។ បទថា **កុម្ភីរយក្សដែលកើតក្នុងនគររាជគ្រឹះនោះ ក៏មកកាន់ព្រៃជាទីប្រជុំភិក្ខុទាំងឡាយ** គឺ សុម្បីយក្ខឈ្មោះកុម្ភីរនោះ ព្រមទាំងបរិវារ ក៏មកកាន់ព្រៃនេះ ដើម្បីសរសើរការប្រជុំរបស់ភិក្ខុទាំងឡាយ ។

[៨០] បទថា **ស្តេចធតរដ្ឋ: ទ្រង់គ្រប់គ្រងទិសខាងកើត** គឺ ទ្រង់គ្រប់គ្រងទិសខាងកើត ។ បទថា **ទ្រង់ជាអធិបតីនៃពួកគន្ធព្វ** គឺ ទ្រង់ជាប្រធានរបស់ពួកគន្ធព្វ (គន្ធព្វ-អ្នកតន្ត្រី) គន្ធព្វទាំងអស់នោះ ប្រព្រឹត្តទៅ

ទៅក្នុងអំណាចរបស់ស្តេចធតរដ្ឋៈនោះ ។ បទថា **ព្រះអង្គជាមហារាជ ទ្រង់មានយស** គឺ មហារាជព្រះអង្គនោះ ទ្រង់មានបរិវារច្រើន ។ បទថា **សូម្បីពួកបុត្តរបស់មហារាជនោះ ក៏ច្រើន** មាននាមថា **ឥន្ទៈ** មានឫទ្ធិច្រើន គឺ ពួកកូន ៗ របស់ព្រះបាទធតរដ្ឋនោះ មានច្រើន មានកម្លាំងច្រើន ។ អ្នកទាំងឡាយ ចូរស្គាល់ស្តេចសក្កៈ ដែលជារាជារបស់ទេវតា ។ បទថា **ស្តេចវិរុឡ្ហ ទ្រង់គ្រប់គ្រងទិសនោះ** គឺ ទិសនោះ ព្រះបាទវិរុឡ្ហៈទ្រង់ប្រៀប្រដៅ ។ បទថា **សូម្បីពួកកូនៗ របស់មហារាជ** គឺ កូន ៗ សូម្បីរបស់មហារាជនោះ ក៏ដូចគ្នា ។ ក៏ក្នុងបាលី លោកសរសេរថា មហព្វលា មានកម្លាំងច្រើន ។ ក្នុងវារៈទាំងអស់ក្នុងអដ្ឋកថា បាឋៈថា មហាពលា មានកម្លាំងច្រើន ។ ចំណែកគាថា ព្រះមានព្រះភាគ ត្រាស់ដោយអំណាចរួមយកទាំងអស់យ៉ាងនេះថា ៖

ព្រះបាទធតរដ្ឋៈទ្រង់គ្រប់គ្រងទិសខាងកើត, ព្រះបាទវិរុឡ្ហកៈទ្រង់គ្រប់គ្រងទិសខាងត្បូង, ព្រះបាទវិរូបក្ខៈទ្រង់គ្រប់គ្រងទិសខាងលិច, ព្រះបាទកុវេរៈទ្រង់គ្រប់គ្រងទិសខាងជើង, មហារាជទាំង ៤ ព្រះអង្គនោះ ទ្រង់ញុំាងទិសទាំង ៤ ដោយជុំវិញឲ្យរុងរឿង ប្រថាប់

នៅក្នុងព្រៃជិតក្រុងកបិលកស្ថុ ។

ក្នុងគាថានោះ មានខ្លឹមសារដូចតទៅនេះ ក្នុងម៉ឺនចក្រវាឡដទៃទៀត ក៏មានពួកមហារាជ ទ្រង់ព្រះនាមថា **ធតរដ្ឋៈ** ។ សូម្បីមហារាជទាំងអស់នោះផ្សេង ក៏ទ្រង់មានគន្ធព្វសែនកោដិជាបរិវារ ឈរពេញផ្ទៃចក្រវាឡ តាំងពីព្រៃធំជិតក្រុងកបិលកស្ថុនាទិសខាងកើត ។ ស្ដេចវិរុឡ្ហកៈជាដើម ក្នុងទិសខាងត្បូងជាដើម ក៏យ៉ាងនេះ ។ ព្រោះហេតុនោះឯង ព្រះមានព្រះភាគ ទើបត្រាស់ថា ទ្រង់ញ៉ាំងទិសទាំង ៤ ដោយជុំវិញ ឲ្យរុងរឿងហើយប្រថាប់ ។ក៏ពាក្យអធិប្បាយមានយ៉ាងនេះថា មកពីចក្រវាឡដោយជុំវិញ ញ៉ាំងទិសទាំង ៤ ឲ្យរុងរឿងយ៉ាងល្អ ប្រថាប់នៅដូចគងភ្លើងលើកំពូលភ្នំ ។ ក៏លោកទាំងនោះ ទ្រង់សំដៅយកព្រៃជិតក្រុងកបិលកស្ថុប៉ុណ្ណោះឯង ទើបមក ព្រោះហេតុណា ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ដល់ពួកលោកថា ជាអ្នកញ៉ាំងចក្រវាឡឲ្យពេញស្មើ ហើយប្រថាប់ត្រង់ព្រៃជិតក្រុងកបិលកស្ថុ ដូច្នេះ ។

[៨១] បទថា **ពួកទាសៈរបស់មហារាជទាំង ៤ ព្រះអង្គនោះ មានមាយា អ្នកល្បួងបញ្ឆោត អួតអាង ក៏មក** សេចក្ដីថា មហារាជទាំងនោះទ្រង់មានទាសៈដែលប្រព្រឹត្តកោងកាច ប្រកបដោយអ្នកខិលខូចបោកប្រាស

មានការបិទបាំងទុកនូវសេចក្តីអាក្រក់ ជាលក្ខណៈ ជាពួកដែលហៅថា អ្នកល្បួង បញ្ឆោតបន្ទំលោក ដោយការបញ្ឆោតបន្ទំទាំងចំពោះមុខ និង កំបាំងមុខ និងពួកដែលហៅថា អ្នកអួតអាង ព្រោះប្រកបដោយការធបោក និងអួតអាង សូម្បីពួកទាំងនោះ ក៏មក ។ បទថា **ទេវកជទាំងអម្បាលនេះ គឺ កុដេណ្ឌុ វេដេណ្ឌុ វិដូ វិដូដៈ** គឺ សូម្បីទាសៈទាំងអស់នោះ សុទ្ធ តែជាអ្នកធ្វើមារយាទាំងអស់ ក៏ក្នុងពួកធ្វើមារយានេះ ដោយឈ្មោះក៏មាន កុដេណ្ឌុ ១ វិដេណ្ឌុ ១ ។ ចំណែកក្នុងបាលី លោកសរសេរថា វេដេណ្ឌុ ( តទៅក៏ជា ) វិដុ ១ វិដុដៈ ១ ។

បទថា **ជាមួយ** គឺ សូម្បីវិដុដៈនោះ ក៏មកជាមួយពួកទាំងនោះ ដូចគ្នា ។ ( បន្ទាប់មកក៏មាន ) ចន្ទនៈ ១ កាមសេដ្ឋៈ ១ កិន្នុឃណ្ឌុ ១ និឃណ្ឌុ ១ កិន្នុឃណ្ឌុៈម្នាក់ទៀត ១ ។ តែក្នុងបិដកសរសេរជាកិន្នុឃណ្ឌុ ។ ឈ្មោះនិឃណ្ឌុដទៃ ក៏ឈ្មោះនិឃណ្ឌុផង ។ ( និឃណ្ឌុមានពីរនាក់ ) ពួក អ្នកបម្រើមាន (១០ នាក់) ប៉ុណ្ណោះ ។ ចំណែកពួកដទៃពីនេះ ក៏បានដល់ ទេវកជទាំងនេះ គឺ ៖

**បនាទៈ ១ ឱបមញ្ញៈ ១ ទេវសូតៈ ១ មាតលី ១**

**ចិត្តសេនៈ ១ គន្ធព្វៈ ១ នឡោរាជៈ ១ ជនោសភៈ ១**

**បញ្ចសិខៈ ១ តិម្ពរូ ១ សុរិយវច្ចសា ១ ក៏នាំគ្នាមកដែរ ។**

បណ្ដាបទទាំងនោះ បទថា ចេវសូត គឺ ទេវសារថី ។ បទថា ចិត្តសេន គឺ បែកជាទេវរាជបាន ៣ អង្គចិត្តៈ ១ សេនៈ ១ ចិត្តសេនៈ ១ ។ បទថា គន្ធព្វ ក៏បានដល់ ចិត្តសេនៈ ដែលជាពួកគន្ធព្វនេះ ។ មិនមែនតែចិត្តសេនៈនេះប៉ុណ្ណោះ សូម្បីបនាទៈជាដើម ទាំងអស់នេះក៏ជាគន្ធព្វទាំងអស់នោះឯង ។ បទថា ឧទ្យោរាជា បានដល់ ទេវតាមួយអង្គ ឈ្មោះនឡការទេវបុត្រ ។ បទថា ជនោសភ គឺ ទេវបុត្រឈ្មោះ ជនវសភៈ ។ បទថា តិម្ពរូ គឺ គន្ធព្វទេវរាជ ។ បទថា សុរិយវច្ចសា បានដល់ ជាធីតារបស់ស្ដេចតិម្ពរូនុ៎ះឯង ។ បទថា **ទេពទាំងនេះ និងគន្ធព្វដែលជារាជាព្រមទាំងរាជាដទៃ** គឺ ទេវតាទាំងនេះ ពួកស្ដេចគន្ធព្វ ដែលពោលដោយអំណាចព្រះនាម និងគន្ធព្វចំនួនច្រើនពួកដទៃ ព្រមទាំងព្រះរាជាទាំងនោះ ។ បទថា **ត្រេកអរត្នោះមុខមកកាន់ព្រៃដែលជាទីប្រជុំរបស់ពួកភិក្ខុទាំងឡាយ** មានសេចក្ដីថា មានចិត្តរីករាយត្រេកអរមកហើយ កាន់ព្រៃនេះ ដែលជាទីប្រជុំរបស់ភិក្ខុទាំងឡាយ ។

បទថា **នាគមួយពួកនៅក្នុងស្រះនាសកៈ និងនាគមួយពួកទៀតនៅក្នុងក្រុងវេសាលី ក៏មកព្រមគ្នាជាមួយតច្ឆកៈ** គឺ នាគទាំងឡាយនៅ

ក្នុងស្រះនកសៈ និងនាគនៅក្នុងក្រុងវេសាលី ក៏មកព្រមទាំងបរិស័ទរបស់តច្ឆកនាគរាជ ។ បទថា **កម្ពល និងអស្សតរ** គឺ កម្ពលៈ ១ អស្សតរៈ ១ ។ ដំណាលមកថា នាគទាំងនេះ នៅត្រង់ជើងភ្នំសិនេរុ ជានាគថ្នាក់ធំ ដែលសូម្បីពួកសុបណ្ណ ( គ្រុឌ ) ក៏គប្បីឆក់យកទៅ ( នាំទៅ ចាប់ទៅ ) មិនបាន ។ បទថា **និងពួកនាគនៅក្នុងកំពង់បយាគៈ ព្រមទាំងពួកញាតិ** គឺ និងពួកនាគដែលអាស្រ័យនៅកំពង់បយាគៈ ក៏មកជាមួយពួកញាតិ ។ បទថា **និងពួកអ្នកយមុនា និងពួកធតរដ្ឋ** គឺ ពួកនាគដែលនៅក្នុងទន្លេយមុនា និងពួកនាគដែលកើតក្នុងត្រកូលស្តេចធតរដ្ឋៈ ។ បទថា **ដំរីធំឈ្មោះឯរាវ័ណ** គឺ ឯរាវ័ណជាទេវបុត្រ មិនមែនជាដំរីដោយកំណើត តែទេវបុត្រនោះ ត្រូវហៅថា ដំរី ។ បទថា **សូម្បីគេក៏មក** គឺ សូម្បីឯរាវ័ណទេវបុត្រនោះ ក៏បានមក ។

[៨២] បទថា **ពួកអ្នកនាំនាគរាជទៅបានរហ័ស** គឺ ពួកគ្រុឌណាមានសេចក្តីលោភគ្របសង្កត់ហើយ គឺ ចាប់យកពួកនាគមានប្រការដូចដែលពោលហើយនេះ ទៅបានយ៉ាងរហ័ស ។ បទថា **ជាទិព្វ កើតពីរដងមានស្លាប មានភ្នែកបរិសុទ្ធិ** គឺ ឈ្មោះថា ជាទិព្វ ព្រោះមានអានុភាពទិព្វ ឈ្មោះថា កើតពីរដង ព្រោះកើតហើយពីរដង គឺ អំពីផ្ទៃមេ និងអំពីពង

ឈ្មោះថា មានស្លាប ព្រោះប្រកបដោយស្លាប ឈ្មោះថា មានភ្នែកបរិសុទ្ធ ព្រោះប្រកបដោយភ្នែក ដែលអាចឃើញពួកនាគក្នុងចន្លោះរយយោជន៍ខ្លះ ពាន់យោជន៍ខ្លះ ។ បទថា **ពួកទាំងនោះ ទៅដល់កណ្តាលព្រៃតាមផ្លូវវេហាស៍** គឺ ពួកគ្រុឌទាំងនោះ មកដល់ព្រៃធំនេះតាមផ្លូវអាកាសនោះឯង ។ បទថា **ឈ្មោះរបស់ពួកទាំងនោះថា ចិត្រ និងសុបណ្ណ** គឺ គ្រុឌទាំងនោះ ឈ្មោះចិត្រៈ និងសុបណ្ណៈ ។ បទថា **ក្នុងគ្រានោះ មានការអភ័យដល់ពួកនាគរាជ ព្រះសម្ពុទ្ធទ្រង់ធ្វើការរួចអភ័យពីសុបណ្ណ** គឺ (ព្រោះហេតុណា) ព្រោះហេតុនោះ ពួកនាគ និងគ្រុឌទាំងអស់នោះ ក៏ត្រឡប់និយាយដោយសំដីដ៏ពីរោះរីករាយរកគ្នា ដូចសម្លាញ់ និងដូចញាតិ ឱបក្រសោបគ្នា ចាប់ដៃគ្នា ដាក់ដៃលើស្មាគ្នា មានចិត្តរីករាយត្រេកអរ ។ បទថា **ពួកនាគ ពួកសុបណ្ណដល់ព្រះពុទ្ធជាសរណៈ** គឺ ពួកគេទាំងនោះ ដល់ព្រះពុទ្ធ ជាទីពឹងទីរលឹក ។

ពួកដែលនៅក្នុងសមុទ្រ គឺ ពួកអសុរ អ្នកអាស្រ័យសមុទ្រ ដែលត្រូវព្រះឥន្ទ្រជារាជានៃទេវតា មានព្រះនាមថា ស្តេចវជិរហស្ត (មានវជិ-រាវុធក្នុងព្រះហស្ត) បង្ក្រាបហើយក្នុងកាលមុន ព្រោះហេតុនាងសុជាតាជីតារបស់អសុរ សួម្បីពួកណា សូម្បីពួកអសុរទាំងអស់នោះ ជាបងប្អូនរបស់

ស្តេចវាសវៈ (ព្រះឥន្ទ្រ) ជាអ្នកមានឫទ្ធិ មានយស ។ បទថា **ពួកកាលកញ្ជា មានកាយធំពន្លឹក** គឺ ពួកអសុរកាលកញ្ជានិម្មិតរាងកាយធំ គួរភ័យខ្លាច ក៏មក ។ បទថា **ពួកអសុរត្រកូលទានវេឃសៈ** បានដល់ ពួកអសុរកាន់ធ្នូពួកដទៃ ឈ្មោះទានវេឃសៈ ។ បទថា **វេបចិត្ត សុចិត្ត និងមហាភទៈ និងនមុចិ** បានដល់ និងពួកអសុរទាំងនេះ គឺ អសុរ ឈ្មោះវេបចិត្តិ ១ អសុរឈ្មោះសុចិត្តិ ១ ។ ពាក្យថា **និងនមុចី** បានដល់និងមារឈ្មោះ នមុចិ ដែលជាទេវបុត្រ ក៏មកជាមួយអសុរទាំងនោះឯង ។ អសុរទាំងនេះនៅក្នុងសមុទ្រ តែនមុចីនេះ នៅក្នុងទេវលោកជាន់បរនិម្មិត ហេតុអ្វី ទើបមកព្រមជាមួយអសុរទាំងនោះ ? ព្រោះជាពួកមិនពេញចិត្តជាពួកអភ័ព្វ ។ ចំណែកនមុចីនេះ ក៏ដូចគ្នានុ៎ះឯង ជាតុត្រូវគ្នា ព្រោះដូច្នោះទើបមក ។ បទថា **និងពួកកូនរបស់ពលិអសុរ ១០០** គឺ កូន ១០០ នាក់របស់ពលី ជាអសុរធំ ។ បទថា **គ្រប់គ្នាឈ្មោះវេរោចនៈ** គឺ ទ្រង់ឈ្មោះរាហូ ជាអ៊ំរបស់ខ្លួននុ៎ះឯង ។ បទថា **ចងសៀតនូវគ្រឿងសេនាដែលមានកម្លាំង** គឺ ចងសៀតគ្រឿងសេនា ដែលមានកំលាំងរៀងៗ ខ្លួន ក្លាយជាអ្នកចាត់ចែងគ្រឿងចូលទីលានសម្រេចហើយ ។ បទថា **ចូលជិតរាហូកទ្រហើយ** គឺ ចូលទៅរកស្តេចអសុរឈ្មោះរាហូ ។ បទថា **លោកដ៏ចម្រើន**

**ពេលនេះជាសម័យរបស់លោក** គឺ សេចក្តីចម្រើនចូរមានដល់លោក ឥឡូវនេះជាវេលាប្រជុំ ។ អធិប្បាយថា លោកចូរចូលទៅកាន់ព្រៃជាទីប្រជុំនៃភិក្ខុទាំងឡាយ ដើម្បីមើលពួកភិក្ខុ ។

[៨៣] បទថា **ពួកអាបោទេព ពួកបឋវីទេព ពួកតេជោទេព និងពួកវាយោទេព ក៏មកក្នុងទីនោះ** គឺ ពួកទេវតាដែលមានឈ្មោះជាដើមថាទឹក ព្រោះធ្វើបរិកម្មក្នុងកសិណទឹកជាដើម ទើបកើតឡើង ក៏មកក្នុងគ្រានោះ ។ បទថា **ពួកវរុណទេព ពួកវារុណទេព សោមទេព និងយសទេព** សេចក្តីថា ពួកទេវតាដែលមានឈ្មោះយ៉ាងនេះ គឺ វរុណទេវតា វារុណ-ទេវតា សោមទេវតា ក៏មកជាមួយគ្នានឹងយសទេវតា ។

បទថា **ពួកមេត្តាករុណា** គឺ ពួកទេវតាដែលធ្វើបរិកម្មក្នុងឈានប្រកបដោយសេចក្តីស្រឡាញ់ និងក្នុងឈានដែលប្រកបដោយសេចក្តីអាណិតហើយ ទើបកើតឡើង ។ បទថា **ពួកទេវតា ដែលមានយស មកហើយ** គឺ សូម្បីពួកទេវតាទាំងនេះ ជាអ្នកមានយសធំ ក៏បាននាំគ្នាមកហើយ ។ បទថា **ពួកទេព ១០ ពួកទាំងនេះ តាំងនៅដោយចំណែក ១០ ទាំងអស់** មានពណ៌សម្បុរផ្សេងៗ គ្នា ដោយអំណាចនៃពណ៌ខៀវជាដើម ក៏បាននាំគ្នាមកហើយ ។

បទថា **និងទេព ឈ្មោះវេណ្ហុ** គឺ វេណ្ហុទេវតា ១ ។ បទថា **សហលី ផង** គឺ ទេវតាឈ្មោះសហលី ១ ។ បទថា **ទេពឈ្មោះថា អសមា និង មយៈទាំងពីរ** គឺ អសមទេព និងសមទេព ២ ទៀត ។ បទថា **ពួកទេវតា ដែលអាស្រ័យព្រះចន្ទ ធ្វើព្រះចន្ទទុកខាងមុខហើយ ក៏មក សូម្បីពួកទេវតា ដែលអាស្រ័យព្រះអាទិត្យ ក៏ធ្វើព្រះអាទិត្យទុកខាងមុខហើយ** ក៏មកដូចគ្នា ។ បទថា **ធ្វើនក្សត្រទុកខាងមុខ** គឺ ទេវតាទាំងឡាយ ដែលអាស្រ័យផ្កាយ ( ផ្កាយគ្រោះ ) ធ្វើពួកនក្សត្រទុកខាងមុខហើយ ក៏មក ។ បទថា **មន្ទ-វលាហកៈទាំងឡាយ ក៏មក** សេចក្តីថា ពួកវាតវលាហកៈ ពួកអព្ភវលា-ហកៈ ពួកឧណ្ហវលាហកៈ ពួកវលាហកទេវតាសូម្បីទាំងអស់នេះ ហៅ ឈ្មោះថា មន្ទវលាហកៈ សូម្បីពួកមន្ទវលាហកៈនោះ ក៏មក ។ បទថា **សូម្បីសក្កទេវរាជ វាសវៈ បុរិន្ទទៈ** ដ៏ប្រសើរជាងពួកវសុ ក៏មក គឺ វាសវៈ គឺ ព្រះអង្គណា ដែលហៅថា សក្កៈ និងបុរិន្ទទៈ អ្នកប្រសើរជាង វសុទេវតាទាំងឡាយ សូម្បីស្តេចវាសវៈនោះ ក៏ស្តេចមក ។ បទថា **ពួក ទេពទាំង ១០ នោះ** គឺ ពួកទេវតាទាំង ១០ នេះ មកហើយដោយចំណែក ១០ ។ បទថា **សុទ្ធតែមានពណ៌សម្បុរៗ គ្នា** គឺ មានពណ៌សម្បុរផ្សេងៗ គ្នា ដោយពណ៌ខៀវជាដើម ។

បទថា **តមក ពួកសហភូទេពក៏មក** គឺ លំដាប់តមក ពួកទេវតាឈ្មោះសហភូក៏មក ។ បទថា ជលមគ្គិសិខារិវ គឺ រុងរឿងបីដូចអណ្តាតភ្លើង ។ លោកពោលថា បទថា **រុងរឿងដូចអណ្តាតភ្លើង** នេះ ជាឈ្មោះរបស់ទេវតាទាំងនោះ ដូច្នេះក៏មាន ។ បទថា **ពួកអរិដ្ឋកៈក្តី ពួករោជៈក្តី** គឺ ពួកអរិដ្ឋកទេវតា និងពួករោជទេវតា ។ បទថា **មានរស្មីដូចផ្កាកប្បាស**១ គឺ ពួកទេវតាទាំងនោះ ឈ្មោះថា ពួកទេវតាផ្កាកប្បាស ។ ព្រោះថា ពន្លឺខ្លួនទេវតាទាំងនោះដូចគ្នានឹងផ្កាកប្បាស ដូច្នោះ ទើបហៅថា ឧម្មាបុប្ផនិភាសី-មានរស្មីដូចផ្កាកប្បាស ។ ពាក្យថា **វរុណ និងសហធម្ម** គឺ ពួកទេវតាទាំងពីរអង្គនេះផង ។ ពាក្យថា **អច្ចុត និងអនេជក** គឺ ពួកអច្ចុតទេវតា និងពួកអនេជកទេវតា ។ ពាក្យថា **សុលេយ្យ និងរុចិរក៏មក** គឺ ពួកទេវតាឈ្មោះសុលេយ្យៈ និងពួកទេវតាឈ្មោះរុចិរៈ ក៏មក ។ ពាក្យថា **វាសវនេសី ក៏មក** គឺ ពួកទេវតាវាសវនេសី ក៏បានមក ។ ពាក្យថា **ពួកទេពទាំង ១០ នេះ** គឺ សូម្បីពួកទេវតាទាំង ១០ ពួកនេះ មកហើយដោយចំណែក ១០ តែម្តង ។

ពាក្យថា សមាន មហាសមាន គឺ ពួកទេវតាឈ្មោះសមានៈ និង

---

១-ថៃប្រែថា ផ្កាត្រកៀត , បិដកខ្មែរលេខ ១៧ ទំព័រ ១៨៤ ប្រែថា ផ្កាកប្បាស ។

ពួកទេវតាឈ្មោះមហាសមានៈ ។ ពាក្យថា មានុស មានុសុត្តម គឺ ពួកទេវតាឈ្មោះមានុសៈ និងពួកទេវតាឈ្មោះមានុស្សុត្តមៈ ។ ពាក្យថា **ពួកខិឌ្ឌាបទោសិកៈក៏មក ពួកមនោបទោសិកៈក៏មក** គឺ ពួកទេវតាដែលមានការលេង ប្រទូសរ៉ាយ និងពួកទេវតាដែលមានចិត្តប្រទូសរ៉ាយក៏មក ។ ពាក្យថា **បន្ទាប់មកទៀត ពួកហរិទេវតាក៏មក** គឺ ពួកដែល ឈ្មោះហរិ-ទេវតា ក៏មក ។ ពាក្យថា **ពួកណាឈ្មោះលោហិតវាសីក្តី** គឺ ពួកទេវតាលោហិតវាសីក្តី ក៏បានមក ។ ពួកទេវតាទាំងពីរនេះ គឺ ពួកដែលឈ្មោះបារគៈ និងពួកដែលឈ្មោះ មហាបារគៈ ក៏មក ។ ពាក្យថា **ពួកទេពទាំង ១០ ពួកនេះ** គឺ ពួកទេវតាទាំង ១០ នេះ មកហើយដោយចំណែក ១០ នោះឯង ។

ពាក្យថា **ពួកទេពឈ្មោះសុក្កៈ ឈ្មោះករុមហៈ ឈ្មោះអរុណៈ ឈ្មោះវេឃនសៈ ក៏មកជាមួយគ្នា** គឺ ពួកទេវតាទាំងបី មានពួកសុក្កៈជាដើម និងពួកវេឃនសទេវតា ក៏មកព្រមជាមួយទេវតាទាំងនោះ ។ ពាក្យថា **ពួកទេពដែលជាប្រធាន ឈ្មោះឱទាតគយ្ហៈ** គឺ ពួកទេវតាជាប្រធានឈ្មោះឱទាតគយ្ហៈ ក៏មក ។ ពាក្យថា **ពួកវិចក្ខណទេព ក៏មក** គឺ ពួកទេវតាឈ្មោះ វិចក្ខណៈ ក៏មក ។ ពាក្យថា **ពួកសទាមត្តៈ ពួកហារគជៈ** គឺ ពួក

ទេវតាឈ្មោះ សទាមត្ត: និងពួកទេវតាឈ្មោះហារគជ: ។ ពាក្យថា **និងពួកមិស្សក:អ្នកមានយស** គឺ ពួកឈ្មោះមិស្សកទេវតា ដល់ព្រមដោយយស ។ ពាក្យថា **បជ្ជុន: គម្រាមហើយ ក៏មក** គឺ និងទេវរាជឈ្មោះបជ្ជុន: ក៏មក ។ ពាក្យថា **អ្នកឲ្យភ្លៀងធ្លាក់ទូទាំងទិស** គឺ អ្នកដែលទៅកាន់ទិសណា ៗ ភ្លៀងក៏ធ្លាក់ក្នុងទិសនោះ ៗ ។ ពាក្យថា **ពួកទេពទាំង ១០ នេះ** គឺ ពួកទេវតាទាំង ១០ សូម្បីទាំងនេះ មកហើយដោយចំណែក ១០ នោះឯង ។

ពាក្យថា **ពួកទេពជាន់តុសិតអ្នកមានសេចក្តីក្សេម និងពួកទេពជាន់យាមា** បានដល់ ពួកទេវតាដែលមានសេចក្តីក្សេមនៅតុសិតបុរី និងពួកទេពដែលនៅក្នុងយាមាទេវលោក ។ ពាក្យថា **និងពួកកឋកាអ្នកមានយស** បានដល់ ពួកទេវតាឈ្មោះកឋក: អ្នកសម្បូរណ៍ដោយយសផង ។ ចំណែកក្នុងបិដកសរសេរថា **កដ្ឋក:** ។ ពាក្យថា **លម្ពិតក: (និង) លាមសេដ្ឋ:** បានដល់ ពួកទេវតាឈ្មោះលម្ពិតក: និងពួកទេវតាឈ្មោះលាមសេដ្ឋ: ។ ពាក្យថា **ជោតនាម និងអាសវ:** សេចក្តីថា មានពួកទេវតាឈ្មោះជោតិទេវតា រុងរឿងដូចដុំភ្លើងបបុសដែលដុតលើកំពូលភ្នំ និងពួកអាសាទេវតាក៏មក ។ តែក្នុងបាលីសរសេរ ជោតិនាម , លោកហៅអាសាទេវតាថាអាសវ: ដោយអំណាចឆន្ទ ។ ទេវតាជាន់និម្មានរតី ក៏មក បន្ទាប់មកទេវតា

ជាន់បរនិម្មិតា ក៏មក ។ ពាក្យថា **ពួកទេពទាំង ១០ នេះ** បានដល់ ពួកទេពទាំង ១០ សូម្បីនេះ មកហើយ ដោយចំណែក ១០ នោះឯង ។

ពាក្យថា **ពួកទេព ៦០ ទាំងនេះ** បានដល់ ទេវតា ១០ ពួក ៦ ដង ចាប់តាំងអំពីអាបោជាដើម ក៏ជាពួកទេវតា ៦០ ពួក ។ ទេវតាទាំងអស់ មានពណ៌សម្បុរផ្សេងគ្នា ដោយអំណាចពណ៌ខៀវជាដើម ។ ពាក្យថា **មកហើយដោយកំណើត ឈ្មោះ** បានដល់ មកហើយដោយភាគនៃឈ្មោះ គឺ ដោយចំណែកនៃឈ្មោះនោះឯង ។ ពាក្យថា **និងទេពពួកដទៃណា ដែលដូចគ្នា** បានដល់ សូម្បីទេវតាក្នុងចក្រវាឡដ៏សេសពួកដទៃណា ដែលដូចគ្នានឹងទេវតាទាំងនេះ គឺ ដូច្នោះដូចគ្នា ទាំងដោយពណ៌សម្បុរ ទាំងដោយឈ្មោះ ទេវតាទាំងនោះ មកហើយ ដូច្នេះ មានសេចក្តីថា ព្រះមានព្រះភាគទ្រង់សម្តែងទេវតាទាំងអស់ ដូចប្រមូលចងជាក្រុម ៗ ដោយបទតែមួយប៉ុណ្ណោះ ។ គ្រាទ្រង់សម្តែងពួកទេវតាក្នុងម៉ឺនលោកធាតុយ៉ាងនេះស្រេចហើយ ឥឡូវនេះ កាលនឹងទ្រង់សម្តែងសេចក្តីត្រូវការ ដែលទេវតាទាំងនោះមក ទើបត្រាស់គាថាជាដើមថា **មានជាតិ ( ការកើត ) ដែលតាំងនៅហើយ** ដូច្នេះ ។

គប្បីជ្រាបខ្លឹមសារនៃគាថានោះ ព្រះអរិយសង្ឃ ឈ្មោះថា **មាន**

**ជាតិដែលនៅចប់ហើយ** ព្រោះជាតិរបស់លោក ទៅប្រាសហើយ ។ លោកមានជាតិដែលទៅប្រាសហើយនោះឯង ។ ពួកយើងនឹងមើល គឺ នឹងឃើញព្រះអរិយសង្ឃ ដែលឈ្មោះថា មិនមានដែកគោល ព្រោះដែកគោល គឺ រាគៈ ទោសៈ និងមោហៈមិនមាន ឈ្មោះថា **ឆ្លងឱឃៈ (អន្លង់ទឹក) ហើយ** ព្រោះឆ្លងអន្លង់ទាំងបួនបានហើយ តាំងនៅ ឈ្មោះថា **រកអាសវៈមិនបាន** ព្រោះមិនមានអាសវៈទាំង ៤ ។ ឈ្មោះថា **អ្នកឆ្លងឱឃៈ** ព្រោះឆ្លងឱឃៈទាំងនោះឯង បានហើយ ឈ្មោះថា **នាគៈ** ព្រោះមិនធ្វើសេចក្តីអាក្រក់ ។ ពាក្យថា **អ្នកកន្លងកម្មខ្មៅ** គឺ និងពួកយើងគប្បីមើល គឺ គប្បីឃើញព្រះទសពលដែលទ្រង់រុងរឿងហើយ ដោយព្រះសិរី ដូចព្រះចន្ទដែលកន្លងអ័ព្ទខ្មៅ គឺ ពពកវលាហកៈ (ដូច្នោះ) ។ ទេវតាទាំងនោះ និងពួកទេវតាដទៃណា ដែលដូចគ្នានឹងទេវតាទាំងនោះ សូម្បីទាំងអស់ មកហើយដោយការប្រកាសឈ្មោះដើម្បីប្រយោជន៍នោះ ដោយប្រការដូច្នេះ ។

## ពាក្យរបស់មារ

[៨៤] ឥឡូវនេះ កាលនឹងទ្រង់សម្តែងដល់ពួកព្រហ្ម ទើបត្រាស់ពាក្យជាដើមថា **សុព្រហ្ម និងបរមត្ត** (បរមាត្ម័ន) ព្រហ្ម ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សុព្រហ្ម** បានដល់ ព្រហ្មប្រសើរមួយអង្គ និងព្រហ្មឈ្មោះបរមត្ត: ។ បទថា **ជាបុត្តរបស់អ្នកមានឫទ្ធិ ក៏មកជាមួយ** បានដល់ អរិយព្រហ្មទាំងនេះ ជាបុត្ររបស់ព្រះមានព្រះភាគ ទ្រង់មានឫទ្ធិ ក៏មកជាមួយគ្នា ។ បទថា **សុនង្កុមារ និងតិស្ស:** បានដល់ សនង្កុមារព្រហ្ម ១ អង្គ , តិស្សមហាព្រហ្ម ១ អង្គ ។ បទថា **សូម្បីគេក៏មក** បានដល់ សូម្បីតិស្សមហាព្រហ្មនោះ ក៏បានមក ។ មានព្រះតម្រាស់ក្នុងរឿងព្រហ្មនេះថា ៖

**មហាព្រហ្ម ចូលដល់ព្រហ្មលោក មានសេចក្ដីរុងរឿង មាន**
**រាងកាយធំ មានយស គ្រប់គ្រងព្រហ្មលោកមួយពាន់ ។**

បទថា **ព្រហ្មលោកមួពាន់** បានដល់ ព្រហ្មថ្នាក់អ្នកធំមួយពាន់អង្គមកហើយ អាចធ្វើពន្លឺក្នុងពាន់ចក្រវាឡ ដោយម្រាមព្រះហស្តតែមួយ ក្នុងម៉ឺនចក្រវាឡដោយម្រាមព្រះហស្តទាំង ១០ ។ បទថា **មហាព្រហ្មគ្រប់គ្រង** បានដល់ ព្រហ្មអ្នកធំតែមួយអង្គ គ្របសង្កត់ព្រហ្មពួកដទៃហើយ តាំងនៅក្នុងទីណា ។ បទថា **ចូលដល់** បានដល់ កើតក្នុងព្រហ្មលោក ។ បទថា **មានសេចក្ដីរុងរឿង** បានដល់ សម្បូរណ៍ដោយអានុភាព ។ បទថា **មានរាងកាយធំ** បានដល់ មានរាងកាយធំ មានទំហំរាងកាយស្មើនឹងពីរបីខេត្ត

របស់ពួកអ្នកស្រុកដែនមគធៈ ។ បទថា **មានយស** បានដល់ ប្រកបព្រម ដោយយស គោលគឺ សិរីនៃអត្តភាព ។ បទថា **ព្រហ្ម ១០ អង្គ ក៏មានឥស្សរៈក្នុងព្រហ្មមួយពាន់នោះ មានអំណាចប្រព្រឹត្តទៅចំពោះ ក៏មក** បាន ដល់ មហាព្រហ្មជាឥស្សរៈ ១០ អង្គ មានសភាពបែបនោះ ញុំាងអំណាច ឲ្យប្រព្រឹត្តទៅដោយចំពោះ ក៏បានមក ។ បទថា **និងព្រហ្មឈ្មោះ ហារិតៈ ដែលជាបរិវារហែហមហើយ ក៏មកក្នុងចំណោមព្រហ្មទាំងនោះ** សេចក្តីថា ក៏មហាព្រហ្មឈ្មោះ ហារិតៈ មានព្រហ្មទាំងសែនអង្គជាបរិវារ ក៏មកក្នុង ចំណោមព្រហ្មទាំងនោះ ។ បទថា **និងឃើញពួកទេវតាដែលមកទាំងអស់ ទាំងព្រះឥន្ទ្រ ព្រមទាំងព្រះព្រហ្ម** សេចក្តីថា ពួកទេវតា សូម្បីទាំងអស់ នោះ ធ្វើស្តេចសក្កទេវរាជឲ្យជាប្រធាន ហើយមក និងពួកព្រហ្ម ក៏ធ្វើ ហារិតមហាព្រហ្ម ឲ្យជាប្រធានហើយមក ។ បទថា **កងទ័ពមារ ក៏មក** សេចក្តីថា កងទ័ពមារ ក៏ចូលមក ។ បទថា **ពួកអ្នកចូរមើលសេចក្តី ល្ងង់ខ្លៅរបស់ក្រឹះស្ណៈ ( មារមានចិត្តបាប )** សេចក្តីថា អ្នកទាំងឡាយចូរ មើលភាពល្ងង់ខ្លៅរបស់មារមានចិត្តបាប ស្តេចមារ បង្គាប់បរិស័ទរបស់ខ្លួន យ៉ាងនេះថា ពួកអ្នកចូរចងទុក ។ បទថា **ការចងដោយរាគៈ ចូរមានដល់ ពួកអ្នក** សេចក្តីថា ទេវមណ្ឌលរបស់លោកទាំងអស់នេះ ចូរជាការចងទុក

ហើយដោយពាក្យ ។ បទថា **ពួកអ្នកចូរឡោមព័ទ្ធទុកដោយជុំវិញ បណ្តាពួកអ្នក នរណាៗ កុំបណ្តោយឲ្យរួចខ្លួន** សេចក្តីថា បណ្តាពួកអ្នក សូម្បីតែម្នាក់ កុំបណ្តោយឲ្យរួចខ្លួនសូម្បីតែម្នាក់ក្នុងពួកទាំងនេះ បាឋៈថា មាវោ មុញ្ចិត្ថ ពួកអ្នកកុំព្រលែង សេចក្តីក៏ដូចគ្នា ។ បទថា **មេទ័ពធំបញ្ជាកងទ័ពក្រឹះស្នៈក្នុងទីប្រជុំនោះ ដូច្នេះ** សេចក្តីថា មារដែលជាមេទ័ពធំបញ្ជាកងទ័ពមារក្នុងទីប្រជុំនោះយ៉ាងនេះ ។ បទថា **លើកដៃទះផែនដី** សេចក្តីថា ទះផែនដីដោយបាតដៃ ។ បទថា **ធ្វើសំឡេងគួរខ្លាច** សេចក្តីថា និងធ្វើសំឡេងដែលគួរខ្លាច ដើម្បីសម្តែងសំឡេងដែលគួរខ្លាចរបស់មារ ។ បទថា **ដូចមហាមេឃគ្រហឹម បង្អុរភ្លៀងព្រមទាំងផ្លេកបន្ទោរ** សេចក្តីថា ដូចមហាមេឃបង្អុរទឹកភ្លៀង ប្រព្រឹត្តទៅព្រមដោយផ្លេកបន្ទោរ ផ្គរគ្រហឹមយ៉ាងខ្លាំង ។ បទថា **គ្រានោះ មារនោះក៏ត្រឡប់ទៅហើយ** សេចក្តីថា សម័យនោះ កាលសម្តែងវត្ថុដែលគួរខ្លាចនោះស្រេចហើយ មារនោះ ក៏ត្រឡប់ទៅ ។ បទថា **ក្រេវក្រោធនឹងអ្នកដែលមិនប្រព្រឹត្តទៅក្នុងអំណាចខ្លួន** សេចក្តីថា កាលមិនអាចនឹងឲ្យនរណា ៗ ប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួនបាន ក៏ក្រេវក្រោធ ប្រទូស្តនឹងអ្នកដែលមិននៅក្នុងអំណាចខ្លួនអស់ចំណង់ដោយអំណាចរបស់ខ្លួនហើយ ក៏ថយចេញបាត់ទៅ ។

ដំណាលមកថា ព្រះមានព្រះភាគ ទ្រង់បានជ្រាបថា មារនេះឃើញសមាគមនេះធំ គិតថា នឹងធ្វើអន្តរាយដល់ការ **សម្រេចមគ្គផលក្នុងទីប្រជុំដ៏សំខាន់** ទើបបញ្ជូនកងទ័ពមារទៅសម្តែងវត្ថុដែលគួរខ្លាចប្លែក ៗ ក៏ឯប្រក្រតីរបស់ព្រះមានព្រះភាគ ក៏គឺ ក្នុងទីណានឹងមិនមានការសម្រេចមគ្គផល ក្នុងទីនោះ ព្រះអង្គទ្រង់មិនហាមមារ ដែលសម្តែងវត្ថុដែលគួរខ្លាចរបស់មារ តែក្នុងទីណាមានការសម្រេចមគ្គផល ក្នុងទីនោះព្រះអង្គ ទ្រង់អធិដ្ឋានមិនឲ្យបរិស័ទឃើញរូប មិនឲ្យឮសំឡេងមារ ក៏ព្រោះក្នុងសម័យនេះ នឹងមានការត្រាស់ដឹងមគ្គផលធំ ដូច្នោះ ទើបទ្រង់អធិដ្ឋានដោយប្រការដែលពួកទេវតានឹងមិនឃើញ នឹងមិនឮសំឡេងរបស់មារនោះ ។ ព្រោះដូច្នោះ ព្រះមាន-ព្រះភាគទើបត្រាស់ថា កាលនោះ មារនោះ ក្រេវក្រោធជាមួយអ្នកដែលមិនប្រព្រឹត្តទៅក្នុងអំណាចខ្លួន បានគេចចេញបាត់ទៅ ។

បទថា **ព្រះសាស្តាទ្រង់មានភ្នែក ទ្រង់ពិចារណា និងទ្រង់ជ្រាបហេតុនោះទាំងអស់ហើយ** សេចក្តីថា ព្រះមានព្រះភាគទ្រង់ជ្រាប និងទ្រង់ពិចារណាហេតុនោះទាំងអស់ហើយ ។ បទថា **កងទ័ពមារចូលមកហើយ ភិក្ខុទាំងឡាយ ពួកអ្នកចូរដឹងច្បាស់ចំពោះពួកគេ** សេចក្តីថា ព្រះមាន-ព្រះភាគត្រាស់ថា ភិក្ខុទាំងឡាយកងទ័ពមារចូលមកហើយ ពួកអ្នកចូរដឹង

ពួកគេតាមសមគួរដល់ខ្លួន ពួកអ្នកចូរចូលផលសមាបត្តិ ។ បទថា **បានធ្វើសេចក្តីព្យាយាមហើយ** សេចក្តីថា ភិក្ខុទាំងនោះ ប្រារព្ធសេចក្តីព្យាយាមដើម្បីប្រយោជន៍ចូលផលសមាបត្តិ ។ បទថា **គេចចេញពីលោកដែលប្រាសរាគៈហើយ** សេចក្តីថា មារ និងអ្នកត្រាច់ទៅតាមមារ បានចៀសចេញទៅយ៉ាងឆ្ងាយពីពួកព្រះអរិយៈ អ្នកប្រាសចាករាគៈហើយនោះឯង ។ បទថា **សូម្បីតែរោមរបស់ពួកលោក ក៏មិនកម្រើក** សេចក្តីថា សូម្បីតែរោមរបស់លោកអ្នកប្រាសចាករាគៈទាំងនោះ ក៏មិនញាប់ញ័រ ។ គ្រានោះមារប្រារព្ធពួកភិក្ខុហើយ បានពោលគាថានេះថា ៖

**ពួកសាវករបស់ព្រះអង្គទាំងអស់ ពិជិតសង្គ្រាមបានហើយ កន្លងបង់នូវសេចក្តីភ័យខ្លាចបានហើយ មានយស ប្រាកដក្នុងប្រជុំជន រីករាយហើយជាមួយជាមួយព្រះអរិយៈ ដែលកើតហើយ ។**

បណ្តាបទទាំងនោះ បទថា **រីករាយហើយ ជាមួយភូតទាំងឡាយ** សេចក្តីថា រីករាយ គឺ រីករាយទូទៅជាមួយនឹងពួកព្រះអរិយៈ ដែលកើតហើយ (ភូត) គឺ កើតព្រមហើយ ក្នុងសាសនារបស់ព្រះទសពល ។ បទថា **ប្រាកដក្នុងប្រជុំជន** សេចក្តីថា ប្រាកដដោយវិសេស គឺ ដឹងច្បាស់

បានដល់ ដែលពួកជនស្គាល់ជាក់ជាយ៉ាងក្រៃលែង ។ ក៏ព្រោះមហាសម័យ-សូត្រនេះ ជាទីស្រឡាញ់ ជាទីពេញចិត្តរបស់ពួកទេវតា ដូច្នោះ ក្នុងស្ថានទីថ្មីៗ កាលនឹងពោលមង្គល ក៏គប្បីពោលតែព្រះសូត្រនេះ ប៉ុណ្ណោះឯង ។

បានឮថា ពួកទេវតានាំគ្នាគិតថា ពួកយើងនឹងស្តាប់ព្រះសូត្រនេះហើយ ក៏ផ្ទៀងត្រចៀកស្តាប់ ។ ក៏ឯកាលព្រះមានព្រះភាគ ទ្រង់សម្តែងចប់ ទេវតាចំនួនមួយសែនកោដិ បានសម្រេចព្រះអរហត្តហើយ អ្នកដែលជាព្រះសោតាបន្នជាដើម មិនមានការរាប់ ។ និងរឿងនេះ គប្បីមាន ព្រោះសេចក្តីដែលជាទីស្រឡាញ់ ជាពេញចិត្តរបស់ពួកទេវតា ។

មានរឿងដំណាលថា ទីវត្តកោដិបព៌ត មានទេពធីតាមួយអង្គអាស្រ័យនៅត្រង់ដើមខ្នុរ ជិតទ្វារល្ហានខ្នុរ ។ ភិក្ខុកម្លោះមួយរូបទន្ទេញព្រះសូត្រនេះ ក្នុងខាងមុខ ។ ទេពធីតាបានស្តាប់ ក្នុងវេលាចប់ព្រះសូត្រ ក៏បានឲ្យសាធុការដោយសំឡេងយ៉ាងខ្លាំង ។

នោះអ្នកណា ? ភិក្ខុកម្លោះសួរ ។

ខ្ញុំម្ចាស់ជាទេពធីតាលោកម្ចាស់ ទេពធីតាឆ្លើយ ។

ហេតុដូចម្តេច ទើបបានឲ្យសាធុការ ភិក្ខុកម្លោះសួរទៀត ។

លោកលោកម្ចាស់ ខ្ញុំម្ចាស់បានស្តាប់ព្រះសូត្រនេះ ក្នុងថ្ងៃដែល

ព្រះទសពលប្រថាប់គង់សម្ដែងត្រង់ព្រៃធំ ថ្ងៃនេះបានស្ដាប់ ( ទៀត ) ធម្មបទនេះ លោកកាន់យកល្អហើយ ព្រោះមិនធ្វើឲ្យអក្សរសូម្បីតែមួយតួឃ្លាតពីពាក្យដែលព្រះមានព្រះភាគសម្ដែងទុកវិនាសទៅ ទេពធីតាបញ្ចាក់ ។

កាលព្រះទសពលកំពុងសម្ដែង នាងបានស្ដាប់ឬ ? ភិក្ខុសួរទៀត ។

ពិតហើយ លោកម្ចាស់ ទេពធីតាទទួល ។

គេថា ទេវតាមកប្រជុំគ្នាច្រើន ហើយនាងឈរស្ដាប់ទីណា ?

លោកម្ចាស់ ខ្ញុំម្ចាស់ជាទេវតាអ្នកនៅព្រៃធំ ក៏កាលពួកទេវតាអ្នកមានសក្តិធំកំពុងនាំគ្នាមក ខ្ញុំមិនមានកន្លែងនៅក្នុងជម្ពូទ្វីបឡើយ បានទៅកាន់តម្ពបណ្ណិទ្វីបនេះ ឈរនៅមាត់ប្រាំងត្រង់កំពង់ជម្ពុកោល សូម្បីថយដល់កំពង់នោះក៏ដោយ កាលពួកទេវតាអ្នកមានសក្តិធំកំពុងនាំគ្នាមក ក៏ថយៗ ទៅដោយលំដាប់ ត្រាំទឹកសមុទ្រជ្រៅត្រឹម.ក ផ្នែកខាងក្រោយស្រុកធំក្នុងខេត្តរោហណៈ ហើយក៏ឈរស្ដាប់ក្នុងទីនោះ នាងបរិយាយរៀបរាប់ល្អិតល្អន់ ។

ពីទីដែលនាងឈរនោះ ឆ្ងាយណាស់ នាងនឹងឃើញព្រះសាស្ដាឬទេវតា ។

លោកម្ចាស់ ! និយាយអ្វី ខ្ញុំម្ចាស់យល់ថា ព្រះសាស្ដាទ្រង់សម្ដែង

ធម៌នៅត្រង់ព្រៃធំ ទ្រង់ក្រឡេកមើលខ្ញុំម្ចាស់រឿយៗ ខ្ញុំខ្លាច ខ្ញុំខ្មាស ។

បានឮមកថា ថ្ងៃនោះ មានទេវតាមួយសែនកោដិសម្រេចព្រះអរហត្ត ហើយ ឯនាងសោត ពេលនោះសម្រេចព្រះអរហត្តឬ ?

មិនទេ លោកម្ចាស់ដ៏ចម្រើន

សម្រេចអនាគាមិផល ឬ ?

មិនទេ លោកម្ចាស់ដ៏ចម្រើន

ដូច្នោះ នឹងសម្រេចសកទាគាមិផល ឬ ?

មិនទេ លោកម្ចាស់ដ៏ចម្រើន

គេថា ពួកទេវតាដែលសម្រេចមគ្គបីរាប់មិនបាន មែនទេនាង នាងនឹងជាព្រះសោតាបន្ន ឬ ?

ក្នុងថ្ងៃនោះ ទេពធីតាសម្រេចសោតាបត្តិផល មានការខ្មាស ទើបនិយាយថា លោកម្ចាស់សួរវត្ថុមិនគួរសួរ ( សួរជ្រៀតជ្រែក ) លំដាប់នោះភិក្ខុនោះ ទើបពោលចំពោះនាងថា ទេវតា ! នាងនឹងសម្តែងកាយឲ្យអាត្មាឃើញបានទេ ?

នឹងសម្តែងខ្លួនអស់ទាំងមិនបានទេ លោកដ៏ចម្រើន ! ខ្ញុំម្ចាស់នឹងសម្តែងដល់លោកម្ចាស់ត្រឹមតែម្រាមដៃ ។

ថាហើយ ក៏យកម្រាមដៃស៊កចូលខាងក្នុងល្អាង តាមវន្ទសោរ ។ ម្រាមដៃក៏ដូចជាវេលាព្រះចន្ទ ព្រះអាទិត្យរះឡើងជាពាន់ ៗ ដួង ទេពធីតាពោលថា ចូរកុំប្រមាទណា លោកលោកម្ចាស់ ! ហើយសំពះភិក្ខុកម្ដោះត្រឡប់ទៅ ។ សូត្រនេះ ជាទីស្រឡាញ់ ជាទីពេញចិត្តរបស់ទេវតាទាំងឡាយយ៉ាងនេះ ទេវតាទាំងឡាយ រមែងសម្គាល់ថា ព្រះសូត្រនោះជារបស់យើងដោយប្រការដូច្នេះ ។

" ចប់ អដ្ឋកថា មហាសម័យសូត្រទី ៧ "

## អដ្ឋកថា សក្កបញ្ហសូត្រទី ៨

*[៨៥] សក្កបញ្ហសូត្រផ្តើមឡើងថា ខ្ញុំបានស្តាប់មកយ៉ាងនេះ ។*

*តទៅនេះ ជាការអធិប្បាយសេចក្តីចំពោះបទដែលមិនជាក់ច្បាស់ក្នុងសក្កបញ្ហសូត្រនោះ ។ បទថា អម្ពសណ្ឌា នាម ព្រាហ្មណគាមោ គឺដំណាលមកថា ស្រុកនោះ នៅមិនឆ្ងាយពីព្រៃស្វាយ ដូច្នោះទើបហៅថា អម្ពសណ្ឌ ។ បទថា វេទិយកេ បព្វតេ គឺ ន័យថា ភ្នំនោះមានព្រៃពណ៌ខៀវ ដូចវេទិកាកែវមណី ដែលកើតឡោមព័ទ្ធជុំវិញត្រង់ជើងភ្នំ ដូច្នោះទើបហៅថា ភ្នំវេទិយកៈ ។ បទថា ឥន្ទសាលគុហាយំ គឺ ពីមុនមកល្អាងនោះ នៅចន្លោះកូនភ្នំពីរ និងក្បែរទ្វារល្អាងនោះ មានដើមពោនស្វា ដូច្នោះទើបហៅថា ល្អាងពោនស្វា តមកពួកមនុស្សក៏ការពារជញ្ជាំងល្អាងនោះបិទទ្វារមុខ ធ្វើទីពួនសម្ងំ ដែលវិចិត្រដោយក្បាច់ផ្កា ក្បាច់វល្លិ៍ បូកកំបោរស្រួចស្រេចរៀបរយហើយ ក៏ថ្វាយចំពោះព្រះមានព្រះភាគ ។ តែមនុស្សទាំងឡាយ ក៏នៅស្គាល់ល្អាងនោះថា ល្អាងពោនស្វា តាមឈ្មោះពីដើមនោះឯង ។ ព្រះអានន្ទសំដៅយកល្អាងនោះ ទើបពោលថា ក្នុងល្អាងពោនស្វា ។*

បទថា ឧស្សុក្កំ ឧទនាទិ គឺ កើតសេចក្ដីឧស្សាហ៍ដែលប្រកបដោយធម៌ ។ សួរថា ក៏ស្ដេចសក្កៈនោះ ទ្រង់គាល់ព្រះមានព្រះភាគ មករឿយៗមិនមែនឬ មានទេវតាប្រជុំគ្នានៅទីណានោះ ក៏មិនមែនថា ស្ដេចសក្កៈនេះមិនធ្លាប់យាងមក ដែលឈ្មោះថា ទេវបុត្តដូចស្ដេចសក្កៈនៅដោយប្រមាទក៏មិនមែន កាលបើដូច្នោះ ហេតុដូចម្ដេច ស្ដេចសក្កៈនោះ ទើបទ្រង់កើតសេចក្ដីឧស្សាហ៍ ដូចអ្នកមិនធ្លាប់មកគាល់ព្រះពុទ្ធហ្ន៎ ? ឆ្លើយថា ព្រោះត្រូវសេចក្ដីខ្លាចស្លាប់គំរាម ។

ន័យថា សម័យនោះ ព្រះជន្មាយុរបស់ស្ដេចសក្កៈអស់ហើយ ។ ស្ដេចសក្កៈទ្រង់បានឃើញបុព្វនិមិត្ត ៥ ប្រការ ទ្រង់ជ្រាបថា ឥឡូវនេះយើងអស់អាយុហើយ ក៏គ្រៀងសម្គាល់សេចក្ដីស្លាប់ ប្រាកដដល់ទេវបុត្តពួកណា ក្នុងទេវបុត្តទាំងនោះ ពួកណាកើតក្នុងទេវលោកដោយបុញ្ញកម្មបន្តិចបន្តួច ពួកនោះក៏រមែងដល់សេចក្ដីភ័យតក់ស្លុត ព្រោះសេចក្ដីខ្លាចថា គ្រានេះយើងនឹងកើតទីណាហ្ន៎ ពួកណា បានត្រៀមការពារភ័យដែលគួរភ័យខ្លាចទុក ធ្វើបុណ្យទុកច្រើនបានកើតហើយ ពួកនោះគិតថា យើងអាស្រ័យទានដែលខ្លួនបានឲ្យ សីលដែលរក្សាមក និងភាវនាដែលបានអប់រំទុកហើយ នឹងសោយសម្បត្តិក្នុងទេវលោកជាន់ខ្ពស់ រមែងមិនខ្លាច ។

ចំណែកស្តេចសក្កទេវរាជ កាលទ្រង់បានឃើញបុព្វនិមិត្ត ក៏ទ្រង់សម្លឹង មើលសម្បត្តិទាំងអស់យ៉ាងនេះថា ទេវនគរម៉ឺនយោជន៍ វេជយន្តប្រាសាទ កម្ពស់ ១,០០០ យោជន៍ សុធម្មាទេវសភា ៣០០ យោជន៍ ដើមមហា បារិឆត្តកៈ កម្ពស់ ១០០ យោជន៍ ថ្មបណ្ឌុកម្ពល ៦០ យោជន៍ នាង ទេពអប្សរ ២៥ កោដិ ទេវបរិស័ទក្នុងពីរទេវលោក នន្ទឧទ្យាន ចិត្តលតា- ឧទ្យាន មិស្សកឧទ្យាន ផារុសកឧទ្យាន ទ្រង់ត្រូវសេចក្តីភ័យខ្លាចគ្រប សង្កត់ថា លោកអើយ សម្បត្តិរបស់យើងនេះ នឹងវិនាសហ្ន៎ តទៅក៏ទ្រង់ សម្លឹងមើលថា មាននរណាខ្លះហ្ន៎ មិនថា ជាសមណៈ ជាព្រាហ្មណ៍ ឬ មហាព្រហ្មអ្នកជាព្រះបិតារបស់លោក ដែលគប្បីដកកូនសរ គឺ សេចក្តី សោក ដែលអាស្រ័យបេះដូងយើង ហើយធ្វើឲ្យសម្បត្តិនេះតាំងមាំបាន កាលទ្រង់ពិចារណារកមើលអ្នកណា ៗ ក៏មិនឃើញ ក៏ទ្រង់បានឃើញថា មានតែព្រះសម្មាសម្ពុទ្ធប៉ុណ្ណោះ ដែលទ្រង់អាចដកសេចក្តីសោក ដែល កើតដល់ទេវតាទាំងឡាយ ដូចយើង សូម្បីទាំងសែនបាន ។ តមក ដោយ សម័យនោះឯង សេចក្តីខ្វល់ខ្វាយដើម្បីនឹងគាល់ព្រះមានព្រះភាគ ក៏បាន កើតឡើងដល់ស្តេចសក្កៈដែលជាធំលើទេវតា ដែលទ្រង់ត្រិះរិះយ៉ាងនេះ ។

ពាក្យថា **ឥឡូវនេះ ព្រះមានព្រះភាគប្រថាប់នៅទីណាហ្ន៎** គឺ ស្តេច

សក្កៈទ្រង់គិតថា ព្រះមានព្រះភាគប្រថាប់នៅត្រង់ខេត្តណា ទ្រង់ចូលទៅអាស្រ័យក្រុងអ្វី កំពុងសោយបច្ច័យរបស់អ្នកណា ទ្រង់កំពុងសម្តែងអម្រឹតធម៌ដល់អ្នកណា ។ ពាក្យថា **ទ្រង់បានឃើញហើយដែរ** សេចក្តីថា ទ្រង់បានឃើញ គឺ ទ្រង់ចាក់ធ្លុះហើយ ។ ពាក្យថា **អ្នកនិរទុក្ខទាំងឡាយ** នេះជាពាក្យដែលគួរស្រឡាញ់ ជាសំនួនពាក្យរបស់ពួកទេវតាដោយចំពោះ មានអធិប្បាយថា អ្នកមិនមានទុក្ខក៏បាន ។ ក៏ហេតុដូចម្តេច ស្តេចសក្កៈនេះទ្រង់ទើបហៅពួកទេវតា ដើម្បីត្រូវការជាសម្លាញ់ ។

ក្នុងកាលមុន ក៏បានឮមកថា ស្តេចសក្កៈនេះ កាលព្រះមានព្រះ-ភាគកំពុងប្រថាប់នៅក្នុងកុដិជិតដើមសាល ក៏ស្តេចទៅបានគាល់ដោយខ្លួនឯងម្តងហើយ ។ ព្រះសាស្តាទ្រង់ព្រះតម្រិះថា ញាណរបស់ស្តេចសក្កៈមិនទាន់ចាស់ក្លា តែបើរង់ចាំបន្តិចទៀត ខណៈដែលតថាគតនៅឈ្នាងពោនស្វា ស្តេចសក្កៈនឹងឃើញបុព្វនិមិត្ត ៥ យ៉ាង ទ្រង់ខ្លាចចំពោះមរណភ័យនឹងចូលមករកព្រមជាមួយពួកទេវតាក្នុងពីរទេវលោក ទ្រង់សួរបញ្ហា ១៤ ប្រការ កាលដោះស្រាយចប់បញ្ហា ជាប់ទាក់ទងនឹងឧបេក្ខាហើយ ទ្រង់តាំងនៅក្នុងសោតាបត្តិផលព្រមនឹងទេវតា ៨ ម៉ឺនអង្គ ដូច្នេះ ទើបមិនប្រទានព្រះឱកាស ។ ស្តេចសក្កៈនោះ ទ្រង់ព្រះតម្រិះថា ព្រះសាស្តាមិន

ប្រទានព្រះឱកាស ព្រោះកាលមុនយើងទៅតែម្នាក់ឯង យើងមិនទាន់មាន ឧបនិស្ស័យនៃមគ្គផលដោយពិត ក៏កាលយើងតែម្នាក់មានឧបនិស្ស័យ ព្រះមានព្រះភាគ ទ្រង់នឹងសម្ដែងធម៌ដល់បរិស័ទ សូម្បីជាបដល់ទីបំផុតចក្រវាឡ ក៏ជាការពិតណាស់ ក្នុងទេវលោកទាំងពីរជាន់ អ្នកណាម្នាក់គង់នឹងមានឧបនិស្ស័យជាពិតប្រាកដ ព្រះសាស្ដាគង់នឹងទ្រង់សំដៅយកអ្នកនោះ ហើយទ្រង់សម្ដែងធម៌ដល់យើង កាលបានស្ដាប់ធម៌នោះហើយ ក៏គង់នឹងរលត់សេចក្ដីទោមនស្សរបស់ខ្លួនបាន ដូច្នេះហើយ ទើបត្រាស់ហៅដើម្បីត្រូវការជាសម្ងាញ់ ។

ពាក្យថា **ពួកទេពជាន់តាវតឹង្សទទួលនូវព្រះតម្រាស់ថា សូមសេចក្ដីចម្រើនចូរមានដល់ព្រះអង្គយ៉ាងនោះ** សេចក្ដីថា ចូរជាយ៉ាងនោះចុះមហារាជ ពួកយើងនឹងទៅគាល់ព្រះដ៏មានព្រះភាគ ការកើតឡើងរបស់ព្រះពុទ្ធ មានសភាពដែលរកបានលំបាក សូមសេចក្ដីចម្រើន ចូរមានចំពោះព្រះអង្គ តែទ្រង់មិនត្រាស់ថា សូមឲ្យយើងទាំងឡាយចូរទៅលេងតាមភ្នំ ទៅលេងតាមទន្លេ ហើយទ្រង់ប្រកបពួកខ្ញុំព្រះអង្គទុកក្នុងឋានៈបែបនេះ ។ ពាក្យថា **បានស្ដាប់ហើយ** គឺ ទទួលព្រះរាជឱង្ការរបស់ស្ដេច ទុកដោយសិរសា ។

ពាក្យថា **ត្រាស់ហៅបញ្ចសិខៈ បុត្តគន្ធព្វ** គឺ (សួរថា) ក៏កាល

ត្រាស់ហៅពួកទេវតាទាំងនោះហើយ ហេតុដូចម្តេច ទើបត្រាស់ហៅបញ្ច-សិខគន្ធព្វទេវបុត្តនេះទៀត ? ឆ្លើយថា ដើម្បីឲ្យសូមប្រទានព្រះឱកាស ។ ដំណាលមកថា ស្តេចសក្កៈនោះ ទ្រង់មានសេចក្តីគិតយ៉ាងនេះថា ការនឹងនាំយកពួកទេវតាក្នុងពីរទេវលោក ចូលទៅគាល់ព្រះសាស្តាព្រមគ្នា មិនសមគួរ ក៏បញ្ចសិខៈនេះ ជាឧបដ្ឋាកអ្នកបម្រើ ដែលព្រះទសពលប្រោសប្រាណ ទៅទូលសួរបញ្ហាហើយ ស្តាប់ធម៌បានគ្រប់ខណៈដែលត្រូវការ ពួកយើងបញ្ជូនបញ្ចសិខៈនេះ ទៅជាមុនឲ្យសូមប្រទានព្រះឱកាស ហើយទើបចូលគាល់ទូលសួរបញ្ហាក្នុងវេលាដែលបញ្ចសិខៈនេះ សូមប្រទានព្រះឱកាសស្រេចហើយ ទើបត្រាស់ហៅដើម្បីឲ្យសូមប្រទានព្រះឱកាស ។

ពាក្យថា **សូមសេចក្តីចម្រើន ចូរមានដល់ព្រះអង្គយ៉ាងនោះ** សេចក្តីថា សូម្បីបញ្ចសិខៈនោះក៏គាំទ្រយ៉ាង ម៉ឺងម៉ាត់ថា ព្រះកុរុណាថ្លៃវិសេសមហារាជ សូមសេចក្តីចម្រើនចូរមានដល់ព្រះអង្គ ដែលព្រះអង្គមិនត្រាស់ចំពោះទូលព្រះបង្គំថា អ្នកនិរទុក្ខមកចុះ ពួកយើងនឹងត្រាច់ទៅលេងកីឡាឯឧទ្យានជាដើម ឬទៅលេងមហោស្រពរបស់អ្នករបាំជាដើម (តែ) ត្រាស់ថា ពួកយើងនឹងទៅគាល់ព្រះពុទ្ធ នឹងស្តាប់ធម៌ ហើយក៏ទទួលព្រះតម្រាស់របស់ស្តេចសក្កៈជាធំជាងពួកទេវតា ហើយក៏ចូលរួមក្បួនតាមស្តេចទៅជា

មួយគ្នា ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ពិណពណ៌លឿងដូចផ្លែព្នៅ** គឺ ពិណពណ៌លឿងដូចផ្លែព្នៅទុំ ។ បានឮមកថា ប្រហោងពិណនោះ ធ្វើដោយមាស ដងធ្វើដោយកែវឥន្ទនិល ខ្សែធ្វើដោយប្រាក់ ត្រឡោកធ្វើដោយកែវប្រវាឡ ។ ស្នូកពិណមួយគាវុត ឈើរឹតខ្សែឲ្យតឹងមួយគាវុត ដងកំណាត់លើមួយគាវុត ដូច្នេះ ពិណទើបមានខ្នាតបីគាវុត ។ បញ្ចសិខៈនោះ កាន់ពិណនោះ ដូចដែលពោលមកនេះហើយ ក៏បញ្ចេញការប្រគំយ៉ាងជំនាញ ប្រើចុងក្រចកដេញបន្ទរសំឡេងយ៉ាងពីរោះ ឲ្យពួកទេវតាដ៏សេសជ្រាបវេលាការទៅរបស់ស្តេចសក្កៈ ហើយឈរក្នុងទីដ៏សមគួរមួយ ។ កាលគណៈទេវតាប្រជុំគ្នាតាមសញ្ញានៃសំឡេងភ្លេងរបស់បញ្ច-សិខៈនោះ ពេលនោះឯង ស្តេចសក្កៈជាធំជាងទេវតា ។ល។ ក៏ស្តេចទៅប្រាកដត្រង់ក្នុំវេទិយកៈ ។

ពាក្យថា **កើតពន្លឺរុងរឿងក្រៃលែង** គឺ ក្នុងថ្ងៃដទៃៗ ក៏កើតពន្លឺភ្លឺដោយពន្លឺរបស់ទេវតា មារ ឬព្រហ្ម ត្រឹមតែម្នាក់ប៉ុណ្ណោះ តែថ្ងៃនោះកើតមានពន្លឺភ្លឺស្វាងដូចគ្នា រុងរឿងទៅជាប់តគ្នាតែមួយ ដូចវេលាព្រះចន្ទនិង ព្រះអាទិត្យរះឡើងដល់ទៅ ១ ពាន់ដួង ព្រោះពន្លឺនៃពួកទេវតា ក្នុងទេវលោកទាំងពីរជាន់ ។

ពាក្យថា **ពួកអ្នកនៅក្នុងស្រុកដោយជុំវិញ** គឺ ពួកអ្នកនៅក្នុងស្រុកជិតខាង ។ ជំណាលមកថា ក្នុងវេលាអាហារល្ងាចជាប្រក្រតីនោះឯងកាលពួកក្មេងៗ កំពុងនាំគ្នាលេងត្រង់កណ្តាលភូមិស្រុក ស្តេចសក្កៈក៏បានយាងទៅក្នុំវេទិយកៈនោះ ព្រោះដូច្នោះ ពួកមនុស្សកាលបានឃើញ ទើបនាំគ្នាពោលយ៉ាងនោះ ។ ក៏ពួកទេវតាចូលមកគាល់ព្រះមានព្រះភាគ ត្រង់យាមកណ្តាលមិនមែនឬ ហេតុដូចម្តេច ស្តេចសក្កៈនេះ ទើបបានស្តេចមកក្នុងភាគជំបូងនៃយាមដើមហ្ន៎ ។ ព្រោះទ្រង់ត្រូវមរណភ័យន៉ុះឯងគម្រាម ។ ពាក្យថា **អ្វីហ្ន៎** សេចក្តីថា ពួកមនុស្សនិយាយគ្នាថា ហេតុអ្វីថ្ងៃនេះទេវតាឬព្រហ្ម ដែលមានសក្តិធំអង្គណាហ្ន៎ ចូលគាល់ព្រះមានព្រះភាគ ដើម្បីនឹងទូលសួរបញ្ហា ដើម្បីនឹងស្តាប់ធម៌ ហើយព្រះមានព្រះភាគនឹងទ្រង់ដោះស្រាយបញ្ហា នឹងទ្រង់សម្តែងធម៌យ៉ាងណា លាភរបស់ពួកយើង ពួកយើងដែលមានព្រះសាស្តា ទ្រង់បន្ទោបង់សេចក្តីសង្ស័យរបស់ពួកទេវតា ស្តេចប្រថាប់នៅក្នុងវត្តជិត ៗ ដែលពួកយើងបានថ្វាយកិច្ចាមួយថាសខ្លះ កិច្ចាមួយវែកខ្លះ ហើយក៏តក់ស្លុតរោមបះឡើង រោមព្រឺព្រួច ប្រណម្យដៃដ៏រុងរឿង ដែលរួមយកម្រាមទាំង ១០ ដាក់លើសិរសា ឈរនមស្ការ ។

ពាក្យថា **ចូលគាល់លំបាក** គឺ គប្បីចូលទៅអង្គុយជិតបានលំបាក ។

យើងនៅមានរាគៈ ទោសៈ មោហៈ (តែ) ព្រះសាស្តា មិនមានរាគៈ ទោសៈ មោហៈ ព្រោះដូច្នោះ ព្រះតថាគតទាំងឡាយ ដែលមនុស្សដូចជាយើង គប្បីចូលទៅអង្គុយជិតបានលំបាក ។ បទថា **ទ្រង់មានឈាន** គឺ ទ្រង់មានឈានដោយលក្ខណូបនិជ្ឈាន និងអារម្មណូបនិជ្ឈាន ។ ឈ្មោះថា ទ្រង់ត្រេកអរក្នុងឈាន ព្រោះទ្រង់ត្រេកអរក្នុងឈាននោះឯង ។ ពាក្យថា **បន្ទាប់ពីទ្រង់ពួនសម្ងំ** គឺ ក្នុងលំដាប់ដែលទ្រង់ពួនសម្ងំនោះ ឬពេលដែលទ្រង់ពួនសម្ងំ ព្រោះដូច្នោះ ទើបមិនមែនចូលគាល់លំបាក ព្រោះទ្រង់មានឈានទ្រង់ត្រេកអរក្នុងឈាន ប៉ុណ្ណោះ តែចូលគាល់លំបាក ព្រោះស្តេចទើបតែទ្រង់ពួនសម្ងំកាលប៉ុន្មាននេះឯង ។ ពាក្យថា **គប្បីឲ្យប្រោស** គឺ គប្បីឲ្យទ្រង់ពេញព្រះហឫទ័យ ។ ស្តេចសក្កៈត្រាស់ថា អ្នកគប្បីធ្វើឲ្យទ្រង់ប្រទានព្រះឱកាសដល់យើង ។ សួរថា កាន់ពិណដែលមានពណ៌លឿងដូចផ្លែព្នៅហើយក៏ពិណនោះទុកមុន មិនមែនឬ ? ឆ្លើយថា អើ ! កាន់ទុកហើយក៏ពិណនោះស្ពាយទុកត្រង់ចង្កេះស្មា ដោយអំណាចទៅតាមផ្លូវ ឥឡូវនេះយកវាមកដាក់ទុកត្រង់ដៃឆ្វេង ធ្វើការត្រៀមនឹងច្រៀង ទើបកាន់ទុក ដូច្នោះទើបពោលថា កាន់ទុកហើយ ។ ពាក្យថា **ឲ្យទ្រង់បានឮ** គឺ ឲ្យទ្រង់ស្តាប់ ។ ពាក្យថា **ទាក់ទងដោយព្រះពុទ្ធ** គឺ ប្រារព្ធព្រះពុទ្ធ អធិប្បាយថា ធ្វើ

ព្រះពុទ្ធជាទីពឹងឲ្យប្រព្រឹត្តទៅ ។ សូម្បីក្នុងបទដ៏សេស ក៏ន័យនេះឯង ។

## គាថារបស់បញ្ចសិខគន្ធព្វទេវបុត្ត

[៨៦] គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **ប្អូនសុរិយវច្ចសា បងសូមសំពះស្តេចតិម្ពរុជាបិតារបស់ប្អូន** នេះតទៅ ៖

ពាក្យថា សូរិយវច្ចសា គឺ មានរាងកាយស្មើនឹងព្រះសុរិយៈ ។ បានឮមកថា រស្មីតាំងឡើងត្រង់ចុងជើងរបស់ទេវធីតានោះ ហើយផ្សាយឡើងទៅជរាបទល់នឹងចុងសក់ដូច្នោះ ទើបប្រាកដដូចពន្លឺព្រះអាទិត្យដ៏ស្រទន់ ៗ ដោយប្រការដូច្នេះ ទេវតាទាំងឡាយ ទើបស្គាល់នាងថា **សុរិយវច្ចសា** ។ បញ្ចសិខៈ ប្រាថ្នាយកសេចក្តីនោះ ទើបពោលថា **ប្អូនសុរិយវច្ចសា** ដូច្នេះ ។ បញ្ចសិខៈ បងសូមសំពះស្តេចតិម្ពរុគន្ធព្វទេវរាជជាបិតារបស់ប្អូន ។ ពាក្យថា **ព្រោះហេតុដែលប្អូនជាកល្យាណី បានកើតមកហើយ** គឺ ព្រោះអាស្រ័យតិម្ពរុទេវរាជណា ប្អូនស្រស់ល្អ គឺ ស្អាតគ្រប់ចំណែក ទើបបានកើតមក ។ ពាក្យថា **ញុំាងសេចក្តីត្រេកអរឲ្យកើតដល់បង** គឺ ធ្វើឲ្យសេចក្តីរីករាយនិងសេចក្តីពេញចិត្ត ចម្រើនដល់បង ។

ពាក្យថា **ដូចខ្យល់ ជាទីប្រាថ្នារបស់អ្នកបែកញើស** អធិប្បាយថា

ខ្យល់ជាទីស្រឡាញ់ពេញចិត្តរបស់អ្នកដែលបែកញើស ដើម្បីឲ្យញើសស្ងួតអស់យ៉ាងណា ក៏ដូច្នោះ ។ ពាក្យថា **ដូចទឹក ជាទីប្រាថ្នារបស់អ្នកស្រេក** គឺ ( ទឹកជាទីប្រាថ្នា ) របស់អ្នកដែលត្រូវសេចក្តីស្រេកគ្របសង្កត់ហើយ ប្រាថ្នានឹងផឹក ។ ពាក្យថា **អ្នកមានរស្មីចាកកាយ** គឺ រស្មីចាកកាយរបស់អ្នកមានហើយ ហេតុនោះ អ្នកទើបឈ្មោះថា អ្នកមានរស្មីចាកកាយ ។ បញ្ចសិខៈ ពោលប្រារព្ធដល់នាងសុរិយវច្ចសានោះឯង ។ ពាក្យថា **ដូចធម៌ជាទីស្រឡាញ់នៃព្រះអរហន្តទាំងឡាយ** គឺ ដូចលោកុត្តរធម៌ ៩ យ៉ាង របស់ព្រះអរហន្តទាំងឡាយ ។

ពាក្យថា **របស់បុគ្គលឃ្លាន** គឺ របស់អ្នកដែលត្រូវសេចក្តីឃ្លាន គ្របសង្កត់ ប្រាថ្នានឹងបរិភោគ ។ ពាក្យថា **ត្រូវយកទឹករំលត់ភ្លើងដែលកំពុងឆេះ** គឺ បញ្ចសិខៈ ពោលថា នរណា ៗ គប្បីយកទឹករំលត់ភ្លើងដែលកំពុងឆេះសន្ធោសន្ធៅ យ៉ាងណា ប្អូនចូររំលត់សេចក្តីរបរិត ព្រោះតម្រេករបស់បង ដែលកើតឡើងហើយ ព្រោះប្អូនជាហេតុ ដូច្នោះ ។

ពាក្យថា **ប្រកបដោយកេសរ និងលំអង** គឺ ប្រកបដោយកេសរ និងលំអងផ្កាឈូក ពាក្យថា **ដូចដំរីដែលត្រូវកំដៅថ្ងៃដុតពេលមុខ** គឺ ដូចដំរីដែលត្រូវកំដៅថ្ងៃដុតពេលក្នុងរដូវក្តៅ ។ ពាក្យថា **ឈានចុះកាន់ដោះ**

**និង៥ទរ របស់ប្អូន** គឺ បញ្ចសិខៈពោលថា កាលណាហ្ន៎ បងនឹងបានចុះកាន់ដោះ និង៥ទរ ដែលបានដល់ នៃបនិត្យត្រង់ចន្លោះដោះ និង៥ទររបស់ប្អូន ហើយបានទទួលសេចក្តីសុខ និងសេចក្តីរីករាយ ដូចដំរីចុះកាន់ស្រះឈូក ផឹក ហើយត្រាំខ្លួនងើបឡើងតែចុងប្រមោយ ប៉ុណ្ណោះ ឲ្យប្រាកដ បានទទួលសេចក្តីសុខ និងសេចក្តីរីករាយ ដូច្នោះ ។ បន្ទាដែក ដែលប្រើចាក់ទាក់ត្រចៀក ហៅថា កង្វេរ ដោយគាថា នេះថា ៖

**បងវង្វេងក្នុងប្អូន ដែលមានភ្លៅស្អាត ទើបមិនដឹង**

**ច្បាស់នូវហេតុការណ៍ ដូចដំរីសាចុះប្រេង យល់**

**ថា ខ្លួនឈ្នះកង្វេរ និងលំពែង ។**

ដែលហៅថា **លំពែង** បានដល់ លំពែងអាជ្ញាប្រើចាក់ជើងជាដើម ។ ដែលហៅថា **កង្វេរ** បានដល់ ដែកស្រួចកោងប្រើចាក់ក្បាល (ដំរី) ។ ក៏ដំរីដែលចុះប្រេងពេញទី ជាដំរីដែលហួសវិស័យកង្វេរ ចចេសនឹងកង្វេរ ទោះជាឲ្យយកកង្វេរចាក់-ទាក់ ក៏មិននៅ និងវាយល់ថា យើងយកឈ្នះកង្វេរ និងលំពែងបានហើយ ព្រោះសូម្បីតែកង្វេរក៏នៅទាក់យើងទុកមិនបាន វាមិនព្រមទទួលដឹងហេតុការណ៍អ្វី ៗ ព្រោះកម្លាំងនៃការស្រវឹងវីវក់ ។ បញ្ចសិខៈពោលថា សូម្បីខ្លួនបង ក៏វង្វេងវង្វាន់ ស្រវឹង ស្រវឹងវីវក់ដូចជា

ធ្លាក់ក្នុងប្អូនអ្នកមានភ្លៅល្អ ព្រោះមានភ្លៅដល់ព្រមដោយលក្ខណៈ ទើបមិនដឹងច្បាស់ហេតុការណ៍អ្វី ៗ ដូចដំរីចុះប្រេងនោះ វាយល់ថា យើងយកឈ្នះសូម្បីកង្វេ និងលំពែងបានហើយ ក៏មិនដឹងច្បាស់ហេតុការណ៍អ្វី ៗ ដូច្នោះ ។ មួយទៀត ខ្ញុំនេះបងដូចជាដំរីដែលចេចសនឹងកង្វេរ វង្វេងវង្វាន់នឹងប្អូនដែលមានភ្លៅល្អ ដូច្នោះ ទើបមិនដឹងច្បាស់ហេតុនៃការប្រោសចាកតម្រេកត្រឹមតែបន្តិចបាន ។ ព្រោះហេតុអ្វី ? ព្រោះឲ្យនរណា ៗ មកពោលបងក៏មិនកាន់យកពាក្យ ដូចដំរីដែលគិតថា យើងយកឈ្នះសូម្បីកង្វេ និងលំពែងបានហើយ ដូច្នោះ ។

ពាក្យថា **បងមានចិត្តជាប់ជំពាក់ក្នុងប្អូន** សេចក្ដីថា ប្អូនជាទីស្រឡាញ់ បងនេះជាអ្នកមានចិត្តប្រតិព័ទ្ធក្នុងប្អូនដែលមានភ្លៅល្អ ។ ឬពាក្យថា **មានចិត្តជាប់ជំពាក់** បានដល់ មានចិត្តសម្ងំផ្ដោតដោយសេចក្ដីស្រឡាញ់ ។ ពាក្យថា **ចិត្តប្រែប្រួលហើយ** គឺ លះបង់ចិត្តប្រក្រតី តាំងនៅ ។ ពាក្យថា **មិនអាចត្រឡប់បាន** គឺ បងឲ្យត្រឡប់មិនបាន ។ ពាក្យថា **ដូចត្រីជាប់សន្ទូច** គឺ ដូចត្រីដែលលេបសន្ទូចហើយជាប់នៅ បាឋៈថា ឃសោ ក៏មាន ។ មានសេចក្ដីដូចគ្នា ។

ពាក្យថា **មានដើមភ្លៅដ៏ល្អស្អាត** គឺ មានភ្លៅដែលតាំងមាំដោយល្អ

ឬអធិប្បាយថា មានដើមភ្លៅដូចដើមចេក ។ ពាក្យថា **ឱប** គឺ មេត្តាចូរក្រសោបបងទុកឲ្យជាប់ ។ ពាក្យថា **មានភ្នែកដ៏ស្រទន់** គឺ ពួកស្រីរមែងមិនផ្តោតមើលចំ តែរមែងជៀងភ្នែកមើល ដូច្នោះទើបហៅថា **អ្នកមានភ្នែកស្រទន់** ។ ពាក្យថា **ឱបត្រកង** គឺ ចូរត្រកងក្រសោបបងទុកគ្រប់ចំណែក ។ ពាក្យថា **បងប្រាថ្នាដូច្នេះ ក្រៃលែងណាស់** គឺ បងត្រូវការយ៉ាងនេះជានិច្ច ។

ពាក្យថា **មាន ( សេចក្តីស្រឡាញ់ ) បន្តិចបន្តួច** គឺ មានតិចដោយប្រក្រតីតែម្យ៉ាង ។ ពាក្យថា **មានសក់ងឿង** គឺ ឈ្មោះថាមានសក់ត្រសាយងឿង ព្រោះសក់របស់ស្រីនោះក្នុងវេលាដែលរំសាយហើយ ធ្លាក់ទៅខាងក្រោយលូនទៅដូចពស់ ។ អ្នកមានសក់ដូចរលកនោះ ។ ពាក្យថា **កើតមានឡើងមិនមែនតិច** គឺ កើតឡើងមិនមែនតែម្តង ។ បាឋៈថា **មិនមែនតិច** ក៏មាន ។ ពាក្យថា **ដូចទក្ខិណាក្នុងព្រះអរហន្ត** គឺ ផ្សាយចេញទៅដោយប្រការផ្សេង ៗ ដូចទានដែលថ្វាយក្នុងព្រះអរហន្ត ( ឲ្យផលច្រើនណាស់ ដូច្នោះ ) ។

ពាក្យថា **មានបុណ្យណាដែលបងបានធ្វើទុកហើយ** គឺ បុណ្យណារបស់បងបានធ្វើទុក មានហើយ ។ ពាក្យថា **ក្នុងព្រះអរហន្តទាំងឡាយ**

**មិនញាប់ញ័រ** គឺ ក្នុងពួកព្រះអរហន្ត អ្នកដល់លក្ខណៈនៃបុគ្គលនឹងធឹង ។ ពាក្យថា **ចូរអំណោយផលចំពោះបង និងប្អូន** គឺ បុណ្យទាំងអស់ ចូរផ្តល់ផលឲ្យបងនឹងប្អូនទាំងឯង ។

បទថា **តែមួយ** គឺ ដល់ភាពតែម្នាក់ឯង ។ បទថា **មានបញ្ញាជាគ្រឿងរក្សាខ្លួន** បានដល់ ឈ្មោះថា បញ្ញាជាគ្រឿងឃុំគ្រងខ្លួន ព្រោះប្រកបដោយបញ្ញាដែលហៅថា ជាគ្រឿងរក្សាខ្លួននោះ , ព្រោះប្រកបដោយសតិ ទើបឈ្មោះថា មានស្មារតី ។ បទថា **ព្រះមុនីស្វែងរកអម្រឹតធម៌** គឺ អង្គព្រះពុទ្ធមុនីនោះ ទ្រង់ស្វែងរក គឺ ស្វែងរកអម្រឹត បានដល់ព្រះនិព្វាន យ៉ាងណា បងក៏ដូច្នោះ ណាំប្អូនសុរិយវច្ចសា រមែងស្វែងរក គឺ ស្វះស្វែងរកប្អូន ។ មយ៉ាងទៀត អធិប្បាយថា ព្រះពុទ្ធមុនីអង្គនោះ ទ្រង់ត្រាច់ស្វែងរកអម្រឹតធម៌ យ៉ាងណា បងក៏ត្រាច់ស្វែងរកប្អូនដូច្នោះដែរ ។

បទថា **ព្រះមុនី ទ្រង់សម្រេចព្រះសម្ពោធិញ្ញាណដ៏កំពូលហើយគប្បីទ្រង់រីករាយ យ៉ាងណា** សេចក្តីថា ព្រះពុទ្ធមុនីទ្រង់ប្រថាប់អង្គុយត្រង់ពោធិបល្ល័ង្ក ទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណហើយ គប្បីទ្រង់រីក-រាយ គឺ គប្បីទ្រង់ត្រេកអរ យ៉ាងណា ។ បទថា **គប្បីរីករាយ ដូច្នេះ** សេចក្តីថា បញ្ចសិខៈពោលថា សូម្បីបងក៏ដល់ការប្រកៀកនឹងប្អូនហើយ

ក៏គប្បីភ្ញើតភ្ញើន គឺ គប្បីជាអ្នកកើតសេចក្ដីរីករាយ និងសេចក្ដីពេញចិត្ត ដូច្នោះ ដូចគ្នា ។ ពាក្យថា អហោ ក្នុងបាទគាថាថា តាហំ ភទ្ទេ វរេយ្យាហោ ជាពាក្យសម្រាប់ហៅ ។ អធិប្បាយថា នែះនែ៎ សុរិយវច្ចសាកំពូលស្នេហ៍ បើស្ដេចសក្កទេវរាជជាធំជាងពួកទេវតា ប្រទានពរយ៉ាងនេះថា អ្នកនឹងយក ទេវរាជ្យក្នុងទេវលោកទាំងពីរជាន់ ឬសុរិយវច្ចសា បងនឹងក្រាបទូលថា ខ្ញុំ ព្រះអង្គសូមលះបង់ទេវរាជ្យ ហើយយកនាងសុរិយវច្ចសា បងត្រូវជ្រើស រើស គឺ ត្រូវការ បានដល់ ត្រូវយកប្អូនទុក ដោយប្រការដូច្នេះ ។

ពាក្យថា **ដូចឈើសាលដែលទើបនឹងមានផ្កា** សេចក្ដីថា ជិតទ្វារ ក្រុងរបស់បិតាប្អូន មានដើមសាលៈដែលទើបនឹងមានផ្កា ដើមសាលៈនោះ គួររីករាយក្រៃពេក ប្រៀបដូចសាលៈដែលទើបនឹងមានផ្ការីកនោះ ។ ពាក្យ ថា **ម្នាលប្អូនមានបញ្ញាឈ្លាសវៃ បិតារបស់ប្អូន** សេចក្ដីថា កាលបើបង សំពះ ក៏សូមធ្វើការសំពះបិតារបស់ប្អូន ដែលទ្រទ្រង់សិរីរកអ្វីប្រៀបផ្ទឹម មិនបាន ។ ពាក្យថា **អ្នកមានសភាពដូច្នេះ ជាប្រជារបស់អ្នកណា** សេចក្ដី ថា នាងដែលមានរូបប្រាកដដូច្នេះ ជាធីតារបស់អ្នកណា ។

## រឿង បញ្ចសិខគន្ធព្វទេវបុត្ត

[៨៧] សួរថា ហេតុដូចម្ដេចព្រះមានព្រះភាគ ទើបត្រាស់សរសើរ

សំឡេងដេញ និងសំឡេងពិណថា **សមលម្មតា** សេចក្តីតម្រេកខ្វាំងក្នុងសំឡេងនោះ របស់ព្រះមានព្រះភាគ នៅមានដែរឬ ?

ឆ្លើយថា មិនមាន ។ ព្រះមានព្រះភាគ ទ្រង់ជាអ្នកប្រងើយដោយភាពប្រងើយមានអង្គ ៦ ប្រការ ក្នុងឋានៈដូច្នេះ ក៏ទ្រង់ជ្រាបអារម្មណ៍ដែលគួរពេញចិត្ត និងមិនគួរពេញចិត្តគ្រប់យ៉ាង ក៏ទ្រង់មិនជាប់ក្នុងអារម្មណ៍នោះ ។ សមពិតដូចពាក្យ ដែលលោកពោលទុកយ៉ាងនេះថា អ្នកមានអាយុ ព្រះនេត្ររបស់ព្រះមានព្រះភាគមានហើយ ព្រះមានព្រះភាគ ទ្រង់ឃើញរូបដោយព្រះនេត្រ តម្រេក ព្រោះសេចក្តីពេញចិត្តរបស់ព្រះមាន-ព្រះភាគ មិនមាននៅទេ ព្រះមានព្រះភាគ ទ្រង់មានព្រះហឫទ័យរួចផុតហើយយ៉ាងល្អ អ្នកមានអាយុ ព្រះកណ្ណៈរបស់ព្រះមានព្រះភាគ ក៏នៅមានដូច្នេះជាដើម ។ ព្រះមានព្រះភាគត្រាស់សរសើរ ព្រោះទ្រង់ជ្រាបថា បើតថាគតមិនពោលសរសើរ បញ្ចសិខៈក៏ជ្រាបមិនបានថា តថាគតបានឲ្យឱកាសហើយ ពេលនោះ ស្តេចសក្កៈក៏នឹងទ្រង់នាំពួកទេវតា ត្រឡប់ទៅអំពីទីនោះ ព្រោះទ្រង់យល់ក្នុងព្រះទ័យថា ព្រះមានព្រះភាគ មិនប្រទានព្រះឱកាសដល់បញ្ចសិខៈ អំពីនោះ ក៏នឹងគប្បីវិនាសធំ កាលត្រាស់សរសើរដូច្នោះ ស្តេចសក្កៈក៏នឹងទ្រង់យល់ក្នុងព្រះទ័យថា ព្រះមានព្រះភាគ បាន

ប្រទានព្រះឱកាសដល់បញ្ចសិខៈហើយ ក៏ទ្រង់នឹងចូលមកគាល់ព្រមនឹងពួកទេវតា ទ្រង់សួរបញ្ហា កាលដោះស្រាយបញ្ហាស្រេច ស្ដេចសក្កៈព្រមនឹងពួកទេវតា ៨ ម៉ឺន ក៏នឹងទ្រង់តាំងនៅក្នុងសោតាបត្តិផល ។

ក្នុងបទទាំងនោះ បទថា **ដោតក្រងទុកអំពីកាលណា** សេចក្ដីថា ( គាថាទាំងនេះ អ្នក ) តែង គឺ រូបរួមទុកអំពីពេលណា ។

ពាក្យថា **បពិត្រព្រះមានព្រះភាគ ក៏ដោយសម័យនោះឯង ខ្ញុំព្រះអង្គ** សេចក្ដីថា ដោយសម័យនោះ គឺ ក្នុងសប្ដាហ៍ទី ៨ បន្ទាប់ពីព្រះអង្គសម្រេចសម្ពោធិញ្ញាណនោះ ។

ពាក្យថា **ភទ្ទាសុរិយវច្ចសា** គឺ ដោយឈ្មោះ ឈ្មោះភទ្ទា ព្រោះដល់ព្រមដោយរូបរាងដែលស្អាតល្អ ទើបឈ្មោះ សុរិយវច្ចសា ។ ពាក្យថា **ប្អូនស្រី** នេះ ជាពាក្យសំនួនហៅ ។ មានន័យថា ទេវធីតា ។ ពាក្យថា **ស្រឡាញ់អ្នកដទៃហើយ គឺ ស្រឡាញ់** បានដល់ ប្រាថ្នាអ្នកដទៃ ។

## ការត្រិះរិះរបស់ទេវានមិន្ទ

[៨៨] ពាក្យថា **កំពុងចូលទៅរាំ** បានដល់ កំពុងតែរាំ ។ ដំណាលមកថា សម័យមួយ នាងទៅដើម្បីត្រូវការសេរសើរការរាំ របស់ស្ដេចសក្ក-

ទេវរាជ នឹងពួកទេវតាជាន់ចាតុម្មហារាជិកា ។ ក៏ក្នុងខណៈនោះ ស្ដេចសក្កៈ ទ្រង់បានពោលសរសើរព្រះគុណតាមសេចក្ដីពិត ៨ ប្រការ របស់ព្រះ-តថាគត ។ ដោយប្រការដូច្នេះ ក៏ជាការពោលបានថា ក្នុងថ្ងៃនោះ នាងក៏បានទៅសរសើរប៉ាំ ។

ពាក្យថា **រមែងរីករាយដល់គ្នា** សេចក្ដីថា កាលព្រះមានព្រះភាគត្រាស់ពាក្យជាដើមថា រមែងលាយឡំគ្នាពិត របស់អ្នក ក៏ឈ្មោះថា ទ្រង់រីករាយ បញ្ចសិខៈក៏ឈ្មោះថា រីករាយតប កាលបញ្ចសិខៈកំពុងពោលគាថា ក៏ឈ្មោះថា រីករាយ ព្រះមានព្រះភាគ ក៏ឈ្មោះថា ទ្រង់រីករាយតប ។ ពាក្យថា **ត្រាស់ហៅ** គឺ ទ្រង់បញ្ជាក់ឲ្យជ្រាប ។ បានជ្រាបមកថា ស្ដេចសក្កៈនោះ ទ្រង់មានព្រះតម្រិះយ៉ាងនេះថា យើងបញ្ជូនបញ្ចសិខៈនេះទៅដោយការងាររបស់យើង គេក៏ទៅធ្វើការងាររបស់ខ្លួនឯងទៅវិញ គេឈរក្នុងសម្នាក់ព្រះសាស្ដាបែបនោះហើយ ទៅជាពោលពាក្យដែលប្រកបដោយកាមគុណ ដែលជាពាក្យមិនសមគួរ ក៏ដែលឈ្មោះថា ពួកអ្នករបាំជាពួកគ្មានអៀនខ្មាស បញ្ចសិខៈកាលកំពុងពោលហើយ គប្បីសម្ដែងអាការដែលខុសច្បងក៏បាន ណ្ហើយចុះ យើងនឹងជាស់តឿនឲ្យគេដឹងការងាររបស់យើង កាលទ្រង់គិតដូច្នេះហើយ ក៏ត្រាស់ហៅមក ។

[៨៩] បទថា **កាលបើដូច្នេះ ព្រះតថាគតទាំងឡាយ** ដូច្នេះ ដែលពួកព្រះថេរៈអ្នករួបរួមធម៌តាំងទុកហើយ ។ ពាក្យថា **ពោលបន្ថែម** គឺពោលអំពីការទទួល ការសំពះ បានដល់ ដោយពាក្យដែលបន្ថែមឡើង ។ ពាក្យថា **ការពោលដ៏ក្រៃលែងហើយ** គឺ ការពោលដោយពាក្យដែលបន្ថែមឡើង ។ ពាក្យថា **បានដល់ភាពធំទូលាយ** គឺ ក្លាយជាបើធំទូលាយ ។ ពាក្យថា **ភាពងងឹតក្នុងល្អាងបានវិនាសទៅ ការភ្លឺស្វាងកើតឡើងជំនួស** គឺភាពងងឹតដោយប្រក្រតីរបស់ល្អាងនោះ បានបាត់ទៅ កើតពន្លឺភ្លឺជំនួស ។ ទាំងអស់នេះ ជាពាក្យរបស់ពួកលោកអ្នករួបរួមធម៌ ។

[៩០] ពាក្យថា **ខ្ញុំព្រះអង្គគេចចេញយូរហើយ ព្រះអង្គ** សេចក្ដីថា ខ្ញុំព្រះអង្គ ប្រាថ្នានឹងគាល់ជាយូរមកហើយ អធិប្បាយថា ខ្ញុំព្រះអង្គប្រាថ្នានឹងគាល់តាំងពីយូរមកហើយ ។ ពាក្យថា **ដោយកិច្ច និងករណីយ៍ខ្លះៗ** សេចក្ដីថា ពួកកូនស្រី និងកូនប្រុស រមែងកើតលើភ្លៅរបស់ពួកទេវតា ពួកស្រ្តីដែលជាបាទបរិចារិកា រមែងកើតលើទីដេក ពួកទេវតាដែលជាអ្នកធ្វើគ្រឿងប្រដាប់តាក់តែងរបស់ ទេវតាទាំងនោះ រមែងកើតជុំវិញទីដេក ពួកទេវតាជាអ្នកបំរើ ( វេយ្យាវច្ចករ ) រមែងកើតខាងក្នុងវិមាន ។ ការធ្វើក្តី ដើម្បីប្រយោជន៍ដល់ទេវតាទាំងនេះ មិនមាន តែពួកដែលកើតចន្លោះ

ព្រំប្រទល់នោះ កាលមិនអាចកាត់ក្ដីថា របស់លោក របស់ខ្ញុំ ដូច្នេះ ក៏កើតក្ដីក្ដាំគ្នា រមែងទូលសួរស្ដេចសក្កៈដែលជាព្រះរាជារបស់ទេវតា ព្រះអង្គក៏នឹងត្រាស់ថា ជិតវិមានអ្នកណាជាង ជារបស់អ្នកនោះ បើវិមានទាំងពីរកើតមានរយៈស្មើៗ គ្នា ព្រះអង្គក៏នឹងត្រាស់ថា ឈរមើលវិមានអ្នកណាជារបស់អ្នកនោះ បើមិនសម្លឹងមើលសូម្បីវិមានមួយណាទេ ដើម្បីកាត់ការឈ្លោះទាំងពីរចំណែក ក៏ទ្រង់យកដោយខ្លួនឯង ញ៉ាំងកិច្ច មានការលេងកីឡាជាដើម ក៏ចាំបាច់ទ្រង់ត្រូវចាត់ការទាំងអស់ ស្ដេចសក្កៈទ្រង់សំដៅយកករណីយ៍ទាំងនោះ មានសភាពបែបនេះហើយ ទើបត្រាស់ថា **ដោយកិច្ច និងករណីយ៍ខ្លះ ៗ** ដូច្នេះ ។

ពាក្យថា **អាគារឈើស្រល់** បានដល់ ព្រះគន្ធកុដិដែលសាងដោយឈើស្រល់ ។ ពាក្យថា **ដោយសមាធិណាមួយ** គឺ មានរឿងដំណាលថា គ្រានោះ ព្រះមានព្រះភាគទ្រង់ជ្រាបថា ព្រះញាណរបស់ស្ដេចសក្កៈនុ៎ះមិនទាន់ចាស់ក្លា ទើបទ្រង់មិនប្រទានព្រះឱកាសឡើយ ប្រថាប់អង្គុយដោយធម៌ជាគ្រឿងសម្រាក គឺ ផលសមាបត្តិ ស្ដេចសក្កៈទ្រង់មិនជ្រាបដល់សេចក្ដីនោះ ទើបត្រាស់ថា **ដោយសមាធិឯណាមួយ** ដូច្នេះ ។ ពាក្យថា **ឈ្មោះភុជតី** គឺ ទេវធីតានោះ ឈ្មោះថា ភុជតី ។ ពាក្យថា បរិចារិកា គឺ

ទេវធីតាអ្នកជាបាទបរិចារិកា ។ មានរឿងដំណាលមកថា នាងសម្រេចផលពីរយ៉ាង ហេតុនោះ នាងទើបមិនមានសេចក្តីត្រេកអរក្នុងទេវលោកឡើយ នាងមកកាន់ទីទំនុកបម្រុងព្រះមានព្រះភាគជានិច្ច ឈរប្រណម្យដៃដាក់លើសិរសា សំពះព្រះមានព្រះភាគ ។

ក្នុងពាក្យថា **ចេញចាកសមាធិនោះ ព្រោះសំឡេងកង់ និងសំឡេងជុំនៃរថ** នេះ មិនត្រូវនិយាយថា ទ្រង់ចូលសមាបត្តិហើយ ទ្រង់បានឮសំឡេង ។ សួរថា ព្រះមានព្រះភាគ ក៏នៅតែត្រាស់នឹងស្តេចសក្កទេវរាជជាធំជាងពួកទេវតាថា ប្រការមួយទៀត តថាគតចេញចាកសមាធិនោះ ក៏ព្រោះសំឡេងកង់ និងជុំនៃរថរបស់មហាបពិត្រ មិនមែនឬ ។ ឆ្លើយថា សំឡេងជុំនៃរថ លើកទុកចុះ ធម្មតាអ្នកចូលសមាបត្តិ ក្នុងខាងក្នុងសមា-បត្តិ ទោះជាឲ្យអ្នកណាយកគូស័ន្ទមកផ្លុំដាក់ជិតៗ គុម្ពត្រចៀកក្តី រន្ទះឮផ្លូងផាំងក្តី ក៏រមែងមិនបានឮសំឡេង ។ ចំណែកព្រះមានព្រះភាគ ទ្រង់កំណត់ថា រហូតដល់អស់វេលាប៉ុណ្ណេះ តថាគតនឹងមិនទាន់ឲ្យឱកាសដល់ស្តេចសក្កៈ ទើបទ្រង់ចូលផលសមាបត្តិ ដោយអំណាចវេលា ។ ស្តេចសក្កៈទ្រង់គិតថា ឥឡូវនេះ ព្រះសាស្តាមិនទាន់ប្រទានឱកាសដល់យើង ទើបទ្រង់ធ្វើប្រទក្សិណព្រះគន្ធកុដិ ហើយឲ្យត្រឡប់រថបែរព្រះភក្ត្រកាន់ទេវលោក ។

បរិវេណព្រះគន្ធកុដិ ក៏មានការលាន់រំពង ព្រោះសំឡេងវថ ដូចតន្ត្រី មានអង្គ ៥ ។ កាលព្រះមានព្រះភាគ ទ្រង់ចេញចាកសមាបត្តិ តាមអំណាចវេលាដែលទ្រង់បានកំណត់ទុកហើយ ចិត្តដែលធ្វើនាទីពិចារណាអារម្មណ៍ ដួងដំបូងក៏កើតឡើង ដូច្នោះ ព្រះអង្គទើបត្រាស់យ៉ាងនោះ ។

ពាក្យថា **ធ្វើឲ្យបរិបូរក្នុងសីលទាំងឡាយជាប្រក្រតី** គឺ ជាអ្នកមានប្រក្រតីធ្វើឲ្យបរិបូណ៌ក្នុងសីល ៥ ប្រការ ។ ពាក្យថា **នឿយណាយចិត្តក្នុងភាពជាស្ត្រី** គឺ មកគិតថា ល្មមហើយសម្រាប់ភាពជាស្ត្រី ព្រោះថាតាំងនៅក្នុងភាពជាស្ត្រីហើយ នឹងសោយសិរីរបស់ស្តេចចក្រពត្តិក៏មិនបាន សោយសិរីរបស់ព្រះឥន្ទ្រ មារ និងព្រហ្មក៏មិនបាន នឹងសម្រេចបច្ចេក-ពោធិញ្ញាណក៏មិនបាន នឹងសម្រេចសម្មាសម្ពោធិញ្ញាណក៏មិនបាន យ៉ាងនេះហើយ ឈ្មោះថា រមែងប្រាសចាកសេចក្ដីប្រាថ្នាក្នុងភាពជាស្ត្រី ចំណែកអ្នកដែលគិតថា ធម្មតាភាពជាបុរសនេះ ជាក្រៃលែង ប្រសើរបំផុត ព្រោះអ្នកតាំងនៅក្នុងភាពជាបុរសនេះ អាចដល់ព្រមនូវសម្បត្តិទាំងនេះ យ៉ាងនេះហើយ ឈ្មោះថា រមែងធ្វើភាពជាបុរសឲ្យមាន សូម្បីនាងក៏បានធ្វើយ៉ាងនោះ ព្រោះដូច្នោះ ទើបពោលថា **ក៏នឿយណាយចិត្តក្នុងភាពជាស្ត្រីហើយ ធ្វើចិត្តបុរសឲ្យមាន** ដូច្នេះ ។ ពាក្យថា **កាយគន្ធព្វអាក្រក់** គឺ

ពួកគន្ធព្វថោកទាប គឺ លាមក ។ សួរថា ក៏ពួកអ្នកទាំងនោះ សុទ្ធតែមានសីលបរិសុទ្ធិ ហេតុដូចម្តេច ទើបកើតឡើងក្នុងទេវលោកនោះហ្ន៎ ។ ឆ្លើយថា ព្រោះសេចក្តីពេញចិត្តមកពីមុន ។ ដំណាលមកថា កាលពីមុនមក ទីទុំះឯង ជាទីដែលធ្លាប់នៅមកហើយរបស់ពួកនោះ ព្រោះដូច្នោះ ទើបកើតឡើងក្នុងទីនោះ ដោយអំណាចនៃសេចក្តីពេញចិត្ត ។ ពាក្យថា **ទីទំនុកបម្រុង** បានដល់ គេងសម្រាប់ទំនុកបម្រុង ។ ពាក្យថា **បម្រើ** បានដល់ ការបម្រើ ។ គន្ធព្វទាំងនោះរមែងមក ដោយគិតថា ពួកយើងនឹងបម្រើ ដោយការប្រគុំ និងការច្រៀង ។

ពាក្យថា **ដាស់តឿន** គឺ ឲ្យសតិ ។ ដំណាលមកថា កាលគោបកទេវបុត្ត ឃើញគន្ធព្វទាំងនោះ ទើបពិចារណាថា ទេវបុត្តទាំងនេះ មានរស្មីហួសប្រមាណ ធ្វើកម្មអ្វីទុកហ្ន៎ ទើបបានមក បានឃើញថា ជាពួកភិក្ខុ បន្ទាប់ពីនោះក៏ពិចារណាទៀតថា ពួកភិក្ខុ មានប្រក្រតីធ្វើឲ្យបរិបូរក្នុងសីលទាំងឡាយឬទេ បានឃើញថា មានប្រក្រតីធ្វើឲ្យបរិបូរ ពិចារណាតទៅថា មានប្រក្រតីធ្វើឲ្យបរិបូរ ចុះគុណពិសេសយ៉ាងដទៃមាន ឬមិនមាន បានឃើញថា ជាពួកមានប្រក្រតីបានឈាន ពិចារណាតទៅទៀតថា សូម្បីមានប្រក្រតីបានឈាន ចុះជាអ្នកណា បានឃើញថា ជាអ្នកមកទទួលបាត្រ

ប្រចាំត្រកូលរបស់យើងនុ៎ះឯង ទើបគិតថា ធម្មតាអ្នកមានសីលបរិសុទ្ធិ រមែងកើតក្នុងទេវលោក ៦ ជាន់ ក្នុងជាន់ដែលត្រូវការ តែពួកនេះ មិនកើតក្នុងទេវលោកជាន់ខ្ពស់ ធម្មតាអ្នកបានឈាន រមែងកើតក្នុងព្រហ្ម-លោក តែពួកនេះមិនកើតក្នុងព្រហ្មលោក ចំណែកខ្លួនយើង តាំងនៅក្នុងឱវាទរបស់ពួកអ្នកទាំងនេះ កើតជាបុត្រត្រង់បល្ល័ង្ករបស់ស្តេចសក្កៈទេវរាជដែលជាម្ចាស់នៃទេវលោក អ្នកទាំងនេះកើតក្នុងពួកគន្ធព្វដែលអាក្រក់ ដែលឈ្មោះថា ពួកគន្ធព្វនោះ នរណា ៗ គេក៏ជួបប្រទះតែពួកបុគ្គលដែលយកធ្មឹងមកបោះ ( ពាក់ក ) កាំរែកទៅកាំរែកមកប៉ុណ្ណោះឯង ទើបដាស់តឿនដោយពាក្យជាដើមថា **យកមុខទៅទុកទីណា** ។ ក្នុងបទទាំងនោះ ពាក្យថា **យកមុខទៅទុកទីណា** សេចក្តីថា កាលព្រះមានព្រះភាគ ទ្រង់បែរព្រះភ័ក្រ្តមកសម្តែងធម៌ ពួកលោករវល់តែយកមុខទៅទុកក្នុងទីណា ឬរវល់តែបញ្ជូនចិត្តទៅទីដទៃ មើលនោះមើលនេះ ឬរវល់តែលង់លក់ ។ ពាក្យថា **រូបដែលមិនគួរឃើញ** គឺ មិនសមគួរនឹងឃើញ សភាពដែលមិនគួរមើល ។ ពាក្យថា **ពួកសហធម្មិក** គឺ អ្នកប្រព្រឹត្តធម៌ បានដល់ ធ្វើបុណ្យក្នុងសាសនារបស់ព្រះសាស្តាជាមួយគ្នា ។

ពាក្យថា **តែទេវបុត្តទាំងនោះ ព្រះអង្គ** សេចក្តីថា បណ្តាទេវបុត្ត

ទាំងនោះ អ្នកដែលត្រូវគោបកទេវបុត្តពោលយ៉ាងនោះហើយ ដាស់តឿនទៀតដោយពាក្យជាដើមថា ឱហ្ន៎ ! ពួកលោក ពូកែឥតអៀនខ្មាស ពូកែមិនមានបេះខ្មាស ទេវតាទាំងពីរអង្គក៏ត្រឡប់បានសតិក្នុងពេលភ្លាមនោះឯង ។ ពាក្យថា **ពួកព្រហ្មបុរោហិត** គឺ បានឮថា ទេវបុត្តទាំងនោះ នាំគ្នាគិតថា ដែលឈ្មោះថា ពួកអ្នករបាំ ដែលរាំច្រៀង លេងភ្លេងតន្ត្រីមកហើយ ក៏ត្រូវបានតម្លៃជារង្វាន់ ចំណែកគោបកទេវបុត្តនេះ តាំងពីវេលាដែលយើងឃើញ គិតតែប្រទូស្តប្រែះ ៗ ដូចយកអំបិលរោយដាក់ចង្ក្រានភ្លើង នេះយ៉ាងណាហ្ន៎ កាលពិចារណាតទៅ ក៏ឃើញថា ខ្លួនជាសមណៈ មានសីលបរិសុទ្ធិ បានឈាន និងជាអ្នកទទួលបាត្រប្រចាំត្រកូលរបស់គោបកទេវ-បុត្រនោះផង ហើយបានជ្រាបថា ធម្មតាអ្នកមានសីលបរិសុទ្ធិ រមែងជ្រើសរើសកើតក្នុងទេវលោកទាំង ៦ ជាន់បាន អ្នកបានឈាន ក៏រមែងកើតក្នុងព្រហ្មលោក (តែ) ពួកយើង ទាំងក្នុងទេវលោកជាន់ខ្ពស់ ទាំងក្នុងព្រហ្ម មិនបានកើតទេ គោបកទេវបុត្តនេះ ធ្លាប់ជាស្ត្រី តាំងនៅក្នុងឱវាទរបស់ពួកយើង អាចកើតបានខ្ពស់ ពួកយើងជាភិក្ខុប្រព្រឹត្តព្រហ្មចរិយៈក្នុងសម្នាក់ព្រះមានព្រះភាគ កើតក្នុងពួកគន្ធព្វដែលថោកទាប ហេតុនោះ គោបកទេវបុត្តនេះ ទើបគ្របសង្កត់ពួកយើងយ៉ាងនេះបាន ទើបបានព្រម

ស្ដាប់ពាក្យរបស់គោបកទេវបុត្តនោះ ។ ក្នុងទេវតាទាំង ៣ អង្គនោះ ពីរអង្គ ត្រឡប់បានការរឭកដល់ឈានទី ១ យកឈានជាបាទ ហើយក៏ពិចារណាសង្ខារ តាំងនៅក្នុងអនាគាមិផលទុំះឯង ។ ពេលនោះ អត្តភាពដែលត្រាច់អន្ទោលក្នុងកាម ដែលមានសភាពបន្ថិចបន្តួចរបស់ពួកលោកទាំងនោះ តាំងនៅមិនញាប់ញ័រ ដូច្នោះភ្លាមទុំះឯង លោកក៏ឃ្លាតទៅកើតក្នុងជាន់ព្រហ្មបុរោហិត និងកាយរបស់ពួកគេ ដែលនៅក្នុងជាន់ព្រហ្មបុរោ-ហិតនោះ ក៏កើតហើយ ព្រោះហេតុនោះ ស្ដេចសក្កៈទើបត្រាស់ថា បពិត្រព្រះអង្គ កន្លែងទេវបុត្តទាំងនោះ ដែលគោបកទេវបុត្តជាស់តឿនហើយ ទេវតាពីរអង្គ ត្រឡប់បានសតិក្នុងពេលភ្លាមនោះឯង ចូលដល់ ពួកព្រហ្ម-បុរោហិតហើយ ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា **ក្នុងពេលភ្លាម ៗ នោះ តែម្ដង** គឺ ត្រឡប់បានសតិនៅក្នុងអត្តភាពនោះឯង ។ គប្បីឃើញអធិប្បាយក្នុងពាក្យនោះ យ៉ាងនេះថា ក៏នៅក្នុងទីនោះ ៗ ឯង ។ ចុតិហើយ ត្រឡប់បានកាយជាព្រហ្មបុរោហិត ។ គឺ សរីរៈ ជាព្រហ្មបុរោហិត ។ ពាក្យថា **ប៉ុន្តែទេវបុត្ត ១ អង្គ** គឺ ទេវបុត្តម្នាក់ ទំលាយភាពជាប់ចិត្តមិនទាន់បាន ក៏នៅគ្រប់គ្រងកាម គឺ នៅប្រចាំ គឺ អាស្រ័យនៅក្នុងកាមាវចរភពទុំះឯង ។

## រឿង គោបិកាសក្យធីតា

[៩១] ពាក្យថា **និងទំនុកបម្រុងសង្ឃ** គឺ បានទំនុកបម្រុងសង្ឃផង ។ ពាក្យថា **ជាធម៌ល្អ** គឺ ដោយសេចក្ដីដែលព្រះធម៌ជាធម៌ល្អ ។ ពាក្យថា **ចូលដល់ត្រៃទិព្វ** គឺ កើតក្នុងត្រៃទិព្វ បានដល់ ត្រៃទសបុរី ។ ពាក្យថា **គេអាស្រ័យនៅក្នុងពួកអ្នកតន្ត្រី** គឺ ជាអ្នកចូលទៅនៅអាស្រ័យក្នុងពួកគន្ធព្វ ។ ពាក្យថា **ក៏ពួកយើងអំពីកាលមុនជាមនុស្ស** គឺ កាលមុននេះ ពួកយើងជាមនុស្ស ។ គប្បីប្រកបនឹងពាក្យនេះថា ខ្ញុំទំនុកបម្រុងដោយបាយទឹក ។ ពាក្យថា **នៅបានលាងជើង** គឺ ចូលទៅជិតជើងហើយទាំងបូជាដោយការបំពេញការលាងជើង និងការលាបជើង ទាំងថ្វាយបន្តុំទៀបជើង ។ ពាក្យថា **ក្នុងនិវេសន៍របស់ខ្លួន** គឺ ក្នុងផ្ទះរបស់ខ្លួន ។ ចំពោះបទនេះ ក៏ត្រូវយកទៅភ្ជាប់នឹងបទថា រក្សាហើយ នេះដូចគ្នា ។ ពាក្យថា **គប្បីដឹងចំពោះខ្លួន** គឺ គប្បីដឹងបានដោយខ្លួនឯង ។ ពាក្យថា **សុភាសិតទាំងឡាយរបស់ពួកព្រះអរិយៈ** គឺ សុភាសិតទាំងឡាយ របស់ព្រះមានព្រះភាគ ដែលពួកលោកបានពោល ។ ពាក្យថា **តែពួកលោកអង្គុយជិតបុគ្គលដ៏ប្រសើរ** គឺ អង្គុយនៅជិតព្រះមានព្រះភាគ ជាបុគ្គលដ៏ឧត្តម ។ បទថា **ដ៏ប្រសើ** គឺ ឬក្នុងព្រះពុទ្ធសាសនា ។ បទថា **ព្រហ្មចារ្យ**

បានដល់ ការប្រព្រឹត្តដ៏ប្រសើរបំផុត ។ បទថា **ការឧប្បត្តិរបស់ពួកលោក** បានដល់ ការចូលដល់របស់ពួកលោក ។ ពាក្យថា **កាលខ្ញុំនៅក្នុងអាគារ** បានដល់ កាលខ្ញុំនៅក្នុងផ្ទះ ។ ពាក្យថា **ស្វាជ្ជ** កាត់បទថា **សោ អជ្ជ** ប្រែថា គោបកទេវបុត្តនោះ ក្នុងថ្ងៃនេះ ។

លោកហៅគោបកៈថា សាវកព្រះគោតម ក្នុងទីនេះថា **ជាសាវកព្រះគោតម** ។ ពាក្យថា **មកព្រមហើយ** គឺ ប្រជុំគ្នាហើយ ។ ពាក្យថា **ណ្ហើយចុះ មកប្រឹងប្រែងព្យាយាមជាមួយគ្នាចុះ** គឺ ណ្ហើយចុះ ពួកយើងមកខ្នះខ្នែងព្យាយាមចុះ ។ ពាក្យថា **នោ** ក្នុងបទថា **ពួកយើងកុំមកជាអ្នកបម្រើគេឡើយ** នេះត្រឹមតែជាពាក្យជ្រែកចូលមកប៉ុណ្ណោះ ។ អត្ថន័យក៏គឺ ពួកយើងកុំមកជាអ្នកបម្រើរបស់អ្នកដទៃឡើយ ។ ក្នុងពាក្យថា **ពាក្យទូន្មានរបស់ព្រះគោតម** នេះ ដោយប្រក្រតី លោកហៅបឋមឈានដែលបានទុកឯងថា ពាក្យប្រៀនប្រដៅរបស់ព្រះគោតម មានន័យថា អនុស្សរណៈ គឺ តាមរឭកដល់បឋមជ្ឈាននោះ ។ ពាក្យថា **ប្រាសចាកចិត្តទាំងឡាយ** គឺ ប្រាសចាកពួកចិត្តដែលប្រកបដោយកាមគុណ ៥ យ៉ាង ។ ពាក្យថា **ទោសក្នុងពួកកាម** គឺ បានឃើញទោសក្នុងកាមទាំងឡាយ ដោយបឋមឈាន ព្រោះដោយអំណាចការគ្របសង្កត់ ព្រោះដោយអំណាចការ

កាត់ផ្តាច់ដោយដាច់ខាត លោកទាំងនោះបានឃើញទាំងគ្រឿងប្រកប គឺ កាម និងគ្រឿងចង គឺ កាម , ដែលឈ្មោះថា **កាមសញ្ញោជន៍** ដោយមគ្គទីបី ។ ពាក្យថា **ជាគ្រឿងប្រកបរបស់អ្នកមានបាប** មានន័យថា ជាគ្រឿងប្រកប ជាគ្រឿងចងរបស់បុគ្គលមានបាប គឺ របស់មារ ។ ពាក្យថា **រួចផុតបានលំបាក** គឺ លំបាកនឹងឈានកន្លងទៅបាន ។ ពាក្យថា **ពួកទេពរួមទាំងព្រះឥន្ទ រួមទាំងបជាធិបតី** សេចក្តីថា អ្នកដែលធ្វើព្រះឥន្ទ្រឲ្យជាប្រធានហើយចូលទៅ ឈ្មោះថា រួមទាំងព្រះឥន្ទ្រ អ្នកដែលធ្វើបជាបតិទេវរាជឲ្យជាប្រធាន ហើយចូលទៅ ឈ្មោះថា ព្រមទាំងបជាធិបតី ។ ពាក្យថា **ចូលទៅក្នុងសភា** សេចក្តីថា ចូលទៅអង្គុយក្នុងទីប្រជុំ ។ ពាក្យថា **អ្នកក្លៀវក្លា** គឺ អ្នកក្លាហាន ។ ពាក្យថា **ប្រាសចាកតម្រេក** គឺ ប្រាសចាកតម្រេក ។ ពាក្យថា **ធ្វើធម៌ដែលប្រាសចាកមន្ទិល** គឺ ធ្វើបានដល់ ធ្វើអនាគាមិមគ្គដែលមិនមានមន្ទិល ឲ្យកើតឡើង ។ ពាក្យថា **លះកាមគុណដ៏ល្អិត ដូចដំរី** គឺ កាត់គ្រឿងប្រកប គឺ កាម និងគ្រឿងចងបានហើយ ក៏ឈានកន្លងពួកទេវតាជាន់តាវតឹង្សទៅ ។

ពាក្យថា **ទ្រង់កើតសេចក្តីសង្វេគ** គឺ ស្តេចសក្កៈ ក៏ទ្រង់កើតសេចក្តីសង្វេគ ។ ពាក្យថា **អ្នកប្រសន្តតកាម** គឺ អ្នកទ្រង់គ្របសង្កត់កាម

សម្បត្តិទាំងពីរយ៉ាង ។ ពាក្យថា **អ្នកវិនាសចាកសតិ** គឺ អ្នកវៀរចាកសេចក្តីរឭកដល់ឈាន ។ ពាក្យថា **នៃបីអន្លើនោះ** គឺ ក្នុងបីអន្លើនោះ ។ ពាក្យថា **មួយអន្លើនៅក្នុងភពនោះ** គឺ ដែលជាអ្នកកើតនៅក្នុងពួកជាន់ថោកទាបនោះ មានត្រឹមតែម្នាក់ប៉ុណ្ណោះ ។ ពាក្យថា **មានប្រក្រតីតាមរឭកដល់ផ្លូវនៃសេចក្តីត្រាស់ដឹង** គឺ មានប្រក្រតីតាមរឭកដល់អនាគាមិមគ្គ ។ ពាក្យថា **រមែងមើលឆាយ សម្បត្តិដល់ពួកទេព** គឺ មើលឆាយបានដល់ ធ្វើទេវលោកសម្បត្តិទាំងពីរជាន់ឲ្យធ្លាក់ទាបចុះ ព្រោះភាពដែលខ្លួនតាំងមាំដោយឧបចារសមាធិ និងអប្បនាសមាធិ ទើបយកធូលីដែលជាប់ជើងរបស់ខ្លួន មកកោយដាក់សិរសៈពួកទេវតា ហើយហោះទៅក្នុងអាកាស ។ ពាក្យថា **អ្នកប្រកាសធម៌ដូច្នេះ ក្នុងសាសនានេះ** គឺ ពួកសាវក ជាអ្នកប្រកបព្រមដោយគុណសម្បត្តិទាំងនេះ ដែលជាគុណសម្បត្តិរបស់អ្នកដែលប្រកាសធម៌ មានសភាពដូច្នេះ ក្នុងព្រះសាសនានេះ ។ ពាក្យថា **នរណាៗ ដែលជាសាវក រមែងមិនសង្ស័យអ្វីក្នុងប្រការនោះ** គឺ ក្នុងសាវកទាំងនោះ នរណាៗ សូម្បីសាវកតែមួយរូប ក៏មិនសង្ស័យក្នុងព្រះពុទ្ធជាដើម ឬក្នុងភាពជាអ្នកនៅក្នុងទិសទាំងបួន ជាអ្នកមិនទើសទាក់ មិនប្រកាន់មាំក្នុងទិសទាំងអស់ ។ ឥឡូវនេះ កាលនឹងទ្រង់សរសើរព្រះ-

គុណរបស់ព្រះមានព្រះភាគ ទើបត្រាស់ថា សូមនមស្ការព្រះពុទ្ធ អ្នកទ្រង់ធួនអន្ទង់បានហើយ កាត់សេចក្តីសង្ស័យបានហើយ ព្រះអង្គទ្រង់ឈ្នះព្រះអង្គជាធំជាងជន ដូច្នេះ ។

ក្នុងបទទាំងនោះ ពាក្យថា **អ្នកកាត់សេចក្តីសង្ស័យបានហើយ** គឺ សេចក្តីសង្ស័យបានហើយ ។ ពាក្យថា **ជាអ្នកធំជាងជន** គឺ ព្រះអង្គទ្រង់ខ្ពស់បំផុតក្នុងលោកទាំងអស់ ។ ពាក្យថា **ធម៌ណារបស់ព្រះអង្គ** គឺ ធម៌របស់ព្រះអង្គណា ។ ពាក្យថា **លោកទាំងនោះបានដល់ហើយ** គឺ ទេវបុត្តទាំងនោះបានសម្រេចហើយ ។ ពាក្យថា **កាយព្រហ្មបុរោហិត** គឺ កាលពួកខ្ញុំព្រះអង្គកំពុងមើលនោះ ក៏សរីរៈក្លាយជាព្រហ្មបុរោហិត ។ មានពាក្យដែលស្តេចសក្កៈទ្រង់អធិប្បាយទុកដូច្នេះថា ទេវតាទាំងនោះ ជ្រាបធម៌របស់ព្រះអង្គណាហើយ ក្នុងទេវបុត្តទាំងបីនោះ ទេវបុត្តទាំងពីរនោះ បានដល់គុណពិសេស ខណៈដែលពួកខ្ញុំព្រះអង្គឃើញទាំងអស់គ្នានោះ ក៏សម្រេចកាយជាព្រហ្មបុរោហិតហើយ បានសម្រេចគុណពិសេស គឺ មគ្គផល ម្នាលអ្នកនិរទុក្ខ សូម្បីពួកខ្ញុំព្រះអង្គ ក៏មកដើម្បីសម្រេចធម៌នោះ ។ ពាក្យថា **មកហើយ** គឺ ដល់ព្រមហើយ ។ ពាក្យថា **ពួកខ្ញុំព្រះអង្គ ដែលព្រះមានព្រះភាគបានប្រទានព្រះឱកាសហើយ នឹងគប្បីទូលសួរបញ្ហា ម្នាល**

**អ្នកនិគ្រោធ** មានសេចក្ដីថា ប្រសិនបើព្រះមានព្រះភាគ នឹងប្រទានព្រះឱកាស ពេលនោះ ម្នាលអ្នកនិគ្រោធ ពួកខ្ញុំព្រះអង្គ ដែលព្រះមានព្រះភាគបាន ប្រទានព្រះឱកាសហើយ ក៏នឹងគប្បីទូលសួរបញ្ហា ។

## ព្រះមានព្រះភាគទ្រង់ត្រិះរិះ

[៩២] ពាក្យថា **យក្ស ( ព្រះឥន្ទ្រ ) នេះ ជាអ្នកបរិសុទ្ធមកយូរ ហើយ** គឺ ជាអ្នកបរិសុទ្ធ បរិសុទ្ធល្អចាប់ផ្ដើមតាំងពីកាលយូរមកហើយ ។ កាលយូរប៉ុនណា ។ យូរចាប់ផ្ដើមពីគ្រាជាមាឃមាណពជាអ្នកស្រុកមចល: ដែនមគធ គ្រាព្រះពុទ្ធទ្រង់មិនទាន់កើតឡើងមកម្ល៉េះ ។ ដូចមានរឿងមក ថា គ្រានោះ ថ្ងៃមួយ មាឃមាណពនោះ ក្រោកឡើងពីព្រឹកព្រលឹម ហើយ ទៅកាន់កន្លែងធ្វើការងារប្រចាំក្នុងស្រុក ជាមួយពួកអ្នកស្រុក យកចុងជើង ទុះឯង កៀរដុំដី និងសម្រាម លាមកចេញទៅ ធ្វើកន្លែងដែលខ្លួនឈរ ឲ្យគួររីករាយ ។ អ្នកដទៃក៏មកឈរក្នុងទីនោះ ។ ដោយហេតុត្រឹមតែ ប៉ុណ្ណោះឯង គេក៏ត្រឡប់បានសេចក្ដីរឭក ទើបកាប់ឆ្ការកន្លែងជារង្វង់ ត្រង់ផ្លាកណ្ដាលស្រុក ហើយក៏ជញ្ជូនខ្សាច់មករោយ ជញ្ជូនយកឧសមក បង្កាត់ភ្លើងក្នុងវេលាត្រជាក់ ។ ទាំងកម្លោះក្រមុំ និងមនុស្សចាស់ ក៏នាំ

គ្នាមកអង្គុយក្នុងទីនោះ ។ តមកថ្ងៃមួយ គេកើតសេចក្ដីគិតថា កាលយើងទៅទីក្រុង ក៏ឃើញព្រះរាជា និងអ្នករាជការជាអ្នកធំជាដើម អ្នកទាំងឡាយនោះក៏ពោលថា ក្នុងព្រះចន្ទ និងព្រះអាទិត្យទាំងនោះ ក៏មានទេវបុត្តឈ្មោះចន្ទទេវបុត្ត ឈ្មោះសុរិយៈ ពួកអ្នកទាំងនោះធ្វើអ្វីហ្ន៎ ទើបបានសម្បត្តិទាំងនេះ ។ តមកទើប គិតបានថា វត្ថុដទៃណា ៗ មិនមាន ត្រូវធ្វើបុណ្យប៉ុណ្ណោះ ហើយគិតថា សូម្បីយើងក៏ត្រូវធ្វើបុណ្យដែលឲ្យសម្បត្តិយ៉ាងនេះដូចគ្នា ។ គេទើបក្រោកឡើងតាំងពីព្រឹកព្រលឹម ផឹកបបរហើយ ក៏កាន់យកកាំបិត ពូថៅ ចបជីក និងឈើអន្ទង ទៅត្រង់ផ្លូវធំបែកជាបួន យកឈើអន្ទងគាស់ដុំថ្មឲ្យរបើក ហើយប្រមៀលចេញទៅ យកឈើមកធ្វើជាភ្លៅយាន ពង្រាបទីដែលរដិបរដុបឲ្យរាបស្មើ ហើយសាងសាលាត្រង់ផ្លូវធំបែកជា ៤ ជីកស្រះឈូក ចងស្ពាន ធ្វើការងារយ៉ាងនេះ រហូតដល់ថ្ងៃលិច ទើបត្រឡប់មកផ្ទះ ។

មានអ្នកដទៃសួរគេថា សម្លាញ់មាឃៈ លោកចេញទៅតាំងពីព្រឹកល្ងាចទើបមកពីព្រៃ លោកធ្វើការងារអ្វី ។ ខ្ញុំធ្វើបុណ្យ សាងផ្លូវទៅសួគ៌ ។ ឈ្មោះថា បុណ្យនេះ គឺ អ្វីសម្លាញ់ ។ លោកមិនដឹងទេឬ ។ អើ ខ្ញុំមិនដឹង ។ វេលាទៅទីក្រុង លោកធ្លាប់ឃើញពួករាជា និងអ្នករាជការ

ជាអ្នកធំជាដើមឬទេ ។ ធ្លាប់ឃើញ ។ ពួកអ្នកនោះធ្វើបុណ្យហើយ ទើបបានតំណែងនោះ ខ្ញុំក៏នឹងធ្វើការងារដែលឲ្យសម្បត្តិយ៉ាងនោះខ្លះ លោកធ្លាប់ឮទេថា ទេវបុត្តឈ្មោះចន្ទ ទេវបុត្តឈ្មោះសរិយៈ ។ អើ ធ្លាប់ឮ ។ ខ្ញុំក៏នឹងសាងផ្លូវទៅកាន់សួគ៌នោះ ។ អើ ក៏បុញ្ញកម្មនេះ សមគួរសម្រាប់លោកប៉ុណ្ណោះ ឬសម្រាប់អ្នកដទៃក៏សមគួរផង ។ បុណ្យនោះ មិនជំទាស់ដល់នរណា ៗ ទេ ។ បើដូច្នោះ ស្អែកនេះ វេលាទៅព្រៃលោក ហៅខ្ញុំផងណា ។ ថ្ងៃស្អែកឡើង គេក៏នាំអ្នកនោះទៅ ។ ដោយប្រការដូច្នេះ ក្នុងពួកអ្នកស្រុកនោះ ទើបមានអ្នកនៅក្នុងវ័យធកញ្ច រួមសាមសិបបីនាក់គ្រប់គ្នាសុទ្ធតែប្រព្រឹត្តទៅតាមនាយមាឃៈទាំងអស់ ។ ពួកគេធ្វើបុណ្យជាឯកឆន្ទៈ ថ្ងៃណាទៅកាលនឹងពន្រាបផ្លូវឲ្យរៀបស្មើ មួយថ្ងៃប៉ុណ្ណោះ កាលនឹងជីកស្រះឈូក សាងសាលា សាងស្ពានក៏ឲ្យសម្រេចក្នុងមួយថ្ងៃប៉ុណ្ណោះ ។

តមក មេស្រុករបស់ពួកគេ ក៏គិតថា ពីមុន កាលពួកនេះនៅផឹកស្រា និងនៅសម្លាប់សត្វជាដើម យើងរមែងបានទ្រព្យដោយអំណាចកហាបណៈបន្តិចបន្តួចជាដើមខ្លះ ដោយអំណាចកាសុីអាជ្ញាប័ត្រខ្លះ ឥឡូវនេះ តាំងពីពួកនេះ បានធ្វើបុណ្យ តម្លៃបានដូចចំនួននោះក៏អស់ទៅ ណ្ហើយចុះ យើងនឹង ទំលាយពួកនោះក្នុងរាជត្រកូល ទើបចូលគាល់ព្រះរាជាក្រាបទូលថា

មហារាជ ខ្ញុំព្រះករុណាជួបក្រុមចោរ ។

រាជា . ទីណា បា ! ។

មេស្រុក . ក្នុងស្រុកខ្ញុំ ព្រះករុណា ។

រាជា . ចោរប្រភេទណា បា ! ។

មេស្រុក . ប្រភេទធ្វើខុសចំពោះព្រះរាជា ព្រះអង្គ ។

រាជា . ជាតិអ្វី ? ។

មេស្រុក . ជាតិជាអ្នកស្រុក ព្រះអង្គ ។

ព្រះរាជា . អ្នកស្រុកនឹងធ្វើអ្វីបាន កាលបើអ្នកដឹងដូច្នោះ ហេតុដូចម្តេច ទើបមិនប្រាប់យើង ។

មេស្រុក . មហារាជ ដែលមិនបានក្រាបទូល ព្រោះខ្លាចព្រះអាជ្ញា ឥឡូវនេះ សូមព្រះអង្គកុំគប្បីដាក់ព្រះអាជ្ញាដល់ខ្ញុំព្រះករុណា ។

លំដាប់នោះ ព្រះរាជាទ្រង់គិតថា មេស្រុកនេះបន្លឺសំឡេងខ្លាំង ៗ ទើបទ្រង់ជឿ ទើបត្រាស់ថា បើដូច្នោះ អ្នកឯងចូរទៅនាំពួកចោរទាំងនោះមក ហើយក៏ប្រទានកម្លាំងបញ្ជូនទៅ ។ មេស្រុកនោះក៏ទៅ ឈោមព័ទ្ធពួកនោះ ខណៈដែលកំពុងធ្វើការងារប្រចាំថ្ងៃក្នុងព្រៃស្រេចហើយ អន្ទុយទទួលទានអាហារត្រជាក់ កណ្តាលពួកអ្នកស្រុក ហើយក៏ប្រឹក្សាគ្នាថា

ស្អែកនេះពួកយើងនឹងធ្វើការងារអ្វី នឹងពង្រាបផ្លូវឲ្យស្មើ នឹងជីកស្រះ ឬនឹងចងស្ពាន ហើយស្រែកសន្ទាប់ទៅថា កុំផ្លាស់ប្តូរកន្ទែងណា នេះពាក្យបញ្ជារបស់ហ្វូង ហើយចងនាំទៅ ។

លំដាប់នោះ ពួកស្ត្រីជាប្រពន្ធរបស់អ្នកទាំងនោះ បានស្តាប់ថា ន័យថា ពួកស្វាមីរបស់ពួកយើងជាចោរក្បត់ចំពោះព្រះរាជា ដែលគេកំពុងរកមុខថា ជាចោរ ទើបចងនាំចេញទៅ ទើបនិយាយថា ពួកនេះជាអ្នកកោងមកយូរហើយ មួយថ្ងៃ ៗ មានតែនិយាយថា ធ្វើបុណ្យ ហើយក៏ទៅព្រៃតែម្យ៉ាង ការងារគ្រប់យ៉ាងក៏វិនាសអស់ ក្នុងផ្ទះនឹងរកអ្វីតែបន្តិច ក៏មិនមាន ចងឲ្យល្អ នាំទៅឲ្យល្អ ។ សូម្បីមេស្រុក ក៏នាំពួកគេទៅសម្តែងដល់ព្រះរាជា ។ ព្រះរាជាទ្រង់មិនទាន់បានដេញដោលសួរឡើយ ត្រាស់ថា ចូរឲ្យដំរីជាន់ ។ កាលពួកគេត្រូវនាំទៅ មាឃះ និយាយនឹងអ្នកដទៃនេះថា សម្លាញ់ ! ពួកលោកនឹងធ្វើតាមពាក្យរបស់ខ្ញុំ បានទេ ។

កាលធ្វើតាមពាក្យរបស់លោកទុំះឯង ពួកយើងទើបដល់ភ័យ ដូច្នោះ ណ្ហើយចុះ យើងក៏នៅធ្វើតាមពាក្យរបស់លោក តែថា លោកនឹងឲ្យពួកយើងធ្វើអ្វី បក្ខពួកពោល ។

សម្លាញ់ មកចុះ នេះជារឿងដែលជាប់ទាក់ទងនឹងអ្នកដែលត្រាច់

ទៅក្នុងវត្ថុ: ក៏ពួកលោកជាចោរឬ មាឃ:បញ្ជាក់ និងសួរបក្ខពួកខ្លួន ។

ពួកយើងមិនមែនចោរ បក្ខពួកឆ្លើយយ៉ាងម៉ឺងម៉ាត់ ។

ឈ្មោះថា ការធ្វើសច្ចៈជាទីពឹងរបស់ពួកលោក ដូច្នោះ បើពួកយើងសូម្បីទាំងអស់ជាចោរ សូមឲ្យដំរីជាន់ បើមិនមែនជាចោរ ចូរកុំជាន់ សូមឲ្យពួកលោកធ្វើសច្ចៈដូចដែលពោលមកនេះ មាឃ:ណែនាំ ។ ពួកគេក៏បានធ្វើយ៉ាងនោះ ។

ដំរីសូម្បីតែនឹងចូលជិតក៏មិនបាន ស្រែកបណ្តើរ គេចចៀសចេញទៅបណ្តើរ សូម្បីនឹងយកដែកស្រួច លំពែង និងកន្ទ្រវចាក់យ៉ាងណា ក៏បញ្ឈប់មិននៅ ។ ពួកទ្រមាក់ដំរី ទើបទៅក្រាបទូលព្រះរាជាថា ពួកទូលបង្គំដេញដំរីចូលទៅជិតមិនបាន ។

បើដូច្នោះ ចូរយកកន្ទេលផែងគ្របបិទខាងលើពួកវា ហើយឲ្យជាន់ ព្រះរាជាត្រាស់បង្គាប់ ។ កាលគ្របកន្ទេលផែងទុកខាងលើហើយ ដំរីក៏ស្រែកយ៉ាងខ្លាំងជាលើកទីពីរ ហើយក៏គេចចេញទៅ ។

ព្រះរាជាទ្រង់ស្តាប់ហើយ ក៏ទ្រង់ត្រាស់បង្គាប់ឲ្យហៅអ្នកញុះញង់មក ហើយត្រាស់ថា បា ! ដំរីវាមិនព្រមជាន់ ។

សូមទ្រង់មេត្តាជ្រាប មាណពដែលជាប្រធាន ចេះមន្ត នោះជាអានុភាព

របស់មន្តពិតប្រាកដមែន មេស្រុកធ្វើយនឹងព្រះតម្រាស់ព្រះរាជា និងក្រាបទូលសេចក្តី ។

ព្រះរាជាទ្រង់ត្រាស់បង្គាប់ឲ្យប្រធាននោះចូលគាល់ ហើយត្រាស់សួរថា គេថា អ្នកមានមន្តឬ ។

សូមទ្រង់មេត្តាប្រោស ខ្ញុំព្រះអង្គ មិនមានមន្តទេ តែពួកខ្ញុំព្រះអង្គបានធ្វើសច្ចកិរិយាទុកថា បើពួកយើងជាចោររបស់ព្រះរាជា សូមឲ្យដំរីជាន់ចុះ បើមិនមែនជាចោរ សូមកុំឲ្យជាន់ នោះជាអំណាចរបស់សច្ច-កិរិយា របស់ពួកខ្ញុំព្រះអង្គ ។

រាជា . ចុះពួកអ្នកធ្វើការងារអ្វី ? ។

ប្រធាន . ពួកខ្ញុំព្រះអង្គ ពង្រាបផ្លូវដែលរដិបរដុបឲ្យរាបស្មើ សាងសាលាក្នុងផ្លូវធំបែកជាបួន ជីកស្រះឈូក ចងស្ពាន សូមទ្រង់មេត្តាជ្រាបពួកខ្ញុំព្រះអង្គ ត្រាច់សាងបុញ្ញកម្មបែបនេះ ។

រាជា . មេស្រុកញុះញង់ពួកអ្នក ដើម្បីអ្វី ?

ប្រធាន . វេលាដែលពួកខ្ញុំព្រះអង្គប្រមាទ គេរមែងបានវត្ថុនេះ និងវត្ថុនេះ វេលាមិនប្រមាទ វត្ថុនោះក៏មិនមាន ដោយហេតុនេះ ទើបញុះញង់ ។

រាជា . បា ដំរីនេះជាតិរច្ឆាន សូម្បីវាក៏គង់ដឹងគុណរបស់ពួកបា ខ្ញុំ

សូម្បីជាមនុស្សក៏មិនដឹង ខ្ញុំសូមលើកលែងស្រុកដែលជាទីនៅរបស់ពួកអ្នក ជាស្រុករួចផុតភាសុី ដែលនរណា ៗ មករក្សាមិនបាន ឲ្យដល់ពួកអ្នក ថែមទៀត សូម្បីដំរីនេះ ក៏ចូរជារបស់ពួកបាដូចគ្នា ចំណែកអ្នកខ្វែងគំនិត សូមប្រគល់ឲ្យជាទាសៈរបស់ពួកអ្នកចុះ តាំងពីនេះទៅ សូមឲ្យពួកអ្នក ចូរធ្វើបុណ្យដើម្បីខ្ញុំខ្លះណា ត្រាស់ហើយ ក៏ព្រះរាជទានព្រះរាជទ្រព្យឲ្យ ហើយទ្រង់ក៏ត្រឡប់ទៅ ។

ពួកគេទទួលព្រះរាជទ្រព្យហើយ ក៏ផ្លាស់វេនគ្នាឡើងដំរីទៅបណ្ដើរ ប្រឹក្សាគ្នាថា សម្លាញ់អើយ ធម្មតាបុញ្ញកម្ម ជារបស់ដែលត្រូវធ្វើដើម្បី ប្រយោជន៍នៃភពក្នុងអនាគត ព្រោះបុណ្យនោះរបស់ពួកយើងឲ្យផលក្នុង អត្តភាពនេះឯង ដូចឧប្បលខៀវដែលចេញផ្កាចេញផ្លែខាងក្នុងទឹក ឥឡូវនេះ ពួកយើងនឹងធ្វើបុណ្យឲ្យក្រៃលែងឡើងទៅ ។ ពួកយើងនឹងធ្វើយ៉ាងណា ? យើងធ្វើជាវេវត្ថុក្នុងផ្លូវធំបែកជាបួន ហើយសាងសាលាសម្រាប់សម្រាក របស់មហាជន ។ តែពួកស្ត្រីនឹងមិនព្រមឲ្យមានចំណែករួម ព្រោះកាល ពួកយើងត្រូវជាប្រធានមិនថា ចោរចាប់នាំទៅ ក្នុងពួកស្ត្រីសូម្បីមួយនាក់ ក៏មិនធ្វើសូម្បីត្រឹមតែមានចិត្តជួយ មានតែបញ្ចូនថែមថា ចងឲ្យល្អ ចាប់ ឲ្យល្អ ព្រោះដូច្នោះ ពួកយើងនឹងមិនព្រមឲ្យស្ត្រីទាំងនោះ មានចំណែករួម ។

ពួកគេក៏នាំគ្នាទៅផ្ទះខ្លួន ឲ្យបាយ ៣៣ ដុំ នាំស្មៅ ៣៣ បាច់ដល់ដំរី ។ ទាំងអស់នោះ ក៏ពេញពោះដំរី ។ ពួកគេចូលព្រៃកាត់ឈើ ។ ដំរីក៏ទាញយកឈើដែលកាត់ហើយ ៗ មកដាក់ទុកត្រង់ផ្លូវរទេះ ។ ពួកគេជួយគ្នាចាំងឈើ ផ្ដើមសាងសាលា ។

មាឃៈ មានភរិយានៅក្នុងផ្ទះបួននាក់ គឺ នាងសុជាតា នាងសុធម្មា នាងសុចិត្រា នាងសុនន្ទា ។ នាងសុធម្មា សួរជាងឈើថា ពុក ! ពួកសម្លាញ់ទាំងនេះ ព្រឹកក៏ទៅ ល្ងាចទើបមក ពួកគេធ្វើការងារអ្វី ។ ធ្វើសាលា នាង ។ ពុក ! សូមឲ្យលោកជួយធ្វើឲ្យនាងខ្ញុំមានចំណែករួមក្នុងសាលាជាមួយអ្នកផង ។ ពួកសម្លាញ់ទាំងនេះពោលថា ពួកយើងនឹងមិនព្រមឲ្យពួកមនុស្សស្រីមានចំណែករួម ។ នាងបានឲ្យប្រាក់ជាងឈើ ៨ កហាបណៈ ដោយនិយាយថា យកចុះ លោកពុក សូមឲ្យលោកជួយរកឧបាយយ៉ាងណាមួយ ធ្វើឲ្យខ្ញុំមានចំណែករួមផង ។ គេពោលថា ធ្លាក់ព្រមនឹងហើយ ក៏កាន់យកកាំបិទ និងយកពូថៅយ៉ាងរហ័ស ទៅឈរកណ្ដាលស្រុក ស្រែកសំឡេងខ្លាំង ៗ ថា លោក ! ថ្ងៃនេះ វេលាថ្មើនេះហើយ មិនទាន់ចេញទៅទៀតឬ ? ដឹងថា ឡើងកាន់ផ្លូវអស់ហើយ ទើបថា ពួកលោក ចូរដើរទៅមុន ខ្ញុំមានការចាំបាច់ត្រូវពន្យា ហើយក៏ឲ្យអ្នកទាំងនោះ

ទៅមុន ហើយដើរទៅផ្លូវដទៃ កាត់ឈើសម្រាប់ប្រើជាជហ្វា ចាំងស្រេច ហើយ ជញ្ជូនមកទុកត្រង់ផ្ទះនាងសុធម្មា ប្រាប់នាងថា នាងគប្បីឲ្យជញ្ជូន ចេញទៅបាន ក្នុងថ្ងៃដែលខ្ញុំប្រាប់ថា ចូរឲ្យចុះ ។

តមក កាលសម្រេចការងារដែលទាក់ទងនឹងគ្រឿងធ្វើសាលា និង កាលធ្វើគ្រឿងចងត្រង់ទីតោង ការលើកសរសរ ការប្រកបផ្ទឹម និងទីភ្ជាប់ ជហ្វាតាំងពីផ្ទៃដីសម្រេចហើយ ជាងឈើនោះ ក៏អង្គុយក្នុងទីសម្រាប់ភ្ជាប់ ជហ្វា ឲ្យលើកបន្ទង់ទាំងបួនទិស និយាយថា ឱ ! មានក្មេចអ្វីមួយទេ ។ លោកមានអ្វីដែលមិនក្មេចទេ ? ក្មេចទាំងអស់ទុំះឯង ។ ហើយយកឈើ បន្ទង់ទាំងនេះ ទៅតាំងទុកត្រង់ណា ? គួរនឹងបានជហ្វាមក ។ បាអើយ ឥឡូវនេះ យើងអាចបានពីទីណាហ្ន៎ ។ អាចបានក្នុងផ្ទះនៃត្រកូលទាំងឡាយ សាកដើរសួរមើល ។ ពួកគេក៏ចូលទៅសួរក្នុងស្រុក ហើយមកឈរត្រង់ ទ្វារផ្ទះនាងសុធម្មា សួរថា ក្នុងផ្ទះនេះមានជហ្វាទេ ។ នាងប្រាប់ថា មាន ។ អញ្ជើញទទួលតម្លៃទៅ ។ មិនទទួលតម្លៃទេ បើពួកលោកព្រមឲ្យខ្ញុំមាន ចំណែករួមផង ខ្ញុំនឹងឲ្យ ។ ពួកយើង នឹងមិនព្រមឲ្យមនុស្សស្រីមាន ចំណែករួមទេ ពួកយើងនឹងទៅព្រៃ ហើយកាត់ឈើ ថាហើយ ក៏នាំគ្នា ចេញទៅ ។ តពីនោះពួកគេ កាលត្រូវជាងឈើសួរថា យ៉ាងណា លោក

រកបានជហ្វាទេ ? ក៏ដឹងច្បាស់សេចក្តីនោះ ។ ជាងឈើអន្ទុយនៅត្រង់ទី ភ្ជាប់ជហ្វាដូចដើម ងើយសម្លឹងមើលអាកាស ហើយនិយាយថា លោកដ៏ចម្រើន ថ្ងៃនេះឫក្សល្អ កន្លងឫក្សនេះហើយ ឆ្នាំដទៃ ទើបនឹងអាចបាននិងពួកលោក ក៏នឹងនាំយកគ្រឿងធ្វើសាលាមកលំបាកណាស់ គ្រឿងគ្រៅទាំងនោះ យកមកគរទុក រហូតដល់អស់ឆ្នាំ ក៏នឹងពុកផុយក្នុងទីនេះឯង វេលាកើតក្នុងទេវលោក ក៏ចូរព្រមឲ្យសាលា មួយជ្រុងដល់នាងចុះ ទៅយកជហ្វានោះមក ។ សូម្បីនាងសុធម្មានោះ វេលាដែលពួកទាំងនោះមិនទាន់មកម្តងទៀត បានប្រាប់ឲ្យឆ្លាក់អក្សរថា សាលាមួយខ្នងនេះ ឈ្មោះសុធម្មា ទុកត្រង់ផ្ទៃក្រោមជហ្វា ហើយយកសម្ពត់ថ្មីមករុំទុក ។

កាលពួកអ្នកការងារមកហើយ ពោលថា ជួយនាំយកជហ្វាមកស្មើនឹងបាន ពួកយើងនឹងធ្វើឲ្យនាងមានចំណែករួមផង ។ នាង ក៏នាំចេញមក ប្រាប់ថា បាទាំងឡាយ ! កុំយកសម្ពត់នេះចេញណា ដរាបដល់ជាងមិនទាន់ឡើងឈើបង្គន់បាន ៨ ឬ ១៦ កំណាត់មុន ហើយក៏ឲ្យទៅ ។ ពួកអ្នកទាំងនោះក៏ទទួលថា ព្រម គ្រាលើកឈើបង្គន់ឡើងស្រេចហើយ ក៏យកសំពត់ចេញ ។ សម្ងាញ់ម្នាក់ ងើយមុខឡើងខាងលើ ឃើញអក្សរ ទើបនិយាយថា នេះអ្វី ? ហើយឲ្យទៅតាមអ្នកដែលចេះអានអក្សរមក

សម្ដេច ។ អ្នកនោះក៏អានថា សាលាមួយខ្នងនេះ ឈ្មោះ **សុធម្មា** ។ ពួកគេក៏ស្រែកឡើងថា យកចេញទៅលោក តាំងពីដើមមក កាលសាងសាលា ពួកយើងមិនបានសូម្បីតែឈ្មោះ នាងនេះ គ្រាន់តែយកឈើជហ្វាមកដាក់ ហើយឲ្យធ្វើសាលាដោយឈ្មោះខ្លួន ។ កាលពួកគេកំពុងស្រែកឡើងហើយទុំះឯង ជាងឈើ ក៏ស៊កឈើបន្ទន់ ហើយដំគន្លឹះដែលជាការសម្រេចការសាងសាលា ។ គេបែងចែកសាលាជាបីចំណែក គឺ ចំណែកមួយ ធ្វើជាទីសម្រាកពួកមនុស្សចាស់ៗ , ចំណែកមួយ សម្រាប់ពួកអ្នកក្រលំបាក , ចំណែកមួយទៀត សម្រាប់អ្នកជម្ងឺ ។ ៣៣ នាក់ ក្រាលក្ដា ៣៣ ផ្ទាំង ហើយឲ្យសញ្ញាដំរីថា អាគន្តុកៈមកអង្គុយលើក្ដារបស់អ្នកណាក្រាលទុក ចូរនាំអ្នកនោះឯងទៅកាន់ត្រង់ផ្ទះរបស់ម្ចាស់របស់សន្ទឹកក្ដាទុំះចុះ ឲ្យការប្រេបាច់ជើង ឲ្យការគក់ខ្នង របស់ទំពារ របស់ស៊ី និងទីដេកទាំងអស់ដល់ អាគន្តុកៈនោះ នឹងជាការៈរបស់ម្ចាស់នៃសន្ទឹកក្ដាទុំះឯង ។ ដំរីក៏នាំភ្ញៀវ ដែលមកហើយ នាំទៅកាន់ផ្ទះរបស់ម្ចាស់សន្ទឹកក្ដាទុំះឯង ។ ថ្ងៃនោះ ម្ចាស់របស់សន្ទឹកក្ដានោះ ក៏ចាត់ចែងទឹកខ្ទែងគប្បីធ្វើដល់ភ្ញៀវនោះ ។

ក្នុងទីមិនឆ្ងាយសាលា មាឃមាណពដាំដើមរលួសទុក ។ ត្រង់គល់ឈើនោះក្រាលផ្ទាំងថ្មទុក ។ សូម្បីកិរិយារបស់គេដែលឈ្មោះសុនន្ទា

ក៏ឲ្យជីកស្រះឈ្មួកទុកជិត ៗ ។ នាងសុចិត្រា ដាំឈើផ្កា ។ ចំណែក ប្រពន្ធធំយកតែកញ្ចក់ធ្មុះតាក់តែងរាងកាយប៉ុណ្ណោះ ។ មាឃៈនិយាយនឹង នាងថា ប្អូន នាងសុធម្មានេះ គេមានចំណែកនៃសាលា នាងសុនន្ទា គេឲ្យ ជីកស្រះឈ្មួក រីឯនាងសុចិត្រា គេក៏ដាំឈើផ្កា ចំណែកប្អូន មិនទាន់មាន បុញ្ញកម្ម ប្អូន ចូរធ្វើបុណ្យឯណាដែលជាទីស្រឡាញ់តែម្យ៉ាងចុះ ។ នាង ឆ្លើយថា បងធ្វើព្រោះហេតុអ្នកណា ដែលបងធ្វើក៏ដើម្បីប្អូនដូចគ្នាមិនមែន ឬ ? ហើយក៏ជំពាក់ចិត្តនឹងការតាក់តែងខ្លួនតែម្យ៉ាង ។

កាលមាឃៈ រស់នៅដកាបដល់អស់អាយុហើយ ក៏ចុតិចាកមនុស្ស លោកនោះ ទៅកើតជាស្តេចសក្កៈក្នុងជាន់តាវត្តិង្ស ។ ឯសម្លាញ់ទាំង ៣៣ នាក់ ស្លាប់ហើយ ក៏ជាទេវបុត្រ ៣៣ អង្គ កើតក្នុងសម្នាក់របស់ស្តេចសក្កៈ នោះឯង ។ ប្រាសាទឈ្មោះ វេជយ័ន្ត របស់ស្តេចសក្កៈ ផុសឡើងមាន កម្ពស់ ៧០០ យោជន៍ ។ ទង់ផុសឡើងកម្ពស់ ៣០០ យោជន៍ ។ ដោយ ផលរបស់ដើមរលួសជាដើមបារិឆត្ត មានបរិមណ្ឌលដោយជុំវិញ ៣០០ យោជន៍ ទទឹង ១៥ យោជន៍ ។ ដោយផលនៃផ្ទាំងថ្ម កើតថ្មដូចសម្ពត់ កោមសត្វពណ៌លឿង ៦០ យោជន៍ ត្រង់គល់បារិឆត្ត ។ ដោយផលនៃ ជហ្វារបស់នាងសុធម្មា កើតទេវសភា ឈ្មោះសុធម្មា ៣០០ យោជន៍ ។

ដោយផលនៃស្រះឈូករបស់នាងសុនន្ទា កើតស្រះឈូក ឈ្មោះសុនន្ទា ៥០ យោជន៍ ។ ដោយផលនៃសួនឈើផ្ការបស់នាងសុចិត្រា កើតឧទ្យាន ឈ្មោះចិត្តលតាវ័ន ៦០ យោជន៍ ។

ស្ដេចសក្កៈ ជារាជានៃទេវតា ប្រថាប់លើបល្ល័ង្កមាសមួយយោជន៍ ក្នុងសុធម្មាទេវសភា មានស្វេតឆត្រ បីយោជន៍បាំងការពារ ហែហមទៅ ដោយទេវបុត្រទាំងនោះ ដោយទេវធីតាទាំងនោះ ដោយនាងរបាំ ២៥ កោដិ និងដោយពួកទេវតាក្នុងទេវលោកពីរជាន់ កាលត្រួតមើលមហាសម្បត្តិ ទ្រង់ឃើញស្ត្រីបីនាក់ទាំងនោះ ទ្រង់មើលថា បីនាក់នេះប្រាកដមុន សុជាតានៅទីណា ទ្រង់ឃើញថា នាងទៅកើតជានាងសត្វកុកមួយក្នុងញកភ្នំ ព្រោះមិនព្រមធ្វើតាមពាក្យយើង ហើយទ្រង់ចុះចាកទេវលោក ស្ដេចទៅកាន់សម្នាក់នាង ។ ពេលនាងឃើញប៉ុណ្ណោះឯង ក៏ចាំបាន ហើយឱនមុខ ។ ស្ដេចសក្កៈ ទើបត្រាស់ថា អ្នកឯងជាមនុស្សខ្លៅ ឥឡូវនេះ ដូចម្ដេច ? ទើបមិនព្រមងើបក្បាលឡើងមែនទេ អ្នកឯងមិនធ្វើតាមពាក្យយើង យកតែតែងសាច់តែងខ្លួន ធ្វើឲ្យអស់វេលា សម្បត្តិដែលធំក្រៃលែងកើតហើយ ដល់នាងសុធម្មា នាងសុនន្ទា និងនាងសុចិត្រា ចូរមកមើលសម្បត្តិពួកយើងចុះ ហើយក៏ទ្រង់នាំទៅទេវលោក ទ្រង់ព្រលែងក្នុងស្រះឈូកឈ្មោះ

សុនន្ទា ហើយស្តេចប្រថាប់អង្គុយលើបល្ល័ង្ក ។ ពួកនាងវប៉ាំក្រាបទូលសួរថា មហារាជ ស្តេចយាងទៅណា ។ ព្រះអង្គសូម្បីទ្រង់មិនចង់នឹងប្រាប់កាលត្រូវពួកនាងទាំងនោះ បៀតបៀនហើយ ក៏ត្រាស់ថា ទៅកាន់សម្នាក់សុជាតា ។

នាងវប៉ាំ. មហារាជ នាងកើតទីណា ។

សក្កៈ. ត្រង់ញកក្នុំ ។

នាងវប៉ាំ. ឥឡូវនេះនៅទីណា ។

សក្កៈ. យើងព្រលែងទុកត្រង់ស្រះឈូក ឈ្មោះសុនន្ទា ។

នាងវប៉ាំ. មកចុះ អ្នកដ៏ចម្រើន ពួកយើងទៅមើលអ្នកជាម្ចាស់របស់ពួកយើង ហើយទាំងអស់គ្នាក៏ទៅទីនោះ ។

នាងសុជាតានោះ អំពីមុនមក ប្រកាន់ខ្លួនថា ជាធំជាងគេទាំងអស់ ។ ឥឡូវនេះ ត្រឹមតែពួកស្រីអ្នករប៉ាំ កាលឃើញនាង ក៏នាំគ្នានិយាយចំអកឡកឡឺយជាដើមថា មើលចុះគ្នាយើង ម៉ែម្ចាស់ពួកយើងដូចជាច្បុកចាក់ក្តាម ។

នាងកើតសេចក្តីតូចចិត្តហួសប្រមាណ ទើបទូលស្តេចសក្កៈ អ្នកជារាជារបស់ទេវតាថា មហារាជ វិមានមាស វិមានប្រាក់ ឬសុនន្ទាបោក្ខរណី

ទាំងនេះ នឹងធ្វើអ្វីដល់នាងខ្ញុំ មហារាជ ជាតិភូមិប៉ុណ្ណោះឯង ដែលជាសុខរបស់ពួកសត្វ មេត្តាប្រលែងនាងខ្ញុំ ទុកត្រង់ជើងភ្នំនោះដូចដើមចុះ ។ ស្តេចសក្កៈ ទ្រង់ប្រលែងនាងទុកទីនោះ ហើយត្រាស់ថា នាងឯងនឹងធ្វើតាមពាក្យរបស់ខ្ញុំទេ ។ នាងទូលសួរថា នឹងធ្វើតាមមហារាជ ។ ស្តេចសក្កៈ ទើបត្រាស់ថា អ្នកឯងចូរទទួលសីល ៥ រក្សាកុំឲ្យដាច់ មិនប៉ុន្មានថ្ងៃ ខ្ញុំនឹងធ្វើនាងឲ្យធំជាងនាងទាំងនោះ ។ នាងក៏បានធ្វើយ៉ាងនោះ ។ កន្លងទៅបានពីរបីថ្ងៃ ស្តេចសក្កៈទ្រង់គិតថា នាងរក្សាសីល បានទេហ្ន៎ ទើបស្តេចប្លែងខ្លួនជាត្រីផ្ការពោះ អណ្តែតលើទឹកខាងមុខនាង ។ នាងគិតថា ស្មានថាត្រីស្លាប់ ទើបទៅចឹកយកត្រង់ក្បាល ។ ត្រីកម្រើកកន្ទុយ ។ នាងគិតថា ប្រហែលជាត្រីនៅរស់ហើយក៏ប្រលែងក្នុងទឹកទៅ ។ ស្តេចសក្កៈប្រថាប់ឈរត្រង់អាកាស ត្រាស់ថា សាធុ សាធុ អ្នកឯងរក្សាសិក្ខាបទបាន ខ្ញុំនឹងធ្វើនាងដែលរក្សាបានយ៉ាងនេះ ឲ្យជាប្រធានរបស់ពួកនាងទេវតារបាំ ដោយមិនយូរឡើយ ។ នាងមានអាយុ ៥០០ ឆ្នាំ ។ សូម្បីតែមួយថ្ងៃ ក៏មិនបានអាហារពេញពោះ សូម្បីនឹងស្ងួតហួតហែងក្រៀមក្រោះអស់កម្លាំងក៏ដោយ ក៏មិនធ្វើឲ្យសីលដាច់ កាលស្លាប់ហើយ ក៏កើតក្នុងផ្ទះជាងឆ្នាំងក្នុងក្រុងពារាណសី ។

កាលស្តេចសក្កៈទ្រង់ត្រួតមើលថា កើតទីណា ក៏ទ្រង់ឃើញ ទ្រង់គិតថា យើងនឹងនាំនាងមកទីនេះ ពីទីនោះមិនបាន យើងនឹងឲ្យការប្រព្រឹត្តទៅនៃជីវិតដល់នាង ទើបទ្រង់យកឃ្លោកមាសដាក់ក្នុងយានតូចដរាបពេញ ប្លែងភេទជាមនុស្សចាស់ អង្គុយត្រង់កណ្តាលភូមិ ស្រែកថា ពួកលោកចូរមកយកឃ្លោកមាស ។ ពួកអ្នកភូមិដោយជុំវិញមក ពោលថា ចូរឲ្យមកលោកតា ។ មនុស្សចាស់និយាយថា ខ្ញុំនឹងឲ្យដល់អ្នករក្សាសីល ពួកលោករក្សាសីលទេ ។ ពួកអ្នកទាំងនោះក៏ថា លោកតាអើយ ពួកយើងមិនដឹងថា សីលជាយ៉ាងណា តាចូរលក់ចុះ ។ តាចាស់និយាយថា ខ្ញុំនឹងឲ្យដល់អ្នករក្សាសីលប៉ុណ្ណោះ ។ ពួកមនុស្សនិយាយថា មកចុះលោក តាចាស់លក់ឃ្លោកមាសនេះ ជាអ្នកណា ហើយនាំគ្នាត្រឡប់វិញអស់ ។ ក្មេងស្រីនោះក៏សួរថា នាងម្ចាស់ទៅដើម្បីត្រូវការឃ្លោកមាស ហេតុដូចម្តេច ទើបត្រឡប់មកដៃទទេ ។ ពួកស្រីទាំងនោះឆ្លើយថា នាងអើយ តាចាស់លក់ឃ្លោកមាសជាអ្នកណា គាត់និយាយថា ខ្ញុំនឹងឲ្យដល់អ្នករក្សាសីល សូម្បីក្មេងស្រីរក្សាសីល រមែងបានឃ្លោកមាសនេះពិត ពួកយើងមិនស្គាល់សីលឡើយ ។ នាងគិតថា គង់នឹងនាំមកដើម្បីយើងពិត ទើបទៅ ហើយនិយាយថា លោកតា សូមលោកតា ឲ្យឃ្លោកមាសមកខ្ញុំ ។

ឥន្ទ្រ. នាងរក្សាសីលឬទេ ។

ក្មេងស្រី. ចាស៎ លោកតា នាងខ្ញុំរក្សាសីល ។

ឥន្ទ្រ. យើងនាំយកឃ្លោកមាសនេះមកដើម្បីនាងប៉ុណ្ណោះ ហើយក៏តាំងទុកព្រមទាំងយានតូចត្រង់ទ្វារផ្ទះ ហើយស្ដេចចៀសចេញទៅ ។ សូម្បីនាង ក៏រក្សាសីលរហូតអស់ជីវិត ចុតិហើយ ក៏កើតជាធីតារបស់វេបចិត្តិ-អសុរ ។ ព្រោះផលរបស់សីល នាងទើបជាអ្នកដែលគួរជ្រះថ្លា ។ ស្ដេចវេបចិត្តិគិតថា យើងនឹងធ្វើវិវាហមង្គលដល់កូនក្រមុំ ទើបឲ្យពួកអសុរប្រជុំគ្នា ។

ស្ដេចសក្កៈទ្រង់ត្រួតមើលថា កើតទីណា ទ្រង់ឃើញថា កើតក្នុងពិភពអសុរ ថ្ងៃនេះនឹងធ្វើវិវាហមង្គលដល់នាង ទ្រង់គិតថា ឥឡូវនេះយើងគួរធ្វើយ៉ាងណាមួយ ដើម្បីនាំនាងមក ទើបទ្រង់និម្មិតភេទជាអសុរចាស់ ប្រថាប់ឈរក្នុងចន្លោះពួកអសុរ ។ ព្រះបិតាត្រាស់ថា បានអនុញ្ញាតឲ្យកូនជ្រើសរើសស្វាមី ហើយក៏ប្រទានកម្រងផ្កាឈើដល់ដៃរបស់នាង ប្រាប់ថា កូនត្រូវការអ្នកណា ក៏ចូរបោះផ្កាឈើលើអ្នកនោះ ។ កាលនាងត្រួតមើល ក៏ឃើញស្ដេចសក្កៈ កើតសេចក្ដីស្រឡាញ់ ព្រោះធ្លាប់នៅរួមគ្នាមកពីកាលមុន កំណត់ថា នេះជាស្វាមីរបស់យើង ហើយក៏បោះកម្រងទៅលើ

គេ ។ ស្តេចសក្កៈនោះ ក៏ទ្រង់ចាប់ដៃនាងហោះទៅលើអាកាស ។ ខណៈនោះ ពួកអសុរក៏ចាំបាន ។ ពួកអសុរទាំងនោះ ស្រែកទៅថា ចាប់ ចាប់ សក្កៈកញ្ចាស់ទុក ជាសត្រូវពួកយើង ពួកយើងនឹងមិនព្រមឲ្យកូនក្រមុំដល់សក្កៈកញ្ចាស់នោះ ហើយក៏នាំគ្នាដេញតាម ។ ស្តេចវេបចិត្តិត្រាស់សួរថា អ្នកណានាំទៅ ។ ពួកអាសុរឆ្លើយថា សក្កៈកញ្ចាស់ មហារាជ ។ ក្នុងបណ្តាអ្នកដ៏សេស ស្តេចសក្កៈនេះប៉ុណ្ណោះ ប្រសើរបំផុត ចេញទៅ ស្តេចវេបចិត្តិត្រាស់ ។ កាលស្តេចសក្កៈនាំនាងទៅហើយ ក៏ទ្រង់តាំងទុកក្នុងតំណែងប្រធាននាងរបាំ ២៥ កោដិ ។ នាងទូលសូមពរចំពោះស្តេចសក្កៈថា មហារាជ ក្នុងទេវលោកនេះ នាងខ្ញុំមិនមានមាតា បិតា ឬបងប្អូនប្រុសស្រី ព្រះអង្គស្តេចទៅទីណា ៗ មេត្តានាំនាងខ្ញុំទៅក្នុងទីនោះ ៗ ផង មហារាជ ។ ស្តេចសក្កៈប្រទានព្រះបដិញ្ញាណយល់ព្រម ។ ព្រះមានព្រះភាគ កាលទ្រង់ឃើញសេចក្តីដែលស្តេចសក្កៈនោះ ជាអ្នកបរិសុទ្ធិតាំងពីកាលនៅជាមាយមាណព ក្នុងពួកស្រុកមចលៈ ដូចដែលពោលមកនេះ ទើបត្រាស់ថា យក្ខនេះ ជាអ្នកបរិសុទ្ធអស់កាលយូរហើយ ។ ពាក្យថា **ប្រកបដោយប្រយោជន៍** គឺ អាស្រ័យហេតុ អាស្រ័យផល ។

" ចប់ បឋមភាណវារៈ "

[៩៣] បទថា **មានអ្វីជាគ្រឿងប្រកបទុក** គឺ មានអ្វីជាគ្រឿងចង បានដល់ ជាអ្នកត្រូវគ្រឿងចង អ្វីចងយកទុក ។ បទថា **កាយក្រាស់** គឺ ពួកជនច្រើន ។ បទថា **មិនមានពៀរ** គឺ មិនមានការប៉ះទង្គិច ។ បទថា **មិនមានអាជ្ញា** គឺ ផុតពីអាជ្ញា គឺ អាវុធ និងអាជ្ញា គឺ ធ្នូ ។ បទថា **មិនមានសត្រូវ** គឺ មិនមានសត្រូវ ។ បទថា **មិនមានការព្យាបាទ** បានដល់ ប្រាសចាកទោមនស្ស ។ បទថា **គប្បីជាអ្នកមិនមានពៀរ** គឺ រមែងឲ្យទាន រមែងធ្វើការបូជាហើយប្រាថ្នាថា ឱហ្ន៎ សូមឲ្យពួកយើងជាអ្នកមិនមានពៀរ នឹងអ្នកណា ៗ ចុះ សូមឲ្យពួកយើងមិនបង្ករការកម្រើកឲ្យកើតក្នុងអ្នកណាៗ ហើយប្រើប្រាស់របស់ដែលកាន់យកដោយម្រាមដៃ ព្រមនឹងមនុស្ស ១.០០០ នាក់ចុះ ។ បទថា **នឹងរមែងមានដល់ពួកគេ ដោយប្រការដូច្នេះ** គឺ ក៏សេចក្តីប្រាថ្នានេះ រមែងមានដល់ពួកគេ ដោយប្រការដូច្នេះ ។ បទថា **កាលបើដូច្នេះ** គឺ កាលសេចក្តីប្រាថ្នាដូច្នោះមាន ។ បទថា **ឥស្សា និងមច្ឆរិយ ជាគ្រឿងប្រកបទុក** គឺ សេចក្តីច្រណែន មានការអស់ទៅនៃសម្បត្តិរបស់ជនដទៃ ជាលក្ខណៈ , និងសេចក្តីកំណាញ់ មានការទ្រាំមិនបានចំពោះសម្បត្តិរបស់ខ្លួនទៅជារបស់សាធារណៈ នឹងពួកអ្នកដទៃ ជាលក្ខណៈ ។ ឈ្មោះថា អ្នកមានសេចក្តីច្រណែន និងសេចក្តីកំណាញ់ ជាគ្រឿងចង

រូបរឹត ព្រោះសេចក្តីប្រណែន និងសេចក្តីកំណាញ់ ជាគ្រឿងចងរូបរឹតរបស់ពួកគេ ។ នេះជាសេចក្តីសង្ខេបក្នុងទីនេះ ។ ចំណែកសេចក្តីប្រណែន និងសេចក្តីកំណាញ់យ៉ាងពិស្តារ បានពោលទុករួចហើយក្នុងអភិធម្ម ។

ចំណែកក្នុងរឿងសេចក្តីកំណាញ់នេះ ព្រោះសេចក្តីកំណាញ់ដែលមានសត្វមិនថា ជាយក្ខ ឬជាប្រេត ម្នាក់ៗ ក៏ដើរទូលសម្រាម របស់ដែលមាននោះឯង ។ ព្រោះសេចក្តីកំណាញ់ត្រកូល កាលបុគ្គលឃើញអ្នកដែលកំពុងធ្វើទានជាដើមដល់អ្នកដទៃ ក្នុងត្រកូលនោះ ក៏គិតថា ត្រកូលរបស់យើងនេះបែកហើយហ្ន៎ នឹងដល់ការក្អួតឈាមខ្លះ ធ្លាយពោះខ្លះ ពោះវៀនដាច់ជាកំណាត់តូចធំធ្លាក់ចេញមកខ្លះ ។ ព្រោះសេចក្តីកំណាញ់លាភ អ្នកមានសេចក្តីកំណាញ់ក្នុងលាភរបស់សង្ឃ ឬរបស់គណៈ បរិភោគ ដូចបរិភោគចំណែករបស់បុគ្គលកើតជាយក្ខខ្លះ ប្រេតខ្លះ ពោះថ្លាន់ធំខ្លះ ។ ក៏ព្រោះសេចក្តីកំណាញ់វណ្ណនៃសរីរៈ និងវណ្ណនៃគុណ និងព្រោះសេចក្តីកំណាញ់ការសិក្សារៀនសូត្រ បុគ្គលនឹងពោលសរសើរតែគុណរបស់ខ្លួនឯងប៉ុណ្ណោះ មិនពោលសរសើរគុណរបស់បុគ្គលពួកដទៃទេ ពោលតែទោសនោះៗ ថា បុគ្គលនេះ មានស្អីល្អ និងមិនឲ្យការសិក្សារៀនសូត្រអ្វី ៗ ដល់អ្នកណា ៗ និយាយតែទោសថា អ្នកនេះអាក្រក់ និងគ្លួត ក្លីភ្លើ ។

ម្យ៉ាងទៀត ដោយសេចក្ដីកំណាញ់ដែលមាន គេរមែងចេះក្នុងខ្វះលោហៈ ។ ដោយសេចក្ដីកំណាញ់ត្រកូល គេរមែងជាអ្នកមានលាភតិច ។ ដោយសេចក្ដីកំណាញ់លាភ គេរមែងកើតក្នុងគូថនរក ។ ដោយសេចក្ដីកំណាញ់វណ្ណៈ កាលកើតក្នុងភព នឹងមិនមានវណ្ណៈ ។ ដោយសេចក្ដីកំណាញ់ធម៌ គេរមែងកើតក្នុងនរកផេះក្ដៅ ។

ក៏ឯសេចក្ដីប្រណែន និងសេចក្ដីកំណាញ់ដែលជាគ្រឿងប្រកប (សត្វទុកក្នុងភព) នេះ នឹងលះបានដោយសោតាបត្តិមគ្គ ។ រហូតដល់អស់វេលាដែលនៅលះវាមិនបាន ទេវតា និងមនុស្ស សូម្បីប្រាថ្នាភាពជាអ្នកមិនមានពៀរជាដើមក៏ដោយ ក៏មិនអាចរួចផុតចាកពៀរជាដើមឡើយ ។

បទថា **ខ្ញុំព្រះអង្គ ឆ្លងសេចក្ដីសង្ស័យក្នុងបញ្ហានេះ** សេចក្ដីថា ស្ដេចសក្កៈត្រាស់ថា ក្នុងបញ្ហានេះ ព្រោះស្ដាប់ព្រះតម្រាស់របស់ព្រះអង្គ ខ្ញុំព្រះអង្គទើបឆ្លងសេចក្ដីសង្ស័យបាន ។ ស្ដេចសក្កៈ ទ្រង់មិនបានសម្ដែងសេចក្ដីសង្ស័យ ដែលទ្រង់ឆ្លងបានដោយអំណាចមគ្គ ។ ពាក្យថា **សេចក្ដីសង្ស័យ ដែលត្រូវសួរថា យ៉ាងណាៗ ប្រាសទៅហើយ** គឺ សេចក្ដីសង្ស័យសូម្បីយ៉ាងនេះថា នេះយ៉ាងណា នេះយ៉ាងណា ប្រាសចាកទៅហើយ ។

## ប្រស្នាព្រះឥន្ទ្រ ព្រះមានព្រះភាគទ្រង់ព្យាករ

[៩៤] ពាក្យមាន និទានំ ជាដើម មានសេចក្ដីដូចបានពោលទុកស្រេចហើយ ។ បទថា *ដែលពេញចិត្ត និងទាស់ចិត្ត* គឺ សេចក្ដីកំណាញ់មានសត្វ និងសង្ខារដែលជាទីស្រឡាញ់ជាដើមហេតុ ឥស្សាមានសត្វ និងសង្ខារដែលមិនជាទីស្រឡាញ់ជាដើមហេតុ ឬទាំងពីរ ក៏មានទាំងពីរជាដើមហេតុ ។ ក៏ចំពោះអ្នកបួស មិនជាកូនសិស្សជាដើម ចំណែកអ្នកស្រុកជាដើម ឬសត្វ មានដំរី សេះជាដើម រមែងជាទីស្រឡាញ់ ជាទីប្រលែងលេង ជាទីប្រកាន់ថា របស់យើង ។ កាលមិនឃើញពួកទាំងនោះ សូម្បីត្រឹមតែមួយក្ដែត ក៏ទ្រាំមិនបាន ។ កាលគេបានឃើញអ្នកដទៃ អ្នកបានសត្វដែលគួរស្រឡាញ់យ៉ាងនោះ ក៏កើតឥស្សា ត្រូវអ្នកដទៃសូមសត្វនោះឯងថា ពួកយើងមានការងារខ្លះ ដោយសត្វនេះ មេត្តាឲ្យខ្ចីត្រឹមតែមួយពេលចុះ ក៏ឲ្យមិនបាន ពោលថា គេនឹងនឿយហត់ ឬគេនឹងកើតទុក្ខ ហើយក៏កើតសេចក្ដីកំណាញ់ ។ ដោយប្រការដូច្នេះ ក៏ពោលបានថា សេចក្ដីឫស្សា និងសេចក្ដីកំណាញ់ សូម្បីទាំងពីរ មានសត្វដែលជាទីស្រឡាញ់ជាមូល ។ ឯចំពោះភិក្ខុ មានបរិក្ខារ បាត្រ និងចីវរជាដើម មានសត្វដែលជាទីស្រឡាញ់ ជាដើមហេតុ ។ ឯចំពោះភិក្ខុ មានបរិក្ខារ មានបាត្រ និង

ចីវរជាដើម ឬចំពោះអ្នកស្រុក ឧបករណ៍ មានគ្រឿងប្រដាប់ជាដើម រមែង ជាទីស្រឡាញ់ ជាទីរីករាយ ។ កាលគេឃើញវត្ថុប្រភេទនោះ កំពុងកើត ដល់អ្នកដទៃ ក៏កើតសេចក្ដីឫស្យាថា ឱហ្ន៎ សូមវត្ថុបែបនេះ កុំគប្បីមាន ដល់អ្នកនោះ និងសូម្បីត្រូវសូម ក៏កើតសេចក្ដីកំណាញ់ថា សូម្បីពួកយើង កំពុងស្រឡាញ់ នៅប្រើប្រាស់វត្ថុនេះ ឲ្យមិនបានទេ ។ ដោយប្រការដូច្នេះ ក៏ពោលបានថា សូម្បីសេចក្ដីឫស្យា និងសេចក្ដីកំណាញ់ទាំងពីរ រមែង មានសង្ខារដែលជាទីស្រឡាញ់ ជាមូល ។ តែកាលបានសត្វ និងសង្ខារ ដូចប្រការដែលពោលមកហើយនោះ តែជាប្រភេទដែលមិនគួរស្រឡាញ់ សូម្បីថា សត្វ និងសង្ខារទាំងនោះ មិនជាទីរីករាយ សូម្បីយ៉ាងនោះក៏ ដោយ ដើម្បីឲ្យពួកកិលេសដែលផ្ទុយគ្នាប្រព្រឹត្តទៅបាន ក៏ធ្វើសេចក្ដី ឫស្យាថា វៀរខ្ញុំចេញហើយ អ្នកដទៃណា ជាអ្នកបានសត្វ និងសង្ខារបែប នេះ ឬត្រូវសូមខ្ញុំក៏មិនឲ្យ រមែងធ្វើសេចក្ដីហួងហែង ។ ដោយប្រការ ដូច្នេះ ក៏ជាការពោលថា សេចក្ដីប្រណែន និងសេចក្ដីកំណាញ់ សូម្បីទាំង ពីរ រមែងមានសត្វ និងសង្ខារ ដែលមិនជាទីស្រឡាញ់ ជាមូល ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **មានសេចក្ដីពេញចិត្តជាមូល** នេះ ។ សេចក្ដីពេញចិត្ត មាន ៥ យ៉ាង គឺ ៖ សេចក្ដីពេញចិត្តក្នុងការស្វែងរក ,

សេចក្តីពេញចិត្តក្នុងការបានចំពោះ , សេចក្តីពេញចិត្តក្នុងការប្រើប្រាស់ , សេចក្តីពេញចិត្តក្នុងការសន្សំ , សេចក្តីពេញចិត្តក្នុងការលះបង់ ។

**សេចក្តីពេញចិត្តក្នុងការស្វែងរក** ដូចម្តេច ? គឺ បុគ្គលខ្លះក្នុងលោកនេះ កើតសេចក្តីពេញចិត្តមិនឆ្អែត រមែងស្វែងរករូប សំឡេង ក្លិន រស រមែងស្វែងរកវត្ថុដែលគប្បីពាល់ត្រូវ រមែងស្វែងរកទ្រព្យ នេះសេចក្តីពេញចិត្តក្នុងការស្វែងរក ។

**សេចក្តីពេញចិត្តក្នុងការបានចំពោះ** ដូចម្តេច ? គឺ បុគ្គលខ្លះក្នុងលោកនេះ កើតសេចក្តីពេញចិត្តមិនឆ្អែត រមែងបានចំពោះរូប សំឡេង ក្លិន រស រមែងបានចំពោះវត្ថុដែលគប្បីពាល់ត្រូវ រមែងបានចំពោះនូវទ្រព្យ នេះសេចក្តីពេញចិត្តក្នុងការបានចំពោះ ។

**សេចក្តីពេញចិត្តក្នុងការប្រើប្រាស់** ដូចម្តេច ? គឺ បុគ្គលខ្លះក្នុងលោកនេះ កើតសេចក្តីពេញចិត្តមិនឆ្អែត រមែងប្រើប្រាស រូប សំឡេង ក្លិន រស រមែងប្រើប្រាស់វត្ថុដែលគប្បីពាល់ត្រូវ រមែងប្រើប្រាស់ទ្រព្យ នេះសេចក្តីពេញចិត្តក្នុងការប្រើប្រាស់ ។

**សេចក្តីពេញចិត្តក្នុងការសន្សំ** ដូចម្តេច ? គឺ បុគ្គលខ្លះក្នុងលោកនេះ កើតសេចក្តីពេញចិត្តមិនឆ្អែត រមែងធ្វើការសន្សំទ្រព្យដោយគិតថា

នឹងមានក្នុងគ្រាវិបត្តិ នេះសេចក្តីពេញចិត្តក្នុងការសេទរំ ។

**សេចក្តីពេញចិត្តក្នុងការលះបង់** ដូចម្តេច ? គឺ បុគ្គលខ្លះក្នុងលោកនេះ កើតសេចក្តីពេញចិត្តមិនឆ្អែត រមែងចាយវាយទ្រព្យដល់ពលដំរី ពលសេះ ពលរថ ខ្មាន់ធ្នូ ដោយគិតថា អ្នកទាំងនេះ នឹងរក្សា នឹងឃុំគ្រង នឹងស្រឡាញ់ នឹងហែហមយើង នេះសេចក្តីពេញចិត្តក្នុងការលះបង់ ។

សេចក្តីពេញចិត្តសូម្បីទាំង ៥ យ៉ាងនេះ ក្នុងទីនេះមានត្រឹមតែតណ្ហាប៉ុណ្ណោះឯង ។ ព្រះមានព្រះភាគ ទ្រង់សំដៅយកសេចក្តីពេញចិត្តនោះ ទើបបានត្រាស់ពាក្យនេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **មានសេចក្តីត្រិះរិះជាមូល** នេះ ។ សេចក្តីត្រិះរិះដែលកើតពីការវិនិច្ឆ័យ ដែលត្រាស់ទុកយ៉ាងនេះថា **អាស្រ័យលាភ ការវិនិច្ឆ័យកើតមាន** ឈ្មោះថា សេចក្តីត្រិះរិះ ។ ពាក្យថា **ការវិនិច្ឆ័យ** គឺ ការវិនិច្ឆ័យ មានពីរយ៉ាង គឺ ការវិនិច្ឆ័យ គឺ តណ្ហា និងការវិនិច្ឆ័យ គឺ ទិដ្ឋិ ។ តណ្ហាវិចរិត ១០៨ ប្រភេទ ឈ្មោះថា ការវិនិច្ឆ័យ គឺ តណ្ហា , ការឃើញ ៦២ យ៉ាង ឈ្មោះថា ការវិនិច្ឆ័យ គឺ ទិដ្ឋិ ក៏ដោយប្រការដូច្នេះ ទើបមិនមានការចង្អុលបង្ហាញទៅថា គួរប្រាថ្នា មិនគួរប្រាថ្នា និងគួរស្រឡាញ់ មិនគួរស្រឡាញ់ ដោយអំណាចការវិនិច្ឆ័យ គឺ តណ្ហា ដែលពោលមក

ហើយយ៉ាងនោះ ។ ព្រោះវត្ថុនោះឯង ជារបស់គួរប្រាថ្នាសម្រាប់បុគ្គលខ្លះ មិនគួរប្រាថ្នាសម្រាប់បុគ្គលខ្លះ ដូចការចង្អុលបង្ហាញក្នុងជនទ្វេន ម្រឹគ និងសាច់ជាដើម របស់ព្រះរាជាក្នុងចំណែកភូមិភាគ និងព្រះរាជាក្នុងប្រទេសដែលជាកណ្តាល ក៏កាលវត្ថុដែលបានទទួលមកនោះ ត្រូវបង្ហាញដោយវិនិច្ឆ័យ គឺ តណ្ហា ទើបនឹងមានការចង្អុលឲ្យច្បាស់ ដោយការវិនិច្ឆ័យ គឺ សេចក្តីត្រិះរិះថា ជារបស់រូបប៉ុណ្ណេះ ប៉ុណ្ណេះជារបស់សំឡេង ជារបស់ក្លិនប៉ុណ្ណេះ ប៉ុណ្ណេះជារបស់រស ជាវត្ថុដែលគប្បីពាល់ត្រូវប៉ុណ្ណេះ ប៉ុណ្ណេះជារបស់យើង ជារបស់គេប៉ុណ្ណេះ ប៉ុណ្ណេះនឹងរក្សាទុក នឹងឲ្យប៉ុណ្ណេះ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា **ស្តេចទេវតា** សេចក្តីពេញចិត្តនេះឯង មានសេចក្តីត្រិះរិះជាដើមហេតុ ដូច្នេះ ។

ពាក្យថា **ចំណែការសម្គាល់ដែលប្រកបដោយធម៌ជាគ្រឿងយឺតយូរជាមូល** គឺ ធម៌ជាគ្រឿងយឺតយូរមាន ៣ យ៉ាង គឺ ធម៌ជាគ្រឿងយឺតយូរ គឺ តណ្ហា , ធម៌ជាគ្រឿងយឺតយូរ គឺ មានះ , ធម៌ជាគ្រឿងយឺតយូរ គឺ ទិដ្ឋិ ។ ក្នុង ៣ យ៉ាងនោះ តណ្ហាវិចរិត ១០៨ យ៉ាង ឈ្មោះថា ធម៌ជាគ្រឿងយឺតយូរ គឺ តណ្ហា , មានះ ៩ យ៉ាង ឈ្មោះថា ធម៌ជាគ្រឿងយឺតយូរ គឺ មានះ , ទិដ្ឋិ ៦២ ប្រភេទ ឈ្មោះថា ធម៌ជាគ្រឿងយឺតយូរ

គឺ ទិដ្ឋិ ។ ក្នុងធម៌ជាគ្រឿងយឺតយូរទាំងនោះ ក្នុងទីនេះ លោកសំដៅយក ធម៌ជាគ្រឿងយឺតយូរ គឺ តណ្ហា ។ ដែលហៅថា ធម៌ជាគ្រឿងយឺតយូរ ព្រោះអត្ថថា យ៉ាងណា ។ ដែលហៅថា ធម៌ជាគ្រឿងយឺតយូរ ព្រោះអត្ថថា ឲ្យដល់អាការរបស់អ្នកស្រវឹង ប្រមាទ ។ ការសម្គាល់ ដែលប្រកបដោយ ធម៌ជាគ្រឿងយឺតយូរនោះ ឈ្មោះថា **បបញ្ចសញ្ញា** (ការសម្គាល់ដែល លាយឡំទៅដោយធម៌ជាគ្រឿងយឺតយូរ) ។ ចំណែកហៅថា **សង្ខា** ដូច ក្នុងពាក្យជាដើមថា ក៏ចំណែកនៃធម៌ជាគ្រឿងយឺតយូរ មានការសម្គាល់ ជាដើមហេតុ ។ ដោយប្រការដូច្នេះ ពាក្យថា មានសេចក្តីសម្គាល់ ដែល ប្រកបដោយធម៌ជាគ្រឿងយឺតយូរជាមូល ទើបសំដៅសេចក្តីថា សេចក្តី ត្រិះរិះមានចំណែកនៃសេចក្តីសម្គាល់ ដែលប្រកបដោយធម៌ជាគ្រឿងយឺត យូរជាមូល ។

[៩៥] ពាក្យថា **ប្រការបដិបត្តិឲ្យចូលដល់សេចក្តីសមគួរដល់ការ រលត់ ដោយមិនមានសល់នៃចំណែកការសម្គាល់ ដែលប្រកបដោយធម៌ ជាគ្រឿងយឺតយូរ** សេចក្តីថា សេចក្តីរលត់ដោយមិនមានសល់ បានដល់ សេចក្តីស្ងប់រម្ងាប់ យ៉ាងណា នៃចំណែកសេចក្តីសម្គាល់ ដែលប្រកបទៅ ដោយគ្រឿងយឺតយូរនេះ ស្តេចសក្កៈ រមែងទូលសួរផ្លូវ ព្រមទាំងវិបស្សនា

គឺ ភាពសមរម្យនៃការរលត់ដោយមិនមានសល់នោះ និងប្រការបដិបត្តិឲ្យដល់ក្នុងការរលត់ ដោយមិនមានសល់នោះ ។

លំដាប់នោះ ព្រះមានព្រះភាគទ្រង់ផ្ដើមវេទនា ៣ យ៉ាង ដល់ស្ដេចសក្កៈនោះថា **តថាគតសោមនស្សំ** ។ សួរថា ក៏ព្រះមានព្រះភាគត្រាស់តែប្រការដែលទូលសួរ ប្រការមិនទូលសួរ ប្រការដែលមានការបន្តប្រការដែលមិនមានការបន្តឬ ។ ឆ្លើយថា ត្រាស់តែប្រការដែលទូលសួរប៉ុណ្ណោះ មិនមែនប្រការដែលមិនទូលសួរ ត្រាស់ប្រការដែលមានសេចក្ដីតជាប់គ្នា ប៉ុណ្ណោះ មិនមែនប្រការដែលមិនមានសេចក្ដីបន្ត ។ ពិតណាស់ចំពោះ ទេវតាទាំងឡាយ អរូបប្រាកដថា ដោយភាពជារូប សូម្បីក្នុងអរូប-វេទនា ក៏ប្រាកដ ។ ព្រោះហេតុណា ។ ព្រោះកាយដែលកើតពីធូលីក្នុងទឹក (ករជកាយ ) របស់ពួកទេវតា ជារបស់ល្អិត , រូបដែលកើតពីកម្មជារបស់មានកម្លាំង ព្រោះកាយដែលកើតពីធូលីក្នុងទឹក ជារបស់ល្អិត (និង) ព្រោះរូបដែលកើតពីកម្មជារបស់មានកម្លាំង បើឃានកន្ទងអាហារ សូម្បីតែមួយពេល ពួកទេវតាក៏តាំងនៅមិនបាន រមែងវិនាសទៅ ដូចដុំទឹកដោះថ្លា ដាក់លើថ្មាំងថ្មដែលក្ដៅ ។ គប្បីជ្រាបពាក្យទាំងអស់ តាមន័យដែលពោលហើយ ក្នុងព្រហ្មជាលសូត្រនោះឯង ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ

ទើបទ្រង់ផ្ដើមវេទនាទាំង ៣ យ៉ាង ដល់ស្ដេចសក្កៈ ។

ក៏ឯកម្មដ្ឋានមាន ២ យ៉ាង គឺ រូបកម្មដ្ឋាន និងអរូបកម្មដ្ឋាន ។ នឹងហៅកម្មដ្ឋាននោះឯងថា ការកំណត់រូប និងការកំណត់អរូបក៏បាន ។ ក្នុងកម្មដ្ឋាន ២ យ៉ាងនោះ រូបប្រាកដដល់បុគ្គលណា ព្រះមានព្រះភាគ កាលទ្រង់នឹងធ្វើការកំណត់ធាតុ ៤ ឲ្យពិស្ដារដល់អ្នកនោះ ដោយអំណាចធ្វើទុកក្នុងចិត្តដោយសង្ខេប ឬដោយអំណាចធ្វើទុកក្នុងចិត្តដោយពិស្ដារ ក៏ត្រាស់រូបកម្មដ្ឋាន , អរូបប្រាកដដល់បុគ្គលណា ក៏ត្រាស់អរូបកម្មដ្ឋានដល់អ្នកនោះ ។ កាលនឹងត្រាស់អរូប ក៏ទ្រង់សម្ដែងរូបកម្មដ្ឋាន ដែលជាទីតាំងរបស់អរូបនោះ ទើបត្រាស់ ។ តែសម្រាប់ពួកទេវតា ទ្រង់ជ្រាបថា អរូបប្រាកដ ទើបទ្រង់ផ្ដើមទេសនាដោយអំណាចអរូបកម្មដ្ឋាន ។

ក៏សេចក្ដីតាំងមាំក្នុងអរូបកម្មដ្ឋានមាន ៣ យ៉ាង គឺ ដោយអំណាចផស្សៈ ដោយអំណាចវេទនា ដោយអំណាចចិត្ត ។ យ៉ាងណា គឺ ចំពោះបុគ្គលខ្លះ កាលទទួលយករូបកម្មដ្ឋានដោយសង្ខេប ឬដោយពិស្ដារ ក៏ដោយ រមែងមានការធ្លាក់ទៅយ៉ាងក្រៃលែង ក្នុងគ្រាដំបូងរបស់ចិត្ត និងចេតសិកទាំងឡាយក្នុងអារម្មណ៍នោះ ផស្សៈកើតពាល់ត្រូវអារម្មណ៍នោះ រមែងជារបស់ប្រាកដ ។ ចំពោះបុគ្គលខ្លះ វេទនាកើត សោយអារម្មណ៍

នោះ រមែងជារបស់ប្រាកដ ៗ ចំពោះបុគ្គលខ្លះ វិញ្ញាណដែលកើតឡើង ដឹងច្បាស់អារម្មណ៍នោះ រមែងជារបស់ប្រាកដ ៗ

ក្នុងការតាំងមាំទាំង ៣ យ៉ាងនោះ បុគ្គលណាមានផស្សៈប្រាកដច្បាស់ សូម្បីបុគ្គលនោះ មិនមែនកើតឡើងតែផស្សៈតែម្យ៉ាងប៉ុណ្ណោះ ព្រមនឹងផស្សៈនោះ សូម្បីវេទនាដែលសោយអារម្មណ៍នោះឯង ក៏រមែងកើតឡើងផង សូម្បីសញ្ញាដែលចាំអារម្មណ៍នោះ សូម្បីចេតនាដែលគិតអារម្មណ៍នោះ សូម្បីវិញ្ញាណដែលដឹងច្បាស់អារម្មណ៍នោះ ក៏រមែងកើតឡើងផង ទើបឈ្មោះថា រមែងប្រមូលកាន់យកពួកចេតសិកធម៌ ដែលមានផស្សៈជាទី ៥ ដោយប្រការដូច្នេះ ។ បុគ្គលណា មានវេទនាប្រាកដច្បាស់ សូម្បីបុគ្គលនោះ ក៏រមែងឈ្មោះថា ប្រមូលកាន់យកពួកចេតសិកធម៌ ដែលមានផស្សៈជាទី ៥ ដូចគ្នា ព្រោះមិនមែនតែវេទនាតែម្យ៉ាងប៉ុណ្ណោះ រមែងកើតឡើងព្រមនឹងវេទនានោះ នៅមានផស្សៈកើតឡើងប៉ះខ្ទប់អារម្មណ៍នោះឯង នៅមានសញ្ញាដែលចាំអារម្មណ៍ ញុំាងចេតនាដែលគិតអារម្មណ៍ ញុំាងវិញ្ញាណដែលដឹងច្បាស់អារម្មណ៍នោះ កើតឡើងផង ។ ចំពោះបុគ្គលដែលមានវិញ្ញាណប្រាកដច្បាស់ ក៏រមែងឈ្មោះថា ប្រមូលកាន់យកពួកចេតសិកធម៌ ដែលមានផស្សៈជាទី ៥ ដូចគ្នាទុំះឯង ព្រោះមិនមែន

កើតឡើងចំពោះវិញ្ញាណតែម្យ៉ាងប៉ុណ្ណោះ ព្រមទាំងវិញ្ញាណនោះ ក៏នៅមានផស្សៈដែលកើតឡើង ប៉ះខ្ទប់អារម្មណ៍នោះឯង នៅមានវេទនាដែលតាមសោយអារម្មណ៍ នៅមានសញ្ញាដែលចាំអារម្មណ៍ នៅមានមនោសញ្ចេតនាដែលគិតអារម្មណ៍ កើតឡើងផង ។

កាលគេពិចារណាថា ធម៌ពួកដែលមានផស្សៈជាគម្រប់ ៥ ទាំងនេះអាស្រ័យអ្វី ក៏រមែងដឹងច្បាស់ថា អាស្រ័យទីតាំង ។ ឈ្មោះថា ទីតាំងក៏គឺ រាងកាយ ( ដែលកើតពីធូលីក្នុងទឹក ) ដែលលោកសំដៅយកថា ក៏ឯវិញ្ញាណរបស់យើងនេះ អាស្រ័យនៅក្នុងរាងកាយនេះ ជាប់ទាក់ទងក្នុងរាងកាយនេះ ។ ដោយសេចក្តី គឺ គេរមែងដឹងច្បាស់ទាំងភូតរូប និងឧបាទារូប ។ កាលដឹងច្បាស់ថា ទីតាំងក្នុងរាងកាយនេះ ជារូប ពួកដែលមានផស្សៈជាគម្រប់ ៥ ជានាម យ៉ាងនេះក៏ឈ្មោះថា រមែងឃើញត្រឹមតែជានាមរូបប៉ុណ្ណោះ ។ និងនាមរូបក៏ត្រឹមតែខន្ធ ៥ គឺ រូបក្នុងទីនេះ ជារូបខន្ធ និងនាម ក៏ជាខន្ធដែលមិនមែនរូបទាំង ៤ ។ ក៏ខន្ធ ៥ ដែលផ្សេងអំពីនាមរូប ឬនាមរូបដែលផ្សេងអំពីខន្ធ ៥ មិនមានទេ ។ កាលគេត្រិះរិះថា ខន្ធ ៥ ទាំងនេះ មានអ្វីជាហេតុ ក៏រមែងឃើញថា មានអវិជ្ជាជាដើមជាហេតុ តពីនោះកាលត្រិះរិះដល់បច្ច័យ និងវត្ថុ ដែលកើតព្រោះបច្ច័យ

ក៏ដឹងថា ក្រៅពីបច្ច័យ និងវត្ថុដែលកើតពីបច្ច័យនោះហើយ មិនមានសត្វ ឬបុគ្គលដទៃ មានតែគំនរសង្ខារសុទ្ធ ៗ ប៉ុណ្ណោះឯង ហើយក៏លើកឡើងកាន់ត្រៃលក្ខណ៍ ដោយអំណាចនាមរូបព្រមនឹងបច្ច័យ នឹងពិចារណាថា មិនទៀង ទ្រាំមិនបាន មិនមានអ្វីជាតួខ្លួន តាមលំដាប់នៃវិបស្សនា ។ គេប្រាថ្នាការចាក់ធ្លុះរហូតថា ថ្ងៃនេះ ថ្ងៃនេះ ក្នុងថ្ងៃបែបនោះ កាលបានរដូវជាទីសប្បាយ បុគ្គលជាទីសប្បាយ អាហារជាទីសប្បាយ ឬការស្តាប់ធម៌ជាទីសប្បាយហើយ ក៏អង្គុយដោយបល្ល័ង្កតែមួយប៉ុណ្ណោះ ញុាំងវិបស្សនាឲ្យដល់កំពូល ក៏រមែងតាំងនៅក្នុងអរហត្តផល ។ គោបកទេវបុត្រ ប្រាប់កម្មដ្ឋានដរាបដល់អរហត្ត ដល់ លោកទាំងបីនេះ យ៉ាងនេះឯង ។

តែក្នុងទីនេះ កាលព្រះមានព្រះភាគ ទ្រង់នឹងសម្តែងអរូបកម្មដ្ឋាន ក៏ទ្រង់សម្តែងដោយវេទនាជាប្រធាន ។ កាលព្រះអង្គនឹងសម្តែងដោយអំណាចផស្សៈ ឬដោយអំណាចវិញ្ញាណ នឹងមិនមានភាពជាក់ច្បាស់ដល់ស្តេចសក្កៈនេះ តែនឹងប្រាកដដូចសេចក្តីងងឹត ។ តែដោយអំណាចវេទនាទើបនឹងជាក់ច្បាស់ ។ ព្រោះហេតុណា ។ ព្រោះការកើតវេទនាឡើង ជារបស់ជាក់ច្បាស់ ។ ពិតណាស់ ការកើតសេចក្តីសុខ និងទុក្ខវេទនាឡើង ជាវត្ថុប្រាកដច្បាស់ ។ កាលសេចក្តីសុខកើតឡើង ទូទៅទាំងរាងកាយ

ក៏កើតចុះឡើង គ្របសង្កត់ ជ្រួតជ្រាប ផ្សព្វផ្សាយ ដូចឲ្យផឹកទឹកដោះថ្លា ដែលជម្រះរយជន ដូចកំពុងលាបប្រេងដែលចម្រាញ់រយជន ដូចកំពុងយកទឹកពាន់ផ្ទាំងមករំលត់សេចក្ដីក្ដៅផ្សា បន្លឺវាចាថា សុខហ្ន៎ សុខហ្ន៎ ទុំះឯង ។ កាលកើតសេចក្ដីទុក្ខឡើង ទូទាំងរាងកាយ ក៏កើតចុះឡើង គ្របសង្កត់ ស្រោចស្រប់ ផ្សព្វផ្សាយ ដូចចូលកាន់អំបែងក្ដៅ ដូចយកទឹកទង់ដែងរាវមកស្រោច ដូចប៉ះទង្គិចគប់ភ្លើងក្នុងព្រៃ ដែលមានស្មៅនិងឈើធំ ៗ ដែលស្ងួត ទួញយំថា ទុក្ខហ្ន៎ ទុក្ខហ្ន៎ ទុំះឯង ។ សុខនិងទុក្ខវេទនា កើតឡើងប្រាកដដូចពោលមកនេះ ។ ចំណែកអទុក្ខមសុខ-វេទនា ប្រាកដលំបាក ដូចត្រូវសេចក្ដីងងឹតគ្របសង្កត់ ។ អទុក្ខមសុខ-វេទនានោះ ព្រោះវៀរសុខ និងទុក្ខទៅ ទើបមានអាការជាកណ្ដាល ដោយអំណាចជាបដិបក្ខចំពោះសុខ និងទុក្ខ ដូច្នេះ កាលកាន់យកដោយន័យទើបនឹងជាក់ច្បាស់ ។ ដូចអ្វី ព្រានម្រឹគ ដើរទៅតាមស្នាមជើងម្រឹគដែលឡើងជាន់ផ្ទាំងថ្មក្នុងរវាងផ្លូវ ហើយចៀសទៅ បានឃើញស្នាមជើងដោយចំណែកខ្លះ ចំណែកដទៃខ្លះរបស់ផ្ទាំងថ្ម សូម្បីត្រង់កណ្ដាលមិនឃើញ ក៏រមែងដឹងបាន ដោយន័យថា វាគង់នឹងឡើងផ្លូវនេះ ហើយចុះផ្លូវនេះទៅតាមប្រទេសនេះ ត្រង់កណ្ដាលលើផ្ទាំងថ្មយ៉ាងណា ក៏ការកើតសុខវេទនា

ឡើង រមែងជាវត្ថុជាក់ច្បាស់ ដូចស្នាមជើងត្រង់ទីដែលម្រឹគឡើង ការកើតឡើងនៃទុក្ខវេទនា ក៏ជាវត្ថុជាក់ច្បាស់ ដូចស្នាមជើងត្រង់ទីម្រឹគចុះ កាលកាន់យកដោយន័យថា ព្រោះចៀសវាងអំពីសុខ និងទុក្ខទៅ អទុក្ខមសុខ-វេទនានោះ ទើបមានអាការជាកណ្តាល ដោយអំណាចជាបដិបក្ខចំពោះទាំងសុខ និងទុក្ខ ក៏រមែងជារបស់ជាក់ច្បាស់ ដូចការកាន់យកដោយន័យថា ម្រឹគឡើងត្រង់នេះ ចុះត្រង់នេះ ហើយទៅយ៉ាងនេះ ដូច្នោះ ។

កាលត្រាស់រូបកម្មដ្ឋានទុកមុន យ៉ាងនេះហើយ ព្រះមានព្រះភាគក៏ទ្រង់បែរត្រឡប់សម្តែងអរូបកម្មដ្ឋាន ដោយអំណាចវេទនាក្នុងខាងក្រោយ ។ ក៏មិនមែនទ្រង់សម្តែងយ៉ាងនេះតែម្យ៉ាង ក្នុងទីនេះប៉ុណ្ណោះ តែបើទ្រង់សម្តែងរូបកម្មដ្ឋានមុន ក្នុងព្រះសូត្រមិនមែនតិច យ៉ាងនេះ គឺ ក្នុងមហាសតិប្បដ្ឋានសូត្រ ចូឡតណ្ហាសង្ខយសូត្រ មហាតណ្ហាសង្ខយសូត្រ ចូឡ-វេទល្លសូត្រ មហាវេទល្លសូត្រ រដ្ឋបាលសូត្រ មាគន្ទិយសូត្រ ធាតុវិភង្គសូត្រ អនេញ្ជសប្បាយសូត្រ (និង) ក្នុងវេទនាសំយុត្តទាំងអស់ ហើយទើបទ្រង់ត្រឡប់សម្តែងអរូបកម្មដ្ឋាន ដោយអំណាចវេទនាក្នុងខាងក្រោយ ។ ក្នុងព្រះសូត្រទាំងនោះ យ៉ាងណា សូម្បីក្នុងសក្កបញ្ហសូត្រនេះ ក៏ដូច្នោះ គ្រាដំបូងទ្រង់សម្តែងរូបកម្មដ្ឋាន ហើយខាងក្រោយ ទើបទ្រង់ត្រឡប់សម្តែង

អរូបកម្មដ្ឋាន ដោយអំណាចវេទនា ។ ចំណែកក្នុងសក្កបញ្ហសូត្រនេះ រូបកម្មដ្ឋាន ព្រះមានព្រះភាគ ទ្រង់សង្ខេបត្រឹមតែជាអារម្មណ៍របស់វេទនាប៉ុណ្ណោះ ដូច្នោះក្នុងបាលី ទើបមិនមានលើកឡើងមក ។ ដើម្បីនឹងទ្រង់សម្តែងប្រការដែលជាគោលសម្រាប់តាំងមាំ ដោយអំណាចរបស់វេទនា ដែលជាក់ច្បាស់ដល់ស្តេចសក្កៈនោះឯង ក្នុងអរូបកម្មដ្ឋាន ព្រះមានព្រះភាគ ទើបត្រាស់ពាក្យជាដើមថា **ស្តេចទេវតា អាត្មាភាពពោលសោមនស្ស** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ពីរយ៉ាង** គឺ ពីរប្រភេទ មានសេចក្តីថា ដោយចំណែកពីរ ។ ពាក្យថា **មិនគប្បីសេពសោមនស្សបែបនេះ** គឺ មិនគប្បីសេពសោមនស្សដែលអាស្រ័យផ្ទះបែបនេះ ។ ឈ្មោះថា សោ-មនស្សដែលអាស្រ័យផ្ទះ បានដល់ សោមនស្សដែលអាស្រ័យកាមគុណប្រព្រឹត្តទៅក្នុងទ្វារ ៦ យ៉ាងនេះ គឺ ក្នុងវេទនាទាំងនោះ សោមនស្សដែលអាស្រ័យផ្ទះ មាន ៦ យ៉ាង តើដូចម្តេច ? កាលបុគ្គលពិចារណាឃើញការបានចំពោះនូវរូប ដែលគប្បីដឹងច្បាស់ដោយភ្នែក ដែលជាទីស្រឡាញ់ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ជាតម្រេកនៃចិត្តប្រកបដោយលោកាមិសៈ ដោយការបានចំពោះ ឬកាលតាមឃើញនូវរូបដែលខ្លួនធ្លាប់បានចំពោះក្នុងកាលមុន ដែលកន្លងហើយ ដែលរលត់ហើយ

ដែលប្រែប្រួលហើយ ទើបកើតសោមនស្សឡើង សោមនស្សណា មាន សភាពដូច្នេះ សោមនស្សនេះ តថាគតហៅថា សោមនស្សដែលអាស្រ័យ ផ្ទះ ដូច្នេះជាដើម ។ ពាក្យថា **គប្បីសេពសោមនស្សបែបនេះ** គឺ គប្បី សេពសោមនស្ស ដែលអាស្រ័យការចេញចាកផ្ទះបែបនេះ ។ ឈ្មោះថា សោមនស្សដែលអាស្រ័យការចេញចាកផ្ទះ បានដល់ សោមនស្សដែល កើតឡើងដល់អ្នកកើតសោមនស្សថា យើងបានខ្វល់ខ្វាយក្នុងវិបស្សនា ហើយ អ្នកអាចបង្ខំចិត្តឲ្យខ្វល់ខ្វាយ ផ្ដើមតាំងវិបស្សនា ដោយអំណាច ត្រៃលក្ខណ៍ មានការមិនទៀងជាដើម ក្នុងអារម្មណ៍ដែលគួរស្រឡាញ់ ដែលមកកាន់គន្លងក្នុងទ្វារទាំង ៦ យ៉ាងនេះជាដើមថា ក្នុងវេទនាទាំងនោះ សោមនស្សដែលអាស្រ័យការចេញចាកផ្ទះ មាន ៦ យ៉ាង តើដូចម្ដេច ? កាលបុគ្គលមកដឹងនូវរូបទាំងឡាយ មិនទៀង ប្រែប្រួលទៅ បែកធ្លាយ ទៅ រលត់ទៅ ហើយឃើញរូបនោះដោយបញ្ញាដ៏ប្រពៃ យ៉ាងនេះថា រូបទាំងឡាយក្នុងកាលមុន និងក្នុងកាលឥឡូវនេះ រូបទាំងអស់នោះ មិន ទៀង ទ្រាំនៅមិនបាន មានការប្រែប្រួលជាធម្មតា ទើបក៏កើតសោមនស្ស ឡើង សោមនស្សបែបនេះណា នេះហៅថា សោមនស្សដែលអាស្រ័យការ ចេញចាកផ្ទះ ។ ពាក្យថា **គប្បីសេព** គឺ សោមនស្សដែលកើតឡើង

ដោយអំណាចការចេញចាកផ្ទះ ដោយអំណាចវិបស្សនា ដោយអំណាចការតាមរឭកដល់ ដោយអំណាចឈានទីមួយជាដើម នេះឈ្មោះថា គួរសេព ។

ក្នុងបទទាំងនោះ បទថា **ប្រសិនបើសោមនស្សណា មានសេចក្តីត្រិះរិះ មានសេចក្តីពិចារណា** គឺ ក្នុងសោមនស្ស ដែលអាស្រ័យការចេញចាកផ្ទះសូម្បីនោះ ក៏ត្រូវដឹងថា សោមនស្សដែល កើតឡើងដោយអំណាចការចេញចាកផ្ទះ ដោយអំណាចវិបស្សនា ដោយអំណាចការតាមរឭកដល់ និងដោយអំណាចនៃឈានទីមួយនោះ ជាសោមនស្សដែលនៅមានសេចក្តីត្រិះរិះ មានសេចក្តីពិចារណា។ បទថា **ប្រសិនបើសោមនស្សណា មិនមានការត្រិះរិះ មិនមានការពិចារណា** គឺ ចំណែកសោមនស្សដែលកើតដោយអំណាចឈានទីពីរ និងទីបីនោះ ក៏ត្រូវដឹងថា ជាសោមនស្សដែលមិនមានសេចក្តីត្រិះរិះ មិនមានសេចក្តីពិចារណា ។ ពាក្យថា **ពួកណាមិនមានការត្រិះរិះ មិនមានការពិចារណាប្រណីតជាង** សេចក្តីថា សូម្បីក្នុងសោមនស្សទាំងពីរនេះ សោមនស្សដែលមិនមាន សេចក្តីត្រិះរិះ មិនមានសេចក្តីពិចារណានោះ ប្រណីតជាង ។ ដោយពាក្យនេះ លោកពោលដល់អ្វី ។ ពោលដល់អរហត្តផលរបស់លោកទាំងពីរ ។ យ៉ាងណា ពិត

ណាស់ ភិក្ខុមួយរូប កាលផ្ដើមវិបស្សនាក្នុងសោមនស្សដែលនៅមានសេចក្ដីត្រិះរិះ នៅមានសេចក្ដីពិចារណា ហើយក៏មកពិចារណាថា សោមនស្សនេះអាស្រ័យអ្វី ក៏ជ្រាបច្បាស់ថា អាស្រ័យទីតាំង ហើយក៏តាំងនៅក្នុងអរហត្តផលដោយលំដាប់ តាមន័យដែលពោលហើយក្នុងពួកដែលមានផស្សៈជាទី ៥ នុ៎ះឯង ។ មួយរូប ផ្ដើមវិបស្សនាក្នុងសោមនស្ស ដែលមិនមានសេចក្ដីត្រិះរិះ មិនមានសេចក្ដីពិចារណា ហើយក៏តាំងនៅក្នុងអរហត្តផលតាមន័យដែលពោលហើយដូចគ្នា ។

សូម្បីក្នុងសោមនស្សដែលតាំងមាំទាំងនោះ សោមនស្សដែលមិនមានសេចក្ដីត្រិះរិះ និងមិនមានសេចក្ដីពិចារណា ប្រណីតជាង ដែលនៅមានសេចក្ដីត្រិះរិះ និងនៅមានសេចក្ដីពិចារណា សោមនស្សវិបស្សនាដែលមិនមានសេចក្ដីត្រិះរិះ និងមិនមានសេចក្ដីពិចារណា ប្រណីតជាងសូម្បីសោមនស្សវិបស្សនាដែលមានសេចក្ដីត្រិះរិះ និងមានសេចក្ដីពិចារណា សោមនស្សផលសមាបត្តិ ដែលមិនមានសេចក្ដីត្រិះរិះ និងមិនមានសេចក្ដីពិចារណាប៉ុណ្ណោះ ដែលប្រណីតជាង សោមនស្សផលសមាបត្តិ ដែលនៅមានសេចក្ដីត្រិះរិះ និងនៅមានសេចក្ដីពិចារណា ។ ព្រោះហេតុនោះព្រះមានព្រះភាគ ទើបត្រាស់ថា ពួកសោមនស្សណាមិនមានសេចក្ដីត្រិះរិះ

មិនមានសេចក្តីពិចារណា ប្រណីតជាង ដូច្នេះ ។

ពាក្យថា **មិនគប្បីសេពទោមនស្សបែបនេះ** សេចក្តីថា មិនគប្បីសេពទោមនស្សដែលអាស្រ័យផ្ទះបែបនេះ ។ ដែលឈ្មោះថា ទោមនស្សដែលអាស្រ័យផ្ទះ បានដល់ ទោមនស្សដែលអាស្រ័យកាមគុណដែលកើតដល់អ្នកត្រិះរិះថា យើងមិនតាមសោយហើយ នឹងមិនតាមសោយ រមែងមិនតាមសោយ នូវឥដ្ឋារម្មណ៍ក្នុងទ្វារទាំង ៦ យ៉ាងនេះថា បណ្តាវេទនាទាំងនោះ **ទោមនស្សដែលអាស្រ័យផ្ទះ** ៦ យ៉ាង តើដូចម្តេច ? កាលបុគ្គលពិចារណាឃើញការមិនបានចំពោះនូវរូប ដែលគួរស្រឡាញ់ គួរប្រាថ្នា គួរពេញចិត្ត គួររីករាយ ដែលជាប់ទាក់ទងក្នុងលោក ដែលគប្បីដឹងច្បាស់ដោយភ្នែក ដោយការមិនបានចំពោះ ឬកាលតាមរឭកដល់រូបដែលមិនធ្លាប់បានចំពោះ កាលបើកន្លងទៅហើយ រលត់ទៅហើយ ប្រែប្រួលទៅហើយ ទើបកើតទោមនស្សឡើង ទោមនស្សបែបនេះ នេះហៅថា ទោមនស្សដែលអាស្រ័យផ្ទះ ដូច្នេះជាដើម ។

ពាក្យថា **គប្បីសេពទោមនស្សបែបនេះ** គឺ គប្បីសេពទោមនស្សដែលអាស្រ័យការចេញចាកផ្ទះបែបនេះ ។ ដែលឈ្មោះថា ទោមនស្សដែលអាស្រ័យការចេញចាកផ្ទះ បានដល់ ទោមនស្សដែលកើតដល់អ្នក

ដែលមិនអាចដើម្បីនឹងបង្ខំចិត្តឲ្យខ្វល់ខ្វាយ ចូលទៅតាំងសេចក្តីប្រាថ្នាក្នុងធម៌ គឺ អរិយផល ពោលគឺ សេចក្តីរួចផុតដ៏កំពូល ហើយផ្តើមវិបស្សនាដោយអំណាចត្រៃលក្ខណ៍ មានភាពមិនទៀងជាដើម ដើម្បីសម្រេចអរិយ-ផលនោះ អ្នកតាមទាស់ចិត្តថា យើងមិនអាចនឹងបង្ខំចិត្ត ឲ្យខ្វល់ខ្វាយក្នុងវិបស្សនាមករហូតដល់អស់បក្ខនេះ អស់ខែនេះ អស់ឆ្នាំនេះ ហើយសម្រេចអរិយភូមិបាន ក្នុងអារម្មណ៍ដែលគួរស្រឡាញ់ ដែលមកកាន់គន្លងក្នុងទ្វារទាំង ៦ យ៉ាងនេះថា ក្នុងវេទនាទាំងនោះ ទោមនស្សដែលអាស្រ័យការចេញចាកផ្ទះ តើដូចម្តេច ? ក៏កាលបុគ្គលដឹងច្បាស់នូវរូបទាំងឡាយ មិនទៀង ប្រែប្រួលទៅ បែកធ្លាយទៅ រលត់ទៅ ឃើញរូបនោះដោយបញ្ញាដ៏ប្រពៃតាមសេចក្តីពិតយ៉ាងនេះថា រូបទាំងឡាយ ក្នុងកាលមុន និងក្នុងកាលឥឡូវនេះណា រូបទាំងអស់នោះ មិនទៀង ទ្រាំនៅមិនបាន មានការប្រែប្រួលជាធម្មតា ហើយទើបចូលទៅតាំងសេចក្តីប្រាថ្នា ក្នុងការរួចផុតដ៏កំពូលថា ឈ្មោះថា កាលណាហ្ន៎ យើងនឹងចូលដល់អាយតនៈនោះ ។ កាលចូលទៅតាំងសេចក្តីប្រាថ្នាក្នុងការរួចផុតដ៏កំពូល ដូចដែលពោលមកនេះ ទោមនស្សក៏រមែងកើតឡើង ព្រោះសេចក្តីប្រាថ្នាជាបច្ច័យ ។ ទោម-នស្សបែបនេះ នេះហៅថា ទោមនស្សដែកអាស្រ័យការចេញចាកផ្ទះ ដូច្នេះ

ជាដើម ។ ពាក្យថា **គេហស្សិតេ** គឺ ទោមនស្សដែលកើតឡើងដោយអំណាចការចេញចាកផ្ទះ ដោយអំណាចវិបស្សនា ដោយអំណាចការតាមរឭកដល់ដោយអំណាចឈានទីមួយជាដើមនេះ ឈ្មោះថា ជាទោមនស្សគេហស្សិតេ ។

ក្នុងពាក្យទាំងនោះ ពាក្យថា **បើទោមនស្សណា មានសេចក្តីត្រិះរិះមានសេចក្តីពិចារណា** គឺ ក្នុងទោមនស្សទាំងពីរយ៉ាងសូម្បីនោះ ទោមនស្សដែលអាស្រ័យផ្ទះប៉ុណ្ណោះ ដែលឈ្មោះថា ទោមនស្សដែលមានការត្រិះរិះមានការពិចារណា ។ ចំណែកទោមនស្សដែលកើតឡើង ដោយអំណាចការចេញចាកផ្ទះ ដោយអំណាចវិបស្សនា ដោយអំណាចការតាមរឭកដល់ដោយអំណាចឈានទីមួយ និងឈានទីពីរ គប្បីជ្រាបថា ជាទោមនស្សដែលនៅមានការត្រិះរិះ និងនៅមានការពិចារណា ។ ចំណែកពោលដោយត្រង់ ដែលឈ្មោះថា ទោមនស្សមិនមានការត្រិះរិះ និងមិនមានការពិចារណាមិនមាន ។ សម្រាប់ឥន្ទ្រិយ គឺ ទោមនស្ស ជាអកុសលតែម្យ៉ាងប៉ុណ្ណោះ និងនៅមានការត្រិះរិះ និងនៅមានការពិចារណាផង ។ តែដោយអំណាចសេចក្តីយល់របស់ភិក្ខុនោះ ទើបលោកពោលថា ឥន្ទ្រិយ គឺ ទោមនស្សនៅមានការត្រិះរិះ និងនៅមានការពិចារណា និងថា ដែលមិនមានការត្រិះរិះ និងមិនមានការពិចារណា ដូច្នេះ ។

តទៅនេះ ជាន័យក្នុងរឿងទោមនស្សនោះ គឺ ក្នុងករណីនេះ ភិក្ខុកាន់យកធម៌ដែលនៅមានការត្រិះរិះ និងនៅមានការពិចារណា និងធម៌ដែលមិនមានការត្រិះរិះ និងមិនមានការពិចារណា ជាធម៌ដែលមានទោមនស្សជាបច្ច័យ និងធម៌ គឺ មគ្គ និងផលដែលកើតឡើង មានទោមនស្សជាបច្ច័យនុ៎ះឯង ថាជាទោមនស្ស ព្រោះអំណាចឃើញការបដិបត្តិរបស់ភិក្ខុពួកដទៃ ហើយក៏មកគិតថា កាលណាហ្ន៎ យើងទើបនឹងផ្តើមវិបស្សនា ក្នុងទោមនស្សដែលនៅមានការត្រិះរិះ និងនៅមានការពិចារណាចេញបាន កាលណាយើងទើបផ្តើមវិបស្សនា ក្នុងទោមនស្សដែលមិនមានការត្រិះរិះ និងមិនមានការពិចារណាចេញបាន និងគិតទៀតថា កាលណាហ្ន៎ ទើបយើងញ៉ាំងផលសមាបត្តិក្នុងទោមនស្ស ដែលនៅមានការត្រិះរិះ និងនៅមានការពិចារណាកើតបាន កាលណាទើបយើងញ៉ាំងផលសមាបត្តិក្នុងទោមនស្ស ដែលមិនមានការត្រិះរិះ និងមិនមានការពិចារណាកើតបាន ហើយក៏កាន់យកការបដិបត្តិរហូតដល់អស់ ៣ ខែ ៦ ខែ ឬ ៩ ខែ កាលកាន់យកការបដិបត្តិរហូតដល់អស់បីខែ ក្នុងខែដំបូង ដើរចេញមួយយាមពីរយាម ធ្វើឱកាសដល់ការដេកលក់ , ក្នុងខែកណ្តាល ដើរចេញពីរយាមធ្វើឱកាសដល់ការដេកលក់មួយយាម , ក្នុងខែចុងបង្អស់ឲ្យរាងកាយប្រព្រឹត្ត

ទៅ ដោយការដើរចង្ក្រម និងការអង្គុយប៉ុណ្ណោះឯង បើបែបនេះ សម្រេចព្រះអរហត្តនោះ ក៏ល្អ ។ បើមិនសម្រេច លោកក៏កាន់យកការបដិបត្តិប្រភេទ ៦ ខែ ឲ្យវិសេស ( ឡើងទៅទៀត ) សូម្បីក្នុងការបដិបត្តិប្រភេទ ៦ ខែនោះ គ្រប់ពីរខែ ៗ ក៏បដិបត្តិតាមន័យដែលពោលហើយ កាលមិនអាចសម្រេចព្រះអរហត្តបាន ក៏កាន់យកការបដិបត្តិប្រភេទ ៩ ខែ ឲ្យវិសេស (ក្រៃលែងឡើងទៅទៀត) សូម្បីក្នុងការបដិបត្តិប្រភេទ ៩ ខែនោះ គ្រប់បីខែ ៗ ក៏បដិបត្តិយ៉ាងនោះឯង កាលមិនអាចសម្រេចភាពជាព្រះអរហន្តបាន ( និង ) កាលពិចារណាថា ឱហ្ន៎ ! យើងមិនបានបវារណាបែបវិសុទ្ធិបវារណាព្រមជាមួយពួកមិត្តព្រហ្មចរិយៈ ហើយទោមនស្ស ក៏រមែងកើតឡើង ។ ទឹកភ្នែកក៏ហូរស្រោក ដូចទឹកភ្នែករបស់ព្រះមហាសិវត្ថេរ ដែលនៅត្រង់ញកភ្នំ ខាងចុងស្រុក ។

បានឮមកថា ព្រះថេរៈអ្នកបង្រៀនពួកធំ ១៨ ពួក ពួកភិក្ខុបីម៉ឺនរូបតាំងនៅក្នុងឱវាទរបស់លោកសម្រេចអរហត្តហើយ ។ តមក មានភិក្ខុមួយរូប មករំពឹងថា ខាងក្នុងខ្លួនយើង មានគុណប្រមាណមិនបាន គុណរបស់អាចារ្យយើង មានយ៉ាងណាហ្ន៎ កំពុងរំពឹង ក៏ឃើញភាពជាបុថុជ្ជន ទើបគិតថា អាចារ្យពួកយើងជាទីពឹងរបស់ពួកអ្នកដទៃ (តែ) មិនអាចជាទីពឹង

របស់ខ្លួនបាន យើងនឹងឲ្យឱវាទដល់លោក ហើយក៏ហោះមក ចុះជិតវត្ត ចូលទៅរកអាចារ្យ អង្គុយក្នុងទីសម្រាកពេលថ្ងៃ សម្តែងវត្តហើយ ក៏អង្គុយក្នុងទីសមគួរម្ខាង ។ ព្រះថេរៈពោលថា ម្នាលអ្នកកាន់បិណ្ឌបាតជាវត្ត លោកមកព្រោះហេតុណា ។

ភិក្ខុ. បពិត្រលោកដ៏ចម្រើន ខ្ញុំជាអ្នកមកហើយ ដោយគិតថា នឹងលើកយកអនុមោទនា ត្រឹមតែមួយបទ ។

ថេរៈ. គង់នឹងមិនមានឱកាសទេលោក ។

ភិក្ខុ. លោកម្ចាស់ ខ្ញុំនឹងទូលសួរក្នុងវេលាឈរ ត្រង់រោងត្រិះរិះ ។

ថេរៈ. ក្នុងទីនោះ ពួកអ្នកដទៃក៏នឹងសួរ ។

ភិក្ខុ. ក្នុងផ្លូវត្រាច់បិណ្ឌបាតមែនទេ ករុណា ។

ថេរៈ. សូម្បីក្នុងផ្លូវនោះ ពួកអ្នកដទៃក៏នឹងសួរ ។

ភិក្ខុ. ក្នុងទីស្លៀកសំពត់ពីរជាន់ ក្នុងទីដណ្តប់សង្ឃាដិ ក្នុងទីនាំយកបាត្រចេញ ក្នុងវេលាត្រាច់ទៅក្នុងស្រុក ហើយផឹកបបរក្នុងរោងឆាន់មែនទេ ករុណា ។

ថេរៈ. ក្នុងទីនោះ ៗ ក៏នឹងមានពួកព្រះថេរៈខាងអដ្ឋកថា បន្ទោបង់សេចក្តីសង្ស័យរបស់ខ្លួន ។

ភិក្ខុ.ខ្ញុំនឹងទូលសួរក្នុងវេលាចេញអំពីក្នុងស្រុក ករុណា ។

ថេរ:. សូម្បីក្នុងទីនោះ ក៏នឹងមានពួកអ្នកដទៃសួរ លោក ។

ភិក្ខុ. លោកម្ចាស់ ក្នុងចន្លោះផ្លូវលោកម្ចាស់ ក្នុងវេលាសម្រេចការឆាន់ ក្នុងរោងអាហារ លោកម្ចាស់ ក្នុងវេលាលាងជើង ក្នុងវេលាលុបមុខ ក្នុងទីសម្រាកពេលថ្ងៃ ។

ថេរ:. តាំងពីនោះទៅដរាបដល់ភ្លឺ ក៏មានពួកដទៃទៀតសួរ លោក ។

ភិក្ខុ. ក្នុងវេលាយកឈើស្ទន់ហើយទៅកាន់ទីលុបមុខ លោកម្ចាស់ ។

ថេរ:. ពេលនោះ ពួកដទៃ ក៏នឹងសួរ ។

ភិក្ខុ. ក្នុងវេលាលុបមុខហើយមែនទេ លោកម្ចាស់ ។

ថេរ:. សូម្បីក្នុងពេលនោះ ពួកដទៃក៏នឹងសួរ ។

ភិក្ខុ. ក្នុងវេលាចូលសេនាសនៈហើយអង្គុយ លោកម្ចាស់ ។

ថេរ:. សូម្បីក្នុងពេលនោះ ពួកដទៃ ក៏នឹងសួរ ។

ភិក្ខុ. លោកម្ចាស់ គួរនឹងជាឱកាស និងវេលារបស់ពួកអ្នកដែលលុបមុខស្រេចហើយ ចូលកាន់សេនាសនៈ ឲ្យបីបួនបល្ល័ង្កបានទទួលការអប់កំដៅហើយ ធ្វើការងារដោយការយកចិត្តទុកដាក់ យ៉ាងមានហេតុផលមិនមែនឬ លោកម្ចាស់ លោកម្ចាស់នឹងមិនបានសូម្បីតែខណៈនៃការស្តាប់

លោកចូរដូចជាវនោបក្កាចុះ លោកម្ចាស់ ចូរជាទីពឹងរបស់អ្នកដទៃចុះ លោកម្ចាស់ មិនអាចដើម្បីនឹងជាទីពឹងរបស់ខ្លួន ខ្ញុំមិនមានសេចក្ដីត្រូវការដោយការអនុមោទនាដល់លោកម្ចាស់ ថាហើយ ក៏បានហោះទៅក្នុងអាកាស ។ ព្រះថេរៈជ្រាបថា ការងារដែលជាប់ទាក់ទងនឹងការសិក្សារៀនសូត្ររបស់ភិក្ខុរូបនេះ មិនមែនលោកមកដោយគិតថា នឹងជាអ្នកប្រៀនប្រដៅយើង ហើយគិតថា ឥឡូវនេះនឹងមិនមានឱកាស វេលាជិតភ្លឺយើងនឹងទៅ ហើយក៏រក្សាបាត្រ ចីវរទុកជិតៗ ទូន្មានធម៌រហូតដល់អស់យាមដើម និងយាមកណ្ដាល ជិតភ្លឺ ខណៈដែលព្រះថេរៈមួយរូបរៀនឧទ្ទេស ហើយចេញទៅក្នុងយាមចុងក្រោយ ក៏កាន់បាត្រ ចីវរ ចេញទៅជាមួយគ្នានឹងព្រះថេរៈនោះឯង ពួកសិស្ស (អន្តេវាសិក) ដែលអង្គុយ យល់ថា អាចារ្យចេញទៅដោយធុរៈយ៉ាងណាខ្លះ ។ ព្រះថេរៈដែលចេញទៅ ក៏ធ្វើការយល់ថាជាភិក្ខុដែលរួមអាចារ្យគ្នា រូបខ្លះនុ៎ះឯង ។ បានឮថា ព្រះថេរៈគិតថា ឈ្មោះថា ភាពជាព្រះអរហន្ត សម្រាប់បុគ្គលដូចជាយើង នឹងមានអ្វីធ្ងន់ហ្ន៎ គ្រាន់តែពីរបីថ្ងៃប៉ុណ្ណោះឯង ក៏នឹងសម្រេច ទើបនឹងត្រឡប់មក ដូច្នេះ ទើបមិនប្រាប់ពួកកូនសិស្សឡើយ ក្នុងថ្ងៃ ១៣ កើត ខែ ៨ ទៅកាន់ញកភ្នំខាងចុងស្រុក កាលឡើងកាន់ទីចង្ក្រមហើយ យកចិត្តទុកដាក់ក្នុងកម្ម-

ដ្ឋាន ក្នុងថ្ងៃនោះក៏ញ៉ាំងព្រះអរហត្តផលមិនបាន ។ កាលដល់ថ្ងៃឧបោសថ ក៏គិតថា យើងមកដោយគិតថា ពីរបីថ្ងៃយើងនឹងយក ព្រះអរហត្តផលឲ្យបាន ក៏នៅមិនបាន បីខែ ក៏ដូចបីថ្ងៃនុ៎ះឯង រហូតដល់ថ្ងៃ មហាបវារណា នៅមិនដឹង ដល់ចូលវស្សាហើយ ក៏នៅមិនបាន ។ ក្នុងថ្ងៃបវារណា លោកគិតថា យើងមកហើយដោយគិតថា ដោយពីរបីថ្ងៃ យើងនឹងញ៉ាំង ព្រះអរហត្តផលឲ្យបាន នេះបីខែហើយ ក៏មិនអាចនឹងយកបាន ចំណែកពួក មិត្តព្រហ្មចរិយៈ នឹងបវារណាប្រភេទវិសុទ្ធិបវារណា កាលលោកគិតដូច្នោះ ទឹកភ្នែកក៏ហូរ ។ បន្ទាប់ពីនោះ លោកគិតថា មគ្គផលនឹងមិនកើតឡើង ព្រោះឥរិយាបថ ៤ របស់យើងនៅលើគ្រែ បើឥឡូវនេះ មិនទាន់សម្រេច ព្រះអរហត្តផល យើងនឹងមិនព្រមទម្រេតខ្នងលើគ្រែជាដាច់ខាត និងមិន ព្រមលាងជើង ហើយក៏ឲ្យលើកយកគ្រែទៅរក្សាទុក រដូវវស្សាក៏ដល់ ទៀត ។ លោកក៏ញ៉ាំងព្រះអរហត្តផលមិនបាន ទឹកភ្នែកក៏ហូរ ក្នុងថ្ងៃ បវារណា ២៩ ដង ។ ពួកក្មេងក្នុងស្រុក នាំគ្នាយកបន្ទាមកស្រោស់ត្រង់ ទីដែលបែកក្នុងជើងទាំងពីរខាងរបស់ព្រះថេរៈ ។ សូម្បីកាលនឹងនាំគ្នាលេង ក៏និយាយលេងថា សូមឲ្យជើងទាំងពីរខាង ចូរដូចជើងរបស់លោកម្ចាស់ មហាសិវត្ថេរចុះ ។

ក្នុងថ្ងៃមហាបវារណាឆ្នាំ (ទី) សាមសិប ព្រះថេរៈឈរតោងបង្ខូះ ក្ដាសម្រាប់ផ្អែក គិតថា កាលយើងធ្វើសមណធម៌មក ចូលសាមសិបឆ្នាំថ្មីនេះហើយ យើងក៏មិនអាចសម្រេចព្រះអរហត្តផលបាន ក្នុងអត្តភាពរបស់យើងនេះ មគ្គ ឬផល រមែងមិនមានពិត យើងមិនបានបវារណាប្រភេទវិសុទ្ធិបវារណាជាមួយមិត្តព្រហ្មចរិយៈ ។ កាលលោកគិតយ៉ាងនោះ ក៏កើតទោមនស្សឡើង ទឹកភ្នែកក៏ហូរហៀរ ។ ខណៈនោះ ក្នុងទីជិតៗ មានទេវធីតាអង្គមួយ កំពុងឈរយំ ។

ថេរៈ. អ្នកណាយំទីនេះ ។

ទេវធីតា. ខ្ញុំម្ចាស់ ទេវធីតា លោកម្ចាស់ ។

ថេរៈ. យំធ្វើអ្វី ។

ទេវធីតា. កាលមគ្គផលកំពុងកើត ព្រោះការយំ ខ្ញុំម្ចាស់គិតថា សូម្បីយើងក៏នឹងឲ្យកើតមគ្គផលមួយ (ឬ) ពីរ ទើបយំលោកម្ចាស់ ។

តពីនោះព្រះថេរៈក៏គិតថា នេះនែ៎ មហាសិវៈ សូម្បីតែទេវធីតាក៏នៅមកចំអកឡកឡឺយអ្នកដែរ នេះគួរដល់លោកឬហ្ន៎ ហើយក៏ចម្រើនវិបស្សនា បានញ៉ាំងភាពជាព្រះអរហន្តព្រមទាំងបដិសម្ភិទាទាំងឡាយ ។

លោកគិតថា ឥឡូវនេះយើងនឹងដេក ហើយក៏ចាត់ចែងសេនាសនៈ

ក្រោយគ្រែ តាំងទឹកក្នុងទីមានទឹក គិតថា យើងនឹងលាងជើងទាំងពីរខាង ហើយអង្គុយចុះត្រង់កាំជណ្តើរ ។ សូម្បីពួកសិស្សរបស់លោក ក៏នាំគ្នាគិតថា កាលអាចារ្យរបស់យើងទៅធ្វើសមណធម៌រហូតសាមសិបឆ្នាំ លោកអាចធ្វើគុណវិសេសឲ្យកើតបានឬទេ ឃើញថា លោកសម្រេចព្រះអរហត្តហើយអង្គុយចុះដើម្បីលាងជើង ទើបគិតថា អាចារ្យពួកយើង កាលពួកសិស្សដូចយើងនៅមាន គិតថា នឹងលាងជើង ដោយខ្លួនឯងនេះ មិនមែនជាឋាន: យើងនឹងលាង យើងនឹងលាង ទាំង ៣០,០០០ រូប ក៏ហោះមកសំពះ ហើយពោលប្រាប់ថា ខ្ញុំនឹងលាងជើងប្រគេន លោកម្ចាស់ ។ លោកហាមថា លោក ខ្ញុំមិនបានលាងជើងមកសាមសិបឆ្នាំក្នុងឆ្នាំនេះឯង ពួកលោកមិនចាំបាច់ទេ ខ្ញុំនឹងលាងខ្លួនឯង ។

សូម្បីស្តេចសក្កៈក៏ទ្រង់ពិចារណាថា លោកម្ចាស់មហាសិវៈត្ថេររបស់យើងសម្រេចព្រះអរហត្តហើយ កាលពួកសិស្សបីម៉ឺនរូបមកហើយដោយគិតថា ពួកយើងនឹងលាងជើងទាំងឡាយប្រគេន ក៏មិនឲ្យលាងជើង ក៏កាលឧបដ្ឋាកដូចយើងនៅមាន លោកម្ចាស់គិតថា នឹងលាងជើងខ្លួនឯងនេះប្រព្រឹត្តទៅមិនបាន ហើយទ្រង់សម្រេចព្រះទ័យថា យើងនឹងលាងជើងប្រគេន ទើបព្រមដោយសុជាតាទេវី ទ្រង់ប្រាកដក្នុងសម្នាក់របស់ពួក

ភិក្ខុ ។ ស្តេចទ្រង់បញ្ជូននាងសុជាតា ដែលជាអសុរកញ្ញាឲ្យដើរទៅមុន ឲ្យបើកឱកាសថា លោកម្ចាស់ លោកម្ចាស់ចូរចៀសទៅ មេត្តាឲ្យឱកាសមនុស្សស្រី ហើយទ្រង់ចូលទៅរកព្រះថេរៈ សំពះហើយអង្គុយប្រហោងចំពោះមុខ ត្រាស់ថា លោកម្ចាស់ខ្ញុំនឹងលាងជើងប្រគេន ព្រះថេរៈឆ្លើយថា កោសិ អាត្មាភាពមិនបានលាងជើងមកអស់សាមសិបឆ្នាំ នឹងឆ្នាំនេះហើយ និងសូម្បីដោយប្រក្រតីឈ្មោះថា ក្លិនខ្លួនមនុស្សជារបស់គួរខ្ពើមសម្រាប់ពួកទេវតា សូម្បីនៅឆ្ងាយទាំងរយយោជន៍ ដូចយកសាកសពមកព្យួរក អាត្មាភាពនឹងលាងខ្លួនឯង ។ ត្រាស់ឆ្លើយថា លោកម្ចាស់ ឈ្មោះថា ក្លិនយ៉ាងនេះមិនប្រាកដ ព្រោះថា ក្លិនសីលរបស់លោកផ្សាយទៅកាន់ទេវលោក ៦ ជាន់ ដែលតាំងនៅខ្ពស់ ដល់ជាន់ភវគ្គព្រហ្មក្នុងខាងលើមិនមានក្លិនដទៃក្រៃលែងជាងក្លិនសីលលោកម្ចាស់ ខ្ញុំមកព្រោះក្លិនសីលរបស់លោក ហើយក៏ទ្រង់យកព្រះហស្តឆ្វេងចាប់ត្រង់ក្អែកគោ យកព្រះហស្តស្តាំជូតបាតជើង ។ ជើងរបស់លោក ក៏ដូចគ្នានឹងជើងរបស់ទារកទើបនឹងកើតឡើងភ្លាម ។ គ្រាស្តេចសក្កៈ ទ្រង់លាងជើងប្រគេនស្រេចហើយ ទ្រង់សំពះ និងស្តេចទៅកាន់ទេវលោកដូចដើម ។

គប្បីជ្រាបថា លោកហៅអារម្មណ៍របស់វិបស្សនាក្តី វិបស្សនាក្តី

មគ្គក្តី ផលក្តី ថា ទោមនស្សដែលនៅមានការត្រិះរិះ និងនៅមានការពិចារណា និងថា ទោមនស្សដែលមិនមានការត្រិះរិះ និងមិនមានការពិចារណា ដោយអំណាចការយល់របស់ភិក្ខុដែលអាស្រ័យទោមនស្ស ដែលកើតឡើងហើយ ពិចារណាថា យើងមិនបានបវារណាប្រភេទវិសុទ្ធិ បវារណាជាមួយនឹងពួកសព្រហ្មចារី ដូចដែលពោលមកនេះ ។

ក្នុងរឿងរបស់ទោមនស្សនោះ មានភិក្ខុមួយរូបផ្តើមវិបស្សនា ក្នុងទោមនស្សដែលនៅមានការត្រិះរិះ និងនៅមានការពិចារណា មកពិចារណាថា ទោមនស្សនេះអាស្រ័យអ្វី ក៏ដឹងច្បាស់ថា អាស្រ័យវត្ថុ ទើបតាំងនៅក្នុងព្រះអរហត្តផលដោយលំដាប់ ដោយន័យដែលពោលហើយក្នុងពួកធម៌ដែលមានផស្សៈជាគម្រប់ ៥ នុ៎ះឯង ។ មួយរូបទៀត ផ្តើមវិបស្សនាក្នុងទោមនស្ស ដែលមិនមានការត្រិះរិះ និងមិនមានការពិចារណា ក៏តាំងនៅក្នុងព្រះអរហត្តផល តាមន័យដែលពោលហើយ ដូចគ្នា ។

សូម្បីក្នុងទោមនស្សតាំងមាំហើយទាំងនោះ ទោមនស្សដែលមិនមានការត្រិះរិះ និងមិនមានការពិចារណា ប្រណីតជាង ដែលមានការត្រិះរិះ និងការពិចារណា វិបស្សនាក្នុងទោមនស្ស ដែលមិនមានការត្រិះរិះ និងមិនមានការពិចារណា ក៏ប្រណីតជាងវិបស្សនាក្នុងទោមនស្ស ដែល

មានការត្រិះរិះ និងមានការពិចារណា ផលសមាបត្តិក្នុងទោមនស្ស ដែលមិនមានការត្រិះរិះ និងមិនមានការពិចារណា ក៏ប្រណីតជាង សូម្បីផលសមាបត្តិក្នុងទោមនស្ស ដែលនៅមានសេចក្តីត្រិះរិះ និងនៅមានការពិចារណានោះពិត ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា ពួកទោមនស្សណា ដែលមិនមានការត្រិះរិះ និងមិនមានការពិចារណា ប្រណីតជាង ដូច្នេះ ។

ពាក្យថា **មិនគប្បីសេពឧបេក្ខាបែបនោះ** សេចក្តីថា មិនគប្បីសេពឧបេក្ខា ដែលអាស្រ័យផ្ទះបែបនោះ ។ ដែលឈ្មោះថា ឧបេក្ខាដែលអាស្រ័យផ្ទះ បានដល់ ឧបេក្ខាដែលអាស្រ័យកាមគុណ ដែលជាប់ជំពាក់កើតឡើងក្នុងកាមគុណនោះឯង ប្រព្រឹត្តទៅកន្លងរូបជាដើមមិនបាន ដូចរុយចោមរោមដុំស្ករអំពៅ ក្នុងអារម្មណ៍ដែលគួរស្រឡាញ់ ដែលមកកាន់គន្លងក្នុងទ្វារទាំង ៦ យ៉ាងនេះ គឺ ក្នុងវេទនាទាំងនោះ **ឧបេក្ខាដែលអាស្រ័យផ្ទះ** មាន ៦ យ៉ាង តើដូចម្តេច ? ព្រោះឃើញរូបដោយភ្នែក ឧបេក្ខារមែងកើតឡើងដល់បុគ្គលល្ងង់ បុគ្គលវង្វេង បុគ្គលមានកិលេសក្រាស់ បុគ្គលយកតែឈ្នះមិនមានព្រំដែន យកតែឈ្នះមិនមានហេតុផល មានប្រក្រតីមិនឃើញទោស មិនបានទទួលការសិក្សា គឺ ជាបុថុជ្ជន

ឧបេក្ខាបែបនេះណា ឧបេក្ខានោះឈានកន្លងនូវរូបមិនបាន ព្រោះដូច្នោះ ទើបហៅឧបេក្ខានោះថា អាស្រ័យផ្ទះ ដូច្នេះជាដើម ។

ពាក្យថា **ឧបេក្ខាបែបនេះ ដែលបុគ្គលគប្បីសេព** គឺ គប្បីសេពឧបេក្ខាដែលអាស្រ័យការចេញចាកផ្ទះបែបនេះ ។ ដែលឈ្មោះថា ឧបេក្ខាដែលអាស្រ័យការចេញចាកផ្ទះ បានដល់ ឧបេក្ខាដែលប្រកបព្រមដោយវិបស្សនាញាណ ដែលកើតដល់បុគ្គលអ្នកមិនត្រេកអរក្នុងអារម្មណ៍ ដែលគួរស្រឡាញ់ មិនប្រទូស៉ាយក្នុងអារម្មណ៍ដែលមិនជាទីស្រឡាញ់ មិនឈ្លក់វង្វេង ព្រោះមិនមានការសម្លឹងពិចារណាក្នុងអារម្មណ៍ មានអារម្មណ៍ដែលគួរស្រឡាញ់ជាដើម ដែលមកកាន់គន្លងក្នុងទ្វារទាំង ៦ យ៉ាងនេះ គឺក្នុងវេទនាទាំងនោះ ឧបេក្ខាដែលអាស្រ័យការចេញចាកផ្ទះ ៦ យ៉ាង តើដូចម្តេច ? គឺ ឧបេក្ខា រមែងកើតឡើងដល់បុគ្គលដឹងច្បាស់ការមិនទៀងការប្រែប្រួល ការបែកធ្លាយ ការរលត់របស់រូប ហើយឃើញរូបនោះដោយបញ្ញាដ៏ប្រពៃតាមសេចក្តីពិតយ៉ាងនេះថា រូបទាំងឡាយក្នុងកាលមុនទាំងក្នុងពេលនេះ រូបទាំងនោះ សុទ្ធតែមិនទៀង ទ្រាំនៅមិនបាន មានការប្រែប្រួលទៅជាធម្មតា ឧបេក្ខាបែបនេះណា ឧបេក្ខានោះ ឈានកន្លងរូបបាន ព្រោះដូច្នោះ ឧបេក្ខានោះ ទើបហៅថា អាស្រ័យការចេញចាកផ្ទះ

ដូច្នេះ ជាដើម ។ មួយវិញទៀត សុមង្គលឧបេក្ខាដែលជាកណ្តាលក្នុងអារម្មណ៍នោះ ៗ មានចំណែកស្មើគ្នានឹងវេទនា ក៏ចាត់ជាឧបេក្ខាក្នុងទីនេះបានដូចគ្នា ។ ពាក្យថា **ព្រោះដូច្នោះ គប្បីសេព** សេចក្តីថា គប្បីសេពឧបេក្ខាដែលកើតដោយអំណាចការចេញចាកផ្ទះ ដោយអំណាចវិបស្សនា ដោយអំណាចការតាមរឭកដល់ ដោយអំណាចឈានទីមួយ ទីពីរ ទីបី និងទីបួន នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា **បើឧបេក្ខាណានៅមានសេចក្តីត្រិះរិះនៅមានសេចក្តីពិចារណា** គឺ សុមង្គលក្នុងឧបេក្ខា ដែលអាស្រ័យការចេញចាកផ្ទះនោះ ក៏គប្បីជ្រាបថា ឧបេក្ខានៅមានការត្រិះរិះ នៅមានការពិចារណា ដែលកើតឡើងដោយអំណាចការចេញចាកផ្ទះ ដោយអំណាចវិបស្សនា ដោយអំណាចការតាមរឭកដល់ និងដោយអំណាចឈានទីមួយណា ។ ពាក្យថា **ណា បើមិនមានការត្រិះរិះ មិនមានការពិចារណា** ក៏គប្បីជ្រាបថា ឧបេក្ខាដែលមិនមានការត្រិះរិះ មិនមានការពិចារណា ដែលកើតឡើងដោយអំណាចឈានទីពីរ និងទីបី ជាដើមណា ។ ពាក្យថា **ពួកណាមិនមានការត្រិះរិះ មិនមានការពិចារណា** សេចក្តីថា ក្នុងឧបេក្ខាទាំងពីរនេះ ឧបេក្ខាដែលមិនមានការត្រិះរិះ និងមិនមានការពិចារណានោះ ប្រណីត

ជាង ។ ដោយពាក្យនេះ លោកពោលដល់អ្វី ពោលដល់អរហត្តផល របស់លោកពីររូប ។ ពិតហើយ ភិក្ខុមួយរូប កាលផ្តើមវិបស្សនាក្នុង ឧបេក្ខាដែលនៅមានការត្រិះរិះ និងនៅមានការពិចារណាហើយ ក៏មក ពិចារណាថា ឧបេក្ខានេះ អាស្រ័យអ្វី ក៏ជ្រាបច្បាស់ថា អាស្រ័យវត្ថុ ហើយក៏តាំងនៅក្នុងអរហត្តផលដោយលំដាប់ តាមន័យដែលពោលហើយ ក្នុងពួកដែលមានផស្សៈជាគម្រប់ ៥ នុ៎ះឯង ។ មួយរូប ផ្តើមវិបស្សនា ក្នុងឧបេក្ខាដែលមិនមានការត្រិះរិះ និងមិនមានការពិចារណា ហើយក៏ តាំងនៅក្នុងអរហត្តផល តាមន័យដែលពោលហើយដូចគ្នា ។

សូម្បីក្នុងឧបេក្ខាដែលតាំងមាំទាំងនោះ ឧបេក្ខាដែលមិនមានវិតក្កៈ និងមិនមានវិចារៈប្រណីតជាង ដែលនៅមានវិតក្កៈ និងនៅមានវិចារៈ ឧបេក្ខាវិបស្សនាដែលមិនមានការត្រិះរិះ និងមិនមានការពិចារណា ប្រណីត ជាង សូម្បីឧបេក្ខាវិបស្សនាដែលមានត្រិះរិះ និងមានការពិចារណា ឧបេក្ខា-ផលសមាបត្តិ ដែលមិនមានការត្រិះរិះ និងមិនមានពិចារណាប៉ុណ្ណោះ ដែលប្រណីតជាង ឧបេក្ខាផលសមាបត្តិដែលនៅមានការត្រិះរិះ និងនៅ មានការពិចារណា ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា **ពួក ណា មិនមានការត្រិះរិះ មិនមានការពិចារណា ប្រណីតជាង** ដូច្នេះ ។

ព្រះមានព្រះភាគត្រាស់ថា បពិត្រ ទេវានមិន្ទ ! ភិក្ខុបដិបត្តិយ៉ាងនេះឯង ឈ្មោះថា រមែងបដិបត្តិក្នុងប្រការបដិបត្តិ ដែលឲ្យដល់សេចក្តីសមគួរដើម្បីលេត់មិនមានសល់នៃចំណែកដែលមានការចាំបាន សម្គាល់ដឹងដែលប្រកបដោយធម៌ជាគ្រឿងយឺតយូរ ហើយក៏ទ្រង់បញ្ចប់ទេសនាដល់កំពូល គឺ ព្រះអរហត្តផល ។ ចំណែកស្តេចសក្កៈ ទ្រង់តាំងនៅក្នុងសោតាបត្តិផលហើយ ។

ធម្មតាព្រះអធ្យាស្រ័យរបស់ព្រះពុទ្ធជាម្ចាស់មិនអាក្រក់ មានតែថ្នាក់កំពូលប៉ុណ្ណោះ ។ កាលទ្រង់នឹងសម្តែងធម៌ដល់បុគ្គលម្នាក់ក្តី ដល់ច្រើននាក់ក្តី សុទ្ធតែទ្រង់កាន់យកដល់កំពូល ដោយព្រះអរហត្តផលប៉ុណ្ណោះ ។ តែពួកសត្វតាំងនៅក្នុងឧបនិស្ស័យ ដែលសមគួរដល់ខ្លួន ។ ពួកខ្លះក៏ជាសោតាបន្ន ពួកខ្លះក៏ជាសកទាគាមី ពួកខ្លះក៏ជាអនាគាមី ពួកខ្លះក៏ជាអរហន្ត ។ ពិតណាស់ ព្រះមានព្រះភាគ ទ្រង់ដូចព្រះរាជា ពួកវេនេយ្យសត្វដូចពួកព្រះរាជកុមារ ។ ដូចសេចក្តីថា ក្នុងវេលាសោយព្រះក្រយាហារ ព្រះរាជាទ្រង់ពូតដុំបាយតាមខ្នាតព្រះអង្គ ហើយទ្រង់បញ្ចុកពួកព្រះរាជកុមារ ។ ពួកព្រះរាជកុមារទាំងនោះ ក៏ទ្រង់ធ្វើដុំបាយតាមខ្នាតព្រះឱស្ឋរបស់ព្រះអង្គអំពីដុំបាយនោះ យ៉ាងណា ព្រះមានព្រះភាគ ក៏ដូច្នោះ

ទ្រង់កាន់យកដល់កំពូល ដោយព្រះអរហត្តផល ដោយទេសនា ដែលសមគួរដល់ព្រះអធ្យាស្រ័យរបស់ព្រះអង្គប៉ុណ្ណោះ វេនេយ្យសត្វទាំងឡាយក៏រមែងទទួលយកសោតាបត្តិផល សកទាគាមិផល អនាគាមិផល ឬអរហត្តផលទាំងឯង អំពីព្រះធម៌ទេសនានោះ តាមប្រមាណនៃឧបនិស្ស័យរបស់ខ្លួន ៗ

ចំណែកស្តេចសក្កៈ គ្រាទ្រង់ជាព្រះសោតាបន្នហើយ ក៏ទ្រង់ចុតិចំពោះព្រះភ័ក្ត្ររបស់ព្រះមានព្រះភាគទាំងឯង ហើយក៏ទ្រង់កើត ក្លាយជាស្តេចសក្កៈកម្លោះ ។ ធម្មតាការដែលទៅ និងដែលមក នៃអត្តភាពរបស់ពួកទេវតាដែលចុតិហើយ រមែងមិនប្រាកដ ។ រមែងដូចជាការប្រាសទៅនៃអណ្តាតប្រទីប ដូច្នោះ ពួកទេវតាដ៏សេស ទើបមិនជ្រាបគ្នា ។ ចំណែកអ្នកដែលជ្រាប មានតែពីរអង្គប៉ុណ្ណោះ គឺ ស្តេចសក្កៈ ព្រោះទ្រង់ចុតិខ្លួនឯង ១ ព្រះមានព្រះភាគ ព្រោះទ្រង់មានព្រះញាណដែលរកអ្វីមករារាំងមិនបាន ១ ។ លំដាប់នោះ ស្តេចសក្កៈទ្រង់គិតថា ព្រះមានព្រះភាគទ្រង់សម្តែងផលរបស់អ្នកកើតក្នុងទីបីស្ថានប៉ុណ្ណោះដល់យើង ចំណែកមគ្គ ឬផលនេះ មិនមានអ្នកណាហោះទៅយកបានដូចបក្សី ព្រោះការកាន់យកមគ្គ ឬផលនោះ គប្បីកើតបានដោយការបដិបត្តិ ដែលជាចំណែកខាង

ដើមនៃមគ្គ ឬផល ដែលនឹងត្រូវសម្រេច យើងនឹងទូលសួរការបដិបត្តិ ដែលជាចំណែកខាងដើមរបស់ព្រះទីណាស្រេច ក្នុងខាងលើឲ្យបាន ។

[៩៦] តពីនោះ កាលនឹងទូលសួរការបដិបត្តិនោះ ទើបត្រាស់ពាក្យជាដើមថា **បពិត្រព្រះអង្គអ្នកនិរទុក្ខ ក៏បុគ្គលបដិបត្តិយ៉ាងណា** ។

បណ្តាពាក្យទាំងនោះ ពាក្យថា **ដោយការសង្រួមក្នុងបាតិមោក្ខ** គឺដោយការសង្រួមក្នុងសីលដែលខ្ពស់បំផុត និងថម្រើនបំផុត ។ ពាក្យជាដើមថា **សូម្បីមារយាទផ្លូវកាយ** ព្រះមានព្រះភាគត្រាស់ដើម្បីទ្រង់សម្តែងដល់ការសង្រួមក្នុងបាតិមោក្ខ ដោយអំណាចមារយាទផ្លូវកាយ ដែលគប្បីសេព ។ ឯឈ្មោះថា ពាក្យដែលជាប់ទាក់ទងនឹងសីលនេះ រមែងជាការពោលដោយអំណាចកម្មបថ ឬដោយអំណាចបញ្ញត្តិក៏បាន ។ ក្នុងកម្មបថ និងបញ្ញត្តិនោះ ដែលនឹងពោលដោយអំណាចកម្មបថ ត្រូវពោលដល់មារយាទផ្លូវកាយមុន ដែលមិនគប្បីសេព ដោយការសម្លាប់សត្វ ការលួចទ្រព្យ និងការប្រព្រឹត្តខុសក្នុងកាមទាំងឡាយមុន កាលនឹងពោលដោយអំណាចបញ្ញត្តិ ត្រូវពោលដោយអំណាចបញ្ញត្តិសិក្ខាបទ និងការល្មើសក្នុងផ្លូវកាយ ។ ត្រូវពោលដល់មាយាទផ្លូវកាយ ដែលគប្បីសេពដោយចេតនាជាគ្រឿងវៀរចាកការសម្លាប់សត្វជាដើម និងដោយបញ្ញត្តិសិក្ខាបទ និង

ការមិនល្មើសក្នុងកាយទ្វារ ។ ត្រូវពោលដល់មារយាទផ្លូវវាចា ដែលមិនគប្បីសេព ដោយការប្រព្រឹត្តអាក្រក់ផ្លូវវាចា មានការពោលកុហកជាដើម និងដោយបញ្ញត្តិសិក្ខាបទ និងការល្មើសក្នុងវចីទ្វារ ត្រូវពោលដល់មារយាទផ្លូវវាចា ដែលគប្បីសេពដោយចេតនា ជាគ្រឿងវៀរចាកពីការពោលកុហកជាដើម និងដោយបញ្ញត្តិសិក្ខាបទ និងការមិនល្មើសក្នុងវចីទ្វារ ។

ចំណែកការស្វែងរក បានដល់ ការស្វែងរកដោយកាយ និងវាចាទាំងឯង ។ ការស្វែងរកនោះ ក៏ជាការកាន់យកហើយដោយសំដូ គឺ មារយាទផ្លូវកាយ និងវាចា ព្រោះហេតុធម្មតាសីល ដែលមានអាជីវៈជាគម្រប់ ៨ រមែងកើតឡើងតែក្នុងពីរទ្វារនេះប៉ុណ្ណោះ មិនមែនក្នុងអាកាស ដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ការស្វែងរកនោះ ទុកមួយផ្នែកដទៃផ្សេង ដើម្បីទ្រង់សម្តែងដល់សីល ដែលមានអាជីវៈជាគម្រប់ ៨ ។ ក្នុងការស្វែងរកនោះ មិនគប្បីពោលដល់ការស្វែងរកដែលគប្បីសេព ដោយការស្វែងរកដែលមិនប្រសើរ គប្បីពោលដល់ការស្វែងរកដែលគប្បីសេព ដោយការស្វែងរកដ៏ប្រសើរ ។

សមពិតដូចព្រះតម្រាស់ ដែលព្រះមានព្រះភាគត្រាស់ទុកថា ភិក្ខុទាំងឡាយ ការស្វែងរកពីរយ៉ាងទាំងនេះ គឺ ការស្វែងរកដែលមិនប្រសើរ

មួយ ការស្វែងរកដែលប្រសើរមួយ ម្នាលភិក្ខុទាំងឡាយ ក៏ការស្វែងរកដែលមិនប្រសើរ ដូចម្ដេច ? ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ខ្លួនឯងជាអ្នកមានការកើតជាធម្មតា ក៏នៅស្វែងរកវត្ថុដែលមានការកើតជាធម្មតានុ៎ះឯង ខ្លួនឯងមានការចាស់ជាធម្មតា... មានសេចក្ដីឈឺជាធម្មតា... មានសេចក្ដីស្លាប់ជាធម្មតា... មានសេចក្ដីសោកជាធម្មតា... មានសេចក្ដីសៅហ្មងជាធម្មតាហើយ ក៏នៅស្វែងរកវត្ថុ ដែលមានសេចក្ដីសៅហ្មងជាធម្មតានុ៎ះឯង ម្នាលភិក្ខុទាំងឡាយ ក៏ពួកអ្នករមែងពោលអ្វីថា មានការកើតជាធម្មតា ម្នាលភិក្ខុទាំងឡាយ កូនប្រពន្ធមានការកើតជាធម្មតា អ្នកបម្រើស្រីប្រុសមានការកើតជាធម្មតា ពពែ កែះ មានការកើតជាធម្មតា មាន់ ជ្រូក មានការកើតជាធម្មតា ដំរី គោ សេះ លា មានការកើតជាធម្មតា ប្រាក់ មាស មានការកើតជាធម្មតា ម្នាលភិក្ខុទាំងឡាយ ក៏វត្ថុដែលមានការកើតជាធម្មតាទាំងនេះ ជាគួឧបធិទាំងឡាយ (ជាគ្រឿងចូលទៅទ្រទ្រង់សត្វទុកក្នុងទុក្ខ) បុគ្គលនេះ ជាអ្នកដែលឧបធិចងទុក ធ្វើឲ្យលុតក្រាប ឲ្យត្រូវទោសក្នុងវត្ថុពួកនេះ ខ្លួនឯងជាអ្នកមានការកើតជាធម្មតាហើយ ក៏ស្វែងរកវត្ថុដែលមានការកើតជាធម្មតានុ៎ះឯង ម្នាលភិក្ខុទាំងឡាយ ក៏ពួកអ្នករមែងពោលដល់អ្វីថា មានការចាស់ជាធម្មតា ម្នាលភិក្ខុទាំងឡាយ

កូនប្រពន្ធមានការចាស់ជាធម្មតា ។បេ។ ក៏នៅស្វែងរកវត្ថុដែលមានការចាស់ជាធម្មតានុ៎ះឯង ម្នាលភិក្ខុទាំងឡាយ ក៏ពួកអ្នករមែងពោលដល់អ្វីថា មានសេចក្តីឈឺចាប់ជាធម្មតា ម្នាលភិក្ខុទាំងឡាយ កូនប្រពន្ធ ក៏មានសេចក្តីឈឺចាប់ជាធម្មតា ។បេ។ ក៏នៅស្វែងរកវត្ថុដែលមានសេចក្តីឈឺចាប់ជាធម្មតានុ៎ះឯង ម្នាលភិក្ខុទាំងឡាយ ក៏ពួកអ្នករមែងពោលដល់អ្វីថា មានសេចក្តីស្លាប់ជាធម្មតា ម្នាលភិក្ខុទាំងឡាយ កូនប្រពន្ធមានសេចក្តីស្លាប់ជាធម្មតា ។បេ។ ក៏នៅស្វែងរកវត្ថុដែលមានសេចក្តីស្លាប់ជាធម្មតានុ៎ះឯង ម្នាលភិក្ខុទាំងឡាយ ក៏ពួកអ្នករមែងពោលដល់វត្ថុអ្វីថា មានសេចក្តីសោកជាធម្មតា ម្នាលភិក្ខុទាំងឡាយ កូនប្រពន្ធ មានសេចក្តីសោកជាធម្មតា ។បេ។ ក៏នៅស្វែងរកវត្ថុដែលមានសេចក្តីសោកជាធម្មតានុ៎ះឯង ម្នាលភិក្ខុទាំងឡាយ ក៏ពួកអ្នករមែងពោលដល់អ្វីថា សៅហ្មងជាធម្មតា ម្នាលភិក្ខុទាំងឡាយ កូនប្រពន្ធ មានសេចក្តីសៅហ្មងជាធម្មតា ។បេ។ ក៏នៅស្វែងរកវត្ថុដែលមានសេចក្តីសៅហ្មងជាធម្មតានុ៎ះឯង ម្នាលភិក្ខុទាំងឡាយ នេះការស្វែងរកដែលមិនប្រសើរ ។ ម្យ៉ាងវិញទៀត គប្បីជ្រាបថា ការស្វែងរកដែលមិនប្រសើរមាន ៥ យ៉ាង ដោយអំណាចការកោងជាដើម , មាន ៦ យ៉ាង ដោយអំណាចអគោចរ , មាន ២១ យ៉ាង ដោយអំណាចការ

នារបស់ពេទ្យជាដើម ។ ការស្វែងរកដែលមិនសមគួរ សូម្បីទាំងអស់ដែលប្រព្រឹត្តទៅយ៉ាងនេះ គប្បីជ្រាបថា ជាការស្វែងរកដែលមិនប្រសើរដោយពិត ។

ម្នាលភិក្ខុទាំងឡាយ ចំណែកការស្វែងរកប្រសើរ តើដូចម្តេច ? ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ខ្លួនឯងជាអ្នកមានការកើតជាធម្មតាហើយ ឃើញទោសក្នុងវត្ថុដែលមានការកើតជាធម្មតា រមែងស្វែងរកនិព្វានដែលមិនកើត ជាទីក្សេមចាកយោគៈ (កិលេសគ្រឿងប្រកបសត្វទុកក្នុងទុក្ខ) ដ៏កំពូល ខ្លួនឯងមានការចាស់ជាធម្មតា... មានសេចក្តីឈឺជាធម្មតា... មានសេចក្តីស្លាប់ សោក និងសៅហ្មង ជាធម្មតាហើយ ឃើញទោសក្នុងវត្ថុ ដែលមានសេចក្តីសៅហ្មងជាធម្មតា រមែងស្វែងរកនិព្វានដែលមិនសៅហ្មង ជាទីក្សេមចាកយោគៈដ៏កំពូល ។ ម្នាលភិក្ខុទាំងឡាយ នេះការស្វែងរកដ៏ប្រសើរ ។ ម្យ៉ាងទៀត សូម្បីវៀរការធ្វើ ៥ យ៉ាង មានការកោងជាដើម អគោចរ ៦ កន្លែង និងការស្វែងរកដែលមិនសមគួរ ២១ យ៉ាង ហើយស្វែងរកដោយការត្រាច់ភិក្ខាដោយធម៌ស្មើ ក៏គប្បីជ្រាបថា ជាការស្វែងរកដ៏ប្រសើរនោះឯង ។

ចំពោះក្នុងរឿងមារយាទរបស់កាយនេះ មារយាទណា ៗ ដែល

ព្រះមានព្រះភាគត្រាស់ថា មិនគប្បីសេពមារយាទនោះ ៗ ត្រូវកុំសេព តាំងពីវេលានៃគ្រឿងដៃ ការស្វែងរក ការធ្វើសេចក្ដីព្យាយាម និងការទៅក្នុងចំណែកខាងដើមនៃការសម្លាប់សត្វជាដើមតែម្ដង ។ ក្រៅនេះ គប្បីសេពតាំងពីដើម ។ អ្នកដែលមិនអាចក៏គប្បីធ្វើ សូម្បីត្រឹមតែចិត្តឲ្យកើតឡើង ( គិតយកក៏បាន ) ។ ម្យ៉ាងទៀត មិនត្រូវសេពមារយាទផ្លូវកាយដូចភិក្ខុទេវទត្តជាដើម ដែលតស៊ូព្រះពារដើម្បីត្រូវការទំលាយសង្ឃជាអាទិ៍ ។ ត្រូវសេពមារយាទផ្លូវកាយ ដូចព្រះធម្មសេនាបតី និងព្រះមហាមោគ្គ-ល្លានត្ថេរជាដើម ដែលប្រព្រឹត្តទៅដោយអំណាចការទៅកាន់ទីបម្រើព្រះរតនត្រ័យមួយថ្ងៃពីរ-បីដង ។ មារយាទផ្លូវវាចា ដែលមិនគប្បីសេពក៏ដូចភិក្ខុទេវទត្តជាដើម ដែលបន្ទឺវាចាដោយ អំណាចការបញ្ជូននាយខ្មាន់ធ្នូជាដើម ។ គប្បីសេពមារយាទផ្លូវវាចា ដែលដូចព្រះធម្មសេនាបតី និងព្រះមហាមោគ្គល្លានត្ថេរជាដើម ដែលប្រព្រឹត្តទៅដោយអំណាចការប្រកាសព្រះគុណព្រះត្រៃរតនៈ ។ មិនត្រូវសេព ការស្វែងរកដូចភិក្ខុទេវទត្តជាដើម ដែលស្វែងរកក្នុងការស្វែងរកមិនប្រសើរ ។ ត្រូវសេពការស្វែងរកដូចព្រះធម្មសេនាបតី និងព្រះមហាមោគ្គល្លានត្ថេរជាដើម ដែលស្វែងរកតែការស្វែងរកដែលប្រសើរប៉ុណ្ណោះ ។ ពាក្យថា **អ្នកបដិបត្តិយ៉ាងនោះ** សេចក្តី

ថា បពិត្រ ទេវានមិន្ទ ភិក្ខុដែលលះមារយាទផ្លូវកាយ និងវាចា និងការស្វែងរកដែលមិនគប្បីសេព បដិបត្តិដើម្បីសេចក្តីពេញបរិបូណ៌នៃមារយាទផ្លូវកាយ និងវាចា និងការស្វែងរកដែលគប្បីសេព ដូចពោលមកនេះហើយ ក៏រមែងឈ្មោះថា ជាអ្នកប្រតិបត្តិដើម្បីត្រូវការសង្រួមក្នុងសីលដែលខ្ពស់បំផុត និងចម្រើនបំផុត ព្រះមានព្រះភាគ ត្រាស់ការបដិបត្តិ ដែលជាចំណែកដំបូង ដែលនឹងត្រូវសម្រេចរបស់អ្នកអស់អាសវៈហើយ ដោយប្រការដូច្នេះ ។

[៩៧] ក្នុងពាក្យសួរទី ២ ។ ពាក្យថា **ដើម្បីសង្រួមឥន្ទ្រិយ** បានដល់ ដើម្បីបិទឥន្ទ្រិយទាំងឡាយ គឺ ដើម្បីឃុំគ្រងទ្វារបាន សំដៅសេចក្តីថា ដើម្បីសេចក្តីប្រុងប្រយ័ត្នទ្វារទុក ។ ចំណែកទ្រង់ដោះស្រាយដល់ស្តេចសក្កៈនោះ ព្រះមានព្រះភាគ បានត្រាស់ពាក្យជាដើមថា **រូបដែលគប្បីដឹងច្បាស់ដោយភ្នែក** ដើម្បីទ្រង់សម្តែងដល់ការសង្រួមឥន្ទ្រិយ ដោយអំណាចរូប ដែលគប្បីសេពជាដើម ។ ពាក្យថា **លុះត្រាស់យ៉ាងនេះ ក្នុងឥន្ទ្រិយនោះហើយ** សេចក្តីថា កាលព្រះមានព្រះភាគ បានត្រាស់យ៉ាងនេះ ស្តេចសក្កទេវរាជ ក៏ទ្រង់កើតសេចក្តីញាណវន្ទត់ថា សូម្បីនេះក៏ត្រូវកើតមានដោយលក្ខណៈការបែបនេះ ដូចគ្នានោះឯង ព្រោះទ្រង់ដោះស្រាយបញ្ហា

ក្នុងរឿងសោមនស្សជាដើម ជារឿងដែលទ្រង់បានស្ដាប់មកហើយក្នុងខាងក្រោយ ទើបបានទ្រង់ក្រាបទូលចំពោះព្រះមានព្រះភាគយ៉ាងនេះ គឺ បានត្រាស់ពាក្យជាដើមនេះថា ដូច្នេះឯងព្រះអង្គ ដូច្នេះឯងព្រះអង្គ ។ សូម្បីព្រះមានព្រះភាគ ក៏ប្រទានឱកាសដល់ស្ដេចសក្កៈ ទើបទ្រង់ស្ងៀម ។ ការពិតមានមកថា អ្នកដែលមិនអាចធ្វើឲ្យសម្រេចប្រយោជន៍បាននោះ ជាអ្នកពេញចិត្តនិយាយ ឬអ្នកដែលអាចធ្វើឲ្យសម្រេចប្រយោជន៍បាននោះ មិនជាអ្នកពេញចិត្តនិយាយ បុគ្គលបែបនោះ ព្រះមានព្រះភាគមិនប្រទានឱកាសឲ្យ ។ ចំណែកស្ដេចសក្កៈនេះ ព្រោះទ្រង់ជាអ្នកពេញចិត្តត្រាស់ និងទាំងញ៉ាំងទ្រង់អាចធ្វើប្រយោជន៍ឲ្យសម្រេចបានផង ដូច្នោះ ព្រះមានព្រះភាគទើបប្រទានព្រះឱកាសឲ្យស្ដេច ។

ក្នុងរឿងការសង្រួមឥន្ទ្រិយនោះ នេះជាសេចក្ដីសង្ខេប ក្នុងពាក្យជាដើមថា **មិនគប្បីសេពបែបនោះ** ។ កាលមើលរូបណា សេចក្ដីស្រឡាញ់ជាដើម រមែងកើតឡើង មិនគប្បីសេព មិនគប្បីក្រឡេកមើលរូបនោះ តែកាលមើលរូបណា សេចក្ដីសម្គាល់ថា មិនស្អាតរមែងតាំងមាំ សេចក្ដីជ្រះថ្លារមែងកើតឡើង ឬការត្រឡប់បាននូវសេចក្ដីសម្គាល់ថា មិនទៀងរមែងមាន គប្បីសេពរូបនោះ ។ កាលស្ដាប់សំឡេង ដែលមានអក្សរ

វិចិត្រក្តី មានព្យញ្ជនៈវិចិត្រក្តី រមែងកើតសេចក្តីស្រឡាញ់ជាដើមឡើង សំឡេងបែបនោះ មិនគប្បីសេព ។ តែកាលស្តាប់សំឡេងណា សូម្បីតែចម្រៀងរបស់នាងទាសីដងទឹក ( កុម្ភទាសី ) ដែលអាស្រ័យអត្ថ ( ផល ) អាស្រ័យធម៌ ( ហេតុ ) រមែងកើតសេចក្តីជ្រះថ្លាឡើង ឬសេចក្តីនឿយ-ណាយរមែងតាំងមាំ សំឡេងបែបនោះគប្បីសេព ។ កាលធុំក្លិនណា រមែងកើតសេចក្តីតម្រេកជាដើមឡើង ក្លិននោះមិនគប្បីសេព ។ តែកាលធុំក្លិនណា រមែងត្រឡប់បានសេចក្តីយល់ថា មិនល្អជាដើម ក្លិនយ៉ាងនោះគប្បីសេព កាលភ្លក់រសណា រមែងកើតសេចក្តីតម្រេកជាដើមឡើង រសនោះមិនគប្បីសេព ។ តែកាលភ្លក់រសណា រមែងកើតសេចក្តីយល់ថា ជារបស់បដិកូលក្នុងអាហារ និងរមែងអាស្រ័យកម្លាំងកាយ ព្រោះរសដែលបានភ្លក់ជាបច្ច័យហើយ អាចឈានចុះកាន់អរិយភូមិបាន ដូចសាមណេរសិវៈ នៅព្រះមហាសិវត្ថេរ ឬកាលបរិភោគ ក៏រមែងមានការអស់កិលេសទៅ រសបែបនោះគប្បីសេព ។ កាលពាល់ត្រូវផោដ្ឋព្វៈណា រមែងកើតរាគៈជាដើម មិនគប្បីសេពផោដ្ឋព្វៈបែបនោះ ។ តែកាលពាល់ត្រូវវត្ថុណា រមែងមានការអស់កិលេសជាគ្រឿងត្រាំបាន ដូចរបស់ព្រះសារីបុត្រត្ថេរ ជាដើម ទាំងសេចក្តីព្យាយាម ក៏បានទទួលការផ្គងទុកយ៉ាងល្អ និងទាំង

ប្រជុំជនក្នុងខាងក្រោយ ក៏រមែងបានទទួលការអនុគ្រោះដោយការដើរតាមគំរូដូចដែលបានឃើញ ផោដ្ឋព្វៈបែបនោះ គប្បីសេពចុះ ។

បានឮមកថា ព្រះសារីបុត្តត្ថេរ មិនធ្លាប់ទម្រេតខ្នងលើគ្រែរហូតដល់អស់ ៣០ ឆ្នាំ ព្រះមហាមោគ្គល្លានត្ថេរក៏ដូចគ្នា ។ ព្រះមហាកស្សបត្ថេរមិនធ្លាប់ទម្រេតខ្នងលើគ្រែ ១២០ ឆ្នាំ ។ ព្រះអនុរុទ្ធត្ថេរ ៥៥ ឆ្នាំ ព្រះភទ្ទិយត្ថេរ ៣០ ឆ្នាំ ព្រះសោណត្ថេរ ១៨ ឆ្នាំ ព្រះរដ្ឋបាលត្ថេរ ១២ ឆ្នាំ ព្រះអានន្ទត្ថេរ ១៥ ឆ្នាំ ព្រះរាហុលត្ថេរ ១២ ឆ្នាំ ព្រះពាកុលត្ថេរ ៨០ ឆ្នាំ ព្រះនាឡកត្ថេរ មិនធ្លាប់ទម្រេតខ្នងលើគ្រែដរាបបរិនិព្វាន ។

កាលពិចារណាធម៌ដែលនឹងគប្បីដឹងច្បាស់បាន ដោយចិត្តពួកណា រមែងកើតភគៈជាដើមឡើង ឬការសម្លឹងរំពៃចង់បាន ដោយន័យជាដើមថា ឱហ្ន៎ សូមឲ្យគ្រឿងឧបករណ៍ គឺ សម្បត្តិដែលអ្នកដទៃសប្បាយចិត្តរបស់អ្នកពួកដទៃនោះ ចូរជារបស់យើងចុះ រមែងមកកាន់គន្លង មិនគប្បីសេព ។ តែធម៌ទាំងឡាយរបស់ព្រះថេរៈ ៣ រូប ពួកណាដោយអំណាចមេត្តាជាដើម យ៉ាងនេះថា សូមឲ្យពួកសត្វទាំងអស់ ចូរជាអ្នកមិនមានពៀរនឹងគ្នាចុះ ធម៌បែបនេះ គប្បីសេពបាន ។

បានឮថា ព្រះថេរៈ ៣ រូប ក្នុងថ្ងៃចូលវស្សា បានធ្វើកតិកាទុកថា

ការត្រិះរិះដែលជាអកុសល មានការត្រិះរិះដល់សេចក្តីប្រាថ្នាជាដើម ពួកយើងមិនគប្បីត្រិះរិះ ។ លុះក្នុងថ្ងៃបវារណា ព្រះសង្ឃត្ថេរសួរ ភិក្ខុពីររូបថា លោកម្ចាស់ ក្នុង ៣ ខែនេះ លោកឲ្យចិត្តស្ទុះទៅប៉ុន្មានកន្លែង ។ ព្រះថេរៈអង្គទី ១ ឆ្លើយប្រាប់ថា លោកម្ចាស់ ខ្ញុំមិនបានឲ្យរត់ចេញក្រៅបរិវេណខេត្ត ។ ព្រះសង្ឃត្ថេរ ទើបសួរអង្គទី ២ ថា របស់លោកប៉ុន្មានកន្លែង ។ អង្គទី ២ នោះ ឆ្លើយថា លោកម្ចាស់ខ្ញុំមិនបានឲ្យរត់ទៅក្រៅទីនៅ ។ គ្រាសួរហើយ ព្រះថេរៈទាំង ២ រូប ក៏នាំគ្នាសួរព្រះថេរៈវិញថា ចុះលោកម្ចាស់វិញ ។ ព្រះថេរៈឆ្លើយថា ខ្ញុំមិនបានឲ្យស្ទុះចេញពីខន្ធ ៥ ដែលតម្កល់មាំក្នុងកាយខាងក្នុង ។ លោកទាំង ២ អង្គ ទើបឆ្លើយប្រាប់ថា លោកម្ចាស់ លោកបានធ្វើវត្តដែលធ្វើបានលំបាកហើយ ។ គប្បីសេពធម៌ដែលត្រូវដឹងច្បាស់បាន ដោយចិត្តបែបនេះចុះ ។

[៩៨] ពាក្យថា **អ្នកមានពាក្យមានទីបំផុតតែម្យ៉ាង** គឺ ដែលឈ្មោះថា អ្នកមានពាក្យ ដែលមានទីបំផុតតែម្យ៉ាង ព្រោះទីបំផុតនៃពាក្យរបស់អ្នកទាំងនេះតែម្យ៉ាង ប៉ុណ្ណោះ មិនមែន ២ ពាក្យ ។ ស្តេចសក្កៈទ្រង់សួរថា រមែងពោលតែម្យ៉ាងប៉ុណ្ណោះ ។ ពាក្យថា **មានសីល មានទីបំផុតតែម្យ៉ាង** គឺ មានមារយាទតែម្យ៉ាង ។ ពាក្យថា **មានការពេញចិត្ត មានទីបំផុតតែ**

**យ៉ាង** គឺ មានលទ្ធិតែយ៉ាង ។ ពាក្យថា **មានការអស់ មានទីបំផុតតែយ៉ាង** គឺ មានការបញ្ចប់ មានទីបំផុតតែយ៉ាង ។ ពាក្យថា **បពិត្រ ទេវានមិន្ទ លោកមានធាតុមិនមែនមួយ មានធាតុផ្សេងគ្នា** សេចក្តីថា បពិត្រ ទេវានមិន្ទ លោកនេះ មានអធ្យាស្រ័យមិនមែនតែមួយ មានអធ្យាស្រ័យផ្សេងៗ គ្នា កាលម្នាក់ចង់ដើរ ម្នាក់ចង់ឈរ កាលទៀតម្នាក់ចង់ឈរ ម្នាក់ចង់ដេក សត្វទាំង ២ ឈ្មោះថា មានអធ្យាស្រ័យដូចគ្នារកបានលំបាក ។

ក្នុងលោកដែលមានធាតុច្រើន និងមានធាតុផ្សេងៗ គ្នានោះ ពួកសត្វ រមែងប្រកាន់មាំ រមែងកាន់យកធាតុណា ៗ អធ្យាស្រ័យណា ៗ គឺ ក៏រមែងប្រកាន់មាំ រមែងកាន់យកធាតុនោះៗ ឯង ដោយក្តៅក្តា ដោយការស្ទាបអង្អែល ព្រោះដូច្នោះ លោកទើបសម្តែង គឺ បញ្ជាក់ថា រមែងចាប់យកច្រើនជាង រមែងកាន់យកមកពោលយ៉ាងល្អ ដោយក្តៅក្តា និងដោយការស្ទាបអង្អែល ។ ពាក្យថា **នេះប៉ុណ្ណោះពិត ដទៃជាមោឃៈ** គឺ ពាក្យរបស់ពួកយើងប៉ុណ្ណោះឯងពិត ពាក្យរបស់អ្នកដទៃជាមោឃៈ គឺ ទទេ បានដល់ មិនមានប្រយោជន៍ ។

[៩៩] សេចក្តីវិនាស ដែលហៅថា **អន្តៈ** (ទីបំផុត) ក្នុងបទថា **មានការរលត់ជាទីបំផុត** ( កន្ទួងចំណែក ) ឈ្មោះថា អ្នកមានការរលត់

កន្លងចំណែក ព្រោះការរលត់របស់គេទាំងនោះ កន្លងទីបំផុតហើយ ។ ការរលត់របស់ពួកគេ សេចក្ដីប្រាថ្នាយ៉ាងក្រៃលែង គឺ ព្រះនិព្វានណា នោះលោកហៅថា វត្ថុមានទីបំផុតកន្លងចំណែក ឈានកន្លងសេចក្ដីវិនាសរបស់ពួកគេទាំងអស់ ។ ពាក្យថា **ការប្រាសចាកកិលេស ជាគ្រឿងប្រកបសត្វទុកក្នុងទុក្ខ** ជាឈ្មោះរបស់ព្រះនិព្វានទ៉ុះឯង ។ ឈ្មោះថា ព្រោះការប្រាសចាកកិលេស ជាគ្រឿងប្រកបសត្វទុកក្នុងទុក្ខ របស់គេទាំងនេះនៅមាន ។ ឈ្មោះថា **អ្នកមានការប្រព្រឹត្តដ៏ប្រសើរ** ព្រោះគេរមែងប្រព្រឹត្តផ្លូវដែលឆ្ងាយចាកសត្រូវ ដែលឈ្មោះថា ប្រសើរ ព្រោះអត្ថថា ប្រសើរបំផុត ។ អ្នកប្រព្រឹត្តប្រសើរ ព្រោះជាការប្រព្រឹត្តដែលកន្លងចំណែក ឈ្មោះថា អ្នកប្រព្រឹត្តប្រសើរកន្លងចំណែក ។ ពាក្យថា **ទីបញ្ចប់** ជាឈ្មោះរបស់ព្រះនិព្វានទ៉ុះឯង ។ ឈ្មោះថា **អ្នកមានការបញ្ចប់** ព្រោះគេមានទីបញ្ចប់ដែលកន្លងចំណែក ។

ពាក្យថា **ការអស់ទៅព្រមនៃចំណង់** ក្នុងពាក្យថា **អ្នករួចផុតហើយព្រោះការអស់ទៅព្រមនៃចំណង់** នេះ ជាមគ្គក៏បាន ជាព្រះនិព្វានក៏បាន , មគ្គ ឈ្មោះថា ជាទីអស់ទៅព្រមនៃចំណង់ ព្រោះធ្វើតណ្ហាឲ្យអស់ទៅព្រម គឺ ឲ្យវិនាសទៅ , ព្រះនិព្វាន ឈ្មោះថា ជាទីអស់ទៅព្រមនៃចំណង់ ព្រោះ

សេចក្តីប្រាថ្នា កាលមកដល់ព្រះនិព្វាននោះហើយ ក៏រមែងអស់ទៅព្រម គឺរមែងវិនាសទៅ , ឈ្មោះថា អ្នករួចផុតហើយ ព្រោះការអស់ទៅព្រមនៃចំណង់ ព្រោះរួចផុតហើយដោយមគ្គ ដែលជាគ្រឿងអស់ទៅនៃចំណង់ ឬរួចផុត គឺ រួចផុតយ៉ាងក្រៃលែង ព្រោះព្រះនិព្វានដែលជាទីអស់ទៅព្រមនៃចំណង់ ។ ដោយព្រះតម្រាស់មានប្រមាណប៉ុណ្ណេះ ក៏ពោលបានថាព្រះមានព្រះភាគ ទ្រង់ព្យាករណ៍បញ្ហាគ្រប់ទាំង ១៤ ប្រការហើយ ។

ឈ្មោះបញ្ហា ១៤ ប្រការគឺ ៖

១ សេចក្តីប្រណែន និងសេចក្តីហួងហែង ( ឥស្សាមច្ឆរិយៈ)

២ សេចក្តីស្រឡាញ់ និងសេចក្តីស្អប់ ( បិយាបិយៈ )

៣ សេចក្តីពេញចិត្ត ( ឆន្ទៈ )

៤ ការត្រិះរិះ ( វិតក្កៈ )

៥ ធម៌ជាគ្រឿងយឺតយូរ ( បបញ្ច )

៦ សេចក្តីសុខចិត្ត ( សោមនស្ស )

៧ សេចក្តីទុក្ខចិត្ត ( ទោមនស្ស )

៨ សេចក្តីដឹងព្រងើយ ៗ ( ឧបេក្ខា )

៩ មារយាទផ្លូវកាយ ( កាយសមាចារ )

១០ មារយាទផ្លូវវាចា ( វចីសមាចារ )

១១ ការស្វែងរក ( បរិយេសនា )

១២ ការសង្រួមឥន្ទ្រិយ ( ឥន្ទ្រិយសំវរៈ )

១៣ ធាតុចំនួនច្រើន ( អនេកធាតុ )

១៤ ការរលត់កន្លងចំណែក ( អច្ចន្តនិដ្ឋា ) ។

## ការនិយាយអំពីសមណព្រាហ្មណ៍ដទៃ

[១០០] សេចក្តីប្រាថ្នា លោកហៅថា ឯជា គឺ ញាប់ញ័រ ព្រោះអត្ថថា ញាប់ញ័រ ។ សេចក្តីញាប់ញ័រនោះ ហៅថា **រោគ** ព្រោះអត្ថថា បៀតបៀន , ហៅថា **បូស** ព្រោះអត្ថថា ប្រទូសរ៉ាយខាងក្នុង , ហៅថា **កូនសរ** ព្រោះអត្ថថា តាមចាក់ ។ ពាក្យថា **ព្រោះដូច្នោះ បុរសនេះ** គឺ សេចក្តីញាប់ញ័រ រមែងអូសទាញបុរស ដើម្បីប្រយោជន៍ដល់ការកើតក្រៃលែងឡើងក្នុងភពនោះ ៗ តាមសមគួរដល់កម្ម ដែលខ្លួនបានធ្វើទុក ព្រោះហេតុណា ព្រោះហេតុនោះ បុរសនេះ ទើបដល់សេចក្តីខ្ពស់ទាបដោយអំណាចភពនោះ ៗ ។ ខ្ពស់ក្នុងព្រហ្មលោក ទាបក្នុងទេវលោក , ខ្ពស់ក្នុងទេវលោក ទាបក្នុងមនុស្សលោក , ខ្ពស់ក្នុងមនុស្សលោក ទាបក្នុងអបាយ , ។ ពាក្យថា យេសាហំ ភន្តេ កាត់បទជា យេសំ អហំ ភន្តេ ។ ព្រោះពាក្យថា យេសាហំ ក្នុងទីនេះ មានដោយអំណាចការភ្ជាប់ (សន្ធិ) ។ ពាក្យថា **តាមដែលបានស្តាប់មក តាមដែលបានរៀនមក** គឺ ខ្ញុំព្រះអង្គបានស្តាប់មក និងបានរៀនមកយ៉ាងណា ។ ពាក្យថា **រមែងសម្តែងមកយ៉ាងនេះ** គឺ រមែងសម្តែងធម៌ គឺ វត្តបទ ៧ ប្រការ ។ ពាក្យថា ន ចាហំ តេសំ គឺ ចំណែកខ្ញុំព្រះអង្គ មិនមែនជាសាវករបស់សមណព្រាហ្មណ៍ទាំងនោះ

ទេ ។ ស្តេចសក្កៈ ទ្រង់បង្ហាញឲ្យព្រះមានព្រះភាគទ្រង់ជ្រាបសេចក្តី ដែលព្រះអង្គទ្រង់ជាព្រះសោតាបន្ន ដោយព្រះតម្រាស់ជាដើមថា បពិត្រ ព្រះអង្គដ៏ចម្រើន ក៏ខ្ញុំព្រះអង្គ ដូច្នេះឯង ។ ពាក្យថា **ការបានចំពោះនូវសេចក្តីវិកកាយ** គឺ ការបានចំពោះនូវសេចក្តីត្រេកអរ ។

## ការនិយាយអំពីសង្គ្រាមទេវតា និងអាសុរ

[១០១] ពាក្យថា **សង្គ្រាមរវាងទេវតា និងអាសុរ** បានដល់សង្គ្រាមរបស់ពួកទេវតា និងពួកអសុរ ។ ពាក្យថា **តទល់គ្នា** បានដល់ប្រឈមមុខគ្នា បានដល់ លក្ខណៈដែលយកថ្ងាស់ចូលទៅប៉ះទង្គិចគ្នា ។ បានឮមកថា ពេលខ្លះ ពួកទាំងនោះ ច្បាំងគ្នាលើផ្ទៃសមុទ្រធំក៏មាន ។ តែក្នុងទីនោះ មិនមានការសម្លាប់គ្នានិងគ្នាដោយការកាប់ ការចាក់ជាដើម ។ គ្រាន់តែ យកឈ្នះ និងចាញ់ ដូចការច្បាំងគ្នារវាងឈើ និងកេះប៉ុណ្ណោះ ។ គ្រាខ្លះពួកទេវតាក៏ឈ្នះ គ្រាខ្លះក៏ពួកអសុរឈ្នះ ។ ក្នុងការច្បាំងគ្នានោះ ពួកទេវតាឈ្នះពួកអសុរ ដោយការមិនត្រឡប់មកទៀត ក្នុងសង្គ្រាមណា ស្តេចសក្កៈ ទ្រង់សំដៅយកសង្គ្រាមនោះ ទើបត្រាស់ពាក្យជាដើមថា តស្មឹ ខោ បន ភន្តេ ដូច្នេះឯង ។ ពាក្យថា **ទាំងពីរនោះ** បានដល់ ពួកទេវតា

ប៉ុណ្ណោះ រមែងបរិភោគឱជារសទាំងពីរ គឺ ពីរយ៉ាងនេះ ក្នុងទេវលោកនេះ ព្រោះដូច្នោះ កាលស្តេចសក្កៈនោះ ទ្រង់ពិចារណាសេចក្តីត្រេកអរ និង សោមនស្សព្រះទ័យដ៏មានកម្លាំង ទើបកើតឡើង ។ ពាក្យថា **ត្រាច់ទៅព្រម ជាមួយអាជ្ញា** បានដល់ អ្នកត្រាច់ជាប្រចាំព្រមដោយអាជ្ញា ។ លោក សម្តែងថា បានជាអ្នកត្រាច់ទៅព្រមដោយការកាន់ដំបង និងការកាន់សស្ត្រា មិនមែនជាក់អាជ្ញា និងអាវុធចុះទេ ។ ពាក្យថា **ដើម្បីសេចក្តីនឿយណាយ ដែលមានទីបំផុតតែម្យ៉ាង** បានដល់ ដើម្បីសេចក្តីនឿយណាយក្នុងការវិល វល់ ស្លាប់កើត ដោយទីបំផុតតែម្យ៉ាងប៉ុណ្ណោះ ។ គប់យ៉ាងបានពោល ទុកក្នុងមហាគោវិន្ទសូត្ររួចហើយ ។ ពាក្យថា **ច្បាស់** បានដល់ ពោលគឺ សម្តែង ។

## អំណាចនៃប្រយោជន៍ ៦ ប្រការ

[១០២] បទថា **ក្នុងនេះឯង** គឺ ក្នុងឱកាសនេះឯង ។ បទថា **ខ្ញុំព្រះអង្គជាទេវតា** គឺ ខ្ញុំព្រះអង្គ ជាទេវតា ។ ពាក្យថា **ខ្ញុំព្រះអង្គក៏បាន នូវអាយុទៀត** សេចក្តីថា ខ្ញុំព្រះអង្គបាននូវជីវិតដោយផលកម្មយ៉ាងដទៃ ទៀត ។ ដោយពាក្យនេះ ស្តេចសក្កៈ ទ្រង់សម្តែងដល់ការចុតិ និងការកើត

របស់ព្រះអង្គ ។

[១០៣] ពាក្យថា **កាយទិព្វ** គឺ អត្តភាពជាទិព្វ ។ ពាក្យថា **លះបង់អាយុដែលមិនមែនជារបស់មនុស្ស** គឺ លះបង់អាយុទិព្វ ។ ពាក្យថា **នឹងមិនវង្វេងចុះកាន់គភ៌** គឺ ជាអ្នកមិនវង្វេង ព្រោះមានគតិទៀងប្រាកដ នឹងចូលដល់គភ៌ក្នុងត្រកូលក្សត្រជាដើម ដែលចិត្តរបស់ខ្ញុំព្រះអង្គត្រេកអរប៉ុណ្ណោះ ។ ស្តេចសក្កៈ ទ្រង់សម្តែងសេចក្តីនេះថា ក្នុងទេវតានិងក្នុងមនុស្ស ៧ ដង ។

[១០៤] ពាក្យថា **នឹងនៅយ៉ាងត្រឹមត្រូវ** សេចក្តីថា សូម្បីខ្ញុំព្រះអង្គ កើតក្នុងពួកមនុស្ស នឹងនៅដោយសេចក្តីដឹងយ៉ាងត្រឹមត្រូវ គឺ តាមហេតុផលដោយស្មើ ព្រោះភាពជាអ្នកមិនគួរដល់ការផ្តាច់ជីវិតមាតាជាដើម (សម្លាប់មាតា) ។

[១០៥] ស្តេចសក្កៈ ទ្រង់ត្រាស់សំដៅដល់សកទាគាមិមគ្គនេះថា **ប្រសិនបើ ការត្រាស់ដឹងគប្បីមាន** ទ្រង់សម្តែងថា បើខ្ញុំព្រះអង្គនឹងជាសកទាគាមី ។ ពាក្យថា **ជាអ្នកដឹងទូទៅ** គឺ ខ្ញុំព្រះករុណានឹងជាអ្នកដឹងទូទៅ គឺ នឹងជាអ្នកប្រាជ្ញាដឹងទូទៅ ។ ពាក្យថា **ទីបំផុតនោះឯងនឹងមាន** គឺ ទីបំផុតក្នុងមនុស្សលោកនោះឯង នឹងមាន ។

[១០៦] ស្តេចសក្កៈ ត្រាស់ថា ខ្ញុំព្រះអង្គនឹងជាសក្កទេវរាជ ដ៏ខ្ពង់ខ្ពស់ក្នុងទេវលោកទៀត ដោយពាក្យនេះថា ខ្ញុំព្រះអង្គនឹងជាទេវតាដ៏ខ្ពង់ខ្ពស់ក្នុងទេវលោកវិញ ។

[១០៧] ពាក្យថា **ដែលមានក្នុងទីបំផុត ដែលកំពុងប្រព្រឹត្តទៅ** គឺ ក្នុងភពដែលមានក្នុងទីបំផុតដែលកំពុងប្រព្រឹត្តទៅ ។ ពាក្យថា **នោះឯងជាទីនៅ** គឺ ពួកទេវតាទាំងនោះណា ដែលមិនតិចជាងអ្នកណា ទាំងដោយអាយុ ទាំងដោយបញ្ញា ជាអ្នកចម្រើនបំផុត ប្រណីតជាងពួកទេវតាទាំងអស់ក្នុងទីបំផុត ភពនោះនឹងជាទីនៅរបស់ខ្ញុំព្រះអង្គ ។ ដំណាលមកថា ស្តេចសក្កៈនេះ ចុតិចាកអត្តភាពនៃស្តេចសក្កៈនោះហើយ នឹងជាអ្នកមានត្រកូលខ្ពស់ទៅជាភពជលជាន់អកនិដ្ឋ ព្រោះទ្រង់នឹងបានជាអនាគាមិមគ្គ ក្នុងអត្តភាពនោះ កាលទ្រង់កើតក្នុងជាន់អវិហាជាដើម ចុងក្រោយនឹងជាអកនិ-ដ្ឋគាមីព្រហ្ម ។ ស្តេចទ្រង់សំដៅដល់សេចក្តីនោះ ទើបត្រាស់យ៉ាងនោះ ។

បានឮថា ស្តេចសក្កៈនេះ នឹងទ្រង់នៅក្នុងជាន់អវិហា ១ ពាន់កប្ប សូម្បីក្នុងជាន់អតប្បា ២ ពាន់កប្ប ក្នុងជាន់សុទស្សា ៤ ពាន់កប្ប ក្នុងជាន់សុទស្សី ៨ ពាន់កប្ប ក្នុងជាន់អកនិដ្ឋ ១៦ ពាន់កប្ប ដូចពោលមកនេះ ស្តេចសក្កទេវរាជ នឹងសោយអាយុព្រហ្ម សាមសិបមុឺនមួយពាន់

កប្ប ។ ពិតណាស់ ឈ្មោះថា សត្វត្រេកអរយ៉ាងក្រៃលែង ក្នុងការវិល ស្លាប់វិលកើត មានប្រមាណអាយុដូចគ្នាពិត ទាំងបីនាក់នេះ បានដល់ សក្កទេវរាជាស្តេចរបស់ទេវតា អនាថបិណ្ឌិកគហបតី នាងវិសាខាមហា ឧបាសិកា ។ ធម្មតាអ្នកមានចំណែកសេចក្តីសុខស្មើនឹងអ្នកទាំងនេះ មិន មាន ។

[១០៨-១០៩] ពាក្យថា **អ្នកមានការត្រិះរិះនៅមិនទាន់ដល់ទីបំផុត** គឺ មានមនោរថនៅមិនទាន់ចប់ ។ ពាក្យថា **ខ្ញុំព្រះអង្គ សម្គាល់សមណៈ ពួកណា** គឺ ខ្ញុំព្រះអង្គ រមែងសម្គាល់ថា សមណៈពួកណាជាអ្នកមាន ប្រក្រតីនៅស្ងប់ស្ងៀម ។ ពាក្យថា អារាធនា គឺ សេចក្តីសម្រេច ។ ពាក្យថា វិរាធនា គឺ ការមិនសម្រេច ។ ពាក្យថា **មិនព្រម** គឺ មិនអាច និយាយឲ្យសម្រេចបាន ។ ពាក្យថា **ជាផៅពង្សរបស់ព្រះអាទិត្យ** គឺ ព្រះអាទិត្យ ក៏ជាគោតមគោត្រផង ។ ព្រះមានព្រះភាគ ក៏ទ្រង់ជាគោតម គោត្រផង ដូច្នោះ ស្តេចសក្កៈ ទើបត្រាស់យ៉ាងនោះ ។ ពាក្យថា **រមែង ធ្វើវត្តណាអំពីមុន** គឺ ពីមុនមក ពួកយើងបានធ្វើការនមស្ការណាដល់ ព្រហ្ម ។ ពាក្យថា **ស្មើនឹងពួកព្រហ្ម** គឺ ព្រមទាំងពួកទេវតា ។ ស្តេច សក្កៈទ្រង់សម្តែងថា ឥឡូវនេះ តាំងពីនេះទៅ ពួកយើងមិនមានការធ្វើ

សេចក្ដីនមស្ការដល់ព្រហ្ម ពួកយើងលើកការសំពះដល់ព្រហ្ម ។ ពាក្យថា **រមែងធ្វើសេចក្ដីសមគួរ** គឺ ពួកយើងសូមធ្វើនូវការនមស្ការ ។

ពាក្យថា **ទ្រង់ស្ទាបអង្អែល** សេចក្ដីថា ស្ដេចសក្កៈមានព្រះទ័យត្រេកអរ រីករាយ ទ្រង់ទះផែនដី ទ្រង់ទះដើម្បីបំណាចឲ្យធ្វើជាសាក្សី ដូចអ្នកយកដៃស្ទាបដៃសម្លាញ់ ត្រាស់ថា យើងក៏ដូចលោកដែលមិនញាប់ញ័រ ។

[១១០] ពាក្យថា **បញ្ហាដែលទ្រង់អាកធនា** គឺ បញ្ហាដែលបានទូលអាកធនា សំដៅសេចក្ដីថា បញ្ហាដែលត្រូវទូលសួរ ។ ពាក្យដ៏សេសក្នុងទីគ្រប់កន្លែងងាយទាំងអស់ នោះឯង ។

ចប់ អដ្ឋកថាសក្កបញ្ហសូត្រ ទី ៨

# អដ្ឋកថា មហាសតិប្បដ្ឋានសូត្រទី ៩

## ឧទ្ទេសវារៈ

[១១១] *មហាសតិប្បដ្ឋានសូត្រ មានពាក្យចាប់ផ្ដើមថា* ***ខ្ញុំបានស្ដាប់មកយ៉ាងនេះ*** *។*

*ក្នុងមហាសតិប្បដ្ឋានសូត្រនោះ មានពណ៌នាតាមលំដាប់បទដូចតទៅនេះ ៖*

## កំណើតមហាសតិប្បដ្ឋានសូត្រ

*ព្រោះហេតុណា ព្រះមានព្រះភាគ ទើបត្រាស់ព្រះសូត្រនេះថា* ***ម្នាលភិក្ខុទាំងឡាយ ផ្លូវនេះជាផ្លូវមូលតែមួយ*** *ក៏ព្រោះជនអ្នកដែនកុរុអាចទទួលទេសនាដែលជ្រាលជ្រៅបាន ។*

*បានឮមកថា អ្នកដែនកុរុ មិនថា ជាភិក្ខុ ភិក្ខុនី និងឧបាសក ឧបាសិកា មានកាយ និងចិត្តសម្បូរណ៌ជានិច្ច ដោយសេពបច្ច័យ គឺរដូវជាទីសប្បាយ ព្រោះដែននោះ សម្បូរណ៌ដោយសប្បាយ មានឧតុជាទីសប្បាយជាដើម ។ អ្នកកុរុនោះ មានកម្លាំងបញ្ញាដែលកាយ និងចិត្តដ៏សម្បូរណ៌ឧបត្ថម្ភហើយ ទើបអាចទទួលទេសនាដ៏ជ្រាលជ្រៅនេះបាន ។*

ព្រោះដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់ឃើញភាពជាអ្នកអាចទទួលទេសនាដ៏ជ្រាលជ្រៅយ៉ាងនេះ ទើបទ្រង់លើកកម្មដ្ឋាន ២១ ឋានៈ ដាក់ចុះក្នុងព្រះអរហត្ត ត្រាស់មហាសតិប្បដ្ឋានសូត្រ ដែលមានអត្ថដ៏ជ្រាលជ្រៅនេះដល់អ្នកកុរុទាំងនោះ ។ ប្រៀបដូចបុរសបានប្រអប់មាសហើយ គប្បីដាក់ផ្កាឈើប្រភេទផ្សេងៗ ចុះក្នុងប្រអប់មាសនោះ ឬថា បុរសបានហិបមាសហើយ គប្បីដាក់រតនៈ ៧ ចុះយ៉ាងណា សូម្បីព្រះមានព្រះភាគ ក៏ដូច្នោះទ្រង់បានបរិស័ទអ្នកកុរុហើយ ទើបទ្រង់ដាក់ទេសនាដ៏ជ្រាលជ្រៅ ។ ដោយហេតុនោះឯង ក្នុងសេចក្តីនេះ ព្រះមានព្រះភាគទ្រង់បានសម្តែងព្រះសូត្រដទៃ ៗ ទៀត មានអត្ថជ្រាលជ្រៅក្នុងគម្ពីរទីឃនិកាយនេះ ក៏គឺ មហានិទានសូត្រ ក្នុងគម្ពីរមជ្ឈិមនិកាយ ក៏គឺ សតិប្បដ្ឋានសូត្រ សារោបមសូត្ររុក្ខូបមសូត្រ រដ្ឋបាលសូត្រ មាគណ្ឌិយសូត្រ អានេញ្ជសប្បាយសូត្រ ។

មួយទៀត បរិស័ទ ៤ ក្នុងដែនកុរុនោះ នាំគ្នាប្រកបរឿយៗ ក្នុងការចម្រើនសតិប្បដ្ឋានជាប្រក្រតី ដោយទីបំផុត អ្នកបម្រើ និងអ្នកធ្វើការងារទាំងឡាយ ក៏និយាយគ្នាតែរឿងដែលជាប់ទាក់ទងដោយសតិប្បដ្ឋានទាំងនោះ សូម្បីតែក្នុងទីកំពង់ទឹក ទីខារអំបោះជាដើម ក៏មិនមានការនិយាយគ្នាដល់រឿងដែលគ្មានប្រយោជន៍ឡើយ ។ បើស្ត្រីខ្លះ ត្រូវសួរថា

ណែ ! នាង នាងតម្កល់ចិត្តក្នុងសតិប្បដ្ឋានមួយណា នាងនឹងមិនឆ្លើយអ្វី អ្នកកុរុនឹងតិះដៀលគេថា គួរតិះដៀលជីវិតរបស់អ្នកឯងពិត ៗ អ្នកឯងរស់នៅ ក៏ដូចស្លាប់ហើយ ហើយក៏នឹងទូន្មានគេថា កុំធ្វើយ៉ាងនេះតទៅទៀត ហើយឲ្យគេរៀនសតិប្បដ្ឋានប្រការណាមួយ ។ តែស្ត្រីណា និយាយថា ខ្ញុំដាក់ចិត្តក្នុងសតិប្បដ្ឋានប្រការឯណោះ អ្នកកុរុ ក៏នឹងពោលសរសើរថា សាធុ សាធុ ដល់នាង សរសើរដោយពាក្យផ្សេង ៗ ជាដើមថា ជីវិតរបស់អ្នក ជាជីវិតល្អ សមនឹងអ្នកកើតមកជាមនុស្ស ព្រះសម្មាសម្ពុទ្ធទ្រង់ឧប្បត្តិមកដើម្បីប្រយោជន៍ ដល់អ្នកឯងពិត ៗ ។ ក្នុងសេចក្តីនេះ មិនមែនអ្នកកុរុដែលកើតមកជាមនុស្ស ប្រកបដោយការដាក់ចិត្តក្នុងសតិប្បដ្ឋានតែម្យ៉ាងប៉ុណ្ណោះ សូម្បីតែសត្វតិរច្ឆាន ដែលអាស្រ័យអ្នកកុរុ ក៏នៅដាក់ចិត្តចម្រើនសតិប្បដ្ឋាន ដូចគ្នា ។ ក្នុងសេចក្តីនោះ មានរឿងសាធកៈដូចតទៅនេះ ។

## រឿង កូនសត្វសេក

គេជំណាលថា អ្នករបាំម្នាក់ ចាប់កូនសត្វសេកបានមួយ បង្រៀនវានិយាយភាសាមនុស្ស ( ខ្លួនឯងត្រាច់ទៅ សម្តែងរបាំក្នុងទីដទៃៗ ) ។

អ្នកបំរើនោះ អាស្រ័យនៅសម្នាក់របស់នាងភិក្ខុនី វេលាទៅក្នុងទីដទៃ ៗ ក៏ក្មេងកូនសេកៗ ពួកសាមណេរី ក៏ចាប់វាមកចិញ្ចឹម តាំងឈ្មោះវាថា ពុទ្ធរក្ខិតៈ ។ ថ្ងៃមួយ ព្រះមហាថេរី ឃើញវាទំនៅត្រង់មុខ ទើបហៅវាថា ពុទ្ធរក្ខិតៈ ។ កូនសេកទើបសួរថា អ្វី ម៉ែម្ចាស់ ។ ព្រះមហាថេរី ទើបសួរថា ការដាក់ចិត្តការនាអ្វី ៗ របស់អ្នកឯងមានខ្លះទេ ។ វាឆ្លើយថា មិនមានទេ ម៉ែម្ចាស់ ។ ព្រះមហាថេរី ទើបទូន្មានថា ដែលឈ្មោះថា អ្នកនៅក្នុងសម្នាក់របស់ពួកអ្នកបួស នឹងនៅបណ្តែតបណ្តោយខ្លួនមិនសមគួរទេ គួរប្រាថ្នាការដាក់ចិត្តយ៉ាងណាមួយ តែអ្នកឯងមិនត្រូវសញ្ជឹងគិតយ៉ាងដទៃទេ ចូរទន្ទេញ ( បរិកម្ម ) ថា **អដ្ឋិ អដ្ឋិ** ក៏បាន ។ កូនសត្វសេកនោះ ក៏នៅក្នុងឱវាទរបស់ព្រះថេរី ទន្ទេញថា **អដ្ឋិ អដ្ឋិ** តែម្យ៉ាង ហើយត្រាច់ទៅ ។ ថ្ងៃមួយ ពេលព្រឹក វាទំនៅត្រង់ចុងទ្វារ នៅហាលកំដៅថ្ងៃស្រទន់ មេស្ទាំងមួយក៏ឆាបវាទៅដោយក្រញាំក្រចក ។ វាបញ្ចេញសំឡេងស្រែកថា **កិរិ** ៗ ។ ពួកសាមណេរីក៏ស្រែកថា ម៉ែម្ចាស់ ពុទ្ធរក្ខិតៈ ត្រូវស្ទាំងឆាបទៅ យើងនឹងជួយវា ក៏នាំគ្នាកាន់យកដុំដីជាដើមដេញតាម ដរាបស្ទាំងព្រលែង ។ ពួកសាមណេរីនាំវាមកដាក់ទុកត្រង់មុខព្រះមហាថេរី , ព្រះមហាថេរីសួរថា ពុទ្ធរក្ខិតៈ ខណៈត្រូវស្ទាំងចាប់យកទៅ អ្នកគិតយ៉ាង

ណា ? ។ កូនសត្វសេកឆ្លើយថា ម៉ែម្ចាស់ ខ្ញុំមិនបានគិតអ្វីៗដទៃ គឺ គិតតែរឿងគំនរឆ្អឹងប៉ុណ្ណោះ ម៉ែម្ចាស់ថា គំនរឆ្អឹង នាំគំនរឆ្អឹងទៅ នឹងរាត់រាយនៅក្នុងទីណាហ្ន៎ ។ ព្រះមហាថេរី ទើបឲ្យសាធុការថា សាធុ សាធុ ពុទ្ធរក្ខិតៈ នោះនឹងជាបច្ច័យនៃការអស់ភពរបស់អ្នកឯង ក្នុងកាលខាងមុខនោះឯង ។ សូម្បីសត្វតិរច្ឆានក្នុងដែនកុរុនោះ ក៏ប្រកបរឿយ ៗ នូវសតិប្បដ្ឋាន ដោយប្រការដូច្នេះ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបដល់សេចក្ដីចម្រើនលូតលាស់នៃសតិប្បដ្ឋានរបស់អ្នកកុរុទាំងនោះ ទើបបានត្រាស់ព្រះសូត្រនេះ ។

## អធិប្បាយសេចក្ដីតាមលំដាប់បទ

ក្នុងព្រះសូត្រនោះ ប្រការថា ជាផ្លូវតែមួយ គឺ ជាផ្លូវឯក ។ ពិតណាស់ ផ្លូវមានច្រើនឈ្មោះ គឺ ៖

**មគ្គៈ បន្ថៈ បថៈ បជ្ជៈ អញ្ជសៈ វដុមៈ អយនៈ**

**នាវា ឧត្តរសេតុ កុល្លៈ ភិសិសង្កមៈ ។**

ផ្លូវនោះ ក្នុងទីនេះ លោកពោលដោយឈ្មោះថា **អយនៈ** ព្រោះដូច្នោះ ក្នុងប្រការថា **ម្នាលភិក្ខុទាំងឡាយ ផ្លូវនេះជាផ្លូវមូលតែមួយ** នេះ

ទើបគួរឃើញសេចក្តីយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ផ្លូវនេះ ជាផ្លូវឯក មិនមែនផ្លូវបែកជាពីរ ។

ន័យមួយទៀត ឈ្មោះថា **ឯកាយនៈ** ព្រោះអត្ថវិគ្រោះថា ជាផ្លូវដែលបុគ្គលគប្បីទៅតែម្នាក់ឯង ។ ពាក្យថា **តែម្នាក់ឯង** គឺ អ្នកដែលលះការច្រឡូកច្រឡំដោយពួក ចៀសចេញទៅដោយស្ងប់ស្ងាត់ ។ ពាក្យថា **គប្បីទៅ** គឺ គប្បីធ្វើដំណើរទៅ ។

ន័យមួយទៀត ឈ្មោះថា **អយនៈ** ព្រោះអត្ថវិគ្រោះថា ជាគ្រឿងទៅ អធិប្បាយថា ចាកសង្សារវដ្តទៅកាន់ព្រះនិព្វាន ។ ផ្លូវទៅរបស់បុគ្គលម្នាក់ ឈ្មោះថា **ឯកាយនៈ** ។ បទថា ឯកស្ស គឺ របស់បុគ្គលដ៏ប្រសើរបំផុតនៃសព្វសត្វ ។ ក៏ព្រះមានព្រះភាគនោះ ទ្រង់ប្រសើរជាងសព្វសត្វ ព្រោះដូច្នោះ ទើបលោកអធិប្បាយថា ផ្លូវរបស់ព្រះមានព្រះ-ភាគ ។ សូម្បីសត្វពួកដទៃ នឹងដើរទៅដោយផ្លូវនោះក៏ពិតហើយ សូម្បីដូច្នោះ ផ្លូវនោះ ក៏ជាផ្លូវដើររបស់ព្រះមានព្រះភាគប៉ុណ្ណោះ ព្រោះជាផ្លូវដែលព្រះអង្គទ្រង់ធ្វើឲ្យកើតឡើង ។ ដូចត្រាស់ទុក ( ក្នុងគោបកមោគ្គល្លានសូត្រ ) ថា ម្នាលព្រាហ្មណ៍ ព្រោះថា ព្រះមានព្រះភាគអង្គនោះ ជាអ្នកធ្វើមគ្គដែលមិនទាន់កើត ឲ្យកើតឡើង ដូច្នេះជាដើម ។

ន័យមួយទៀត **ផ្លូវរមែងទៅ** ហេតុនោះ ទើបឈ្មោះថា **អយនៈ** អធិប្បាយថា ទៅ គឺ ប្រព្រឹត្តទៅ ។ ផ្លូវទៅក្នុងធម្មវិន័យតែមួយ ឈ្មោះថា **ឯកាយនៈ** លោកអធិប្បាយថា ផ្លូវប្រព្រឹត្តទៅក្នុងធម៌វិន័យនេះប៉ុណ្ណោះ មិនប្រព្រឹត្តទៅក្នុងធម្មបវិន័យ ( សាសនា ) ដទៃ ។ ដូចទ្រង់ត្រាស់ទុក ( ក្នុងមហាបរិនិព្វានសូត្រ ) ថា ម្នាលសុភទ្ទៈ មគ្គមានអង្គ ៨ ដែលជាអរិយៈ បុគ្គលដឹងបានតែក្នុងធម្មវិន័យនេះឯង ដូច្នេះ ។ ក៏មគ្គនោះ ផ្សេងគ្នាដោយទេសនា តែដោយអត្ថ ក៏ដូចគ្នានុ៎ះឯង ។

ន័យមួយទៀត **ផ្លូវ** រមែងទៅតែម្តង ហេតុនោះផ្លូវនោះ ទើបឈ្មោះ **ឯកាយនៈ** (ផ្លូវទៅតែម្តង) ។ លោកអធិប្បាយថា ផ្លូវ សូម្បីប្រព្រឹត្តទៅដោយមុខ គឺការនាមានន័យផ្សេង ៗ គ្នា ក្នុងខាងដើម ក្នុងខាងចុង ក៏ទៅកាន់ព្រះនិព្វានតែមួយដូចគ្នានុ៎ះឯង ។ ដូចដែលលោកពោលទុក ( ក្នុងសំយុត្តនិកាយមហាវារវគ្គ ) ថា ស្តេចសហម្បតីព្រហ្មក្រាបទូលព្រះមាន-ព្រះភាគថា

ឯកាយនំ ជាតិខយន្តទស្សី មគ្គំ បជានាតិ ហិតានកម្បី
ឯតេន មគ្គេន តរឹសុ បុព្វេ តរិស្សន្តិ យេ ច តរន្តិ ឱឃំ ។

ព្រះមានព្រះភាគ ទ្រង់ឃើញធម៌ជាទីអស់ទៅនៃជាតិ ទ្រង់ករុណា

អនុគ្រោះដោយប្រយោជន៍ ទ្រង់ជ្រាបច្បាស់ **ឯកាយនមគ្គ** ព្រះពុទ្ធទាំងឡាយក្នុងអតីត ទ្រង់ឆ្លងឱឃៈ ( ឱឃៈ ៤ ) ដោយមគ្គនោះមកហើយ ព្រះពុទ្ធទាំងឡាយក្នុងអនាគត ក៏នឹងឆ្លងឱឃៈដោយមគ្គនោះ និងព្រះពុទ្ធក្នុងបច្ចុប្បន្ន ក៏ឆ្លងឱឃៈដោយមគ្គនោះតែម្យ៉ាងដូចគ្នា ។

តែកេចិអាចារ្យពោលតាមន័យនៃគាថា ដែលថា ជនទាំងឡាយមិនទៅកាន់ត្រើយ (ព្រះនិព្វាន) ពីរដង ដូច្នេះថា ព្រោះហេតុបុគ្គលទៅព្រះនិព្វានបានតែមួយដង ដូច្នោះ ផ្លូវនោះ ទើបឈ្មោះថា **ឯកាយនៈ** ទៅតែមួយដង ។ ពាក្យនោះមិនត្រូវ ។ ព្រោះអត្ថនេះ នឹងគប្បីមានព្យញ្ជនៈយ៉ាងនេះថា សកឹ អយនោ ទៅតែមួយដង ។ ក៏ប្រសិនបើថា នឹងគប្បីប្រកបអត្ថពោលយ៉ាងនេះថា ការទៅតែមួយដង គឺ ប្រព្រឹត្តទៅមួយដងរបស់មគ្គនោះ ប្រព្រឹត្តទៅដូច្នេះ ព្យញ្ជនៈក៏គួរនឹងត្រឹមត្រូវ ។ តែអត្ថ មិនត្រូវទាំងពីរប្រការ ។ ព្រោះហេតុអ្វី ។ ក៏ព្រោះក្នុងទីនេះ លោកប្រាថ្នាយកតែមគ្គ ដែលជាចំណែកខាងដើម ។ ជាការពិត ក្នុងទីនេះលោកប្រាថ្នាយកតែមគ្គ ដែលមានសតិប្បដ្ឋានជាចំណែកខាងដើម ដែលប្រព្រឹត្តទៅដោយអារម្មណ៍ ៤ មានកាយជាដើម ។ មិនបានប្រាថ្នាយកមគ្គដែលជាលោកុត្តរៈ ។ សេចក្តីថា មគ្គដែលជាចំណែកខាងដើមនោះ រមែងប្រព្រឹត្តទៅសូម្បីច្រើន

ទាំងការប្រព្រឹត្តទៅរបស់មគ្គនោះ ក៏មិនមែនមានតែមួយជង ។

## ធម្មសាកច្ឆារបស់ព្រះមហាថេរៈ

ក្នុងសេចក្ដីនេះ ពីមុនព្រះមហាថេរៈទាំងឡាយ ក៏ធ្លាប់បានសន្ទនាគ្នាមកហើយ ។ ព្រះចុល្លនាគត្ថេរ អ្នកទ្រទ្រង់ព្រះត្រៃបិដកពោលថា សតិប្បដ្ឋាន ជាមគ្គខាងដើម (បុព្វភាគ) ។ ចំណែកលោកចុល្លសុមនត្ថេរ អ្នកទ្រទ្រង់ព្រះត្រៃបិដក អាចារ្យរបស់ព្រះចុល្លនាគត្ថេរ ពោលថា ជាមគ្គផ្សំ (មិស្សកៈ) ។ សិស្សថា ជាចំណែកខាងដើម លោកម្ចាស់ ។ អាចារ្យថា ជាមគ្គផ្សំណាលោក ។ តែកាលអាចារ្យនិយាយរឿយៗ ទៅ សិស្សក៏មិនជំទាស់ ហើយនៅស្ងៀម ។ ទាំងសិស្សទាំងអាចារ្យសម្រេចបញ្ហាគ្នាមិនបាន ក៏ក្រោកទៅ ។ ខាងក្រោយ ព្រះថេរៈជាអាចារ្យ ដើរទៅរោងស្រង់ទឹក គិតពិចារណាថា យើងពោលថា ជាមគ្គផ្សំ ចំណែកលោកចុល្លនាគកាន់យកគោល ពោលថា ជាចំណែកខាងដើម សេចក្ដីវិនិច្ឆ័យក្នុងសេចក្ដីនេះយ៉ាងណាហ្ន៎ កាលស្វាធ្យាយព្រះសូត្រ (មហាសតិប្បដ្ឋានសូត្រ) តាំងពីដើម ក៏កំណត់បានត្រង់នេះ ដែលថា ម្នាលភិក្ខុទាំងឡាយ បុគ្គលណាម្នាក់គប្បីចម្រើនសតិប្បដ្ឋាន ៤ ទាំងនេះ ដល់ ៧ ឆ្នាំ ក៏ដឹងថា លោកុត្តរមគ្គ

កើតឡើងហើយ ឈ្មោះថា តាំងនៅដល់ ៧ ឆ្នាំ មិនមាន ដែលយើងពោលថា ជាមគ្គផ្សំ រមែងមិនត្រូវ ចំណែកលោកចុល្លនាគឃើញថា ជាមគ្គចំណែកខាងដើម រមែងត្រូវ កាលគេប្រកាសការស្តាប់ធម៌ថ្ងៃ ៨ កេចលោកក៏ទៅ ។

បានឮមកថា ព្រះថេរៈចាស់ ៗ ជាអ្នកស្រឡាញ់ការស្តាប់ធម៌ គ្រាបានឮសំឡេងប្រកាស ក៏បន្លឺសំឡេងតែមួយថា ខ្ញុំមុន ខ្ញុំមុន ។ ថ្ងៃនោះជាវារៈរបស់ព្រះចុល្លនាគត្ថេរ ។ លោកអង្គុយលើធម្មាសនៈ ចាប់ផ្តើតពោលគាថាខាងដើម ព្រះថេរៈជាអាចារ្យនៅក្រោយអាសនៈ ក៏គិតថា នឹងអង្គុយកំបាំង ៗ មិននិយាយចរចា ។ ពិតហើយ ព្រះថេរៈចាស់ ៗ មិនប្រស្សាគ្នា មិនចាប់យកសេចក្តីពេញចិត្តរបស់ខ្លួនឡើងជាការៈ ដូចជាលីកំណាត់អំពៅ កាន់យកតែហេតុ (ដែលគួរ) ប៉ុណ្ណោះ ដែលមិនមែនក៏លះបង់ទៅ ព្រោះដូច្នោះ ព្រះចុល្លសុមនត្ថេរ ទើបហៅលោកចុល្លនាគតិច ៗ លោកចុល្លនាគត្ថេរបានឮដូចសំឡេងអាចារ្យហៅ ទើបឈប់ធម្មកថា សួរថា អ្វីលោកម្ចាស់ ។ អាចារ្យពោលថា លោកចុល្លនាគ ដែលយើងពោលថា ជាមិស្សកមគ្គនោះ មិនត្រូវទេ ចំណែកដែលលោកពោលថា សតិប្បដ្ឋានជាមគ្គខាងដើម ត្រូវហើយ ។ ព្រះចុល្លនាគត្ថេរគិតថា អាចារ្យរបស់យើង

ទ្រទ្រង់បរិយត្តិធម៌ទុកទាំងអស់ ជាសុតពុទ្ធ ព្រះត្រៃបិដកដែលភិក្ខុបែបនេះនៅខ្វល់ខ្វាយនឹងបញ្ហាច្រើន តទៅខាងមុខ ព្រះធម្មកថិកទាំងឡាយនឹងខ្វល់ខ្វាយចំពោះបញ្ហាប្រភេទនេះ ព្រោះដូច្នោះ យើងនឹងកាន់យកព្រះសូត្រជាគោល ធ្វើបញ្ហាប្រភេទនេះ មិនឲ្យខ្វល់ខ្វាយតទៅ ។ សតិប្បដ្ឋានជាមគ្គខាងដើម តែក្នុងបដិសម្ភិទាមគ្គ ហៅថា **ឯកាយនមគ្គ** ។ លោកទើបនាំព្រះសូត្រ ( ក្នុងធម្មបទខុទ្ទកនិកាយ ) តាំងជាបទឧទ្ទេសឡើង ៖

មគ្គានដ្ឋង្គិកោ សេដ្ឋោ សច្ចានំ ចតុរោ បទា
វិរាគោ សេដ្ឋោ ធម្មានំ ទិបទានញ្ច ចក្ខុមា ។
ឯសេវ មគ្គោ នត្ថញ្ញោ ទស្សនស្ស វិសុទ្ធិយា
ឯតញ្ហិ តុម្ហេ បដិបជ្ជថ មារសេនប្បមទ្ទនំ
ឯតញ្ហិ តុម្ហេ បដិបន្នា ទុក្ខស្សន្តំ ករិស្សថ ។

បណ្តាផ្លូវទាំងឡាយ ផ្លូវមានអង្គ ៨ ប្រសើរបំផុត , បណ្តាសច្ចៈទាំងឡាយ បទទាំង ៤ ( អរិយសច្ចៈ ) ប្រសើរបំផុត , បណ្តាធម៌ទាំងឡាយ វិរាគធម៌ ប្រសើរបំផុត , បណ្តាសត្វជើងពីរទាំងឡាយ ព្រះពុទ្ធមានចក្ខុ ប្រសើរបំផុត ផ្លូវនេះប៉ុណ្ណោះ ដើម្បីសេចក្តីបរិសុទ្ធិនៃទស្សនៈ ផ្លូវដទៃ

**មិនមានទេ អ្នកទាំងឡាយ ចូរដើរផ្លូវនេះ ដែលជាគ្រឿង**

**កម្ចាត់សេនាមារ អ្នកទាំងឡាយដើរផ្លូវនេះហើយ នឹងធ្វើ**

**ទីបំផុតទុក្ខបាន ដូច្នេះ ។**

## អធិប្បាយមគ្គ

ក្នុងប្រការថា មគ្គោ ដែលឈ្មោះថា **មគ្គ** ព្រោះអត្ថថា ដូចម្តេច ? ។ ព្រោះអត្ថថា ជាគ្រឿងដំណើរទៅកាន់ព្រះនិព្វាន ១ , ព្រោះអត្ថថា អ្នកដែលត្រូវការព្រះនិព្វាន គប្បីស្វែងរក ១ ។

ប្រការថា **ដើម្បីសេចក្តីបរិសុទ្ធិនៃសត្វទាំងឡាយ** មានន័យថា ដើម្បីប្រយោជន៍ដល់សេចក្តីបរិសុទ្ធិនៃសត្វទាំងឡាយអ្នកមានចិត្តសៅហ្មង ព្រោះមន្ទិលទាំងឡាយ មានរាគៈជាដើម និងព្រោះឧបក្កិលេសទាំងឡាយ មានអភិជ្ឈាវិសមលោភៈជាដើម ជាការពិត សត្វទាំងនេះ គឺ ព្រះសម្មាសម្ពុទ្ធទាំងឡាយជាអនេក តាំងពីព្រះពុទ្ធ ព្រះនាមថា តណ្ហង្ករ មេធង្ករ សរណង្ករ ទីបង្ករ ដែលបរិនិព្វានក្នុងកប្បតែមួយប៉ុណ្ណោះ ខាងដើមតាំងអំពី ៤ អសង្ខេយ្យ ១ សែនកប្ប តែកប្បនេះចុះមក ដរាបដល់ព្រះពុទ្ធព្រះនាមថា សក្យមុនី ជាទីបំផុត ព្រះបច្ចេកពុទ្ធច្រើនរយ ឯព្រះអរិយ-

សាវកទាំងឡាយទៀតរាប់មិនបាន បានបណ្ដិតមន្ទិលផ្លូវចិត្តទាំងអស់ ដល់សេចក្ដីបរិសុទ្ធិយ៉ាងក្រៃលែង ដោយផ្លូវនេះប៉ុណ្ណោះ ។ ការបញ្ញត្តិសេចក្ដីសៅហ្មង និងផូរផង់ ដោយមន្ទិលព្រោះរូបតែម្យ៉ាង មិនមាន ។ សមពិតដូចពាក្យដែលត្រាស់ទុកថា ៖

រូបេន សង្កិលិដ្ឋេន    សង្កិលិស្សន្តិ មាណវា
រូបេ សុទ្ធេ វិសុជ្ឈន្តិ    អនក្ខាតំ មហេសិនា
ចិត្តេន សង្កិលិដ្ឋេន    សង្កិលិស្សន្តិ មាណវា
ចិត្តេ សុទ្ធេ វិសុជ្ឈន្តិ    ឥតិ វុត្តំ មហេសិនា ។

*ព្រះពុទ្ធ ទ្រង់ស្វែងរកគុណដ៏ធំក្រៃលែង មិនបានត្រាស់ទូន្មានថា អ្នកទាំងឡាយមានរូបសៅហ្មងហើយ ទើបសៅ-ហ្មង មានរូបបរិសុទ្ធិហើយ ទើបបរិសុទ្ធិ តែព្រះអង្គទ្រង់ស្វែងរកគុណដ៏ធំក្រៃលែង ទ្រង់ទូន្មានថា អ្នកទាំងឡាយមានចិត្តសៅហ្មងហើយ ទើបសៅហ្មង មានចិត្តបរិសុទ្ធហើយ ទើបបរិសុទ្ធិ ដូច្នេះ ។*

ដូចដែលត្រាស់ទុក (ក្នុងសំយុត្តនិកាយខន្ធវារវគ្គ) ថា ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយសៅហ្មង ព្រោះចិត្តសៅហ្មង រមែងបរិសុទ្ធិ

ព្រោះចិត្តបរិសុទ្ធិ ដូច្នេះ ។ ក៏សេចក្តីផូរផង់នៃចិត្តនោះ រមែងមានដោយមគ្គ គឺ សតិប្បដ្ឋាននេះ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ថា ដើម្បីសេចក្តីបរិសុទ្ធិនៃសត្វទាំងឡាយ ។

ប្រការថា **ដើម្បីឈានកន្លងសោកៈ និងបរិទេវៈ** មានន័យថា ដើម្បីឈានកន្លង គឺ លះបង់សោកៈ និងបរិទេវៈ ។ ពិតហើយ មគ្គនេះដែលបុគ្គលចម្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីឈានកន្លងសោកៈ ដូចសោកៈរបស់សន្តតិមហាមាត្យជាដើម ដើម្បីឈានកន្លងបរិទេវៈ ដូចបរិទេវៈរបស់នាងបដាចារាជាដើម ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា ដើម្បីឈានកន្លងសោកៈ និងបរិទេវៈ ។ ពិតហើយ សន្តតិមហាមាត្យស្តាប់គាថា ដូច្នេះថា ៖

យំ បុព្វេ តំ វិសោធេហិ　បច្ឆា តេ មាហុ កិញ្ចនំ
មជ្ឈេ ចេ នោ គហេស្សសិ　ឧបសន្តោ ចរិស្សសិ ។

**អ្នកចូរធ្វើសេចក្តីសោកក្នុងកាលមុនឲ្យហួតហែង អ្នកកុំមានសេចក្តីកង្វល់ចិត្តក្នុងកាលជាខាងក្រោយ បើអ្នកមិនប្រកាន់ក្នុងចំណែកកណ្តាល ក៏នឹងជាបុគ្គលស្ងប់ត្រាច់ទៅ ដូច្នេះ ។**

ហើយក៏សម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទា ព្រះនាងបដាចារា

ស្តាប់ព្រះគាថានេះ ដូច្នេះថា ៖

ន សន្តិ បុត្តា តាណាយ ន បិតា នបិ ពន្ធវា
អន្តកេនាធិបន្នស្ស នត្ថិ ញាតីសុ តាណតា

**មានបុត្តទុកដើម្បីជួយក៏មិនបាន បិតាក៏មិនបាន ទាំងផៅពង្ស ក៏មិនបាន កាលបើសេចក្តីស្លាប់មកដល់ខ្លួនហើយ ញាតិ ទាំងឡាយក៏ជួយមិនបាន ដូច្នេះ ។**

ហើយក៏តាំងនៅក្នុងសោតាបត្តិផល ក៏ព្រោះហេតុថា ឈ្មោះថា ការមិនពាល់ត្រូវធម៌ណាខ្លះ ក្នុងកាយ វេទនា ចិត្ត ធម៌ទាំងឡាយហើយ កាវនាមិនមានឡើយ ដូច្នោះ សន្តតិមហាមាត្យ និងនាងបដាចារា សូម្បី នោះ ទើបគួរជ្រាបថា ជាអ្នកឈានកន្លងសោកៈ និងបរិទេវៈដោយមគ្គ នេះឯង ។

ប្រការថា **ដើម្បីរលត់ និងទោមនស្ស** មានន័យថា ដើម្បីតាំង នៅមិនបាន គឺ រលត់ទាំងពីរនេះ គឺ ទុក្ខផ្លូវកាយ និងទោមនស្សផ្លូវចិត្ត ។ សេចក្តីថា មគ្គនេះ បុគ្គលចម្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីរលត់ទុក្ខ ដូចទុក្ខរបស់ព្រះតិស្សត្ថេរជាដើម រលត់ទោមនស្ស ដូចទោមនស្សរបស់ ស្តេចសក្កៈជាដើម ។ ក្នុងរឿងទាំងពីរនោះ សម្តែងសេចក្តីរលត់ដូចតទៅ

នេះ ។

## រឿង ឧក្ខរបស់ព្រះតិស្សត្ថេរ

បានឮមកថា ក្នុងក្រុងសាវត្ថី បុត្ររបស់កុដុម្ពីឈ្មោះតិស្សៈ លះទ្រព្យ ៤០ កោដិ ចេញបួសនៅតែម្នាក់ឯងក្នុងព្រៃ មិនមានផ្ទះ ។ ភរិយារបស់ប្អូនប្រុសលោក បញ្ជូនចោរ ៥០០ ឲ្យទៅសម្លាប់លោក ។ ពួកចោរទៅឡោមព័ទ្ធលោក ។ លោកទើបសួរថា ឧបាសក លោកនាំគ្នាមកធ្វើអ្វី ។ ពួកចោរឆ្លើយថា មកសម្លាប់លោកហ្នឹងឯង ។ លោកទើបនិយាយសូមអង្វរថា ឧបាសកទាំងឡាយ មេត្តាទទួលធានាអាត្មា ឲ្យជីវិតអាត្មាត្រឹមតែមួយយប់ចុះ ។ ពួកចោរពោលថា សមណៈណានឹងធានាលោកក្នុងឋានៈយ៉ាងនេះបាន ។ ព្រះថេរៈក៏ចាប់ថ្មដុំធំគប់ឆ្អឹងស្មងជើងទាំងពីរខាង ហើយពោលថា ធានាល្មមទេ ។ ពួកចោរទាំងនោះ ក៏មិនទាន់គេចទៅ ត្រឡប់មកបង្កាត់ភ្លើងដេកក្នុងទីជិតចង្ក្រម ព្រះថេរៈគ្របសង្កត់វេទនា ពិចារណាសីល អាស្រ័យសីលដែលបរិសុទ្ធិ ក៏កើតបីតិ និងបាមោជ្ជៈ ។ លំដាប់តពីនោះ ក៏ចម្រើនវិបស្សនា ធ្វើសមណធម៌រហូតអស់មួយយប់ ក្នុងយាមទាំងបី ពេលអរុណរះ ក៏សម្រេចព្រះអរហត្ត

ទើបថ្លែងឧទានថា ៖

ឧភោ បាទានិ ភិន្ទិត្វា    សញ្ញមិស្សាមិ តេ អហំ
អដ្ដិយាមិ ហរាយាមិ    សរាគមរណោ    អហំ
ឯវាហំ ចិន្តយិត្វាន    យថាភូតំ    វិបស្សិសំ
សម្បត្តេ អរុណុគ្គម្ហិ    អរហត្តំ    អបាបុណឹ

*យើងគប់ជើងពីរខាង ការពារលោកទាំងឡាយ យើងធុញទ្រាន់ក្នុងសេចក្ដីស្លាប់ទាំងដែលនៅមានរាគៈ យើងគិតយ៉ាងនេះហើយ ក៏ឃើញច្បាស់តាមសេចក្ដីពិត ពេលអរុណរះមកដល់ យើងក៏សម្រេចព្រះអរហត្ត ដូច្នេះ ។*

## រឿង ទុក្ខរបស់ភិក្ខុ ៣០ រូប

ភិក្ខុ ៣០ រូប មួយក្រុមទៀត រៀនកម្មដ្ឋានក្នុងសម្នាក់របស់ព្រះមានព្រះភាគហើយ ចាំវស្សាក្នុងព្រៃ ធ្វើកតិកាគ្នាថា អ្នកមានអាយុ យើងគួរធ្វើសមណធម៌ រហូតអស់មួយយប់ក្នុងយាមទាំងបី យើងមិនគួរមកកាន់សម្នាក់នៃគ្នានិងគ្នា ហើយក៏ទៅកាន់ទីផ្សេងៗ គ្នា ។ កាលភិក្ខុទាំងនោះធ្វើសមណធម៌ ក្នុងពេលជិតភ្លឺក៏ដេកលក់ ខ្លាមួយក្បាលក៏មកចាប់

ភិក្ខុទៅស៊ី មួងមួយរូប ៗ ។ ភិក្ខុណា ៗ ក៏មិនបានបញ្ចេញសូម្បីវាចាថា ខ្លាចាប់ខ្ញុំហើយ ។ ភិក្ខុត្រូវខ្លាស៊ីរហូត ១៥ រូប ដោយអាការៈយ៉ាងនេះ ដល់ថ្ងៃឧបោសថ ភិក្ខុដ៏សេស ក៏សួរថា លោកនៅទីណា ក៏បានដឹងរឿង ហើយពោលថា បើត្រូវខ្លាចាប់ គប្បីប្រាប់ថា ឥឡូវនេះយើងត្រូវខ្លាចាប់ ហើយ ក៏នៅបន្តទៅ ។ តមកខ្លាក៏ចាប់ភិក្ខុកម្លោះមួយរូប ដោយន័យមុន ។ ភិក្ខុកម្លោះក៏ស្រែកថា ខ្លា លោកម្ចាស់ ។ ភិក្ខុទាំងឡាយក៏កាន់ឈើប្រត់ និងគប់ភ្លើងដេញតាម បំណងថា នឹងឲ្យវាព្រលែង ខ្លាក៏ឡើងទៅកាន់ទី ដាច់នៃភ្នំ ដែលភិក្ខុទាំងឡាយទៅមិនបាន ផ្តើមស៊ីភិក្ខុនោះតាំងពីជើង ។ ភិក្ខុទាំងឡាយក្រៅនោះ ក៏បានតែពោលថា សប្បុរស ឥឡូវនេះ កិច្ចដែល ពួកយើងនឹងត្រូវធ្វើមិនមាន ដែលឈ្មោះថា សេចក្តីវិសេសរបស់ភិក្ខុ ទាំងឡាយ រមែងប្រាកដក្នុងឋានៈ ដូច្នេះ ។ ភិក្ខុកម្លោះនោះ ដេកនៅក្នុង មាត់ខ្លា គ្របសង្កត់វេទនាដែលឈឺចុកចាប់ ហើយចម្រើនវិបស្សនា ពេល ខ្លាស៊ីដល់កជើង ជាព្រះសោតាបន្ន ពេលស៊ីទៅដល់ក្បាលជង្គង់ ជាព្រះ សកទាគាមី ពេលខ្លាស៊ីទៅដល់ពោះ ជាព្រះអនាគាមី ពេលខ្លាស៊ីជិតដល់ បេះដូង ក៏សម្រេចព្រះអរហត្ត ព្រមដោយបដិសម្ភិទា ទើបថ្លែងឧទាន ដូច្នេះថា ៖

សីលវា វត្តសម្បន្នោ បញ្ញវា សុសមាហិតោ
មុហុត្តំ បមាទមន្វាយ ព្យគ្ឃេ នោ រុទ្ធមានសោ
បញ្ជរស្មិំ សោ គហេត្វា សិលាយ ឧបរី កតោ
កាមំ ខាទតុ មំ ព្យគ្ឃោ អដ្ឋិយា ច ន្ហារុស្ស ច
កិលេសេ ខេបយិស្សាមិ ផុសិស្សាមិ វិមុត្តិយំ ។

*យើងមានសីល ដល់ព្រមដោយវត្ត មានបញ្ញា មានចិត្តតាំងមាំល្អហើយ អាស្រ័យសេចក្តីប្រមាទមួយភ្លែត ទាំងដែលមានចិត្តមិនគិតប្រទូស្តក្នុងខ្លា វាក៏ចាប់ទុកក្នុងក្រញាំក្រចក នាំទៅទុកលើដុំថ្ម ខ្លាស៊ីយើងដល់ឆ្អឹង និងសរសៃក៏ដោយ យើងនឹងធ្វើកិលេសឲ្យអស់ទៅ នឹងពាល់ត្រូវវិមុត្តិ ដូច្នេះ ។*

## រឿង ទុក្ខរបស់ព្រះបីតិមល្លត្ថេរ

*ភិក្ខុមួយរូបទៀត ឈ្មោះ បីតិមល្លត្ថេរ គ្រាជាគ្រហស្ថ លោកកាន់ទង់មកកោះលង្កា ដល់ ៣ រជ្ជកាល ចូលគាល់ព្រះរាជា ហើយបានទទួលព្រះរាជានុគ្រោះ ថ្ងៃមួយ ធ្វើដំណើរទៅកាន់ទ្វារសាលា ដែលមានទីអង្គុយ*

ក្រោលដោយកន្ទេលផែង បានស្តាប់នូវតុម្ហាកវគ្គ (ក្នុងសំយុត្តនិកាយខន្ធវារវគ្គ) ថា ម្នាលភិក្ខុទាំងឡាយ រូបមិនមែនរបស់អ្នក អ្នកចូរលះបង់រូបនោះចេញ រូបនោះអ្នកលះបង់បានហើយ នឹងមានប្រយោជន៍ ដើម្បីសេចក្តីសុខរហូតអស់កាលយូរ ដូច្នេះហើយក៏គិតថា មិនមែនតែរូបប៉ុណ្ណោះទេ វេទនាក៏មិនមែនរបស់ខ្លួន ។ គេធ្វើព្រះបាលីនោះឲ្យជាប្រធាន ហើយចេញទៅកាន់មហាវិហារ សូមបួសបព្វជ្ជាឧបសម្បទា ហើយធ្វើមាតិកាទាំងពីរឲ្យស្ទាត់ជំនាញ នាំភិក្ខុ ៣០ រូប ទៅកាន់លានក្នុងតំបន់គវបរបាលី ធ្វើសមណធម៌ ។ កាលជើងដើរមិនបាន ក៏លុតជង្គង់ដើរចង្រ្កម ។ ក្នុងយប់នោះ ព្រាហ្មណ៍ម្រឹគម្នាក់សម្គាល់ថា ម្រឹគ ក៏ពួយលំពែងចេញទៅ ។ លំពែងក៏ទៅត្រូវលោកដល់ធ្លុះ លោកក៏ឲ្យគេនាំលំពែងចេញ យកស្មៅញាត់មុខរបួស ឲ្យគេលើកខ្លួនអង្គុយលើផ្ទាំងថ្ម ឲ្យគេបើកឱកាស ចម្រើនវិបស្សនា ក៏សម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទា ព្យាករណ៍ដល់ភិក្ខុទាំងឡាយដែលនាំគ្នាមក ដោយឲ្យសំឡេងក្អកគ្រហែម បន្លឺឧទានដូច្នេះថា ៖

ភាសិតំ ពុទ្ធសេដ្ឋស្ស សព្វលោកគ្គវាទិនោ
ន តុម្ហាកមិទំ រូបំ តំ ជហេយ្យាថ ភិក្ខវោ
អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ

ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោ។

ព្រះពុទ្ធដ៏ប្រសើរបំផុត ដែលពោលសរសើរថា កំពូលលើសលោកទាំងពួង ទ្រង់ភាសិតទុកថា ម្នាលភិក្ខុទាំងឡាយ រូបនេះមិនមែនរបស់អ្នក អ្នកទាំងឡាយគប្បីលះបង់រូបនោះចេញ ។

សង្ខារទាំងឡាយមិនទៀងហ្ន៎ មានការកើត និងវិនាសទៅជាធម្មតា កើតហើយក៏រលត់ ការស្ងប់រម្ងាប់នៃសង្ខារទាំងនោះ ជាសុខ ដូច្នេះ ។

មគ្គនេះ រមែងប្រព្រឹត្តទៅដើម្បីរលត់ទុក្ខ ដូចជាទុក្ខរបស់ព្រះ-តិស្សត្ថេរជាដើម ត្រឹមតែប៉ុណ្ណេះមុន ។

## រឿង ទោមនស្សរបស់ស្តេចសក្កៈ

ស្តេចសក្កទេវរាជ ទ្រង់ឃើញបុព្វនិមិត្ត ៥ ប្រការ របស់ព្រះអង្គត្រូវមរណភ័យគ្របសង្កត់ កើតទោមនស្ស ចូលគាល់ព្រះមានព្រះភាគទូលសួរបញ្ហា ។ ស្តេចក៏តាំងនៅក្នុងសោតាបត្តិផលព្រមដោយទេវតា ៨ ម៉ឺនអង្គ ដោយអំណាចការវិសជ្ជនាឧបេក្ខាបញ្ហា ។ រឿងការឧប្បត្តិរបស់

ស្តេចសក្កៈ ទើបត្រឡប់ជាប្រក្រតីវិញ ។

# រឿង ទោមនស្សរបស់សុព្រហ្មទេវបុត្រ

សូម្បីសុព្រហ្មទេវបុត្រ ដែលនាងទេពអប្សរ ១.០០០ ហែហម ក៏សោយសួគ៌សម្បត្តិ ។ ក្នុងចំនួននាងទេពអប្សរ ១.០០០ នោះ នាងទេពអប្សរ ៥០០ រវល់តែបេះផ្កាឈើពីដើម ក៏ចុតិទៅកើតក្នុងនរក សុព្រហ្មទេវបុត្ររំពឹងថា ហេតុដូចម្តេច ទេពអប្សរទាំងនេះទើបយឺតយូរម្ល៉េះ ក៏ដឹងថា ពួកនាងទៅកើតក្នុងនរក ទើបបែរមកពិចារណាមើលខ្លួនឯងថា អាយុប៉ុន្មានហើយហ្ន៎ ក៏ដឹងថា ខ្លួននឹងអស់អាយុ នឹងទៅកើតក្នុងនរកនោះដែរ ក៏ភ័យខ្លាច កើតទោមនស្សយ៉ាងក្រៃលែង ឃើញថា ព្រះបរមសាស្តាប៉ុណ្ណោះ នឹងញ៉ាំងសេចក្តីទោមនស្សរបស់យើងនេះឲ្យវិនាសទៅ មិនមានអ្នកដទៃ ហើយក៏នាំនាងទេពអប្សរ ៥០០ ដ៏សេស ចូលគាល់ព្រះមានព្រះភាគ ទូលសួរបញ្ហាថា ៖

និច្ចុត្រស្តមិទំ ចិត្តំ និច្ចុព្វិគ្គមិទំ មនោ
អនុប្បន្នេសុ កិច្ចេសុ អថោ ឧប្បត្តិតេសុ ច
សចេ អត្ថិ អនុត្តរស្តំ តំ មេ អក្ខាហិ បុច្ឆិតោ

ចិត្តនេះតក់ស្លុតជានិច្ច ចិត្តនេះរន្ធត់ជានិច្ច ទាំងក្នុងកិច្ចដែល មិនទាន់កើត ទាំងក្នុងកិច្ចដែលកើតឡើងហើយ ប្រសិនបើ ថា ការមិនរន្ធត់តក់ស្លុតមាន សូមព្រះអង្គប្រាប់ ដែលត្រូវ ទូលសួរហើយ ទ្រង់មេត្តាប្រោសប្រាប់ ការមិនភ័យតក់- ស្លុតនោះ ដល់ខ្ញុំព្រះអង្គផងចុះ ។

លំដាប់នោះ ព្រះមានព្រះភាគ ទើបបានត្រាស់ប្រាប់សុព្រហ្ម- ទេវបុត្រ (ក្នុងសំយុត្តនិកាយសគាថវគ្គ) ដូច្នេះថា ៖

នាញ្ញត្រ ពោជ្ឈា តបសា នាញ្ញត្រ ឥន្ទ្រិយសំវរា
នាញ្ញត្រ សព្វបដិនិស្សគ្គា សោត្ថឹ បស្សាមិ ចាណិនំ

ក្រៅពីបញ្ញាជាគ្រឿងដឹង តបៈជាគ្រឿងដុតសេចក្តីអាក្រក់ ក្រៅពីសេចក្តីសង្រួមឥន្ទ្រិយ ក្រៅពីការលះបង់នូវគ្រប់ យ៉ាង តថាគតមើលមិនឃើញសួស្តីរបស់ពួកសត្វ ដូច្នេះ ។

ក្នុងទីបំផុតទេសនា សុព្រហ្មទេវបុត្រក៏តាំងនៅក្នុងសោតាបត្តិផល ព្រមដោយនាងទេពអប្សរ ៥ រយ ធ្វើសម្បត្តិនោះឲ្យថាវរៈហើយ ត្រឡប់ ទៅកាន់ទេវលោក ។

មគ្គនេះ ដែលបុគ្គលចម្រើនហើយ បណ្ឌិតគប្បីជ្រាបថា រមែង

ប្រព្រឹត្តទៅដើម្បីរលត់ទោមនស្ស ដូចទោមនស្សរបស់ស្តេចសក្កៈ ជាដើម ដូចពោលមកនេះ ។

មគ្គមានអង្គ ៨ ដែលជាអរិយៈ ហៅថា **ញេយ្យធម៌** ក្នុងពាក្យដែលថា ញាយស្ស អធិគមាយ លោកអធិប្បាយថា ដើម្បីសម្រេច គឺ ដើម្បីដល់ញេយ្យធម៌នោះ ។ ពិតហើយ មគ្គ គឺ សតិប្បដ្ឋានដែលជាលោកិយៈជាខាងដើមនេះ ដែលបុគ្គលចម្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីសម្រេចមគ្គដែលជាលោកុត្តរៈ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា ដើម្បីសម្រេចញេយ្យធម៌ ។

បទថា និព្វានស្ស សច្ឆិកិរិយា លោកអធិប្បាយថា ដើម្បីធ្វើឲ្យច្បាស់ គឺ ដើម្បីប្រចក្សដោយខ្លួនឯង នូវអមតធម៌ ដែលបានឈ្មោះថា **និព្វាន** ព្រោះវៀរចាកតណ្ហាជាគ្រឿងរួបរឹត ។ ពិតណាស់ មគ្គនេះ ដែលបុគ្គលចម្រើនហើយ រមែងធ្វើឲ្យច្បាស់ព្រះនិព្វាន ឲ្យសម្រេចទៅតាមលំដាប់ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ថា ដើម្បីធ្វើឲ្យច្បាស់ព្រះនិព្វាន ដូច្នេះ ។

ក្នុងព្រះសូត្រនោះ សូម្បីកាលព្រះមានព្រះភាគត្រាស់ថា ដើម្បីសេចក្តីបរិសុទ្ធិនៃសត្វទាំងឡាយហើយ ពាក្យដែលថា ដើម្បីឈានកន្លង

សោកៈ និងបរិទេវៈជាដើម ជាការសម្រេចសេចក្ដីបានក៏ពិត វៀរលែង តែអ្នកឆ្លាត ដឹងការយុតិរបស់ពាក្យប្រៀនប្រដៅចេញហើយ ក៏មិនប្រាកដ ដល់អ្នកដទៃ ៗ បាន តែព្រះមានព្រះភាគ ទ្រង់មិនបានធ្វើឲ្យជនអ្នកឆ្លាត ដឹងការយុតិរបស់ពាក្យប្រៀនប្រដៅជាមុន ហើយទ្រង់សម្ដែងធម៌ក្នុងខាង ក្រោយទេ តែបើទ្រង់ញ៉ាំងជនទាំងឡាយឲ្យដឹងអត្ថនោះ ៗ ដោយសូត្រ នោះ ៗ តែម្ដង ព្រោះដូច្នោះ ក្នុងទីនេះ **ឯកាយនមគ្គ** នឹងញ៉ាំងអត្ថណា ៗ ឲ្យសម្រេចបាន ក៏ទ្រង់សម្ដែងអត្ថនោះ ៗ ឲ្យប្រាកដ ទើបត្រាស់ថា ដើម្បី ឈានកន្លងសេចក្ដីសោកៈ និងសេចក្ដីខ្សឹកខ្សួលជាដើម ។ ឬន័យមួយទៀត សេចក្ដីបរិសុទ្ធិរបស់សត្វទាំងឡាយ រមែងប្រព្រឹត្តទៅបានដោយ **ឯកាយ-នមគ្គ** សេចក្ដីបរិសុទ្ធិនោះ រមែងមានដោយការឈានកន្លងសោកៈ និងបរិទេវៈ ការឈានកន្លងសោកៈ និងបរិទេវៈ រមែងមានដោយការរលត់ទុក្ខ និង ទោមនស្ស ការរលត់ទុក្ខ និងទោមនស្ស រមែងមានដោយការសម្រេច ញេយ្យធម៌ ការសម្រេចញេយ្យធម៌ រមែងមានដោយការធ្វើឲ្យច្បាស់ ព្រះនិព្វាន ព្រោះដូច្នោះ កាលទ្រង់សម្ដែងលំដាប់ន័យយ៉ាងនេះ ទើបត្រាស់ ថា ដើម្បីសេចក្ដីបរិសុទ្ធិនៃសត្វទាំងឡាយ ហើយត្រាស់បទថា **ដើម្បី ឈានកន្លងនូវសេចក្ដីសោក និងសេចក្ដីខ្សឹកខ្សួល** ជាដើម ។

ន័យមួយទៀត ពាក្យដែលពោលមកនេះ ជាការពណ៌នាគុណរបស់ **ឯកាយនមគ្គ** ។ ប្រៀបដូចព្រះមានព្រះភាគ បានត្រាស់គុណដោយបទទាំង ៨ ដោយធម្មទេសនា ( ធម្មសូត្រ មជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ ) ថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងធម៌ចំពោះអ្នកទាំងឡាយ មានលម្អបទដើម មានលម្អបទកណ្តាល មានលម្អបទចុង និងប្រកាសព្រហ្មចរិយៈដ៏បរិសុទ្ធិបរិបូណ៌សព្វគ្រប់ ព្រមទាំងអត្ថ ព្រមទាំងព្យញ្ជនៈ គឺ ធម្មធម៌ ដូច្នេះ យ៉ាងណា និងត្រាស់គុណដោយបទទាំង ៩ ដោយអរិយវង្សទេសនា (អង្គុត្តរនិកាយ ចតុក្កនិបាត) ថា ម្នាលភិក្ខុទាំងឡាយ អរិយវង្ស ៤ ទាំងនេះ ដែលដឹងបានថា ជាកំពូលដ៏លើសមានមកយូរ ជាវង្សព្រះអរិយៈ ជារបស់ចាស់ ក្នុងអតីតក៏មិនមានអ្នកណារង្កៀស មិនធ្លាប់រង្កៀស ក្នុងបច្ចុប្បន្នក៏មិនរង្កៀស ក្នុងអនាគតក៏នឹងមិនរង្កៀស សមណព្រាហ្មណ៍ជាបណ្ឌិតក៏មិនរង្កៀស ដូច្នេះ យ៉ាងណា ព្រះមានព្រះភាគ ក៏បានត្រាស់គុណរបស់ **ឯកាយនមគ្គ** សូម្បីយ៉ាងនេះ ដោយបទទាំង ៧ នេះថា ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយជាដើម ក៏ដូច្នោះ ។ បើនឹងសួរថា ព្រោះហេតុអ្វី ក៏ឆ្លើយបានថា ដើម្បីឲ្យកើតឧស្សាហ៍ដល់ភិក្ខុទាំងនោះ ។ ពិតណាស់ ភិក្ខុទាំងនោះ ស្តាប់ការត្រាស់គុណ (របស់ឯកាយនមគ្គ ) ដឹងថា

មគ្គនេះនាំចេញទៅ នូវឧបទ្រវៈ ៤ គឺ សោកៈ ដែលជាគ្រឿងដុតចិត្ត , បរិទេវៈ ដែលជាការយំរៀបរាប់ , ទុក្ខៈ ដែលជាការមិនសប្បាយផ្លូវកាយ , ទោមនស្ស ដែលជាការមិនសប្បាយផ្លូវចិត្ត នាំមកដែលគុណវិសេស ៣ គឺ **វិសុទ្ធិ ញេយ្យធម៌ ព្រះនិព្វាន** ដូច្នេះហើយ ក៏កើតឧស្សាហ៍សម្គាល់ទេសនានេះថា គួរឮ គួររៀន គួរចងចាំ គួរប្រាប់ គួរពោល និងនឹងសម្គាល់មគ្គយ៉ាងនេះថា គួរចម្រើន ។ ព្រោះដូច្នោះ ព្រះមាន-ព្រះភាគ បានត្រាស់គុណ ( របស់ឯកាយនមគ្គ ) ដើម្បីឲ្យកើតឧស្សាហ៍ដល់ភិក្ខុទាំងនោះ ដូចឈ្មួញសម្ពត់កម្ពលជាដើម ឃោសនាគុណភាពរបស់សម្ពត់កម្ពល ជាដើមដូច្នោះ ។

ដូចសេចក្ដីថា សូម្បីថា ឈ្មួញសម្ពត់កម្ពលដែលមានតម្លៃរាប់សែន ឃោសនាថា មេត្តាទិញសម្ពត់កម្ពល មនុស្សទាំងឡាយក៏មិនទាន់ជ្រាបជាមុនថា ខ្ញុំក៏មានសម្ពត់កម្ពលធ្វើដោយរោមសត្វជាដើម វាមានក្លិនស្អុយ សម្ផស្សគ្រោតគ្រាត តែក៏ហៅថា សម្ពត់កម្ពលដូចគ្នា ប៉ុន្តែកាលណាឈ្មួញនោះ ឃោសនាថា សម្ពត់កម្ពលពណ៌ក្រហមធ្វើក្នុងដែនគន្ធារៈ ល្អិតល្អន់ ស្រស់ថ្លា សម្ផស្សទន់ល្មើយ កាលនោះ បើមានប្រាក់ល្មមក៏នឹងទិញយក មានមិនល្មម ក៏នឹងសរសើរ យ៉ាងណា សូម្បីកាលព្រះមាន-

ព្រះភាគត្រាស់ថា **ម្នាលភិក្ខុទាំងឡាយ ផ្លូវនេះ ជាផ្លូវមួយតែមួយ** ដូច្នេះ ក៏មិនទាន់ប្រាកដជាមុនថា ផ្លូវណា ព្រោះថា សូម្បីផ្លូវដែលមិននាំសត្វចេញចាកទុក្ខ មានច្រើនប្រការ ក៏ហៅថា ផ្លូវដូចគ្នា តែកាលព្រះមានព្រះភាគត្រាស់ថា ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ដូច្នេះជាដើម ភិក្ខុទាំងឡាយក៏ជ្រាបថា ផ្លូវនេះនាំចេញនូវឧបទ្រវៈ ៤ នាំមកនូវគុណវិសេស ៣ ហើយក៏កើតឧស្សាហ៍ សម្គាល់ទេសនានេះថា គួរហ្ន៎ គួររៀន គួរចងចាំ គួរប្រាប់ គួរពោល និងសម្គាល់មគ្គនេះថា គួរចម្រើន ព្រោះដូច្នោះ ព្រះមានព្រះភាគ កាលត្រាស់គុណ ( របស់ឯកាយនមគ្គ ) ទើបត្រាស់ថា ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយជាដើម ។

មួយទៀត ការឧបមាពោលដោយឈ្មួញសម្គត់កម្ពលពណ៌លឿង ដែលមានតម្លៃមួយសែន នាំមកប្រៀបធៀបយ៉ាងណា ក្នុងសេចក្តីនេះ ក៏គួរនាំការឧបមាពោលដោយឈ្មួញ មាសជម្ពូនុទ កែវមណីដែលធ្វើទឹកឲ្យថ្លា កែវមុក្តាដែលបរិសុទ្ធិ សម្គត់ពោមសត្វ និងកែវប្រវាឡជាដើម យកមកប្រៀបធៀប ដូច្នោះ ។

## អធិប្បាយសព្ទថា យទិទំ

ពាក្យថា យទិទំ ជានិបាតសព្ទ ។ និបាតសព្ទនោះ មានសេចក្តីដូច្នេះថា ( យេ ឥមេ ) **ទាំងនេះណា** ។ ពាក្យថា ចត្តារោ ( ៤ ) ជាសព្ទកំណត់ចំនួន ។ ដោយចំនួននោះ ព្រះមានព្រះភាគ ទ្រង់សម្តែងការកំណត់ចំនួនសតិប្បដ្ឋានថា មិនតិចជាងនោះ មិនច្រើនជាងនោះ ។

## អធិប្បាយ សតិប្បដ្ឋាន

ពាក្យថា **សតិប្បដ្ឋានទាំងឡាយ** បានដល់ សតិប្បដ្ឋាន ៣ គឺ អារម្មណ៍នៃសតិក៏មាន ការដែលព្រះបរមសាស្តា ទ្រង់កន្លងបង់សេចក្តីប្រទូសរ៉ាយ និងត្រេកអរក្នុងសាវកទាំងឡាយ អ្នកបដិបត្តិ ៣ យ៉ាងក៏មាន តួសតិក៏មាន ។ អារម្មណ៍នៃសតិ ហៅថា **សតិប្បដ្ឋាន** ដូចបាលី ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ជាដើមថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងការកើត និងការរលត់ទៅនៃសតិប្បដ្ឋាន ៤ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ល។ ម្នាលភិក្ខុទាំងឡាយ ការកើតនៃកាយ ដូចម្តេច ។ ការកើតឡើងនៃកាយ ព្រោះការកើតឡើងនៃអាហារ ដូច្នេះ ។ មា៉្យងទៀត ឈ្មោះថា **សតិប្បដ្ឋាន** ដូចបាលី ( ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ ) ជាដើម

ថា កាយ **ជាទីតាំង** មិនមែនសតិ , **សតិ** ជាទីតាំងផង ជាសតិផង ។ ពាក្យនោះ មានសេចក្ដីដូច្នេះ ។ ឈ្មោះថា **បដ្ឋាន** ព្រោះអត្ថវិគ្រោះថា ជាទីតាំងក្នុងទីនេះ ។ សួរថា អ្វីតាំង ។ ឆ្លើយថា សតិ ។ ទីតាំងនៃសតិ ឈ្មោះថា **សតិប្បដ្ឋាន** ។ ន័យមួយទៀត ការតាំងជាប្រធាន ហេតុនោះ ទើបឈ្មោះថា **បដ្ឋាន** ។ ការតាំងនៃសតិ ឈ្មោះថា សតិប្បដ្ឋាន ដូចជា ការឈរបស់ដំរី ការឈរបស់សេះជាដើម ។ ព្រះបរមសាស្ដា ទ្រង់កន្លង បង់សេចក្ដីទាស់ចិត្ត និងសេចក្ដីពេញចិត្តក្នុងសាវកទាំងឡាយ អ្នកបដិបត្តិ ៣ យ៉ាងហៅថា សតិប្បដ្ឋាន បានក្នុងបាលីថា ( សឡាយតនៈ វិភង្គសូត្រ មជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ ) នេះថា សតិប្បដ្ឋាន ៣ ព្រះមានព្រះភាគ ទ្រង់ជាព្រះអរិយៈ ទ្រង់សេពសតិប្បដ្ឋានណា កាលទ្រង់សេពសតិប្បដ្ឋាន នោះ ទើបជាព្រះសាស្ដា សមគួរទូន្មានសាវកទាំងឡាយ ដូច្នេះ ។ ពាក្យ នោះមានសេចក្ដីដូច្នេះ ឈ្មោះថា **បដ្ឋាន** ព្រោះជាធម៌ដែលគប្បីតាំងទុក អធិប្បាយថា គប្បីឲ្យប្រព្រឹត្តទៅ ។ សួរថា ព្រោះជាធម៌ដែលគប្បីតាំង ទុកដោយអ្វី ។ ឆ្លើយថា ដោយសតិ ។ ការតាំងទុកដោយសតិ ឈ្មោះថា **សតិប្បដ្ឋាន** ក៏សតិប៉ុណ្ណោះហៅថា **សតិប្បដ្ឋាន** បានក្នុងបាលី ( សំយុត្ត- និកាយ មហាវារវគ្គ ) ជាដើមថា សតិប្បដ្ឋាន ៤ ដែលបុគ្គលចម្រើនហើយ

ធ្វើឲ្យច្រើនហើយ រមែងញ៉ាំងពោជ្ឈង្គៈ ៧ ឲ្យពេញបរិបូរ ដូច្នេះ ។ ពាក្យនោះមានសេចក្ដីដូច្នេះ ធម្មជាតិណាតាំងនៅហើយ អធិប្បាយថា ចូលទៅតាំងមាំ គឺ ប្រព្រឹត្តទៅ ហេតុនោះ ធម្មជាតិនោះ ឈ្មោះថា **បដ្ឋាន** ។ សតិនោះឯង ឈ្មោះថា **សតិប្បដ្ឋាន** ។ ន័យមួយទៀត ដែលឈ្មោះថា **សតិ** ព្រោះអត្ថថា រឭកបាន ដែលឈ្មោះថា **បដ្ឋាន** ព្រោះអត្ថថា ចូលទៅតាំងទុក ។ ព្រោះដូច្នោះ សតិនោះផង បដ្ឋានផង ព្រោះហេតុនោះ ទើបឈ្មោះថា **សតិប្បដ្ឋាន** ។ ក្នុងទីនេះ ព្រះមានព្រះភាគ ទ្រង់បំណងយកសតិប្បដ្ឋាននេះ ។ សួរថា បើដូច្នោះ ហេតុអ្វី ពាក្យថា **សតិប្បដ្ឋាន** ទាំងឡាយ ទើបជាពាក្យពហុវចនៈ ។ ឆ្លើយថា ព្រោះត្រូវមានសតិច្រើន សេចក្ដីពិត សតិនោះមានច្រើន ព្រោះផ្សេងគ្នានៃអារម្មណ៍ ។ សួរថា តែហេតុអ្វីពាក្យថា **មគ្គ** ទើបជាឯកវចនៈ ។ ឆ្លើយថា ព្រោះជាផ្លូវតែមួយ ដោយអត្ថថា ជាមគ្គ ។ សេចក្ដីពិត សតិទាំងនោះសូម្បីមាន ៤ ក៏រាប់ថា ផ្លូវតែមួយ ដោយអត្ថថា ជាមគ្គ ។ សមពិតដូចដែលលោកពោលទុកថា សួរថា ក្នុងពាក្យថាមគ្គ ដែលឈ្មោះថាមគ្គ ព្រោះអត្ថថាអ្វី ឆ្លើយថា ព្រោះអត្ថថា ជាគ្រឿងនាំទៅកាន់ព្រះនិព្វានផង ព្រោះអត្ថថា អ្នកត្រូវការព្រះនិព្វានទឹងគប្បីស្វែងរកផង ។ សតិទាំង ៤ នោះ ធ្វើកិច្ចឲ្យសម្រេច ក្នុង

អារម្មណ៍ទាំងឡាយ មានកាយជាដើម ទើបដល់ព្រះនិព្វានក្នុងខាងក្រោយ តែអ្នកត្រូវការព្រះនិព្វានទាំងឡាយ ចាំបាច់ត្រូវប្រព្រឹត្តទៅតាំងពីដើមមក ព្រោះដូច្នោះ សតិទាំង ៤ ទើបហៅថា **ផ្លូវតែមួយ** ។ ទេសនាព្រមដោយអនុសន្ធិ រមែងមានដោយការអនុសន្ធិ ពាក្យថា **សតិ** ដូចក្នុងបាលីទាំងឡាយ ( សំយុត្តនិកាយ មហាវារវគ្គ ) ជាដើមថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវមគ្គ ជាគ្រឿងកម្ចាត់កងទ័ពមារ អ្នកទាំងឡាយចូរស្តាប់ មគ្គនោះ ជាគ្រឿងកម្ចាត់កងទ័ពមារ តើដូចម្តេច គឺ សម្ពោជ្ឈង្គៈ ៧ ដូច្នេះ ។ ពាក្យថា **មគ្គ** ជាគ្រឿងកម្ចាត់កងទ័ពមារ និងពាក្យថា សម្ពោ-ជ្ឈង្គៈ ៧ ដោយអត្ថ ក៏តែមួយដូចគ្នា ផ្សេងគ្នាតែព្យញ្ជនៈប៉ុណ្ណោះ យ៉ាងណា ពាក្យថា **ឯកាយនមគ្គ** និងពាក្យថា **សតិប្បដ្ឋាន ៤** ដោយអត្ថក៏ដូចគ្នា ផ្សេងគ្នាតែព្យញ្ជនៈប៉ុណ្ណោះ ក៏ដូច្នោះ ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបថា **ជាឯកវចនៈ** ក៏ព្រោះជាផ្លូវតែមួយ ដោយអត្ថថា ជាមគ្គ , **ជាពហុវចនៈ** ក៏ព្រោះសតិមានច្រើន ដោយសេចក្តីផ្សេងគ្នានៃអារម្មណ៍ ។

សួរថា ព្រោះហេតុអ្វី ព្រះមានព្រះភាគ ទើបត្រាស់សតិប្បដ្ឋានថាមាន ៤ មិនខ្វះមិនលើស ។ ឆ្លើយថា ក៏ព្រោះទ្រង់ធ្វើឲ្យជាប្រយោជន៍ដល់វេនេយ្យសត្វ ។ ពិតណាស់ ក្នុងពួកវេនេយ្យសត្វដែលជាតណ្ហាចរិត

ទិដ្ឋិចរិត អ្នកជាសមថយានិក (អ្នកមានសមថៈជាយាន) និងវិបស្សនាយានិក (អ្នកមានវិបស្សនាជាយាន) ដែលប្រព្រឹត្តទៅដោយចំណែកទាំងពីរ គឺ បញ្ញាទន់ខ្សោយ និងបញ្ញាចាស់ក្លា **កាយានុបស្សនាសតិប្បដ្ឋាន** មានអារម្មណ៍គ្រោតគ្រាតជាផ្លូវបរិសុទ្ធិ សម្រាប់វេនេយ្យសត្វ អ្នកមានតណ្ហាចរិត មានបញ្ញាទន់ខ្សោយ , **វេទនានុបស្សនាសតិប្បដ្ឋាន** មានអារម្មណ៍ល្អិតល្អន់ ជាផ្លូវបរិសុទ្ធិ សម្រាប់វេនេយ្យសត្វអ្នកមានតណ្ហាចរិត មានបញ្ញាចាស់ក្លា , **ចិត្តានុបស្សនាសតិប្បដ្ឋាន** ដែលមានអារម្មណ៍មិនចែកចេញច្រើន ជាផ្លូវហ្មត់ចត់ សម្រាប់វេនេយ្យសត្វអ្នកមានទិដ្ឋិចរិត មានបញ្ញាទន់ខ្សោយ , **ធម្មានុបស្សនាសតិប្បដ្ឋាន** ដែលមានអារម្មណ៍ចែកចេញច្រើន ជាផ្លូវហ្មត់ចត់ សម្រាប់វេនេយ្យសត្វ អ្នកមានទិដ្ឋិចរិត មានបញ្ញាចាស់ក្លា ។ មួយទៀត សតិប្បដ្ឋានប្រការទី ១ ដែលមាននិមិត្ត នឹងគប្បីសម្រេចបានដោយមិនលំបាក ជាផ្លូវហ្មត់ចត់សម្រាប់វេនេយ្យសត្វ អ្នកជាសមថយានិក មានបញ្ញាទន់ខ្សោយ , សតិប្បដ្ឋានប្រការទី ២ ព្រោះមិនតាំងនៅក្នុងអារម្មណ៍យ៉ាងគ្រោតគ្រាត ទើបជាផ្លូវហ្មត់ចត់សម្រាប់វេនេយ្យសត្វ អ្នកជាសមថយានិក មានបញ្ញាចាស់ក្លា , សតិប្បដ្ឋានប្រការ ទី ៣ មានអារម្មណ៍ដែលចែកចេញមិនច្រើន ជាផ្លូវហ្មត់ចត់សម្រាប់វេនេយ្យសត្វ អ្នកជាវិបស្សនាយានិក

មានបញ្ញាទន់ខ្សោយ , សតិប្បដ្ឋានប្រការទី ៤ មានអារម្មណ៍ដែលចែកចេញច្រើន ជាផ្លូវហ្មត់ចត់សម្រាប់វេនេយ្យសត្វ អ្នកជាវិបស្សនាយានិកមានបញ្ញាចាស់ក្លា ។ ព្រោះហេតុដូច្នោះ ទើបពោលថា សតិប្បដ្ឋានមាន ៤ ប៉ុណ្ណោះ មិនខ្វះមិនលើស ។ មួយវិញទៀត ដែលត្រាស់ថា សតិប្បដ្ឋានមាន ៤ ក៏ដើម្បីលះបង់នូវ **វិបល្លាស** សេចក្ដីសម្គាល់ខុសថា ស្អាត សុខ ទៀង និងជាតួខ្លួន ។ ពិតណាស់ កាយជាអសុភៈ មិនស្អាត តែសត្វទាំងឡាយសម្គាល់ថា ស្អាត ក្នុងកាយនោះ ។ ដោយទ្រង់សម្ដែងភាពមិនស្អាតក្នុងកាយនោះ ដល់សត្វទាំងនោះ ទើបត្រាស់សតិប្បដ្ឋានប្រការទី ១ ដើម្បីលះវិបល្លាសនោះចេញ ។ និងក្នុងវេទនាជាដើម ដែលសត្វប្រកាន់ថា សុខ ទៀង ជាតួខ្លួន វេទនាក៏ជាទុក្ខ ចិត្តមិនទៀង ធម៌ទាំងឡាយជាអនត្តា ។ តែសត្វទាំងឡាយក៏សម្គាល់ថា សុខ ទៀង ជាតួខ្លួន ក្នុងវេទនា ចិត្ត ធម៌នោះ ដោយទ្រង់សម្ដែងភាពជាទុក្ខជាដើម ក្នុងវេទនា ចិត្ត ធម៌នោះ ដល់សត្វទាំងនោះ ទើបត្រាស់សតិប្បដ្ឋាន ៣ ដ៏សេស ដើម្បីលះវិបល្លាសទាំងនោះចេញ ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបថា ដែលត្រាស់ថា សតិប្បដ្ឋាន ៤ មិនខ្វះមិនលើស ក៏ដើម្បីលះសេចក្ដីសម្គាល់ខុសថា ស្អាត សុខ ទៀង និងតួខ្លួនចេញ ដូចដែលពោលមកនេះ ។ មិនមែនដើម្បីលះ

វិបល្លាសតែម្យ៉ាងប៉ុណ្ណោះ បណ្ឌិតគប្បីជ្រាបថា ដែលត្រាស់សតិប្បដ្ឋាន ៤ ក៏ដើម្បីលះ ឱឃៈ យោគៈ អាសវៈ គន្ថៈ ឧបាទាន និងអគតិ មួយៗ ៤ ផង ដើម្បីកំណត់ដឹងអាហារ ៤ យ៉ាងផង គប្បីជ្រាបក្នុងទីមកក្នុងបករណ៍ (បាលី) ប៉ុណ្ណេះមុន ។

ចំណែកក្នុងអដ្ឋកថា លោកពោលថា សតិប្បដ្ឋាន មានតែម្យ៉ាងប៉ុណ្ណោះ ដោយការរឭក និងដោយជាទីប្រជុំចុះតែម្យ៉ាង មាន ៤ ដោយអំណាចអារម្មណ៍ ។ ប្រៀបដូចព្រះនគរមានទ្វារ ៤ បុគ្គលដែលមកពីទិសខាងកើត នាំវត្ថុដែលនៅទិសខាងកើតមក ចូលព្រះនគរតាមទ្វារទិសខាងកើត , អ្នកដែលមកពីទិសត្បូង ទិសលិច ក៏ដូចគ្នា បុគ្គលដែលមកពីទិសខាងជើង ក៏នាំវត្ថុដែលនៅក្នុងទិសខាងជើង ចូលព្រះនគរតាមទ្វារទិសជើង យ៉ាងណា ការឧបមេយ្យនេះ ក៏ដូច្នោះ ។ ពិតណាស់ **និព្វាន** ប្រៀបដូចនគរ **លោកុត្តរមគ្គមានអង្គ ៨** ប្រៀបដូចជាទ្វារព្រះនគរ **សតិប្បដ្ឋាន** មានកាយជាដើម ប្រៀបដូចជាទិសទាំងឡាយ មានទិសខាងកើតជាដើម ។ ក៏បុគ្គលដែលមកពីទិសខាងកើត នាំវត្ថុដែលនៅទិសខាងកើតមក ចូលព្រះនគរ តាមទ្វារទិសខាងកើត យ៉ាងណា អ្នកបដិបត្តិដោយមុខនៃកាយានុបស្សនា ចម្រើនកាយានុបស្សនា ១៤ វិធី រមែងឈានចុះកាន់ព្រះនិព្វាន

តែម្យ៉ាងដូចគ្នាទុំះឯង ដោយអរិយមគ្គ ដែលកើតពីអានុភាពនៃការចម្រើនកាយានុបស្សនា ក៏ដូច្នោះ ។ បុគ្គលដែលមកពីទិសខាងត្បូង នាំវត្ថុដែលនៅទិសខាងត្បូង រមែងចូលមកកាន់ព្រះនគរតាមទ្វារទិសខាងត្បូង យ៉ាងណា អ្នកបដិបត្តិដោយមុខនៃវេទនានុបស្សនា ចម្រើនវេទនានុបស្សនា ៩ វិធី រមែងឈានចុះកាន់ព្រះនិព្វានដូចគ្នាទុំះឯង ដោយអរិយមគ្គ ដែលកើតអំពីអានុភាពនៃការចម្រើនវេទនានុបស្សនា ក៏ដូច្នោះ ។ បុគ្គលដែលមកពីទិសខាងលិច នាំវត្ថុដែលនៅទិសខាងលិច រមែងចូលមកកាន់ព្រះនគរតាមទ្វារទិសខាងលិច យ៉ាងណា អ្នកបដិបត្តិដោយមុខនៃចិត្តានុបស្សនា ចម្រើនចិត្តានុបស្សនា ១៦ វិធី រមែងឈានចុះកាន់ព្រះនិព្វានដូចគ្នាទុំះឯង ដោយអរិយមគ្គ ដែលកើតពីអានុភាពនៃការចម្រើនចិត្តានុបស្សនា ដូច្នោះ ។ បុគ្គលដែលមកពីទិសខាងជើង នាំវត្ថុដែលនៅទិសខាងជើង រមែងចូលមកកាន់ព្រះនគរតាមផ្លូវទ្វារទិសខាងជើង យ៉ាងណា អ្នកបដិបត្តិដោយមុខនៃធម្មានុបស្សនា ចម្រើនធម្មានុបស្សនា ៥ វិធី រមែងឈានចុះកាន់ព្រះនិព្វានតែម្យ៉ាងគ្នាដូចគ្នានោះឯង ដោយអរិយមគ្គ ដែលកើតពីអានុភាពនៃការចម្រើនធម្មានុបស្សនា ក៏ដូច្នោះ ។ បណ្ឌិតគប្បីជ្រាបថា ដែលលោកពោលថា សតិប្បដ្ឋានមានតែមួយប៉ុណ្ណោះ ក៏ដោយអំណាចការរួមកបានម្យ៉ាង

ដោយអានុភាពការប្រជុំចុះកាន់ភាពតែមួយដូចគ្នាម្យ៉ាង ដែលពោលថា មាន ៤ ក៏ដោយចាត់តាមអារម្មណ៍ ដូចពោលមក ដូច្នេះ ។

ពាក្យថា **មាន ៤ ដូចម្តេច** ជាពាក្យសួរដោយបំណងនឹងឆ្លើយ (សួរខ្លួនឯងឆ្លើយខ្លួនឯង) ។ ពាក្យថា **ក្នុងធម៌វិន័យនេះ** គឺ ក្នុងព្រះសាសនានេះ ។ ពាក្យថា **ភិក្ខវេ** នោះ ជាពាក្យហៅបុគ្គលអ្នកទទួលធម៌ ។ ពាក្យថា **ភិក្ខុនោះ** ជាពាក្យសម្តែងដល់បុគ្គល ដែលដល់ព្រមដោយការប្រតិបត្តិ ។ ទេវតា និងមនុស្ស សូម្បីពួកដទៃ ក៏ប្រព្រឹត្តបដិបត្តិឲ្យព្រមដូចគ្នា ។ តែដែលត្រាស់ថា **ភិក្ខុ** ក៏ព្រោះជាអ្នកប្រសើរម្យ៉ាង ព្រោះទ្រង់សម្តែងភាវៈនៃភិក្ខុដោយការបដិបត្តិម្យ៉ាង ។ ជាការពិត ក្នុងបុគ្គលទាំងឡាយ អ្នកទទួលពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគ ភិក្ខុជាអ្នកប្រសើរ ព្រោះដូចជាភាជនៈ ទ្រទទួលពាក្យប្រៀនប្រដៅ មានប្រការផ្សេងៗ ព្រោះដូច្នោះទើបត្រាស់ថា **ភិក្ខុ** ព្រោះជាអ្នកប្រសើរ ។ តែកាលទ្រង់កាន់យកភិក្ខុហើយ បុគ្គលទាំងឡាយដ៏សេស ក៏ជាការទ្រង់កាន់យកផង ដូចក្នុងប្រការដែលស្តេចព្រះរាជដំណើរជាដើម ពួករាជបរិវារក្រៅពីនោះ ក៏ជាប្រការដែលលោករួមទុកដោយស័ព្ទថា **រាជ** ។ អ្នកណាបដិបត្តិ ប្រការបដិបត្តិនេះ អ្នកនោះ រមែងឈ្មោះថា **ភិក្ខុ** ព្រោះដូច្នោះ ព្រះអ្នកមានព្រះភាគត្រាស់ថា

**ភិក្ខុ** ក៏ព្រោះទ្រង់សម្តែងការៈរបស់ភិក្ខុដោយការបដិបត្តិ ។ ជាការពិត អ្នកបដិបត្តិ ទឹងជាទេវតា ឬមនុស្សក៏ដោយ រមែងរាប់បានថា ជាភិក្ខុទាំងអស់ ។ ដូចដែលត្រាស់ទុក ( ក្នុងធម្មបទ ខុទ្ទកនិកាយ ) ថា ៖

អលង្កតោ ចេបិ សមំ ចរេយ្យ សន្តោ ទន្តោ និយតោ

ព្រហ្មចារី សព្វេសុ ភូតេសុ និធាយ ទណ្ឌំ សោ ព្រាហ្មណោ

សោ សមណោ ស ភិក្ខុ ។

**ប្រសិនបើបុគ្គលមានធម៌ប្រដាប់ហើយ ជាអ្នកស្ងប់ហើយ ហ្វឹកហាត់ហើយ ជាបុគ្គលទៀង ជាព្រហ្មចារី ដាក់ចុះនូវអាជ្ញាកម្មក្នុងសត្វទាំងពួង គប្បីប្រព្រឹត្តស្មើ បុគ្គលនោះ ក៏ឈ្មោះថា ព្រាហ្មណ៍ បុគ្គលនោះក៏ឈ្មោះថា សមណៈ បុគ្គលនោះក៏ឈ្មោះ ភិក្ខុ ដូច្នេះ ។**

ពាក្យថា **ក្នុងកាយ** គឺ ក្នុងរូបកាយ ។ ពិតណាស់ រូបកាយក្នុងទីនោះ លោកប្រាថ្នាយកថា **កាយ** ព្រោះអត្ថថា ជាទីរួមនៃអវយវៈតូចធំ និងធម៌ទាំងឡាយ មានសក់ជាដើម ដូច **ដូចខ្លួនរបស់ដំរី , តួរថជាដើម** ។ ដែលឈ្មោះថា **កាយ** ព្រោះអត្ថថា **ជាទីរួម** យ៉ាងណា ដែលឈ្មោះថា **កាយ** ព្រោះអត្ថថា ជាប្រភពនៃការមករបស់នូវវត្ថុដែលគួរខ្ពើម ដូច្នោះ ។

ពិតហើយ កាយនោះ ជាប្រភពនៃការមកនូវវត្ថុគួរខ្ពើម គឺ គួរខ្ពើមយ៉ាងក្រៃលែង សូម្បីព្រោះហេតុនោះ ទើបឈ្មោះថា **កាយ** ។ ពាក្យថា ជាប្រភពនៃការមក គឺ ជាប្រទេសកើត ខ្ទឹមសាររបស់ពាក្យ ក្នុងពាក្យថាជាប្រភពនៃការមកនោះ មានដូច្នេះ ធម្មជាតិទាំងឡាយមកអំពីកាយនោះ ហេតុនោះ កាយនោះ ទើបឈ្មោះថា ជាប្រភពនៃការមក ។ តើអ្វីមក ? វត្ថុដែលគួរខ្ពើមទាំងឡាយ មានសក់ជាដើមរមែងមក ។ ឈ្មោះថា **អាយៈ** ព្រោះជាប្រភពនាំមកនូវវត្ថុគួរខ្ពើមទាំងឡាយ ដោយប្រការដូច្នេះ ។

ពាក្យថា **ពិចារណាឃើញកាយ** មានន័យថា មានប្រក្រតីពិចារណាឃើញក្នុងកាយ ឬពិចារណាឃើញកាយ ។ ព្រះមានព្រះភាគ សូម្បីនឹងត្រាស់ថា **ក្នុងកាយ** ហើយ បណ្ឌិតគប្បីជ្រាបថា ទ្រង់ធ្វើស័ព្ទថា **កាយ** លើកទីពីរថា ពិចារណាឃើញនូវកាយម្ដងទៀត ដើម្បីទ្រង់សម្ដែងការកំណត់ និងការបែកចេញពីដុំជាដើម ដោយមិនលាយគ្នា ។ មិនមែន ភិក្ខុពិចារណាឃើញវេទនាក្នុងកាយ ឬពិចារណាឃើញចិត្តក្នុងកាយ ឬពិចារណាឃើញធម៌ក្នុងកាយទេ ដែលពិត ពិចារណាឃើញនូវកាយក្នុងកាយ ព្រោះដូច្នោះ ទើបទ្រង់សម្ដែងការកំណត់មិនលាយគ្នា ដោយទ្រង់សម្ដែងអាការគឺ ពិចារណាឃើញកាយ ក្នុងវត្ថុដែលរាប់ថាកាយ ។ មិនមែនពិចារណា

ឃើញធម៌យ៉ាងណាមួយ ដែលផុតពីអវយវៈតូចធំ ក្នុងកាយទេ ទាំងមិនមែនពិចារណាឃើញជាស្ត្រី ឬជាបុរស ដែលផុតអំពីសក់ រោមជាដើម ។ ពិតហើយ ក្នុងប្រការនោះ កាយសូម្បីយ៉ាងណា ដែលរាប់ថា ជាទីប្រជុំរួមរបស់ភូតរូប និងឧបាទាយរូប មានសក់ រោមជាដើម មិនមែនពិចារណាឃើញធម៌យ៉ាងណាមួយ ដែលផុតពីភូតរូប និងឧបាទាយរូបទេ , ដែលពិតពិចារណាឃើញកាយជាទីប្រជុំរួមនៃអវយវៈតូចធំ ក្នុងកាយនោះ ដូចជាពិចារណាឃើញចំណែកប្រកបរបស់រថ ដូច្នោះ ពិចារណាឃើញកាយជាទីប្រជុំរួមនៃសក់ រោមជាដើម ដូចពិចារណាឃើញ ចំណែកតូចធំនៃព្រះនគរ ពិចារណាឃើញនូវកាយជាទីប្រជុំរួមនៃភូតរូប និងឧបាទាយរូប ដូចចែកស្លឹក និងជាងរបស់ដើមចេក និងដូចលាតដៃក្តាប់ដែលទទេ ដូច្នោះ ព្រោះដូច្នោះ ទើបទ្រង់សម្តែងការចែកចេញអំពីជុំ ដោយទ្រង់សម្តែងវត្ថុដែលរាប់បានថា **កាយ** ដែលជាទីប្រជុំរួមដោយប្រការផ្សេង ៗ នោះឯង ។ សេចក្តីពិត **កាយ** ឬបុរសស្ត្រី ឬធម៌ណា ៗ ដទៃ ដែលផុតអំពីកាយដែលជាទីប្រជុំរួម ដូចពោលហើយ មិនមានប្រាកដក្នុងកាយនោះ តែសត្វទាំងឡាយ ក៏ប្រកាន់ខុស ដោយប្រការនោះ ៗ ក្នុងកាយ ដែលត្រឹមតែជាជាទីប្រជុំរួមនៃធម៌ ដូចពោលហើយនុ៎ះឯង ។ ព្រោះដូច្នោះ ព្រះបុរាណា-

ថាវត្ថុទាំងឡាយ ទើបពោលថា ៖

យំ បស្សតិ ន តំ ទិដ្ឋំ យំ ទិដ្ឋំ តំ ន បស្សតិ

អបស្សំ ពជ្ឈតេ មូឡ្ហោ ពជ្ឈមានោ ន មុច្ចតិ

**បុគ្គលឃើញវត្ថុណា វត្ថុនោះក៏មិនបានឃើញ វត្ថុណា ឃើញហើយ ក៏មិនឃើញវត្ថុនោះ កាលមិនឃើញក៏វង្វេង ជាប់ កាលជាប់ក៏មិនរួចផុត ដូច្នេះ ។**

លោកពោលពាក្យនេះ ក៏ដើម្បីសម្តែងការបែកចេញពីដុំជាដើម ។ ដោយសព្ទថា **ជាដើម** ក្នុងពាក្យនេះ បណ្ឌិតគប្បីជ្រាបសេចក្តី ដូច្នេះ ។ ក៏ភិក្ខុនេះ ពិចារណាឃើញកាយក្នុងកាយនេះប៉ុណ្ណោះ លោកអធិប្បាយថា មិនមែនពិចារណាឃើញធម៌យ៉ាងដទៃ ។ មនុស្សទាំងឡាយក្រឡេកឃើញ ទឹកក្នុងថ្ងៃបណ្តើរកូន សូម្បីមិនមានទឹកយ៉ាងណា ភិក្ខុពិចារណាឃើញ កាយយ៉ាងនេះថា ជារបស់មិនទៀង ជាទុក្ខ មិនមែនតួខ្លួន មិនស្អាត ថាជារបស់ទៀង ជាសុខ ជាតួខ្លួន និងស្អាត ដូច្នោះ មិនមែន ដែលពិត ពិចារណាឃើញកាយ លោកអធិប្បាយថា ពិចារណាឃើញកាយ ជាទី រួមរបស់អាការ គឺ មិនទៀង ជាទុក្ខ មិនមែនតួខ្លួន និងមិនស្អាត ។

ម្យ៉ាងទៀត ក៏កាយនេះយ៉ាងណា ដែលលោកពោលទុកខាងមុខថា

មានខ្យល់អស្សាសៈបស្សាសៈ ជាដើម មានឆ្អឹងជាទីបំផុត តាមន័យព្រះបាលីជាដើមថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ទៅព្រៃក្ដី ។ល។ មានសតិជកជញ្ជើមចូល ដូច្នេះ និងកាយយ៉ាងណា ដែលលោកពោលទុកក្នុងបដិសម្ភិទាមគ្គ ( ខុទ្ទកនិកាយ ) ថា ភិក្ខុក្នុងធម្មវិន័យនេះ ពិចារណាឃើញកាយ គឺ ដី កាយ គឺ ទឹក កាយ គឺ ភ្លើង កាយ គឺ ខ្យល់ កាយ គឺ សក់ កាយ គឺ រោម កាយ គឺ ពណ៌សម្បុរ កាយ គឺ ស្បែក កាយ គឺ សាច់ កាយ គឺ ឈាម កាយ គឺ សរសៃ កាយ គឺ ឆ្អឹង កាយ គឺ ខួរក្នុងឆ្អឹង ដោយភាពជារបស់មិនទៀង ដូច្នេះ បណ្ឌិតគប្បីជ្រាបសេចក្ដីនៃកាយទាំងអស់ សូម្បីយ៉ាងនេះថា ភិក្ខុពិចារណាឃើញកាយក្នុងកាយ ដោយពិចារណាឃើញក្នុងកាយយ៉ាងនេះ ប៉ុណ្ណោះ ។

ម្យ៉ាងទៀត គប្បីជ្រាបសេចក្ដីយ៉ាងនេះថា ពិចារណាឃើញកាយដែលរាប់ថា ជាទីរួមនៃធម៌ មានសក់ជាដើមក្នុងកាយ ដោយមិនពិចារណាឃើញចំណែកណាមួយដែលគប្បីប្រកាន់ថា ជាយើង ជារបស់យើង ក្នុងកាយ តែពិចារណាឃើញកាយនោះ ៗ ប៉ុណ្ណោះ ជាទីរួមនៃធម៌ផ្សេង ៗ មានសក់ រោមជាដើម ។

មួយទៀត គប្បីជ្រាបសេចក្ដីយ៉ាងនេះថា ពិចារណាឃើញកាយ

ក្នុងកាយ សួម្បីដោយពិចារណាឃើញកាយដែលរាប់ថា ជាទីរួមនៃអាការ មានលក្ខណៈមិនទៀងជាដើម ទាំងអស់តែម្យ៉ាង ដែលមានន័យមកក្នុង បដិសម្ភិទាមគ្គ តាមលំដាប់បាលីជាដើមថា ពិចារណាឃើញក្នុងកាយនេះ ដោយភាពជារបស់មិនទៀង មិនមែនជារបស់ទៀង ដូច្នេះ ។ ពិតយ៉ាង នោះ ភិក្ខុដែលបដិបត្តិបដិបទា គឺ ពិចារណាឃើញកាយក្នុងរូបកាយនេះ រមែងពិចារណាឃើញកាយយ៉ាងនេះ ដោយភាពជារបស់មិនទៀង មិនមែន ឃើញដោយភាពជារបស់ទៀង ពិចារណាឃើញដោយភាពជាទុក្ខ មិនមែន ឃើញដោយភាពជាសុខ ពិចារណាឃើញថាមិនមែនតួខ្លួន មិនមែនឃើញ ថាជាតួខ្លួន ដោយអំណាចអនុបស្សនា ( ការពិចារណាឃើញ ) ៧ ប្រការ មានការពិចារណាឃើញការមិនទៀងជាដើម រមែងនឿយណាយ មិនមែន ត្រេកអរ រមែងប្រាសចាកតម្រេក មិនមែនមានតម្រេក រមែងរលត់ទុក្ខ មិនមែនធ្វើឲ្យកើត រមែងលះបង់ មិនមែនប្រកាន់មាំ ។ ភិក្ខុនោះ កាល ពិចារណាឃើញកាយយ៉ាងនេះ ដោយភាពជារបស់មិនទៀង រមែងលះ និច្ចសញ្ញា សេចក្តីសម្គាល់ថា ទៀង ចេញបាន កាលពិចារណាឃើញ ដោយភាពជាទុក្ខ រមែងលះទុក្ខសញ្ញា សេចក្តីសម្គាល់ថា ជាសុខ ចេញ បាន កាលពិចារណាឃើញដោយសភាពមិនមែនតួខ្លួន រមែងលះអត្តសញ្ញា

សេចក្ដីសម្គាល់ថា ជាតួខ្លួន ចេញបាន កាលនៀយណាយ រមែងលះសេចក្ដីត្រេកអរចេញបាន កាលប្រាសចាកតម្រេក រមែងលះសេចក្ដីប្រាថ្នាចេញបាន កាលរលត់ទុក្ខ រមែងលះបង់ហេតុកើតទុក្ខចេញបាន កាលលះបង់ រមែងលះសេចក្ដីប្រកាន់មាំចេញបាន ដូច្នេះ គប្បីជ្រាបដូចពោលដូច្នេះ ។

ពាក្យថា **នៅ** គឺ ប្រព្រឹត្តទៅ ។ ពាក្យថា **ព្យាយាម** មានអត្ថថា សភាវៈណារមែងដុតកិលេសទាំងឡាយក្នុងភពទាំង ៣ ហេតុនោះ សភាវៈនោះ ឈ្មោះថា **អាតាបៈ** ដុតកំដៅកិលេស , ពាក្យនេះ ជាឈ្មោះនៃសេចក្ដីព្យាយាម ។ សេចក្ដីព្យាយាមរបស់អ្នកនោះមាន ហេតុនោះ អ្នកនោះឈ្មោះថា **អាតាបី** អ្នកមានសេចក្ដីព្យាយាម ។ ពាក្យថា **មានសម្បជញ្ញៈ** គឺ អ្នកប្រកបដោយសេចក្ដីដឹង ដែលរាប់ថា សម្បជញ្ញៈ ។ ពាក្យថា **មានសតិ** គឺ ប្រកបដោយសតិពិចារណាកាយ ។ ក៏ភិក្ខុរូបនេះ កំណត់អារម្មណ៍ដោយសតិ ពិចារណាឃើញដោយបញ្ញា ធម្មតាថា បញ្ញាពិចារណាឃើញរបស់អ្នកវៀរចាកសតិមិនមាន ដោយហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សតិជាគ្រឿងសម្រេចប្រយោជន៍គ្រប់យ៉ាង ព្រោះដូច្នោះ ក្នុងទីនេះទើបត្រាស់ថា **រមែងពិចារណាឃើញនូវកាយក្នុង**

**កាយជាប្រក្រតី** ដូច្នេះ ។ កាយានុបស្សនាសតិប្បដ្ឋាន ទ្រង់បានអធិប្បាយដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត សេចក្តីរួញរាខាងក្នុង រមែងធ្វើអន្តរាយដល់អ្នកមិនមានសេចក្តីព្យាយាម អ្នកមិនមានសម្បជញ្ញៈ រមែងវង្វេងភ្លេចក្នុងការកំណត់ឧបាយ ក្នុងការវៀរចាកវត្ថុដែលមិនមែនឧបាយ អ្នកវង្វេងភ្លេចសតិហើយ រមែងមិនអាចក្នុងការកំណត់ឧបាយ និងក្នុងការលះបង់វត្ថុដែលមិនមែនឧបាយ ដោយហេតុនោះ កម្មដ្ឋាននោះ របស់ភិក្ខុនោះរមែងមិនសម្រេច ព្រោះដូច្នោះ កម្មដ្ឋាននោះ រមែងសម្រេចដោយអានុភាពនៃធម៌ពួកណា ដើម្បីទ្រង់សម្តែងធម៌ពួកនោះ គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ថា មានព្យាយាម មានសម្បជញ្ញៈ មានសតិ ។ ទ្រង់សម្តែងកាយានុបស្សនាសតិប្បដ្ឋាន និងអង្គនៃសម្បយោគៈ ឥឡូវនេះ ដើម្បីនឹងទ្រង់សម្តែងអង្គនៃការលះ ទើបត្រាស់ថា **នាំចេញនូវអភិជ្ឈា និងទោមនស្សក្នុងលោក** ។

បណ្តាបទទាំងនោះ បទថា **នាំចេញ** មានន័យថា នាំចេញដោយការនាំចេញមួយខណៈ ឬដោយការនាំចេញដោយការគ្របសង្កត់ ។ ពាក្យថា **ក្នុងលោក** ក៏គឺ ក្នុងកាយនោះឯង ។ ពិតហើយ កាយក្នុងទីនេះទ្រង់សំដៅដល់លោក ព្រោះអត្ថថា ទ្រុឌទ្រោម ។ អភិជ្ឈា និងទោមនស្ស

មិនមែនព្រះយោគាវចរនោះ លះបង់បានក្នុងអារម្មណ៍ត្រឹមតែកាយប៉ុណ្ណោះទេ សូម្បីក្នុងវេទនាជាដើម ក៏លះបានដែរ ព្រោះដូច្នោះ លោកទើបពោលទុកក្នុងវិភង្គ (សតិប្បដ្ឋានវិភង្គ) ថា ឧបាទានខន្ធ ៥ ក៏ ឈ្មោះថា **លោក** ។ ពាក្យនោះ លោកពោលតាមន័យនៃការពង្រីកសេចក្តី ព្រោះធម៌ទាំងនោះរាប់បានថា ជាលោក ។ តែលោកពោលពាក្យយ៉ាងណាទុកថា លោក តើដូចម្តេច លោក ក៏គឺ កាយនោះឯង សេចក្តីក្នុងពាក្យនោះ មានដូច្នេះ ។ គប្បីឃើញការភ្ជាប់សេចក្តីដូច្នេះថា នាំចេញនូវអភិជ្ឈា និងទោមនស្សក្នុងលោកនោះ ។ ក៏ព្រោះក្នុងទីនេះ កាមច្ឆន្ទៈ រួមចូលនឹងស័ព្ទថា **អភិជ្ឈា** ព្យាបាទ រួមចូលនឹងពាក្យថា **ទោមនស្ស** ដូច្នោះ ទើបគួរជ្រាបថា ទ្រង់អធិប្បាយការលះនីវរណៈ ដោយទ្រង់សម្តែងធម៌ដែលជាគូ ដែលមានកម្លាំងជាប់ទាក់ទងក្នុងនីវរណៈ ។ តែដោយពិសេស ក្នុងទីនេះ ត្រាស់ការលះសេចក្តីត្រេកអរ ដែលមានកាយសម្បត្តិជាមូល ដោយការកម្ចាត់អភិជ្ឈា ត្រាស់ការលះសេចក្តីប្រទូសរ៉ាយ ដែលមានកាយវិបត្តិជាមូល ដោយការកម្ចាត់ទោមនស្ស ត្រាស់ការលះសេចក្តីត្រេកអរក្រៃលែងក្នុងកាយ ដោយការកម្ចាត់អភិជ្ឈា ត្រាស់ការលះសេចក្តីមិនត្រេកអរក្រៃលែង ក្នុងការចម្រើនកាយានុបស្សនា ដោយការកម្ចាត់ទោមនស្ស ត្រាស់ការលះកាយរបស់អ្នក

ដាក់នូវការៈថា ស្អាត ជាសុខ ជាដើម ដែលមិនមានពិតក្នុងកាយ ដោយការកម្ចាត់អភិជ្ឈា និងត្រាស់ការលះដល់ការយកចេញទៅនូវការៈដែលមិនស្អាត ជាទុក្ខជាដើម ដែលមានពិតក្នុងកាយ ដោយការកម្ចាត់ទោមនស្ស ។ ដោយព្រះតម្រាស់នោះ ដែលទ្រង់សម្ដែងអានុភាពនៃសេចក្ដីព្យាយាម និងភាពជាអ្នកអាចក្នុងការប្រកបសេចក្ដីព្យាយាមរបស់ព្រះយោគាវចរ ។ ពិតណាស់ អានុភាពរបស់សេចក្ដីព្យាយាមនោះ ក៏គឺ ជាអ្នករួចផុតចាកសេចក្ដីត្រេកអរ ប្រទូសរ៉ាយ គ្របសង្កត់សេចក្ដីមិនត្រេកអរ និងសេចក្ដីត្រេកអរ និងវៀរចាកក្នុងវត្ថុដែលមិនមានពិត និងនាំចេញនូវវត្ថុដែលមានពិត ។ ក៏ព្រះយោគាវចរនោះ ជាអ្នករួចផុតចាកសេចក្ដីត្រេកអរ ប្រទូសរ៉ាយ ជាអ្នកគ្របសង្កត់សេចក្ដីមិនត្រេកអរ និងសេចក្ដីត្រេកអរ មិនដាក់វត្ថុដែលមិនមានពិត មិននាំចេញនូវវត្ថុដែលមានពិត ទើបឈ្មោះថា ជាអ្នកអាចក្នុងការប្រកបសេចក្ដីព្យាយាម ដោយប្រការដូច្នេះ ។

ន័យមួយទៀត ត្រាស់កម្មដ្ឋានដោយអនុបស្សនា ក្នុងពាក្យដែលថា កាយេ កាយានុបស្សី **ពិចារណាឃើញនូវកាយក្នុងកាយ** ។ ត្រាស់ការបរិហារកាយរបស់ព្រះយោគាវចរ បំពេញកម្មដ្ឋាន ដោយវិហារធម៌ដែលពោលទុកហើយ ក្នុងពាក្យនេះថា **វិហរតិ** ។ ក៏ក្នុងពាក្យជាដើមថា **អាតាបី**

មានសេចក្តីព្យាយាម គប្បីជ្រាបថា ត្រាស់សេចក្តីព្យាយាមប្រពៃ ដោយអាតាបៈ សេចក្តីព្យាយាមគ្រឿងដុតកិលេស ត្រាស់កម្មដ្ឋានដែលឲ្យសម្រេចប្រយោជន៍ទូទៅ ឬឧបាយជាគ្រឿងបរិហារកម្មដ្ឋាន ដោយសតិសម្បជញ្ញៈ ឬត្រាស់សមថៈ ដែលបានមកដោយអំណាចកាយានុបស្សនា ត្រាស់វិបស្សនាដោយសម្បជញ្ញៈ ត្រាស់ផលនៃភាវនាដោយការកម្ចាត់នូវអភិជ្ឈា និងទោមនស្ស ដូច្នេះ ។

## បាលីវិភង្គ

ចំណែកក្នុងបាលីវិភង្គ ពោលសេចក្តីរបស់បទទាំងនោះ ទុកយ៉ាងនេះថា បទថា អនុបស្សី សេចក្តីថា អនុបស្សនាក្នុងពាក្យនោះ តើដូចម្តេច ការដឹងជុំវិញ ការដឹងទូទៅ ។ល។ សេចក្តីឃើញប្រពៃ នេះហៅអនុបស្សនា បុគ្គលបានប្រកបហើយ ប្រកបព្រមហើយ ចូលទៅហើយ ចូលទៅព្រមហើយ ចូលដល់ហើយ ចូលដល់ព្រមហើយ មកព្រមហើយ ដោយអនុបស្សនានេះ ហេតុនោះ បុគ្គលនោះទើបឆ្លើយប្រាប់ថា **អនុបស្សី** ។ បទថា វិហរតិ ប្រែថា រស់នៅ ប្រព្រឹត្តទៅ រក្សា ដំណើរទៅ ឲ្យអត្តភាពដំណើរទៅ ត្រាច់ទៅ ហេតុនោះ ទើបហៅថា **វិហរតិ** ។ បទថា អាតាបី

អ្នកមានសេចក្ដីព្យាយាម សេចក្ដីថា **អាតាបៈ** សេចក្ដីព្យាយាមក្នុងពាក្យនោះ តើដូចម្ដេច ការប្រារព្ធសេចក្ដីព្យាយាម ប្រព្រឹត្តទៅតាមផ្លូវចិត្ត ។បេ។ សម្មាវាយាមៈណា នេះហៅថា **អាតាបៈ** បុគ្គលអ្នកប្រកបដោយអាតាបៈនេះ ហេតុនោះ បុគ្គលនោះ ទើបហៅថា **អាតាបី** ។ បទថា សម្បជានោ សេចក្ដីថា សម្បជញ្ញៈ ក្នុងពាក្យនោះ តើដូចម្ដេច ការដឹងជុំវិញ ការដឹងទូទៅ ។បេ។ ការឃើញប្រពៃ នេះហៅថា **សម្បជញ្ញៈ** បុគ្គលណាប្រកបហើយ ។បេ។ មកតាមព្រមហើយ ដោយសម្បជញ្ញៈនេះ ហេតុនោះ បុគ្គលនោះ ទើបហៅថា សម្បជានោ ។ បទថា សតិមា សេចក្ដីថា សតិក្នុងពាក្យនោះ តើដូចម្ដេច ការរឭកបាន ការរឭកដល់ ។បេ។ ការរឭកប្រពៃ នេះហៅថា **សតិ** បុគ្គលណាប្រកបហើយ ។បេ។ តាមព្រមហើយដោយសតិនេះ ហេតុនោះ បុគ្គលនោះ ទើបហៅថា សតិមា ។ បទថា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ សេចក្ដីថា **លោក** ក្នុងពាក្យនោះ តើដូចម្ដេច ? កាយនោះឯង ឈ្មោះថា **លោក** ឧបាទានខន្ធ សូម្បីទាំង ៥ ក៏ឈ្មោះថា **លោក** នេះហៅថា **លោក** ។ **អភិជ្ឈា** ក្នុងពាក្យនោះ តើដូចម្ដេច តម្រេក តម្រេកខ្លាំង សេចក្ដីសប្បាយចិត្ត សេចក្ដីត្រេកអរ សេចក្ដីភ្លើតភ្លើន តម្រេកដោយអំណាចសេចក្ដីភ្លើតភ្លើន តម្រេកខ្លាំងនៃចិត្ត

នេះហៅថា **អភិជ្ឈា** , **ទោមនស្ស** ក្នុងពាក្យនោះ តើដូចម្តេច សេចក្តីមិនសប្បាយផ្លូវចិត្ត ទុក្ខផ្លូវចិត្ត ។បេ។ វេទនាដែលមិនសប្បាយ ជាទុក្ខដែលកើតដល់សម្ផស្សផ្លូវចិត្ត នេះហៅថា **ទោមនស្ស** ។ អភិជ្ឈា និងទោមនស្សនេះ គឺ ព្រះយោគាវចរកម្ចាត់ចេញហើយ នាំចេញទៅហើយ ស្ងប់ហើយ ឲ្យស្ងប់ហើយ ឲ្យរម្ងាប់ហើយ ឲ្យដល់ការតាំងនៅមិនបានហើយ ឲ្យដល់សេចក្តីសាបសូន្យហើយ ឲ្យដល់ការមិនមានហើយ ឲ្យដល់ការសន្ធើបខ្ចីហើយ ឲ្យស្ងួតហួតហែងហើយ ឲ្យស្ងួតព្រមហើយ ធ្វើឲ្យដល់ទីបំផុតហើយ ហេតុនោះ ទើបត្រាស់ថា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ដូច្នេះ ។ ន័យដែលមកក្នុងអដ្ឋកថានេះ នឹងបាលីវិភង្គ នោះបណ្ឌិតគប្បីជ្រាបបានដោយការប្រៀបធៀបគ្នា ។

ពណ៌នាសេចក្តីនៃឧទ្ទេស ដែលពោលដោយកាយានុបស្សនាសតិ-ប្បដ្ឋាន មានត្រឹមតែប៉ុណ្ណេះមុន ។

## ឧទ្ទេសវារៈ នៃវេទនាចិត្តធម្មានុបស្សនា

*ឥឡូវនេះ នឹងវិនិច្ឆ័យ ក្នុងពាក្យថា ភិក្ខុពិចារណាឃើញនូវវេទនា ក្នុងវេទនាទាំងឡាយ ចិត្តក្នុងចិត្ត ធម៌ក្នុងធម៌ទាំងឡាយ ។ល។ កម្ចាត់អភិជ្ឈា និងទោមនស្សក្នុងលោក ដូច្នេះ ប្រយោជន៍ក្នុងការពោលដដែល វេទនាជាដើម ក្នុងពាក្យដែលមានអាទិ៍យ៉ាងនេះថា* ***វេទនាសុ វេទនានុបស្សី*** *ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ គប្បីជ្រាបដោយន័យដែលពោលមកហើយក្នុងកាយានុបស្សនា ទុះឯង ។ មួយវិញទៀត ក្នុងពាក្យដែលថា* ***ពិចារណាឃើញវេទនា ក្នុងវេទនាទាំងឡាយ ពិចារណាឃើញចិត្តក្នុងចិត្ត ពិចារណាឃើញធម៌ ក្នុងធម៌ទាំងឡាយ*** *នេះ មានវិនិច្ឆ័យដូច្នេះ ៖*

***វេទនា*** *បានដល់ វេទនា ៣ ក៏វេទនា ៣ នោះ ជាលោកិយៈតែម្យ៉ាង សូម្បីចិត្ត ក៏ជាលោកិយៈ ធម៌ទាំងឡាយ ក៏ជាលោកិយៈដូចគ្នា ។ ការចែកវេទនា ចិត្ត ធម៌នោះ នឹងប្រាកដក្នុងនិទ្ទេសវារៈ ។ ចំណែកក្នុងឧទ្ទេសវារៈនេះ ភិក្ខុដែលពិចារណាវេទនា ៣ នោះ ដោយប្រការដែលខ្លួនគប្បីពិចារណាឃើញ ក៏គប្បីជ្រាបថា ជាអ្នកពិចារណាឃើញវេទនាក្នុង*

វេទនាទាំងឡាយ ។ សូម្បីក្នុងចិត្ត និងធម៌ ក៏ន័យនេះដូចគ្នា ។

សួរថា នឹងគប្បីពិចារណាឃើញវេទនា ដូចម្ដេច ។ ឆ្លើយថា គប្បីពិចារណាឃើញសុខវេទនា ដោយភាពជាទុក្ខ ឃើញទុក្ខវេទនា ដូចជាកូនសរ ឃើញអទុក្ខមសុខវេទនា ដោយភាពជារបស់មិនទៀង ។ ដូចដែលត្រាស់ទុកដូច្នេះថា ៖

យោ សុខំ ទុក្ខតោ អទ្ទ ទុក្ខមទ្ទក្ខិ សល្លតោ
អទុក្ខមសុខំ សន្តំ អទក្ខិ នំ អនិច្ចតោ
ស វេ សម្មទ្ទសោ ភិក្ខុ ឧបសន្តោ ចរិស្សតិ ។

**ភិក្ខុណាឃើញសុខវេទនាដោយភាពជាទុក្ខវេទនា ឃើញទុក្ខវេទនាដោយភាពជាកូនសរ ឃើញអទុក្ខមសុខវេទនាដោយភាពជារបស់មិនទៀង ភិក្ខុនោះឯងជាអ្នកឃើញប្រពៃនឹងជាអ្នកស្ងប់ ត្រាច់ទៅ ។**

មួយទៀត ព្រះយោគាវចរគប្បីពិចារណាឃើញវេទនាទាំងអស់នុ៎ះឯង ដោយសេចក្ដីជាទុក្ខផង ។ សមពិត ដូចដែលត្រាស់ទុកដូច្នេះថា តថាគតពោលថា អារម្មណ៍ឯណានីមួយ ដែលបុគ្គលបានសោយហើយ អារម្មណ៍នោះជាទុក្ខ ។ គប្បីពិចារណាឃើញវេទនា ដោយភាពជាសុខ ជា

ទុក្ខ ( ផ្លាស់ប្តូរគ្នាទៅ ) ។ ដូចដែលត្រាស់ទុកថា សុខវេទនា ជាសុខ កាលកើតឡើង កាលតាំងនៅ ជាទុក្ខ កាលប្រែប្រួល ដូច្នេះ ពាក្យទាំងអស់ អ្នកសិក្សាគប្បីយល់ឲ្យទូលំទូលាយ ។

មួយទៀត ព្រះយោគាវចរ គប្បីពិចារណាឃើញ សូម្បីដោយអំណាចអនុបស្សនា ៧ មានអនិច្ចានុបស្សនា ជាដើម ។ ពាក្យវគ្គរពោលដ៏សេសនេះ នឹងប្រាកដក្នុងនិទ្ទេសវារៈនោះឯង ។

ជាដំបូង បណ្តាចិត្ត និងធម៌ ចិត្តដែលព្រះយោគាវចរគប្បីពិចារណាឃើញដោយអំណាចប្រភេទនៃចិត្ត ដែលផ្សេង ៗ គ្នា មានអារម្មណចិត្ត អធិបតិចិត្ត សហជាតចិត្ត ភូមិចិត្ត កម្មចិត្ត វិបាកចិត្ត និងកិរិយាចិត្ត ជាដើម និងដោយអំណាចប្រភេទនៃចិត្ត មានចិត្តប្រកបដោយរាគៈជាដើម ដែលមកក្នុងនិទ្ទេសវារៈនៃអនុបស្សនា មានអនិច្ចានុបស្សនាជាដើម ។ ធម៌ដែលព្រះយោគាវចរ គប្បីពិចារណាឃើញដោយអំណាចនៃលក្ខណៈចំពោះខ្លួន និងលក្ខណៈទូទៅ និងនៃធម៌ដែលជាសភាពទទេ និងដោយអំណាចប្រភេទនៃធម៌ មានធម៌ដែលស្ងប់ជាដើម ដែលមកក្នុងនិទ្ទេសវារៈ នៃអនុ-បស្សនា ៧ មានអនិច្ចានុបស្សនាជាដើម ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

អភិជ្ឈា និងទោមនស្ស ក្នុងលោក គឺ កាយ ដែលព្រះយោគាវចរណាលះបានហើយ ក្នុងកាយានុបស្សនាសតិប្បដ្ឋាននេះ សូម្បីអភិជ្ឈា និងទោមនស្ស ក្នុងលោក គឺ វេទនាជាដើម ក៏ព្រះយោគាវចរនោះ លះបានហើយដូចគ្នាក៏ពិត សូម្បីដូច្នោះ ព្រះមានព្រះភាគ ក៏នៅត្រាស់ការលះអភិជ្ឈា និងទោមនស្ស ក្នុងសតិប្បដ្ឋានគ្រប់ប្រការ ដោយអំណាចនៃបុគ្គលផ្សេង ៗ គ្នា និងដោយអំណាចនៃសតិប្បដ្ឋានភាវនា ដែលប្រព្រឹត្តទៅក្នុងខណៈចិត្តផ្សេងគ្នា ។ ន័យមួយទៀត ព្រោះអភិជ្ឈា និងទោមនស្ស ដែលលះបានក្នុងសតិប្បដ្ឋានទីមួយ សូម្បីក្នុងសតិប្បដ្ឋានដ៏សេសទាំង ៣ ប្រការក៏ជាការលះបានដូចគ្នា ។ ព្រោះដូច្នោះឯង ទើបគួរជ្រាបថា ការលះបង់អភិជ្ឈា និងទោមនស្សនេះ ត្រាស់ទុកដើម្បីទ្រង់សម្តែងការលះក្នុងសតិប្បដ្ឋានទាំងនោះ របស់ភិក្ខុនោះ ដូច្នោះឯង ។

***( ចប់ឧទ្ទេសវារកថា )***

## និទ្ទេសវារកថា

## កាយានុបស្សនាសតិប្បដ្ឋាន

### សម្មាសតិ មានអារម្មណ៍ ៤

[១១២] ជាងត្បាញផែងដែលឆ្លាត ប្រាថ្នានឹងធ្វើគ្រឿងប្រើប្រាស ដូចកន្ទេលរឹង កន្ទេលទន់ តៀប តៅ និងសាជីជាដើម បានឫស្សីមួយដើមធំមក កាត់ជា ៤ កំណាត់ហើយ គប្បីយកកំណាត់មួយៗ ពុះជា ៤ នោះ មកពុះចេញធ្វើជាគ្រឿងប្រើនោះ ៗ សូម្បីយ៉ាងណា ព្រះមានព្រះភាគ ក៏ដូច្នោះដូចគ្នា ឥឡូវនេះ ទ្រង់ប្រាថ្នានឹងធ្វើសត្វទាំងឡាយឲ្យសម្រេចគុណវិសេសផ្សេង ៗ ដោយទ្រង់សម្ដែងសតិប្បដ្ឋាន បែកសម្មាសតិតែម្យ៉ាងប៉ុណ្ណោះ ចេញជា ៤ ចំណែក ដោយអំណាចនៃអារម្មណ៍ ដោយន័យជាដើមថា សតិប្បដ្ឋាន ៤ តើដូចម្ដេច ភិក្ខុក្នុងធម្មវិន័យនេះ ពិចារណាឃើញកាយក្នុងកាយ ដូច្នេះ ទ្រង់កាន់យកសតិប្បដ្ឋានតែមួយយ៉ាង ពី ៤ យ៉ាងនោះ កាលនឹងទ្រង់បែកកាយ ទើបទ្រង់ផ្ដើមត្រាស់និទ្ទេសវារៈ ដោយន័យជាដើមថា កថញ្ច ភិក្ខវេ ។

### អធិប្បាយស័ព្ទក្នុងបុច្ឆាវារៈ

ក្នុងនិទ្ទេសវារៈនោះ ពាក្យថា កថញ្ច ជាដើម ជាពាក្យសួរដោយសំដៅនឹងពង្រីកឲ្យធំទូលាយ ។ ក៏ឯសេចក្តីសង្ខេបក្នុងបុច្ឆាវារៈនេះ មានដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញកាយក្នុងកាយ ដោយប្រការណាហ្ន៎ ។ ក្នុងបុច្ឆាវារៈគ្រប់ប្រការក៏ន័យនេះ ។ ពាក្យថា **ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ** គឺ ភិក្ខុក្នុងព្រះសាសនានេះ ។ ក៏ **ឥធ** សព្ទ ក្នុងពាក្យនេះ ជាគ្រឿងសម្តែងសាសនា ដែលជាទីអាស្រ័យយ៉ាងល្អរបស់បុគ្គល អ្នកបំពេញកាយានុបស្សនាសតិប្បដ្ឋានគ្រប់ប្រការ ឲ្យកើតឡើងហើយ និងជាគ្រឿងបដិសេធសេចក្តីមិនមានពិតរបស់សាសនាដទៃ ។ សមពិត ដូចដែលត្រាស់ទុក ( ក្នុងចូឡសីហនាទសូត្រ មជ្ឈិមនិកាយ មូលបណ្ណាសកៈ ) ថា ម្នាលភិក្ខុទាំងឡាយ សមណៈទី ១ , ទី ២ , ទី ៣ , ទី ៤ មាននៅតែក្នុងសាសនានេះប៉ុណ្ណោះ សាសនាដទៃ សូន្យចាកសមណៈដែលជាព្រះអរហន្តទាំងឡាយ ព្រោះដូច្នោះ ទើបត្រាស់ថា ភិក្ខុក្នុងសាសនានេះ ។

## អានាបានបព្វៈ

ពាក្យថា **ភិក្ខុទៅកាន់ព្រៃ ទៅកាន់គល់ឈើក្តី ទៅកាន់ផ្ទះស្ងាត់ក្តី**

នេះជាគ្រឿងសម្តែងការកំណត់យកសេនាសនៈដែលសមគួរ ដល់ការចម្រើនសតិប្បដ្ឋានរបស់ភិក្ខុនោះ ។ ព្រោះចិត្តរបស់ភិក្ខុ ត្រាច់ទៅក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើមមកយូរ រមែងមិនប្រាថ្នានឹងចុះកាន់វីថិនៃកម្មដ្ឋានធ្លាប់តែត្រាច់ចេញក្រៅផ្លូវ ដូចរទេះដែលទឹមដោយគោកោង ដូច្នោះ ។ ព្រោះដូច្នោះ ភិក្ខុនឹងចម្រើនសតិប្បដ្ឋាននេះ ប្រាថ្នានឹងទូន្មានចិត្តដែលកាចដែលចម្រើនមកដោយការផឹករស មានរូបារម្មណ៍ជាដើមមកយូរ គប្បីប្រាសចេញពីអារម្មណ៍ ដូចរូបារម្មណ៍ជាដើម ហើយចូលទៅព្រៃក៏បាន គល់ឈើក៏បាន ផ្ទះស្ងាត់ក៏បាន ហើយយកខ្សែ គឺ សតិ ចងទុកត្រង់បង្គោល គឺអារម្មណ៍របស់សតិប្បដ្ឋាននោះ ចិត្តរបស់ភិក្ខុនោះ សូម្បីនឹងក្តៅក្រហាយទៅផ្លូវនេះ ផ្លូវនោះ កាលមិនបានអារម្មណ៍ដែលធ្លាប់ឃើញមក មិនអាចកាត់ខ្សែ គឺ សតិឲ្យដាច់ ហើយគេចចៀសចេញបាន ក៏នឹងអែបជិតស្និទ្ធចំពោះអារម្មណ៍នោះតែម្យ៉ាង ដោយអំណាចនៃឧបចារភាវនា និងអប្បនា-ភាវនា ដូចជាអ្នកចិញ្ចឹមគោ ត្រូវការទឹងទូន្មានកូនគោកោង ដែលផឹកដោះមេគោកោង ដរាបធំធាត់ គប្បីពង្រាត់វាចេញអំពីមេគោ ហើយបោះបង្គោលធំមួយទុក យកខ្សែចងទុកត្រង់បង្គោលនោះ គ្រានោះ កូនគោរបស់គេនោះ ក៏នឹងដើរទៅផ្លូវនេះ ផ្លូវនោះ កាលមិនអាចគេចចេញទៅបាន

កំក្រាប ឬដេក ជិតបង្គោលនោះឯង ដូច្នោះ ។ ហេតុនោះ ព្រះបុរាណាចារ្យ ទើបពោលថា ៖

យថា ថម្ភេ និពន្ធេយ្យ វច្ឆំ ទមំ នរោ ឥធ
ពន្ធេយ្យេវំ សកំ ចិត្តំ សតិយារម្មណេ ទឡ្ហំ

**នរជនក្នុងព្រះសាសនានេះ គប្បីចងចិត្តរបស់ខ្លួនទុកក្នុង អារម្មណ៍ឲ្យមាំដោយសតិ ដូចអ្នកចិញ្ចឹមគោ កាលទឹង ទូន្មានកូនគោ គប្បីចងវាទុកត្រង់បង្គោល ដូច្នោះ ។**

សេនាសនៈនេះ រមែងសមគួរដល់ការចម្រើនសតិប្បដ្ឋានរបស់ភិក្ខុ អ្នកចម្រើនសតិប្បដ្ឋាននោះ ដោយប្រការដូច្នេះ ។ ព្រោះដូច្នោះ ខ្ញុំទើប ពោលថា ពាក្យនេះ ជាគ្រឿងសម្ដែងការកំណត់សេនាសនៈដែលសមគួរ ដល់ការចម្រើនសតិប្បដ្ឋាន របស់ភិក្ខុនោះដូច្នេះ ។

## សេនាសនៈដែលសមគួរដល់ការចម្រើនអានាបានស្សតិ

ម្យ៉ាងទៀត ព្រោះព្រះយោគាវចរមិនលះលង្វែកស្រុក ដែលអឺងកង ដោយសំឡេងស្រី ប្រុស ដំរី សេះជាដើម នឹងបំពេញអានាបានស្សតិ កម្មដ្ឋាន ដែលជាកំពូលក្នុងកាយានុបស្សនា ជាបទដ្ឋាននៃការសម្រេច

គុណវិសេស និងធម៌ ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្នរបស់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះសាវកទាំងពួងនេះ ឲ្យសម្រេច មិនមែនធ្វើបានងាយ ៗ ឡើយ ព្រោះឈាន មានសំឡេងជាសត្រូវ តែព្រះយោគាវចរកំណត់កម្មដ្ឋាននេះហើយ ឲ្យចតុត្ថជ្ឈាន មានអានាបានស្សតិជាអារម្មណ៍ កើតឡើង ធ្វើឈាននោះឯង ឲ្យជាបាទ ពិចារណាសង្ខារទាំងឡាយ ហើយសម្រេចព្រះអរហត្ត ដែលជាផលដ៏កំពូល នឹងធ្វើបានងាយ ក៏ប៉ុន្តែ ក្នុងព្រៃដែលមិនមានស្រុក ដូច្នោះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងសេនាសនៈដែលសមគួរដល់ភិក្ខុយោគាវចរនោះ ទើបត្រាស់ថា អរញ្ញ-គតោ វា ***ទៅកាន់ព្រៃក្តី*** ជាដើម ។

ព្រះមានព្រះភាគ ប្រៀបដូចអាចារ្យអ្នកដឹងជ័យភូមិ ។ អាចារ្យអ្នកដឹងជ័យភូមិ ឃើញផ្ទៃដីគួរសាងនគរហើយ ពិចារណាសព្វគ្រប់ហើយ ក៏ប្រាប់ថា អ្នកទាំងឡាយចូរសាងនគរត្រង់នេះ កាលគេសាងនគរសម្រេចដោយសួស្តីហើយ រមែងបានទទួលលាភសក្ការៈយ៉ាងធំ ពីរាជត្រកូលយ៉ាងណា ព្រះមានព្រះភាគនោះ ក៏ដូច្នោះ ទ្រង់ពិចារណាដល់សេនាសនៈដែលសមគួរដល់ព្រះយោគាវចរហើយ ទ្រង់ចង្អុលថា សេនាសនៈត្រង់នេះ ព្រះយោគាវចរគួរប្រកបកម្មដ្ឋានរឿយ ៗ បន្ទាប់ពីនោះ ព្រះយោគី

ចម្រើនកម្មដ្ឋានរឿយ ៗ ក្នុងសេនាសនៈនោះ បានសម្រេចព្រះអរហត្ត តាមលំដាប់ ទ្រង់រមែងបានទទួលសក្ការៈយ៉ាងធំថា ព្រះមានព្រះភាគ ព្រះអង្គនោះ ទ្រង់ត្រាស់ដឹងឯងដោយប្រពៃ ពិតហ្ន៎ ។

ក៏ភិក្ខុនេះ លោកពោលថា ដូចគ្នានឹងខ្លាដំបង ។ ដូចជាស្ដេច ខ្លាដំបងធំ អាស្រ័យស្មៅក្រាស់ ព្រៃក្រាស់ ឬជួរភ្នំក្នុងព្រៃ លាក់ខ្លួនចាំ ចាប់ពួកម្រឹគ មានក្របីព្រៃ រមាំង ជ្រូកព្រៃជាដើម យ៉ាងណា ភិក្ខុនេះ ជាអ្នកមានព្យាយាមប្រកបរឿយ ៗ នូវកម្មដ្ឋានក្នុងព្រៃជាដើម រមែងកាន់ យកអរិយមគ្គ ៤ និងអរិយផល ៤ បានតាមលំដាប់ដូច្នោះដូចគ្នា ។ ព្រោះ ហេតុនោះ ព្រះបុរាណាចារ្យទើបពោលថា ៖

យថាបិ ទីបិកោ នាម　　និលីយិត្វា គណ្ហតី មិគេ

តថេវាយំ ពុទ្ធបុត្តោ　　យុត្តយោគោ វិបស្សកោ

អរញ្ញំ បវិសិត្វាន　　គណ្ហាតិ ផលមុត្តមំ

**ចំណែកខ្លាដំបងលាក់ខ្លួនចាំចាប់ពួកម្រឹគ យ៉ាងណា ភិក្ខុ ដែលជាពុទ្ធបុត្រនេះ ក៏ដូច្នោះដូចគ្នា ចូលទៅកាន់ព្រៃ ហើយ ប្រកបសេចក្ដីព្យាយាម ជាអ្នកមានបញ្ញាឃើញ ច្បាស់ ( ចម្រើនវិបស្សនា ) រមែងកាន់ទុកបានដែលជា**

*ផលដ៏ខ្ពស់បំផុតបាន ។*

*ព្រោះដូច្នោះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងសេនាសនៈព្រៃ ដែលជាភូមិដ៏សមគួរដល់ជវនបញ្ញា ដែលជាគ្រឿងព្យាយាមរបស់ព្រះយោគាវចរនោះ ទើបត្រាស់ថា អរញ្ញគតោ វា* ***ទៅកាន់ព្រៃក្តី*** *ជាដើម ។*

*តពីនេះទៅ មុនដំបូង ពាក្យដែលគួរនឹងពោលក្នុងអានាបានបព្វៈនេះ លោកពោលទុកក្នុងគម្ពីរវិសុទ្ធិមគ្គហើយនោះឯង ។*

## កំណាត់ខ្យល់អស្សាសបស្សាសៈ

*ក៏ពាក្យថា* ***ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជាងក្រឡឹងក្តី ឬកូនសិស្សនៃជាងក្រឡឹងក្តី ដែលប៉ិនប្រសប់*** *នេះ ត្រឹមតែជាពាក្យឧបមាប៉ុណ្ណោះ ។ ពាក្យថា* ***ក្នុងកាយខាងក្នុង*** *នេះ មានត្រឹមតែជាអប្បនាប៉ុណ្ណោះ ។ តែអប្បនានោះ ក៏រមែងមិនមកក្នុងពាក្យនោះ ។ មកតែឧបចារកម្មដ្ឋានដ៏សេស ។ តែក៏នៅមកមិនដល់ពាក្យថា* ***អ្នកប៉ិនប្រសប់*** *សំដៅដល់ អ្នកឆ្លាត ( អ្នកជំនាញ ) ។ ពាក្យថា* ***ទាញខ្សែក្រឡឹងវែងក្តី*** *សេចក្តីថា ទម្រេតដៃ ទម្រេតជើង ទាញខ្សែវែង ក្នុងវេលាក្រឡឹងស្គរ ប្រហោងពិណជាដើម ដែលជារបស់ធំ ។ ពាក្យថា* ***ទាញខ្សែក្រឡឹងខ្លីក្តី***

សេចក្ដីថា ទាញខ្សែខ្វី ៗ ក្នុងវេលាក្រឡឹង របស់តូច ៗ ដូចភ្លុក និង ស្នៀតគន្ធឹះជាដើម ។ ពាក្យថា **ដូច្នោះដូចគ្នា** សេចក្ដីថា សូម្បីភិក្ខុនេះ ក៏ដូច្នោះ កាលដកដង្ហើមចូលវែងដោយខ្យល់អស្សាសៈ និងបស្សាសៈ ដែលប្រព្រឹត្តទៅដោយរយៈវែង និងរយៈខ្លី ក៏ដឹងច្បាស់ថា យើងដកដង្ហើម ចូលវែង ។ល។ ដឹងច្បាស់ថា យើងដកដង្ហើមចេញវែង ដូច្នេះ ។ កាល លោកដឹងច្បាស់យ៉ាងនេះ ឈាន ៤ រមែងកើតក្នុងនិមិត្ត នៃខ្យល់អស្សា-សបស្សាសៈ ។ លោកចេញចាកឈានហើយ ទឹងកំណត់ខ្យល់អស្សាស-បស្សាសៈ ឬអង្គឈានបាន ។

ក្នុងការកំណត់ខ្យល់អស្សាសបស្សាសៈនោះ ភិក្ខុប្រកបកម្មដ្ឋាន ក្នុងខ្យល់អស្សាសបស្សាសៈ រមែងកំណត់រូបយ៉ាងនេះថា ខ្យល់អស្សា-សបស្សាសៈ ទាំងនេះ អាស្រ័យអ្វី អាស្រ័យវត្ថុ ករជកាយ ។ ឈ្មោះថា វត្ថុ មហាភូតរូប ៤ និងឧបាទាយរូប ឈ្មោះថា ករជកាយ តអំពីនោះ ទើបកំណត់ក្នុងនាមធម៌ ដែលមានផស្សៈជាគម្រប់ ៥ ( ១ វេទនា , ២ សញ្ញា , ៣ ចេតនា , ៤ វិញ្ញាណ , ៥ ផស្សៈ ) មានរូបនោះជា អារម្មណ៍ ។ គ្រាកំណត់នាមរូបនោះ យ៉ាងនេះ ដោយប្រការដូច្នេះហើយ ស្វែងរកបច្ច័យនៃនាមរូបនោះ ឃើញបដិច្ចសមុប្បាទ មានអវិជ្ជាជាដើម

ធ្វើផុតសេចក្ដីសង្ស័យចេញបានថា នេះជាត្រឹមតែជាបច្ច័យ និងធម៌ដែលកើតឡើង ព្រោះបច្ច័យប៉ុណ្ណោះ មិនមែនសត្វ ឬបុគ្គល ទើបលើកនាមរូប និងទាំងបច្ច័យ ឡើងកាន់ព្រះត្រៃលក្ខណ៍ ចម្រើនវិបស្សនា រមែងសម្រេចព្រះអរហត្តដោយលំដាប់ ។ នេះជាផ្លូវបដិបត្តិចេញចាកទុក្ខ ដរាបដល់ព្រះអរហត្តរបស់ភិក្ខុមួយរូប ។

ភិក្ខុដែលចម្រើនឈានកម្មដ្ឋាន កំណត់នាមរូបថា អង្គឈានទាំងនេះអាស្រ័យអ្វី អាស្រ័យវត្ថុរូប ករជកាយ ឈ្មោះថា វត្ថុរូប អង្គឈានចាត់ជានាម ករជកាយចាត់ជារូប កាលនឹងស្វែងរកបច្ច័យនៃនាមរូបនោះ ទើបឃើញបច្ចយាការ មានអវិជ្ជាជាដើម ទើបធ្វើសេចក្ដីសង្ស័យចេញបាន ថានេះ ត្រឹមតែជាបច្ច័យ និងធម៌អាស្រ័យបច្ច័យកើតឡើង មិនមែនសត្វ ឬបុគ្គល ទើបលើកនាមរូបព្រមទាំងបច្ច័យ ឡើងកាន់ត្រៃលក្ខណ៍ ចម្រើនវិបស្សនា សម្រេចព្រះអរហត្តដោយលំដាប់ ។ នេះជាផ្លូវនៃការចេញចាកទុក្ខ ដរាបដល់ព្រះអរហត្តរបស់ភិក្ខុមួយរូប ។

ពាក្យថា ឥតិ អជ្ឈត្តំ វា ក្នុងកាយខាងក្នុងក្ដី សេចក្ដីថា ពិចារណាឃើញកាយក្នុងកាយ គឺ ខ្យល់អស្សាសបស្សាសៈរបស់ខ្លួន យ៉ាងនេះ ។ ពាក្យថា **ឬខាងក្រៅ** សេចក្ដីថា ឬពិចារណាឃើញកាយក្នុងកាយ គឺ

ខ្យល់អស្សាសបស្សាសៈរបស់អ្នកដទៃ ។ ពាក្យថា **ទាំងខាងក្នុងទាំងខាងក្រៅក្តី** សេចក្តីថា ឬក្នុងកាយ គឺ ខ្យល់អស្សាសបស្សាសៈរបស់ខ្លួនតាមកាល របស់អ្នកដទៃតាមកាល ដោយពាក្យនេះ ព្រះមានព្រះភាគត្រាស់កាលដែលភិក្ខុនោះ មិនបញ្ឈប់កម្មដ្ឋានដោយរហ័ស ឲ្យកាយ គឺ ខ្យល់អស្សាសបស្សាសៈសញ្ចរទៅមកនៅ ក៏កិច្ចទាំងពីរនេះ រមែងមិនបានក្នុងវេលាតែមួយគ្នា ។

ពាក្យថា **ពិចារណាឃើញធម៌ គឺ ការកើត** សេចក្តីថា ខ្យល់អាស្រ័យស្នប់ជាងមាស ១ ដងស្នប់ ១ សេចក្តីព្យាយាមដែលកើតពីដងស្នប់នោះ ១ ទើបនឹងសញ្ចរទៅមកបាន យ៉ាងណា កាយ គឺ ខ្យល់អស្សាសបស្សាសៈ ក៏អាស្រ័យករជកាយ ១ រន្ធច្រមុះ ១ ចិត្ត ១ របស់ភិក្ខុ ទើបសញ្ចរទៅមកបាន ដូច្នោះ ។ ភិក្ខុឃើញធម៌ មានកាយជាដើមដែលមានការកើតជាធម្មតា លោកហៅថា ពិចារណាឃើញធម៌ គឺ ការកើតក្នុងកាយ ។ ពាក្យថា **ពិចារណាឃើញធម៌ គឺ ការវិនាសទៅក្តី** សេចក្តីថា កាលស្នប់ត្រូវនាំចេញទៅហើយ កាលដងស្នប់បាក់ហើយ កាលសេចក្តីព្យាយាមដែលកើតពីដងស្នប់នោះមិនមាន ខ្យល់នោះ រមែងប្រព្រឹត្តទៅមិនបាន យ៉ាងណា កាលកាយបែកធ្លាយហើយ កាលរន្ធច្រមុះត្រូវ

កម្មាត់ហើយ និងកាលចិត្តរលត់ហើយ ឈ្មោះថា កាយ គឺ ខ្យល់អស្សាស-បស្សាសៈ ក៏រមែងប្រព្រឹត្តទៅមិនបាន ដូច្នោះដែរ ។ ភិក្ខុកាលឃើញយ៉ាងនេះថា ខ្យល់អស្សាសបស្សាសៈរលត់ ព្រោះកាយជាដើមរលត់ ដូច្នេះ លោកហៅថា ពិចារណាឃើញធម៌ គឺ ការវិនាសទៅក្នុងកាយ ។ ពាក្យថា **ពិចារណាឃើញធម៌ គឺ ការកើត និងការវិនាសទៅ** មានន័យថា ពិចារណាឃើញការកើតតាមកាល ការវិនាសទៅតាមកាល ។

ពាក្យថា **សតិរបស់អ្នកប្រាកដច្បាស់ថា កាយមានមែន** សេចក្តីថា សតិរបស់ភិក្ខុនោះ ចូលទៅតាំងចំពោះយ៉ាងនេះថា កាយនេះមាន តែមិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រី មិនមែនប្រុស មិនមែនខ្លួន មិនមែនរបស់ខ្លួន មិនមែនយើង មិនមែនរបស់យើង មិនមែនទរណា មិនមែនរបស់នរណា ។ ពាក្យថា **ត្រឹមតែប៉ុណ្ណោះ** នេះ ជាគ្រឿងកំណត់ដែននៃប្រយោជន៍ ។ លោកអធិប្បាយថា សតិដែលចូលទៅតាំងនោះ មិនមែនដើម្បីប្រយោជន៍យ៉ាងដទៃទេ ដែលពិត ក៏ត្រឹមតែដើម្បីប្រយោជន៍ គឺ សេចក្តីដឹង គឺ ប្រមាណនៃសេចក្តីដឹងក្រៃលែងឡើង ៗ និងប្រមាណនៃសតិប៉ុណ្ណោះ អធិប្បាយថា ដើម្បីសេចក្តីចម្រើននៃសតិសម្បជញ្ញៈ ។ ពាក្យថា **មិនត្រូវកិលេសអាស្រ័យនៅ** សេចក្តីថា មិនត្រូវកិលេសអាស្រ័យ

ដោយអំណាចនៃកិលេសជាទីអាស្រ័យ គឺ តណ្ហា និងទិដ្ឋិ ។ ពាក្យថា **មិនប្រកាន់វត្ថុអ្វី ៗ ក្នុងលោកផង** សេចក្តីថា មិនប្រកាន់វត្ថុអ្វីៗ ក្នុងលោក គឺ រូប ។ល។ ឬវិញ្ញាណថា នេះជាខ្លួនរបស់យើង នេះមានក្នុងខ្លួនរបស់យើង ។ **បិ** អក្សរ ក្នុងពាក្យថា **ឯវំបិ** ចុះក្នុងអត្ថ គឺ អាស្រ័យសេចក្តីខាងមុខប្រមូលមក ។ ក៏ព្រះមានព្រះភាគ ទ្រង់ប្រគល់ទេសនា គឺ **អានាបានបព្វៈ** សម្តែងហើយដោយបទនេះ ។

## អានាបានស្សតិ ជាអរិយសច្ច ៤

ក្នុងអានាបានបព្វៈនោះ សតិដែលកំណត់ខ្យល់អស្សាសបស្សាសៈជាអារម្មណ៍ ជាទុក្ខសច្ច តណ្ហាមានក្នុងកាលមុន ដែលញ៉ាំងទុក្ខសច្ចនោះឲ្យតាំងឡើង ជាសមុទ័យសច្ច ការមិនប្រព្រឹត្តទៅនៃសច្ចៈទាំងពីរ ជានិរោធសច្ច អរិយមគ្គដែលកំណត់ដឹងទុក្ខសច្ច លះសមុទ័យសច្ច មាននិរោធសច្ចជាអារម្មណ៍ ជាមគ្គសច្ច ។ ភិក្ខុយោគាវចរ ខ្វល់ខ្វាយដោយអំណាចសច្ចៈ ៤ យ៉ាងនេះ រមែងសម្រេចការរលត់ទុក្ខបាន ដូច្នេះ ។

នេះជាផ្លូវបដិបត្តិនាំចេញចាកទុក្ខ ដរាបសម្រេចព្រះអរហត្តនៃភិក្ខុដែលតាំងមាំហើយ ដោយអំណាចនៃខ្យល់អស្សាសបស្សាសៈ មួយរូប

ដូច្នេះឯង ។

" ចប់ អានាចានបត្ត: "

## ឥរិយាបថបព្វៈ

[១១៣] ព្រះដ៏មានព្រះភាគ ត្រាស់ទ្រង់ចែកកាយានុបស្សនាដោយផ្លូវនៃខ្យល់អស្សាសបស្សាសៈយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់ចែកដោយផ្លូវនៃឥរិយាបថទើបត្រាស់ថា បុន ចបរំ **មួយវិញទៀត** ជាដើម ។ ក្នុងឥរិយាបថនោះ គប្បីជ្រាបសេចក្តីថា សុនខ្សែសត្វតិរច្ឆាន ដូចជាឆ្កែស្រុក ឆ្កែព្រៃជាដើម កាលដើរទៅ ក៏ដឹងថា ខ្លួនដើរក៏ពិត តែក្នុងឥរិយាបថនោះ មិនបានត្រាស់សំដៅយកសេចក្តីដឹងនោះទេ ។ ព្រោះសេចក្តីដឹងនោះ លះការឃើញថា សត្វមិនបាន ដកសេចក្តីសម្គាល់ថា សត្វមិនបាន ។ មិនជាកម្មដ្ឋាន ឬសតិប្បដ្ឋានភាវនាឡើយ ។ ចំណែកការដឹងរបស់ភិក្ខុ ( អ្នកចម្រើនកាយានុបស្សនា ) នេះ រមែងលះការឃើញថា សត្វ ដកសេចក្តីសម្គាល់ថា សត្វបាន ។ ទាំងជាកម្មដ្ឋាន និងជាសតិប្បដ្ឋានភាវនា ។

មួយទៀត ពាក្យដែលត្រាស់សំដៅដល់សេចក្តីដឹងច្បាស់ យ៉ាងនេះថា **នរណាដើរ ការដើររបស់នរណា ដើរបានព្រោះអ្វី** ។ សូម្បីក្នុងឥរិយាបថដទៃ មានការឈរជាដើម ក៏ន័យនេះដូចគ្នា ។

នឹងវិនិច្ឆ័យក្នុងបញ្ហាទាំងនោះ ពាក្យថា **នរណាដើរ** សេចក្តីថា មិនមែនសត្វ ឬបុគ្គលណា ៗ ដើរ ។ ពាក្យថា **ការដើររបស់នរណា** សេចក្តី

ថា មិនមែនការដើររបស់សត្វ ឬបុគ្គលណា ៗ ដើរ ។ ពាក្យថា **ដើរបាន ព្រោះអ្វី** សេចក្តីថា ដើរបានព្រោះការផ្សាយទៅរបស់វាយោធាតុ ដែលកើតពីការធ្វើរបស់ចិត្ត ។ ព្រោះដូច្នោះ ភិក្ខុនោះ រមែងដឹងច្បាស់យ៉ាងនេះ គឺ ចិត្តកើតឡើងថា យើងនឹងដើរ ចិត្តនោះក៏ធ្វើឲ្យកើតវាយោធាតុ ៗ ក៏ធ្វើឲ្យកើតវិញ្ញត្តិ ការកម្រើក ការនាំសកលកាយ ឲ្យឈានទៅខាងមុខ ដោយការកម្រើកនៃវាយោធាតុ ដែលកើតពីការធ្វើរបស់ចិត្ត ហៅថា ដើរ ។ សូម្បីក្នុងឥរិយាបថដទៃ មានឈរជាដើម ក៏ន័យនេះដូចគ្នា ។ ក៏ក្នុងឥរិយាបថឈរជាដើមនោះ ចិត្តកើតឡើងថា យើងនឹងឈរ ចិត្តនោះធ្វើឲ្យកើតវាយោធាតុ ៗ ធ្វើឲ្យកើតការកម្រើក ការទ្រទ្រង់សកលកាយ តាំងឡើងពីផែនដី មានជើងជាទីបំផុត ដោយការកម្រើកនៃវាយោធាតុ ដែលកើតពីការធ្វើរបស់ចិត្ត ហៅថា ឈរ ។ ចិត្តកើតឡើងថា យើងនឹងអង្គុយ ចិត្តនោះ ក៏ធ្វើឲ្យកើតវាយោធាតុ ៗ ក៏ធ្វើឲ្យវិញ្ញត្តិការកម្រើក ការបត់កាយខាងក្រោម ទ្រទ្រង់កាយខាងលើតាំងឡើង ដោយការកម្រើកនៃវាយោធាតុ ដែលកើតអំពីការធ្វើរបស់ចិត្ត ហៅថា អង្គុយ ។ ចិត្តកើតឡើងថា យើងនឹងដេក ចិត្តនោះក៏ធ្វើឲ្យកើតវាយោធាតុ ៗ ធ្វើឲ្យកើតវិញ្ញត្តិការកម្រើក ការសណ្តូកកាយទាំងអស់ឲ្យជារបស់វែង ដោយការកម្រើកនៃវាយោធាតុ

ដែលកើតពីការធ្វើរបស់ចិត្ត ហៅថា ដេក ។ កាលភិក្ខុនោះ ដឹងច្បាស់យ៉ាងនេះ រមែងមានសេចក្ដីគិតឃើញយ៉ាងនេះថា ដែលពោលបានថា សត្វដើរ សត្វឈរ តែដោយអត្ថហើយ សត្វណា ៗ ដែលដើរ ដែលឈរមិនមាន ដូចពាក្យដែលគេពោលថា រទេះទៅ រទេះឈប់ តែជម្មតាថា រទេះណា ៗ ដែលទៅបាន ឈប់បានខ្លួនឯង មិនមានទេ តែកាលនាយសារថីអ្នកឆ្លាត ទឹមគោ ៤ ក្បាល ហើយដេញទៅ រទេះទើបទៅ ទើបឈប់ព្រោះដូច្នោះ ពាក្យនោះ ទើបមានត្រឹមតែបញ្ញត្តិសម្មតិហៅយ៉ាងណា កាយប្រៀបដូចរទេះ ព្រោះអត្ថថា មិនដឹង ខ្យល់ដែលកើតពីចិត្ត ប្រៀបដូចគោចិត្តប្រៀបដូចសារថី កាលចិត្តកើតឡើងថា យើងនឹងដើរ យើងនឹងឈរវាយោធាតុដែលធ្វើឲ្យកើតការកម្រើក ក៏កើតឡើង ឥរិយាបថ មានដើរជាដើម រមែងប្រព្រឹត្តទៅ ព្រោះការកម្រើកនៃវាយោធាតុ ដែលកើតពីការធ្វើរបស់ចិត្ត តអំពីនោះ សត្វក៏ដើរ សត្វក៏ឈរ យើងដើរ យើងឈរព្រោះហេតុនោះ ពាក្យនោះ ទើបមានត្រឹមតែបញ្ញត្តិសម្មតិហៅគ្នា ដូច្នោះដូចគ្នា ។ ព្រោះហេតុនោះ ព្រះបុរាណាចារ្យទើបពោលថា ៖

ណាវា មាលុតវេគេន ជិយាវេគេន តេជនំ
យថា យាតិ តថា កាយោ យាតិ វាតាហតោ អយំ

យន្តំ សុត្តវសេនេវ ចិត្តសុត្តវសេនិទំ
បយុត្តំ កាយយន្តម្បិ យាតិ ឋាតិ និសីទតិ
កោ នាម ឯត្ថ សោ សត្តោ យោ វិនា ហេតុបច្ចយេ
អត្តនោ អានុភាវេន តិដ្ឋេ វា យទិ វា វជេ

*ទូកស្ទុះទៅបានដោយកម្លាំងខ្យល់ កូនធ្នូស្ទុះទៅដោយកម្លាំងខ្សែធ្នូយ៉ាងណា កាយនេះដែលខ្យល់នាំទៅ ទើបដើរដើរទៅបាន ដូច្នោះ សូម្បីយន្ត គឺ កាយនេះ ដែលបច្ច័យប្រកបហើយ ដើរ ដេក ឈរ និងអង្គុយ បានដោយអំណាចខ្សែនាំ គឺ ចិត្ត ដូចគ្រឿងយន្ត វិលទៅបានដោយអំណាចខ្សែនាំ ដូច្នោះឯង ក្នុងលោកនេះ សត្វណាវៀរហេតុបច្ច័យចេញហើយ ឈរបាន ដើរបាន ដោយអានុភាពរបស់ខ្លួនឯង សត្វនោះឈ្មោះថា នឹងមានដូចម្តេច ដូច្នេះ ។*

ព្រោះដូច្នោះ គប្បីជ្រាបថា ភិក្ខុនេះ កំណត់ឥរិយាបថ មានដើរជាដើម ដែលប្រព្រឹត្តទៅបាន ដោយអំណាចហេតុបច្ច័យប៉ុណ្ណោះ យ៉ាងនេះ កាលដើរក៏ដឹងថា យើងដើរ កាលឈរក៏ដឹងថា យើងឈរ កាលអង្គុយក៏ដឹងថា យើងអង្គុយ កាលដេកក៏ដឹងថា យើងដេក ដូច្នេះ ។

ពាក្យថា **ឬកាយរបស់ភិក្ខុតាំងទៅដោយអាការណា ក៏ដឹងកាយនោះដោយអាការនោះៗ** នេះ ជាពាក្យពោលរួមឥរិយាបថទាំងពួង ។ មានពាក្យអធិប្បាយថា ឬកាយរបស់លោកតាំងទៅដោយអាការណា ៗ ក៏ដឹងច្បាស់កាយនោះ ដោយអាការនោះ ៗ គឺ កាយនោះ តាំងទៅដោយអាការដើរ ក៏ដឹងច្បាស់ថា យើងដើរ កាយតាំងទៅដោយអាការឈរ អង្គុយ ដេក ក៏ដឹងច្បាស់ថា យើងឈរ យើងអង្គុយ យើងដេក ។

## ឥរិយាបថខាងក្នុង ខាងក្រៅ

ពាក្យថា **ខាងក្នុងក្តី ដូច្នេះ** សេចក្តីថា ពិចារណាឃើញកាយក្នុងកាយ ដោយការកំណត់ឥរិយាបថ ៤ របស់ខ្លួនឯងយ៉ាងនេះ ។ ពាក្យថា **ខាងក្រៅក្តី** សេចក្តីថា ដោយការកំណត់ឥរិយាបថ ៤ របស់អ្នកដទៃ ។ ពាក្យថា **ទាំងខាងក្នុងទាំងខាងក្រៅក្តី** សេចក្តីថា ពិចារណាឃើញកាយក្នុងកាយ ដោយការកំណត់ឥរិយាបថ ៤ របស់ខ្លួនឯងតាមកាល របស់អ្នកដទៃតាមកាល ។ ក៏ក្នុងពាក្យបាលីជាដើមថា **ពិចារណាឃើញធម៌ គឺការកើតក្តី** គឺ គប្បីនាំការកើត និងការវិនាសនៃរូបក្ខន្ធ សម្តែងដោយអាការទាំង ៥ តាមន័យបាលីជាដើមថា រូបកើត ព្រោះអវិជ្ជាកើត ដូច្នេះ ។

ព្រះមានព្រះភាគ ទ្រង់សំដៅយកការកើត និងការវិនាសនោះឯង ត្រាស់ថា **ពិចារណាឃើញធម៌ គឺ ការកើតក្តី** ដូច្នេះជាដើម ក្នុងទីនេះ ។

ពាក្យបាលីជាដើមថា **សតិរបស់ភិក្ខុក៏ប្រាកដច្បាស់ថា កាយមានមែន** ដូច្នេះ ក៏មានសេចក្តីដូចគ្នាដែលពោលមកហើយនុ៎ះឯង ។

## សតិកំណត់ឥរិយាបថ ជាអរិយសច្ច ៤

សូម្បីក្នុងឥរិយាបថបព្វៈនេះ សតិដែលកំណត់ឥរិយាបថ ៤ ជាអារម្មណ៍ ជាទុក្ខសច្ច , តណ្ហាដែលមានក្នុងកាលមុន ដែលញ៉ាំងសតិដែលកំណត់ឥរិយាបថ ៤ នោះ ឲ្យតាំងឡើង ជាសមុទ័យសច្ច , ការមិនមានទុក្ខសច្ច និងសមុទ័យសច្ចទាំងពីរ ជានិរោធសច្ច , អរិយមគ្គដែលកំណត់ដឹងទុក្ខ លះសមុទ័យ មាននិរោធជាអារម្មណ៍ ជាមគ្គសច្ច ភិក្ខុជាយោគាវចរខ្វល់ខ្វាយដោយផ្លូវសច្ចៈ ៤ យ៉ាងនេះ រមែងសម្រេចព្រះនិព្វានរលត់ទុក្ខ ។ នេះជាផ្លូវបដិបត្តិនាំចេញចាកទុក្ខ ដរាបដល់ព្រះអរហត្ត របស់ភិក្ខុដែលកំណត់ឥរិយាបថ ៤ មួយរូប ដូច្នេះឯង ។

( ចប់ ឥរិយាបថបព្វៈ )

## សម្បជញ្ញបព្វៈ

[១១៤] *ព្រះមានព្រះភាគ លុះទ្រង់ចែកកាយានុបស្សនា ដោយផ្លូវឥរិយាបថ ៤ យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់ចែកដោយផ្លូវសម្បជញ្ញៈ ៤ ទើបត្រាស់ថា បុន ចបរំ ជាដើម ។ ក្នុងសម្បជញ្ញបព្វៈនោះ ពាក្យថា* **ឈានទៅមុខ** *ជាដើម ទ្រង់ពណ៌នាទុកហើយក្នុងសាមញ្ញផលសូត្រ ។ ពាក្យថា* **ខាងក្នុងក្តី** *សេចក្តីថា ពិចារណាឃើញកាយក្នុងកាយរបស់ខ្លួន ឬក្នុងកាយរបស់អ្នកដទៃ ឬក្នុងកាយរបស់ខ្លួនតាមកាលរបស់អ្នកដទៃតាមកាល ដោយកំណត់សម្បជញ្ញៈ ៤ យ៉ាងនេះ ។ ការកើតនិងការវិនាសនៃរូបក្ខន្ធនោះឯង គប្បីនាំមកសំដែងក្នុងពាក្យថា* **ពិចារណាឃើញធម៌ គឺ ការកើត** *ជាដើម សូម្បីក្នុងសម្បជញ្ញបព្វៈនេះ ។ ពាក្យក្រៅពីនេះ ក៏ដូចគ្នានឹងពោលមកហើយនុ៎ះឯង ។*

## សតិកំណត់សម្បជញ្ញៈ ជាអរិយសច្ច ៤

*ក្នុងសម្បជញ្ញបព្វៈនេះ សតិកំណត់សម្បជញ្ញៈ ៤ ជាទុក្ខសច្ច , តណ្ហាដែលមានក្នុងកាលមុន ដែលញុំាងសតិកំណត់សម្បជញ្ញៈ ៤ នោះឲ្យតាំងឡើង ជាសមុទយសច្ច , ការមិនកើតទុក្ខសច្ច និងសមុទយសច្ច*

*ទាំងពីរ ជានិរោធសច្ច , អរិយមគ្គមានប្រការដូចពោលមកហើយ ជាមគ្គ-សច្ច , ភិក្ខុយោគាវចរ ខ្វល់ខ្វាយដោយផ្លូវសច្ចៈ ៤ យ៉ាងនេះ រមែង សម្រេចនិព្វានរលត់ទុក្ខបានឯង ។ នេះជាផ្លូវបដិបត្តិនាំទុក្ខចេញដកពបដល់ ព្រះអរហត្ត របស់ភិក្ខុដែលកំណត់សម្បជញ្ញៈ ៤ មួយរូបដូច្នេះឯង ។*

" ចប់ សម្បជញ្ញបព្វ "

## បដិក្កូលមនសិការបព្វៈ

[១១៥] ព្រះមានព្រះភាគ ត្រាទ្រង់ចែកកាយានុបស្សនាដោយផ្លូវសម្បជញ្ញៈ ៤ យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់ចែកការដាក់ចិត្តដល់កាយ ដោយភាពជារបស់បដិកូលទើបត្រាស់ថា បុន ចបរំ ជាដើម ។ ក្នុងបដិកូលមនសិការបព្វៈនោះ ពាក្យណាដែលគួរពោលក្នុងបាលីជាដើមថា **កាយនេះឯង** ពាក្យនោះទាំងអស់ លោកពោលទុកហើយក្នុងកាយគតាសតិកម្មដ្ឋាន ក្នុងគម្ពីរវិសុទ្ធិមគ្គដោយពិស្តារ ដោយអាការទាំងពួង ។ ពាក្យថា **មានមាត់ទាំងពីរខាង** សេចក្តីថា ប្រកបដោយមាត់ទាំងពីរ , ខាងក្រោម ខាងលើ ។ ពាក្យថា **មានប្រភេទផ្សេងៗ** គឺ មានប្រភេទផ្សេង ៗ ។ ក្នុងសេចក្តីនោះ មានពាក្យប្រៀបធៀបឧបមាដូចតទៅនេះ ។ ក៏កាយដែលប្រកបដោយមហាភូតរូប ៤ គប្បីជ្រាប ប្រៀបដូចថង់ មានមាត់ពីរខាង , អាការ ៣២ មានសក់ជាដើម ប្រៀបដូចធញ្ញជាតប្រភេទផ្សេងៗ ដែលគេដាក់លាយគ្នាចុះទៅក្នុងថង់នោះ , ព្រះយោគាវចរ ប្រៀបដូចបុរសមានចក្ខុ , អាការប្រាកដច្បាស់នៃអាការ ៣២ របស់ព្រះយោគាវចរ គប្បីជ្រាបដូចអាការដែលធញ្ញជាតិប្រភេទផ្សេងៗ ប្រាកដដល់បុរសអ្នកស្រាយថង់នោះចេញ ហើយពិចារណាមើល ។

ពាក្យថា **ខាងក្នុងក្តី** សេចក្តីថា ពិចារណាឃើញកាយក្នុងកាយរបស់ខ្លួន ឬក្នុងកាយរបស់អ្នកដទៃ ឬក្នុងកាយរបស់ខ្លួនតាមកាល របស់អ្នកដទៃតាមកាល ដោយការកំណត់អាការ ៣២ មានសក់ជាដើម យ៉ាងនេះ ៗ សេចក្តីតពីនេះទៅ ក៏មានន័យដូចដែលពោលមកហើយ ៗ ក្នុងបដិកូលមនសិការបព្វៈនេះ ផ្សេងគ្នាតែម្យ៉ាង ក៏គឺ គួរប្រកបសេចក្តីយ៉ាងនេះថា សតិកំណត់អាការ ៣២ ជាអារម្មណ៍ ជាទុក្ខសច្ច ហើយគប្បីជ្រាបថា ជាផ្លូវបដិបត្តិនាំចេញចាកទុក្ខដរាបដល់ព្រះអរហត្ត របស់ភិក្ខុដែលកំណត់អាការ ៣២ មួយរូប ៗ ពាក្យក្រៅពីនេះ ក៏ដូចជាគ្នាដែលពោលមកហើយនោះឯង ៗ

" ចប់ បដិក្កូលមនសិការបព្វៈ "

## ធាតុមនសិការបព្វៈ

[១១៦] ព្រះមានព្រះភាគ ត្រាទ្រង់ចែកកាយានុបស្សនាដោយផ្លូវការដាក់ចិត្តដល់កាយដោយភាពជារបស់បដិកូលយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់ចែកដោយផ្លូវការដាក់ចិត្តដល់កាយ ដោយភាពជាធាតុ ទើបត្រាស់ធាតុមនសិការបព្វៈថា បុន ចបរំ ជាដើម ។ ក្នុងធាតុមនសិការបព្វៈនោះ មានការពណ៌នាអត្ថព្រមដោយសេចក្តីប្រៀបធៀបឧបមាដូចតទៅនេះ ។ អ្នកសម្លាប់គោខ្លះ ឬកូនឈ្នួលរបស់គេ ដែលគេចិញ្ចឹមរក្សាដោយអាហារ និងតម្លៃឈ្នួល សម្លាប់គោហើយ ចៀរ បែងចែកចេញជាចំណែក ៗ ហើយអង្គុយក្នុងផ្លូវធំបែកជា ៤ គឺ ទីប្រជុំផ្លូវ ត្រង់កណ្តាលផ្លូវធំ ដែលទៅបានទាំង ៤ ទិស យ៉ាងណា ភិក្ខុ (អ្នកបំពេញធាតុកម្មដ្ឋាន) ក៏ដូច្នោះនុ៎ះឯង រមែងពិចារណាកាយ ដែលឈ្មោះថា តាមដែលតាំងនៅហើយ ព្រោះតាំងនៅដោយអាការយ៉ាងណាមួយ នៃឥរិយាបថទាំង ៤ និងដែលឈ្មោះថា តាមដែលតម្កល់នៅ ព្រោះតាមដែលតាំងនៅយ៉ាងនេះថា ក្នុងកាយនេះ មានបឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ ។

## កាយត្រឹមតែជា ធាតុ ៤

លោកអធិប្បាយទុកយ៉ាងណា ។ លោកអធិប្បាយទុកថា កាលអ្នកសម្លាប់គោ ចិញ្ចឹមគោក្តី នាំគោទៅកាន់ទីសម្លាប់ក្តី នាំមកចងទុកត្រង់ទីសម្លាប់ក្តី កំពុងសម្លាប់ក្តី សម្លឹងមើលគោដែលសម្លាប់ស្លាប់ហើយក្តី ការសម្គាល់ថា គោ មិនទាន់បាត់ទៅ ដរាបដែលគេមិនទាន់បានចៀរគោនោះ ចេញជាចំណែក ៗ កាលគេចៀរ បែងចែកចេញហើយ ការសម្គាល់ថាគោក៏បាត់ទៅ ត្រឡប់សម្គាល់ថា សាច់គោ គេមិនបានគិតថា យើងលក់គោ អ្នកទាំងនេះទិញគោ ដែលពិត គេគិតថា យើងលក់សាច់គោអ្នកទាំងនេះទិញសាច់គោ យ៉ាងណា សូម្បីភិក្ខុនេះ ក៏ដូច្នោះដូចគ្នា កាលនៅជាបុថុជ្ជនល្ងង់ខ្លៅ ជាគ្រហស្ថក្តី បព្វជិតក្តី ការសម្គាល់ថា សត្វឬបុគ្គល មិនទាន់បាត់ទៅ ដរាបណាដែលនៅទាន់មិនពិចារណាឃើញកាយនេះឯង តាមដែលតាំងនៅ តាមដែលតម្កល់នៅ បែកចេញជាដុំ ដោយភាពជាធាតុ កាលលោកពិចារណាឃើញដោយភាពជាធាតុ ការសម្គាល់ថាសត្វ ទើបបាត់ទៅ ចិត្តក៏តាំងនៅដោយល្អ ដោយភាពជាធាតុតែម្យ៉ាង ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ថា ភិក្ខុពិចារណាឃើញកាយនេះ យ៉ាងនេះឯង តាមដែលតាំងនៅ តាមដែលតម្កល់នៅ ដោយភាពជា

ធាតុថា មាននៅក្នុងកាយនេះ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោ-ធាតុ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចអ្នកសម្លាប់គោ ឬកូនឈ្នួលរបស់អ្នកសម្លាប់គោដែលប៉ិនប្រសប់ ។ល។ វាយោធាតុ ដូច្នេះ ។ ក៏ព្រះយោ-គាវចរ ប្រៀបដូចអ្នកសម្លាប់គោ សេចក្តីសម្គាល់ថា សត្វ ប្រៀបដូចសេចក្តីសម្គាល់ថា គោ , ឥរិយាបថទាំង ៤ ប្រៀបដូចផ្លូវធំបែកជា ៤ ការពិចារណាឃើញថា ជាធាតុ ប្រៀបដូចអ្នកសម្លាប់គោអង្គុយបែងចែកចេញជាចំណែក ៗ នេះជាការពណ៌នាបាលី ក្នុងធាតុមនសិការបព្វៈនេះ ។ ចំណែកកថាពោលដោយកម្មដ្ឋាន លោកពណ៌នាទុកពិស្តារ ក្នុងគម្ពីរវិសុទ្ធិមគ្គហើយ ។ ពាក្យថា **ខាងក្នុងក្តី** សេចក្តីថា ពិចារណាឃើញខាងក្នុងកាយរបស់ខ្លួន ឬក្នុងកាយរបស់អ្នកដទៃ ឬក្នុងកាយរបស់ខ្លួនតាមកាល របស់អ្នកដទៃតាមកាល ដោយការកំណត់ធាតុ ៤ ដោយអាការយ៉ាងនេះ ។ សេចក្តីតទៅពីនេះ ក៏មានន័យដូចពោលមកហើយទាំងនោះ ។ តែក្នុងទីនេះ មានសេចក្តីផ្សេងគ្នាតែម្យ៉ាង គឺ គប្បីប្រកបសេចក្តីយ៉ាងនេះថា សតិកំណត់ធាតុ ៤ ជាអារម្មណ៍ ជាទុក្ខសច្ចជាដើម ។ គប្បីជ្រាបថា នេះជាផ្លូវបដិបត្តិនាំចេញចាកទុក្ខរបស់ភិក្ខុ ដែលកំណត់ធាតុ ៤ ដូច្នេះ ។ ចំណែកពាក្យដ៏សេស ក៏ដូចដែលពោលមកហើយក្នុងកាលមុននុ៎ះឯង ។

" ចប់ ធាតុមនសិការបព្វៈ "

## នវសីវថិកាបព្វៈ

[១១៧] ព្រះមានព្រះភាគ ត្រាស់ចែកកាយានុបស្សនាដោយ ផ្លូវជាគុមនសិការយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់ចែកដោយ នវសីវថិកាបព្វៈ សេចក្ដីកំណត់ថា ដោយព្រៃជាទីចោលសាកសព ៩ ប្រការ ទើបត្រាស់ថា **នៅមានប្រការមួយទៀត** ជាដើម ។ បណ្ដាទាំង នោះ បទថា **ដូចជាថា ឃើញ** គឺ ដូចថា ជួប ។ បទថា **សរីរៈ** គឺ សរីរៈរបស់អ្នកស្លាប់ ។ បទថា **ដែលគេចោលត្រង់ព្រៃស្មសាន** គឺ ដែល គេចោលក្នុងព្រៃស្មសាន ។ សាកសពដែលឈ្មោះថា **ស្លាប់បានមួយថ្ងៃ** ព្រោះជាសាកសពដែលស្លាប់ហើយបាន ១ ថ្ងៃ ។ ដែលឈ្មោះថា **ស្លាប់ បាន ២ ថ្ងៃ** ព្រោះជាសាកសពដែលស្លាប់ហើយបាន ២ ថ្ងៃ ។ ដែល ឈ្មោះថា **ស្លាប់បាន ៣ ថ្ងៃ** ព្រោះសាកសពដែលស្លាប់ហើយបាន ៣ ថ្ងៃ ។ ដែលឈ្មោះថា **សាកសពដែលហើមឡើង** ព្រោះជាសាកសពដែលប៉ោង ឡើង ដោយជាសាកសពដែលហើមប៉ោងឡើង តាមលំដាប់ តាំងពីអស់ ជីវិតទៅ ដូចកូនឈ្នួលជាងមាសដែលសប់ឲ្យប៉ោងឡើង ដោយខ្យល់ ។ សាកសពដែលប៉ោងឡើងនុ៎ះឯង ឈ្មោះថា ឧទ្ធុមាតក ។ ន័យមួយទៀត

សាកសពដែលប៉ោងឡើងគួរខ្ពើម ព្រោះជារបស់បដិកូល ព្រោះហេតុនោះ ទើបឈ្មោះថា ឧទ្ធុមាតកៈ ។ សាកសពដែលមានពណ៌ផ្សេង ៗ លាយដោយពណ៌ខៀវ ហៅថា សាកសពដែលមានពណ៌ខៀវលាយ ។ សាកសពដែលមានពណ៌ខៀវលាយនុ៎ះឯង ឈ្មោះថា វិនីលក ។ ន័យមួយទៀត សាកសពដែលមានពណ៌ខៀវគួរខ្ពើម ព្រោះជារបស់បដិកូល ព្រោះហេតុនោះ ទើបឈ្មោះថា វិនីលក ។ ពាក្យថា វិនីលកៈនេះ ជាឈ្មោះរបស់សាកសពមានពណ៌ក្រហម ក្នុងកន្លែងសាច់ប៉ោងឡើងក្រាស់ មានពណ៌សក្នុងទីដែលខ្ទុះ ដោយច្រើនមានពណ៌ខៀវ ក្នុងទីគួរខៀវ ស្រដៀងសម្ពត់ដណ្ដប់ពណ៌ខៀវ ។ សាកសពដែលមានខ្ទុះហូរចេញចាកទីជុំវិញ នៃទ្វារទាំង ៩ ខ្ទះ ឈ្មោះថា សាកសពមានខ្ទុះហូរ ។ សាកសពមានខ្ទុះហូរនុ៎ះឯង ឈ្មោះថា វិបុព្វក ។ ន័យមួយទៀត សាកសពមានខ្ទុះហូរគួរខ្ពើម ព្រោះជារបស់បដិកូល ព្រោះហេតុនោះ ទើបឈ្មោះថា វិបុព្វកៈ ។ សាកសពដែលជាវិបុព្វកៈ កើតហើយ គឺ ដល់ភាពជាសាកសពមានខ្ទុះហូរយ៉ាងនោះ ព្រោះហេតុនោះ ឈ្មោះថា **វិបុព្វកជាត** ។ ប្រការថា សោ ឥមមេវ កាយំ សេចក្ដីថា ភិក្ខុនោះ ប្រើញាណនុ៎ះឯង បង្អោនទាំកាយរបស់ខ្លួននេះទៅប្រៀបដូចនឹងកាយនោះ ( សាកសព ) ។ តើប្រៀបធៀបយ៉ាងណា ?

ប្រៀបថា កាយនេះឯង មានសភាពយ៉ាងនោះ ជាធម្មតា ត្រូវតែជាយ៉ាងនោះ មិនកន្លងផុតពីសភាពយ៉ាងនោះទៅបានឡើយ ។

## កាយដែលប្រាសចាកអាយុ កម្តៅ វិញ្ញាណ ជាសាកសព

លោកអធិប្បាយទុកថា កាយនេះ ដែលទៅឈរ ដើរ ជាដើមបាន ក៏ព្រោះមានធម៌ ៣ យ៉ាងនេះ គឺ អាយុ កម្តៅ និងវិញ្ញាណ តែព្រោះធម៌ ៣ យ៉ាងនេះ ប្រាសចាកពីគ្នា សូម្បីកាយនេះ ទើបត្រូវមានយ៉ាងនោះ ជាធម្មតា គឺ មានសភាពស្អុយរលួយយ៉ាងនោះដូចគ្នា ត្រូវជាយ៉ាងនោះ គឺ នឹងជាប្រភេទសាកសពឡើងប៉ោងជាដើម យ៉ាងនោះដូចគ្នា មិនកន្លងផុតសភាពជាយ៉ាងនោះទៅបាន គឺ មិនកន្លងផុតសភាពជាសាកសពហើមប៉ោងជាដើមយ៉ាងនោះ ទៅបាន ។

ពាក្យថា **ខាងក្នុងក្តី** សេចក្តីថា ពិចារណាឃើញកាយក្នុងកាយរបស់ខ្លួន ក្នុងកាយរបស់ខ្លួនដទៃ ឬក្នុងកាយរបស់ខ្លួនតាមកាល របស់អ្នកដទៃតាមកាល ដោយការកំណត់សាកសពដែលហើមប៉ោងជាដើម យ៉ាងនេះ ។

## ប្រៀបធៀបកាយជាមួយសាកសព

[**១១៨**] បទថា ១ជ្ជមានំ ដែលសត្វខាំស៊ី បានដល់ សាកសព

ដែលមានសត្វត្មាត ក្អែកជាដើម ទំលើអវយវៈ ដូចជាពោះជាដើម ហើយទាញសាច់ពោះ សាច់មាត់ រន្ធក្អែកជាដើម នាំគ្នាចឹកស៊ី ។

[១១៩] បទថា សមំសលោហិតំ នៅមានសាច់ និងឈាម គឺសាកសពដែលមានសាច់ និងឈាមនៅសល់ ។

[១២០-១២១] បទថា និម្មំសលោហិតមក្ខិតំ ដែលប្រាសចាកសាច់ តែប្រឡាក់ឈាម គឺ កាលសាច់អស់ទៅហើយ តែឈាមមិនទាន់ស្ងួត ។ ព្រះមានព្រះភាគ ទ្រង់សំដៅយកសាកសពប្រភេទនោះ ទើបត្រាស់ថា និម្មំ-សលោហិតមក្ខិតំ ។

[១២២-១២៣] បទថា អញ្ញេន គឺ សាកសពទៅក្នុងទិសដទៃ ។ បទថា ហត្ថដ្ឋិកំ ឆ្អឹងដៃ សេចក្តីថា ឆ្អឹងដៃមានប្រភេទដល់ ៦៤ កំណាត់ ខ្ចាត់ខ្ចាយបែកគ្នាទៅ ។ សូម្បីឆ្អឹងជើងជាដើម ក៏ន័យនេះដូចគ្នា ។

[១២៤] បទថា តេរោវស្សិកានិ លើសពីមួយឆ្នាំឡើងទៅ គឺ កន្លងឆ្នាំទៅហើយ ។

[១២៥] បទថា បូតីនិ ជារបស់ពុកផុយ សេចក្តីថា ឆ្អឹងដែលតាំងនៅកណ្តាលវាល រមែងពុកផុយ ព្រោះប៉ះខ្យល់ កំដៅថ្ងៃ និងភ្លៀង ចំណែកឆ្អឹងដែលនៅក្នុងផែនដី រមែងតាំងនៅបានយូរជាង ។ បទថា

ចុណ្ណកជាតានិ ជាផង់ធូលី គឺ ជាកម្ទេចផង់ខ្ចាត់ខ្ចាយទៅ ។ គប្បីប្រកប ការយល់ចូលក្នុងសេចក្តីទាំងពួង ដោយបទថា ១ជ្ឈមាន ត្រូវសត្វខាំស៊ី ជាដើម ដោយន័យដែលពោលមកហើយថា ភិក្ខុក៏បង្អោនកាយនេះឯង ចូលទៅប្រៀបធៀបនឹងសាកសព ជាដើម ។

បទថា **ខាងក្នុងជាដើម** សេចក្តីថា ពិចារណាឃើញកាយក្នុងកាយ របស់ខ្លួន ក្នុងកាយរបស់អ្នកដទៃ ឬក្នុងកាយរបស់ខ្លួនតាមកាល របស់អ្នក ដទៃតាមកាល ដោយការកំណត់សាកសព ដែលសត្វខាំស៊ីជាដើម ដរាប ដល់ឆ្អឹងដែលបែកខ្ទេចខ្ទីជាកម្ទេចផង់យ៉ាងនេះ ។

## ចាត់ជាបព្វៈ

ព្រៃជាទីចោលសាកសព ៩ ប្រការ ក្នុងនវសីវថិកាបព្វៈនេះ បណ្ឌិត គប្បីប្រមូលមកដូច្នេះ គឺ ៖

១. ពាក្យដែលត្រាស់ដោយន័យជាដើមថា សាកសពស្លាប់អស់ ១ ថ្ងៃខ្លះ សូម្បីទាំងអស់ ជាបព្វៈប្រការទីមួយ ។

២. ពាក្យដែលថា សាកសពដែលត្រូវហ្វូងក្អែកចឹកស៊ីខ្លះ ជាដើម ជាបព្វៈប្រការមួយ ។

៣. ពាក្យដែលថា រាងឆ្អឹង ដែលនៅមានសាច់ និងឈាម មានសរសៃចងរួបរឹត ជាបព្វៈប្រការមួយ ។

៤. ពាក្យថា ប្រាសចាកសាច់ តែប្រឡាក់ឈាម មានសរសៃជាគ្រឿងចងរួបរឹត ជាបព្វៈប្រការមួយ ។

៥. ពាក្យថា ប្រាសចាកសាច់ និងឈាម តែមានសរសៃជាគ្រឿងចងរួបរឹត ជាបព្វៈប្រការមួយ ។

៦. ពាក្យថា ឆ្អឹងទាំងឡាយដែលប្រាសចាកសរសៃចងរួបរឹតជាដើម ជាបព្វៈប្រការមួយ ។

៧. ពាក្យថា ឆ្អឹងទាំងឡាយ-ស ដូចជាសម្បុរនៃស័ង្ខ ជាបព្វៈប្រការមួយ ។

៨. ពាក្យថា ឆ្អឹងទាំងឡាយដែកគរ រាត់រាយ លើសមួយឆ្នាំឡើងទៅ ជាបព្វៈប្រការមួយ ។

៩. ពាក្យថា ឆ្អឹងទាំងឡាយដែលពុកផុយ ជាកម្ទេចតូចធំផ្សេង ៗ ជាបព្វៈប្រការមួយ ។

ព្រះមានព្រះភាគ គ្រាទ្រង់សម្ដែងព្រៃជាទីចោលសាកសពទាំង ៩ ហើយ កាលនឹងទ្រង់បញ្ចប់កាយានុបស្សនា ទើបត្រាស់ពាក្យនេះថា ឯវំ

ខោ ភិក្ខវេ យាននេះឯង ម្នាលភិក្ខុទាំងឡាយ ជាដើម ។

## សតិកំណត់សាកសព ជាអរិយសច្ច ៤

ក្នុងនវសីវថិកាបព្វៈនោះ សតិដែលកំណត់ព្រៃជាទីចោលសាកសពទាំង ៩ ប្រការ ជាទុក្ខសច្ច , តណ្ហាដែលមានក្នុងមុន ដែលញុាំងសតិនោះឲ្យកើតឡើង ជាសមុទយសច្ច , ការមិនមានទុក្ខសច្ច និងសមុទយសច្ចទាំងពីរ ជានិរោធសច្ច , អរិយមគ្គដែលកំណត់ទុក្ខ លះសមុទ័យ មាននិរោធជាអារម្មណ៍ ជាមគ្គសច្ច ។ ភិក្ខុយោគាវចរ ខ្វល់ខ្វាយដោយអំណាចសច្ចៈយ៉ាងនេះ រមែងសម្រេចព្រះនិព្វាន រលត់ទុក្ខបានដូច្នេះ ។ នេះជាផ្លូវបដិបត្តិនាំចេញចាកទុក្ខ ដរាបដល់ព្រះអរហត្តរបស់ពួកភិក្ខុ ដែលកំណត់ព្រៃជាទីចោលសាកសពទាំង ៩ ប្រការ យ៉ាងនេះឯង ។

" ចប់ នវសីវថិកាបព្វៈ "

ក៏កាយានុបស្សនា ១៤ បព្វៈ គឺ អានាបានបព្វៈ ១ ឥរិយាបថ-បព្វៈ ១ ចតុសម្បជញ្ញបព្វៈ ១ បដិកូលមនសិការបព្វៈ ១ ធាតុមន-សិការបព្វៈ ១ នវសីវថិកា ៩ បព្វៈ ជាការចប់ស្រេច ដោយពាក្យពណ៌នា មានប្រមាណត្រឹមតែប៉ុណ្ណេះ ។

ក្នុង ១៤ បព្វៈនោះ អានាបានបព្វៈ នឹងបដិកូលមនសិការបព្វៈ ២ បព្វៈនេះប៉ុណ្ណោះ ជាអប្បនាកម្មដ្ឋាន ចំណែក ១២ បព្វៈដ៏សេស ជាឧបចារកម្មដ្ឋានតែម្យ៉ាង ព្រោះត្រាស់ទុកដោយការពិចារណាឃើញទោសនៃកាយដែលជាប់ទាក់ទងដោយព្រៃជាទីចោលសាកសព ដូច្នេះឯង ។

" ចប់ កាយានុបស្សនាសតិប្បដ្ឋាន "

## វេទនានុបស្សនាសតិប្បដ្ឋាន

[១២៦] ព្រះមានព្រះភាគ ត្រាស់កាយានុបស្សនាសតិប្បដ្ឋាន ១៤ វិធីយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងត្រាស់វេទនានុបស្សនា ៩ វិធី ទើបត្រាស់ថា កថញ្ច ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ វេទនាតើដូចម្ដេច ជាដើម ។

បណ្ដាបទទាំងនោះ បទថា **សុខវេទនា** សេចក្ដីថា ភិក្ខុកំពុងសោយវេទនាដែលជាសុខផ្លូវកាយក្ដី ផ្លូវចិត្តក្ដី ក៏ដឹងច្បាស់ថា យើងសោយសុខវេទនា ។ នឹងវិនិច្ឆ័យក្នុងពាក្យនោះ សូម្បីទារកដែលនៅដេកផ្ងារ កាលសោយសុខក្នុងគ្រាផឹកទឹកដោះជាដើម ក៏ដឹងច្បាស់ថា យើងសោយសុខវេទនាក៏ពិត ។ តែពាក្យថា សុខវេទនាជាដើមនេះ មិនបានត្រាស់សំដៅដល់សេចក្ដីដឹងច្បាស់យ៉ាងនោះ ។ ព្រោះសេចក្ដីដឹងច្បាស់ដូច្នោះ មិនលះការឃើញថា សត្វ មិនដកការសម្គាល់ថា ជាសត្វ មិនជាកម្មដ្ឋាន ឬសតិប្បដ្ឋានភាវនាឡើយ ។ ចំណែកសេចក្ដីដឹងច្បាស់របស់ភិក្ខុនេះ លះការឃើញថា សត្វ ដកការសម្គាល់ថា ជាសត្វបាន ទាំងជាកម្មដ្ឋាន ជាសតិប្បដ្ឋានភាវនា ។ ក៏ពាក្យនេះ ត្រាស់សំដៅដល់ការសោយសុខវេទនា

ព្រមទាំងការដឹងខ្លួនយ៉ាងនេះថា អ្នកណាសោយ ការសោយរបស់អ្នកណា សោយព្រោះហេតុអ្វី ។

## ត្រឹមតែជាវេទនា មិនមែនសត្វបុគ្គលខ្លួនយើងគេ

នឹងវិនិច្ឆ័យក្នុងបញ្ហាទាំងនោះ សួរថា **អ្នកណាសោយ** ឆ្លើយថា មិនមែនសត្វ ឬបុគ្គលណា ៗ សោយ ។ សួរថា **ការសោយរបស់អ្នកណា** ឆ្លើយថា មិនមែនការសោយរបស់សត្វ ឬបុគ្គលណា ៗ ។ សួរថា **សោយព្រោះហេតុអ្វី** ឆ្លើយថា ក៏វេទនារបស់ភិក្ខុនោះ មានវត្ថុជាអារម្មណ៍តែម្យ៉ាង ហេតុនោះ លោកទើបដឹងយ៉ាងនេះថា សត្វទាំងឡាយសោយវេទនា ព្រោះធ្វើវត្ថុជាទីតាំងនៃវេទនា មានសុខវេទនាជាដើមនោះៗ ឲ្យជាអារម្មណ៍ ក៏ពាក្យថា យើងសោយវេទនា ត្រឹមតែការសម្មតិហៅគ្នា ព្រោះចាប់យកការប្រព្រឹត្តទៅនៃវេទនានោះ ។ ភិក្ខុកំណត់ថា សត្វទាំងឡាយសោយវេទនា ព្រោះធ្វើវត្ថុឲ្យជាអារម្មណ៍យ៉ាងនេះ គប្បីជ្រាបថា ភិក្ខុរមែងដឹងច្បាស់ថា យើងសោយសុខវេទនា ដូចព្រះថេរៈមួយរូប ក្នុងសម្នាក់នៅត្រង់ចិត្តលពិត ។

## ព្រះថេរៈអ្នកសោយទុក្ខវេទនា

បានឮថា ព្រះថេរៈបំរេះនទៀល ដោយវេទនាខ្លាំងក្លា គ្រាអាពាធមិនជាសុខ ។ ភិក្ខុកម្នោះមួយរូបសួរថា លោកម្ចាស់ឈឺចាប់ត្រង់ណា ។ លោកឆ្លើយថា ប្រាប់កន្លែងឈឺចាប់មិនបានទេលោក ខ្ញុំធ្វើវត្ថុជាអារម្មណ៍សោយវេទនា ។ សួរថា តាំងពីវេលាដឹងច្បាស់យ៉ាងនេះ លោកអត់ទ្រាំទុកមិនគួរឬ លោកម្ចាស់ ។ ឆ្លើយថា ខ្ញុំនឹងអត់ទ្រាំ ណាលោក ។ ភិក្ខុកម្នោះពោលថា អត់ទ្រាំបានជាការល្អណា លោកម្ចាស់ ។ ព្រះថេរៈក៏អត់ទ្រាំ (ទុក្ខវេទនា) ។ រោគខ្យល់ ក៏ពុះបំបែកដរាបដល់បេះដូង ពោះវៀនរបស់ព្រះថេរៈក៏ចេញមកគរលើគ្រែ ។ ព្រះថេរៈបង្ហាញឲ្យភិក្ខុកម្នោះមើលសួរថា អត់ទ្រាំប៉ុណ្ណេះគួរទេ ។ ភិក្ខុកម្នោះក៏ស្ងៀម ។ ព្រះថេរៈ ក៏ប្រកបសេចក្ដីព្យាយាមស្មើ សម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទាទាំងឡាយជាព្រះអរហត្តសមសីសី បរិនិព្វានហើយ ។

មួយទៀត ភិក្ខុចម្រើនវេទនានុបស្សនាសតិប្បដ្ឋាននោះ សោយទុក្ខ-វេទនា ។ល។ អទុក្ខមសុខវេទនាប្រាសចាកអាមិស ក៏ដឹងច្បាស់ថា យើងសោយទុក្ខវេទនា ។ល។ អទុក្ខមសុខវេទនាប្រាសចាកអាមិស ដូចកាល

លោកសោយសុខវេទនានោះឯង ។

## វេទនា ជាអរូបកម្មដ្ឋាន

ព្រះមានព្រះភាគ ត្រាស់រូបកម្មដ្ឋានដោយប្រការដូច្នេះហើយ កាលនឹងត្រាស់អរូបកម្មដ្ឋាន តែត្រាស់ដោយអំណាចផស្សៈ ឬដោយអំណាចចិត្តកម្មដ្ឋានមិនប្រាកដច្បាស់ ប្រាកដដូចងងឹត ចំណែកការកើតឡើងនៃវេទនាទាំងឡាយ ប្រាកដច្បាស់ កម្មដ្ឋានប្រាកដច្បាស់ ដោយអំណាចវេទនាដូច្នោះ ទើបត្រាស់អរូបកម្មដ្ឋានដោយអំណាចវេទនា សូម្បីក្នុងព្រះសូត្រនេះ ដូចក្នុងសក្កបញ្ហសូត្រ ។ កថាមគ្គក្នុងព្រះសូត្រនេះ គប្បីជ្រាបដោយន័យដែលត្រាស់ទុកក្នុងសក្កបញ្ហសូត្រ ហើយទុះឯង ថា ក៏កម្មដ្ឋាន មាន ២ យ៉ាង គឺ រូបកម្មដ្ឋាន និងអរូបកម្មដ្ឋាន ដូច្នេះ ជាដើម ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងវេទនានុបស្សនាសតិប្បដ្ឋាននោះ ក្នុងពាក្យថា សុខវេទនាដូច្នេះជាដើម មានបរិយាយ (ផ្លូវ) នៃសេចក្តីដឹងច្បាស់ម្យ៉ាងទៀត ដូចតទៅនេះ ។ បទថា សុខំ វេទនំ វេទិយាមីតិ បជានាតិ យើងសោយសុខវេទនា សេចក្តីថា កាលសោយសុខវេទនា ព្រោះខណៈសោយសុខវេទនា មិនមានទុក្ខវេទនា ក៏ដឹងច្បាស់ថា យើងសោយសុខ

វេទនា ដូច្នេះ ។ ព្រោះដូច្នោះ ដែលឈ្មោះថា វេទនាមិនទៀង មិនឋិតថេរ មានសេចក្តីប្រែប្រួលជាធម្មតា ព្រោះក្នុងខណៈដែលមិនមានទុក្ខវេទនា ដែលធ្លាប់មានមកពីមុន និងព្រោះមុននេះ ក៏មិនមានសុខវេទនានេះ ។ ភិក្ខុដឹងខ្លួនក្នុងសុខវេទនានោះ យ៉ាងនេះ ។ សមពិតដូចដែលព្រះមានព្រះភាគត្រាស់ទុក ( ក្នុងទីឃនខសូត្រ មូលបណ្ណាសកៈ មជ្ឈិមនិកាយ ) ដូច្នេះថា ម្នាលអគ្គិវេស្សនៈ សម័យណាបុគ្គលសោយសុខវេទនា សម័យនោះមិនសោយទុក្ខវេទនាទេ មិនសោយអទុក្ខមសុខវេទនាទេ រមែងសោយតែសុខវេទនាប៉ុណ្ណោះ ។ សម័យណា សោយទុក្ខវេទនា ។បេ។ សោយអទុក្ខមសុខវេទនា សម័យនោះ មិនសោយសុខវេទនាទេ មិនសោយទុក្ខ-វេទនាទេ សោយតែអទុក្ខមសុខវេទនាប៉ុណ្ណោះ ។ ម្នាលអគ្គិវេស្សនៈ សូម្បីសុខវេទនានោះឯង មិនទៀង ដែលបច្ច័យតាក់តែង អាស្រ័យបច្ច័យកើតឡើង មានការអស់ទៅជាធម្មតា មានការសូន្យទៅជាធម្មតា មានកិរិយាបែកធ្លាយទៅ មានកិរិយារលត់ទៅជាធម្មតា សូម្បីទុក្ខវេទនា ។បេ។ អទុក្ខមសុខវេទនា មិនទៀង ។បេ។ មានកិរិយារលត់ទៅជាធម្មតា ។ ម្នាលអគ្គិវេស្សនៈ អរិយសាវកអ្នកបានស្តាប់ហើយ កាលឃើញយ៉ាងនេះ រមែងនឿយណាយ សូម្បីក្នុងសុខវេទនា សូម្បីក្នុងទុក្ខវេទនា សូម្បីក្នុង

*អទុក្ខមសុខវេទនា កាលនៀយណាយ រមែងប្រាសចាកតម្រេក ព្រោះប្រាស ចាកតម្រេក ទើបរួចផុត កាលរួចផុត រមែងដឹងច្បាស់ថា រួចផុតហើយ ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌នៅចប់ហើយ កិច្ចដែលគួរ ធ្វើ ក៏ធ្វើស្រេចហើយ កិច្ចដទៃដើម្បីយ៉ាងនេះ មិនមានទៀតឡើយ ។*

## វេទនាដែលជាសាមិសៈ និងនិរាមិសៈ

*នីងវិនិច្ឆ័យក្នុងពាក្យថា សាមិសំ វា សុខំ ឬសុខវេទនាដែលជា អាមិស ជាដើម សោមនស្សវេទនាអាស្រ័យអាមិស គឺ កាមគុណ ៥ អាស្រ័យផ្ទះ ៦ ឈ្មោះថា* ***សាមិសសុខវេទនា*** *, សោមនស្សវេទនា អាស្រ័យនេក្ខម្មៈ ៦ ឈ្មោះថា* ***និរាមិសសុខវេទនា*** *, ទោមនស្សវេទនា អាស្រ័យផ្ទះ ៦ ឈ្មោះថា* ***សាមិសទុក្ខវេទនា*** *, ទោមនស្សវេទនាអាស្រ័យ នេក្ខម្មៈ ៦ ឈ្មោះថា* ***និរាមិសទុក្ខវេទនា*** *, ឧបេក្ខាវេទនាអាស្រ័យផ្ទះ ៦ ឈ្មោះថា* ***សាមិសអទុក្ខមសុខវេទនា*** *, ឧបេក្ខាដែលអាស្រ័យនេក្ខម្មៈ ៦ ឈ្មោះថា* ***និរាមិសអទុក្ខមសុខវេទនា*** *។ មួយទៀត ការចែកវេទនាសូម្បី ទាំងនោះ លោកពោលទុកក្នុងសក្កបញ្ហសូត្រហើយ នោះឯង ។*

## វេទនាក្នុង វេទនាក្រៅ

ប្រការថា ឥតិ អជ្ឈត្តំ វា ខាងក្នុងក្តី សេចក្តីថា ពិចារណាឃើញវេទនាក្នុងវេទនាទាំងឡាយរបស់ខ្លួន ក្នុងវេទនាទាំងឡាយរបស់អ្នកដទៃ ឬក្នុងវេទនាទាំងឡាយរបស់ខ្លួនតាមកាល របស់អ្នកដទៃតាមកាល ដោយការកំណត់សុខវេទនាជាដើម យ៉ាងនេះ ។ ចំណែកក្នុងបទថា សមុទយធម្មានុបស្សីវា ពិចារណាឃើញធម៌ គឺ ការកើត ( ក្នុងវេទនាទាំងឡាយ ) នេះ មានវិនិច្ឆ័យថា ភិក្ខុកាលឃើញការកើត និងការសូន្យទៅនៃវេទនាទាំងឡាយ ដោយអាការមួយយ៉ាងៗ ៥ ថា ព្រោះអវិជ្ជាកើត ទើបវេទនាកើតដូច្នេះជាដើម គប្បីជ្រាបថា ភិក្ខុពិចារណាឃើញធម៌ គឺ ការកើតក្នុងវេទនាទាំងឡាយ ពិចារណាឃើញធម៌ គឺ ការសូន្យទៅក្នុងវេទនាទាំងឡាយ ឬពិចារណាឃើញធម៌ គឺ ការកើតក្នុងវេទនាទាំងឡាយតាមកាល ពិចារណាឃើញធម៌ គឺ ការសូន្យទៅក្នុងវេទនាទាំងឡាយតាមកាល ។ ប្រការតអំពីនេះទៅ ក៏មានន័យដូចដែលពោលមកហើយក្នុងកាយានុបស្សនា នុ៎ះឯង ។

## សតិកំណត់វេទនា ជាអរិយសច្ច ៤

*តែក្នុងវេទនានុបស្សនានេះ មានសេចក្តីផ្សេងគ្នាតែម្យ៉ាង គឺ គប្បីប្រកបសេចក្តីយ៉ាងនេះថា សតិដែលកំណត់វេទនាជាអារម្មណ៍ ជាទុក្ខសច្ចជាដើម គប្បីជ្រាបថា ជាផ្លូវបដិបត្តិនាំចេញចាកទុក្ខរបស់ភិក្ខុដែលកំណត់វេទនាជាអារម្មណ៍ ។ ពាក្យដ៏សេសក៏មានសេចក្តីដូច្នោះដែរ ។*

" ចប់ វេទនានុបស្សនាសតិប្បដ្ឋាន "

## ចិត្តានុបស្សនាសតិប្បដ្ឋាន

[**១២៧**] *ព្រះមានព្រះភាគ ត្រាស់វេទនានុបស្សនាសតិប្បដ្ឋាន ៩ វិធី យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងត្រាស់ចិត្តានុបស្សនា ១៦ វិធី ទើបត្រាស់ថា កថញ្ច ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ ចិត្តានុបស្សនា តើដូចម្តេច ជាដើម ។*

## ចែកអារម្មណ៍របស់ចិត្ត

*បណ្តាបទទាំងនេះ បទថា* ***ចិត្តប្រកបដោយរាគៈ*** *គឺ ចិត្តដែលកើតព្រមដោយលោភៈ ៨ ដួង ។ បទថា* ***ចិត្តដែលប្រាសចាករាគៈ*** *គឺ ចិត្តដែលជាកុសល និងអព្យាក្រិតផ្នែកលោកិយៈ ។ តែប្រការនេះ ជាការពិចារណា មិនមែនជាការប្រជុំធម៌ ព្រោះដូច្នោះក្នុងពាក្យថា ចិត្តប្រកបដោយរាគៈនេះ ទើបមិនមែនជាលោកុត្តរចិត្ត សូម្បីតែមួយបទ ។ អកុសលចិត្ត ៤ ដួងដ៏សេស ទើបមិនចូលនឹងបទដើម មិនចូលនឹងបទក្រោយ ។ បទថា* ***ចិត្តប្រកបដោយទោសៈ*** *បានដល់ ចិត្ត ២ ដួង ដែលកើតព្រមជាមួយទោមនស្ស ។ បទថា* ***ចិត្តដែលប្រាសចាកទោសៈ*** *បានដល់ ចិត្តដែលជាកុសល និងអព្យាក្រិតផ្នែកលោកិយៈ ។ អកុសលចិត្ត ១០ ដួង ដ៏សេស*

មិនចូលបទដើម មិនចូលបទក្រោយ ។ បទថា **ចិត្តប្រកបដោយមោហៈ** បានដល់ ចិត្ត ២ ដួង គឺ ចិត្តដែលកើតព្រមដោយវិចិកិច្ឆា ១ ដែលកើតព្រមដោយឧទ្ធច្ចៈ ១ ។ តែព្រោះមោហៈ រមែងកើតបានក្នុងអកុសលចិត្តទាំងអស់ ដូច្នោះ សូម្បីអកុសលចិត្តដ៏សេស ក៏គួរបានក្នុងបទថា ចិត្តមានមោហៈនេះដោយពិត ។ ពិតណាស់ អកុសលចិត្ត ១២ ( លោភមូលចិត្ត ៨ ទោសមូលចិត្ត ២ មោហមូលចិត្ត ២ ) លោកប្រមូលទុកក្នុងទុកៈ ( ពួក២ ) នេះប៉ុណ្ណោះ ។ បទថា **ចិត្តប្រាសចាកមោហៈ** បានដល់ចិត្តដែលជាកុសល និងអព្យាក្រឹតចំណែកលោកិយៈ ។ បទថា **ចិត្តរួញរា** បានដល់ ចិត្តដែលធ្លាក់ទៅក្នុងថីនមិទ្ធៈ ។ ក៏ចិត្តដែលធ្លាក់ទៅក្នុងថីនមិទ្ធៈនោះ ឈ្មោះថា **ចិត្តរួញរា** ។ បទថា **រាយមាយ** បានដល់ ចិត្តដែលកើតព្រមដោយឧទ្ធច្ចៈ ។ ចិត្តដែលកើតព្រមដោយឧទ្ធច្ចៈនោះ ឈ្មោះថា **ចិត្តរាយមាយ** ។ បទថា **ចិត្តជាមហគ្គតៈ** បានដល់ ចិត្តដែលជារូបាវចរៈ និងអរូបាវចរៈ ។ បទថា **ចិត្តមិនមែនមហគ្គតៈ** បានដល់ ចិត្តដែលជាកាមាវចរៈ ។ បទថា សឧត្តរំ ចិត្តមានចិត្តដទៃក្រៃលែងជាង បានដល់ចិត្តដែលជាកាមាវចរៈ ។ បទថា អនុត្តរំ ចិត្តមិនមានចិត្តដទៃក្រៃលែងជាង បានដល់ ចិត្តដែលជារូបាវចរៈ និងអរូបាវចរៈ ។ សូម្បីក្នុងចិត្តទាំង

នោះ ចិត្តដែលឈ្មោះថា សឧត្តរៈ បានដល់ ចិត្តជារូបាវចរៈ ចិត្តឈ្មោះថា អនុត្តរៈ បានដល់ ចិត្តដែលជាអរូបាវចរៈ ។ បទថា សមាហិតំ ចិត្ត ដែលតាំងមាំ បានដល់ អប្បនាសមាធិ ឬឧបចារសមាធិ ។ បទថា អសមាហិតំ ចិត្តមិនតាំងមាំ បានដល់ ចិត្តដែលវៀរចាកសមាធិទាំងពីរ ។ បទថា វិមុត្តំ ចិត្តរួចផុត បានដល់ ចិត្តរួចផុតដោយតទង្គវិមុត្តិ និង វិក្ខម្ភនវិមុត្តិ ។ បទថា អវិមុត្តំ ចិត្តមិនរួចផុត បានដល់ ចិត្តដែលវៀរចាក វិមុត្តិទាំងពីរ ។ ចំណែកសមុច្ឆេទវិមុត្តិ បដិបស្សទ្ធិវិមុត្តិ និងនិស្សរណ-វិមុត្តិ មិនមានឱកាសក្នុងបទនេះឡើយ ។

## ចិត្តក្នុង ចិត្តក្រៅ

ពាក្យថា ឥតិ អជ្ឈត្តំ វា ឬខាងក្នុង សេចក្តីថា ភិក្ខុយោគាវចរ កំណត់ចិត្តដែលប្រព្រឹត្តទៅក្នុងសម័យណា ៗ ដោយការកំណត់ចិត្ត មាន រាគៈជាដើម យ៉ាងនេះឈ្មោះថា ពិចារណាឃើញចិត្តក្នុងចិត្តរបស់ខ្លួន ឬ ក្នុងចិត្តរបស់អ្នកដទៃ ក្នុងចិត្តរបស់ខ្លួនតាមកាល ឬក្នុងចិត្តរបស់អ្នកដទៃ តាមកាល ។ ក៏ក្នុងពាក្យថា ពិចារណាឃើញធម៌ គឺ ការកើតនេះ គប្បី នាំការកើត និងការសូន្យទៅនៃវិញ្ញាណ មកប្រៀបធៀបដោយអាការមួយៗ

៥ យ៉ាងថា ព្រោះអវិជ្ជាកើត វិញ្ញាណទើបកើត ដូច្នេះជាដើម ។ ប្រការតទៅអំពីនេះ ក៏មានន័យដូចពោលមកហើយនោះឯង ។

## សតិកំណត់ចិត្តជា អរិយសច្ច ៤

តែក្នុងចិត្តានុបស្សនាសតិប្បដ្ឋាននេះ មានសេចក្ដីផ្សេងគ្នាតែម្យ៉ាង គឺ គប្បីប្រកបសេចក្ដីថា សតិដែលកំណត់ចិត្តជាអារម្មណ៍ ជាទុក្ខសច្ច ដូច្នេះជាដើម ហើយគប្បីជ្រាបថា ជាផ្លូវបដិបត្តិនាំចេញចាកទុក្ខ របស់ភិក្ខុដែលកំណត់ចិត្តជាអារម្មណ៍ ។ ពាក្យដ៏សេសក៏ដូចគ្នានុ៎ះឯង ។

" ចប់ ចិត្តានុបស្សនាសតិប្បដ្ឋាន "

## ធម្មានុបស្សនាសតិប្បដ្ឋាន

[១២៨] ព្រះមានព្រះភាគ ត្រាស់ចិត្តានុបស្សនាសតិប្បដ្ឋាន ១៦ វិធី យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងត្រាស់ធម្មានុបស្សនា ៥ វិធី ទើបត្រាស់ថា កថញ្ច ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ ធម្មានុបស្សនា តើដូចម្តេច ជាដើម ។

មួយវិញទៀត ព្រះមានព្រះភាគ ត្រាស់ការកំណត់រូបកម្មដ្ឋានសុទ្ធ ដោយកាយានុបស្សនា ត្រាស់ការកំណត់អរូបកម្មដ្ឋានសុទ្ធ ៗ ដោយវេទនានុបស្សនា និងចិត្តានុបស្សនា ។ ឥឡូវនេះ ដើម្បីនឹងត្រាស់ការកំណត់រូបកម្មដ្ឋាន និងអរូបកម្មដ្ឋានលាយគ្នា ទើបត្រាស់ថា កថញ្ច ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ ធម្មានុបស្សនា តើដូចម្តេច ជាដើម ។

មួយទៀត ព្រះមានព្រះភាគ ត្រាស់ការកំណត់រូបក្ខន្ធដោយកាយានុបស្សនា ត្រាស់ការកំណត់វេទនាខន្ធដោយវេទនានុបស្សនា ត្រាស់ការកំណត់វិញ្ញាណក្ខន្ធដោយចិត្តានុបស្សនា ។ ឥឡូវនេះ ដើម្បីនឹងត្រាស់សូម្បីការកំណត់សញ្ញាខន្ធ និងសង្ខារក្ខន្ធ ទើបត្រាស់ថា កថញ្ច ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ ធម្មានុបស្សនា តើដូចម្តេចខ្លះ ជាដើម ។

## នីវរណបព្វៈ

បណ្តាបទទាំងនោះ បទថា សន្តំ មាននៅ គឺ នៅព្រមដោយអំណាចផ្សាយឡើងរឿយ ៗ ។ បទថា អសន្តំ មិនមាននៅ គឺ មិនមាននៅព្រម ព្រោះមិនផ្សាយឡើង ឬព្រោះលះបានហើយ ។ បទថា **ក៏ដោយប្រការណា** សេចក្តីថា កាមច្ឆន្ទៈ កើតឡើងព្រោះហេតុណា ។ បទថា តញ្ច បជានាតិ គឺ ដឹងច្បាស់ហេតុនោះ ។ គ្រប់ៗ បទ គប្បីជ្រាបសេចក្តីដោយន័យនេះឯង ។

## ហេតុកើតកាមច្ឆន្ទៈ

ក្នុងនិមិត្តទាំងពីរនោះ កាមច្ឆន្ទៈ រមែងកើតឡើង ព្រោះមនសិការមិនដោយឧបាយដ៏ប្រពៃក្នុងសុភនិមិត្ត ។ វត្ថុដែលស្អាតក្តី អារម្មណ៍ដែលល្អក្តី ឈ្មោះថា សុភនិមិត្ត ។ ការធ្វើទុកក្នុងចិត្តដោយមិនមានឧបាយ ការធ្វើទុកក្នុងចិត្តក្រៅផ្លូវ ការធ្វើទុកក្នុងចិត្តក្នុងវត្ថុដែលមិនទៀង ថាទៀង ក្នុងវត្ថុដែលជាទុក្ខ ថាសុខ ក្នុងវត្ថុដែលមិនមែនខ្លួន ថាខ្លួន ឬក្នុងវត្ថុដែលមិនស្អាត ថាស្អាត ឈ្មោះថា អយោនិសោមនសិការ ( ការធ្វើទុកក្នុងចិត្តមិនដោយឧបាយដ៏ប្រពៃ ) ។ កាលភិក្ខុធ្វើអយោនិសោមនសិការ

នោះឲ្យប្រព្រឹត្តទៅច្រើនៗ ក្នុងសុភនិមិត្តនោះ កាមច្ឆន្ទៈ រមែងកើតឡើង ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ទុក ( ក្នុងសំយុត្តនិកាយ មហាវារៈ ) ថា ម្នាលភិក្ខុទាំងឡាយ សុភនិមិត្តមាន ការធ្វើឲ្យច្រើននូវ អយោនិសោមនសិការក្នុងសុភនិមិត្តនោះ នេះជាអាហារដើម្បីការកើតឡើង នៃកាមច្ឆន្ទៈ ដែលមិនទាន់កើត ដើម្បីធ្វើឲ្យកាមច្ឆន្ទៈដែលកើតឡើងហើយ ឲ្យរឹងរឹតតែកើតច្រើនឡើង ដូច្នេះ ។

## ហេតុលះកាមច្ឆន្ទៈ

ចំណែកកាមច្ឆន្ទៈនោះ នឹងលះបាន ក៏ដោយយោនិសោមនសិការ ( ការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃ ) ក្នុងអសុភនិមិត្ត ។ វត្ថុដែលមិនស្អាតក្តី អារម្មណ៍ដែលមិនល្អក្តី ឈ្មោះថា អសុភនិមិត្ត ។ ការធ្វើទុកក្នុងចិត្តដោយឧបាយ ការធ្វើទុកក្នុងចិត្តត្រូវផ្លូវ ការធ្វើទុកក្នុងចិត្តក្នុងវត្ថុដែលមិនទៀង ថាមិនទៀង ក្នុងវត្ថុដែលជាទុក្ខ ថាទុក្ខ ក្នុងវត្ថុដែលមិនមែនខ្លួន ថាមិនមែនខ្លួន ឬក្នុងវត្ថុដែលមិនស្អាត ថាមិនស្អាត ឈ្មោះថា យោនិសោមនសិការ ។ កាលភិក្ខុធ្វើយោនិសោមនសិការនោះ ឲ្យប្រព្រឹត្តទៅច្រើន ៗ ក្នុងអសុភនិមិត្តនោះ រមែងលះកាមច្ឆន្ទៈចេញបាន ។ ព្រោះ

ហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ទុក ( ក្នុងសំយុត្តនិកាយ មហា-វារៈ ) ថា ម្នាលភិក្ខុទាំងឡាយ អសុភនិមិត្តមាន ការធ្វើឲ្យច្រើនៗ នូវយោនិសោមនសិការក្នុងអសុភនិមិត្តនោះ នេះជាអាហារដើម្បីការមិនកើតនៃកាមច្ឆន្ទៈដែលមិនទាន់កើត ឬដើម្បីលះកាមច្ឆន្ទៈដែលកើតហើយ ។

## ធម៌សម្រាប់លះកាមច្ឆន្ទៈ

មួយវិញទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះកាមច្ឆន្ទៈ គឺ

១-ការកាន់យកអសុភនិមិត្ត ជាអារម្មណ៍

២-ការប្រកបរឿយ ៗ នូវអសុភភាវនា

៣-ការរក្សាទ្វារក្នុងឥន្ទ្រិយទាំងឡាយ

៤-សេចក្តីស្គាល់ប្រមាណក្នុងភោជន

៥-ការមានកល្យាណមិត្ត

៦-និយាយតែរឿងដែលជាសប្បាយ ( ជាទីសប្បាយ ) ។

ពិតណាស់ កាលភិក្ខុកំណត់អសុភនិមិត្ត ១០ យ៉ាង ក៏លះកាម-ច្ឆន្ទៈបាន ។ កាលចម្រើនអសុភ ១០ ក្តី កាលបិទទ្វារក្នុងឥន្ទ្រិយទាំងឡាយក្តី ស្គាល់ប្រមាណក្នុងភោជន ព្រោះកាលមានឱកាសនឹងបរិភោគ

៤-៥ ដុំទៀត ក៏ផឹកទឹក ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបាន ក៏រមែងលះកាមច្ឆន្ទៈបាន ។ ព្រោះហេតុនោះ លោកទើបពោលទុក ( ក្នុងខុទ្ទកនិកាយ ថេរគាថា ) ថា ៖

ចត្តារោ បញ្ច អាលោបេ អភុត្វា បិវេ
អលំ ផាសុវិហារាយ បហិតត្តស្ស ភិក្ខុនោ

ភិក្ខុគប្បីវៀរដុំបាយ ៤-៥ ដុំចេញ ឈប់ឆាន់ ហើយផឹក
ទឹក នេះជាការបដិបត្តិដែលសមគួរសម្រាប់ភិក្ខុ ដែលមាន
ខ្លួនដែលបញ្ជូនទៅហើយ ។

សូម្បីភិក្ខុដែលសេពកល្យាណមិត្ត ដែលជាអ្នកត្រេកអរ ក្នុងការបម្រើនអសុភ ដូចព្រះតិស្សត្ថេរ អ្នកចម្រើនអសុភកម្មដ្ឋាន ក៏រមែងលះកាមច្ឆន្ទៈបាន ។ សូម្បីដោយការចរចាប្រារព្ធរឿងជាទីសប្បាយ ដែលអាស្រ័យអសុភ ១០ ក្នុងឥរិយាបថឈរ និងអង្គុយជាដើម ក៏រមែងលះកាមច្ឆន្ទៈបាន ។ ព្រោះហេតុនោះ លោកទើបពោលថា ធម៌ ៦ ប្រការរមែងប្រព្រឹត្តទៅដើម្បីលះកាមច្ឆន្ទៈ ដូច្នេះ ។ ភិក្ខុ រមែងដឹងច្បាស់ថា ក៏កាមច្ឆន្ទៈដែលលះបានហើយ ដោយធម៌ ៦ ប្រការនេះ រមែងមិនកើតទៀតតទៅ ដោយអរហត្តមគ្គ ។

## ហេតុកើតព្យាបាទ

ចំណែកព្យាបាទ រមែងកើត ព្រោះអយោនិសោមនសិការក្នុងបដិឃនិមិត្ត ។ បដិឃៈ ( សេចក្តីថ្នាំងថ្នាក់ចិត្ត ) ក្តី អារម្មណ៍ដែលឲ្យកើតបដិឃៈក្តី ឈ្មោះថា បដិឃនិមិត្ត ក្នុងពាក្យថា បដិឃនិមិត្តជាដើមនោះ ។ អយោនិសោមនសិការ មានលក្ខណៈតែម្យ៉ាងដូចគ្នា ក្នុងធម៌ទាំងពួង ។ កាលភិក្ខុធ្វើអយោនិសោមនសិការនោះឲ្យប្រព្រឹត្តទៅច្រើន ៗ ក្នុង (បដិឃៈ) និមិត្តនោះ ព្យាបាទ រមែងកើត ។ ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ទុក ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ៖

> **ម្នាលភិក្ខុទាំងឡាយ បដិឃនិមិត្តមាន ការមិនធ្វើឲ្យច្រើននូវអយោនិសោមនសិការក្នុងបដិឃនិមិត្តនោះ នេះអាហារដើម្បីការកើតនៃព្យាបាទ ដែលមិនទាន់កើត ឬដើម្បីធ្វើឲ្យព្យាបាទដែលកើតឡើងហើយ ឲ្យរឹងរឹតតែចម្រើនឡើងដូច្នេះ ។**

## ហេតុលះព្យាបាទ

តែព្យាបាទនោះ នឹងលះបាន ក៏ដោយការធ្វើទុកក្នុងចិត្តដោយឧបាយ

ដ៏ប្រពៃ ក្នុងមេត្តាចេតោវិមុត្តិ ។ ក្នុងពាក្យថា មេត្តាចេតោវិមុត្តិនោះ កាលនិយាយគ្នាដល់មេត្តា រមែងគួរទាំងអប្បនា ទាំងឧបចារៈ ។ ពាក្យថា **មេត្តាចេតោវិមុត្តិ** បានដល់ អប្បនាយោនិសោមនសិការ មានលក្ខណៈ ដូចពោលហើយ ។ កាលភិក្ខុធ្វើយោនិសោមនសិការឲ្យប្រព្រឹត្តទៅច្រើន ៗ ក្នុងមេត្តាចេតោវិមុត្តិនោះ រមែងលះព្យាបាទបាន ។ ព្រោះដូច្នោះ ព្រះមាន-ព្រះភាគទើបត្រាស់ទុក ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ៖

> ម្នាលភិក្ខុទាំងឡាយ មេត្តាចេតោវិមុត្តិមាន ការធ្វើឲ្យច្រើនធ្វើនូវយោនិសោមនសិការ ក្នុងមេត្តាចេតោវិមុត្តិនោះ នេះជាអាហារដើម្បីការមិនកើតនៃព្យាបាទ ដែលមិនទាន់កើត ឬដើម្បីលះព្យាបាទដែលកើតហើយ ដូច្នេះ ។

## ធម៌សម្រាប់លះព្យាបាទ

ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅ ដើម្បីលះព្យាបាទ គឺ

១-ការកំណត់និមិត្តក្នុងមេត្តាជាអារម្មណ៍ ។

២-ការប្រកបរឿយ ៗ នូវមេត្តាភាវនា ។

៣-ការពិចារណាដល់សត្វមានកម្មជារបស់ខ្លួន ។

៤-ការធ្វើឲ្យច្រើននូវការពិចារណា ។

៥-ការមានកល្យាណមិត្ត ។

៦-ការនិយាយតែរឿងដែលជាទីសប្បាយ ។

ពិតណាស់ សូម្បីកាលភិក្ខុកំណត់មេត្តាកម្មដ្ឋាន ដោយការផ្សាយមេត្តាទូទៅទាំងទិស ដោយចំពោះ ឬមិនចំពោះយ៉ាងណាមួយ រមែងលះព្យាបាទបាន ។ កាលភិក្ខុចម្រើនមេត្តា ដោយផ្សាយទូទៅទាំងទិស ដោយមិនចំពោះក្តី កាលពិចារណាដល់ភាពនៃខ្លួន និងអ្នកដទៃ មានកម្មជារបស់ខ្លួនយ៉ាងនេះថា លោកក្រោធអ្នកនោះ នឹងធ្វើអ្វីគេបាន លោកអាចនឹងធ្វើសីលជាដើម របស់គេឲ្យវិនាសបានឬ លោកមកហើយដោយកម្មរបស់ខ្លួន នឹងទៅដោយកម្មរបស់ខ្លួនប៉ុះឯង ដែលឈ្មោះថា ការក្រោធនឹងអ្នកដទៃ ក៏ដូចគ្នានឹងអ្នកប្រាថ្នានឹងចាប់រងើកភ្លើងដែលឆាបឆេះប្រវាក់ដែកដ៏ក្តៅ និងចាប់ឧច្ចារៈជាដើម ប្រហារអ្នកដទៃដូច្នោះ ឬបើអ្នកនោះក្រោធនឹងលោកតើធ្វើអ្វីបាន គេនឹងអាចធ្វើសីលជាដើមរបស់លោកឲ្យវិនាសបានឬ គេមកដោយកម្មរបស់គេ ក៏នឹងទៅតាមកម្មរបស់គេប៉ុះឯង សេចក្តីក្រោធនោះនឹងធ្លាក់ចុះលើក្បាលរបស់គេប៉ុះឯង ដូចប្រហារអ្នកមិនប្រហារតប និងដូចនាំធូលីបាចទៅក្នុងទីច្រាសខ្យល់ ដូច្នោះ ដូច្នេះក្តី កាលពិចារណា

កម្មស្សកតាទាំងពីរឈប់ក្នុងការពិចារណាក្តី សេពគប់កល្យាណមិត្តអ្នកត្រេកអរក្នុងការចម្រើនមេត្តា ដូចព្រះអស្សគុត្តត្ថេរក្តី រមែងលះព្យាបាទបាន ។ សូម្បីដោយការចរចារឿងដែលជាទីសប្បាយដែលអាស្រ័យមេត្តាក្នុងឥរិយាបថទាំងឡាយ មានឈរ អង្គុយជាដើម ក៏លះព្យាបាទបាន ។ ព្រោះហេតុនោះ លោកទើបពោលថា ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះព្យាបាទ ដូច្នេះ ។ ភិក្ខុរមែងដឹងច្បាស់ថា ក៏ព្យាបាទដែលលះបានហើយ ដោយធម៌ ៦ ប្រការនេះ រមែងមិនកើតតទៅដោយអនាគាមិមគ្គ ។

## ហេតុកើតថីនមិទ្ធៈ

ថីនមិទ្ធៈ រមែងកើតដោយអយោនិសោមនសិការក្នុងធម៌ទាំងឡាយមានអរតិជាដើម ។ សេចក្តីមិនត្រេកអរនឹងគេ ( ឬស្យា ) ឈ្មោះថា អរតិ ។ សេចក្តីខ្ជិលច្រអូសផ្លូវកាយឈ្មោះថា តន្ទី ។ ការពត់កាយ ឈ្មោះថា វិជម្ភិតា ។ សេចក្តីស្រវឹងព្រោះអាហារ សេចក្តីខ្វល់ខ្វាយព្រោះអាហារ ឈ្មោះថា ភត្តសម្មទ ពុលបាយ ។ អាការ គឺ ការធូរថយនៃចិត្ត ឈ្មោះថា ការរួញរានៃចិត្ត ។ កាលភិក្ខុធ្វើអយោនិសោមនសិការឲ្យប្រព្រឹត្តទៅច្រើន ៗ ក្នុងអរតិជាដើមនេះ ថីនមិទ្ធៈ រមែងកើត ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ

*ទើបត្រាស់ទុក ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ ការវៀញពានៃចិត្តមាន ការធ្វើឲ្យច្រើននូវអយោនិសោមនសិការ ក្នុងធម៌ទាំងនេះ នេះជាអាហារដើម្បីការកើតឡើងនៃថីនមិទ្ធៈ ដែលមិនទាន់កើត ឬដើម្បីធ្វើថីនមិទ្ធៈ ដែលកើតហើយ ឲ្យរឹងរឹតតែចម្រើនឡើង ដូច្នេះ ។*

## ហេតុលះថីនមិទ្ធៈ

*ថីនមិទ្ធៈ នឹងលះបានដោយយោនិសោមនសិការក្នុងធម៌ទាំងឡាយមានអារព្ភធាតុជាដើម ។ សេចក្តីព្យាយាមផ្តើមដំបូង ឈ្មោះថា* **អារព្ភធាតុ** *។ សេចក្តីព្យាយាមដែលមានកម្លាំងជាងអារព្ភធាតុនោះ ព្រោះចេញទៅផុតពីសេចក្តីខ្ជិលច្រអូសហើយ ឈ្មោះថា* **និក្កមធាតុ** *។ សេចក្តីព្យាយាមដែលមានកម្លាំងក្រៃលែងជាងនិក្កមធាតុសូម្បីនោះ ព្រោះកន្លង ឋានៈដទៃៗ ឈ្មោះថា* **បរក្កមធាតុ** *( ឈានទៅខាងមុខ , ព្យាយាម ) ។ កាលភិក្ខុធ្វើយោនិសោមនសិការឲ្យប្រព្រឹត្តទៅច្រើន ៗ ក្នុងសេចក្តីព្យាយាម ៣ ប្រភេទនេះ រមែងលះថីនមិទ្ធៈបាន ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ទុក ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ធាតុ គឺ ការផ្តើមព្យាយាម ធាតុ គឺ ការចេញផុតពីសេចក្តីខ្ជិលច្រអូស ធាតុ គឺ ការឈានកន្លងទៅ*

ខាងមុខមាន ម្នាលភិក្ខុទាំងឡាយ ការធ្វើឲ្យច្រើននូវយោនិសោមនសិការក្នុងធាតុទាំងនោះ នេះជាអាហារដើម្បីការមិនកើតឡើងនៃថីនមិទ្ធៈ ដែលមិនទាន់កើត ឬដើម្បីលះថីនមិទ្ធៈដែលកើតហើយ ដូច្នេះ ។

## ធម៌សម្រាប់លះថីនមិទ្ធៈ

មយ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះថីនមិទ្ធៈ គឺ

១-ការកំណត់និមិត្តក្នុងភោជនដែលលើស ។

២-ការផ្លាស់ប្តូរឥរិយាបថ ។

៣-ការធ្វើទុកក្នុងចិត្តដល់អាលោកសញ្ញា (គឺការសម្គាល់ថាភ្លឺ) ។

៤-ការនៅកណ្តាលវាល ។

៥-ការមានកល្យាណមិត្ត ។

៦-ការចរចាតែរឿងដែលជាទីសប្បាយ ។

ព្រោះថា កាលភិក្ខុបរិភោគភោជន ដូចព្រាហ្មណ៍ ដែលឈ្មោះអាហារហត្ថកៈ ដែលឈ្មោះតត្រវដ្ដកៈ ដែលឈ្មោះអលំសាដកៈ ដែលឈ្មោះកាកមាសកៈ និងដែលឈ្មោះភុត្តវមិតកៈ អង្គុយក្នុងទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃ ធ្វើសមណធម៌ ថីនមិទ្ធៈ រមែងមកគ្របសង្កត់

បានដូចដំរីដ៏ធំ តែថីនមិទ្ធៈនោះ នឹងមិនមានដល់ភិក្ខុដែលរៀវឱកាសបរិភោគ ៤-៥ ដុំហើយ ផឹកទឹក ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅជាប្រក្រតី ព្រោះហេតុនោះ កាលភិក្ខុកំណត់និមិត្ត ក្នុងភោជនដែលលើសយ៉ាងនេះ រមែងលះថីនមិទ្ធៈបាន កាលភិក្ខុកើតថីនមិទ្ធៈក្នុងឥរិយាបថណា ផ្លាស់ប្តូរឥរិ-យាបថជាយ៉ាងដទៃពីឥរិយាបថនោះចេញ ក៏លះថីនមិទ្ធៈបាន ។ កាលភិក្ខុដាក់ចិត្តក្នុងពន្លឺព្រះច័ន្ទ ពន្លឺប្រទីប ពន្លឺគប់ភ្លើងក្នុងវេលាពេលយប់ ពន្លឺព្រះអាទិត្យវេលាពេលថ្ងៃក្តី នៅក្នុងទីកណ្តាលវាលក្តី សេពកល្យាណមិត្តអ្នកលះថីនមិទ្ធៈបាន ដូចព្រះមហាកស្សបត្ថេរក្តី ក៏លះថីនមិទ្ធៈបាន ។ សូម្បីដោយការចរចាតែរឿងដែលជាទីសប្បាយ ដែលអាស្រ័យធុតង្គ ក្នុងឥរិយាបថទាំងឡាយ មានឈរ អង្គុយជាដើម ក៏លះថីនមិទ្ធៈបាន ។ ព្រោះដូច្នោះ លោកទើបពោលធម៌ ៦ ប្រការនេះ រមែងប្រព្រឹត្តទៅដើម្បីលះថីនមិទ្ធៈ ។ ភិក្ខុរមែងដឹងច្បាស់ថា ថីនមិទ្ធៈដែលលះបានដោយធម៌ ៦ ប្រការ នឹងមិនកើតតទៅដោយអរហត្តមគ្គ ដូច្នេះ ។

## ហេតុកើតឧទ្ធច្ចកុក្កុច្ចៈ

ឧទ្ធច្ចកុក្កុច្ចៈ រមែងកើតដោយអយោនិសោមនសិការ ក្នុងការមិន

ស្ងប់នៃចិត្ត ។ អាការដែលមិនស្ងប់ ឈ្មោះថា សេចក្តីមិនស្ងប់ ។ ពាក្យនេះ ដោយអត្ថ ក៏គឺ ឧទ្ធច្ចកុក្កុច្ចៈនុ៎ះឯង ។ កាលភិក្ខុធ្វើអយោនិសោ-មនសិការឲ្យប្រព្រឹត្តទៅច្រើន ៗ ក្នុងសេចក្តីមិនស្ងប់នៃចិត្តនោះ ឧទ្ធច្ច-កុក្កុច្ចៈ រមែងកើត ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ទុក ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ ការមិនស្ងប់នៃចិត្តមាន ការធ្វើឲ្យច្រើននូវអយោនិសោមនសិការក្នុងការមិនស្ងប់នៃចិត្តនោះ នេះជាអាហារដើម្បីការកើតនៃឧទ្ធច្ចកុក្កុច្ចៈដែលមិនទាន់កើត ឬដើម្បីធ្វើឧទ្ធច្ចកុក្កុច្ចៈដែលកើតហើយ ឲ្យរឹងរឹតតែចម្រើនឡើង ដូច្នេះ ។

## ហេតុលះឧទ្ធច្ចកុក្កុច្ចៈ

តែឧទ្ធច្ចកុក្កុច្ចៈនោះ នឹងលះបាន ក៏ដោយយោនិសោមនសិការក្នុងសេចក្តីស្ងប់នៃចិត្ត ពោលគឺ សមាធិ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគត្រាស់ទុក ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ ការស្ងប់នៃចិត្តមាន ការធ្វើឲ្យច្រើននូវយោនិសោមនសិការឲ្យច្រើនក្នុងការស្ងប់ស្ងាត់នៃចិត្តនោះ នេះជាអាហារដើម្បីការមិនកើតនៃឧទ្ធច្ចកុក្កុច្ចៈដែលមិនទាន់កើត ឬដើម្បីលះឧទ្ធច្ចកុក្កុច្ចៈដែលកើតហើយ ដូច្នេះ ។

## ធម៌សម្រាប់លះឧទ្ធច្ចកុក្កុច្ចៈ

ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះឧទ្ធច្ចកុក្កុច្ចៈ គឺ ៖

១-ការស្តាប់ច្រើន ។

២-ការសាកសួរ ។

៣-ភាពជំនាញក្នុងវិន័យ ។

៤-ការគប់រកបុគ្គលដែលចម្រើន ។

៥-ការមានកល្យាណមិត្ត ។

៦-ការចរចាតែរឿងដែលជាទីសប្បាយ ។

ពិតណាស់ កាលភិក្ខុសូម្បីសិក្សារៀនសូត្រ ទាំងបាលី ទាំងអដ្ឋកថា និកាយមួយ ពីរ បី បួននិកាយ ឬ ៥ និកាយ រមែងលះឧទ្ធច្ចកុក្កុច្ចៈបាន ។ សូម្បីដោយភាពជាពហុស្សូត ( ពហុសច្ចៈ ភាពជាអ្នកស្តាប់ច្រើន ) ។ ភិក្ខុដែលច្រើនដោយការសាកសួរវត្ថុដែលគួរ និងមិនគួរក្តី អ្នកជំនាញ ព្រោះមានភាពជំនាញដែលសន្សំទុកក្នុងវិន័យប្បញ្ញត្តិក្តី អ្នកចូលរកព្រះថេរៈចាស់ អ្នកចម្រើនដោយវ័យក្តី សេពគប់កល្យាណមិត្តអ្នកទ្រទ្រង់វិន័យ ដូចព្រះ

ឧបាលិត្ថេរក្តី រមែងលះឧទ្ធច្ចកុក្កុច្ចៈបាន ។ សូម្បីដោយការចរចាតែរឿង ដែលជាទីសប្បាយ ដែលអាស្រ័យវត្ថុដែលគួរ និងមិនគួរ ក្នុងឥរិយាបថ ទាំងឡាយ មានឈរ អង្គុយជាដើម ក៏លះឧទ្ធច្ចកុក្កុច្ចៈបាន ។ ព្រោះ ដូច្នោះ លោកទើបពោលថា ធម៌ ៦ ប្រការនេះ រមែងប្រព្រឹត្តទៅដើម្បី លះឧទ្ធច្ចកុក្កុច្ចៈ ។ ភិក្ខុរមែងដឹងច្បាស់ថា កាលឧទ្ធច្ចកុក្កុច្ចៈលះបាន ហើយដោយធម៌ ៦ ប្រការនេះ ឧទ្ធច្ចៈនឹងមិនកើតតទៅ ដោយអរហត្តមគ្គ កុក្កុច្ចៈមិនកើតតទៅ ដោយអនាគាមិមគ្គ ។

## ហេតុកើតវិចិកិច្ឆា

វិចិកិច្ឆា រមែងកើតបានដោយអយោនិសោមនសិការ ក្នុងធម៌ទាំង ឡាយ ដែលជាទីតាំងនៃវិចិកិច្ឆា ។ សេចក្តីងឿងឆ្ងល់ ព្រោះជាហេតុនៃ សេចក្តីសង្ស័យរឿយ ៗ ឈ្មោះថា ធម៌ជាទីតាំងនៃវិចិកិច្ឆា ។ កាលភិក្ខុ ធ្វើអយោនិសោមនសិការឲ្យប្រព្រឹត្តទៅច្រើន ៗ ក្នុងធម៌ជាទីតាំងនៃវិចិកិច្ឆា នោះ វិចិកិច្ឆារមែងកើត ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ ទុក ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ធម៌ជាទីតាំងនៃវិចិកិច្ឆាមាន ម្នាលភិក្ខុទាំងឡាយ ការធ្វើឲ្យច្រើននូវអយោនិសោមនសិការក្នុងធម៌ជាទី

តាំងនៃវិចិកិច្ឆានោះ នេះជាអាហារដើម្បីការកើតនៃវិចិកិច្ឆា ដែលមិនទាន់កើត ឬដើម្បីធ្វើវិចិកិច្ឆាដែលកើតហើយ ឲ្យរឹងរឹតតែចម្រើនឡើង ដូច្នេះ ។

## ហេតុលះវិចិកិច្ឆា

តែវិចិកិច្ឆានោះ នឹងលះបាន ក៏ដោយយោនិសោមនសិការក្នុងធម៌មានកុសលជាដើម ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ទុក (ក្នុងសំយុត្តនិកាយ មហាវារវគ្គ) ថា ម្នាលភិក្ខុទាំងឡាយ ធម៌ជាកុសល អកុសល ធម៌ដែលមានទោស មិនមានទោស ធម៌ដែលគួរសេព មិនគួរសេព ធម៌ដែលថោកទាប ប្រណីត ធម៌ដែលប្រៀបដោយរបស់ខ្មៅ សការធ្វើឲ្យច្រើននូវយោនិសោមនសិការក្នុងធម៌ទាំងនោះ នេះជាអាហារដើម្បីកាមិនកើតនៃវិចិកិច្ឆា ដែលមិនទាន់កើត ឬដើម្បីលះវិចិកិច្ឆាដែលកើតហើយ ដូច្នេះ ។

## ធម៌សម្រាប់លះវិចិកិច្ឆា

ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះវិចិកិច្ឆា គឺៈ

១-ការស្តាប់ច្រើន ។

២-ការសាកសួរ ។

៣-ភាពជំនាញក្នុងវិន័យ ។

៤-ការច្រើនដោយការបង្អោនចិត្តជឿ ។

៥-ការមានកល្យាណមិត្ត ។

៦-ការចរចាតែរឿងដែលជាទីសប្បាយ ។

ពិតមែន សូម្បីកាលភិក្ខុសិក្សារៀនសូត្រទាំងបាលី ទាំងអដ្ឋកថា និកាយមួយ-ពីរ-បី-បួន ឬប្រាំនិកាយ រមែងលះវិចិកិច្ឆាបាន ដោយភាពជាពហូស្សូត ។ កាលភិក្ខុច្រើនដោយការប្រារព្ធព្រះរតនត្រ័យ សាកសួរក្តី មានភាពជំនាញដែលសន្សំទុកក្នុងវិន័យក្តី ច្រើនទៅដោយការបង្អោនចិត្តជឿ ពោលគឺ សទ្ធាដែលនៅកម្រើកក្នុងព្រះរតនត្រ័យក្តី សេពគប់កល្យាណមិត្ត ដូចព្រះវក្កលិអ្នកបង្អោនចិត្តទៅក្នុងសទ្ធាក្តី រមែងលះវិចិកិច្ឆាបាន ។ សូម្បីដោយការចរចាតែរឿងដែលជាទីសប្បាយ ដែលអាស្រ័យគុណរបស់ព្រះរតនត្រ័យ ក្នុងឥរិយាបថទាំងឡាយ មានឈរអង្គុយជាដើម ក៏លះវិចិកិច្ឆាបាន ។ ព្រោះហេតុនោះ លោកទើបពោលថា ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះវិចិកិច្ឆា ។ ភិក្ខុរមែងដឹងច្បាស់ថា វិចិកិច្ឆាដែលលះបានដោយធម៌ទាំងនេះ រមែងមិនកើតតទៅដោយសោតាបត្តិមគ្គ ដូច្នេះ ។

ពាក្យថា ឥតិ អជ្ឈត្តំ វា ឬខាងក្នុង សេចក្ដីថា ពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយរបស់ខ្លួន ក្នុងធម៌ទាំងឡាយរបស់អ្នកដទៃ ឬក្នុងធម៌ទាំងឡាយរបស់ខ្លួនតាមកាល របស់អ្នកដទៃតាមកាល ដោយការកំណត់នីវរណៈ ៥ យ៉ាងនេះ ។ ក៏ការកើត និងការសូន្យទៅ ក្នុងពាក្យថា ពិចារណាឃើញធម៌ គឺ ការកើត និងការសូន្យទៅនេះ បានពោលហើយក្នុងនីវរណៈ ៥ ដោយអំណាចអយោនិសោមនសិការ និងយោនិសោ-មនសិការក្នុងសុភនិមិត្ត និងអសុភនិមិត្តជាដើម បណ្ឌិតគប្បីនាំមកប្រៀបធៀបចុះ ។ ប្រការតទៅនេះ ក៏មានន័យដូចពោលមកហើយនោះឯង ។

## សតិកំណត់នីវរណៈ ជាអរិយសច្ច ៤

តែក្នុងនីវរណបព្វៈនេះ មានការផ្សេងគ្នាតែម្យ៉ាង គឺ គប្បីប្រកបសេចក្ដីថា សតិដែលកំណត់នីវរណៈជាអារម្មណ៍ ជាទុក្ខសច្ច គប្បីជ្រាបថា ជាផ្លូវបដិបត្តិនាំចេញចាកទុក្ខ របស់ភិក្ខុដែលកំណត់នីវរណៈ ជាអារម្មណ៍ ។ ពាក្យដ៏សេស ក៏ដូច្នោះនុ៎ះឯង ។

" ចប់ នីវរណបព្វៈ "

## ខន្ធបព្វៈ

[១២៩] ព្រះមានព្រះភាគ ត្រាស់ទ្រង់ចែកធម្មានុបស្សនា ដោយនីវរណៈ ៥ យ៉ាងនេះ ឥឡូវនេះ ដើម្បីនឹងទ្រង់ចែកដោយខន្ធ ៥ ទើបត្រាស់ថា បុន ចបរំ ជាដើម ។

បណ្ដាបទទាំងនោះ ពាក្យថា ក្នុងឧបាទានខន្ធ ៥ គឺ កងឧបាទានឈ្មោះថា ឧបាទានខន្ធ អធិប្បាយថា ក្រុមធម៌ គឺ កងធម៌ ដែលជាបច្ច័យនៃឧបាទាន ។ សេចក្ដីសង្ខេបក្នុងទីនេះមានប៉ុណ្ណេះ ចំណែកសេចក្ដីពិស្ដារ លោកពោលទុកហើយ ក្នុងខន្ធកថា ក្នុងគម្ពីរវិសុទ្ធិមគ្គ ។ បទថា ឥតិ រូបំ សេចក្ដីថា នេះរូប រូបមានប្រមាណប៉ុណ្ណេះ ។ ភិក្ខុរមែងដឹងច្បាស់រូបដោយសភាពថា រូបដទៃក្រៅពីនេះមិនមាន ដូច្នេះ ។ សូម្បីក្នុងវេទនាជាដើម ក៏ន័យនេះដូចគ្នា ។ សេចក្ដីសង្ខេបក្នុងទីនេះ មានត្រឹមតែប៉ុណ្ណេះ ។ ចំណែករូបជាដើម លោកពោលទុកហើយក្នុងខន្ធកថា ក្នុងគម្ពីរវិសុទ្ធិមគ្គដោយពិស្ដារ ។ បទថា ឥតិ រូបស្ស សមុទយោ នេះការកើតនៃរូប សេចក្ដីថា ការកើតឡើងនៃរូបដោយអាការ ៥ ដោយការកើតនៃអវិជ្ជាជាដើម រមែងមានដោយអាការយ៉ាងនេះ ។ ពាក្យថា ឥតិ រូបស្ស

អត្ថង្គមោ ការរលត់នៃរូប សេចក្តីថា ការរលត់នៃរូបដោយអាការ ៥ ដោយការរលត់នូវអវិជ្ជាជាដើម រមែងមានដោយអាការយ៉ាងនេះ ។ សូម្បីក្នុងវេទនាជាដើម ក៏ន័យនេះដូចគ្នា ។ សេចក្តីសង្ខេបក្នុងទីនេះ មានត្រឹមតែប៉ុណ្ណេះ ។ ចំណែកសេចក្តីពិស្តារ លោកពោលទុកហើយក្នុងឧទយព្វយញ្ញាណកថា ក្នុងគម្ពីរវិសុទ្ធិមគ្គ ។

ពាក្យថា ឥតិ អជ្ឈត្តំ វា ឬខាងក្នុង សេចក្តីថា ពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយរបស់ខ្លួន ក្នុងធម៌ទាំងឡាយរបស់អ្នកដទៃ ឬក្នុងធម៌ទាំងឡាយរបស់ខ្លួនតាមកាល របស់អ្នកដទៃតាមកាល ដោយការកំណត់ខន្ធ ៥ យ៉ាងនេះ ។ ក៏ការកើត និងការរលត់ ក្នុងពាក្យថា ពិចារណាឃើញធម៌ គឺ ការកើត និងការរលត់ បណ្ឌិតគប្បីនាំមកប្រៀបធៀបដោយលក្ខណៈ ៥០ ដែលពោលទុកក្នុងខន្ធ ៥ ថា ព្រោះអវិជ្ជាកើត រូបទើបកើត ដូច្នេះជាដើម ។ ពាក្យដ៏សេសពីនេះ ក៏មានន័យដូចពោលមកហើយ ។

## សតិកំណត់ខន្ធ ៥ ជាអរិយសច្ច ៤

តែក្នុងទីនេះ មានប្រការផ្សេងគ្នាតែមួយ៉ាង គឺ គប្បីប្រកបសេចក្តីយ៉ាងនេះថា សតិកំណត់ខន្ធជាអារម្មណ៍ ជាទុក្ខសច្ច ដូច្នេះ ហើយគប្បី

*ជ្រាបថា ជាផ្លូវបដិបត្តិនាំចេញចាកទុក្ខរបស់ភិក្ខុ ដែលកំណត់ខន្ធជាអារម្មណ៍ ។ ពាក្យដ៏សេស ក៏ដូច្នោះដូចគ្នា ។*

" ចប់ ខន្ធបព្វៈ "

# អាយតនបព្វៈ

[១៣០] ព្រះមានព្រះភាគ ត្រាស់ទ្រង់បានចែកធម្មានុបស្សនាដោយអំណាចខន្ធ ៥ យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់ចែកដោយអាយតនៈ ទើបត្រាស់ថា បុន ចបរំ ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា ឆសុ អជ្ឈត្តិកពាហិរេសុ អាយតនេសុ ក្នុងអាយតនៈខាងក្នុង និងខាងក្រៅ ៦ សេចក្តីថា ក្នុងអាយតនៈខាងក្នុង ៦ ទាំងនេះ គឺ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ។ ក្នុងអាយតនៈខាងក្រៅ ៦ ទាំងនេះ គឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍ ។ បទថា ចក្ខុញ្ច បជានាតិ ដឹងច្បាស់ចក្ខុ សេចក្តីថា រមែងដឹងច្បាស់ចក្ខុបសាទ ដោយលក្ខណៈ ព្រមដោយកិច្ចតាមសេចក្តីពិត ។ បទថា រូបេ ច បជានាតិ ដឹងច្បាស់នូវរូប សេចក្តីថា រមែងដឹងច្បាស់រូបដែលកើតពីសមុដ្ឋាន ៤ ( កម្ម ចិត្ត ឧតុ អាហារ ) ក្នុងខាងក្រៅ ដោយលក្ខណៈ ព្រមដោយកិច្ចតាមសេចក្តីពិត ។ ពាក្យថា យញ្ច តទុភយំ បដិច្ច ឧប្បជ្ជតិ សញ្ញោជនំ សំយោជនៈ រមែងអាស្រ័យអាយតនៈទាំងពីរ កើតឡើង សេចក្តីថា សញ្ញោជនៈ ១០ យ៉ាង គឺ កាមរាគៈ បដិឃៈ មានៈ

ទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស ភវរាគៈ ឥស្សា មច្ឆរិយៈ និងអវិជ្ជា សញ្ញោជនៈកើតឡើង ព្រោះអាស្រ័យអាយតនៈទាំងពីរ គឺ ចក្ខុ និងរូប ។ មួយវិញទៀត រមែងដឹងច្បាស់សញ្ញោជនៈ ១០ នោះ ដោយលក្ខណៈ ព្រម ដោយកិច្ចតាមការពិត ។

## ហេតុកើតសំយោជនៈ

សួរថា ក៏សញ្ញោជនៈកើតបានយ៉ាងណា ។ ឆ្លើយថា កើតបាន យ៉ាងនេះ នឹងពោលក្នុងចក្ខុទ្វារមុន កាលបុគ្គលត្រេកអរ ត្រេកត្រអាលក្នុង ឥដ្ឋារម្មណ៍ ដែលមកប្រាកដផ្លូវចក្ខុទ្វារ ដោយសេចក្តីត្រេកអរក្នុងកាម សញ្ញោជនៈ គឺ កាមរាគៈក៏កើត ។ កាលបុគ្គលថ្នាំងថ្នាក់ចិត្តក្នុងអនិដ្ឋា-រម្មណ៍ សញ្ញោជនៈ គឺ បដិឃៈក៏កើត ។ កាលសម្គាល់ថា វៀរលែងតែ យើងចេញ អ្នកដទៃណា ដែលអាចសោយអារម្មណ៍នោះ មិនមាន ដូច្នេះ សញ្ញោជនៈ គឺ មានៈក៏កើត ។ កាលប្រកាន់រូបារម្មណ៍នោះថា ទៀង ឋិតថេរ សញ្ញោជនៈ គឺ ទិដ្ឋិក៏កើត ។ កាលសង្ស័យរូបារម្មណ៍នោះថា សត្វឬហ្ន៎ របស់សត្វឬហ្ន៎ សញ្ញោជនៈ គឺ វិចិកិច្ឆាក៏កើត ។ កាល ប្រាថ្នាភពថា អារម្មណ៍នេះ យើងបានដោយងាយ ក្នុងសម្បត្តិភពនេះ

សញ្ញោជនៈ គឺ ភវរាគៈក៏កើត ។ កាលប្រកាន់មាំសីល និងវត្តថា យើងប្រកាន់មាំសីល និងវត្ត អាចបានអារម្មណ៍បែបនេះតទៅទៀត សញ្ញោជនៈ គឺ សីលព្វតុបាទានក៏កើត ។ កាលច្រណែនថា ពួកអ្នកដទៃ មិនគប្បីបានរូបារម្មណ៍បែបនេះឡើយ សញ្ញោជនៈ គឺ ឥស្សាក៏កើត ។ កាលហួងហែងរូបារម្មណ៍ដែលខ្លួនបានហើយ ចំពោះអ្នកដទៃ សញ្ញោជនៈ គឺ មច្ឆរិយៈក៏កើត ។ កាលមិនដឹងច្បាស់ ដោយអំណាចការមិនដឹងវត្ថុដែលកើតព្រមនឹងចក្ខុ និងរូបទាំងមូល សញ្ញោជនៈ គឺ អវិជ្ជាក៏កើត ។

## ការដឹងហេតុ លះសំយោជនៈ

ពាក្យថា យថា ច អនុប្បន្នស្ស ដែលនៅមិនទាន់កើតដោយហេតុណា សេចក្តីថា សញ្ញោជនៈសូម្បី ១០ យ៉ាងនោះ ដែលនៅមិនកើតដោយការមិនផ្សាយឡើង រមែងកើតព្រោះហេតុណា រមែងដឹងច្បាស់ហេតុនោះផង ។ ពាក្យថា យថា ច ឧប្បន្នស្ស ដែលកើតហើយ ព្រោះហេតុណា សេចក្តីថា សញ្ញោជនៈ សូម្បី ១០ យ៉ាងនោះ ដែលកើតហើយ ព្រោះអត្ថថា នៅលះមិនបាន ឬព្រោះផ្សាយឡើង រមែងលះបាន ព្រោះហេតុណា រមែងដឹងច្បាស់ហេតុនោះផង ។ ពាក្យថា យថា ច បហីនស្ស

ដែលលះបាន ព្រោះហេតុណា សេចក្ដីថា សញ្ញោជនៈ ១០ យ៉ាងនោះ សូម្បីលះបង់បានហើយ ដោយតទង្គប្បហាន និងវិក្ខម្ភនប្បហាន រមែងមិនកើតតទៅ ព្រោះហេតុណា រមែងដឹងច្បាស់ហេតុនោះផង ។ សួរថា សញ្ញោជនៈ ១០ នោះមិនកើតតទៅ ព្រោះហេតុណា ។ ឆ្លើយថា មុនដំបូង សញ្ញោជនៈ ៥ គឺ ទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស ឥស្សា និងមច្ឆរិយៈ មិនកើតតទៅ ដោយសោតាបត្តិមគ្គ ។ សញ្ញោជនៈ ២ គឺ កាមរាគៈ បដិឃៈ យ៉ាងគ្រោតគ្រាត មិនកើតតទៅ ដោយសកទាគាមិមគ្គ ។ យ៉ាងល្អិត មិនកើតតទៅ ដោយអនាគាមិមគ្គ ។ សំយោជនៈ ៣ គឺ មានៈ ភវរាគៈ និងអវិជ្ជា មិនកើតតទៅ ដោយអរហត្តមគ្គ ។ សូម្បីក្នុងពាក្យថា សោតញ្ច បជានាតិ សទ្ទេ ច រមែងដឹងច្បាស់សោតៈផង សំឡេងផងជាដើម ក៏ន័យនេះដូចគ្នា ។ មួយទៀត អាយតនៈកថាក្នុងទីនេះ គប្បីជ្រាបដោយពិស្ដារ តាមន័យដែលលោកពោលទុកហើយ ក្នុងអាយតននិទ្ទេស គម្ពីរវិសុទ្ធិមគ្គ ។

ពាក្យថា ឥតិ អជ្ឈត្តំ វា ឬខាងក្រៅ សេចក្ដីថា ពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយរបស់ខ្លួន ដោយការកំណត់អាយតនៈខាងក្នុង ក្នុងធម៌ទាំងឡាយរបស់អ្នកដទៃ ដោយការកំណត់អាយតនៈខាងក្រៅ ឬក្នុងធម៌

ទាំងឡាយរបស់ខ្លួនតាមកាល របស់អ្នកដទៃតាមកាល យ៉ាងនេះ ។ ក៏ការកើត និងការសូន្យទៅក្នុងអាយតនបព្វៈនេះ គប្បីនាំមកប្រៀបធៀប រូបាយតនៈ រួមចូលក្នុងរូបខន្ធ មនាយតនៈក្នុងអរូបាយតនៈទាំងឡាយ រួមចូលក្នុងវិញ្ញាណក្ខន្ធ ធម្មាយតនៈរួមចូលក្នុងខន្ធដ៏សេស មិនគប្បីកាន់យកលោកុត្តរធម៌ ។ សេចក្តីបន្ទាប់ពីនេះ មានន័យដូចដែលពោលមកហើយនុ៎ះឯង ។

## សតិកំណត់អាយតនៈ ជាអរិយសច្ច ៤

ក្នុងបព្វៈនេះ មានប្រការផ្សេងគ្នាតែម្យ៉ាង គឺ គប្បីប្រកបសេចក្តីយ៉ាងនេះថា សតិកំណត់អាយតនៈជាអារម្មណ៍ ជាទុក្ខសច្ច ដូច្នេះជាដើម ហើយគប្បីជ្រាបថា ជាផ្លូវបដិបត្តិនាំចេញចាកទុក្ខ របស់ភិក្ខុដែលកំណត់អាយតនៈជាអារម្មណ៍ ។ ពាក្យដ៏សេសក៏ដូចគ្នានោះឯង ។

" ចប់ អាយតនបព្វៈ "

## ពោជ្ឈង្គបព្វៈ

[១៣១] ព្រះមានព្រះភាគ ត្រាស់ទ្រង់ចែកធម្មានុបស្សនា ដោយអាយតនៈខាងក្នុង ខាងក្រៅមួយយ៉ាង ៗ ៦ យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់ចែកដោយពោជ្ឈង្គៈ ទើបត្រាស់ថា បុន ចបរំ ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **ក្នុងពោជ្ឈង្គៈទាំងឡាយ** គឺ ក្នុងអង្គរបស់សត្វអ្នកត្រាស់ដឹង ។ បទថា **មាន** គឺ មានព្រមដោយការបានមក ។ បទថា សតិសម្ពោជ្ឈង្គ បានដល់ សម្ពោជ្ឈង្គៈ ពោលគឺ សតិ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា សម្ពោជ្ឈង្គៈនេះ ដូច្នេះ ព្រះយោគាវចរត្រាស់ដឹងចាប់ផ្ដើមតាំងពីផ្ដើមវិបស្សនា ឬព្រះយោគាវចរនោះ ភ្ញាក់ឡើងពីកិលេសនិទ្រា ឬចាក់ធ្លុះសច្ចៈទាំងឡាយ ដោយធម្មសាមគ្គី ៧ មានសតិជាដើមយ៉ាងណា ធម៌សាមគ្គីនោះ ឈ្មោះថា **សម្ពោធិ** អង្គរបស់អ្នកភ្ញាក់នោះ ឬធម្មសាមគ្គីជាគ្រឿងដាស់ឲ្យភ្ញាក់នោះ ហេតុនោះ ទើបឈ្មោះថា **សម្ពោជ្ឈង្គៈ** ។ ព្រោះដូច្នោះ លោកទើបពោលថា សម្ពោជ្ឈង្គៈ ពោលគឺ សតិ ។ សូម្បីក្នុងសម្ពោជ្ឈង្គៈដ៏សេស ក៏គប្បីជ្រាបសេចក្ដីនៃពាក្យ តាមន័យនេះ

ឯង ៗ បទថា **មិនមាន** គឺ មិនមាន ព្រោះមិនបានមក ។

វិនិច្ឆ័យក្នុងពាក្យថា យថា ច អនុប្បន្នស្ស ដែលនៅមិនទាន់កើត ព្រោះហេតុណា ជាដើម ដូចតទៅនេះ មុនដំបូង សតិសម្ពោជ្ឈង្គៈ រមែងកើត តាមន័យដែលមកក្នុងបាលី ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយដែលជាទីតាំងដើម្បីកើតសតិសម្ពោជ្ឈង្គៈ និងការធ្វើឲ្យច្រើននូវយោនិសោមនសិការ ក្នុងសតិ-សម្ពោជ្ឈង្គៈនោះ នេះជាអាហារដើម្បីការកើតនៃសតិសម្ពោជ្ឈង្គៈ ដែលមិនទាន់កើត ឬជាផ្លូវចម្រើនសតិសម្ពោជ្ឈង្គៈឲ្យចម្រើនបរិបូរណ៍ក្រៃលែងឡើងទៅ ។ ក្នុងធម៌ទាំងនោះ សតិនោះឯងដែលថា ធម៌ ជាទីតាំងនៃសតិសម្ពោជ្ឈង្គៈ ។ យោនិសោមនសិការ មានលក្ខណៈដូចដែលពោលមកហើយនុ៎ះឯង ។ កាលភិក្ខុធ្វើយោនិសោមនសិការនោះ ឲ្យប្រព្រឹត្តទៅច្រើន ៗ ក្នុងអារម្មណ៍នេះហើយ សតិសម្ពោជ្ឈង្គៈក៏កើត ។

## ធម៌ជាហេតុកើតសតិសម្ពោជ្ឈង្គៈ

ម្យ៉ាងទៀត ធម៌ ៤ ប្រការ ជាផ្លូវកើតសតិសម្ពោជ្ឈង្គៈ គឺ ៖

១- សតិសម្បជញ្ញៈ ។

២- ការវៀរបុគ្គលអ្នកមិនមានសតិ ។

៣- ការគប់រកបុគ្គលអ្នកមានសតិមាំមួន ។

៤- ការបង្អោនចិត្តទៅក្នុងសតិសម្ពោជ្ឈង្គៈនោះ ។

ក៏សតិសម្ពោជ្ឈង្គៈ រមែងកើត ដោយសតិសម្បជញ្ញៈក្នុងឋានៈទាំង ៧ មានឈានទៅខាងមុខជាដើម ដោយការវៀរចាកបុគ្គលអ្នកមិនមានសតិ ដូចគ្នានឹងការរក្សាអាហារ ដោយការគប់រកបុគ្គល អ្នកមានសតិមាំមួន ដូចគ្នានឹងព្រះតិស្សទត្តត្ថេរ និងព្រះអភ័យត្ថេរជាដើម និងដោយភាពជាអ្នកមានចិត្តបង្អោនទៅដើម្បីតាំងសតិ ក្នុងឥរិយាបថទាំងឡាយ មានឈរ អង្គុយជាដើម ។ ភិក្ខុរមែងដឹងច្បាស់ថា ក៏សតិសម្ពោជ្ឈង្គៈនោះ ដែលកើតឡើងដោយហេតុ ៤ ប្រការ យ៉ាងនេះ រមែងចម្រើនបរិបូរណ៍ដោយអរហត្តមគ្គ ។

## ហេតុកើតធម្មវិចយសម្ពោជ្ឈង្គ

ក៏ធម្មវិចយសម្ពោជ្ឈង្គៈ រមែងកើតតាមន័យដែលមកក្នុងបាលីយ៉ាងនេះថា ៖ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលជាកុសល និងអកុសល ។បេ។ ធម៌ដែលប្រៀបធៀបដោយធម៌ចំណែកខ្មៅ និងចំណែកស ការធ្វើឲ្យច្រើន

នូវយោនិសោមនសិការក្នុងធម៌ទាំងនោះ នេះជាអាហារដើម្បីការកើតនៃធម្មវិចយសម្ពោជ្ឈង្គៈ ដែលនៅមិនទាន់កើត ឬដល់វេចម្រើនឲ្យបរិបូរពេញលេញនៃធម្មវិចយសម្ពោជ្ឈង្គៈដែលកើតហើយ ដូច្នេះ ។

## ធម៌ជាហេតុកើតធម្មវិចយសម្ពោជ្ឈង្គៈ

ម្យ៉ាងទៀត ធម៌ ៧ ប្រការ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃធម្មវិចយសម្ពោជ្ឈង្គៈ គឺ ៖

១- ការសាកសួរ ។

២- ការធ្វើវត្ថុឲ្យស្អាតរៀបរយ ។

៣- ការធ្វើឥន្ទ្រិយឲ្យស្មើគ្នា ។

៤- វៀរបុគ្គលមានបញ្ញាទន់ខ្សោយ ។

៥- គប់រកបុគ្គលអ្នកមានបញ្ញា ។

៦- ពិចារណាយកចិត្តទុកដាក់ដោយបញ្ញាដ៏ជ្រាលជ្រៅ ។

៧- ការបង្អោនចិត្តទៅក្នុងធម្មវិចយសម្ពោជ្ឈង្គៈនោះ ។

បណ្តាធម៌ ៧ ប្រការនោះ ភាពជាអ្នកច្រើនទៅដោយការសាកសួរដែលអាស្រ័យអត្ថ នៃខន្ធ ធាតុ អាយតនៈ ឥន្ទ្រិយ ពលៈ ពោជ្ឈង្គៈ

អង្គមគ្គ អង្គឈាន សមថៈ និងវិបស្សនា ឈ្មោះថា ការសោកស្មូរ ។

ការធ្វើវត្ថុខាងក្នុង និងខាងក្រៅឲ្យស្អាតរៀបរយ ឈ្មោះថា ការធ្វើវត្ថុឲ្យស្អាតរៀបរយ ។ ក៏វេលាណា ភិក្ខុមានសក់ ក្រចក និងរោមវែងពេកទៅ ឬរាងកាយ ស្មោកគ្រោកប្រឡាក់ប្រឡូសដោយញើស និងក្អែលវេលានោះ វត្ថុខាងក្នុង (គឺ រាងកាយ) មិនស្អាតរៀបរយ មិនស្អាត ។ តែក្នុងវេលាណា ចីវរចាស់គ្រាំគ្រា ស្មោកគ្រោក ស្អុយឆ្អេះឆ្អាប ឬសេនាសនៈស៊ុបទ្រុប ក្នុងវេលានោះ វត្ថុខាងក្រៅមិនស្អាតរៀបរយ មិនស្អាត ។ ព្រោះដូច្នោះ ទើបគួរធ្វើវត្ថុខាងក្នុងឲ្យស្អាតរៀបរយ ដោយកិច្ច មានការកោរសក់ជាដើម ដោយការធ្វើរាងកាយឲ្យស្រាលសប្បាយ ដោយកិច្ចមានការបន្ទោបង់ជម្រះមន្ទិល ឲ្យទូទៅទាំងខាងលើ ខាងក្រោមជាដើម និងដោយការដុសក្អែល ងូតទឹកបន្ទោបង់ក្លិនស្អុយ ។ គប្បីធ្វើវត្ថុខាងក្រៅឲ្យស្អាត រៀបរយដោយកិច្ច មានការដេរ ជ្រលក់ បោកចីវរ និងធ្វើការដុតបាត្រជាដើម ។ ព្រោះកាលវត្ថុខាងក្នុង និងខាងក្រៅនោះមិនស្អាតរៀបរយកាលចិត្ត និងចេតសិកកើតឡើង សូម្បីបញ្ញាក៏មិនផូរផង់ ដូចជាភាពភ្លឺល្អរបស់ដួងប្រទីបដែលកើតឡើង ព្រោះអាស្រ័យចង្កៀង ប្រឆេះ និងប្រេងដែលមិនស្អាតបរិសុទ្ធិ ដូច្នោះ តែកាលវត្ថុខាងក្នុង និងខាងក្រៅស្អាត

រៀបរយ កាលចិត្ត និងចេតសិកកើតឡើង សូម្បីបញ្ញាក៏ផូរផង់ ដូចពន្លឺរបស់ដួងប្រទីបដែលកើតឡើង ព្រោះអាស្រ័យចង្កៀង ប្រេង និងប្រេងដែលស្អាតបរិសុទ្ធិ ដូច្នោះ ។ ព្រោះហេតុនោះ លោកទើបពោលថា ការធ្វើវត្ថុឲ្យស្អាតរៀបរយ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃធម្មវិចយ-សម្ពោជ្ឈង្គៈ ដូច្នេះ ។

ការធ្វើឥន្ទ្រិយមានសទ្ធាជាដើម ឲ្យស្មើគ្នា ឈ្មោះថា ការធ្វើឥន្ទ្រិយឲ្យស្មើ ។ ព្រោះថា បើឥន្ទ្រិយ គឺ សទ្ធារបស់ភិក្ខុមានកម្លាំងខ្លាំងក្លា ឥន្ទ្រិយក្រៅពីនេះខ្សោយ តពីនោះ ឥន្ទ្រិយ គឺ វីរិយៈ ក៏មិនអាចធ្វើកិច្ច គឺ ការផ្គងចិត្តបាន ឥន្ទ្រិយ គឺ សតិក៏មិនអាចធ្វើកិច្ច គឺ ការប្រាកដ ឥន្ទ្រិយ គឺ សមាធិក៏មិនអាចធ្វើកិច្ច គឺ ការមិនរវើរវាយ ឥន្ទ្រិយ គឺ បញ្ញា ក៏មិនអាចធ្វើកិច្ច គឺ ការឃើញបាន ព្រោះដូច្នោះ កាលមនសិការដល់ឥន្ទ្រិយ គឺ សទ្ធានោះ ដោយការពិចារណាសភាវធម៌ ឬដោយប្រការណា ឥន្ទ្រិយ គឺ សទ្ធា មានកម្លាំងខ្លាំងក្លា គប្បីថយចុះ ដោយការមិនមនសិការដោយប្រការនោះ ។ ក្នុងប្រការនេះ មានរឿងព្រះវក្កលិត្ថេរ ជាឧទាហរណ៍ ។ បើឥន្ទ្រិយ គឺ វីរិយៈមានកម្លាំងខ្លាំងក្លា កាលដូច្នោះ ឥន្ទ្រិយ គឺ សទ្ធាក៏មិនអាចធ្វើកិច្ច គឺ ការបង្អោនចិត្តជឿបាន ឥន្ទ្រិយ ក្រៅនេះ ក៏មិនអាច

ធ្វើកិច្ច គឺ នាទីផ្សេង ៗ របស់ខ្លួនបាន ព្រោះដូច្នោះ ទើបគួរបន្ថយឥន្ទ្រិយ គឺ វីរិយៈនោះចុះ ដោយការចម្រើនបស្សទ្ធិសម្ពោជ្ឈង្គៈ ជាដើម ។ សូម្បីក្នុងប្រការនោះ គប្បីសម្តែងរឿងព្រះសោណត្ថេរ ជាឧទាហរណ៍ ។ សូម្បីក្នុងឥន្ទ្រិយដ៏សេសក៏ដូចគ្នា កាលឥន្ទ្រិយយ៉ាងណាមួយមានកម្លាំងខ្លាំងក្លា ក៏គប្បីជ្រាបថា ឥន្ទ្រិយក្រៅនេះក៏មិនអាចធ្វើកិច្ច គឺ នាទីរបស់ខ្លួនបាន ។ តែដោយចំពោះយ៉ាងក្រៃលែង ក្នុងរឿងឥន្ទ្រិយនេះ លោកសរសើរ សទ្ធា និងបញ្ញា និងសមាធិ និងវីរិយៈ ត្រូវស្មើគ្នា ។ ព្រោះអ្នកមានសទ្ធាខ្លាំងក្លា តែមានបញ្ញាទន់ខ្សោយ សេចក្តីជ្រះថ្លាមានកម្លាំង រមែងជ្រះថ្លាទៅខាងក្រៅរឿង ។ មានបញ្ញាខ្លាំងក្លា តែមានសទ្ធាខ្សោយ រមែងនិយមចូលចិត្តទៅខាងខិលខូច ដូចរោគកើត ព្រោះខុសថ្នាំ ដោះស្រាយមិនបាន ដូច្នោះ ។ អ្នកមានបញ្ញាខ្លាំងក្លា ក៏ស្ទុះលោត ឆ្ងល់ខ្លាទៅថា កុសលមិនបានដោយត្រឹមតែចិត្តប្បាទ ចិត្តគិតមួយខណៈប៉ុណ្ណោះ ដូច្នេះហើយ ក៏មិនធ្វើបុណ្យ មានទានជាដើម រមែងកើតក្នុងនរក ។ ព្រោះ ឥន្ទ្រិយ គឺ សទ្ធា និងបញ្ញា ទាំងពីរស្មើគ្នា ទើបជ្រះថ្លាក្នុងវត្ថុ គឺ ព្រះរតនត្រ័យតែម្យ៉ាង ។ តែសមាធិខ្លាំងក្លា វីរិយៈខ្សោយ កោសជ្ជៈ សេចក្តីខ្ជិលច្រអូស រមែងគ្របសង្កត់បាន ព្រោះសមាធិជាសភាគៈនឹងកោសជ្ជៈ ។ វីរិយៈខ្លាំងក្លា សមាធិខ្សោយ

ឧទ្ធច្ចៈរមែងគ្របសង្កត់បាន ព្រោះវីរិយៈជាសភាគៈនឹងឧទ្ធច្ចៈ ។ តែសមាធិ ដែលវីរិយៈចូលប្រកបទុក រមែងមិនធ្លាក់ទៅក្នុងកោសជ្ជៈ វីរិយៈ ដែល សមាធិចូលប្រកបទុក ក៏មិនធ្លាក់ទៅក្នុងឧទ្ធច្ចៈ ។ ព្រោះដូច្នោះ ទើប គួរធ្វើឥន្ទ្រិយពីរគូនោះ ឲ្យស្មើគ្នាៗ ។ ព្រោះថា អប្បនានឹងមាន ក៏ព្រោះ ឥន្ទ្រិយពីរគូស្មើគ្នា ។ម្យ៉ាងទៀត **សទ្ធា** សូម្បីមានកម្លាំងខ្លាំងក្លា ក៏គួរ ដល់អ្នកចម្រើនសមាធិ ។ ព្រោះអ្នកចម្រើនសមាធិ ជឿមាំយ៉ាងនេះ នឹង សម្រេចអប្បនាបាន ចំណែកក្នុងសមាធិ និងបញ្ញា ឯកគ្គតា ភាពនៃចិត្ត មានអារម្មណ៍តែមួយ មានកម្លាំងខ្លាំងក្លា រមែងគួរដល់អ្នកចម្រើនសមាធិ ។ ព្រោះថា អ្នកចម្រើនសមាធិនោះ រមែងសម្រេចអប្បនាបាន ដោយឯកគ្គតា យ៉ាងនេះ ។ បញ្ញាមានកម្លាំងខ្លាំងក្លា រមែងគួរដល់អ្នកចម្រើនវិបស្សនា ។ ព្រោះថា អ្នកចម្រើនវិបស្សនានោះ រមែងដល់ការចាក់ធ្លុះរហូតដល់ត្រៃ- លក្ខណ៍ ដោយបញ្ញាយ៉ាងនេះ ។ តែអប្បនានឹងមានបាន ក៏ព្រោះសទ្ធា និងបញ្ញាទាំងពីរស្មើគ្នាដោយពិត ។ ចំណែកសតិមានកម្លាំងហើយ រមែង គួរក្នុងទីទាំងពួង ។ ព្រោះថា សតិ រមែងរក្សាចិត្តមិនឲ្យធ្លាក់ទៅក្នុងឧទ្ធច្ចៈ ដោយអំណាចសទ្ធា វីរិយៈ បញ្ញា ដែលជាចំណែកឧទ្ធច្ចៈ មិនឲ្យធ្លាក់ទៅ ក្នុងកោសជ្ជៈ ព្រោះសមាធិជាចំណែកកោសជ្ជៈ ។ ព្រោះដូច្នោះ សតិនោះ

ទើបចាំបាច់ត្រូវប្រាថ្នាក្នុងទីទាំងពួង ដូចការផ្សំរសដោយអំបិល ចាំបាច់ត្រូវប្រាថ្នាក្នុងការផ្សំអាហារគ្រប់យ៉ាង និងដូចអាមាត្រដែលជំនាញក្នុងរាជកិច្ចគ្រប់យ៉ាង ចាំបាច់ត្រូវប្រាថ្នាក្នុងរាជកិច្ចគ្រប់យ៉ាង ដូច្នោះ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា សតិចាំបាច់ត្រូវប្រាថ្នាក្នុងទីទាំងពួង ព្រោះហេតុណា ព្រោះចិត្តមានសតិជាទីអាស្រ័យ និងសតិមានការរក្សាជាអាការប្រាកដ វៀរសតិចេញហើយនឹងផ្គង នឹងគ្របសង្កត់ចិត្តមិនបានឡើយ ។

ការវៀរបុគ្គលដែលមានបញ្ញាទន់ខ្សោយ មិនមានបញ្ញា ឈានចុះក្នុងប្រភេទនៃធម៌ មានខន្ធជាដើម ឈ្មោះថា ការវៀរចាកបុគ្គលមានបញ្ញាខ្សោយ ។ ការគប់រកបុគ្គលអ្នកប្រកបដោយបញ្ញាជុំវិញ ដឹងការកើត និងការរលត់នៃសង្ខារធម៌ ដែលកំណត់ដោយលក្ខណៈ ៥០ គត់ ឈ្មោះថា គប់រកបុគ្គលអ្នកមានបញ្ញា ។ ការពិចារណាប្រភេទនៃបញ្ញា ដ៏ជ្រាលជ្រៅដែលប្រព្រឹត្តទៅក្នុងសង្ខារធម៌ទាំងឡាយ មានខន្ធជាដើម ដ៏ជ្រាលជ្រៅ ឈ្មោះថា ការពិចារណាយកចិត្តទុកដាក់ ដោយបញ្ញាដ៏ជ្រាលជ្រៅ ។ ភាពជាអ្នកមានចិត្តដែលបង្អោនទៅ ដើម្បីតម្កល់ក្នុងធម្មវិចយសម្ពោជ្ឈង្គៈ ក្នុងឥរិយាបថទាំងឡាយ មានឈរ អង្គុយជាដើម ឈ្មោះថា ការបង្អោនចិត្ត

ទៅក្នុងធម្មវិចយសម្ពោជ្ឈង្គៈនោះ ។ ភិក្ខុរមែងដឹងច្បាស់ថា ក៏ធម្មវិចយ-សម្ពោជ្ឈង្គៈនោះ ដែលកើតដោយអាការយ៉ាងនេះ រមែងចម្រើនបរិបូរដោយអំណាចអរហត្តមគ្គ ។

## វីរិយសម្ពោជ្ឈង្គៈ

វីរិយសម្ពោជ្ឈង្គៈ រមែងកើត តាមន័យដែលមកហើយក្នុងបាលី (សំយុត្តនិកាយមហាវារវគ្គ) យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អារព្ភធាតុ (ធាតុ គឺ ការផ្ដើមសេចក្ដីព្យាយាម) និក្កមធាតុ បរក្កមធាតុ (ធាតុ គឺ សេចក្ដីព្យាយាមឈានទៅខាងមុខ) ការធ្វើឲ្យច្រើននូវយោនិសោមនសិ-ការក្នុងធាតុទាំង ៣ នោះ នេះជាអាហារដើម្បីការកើតនៃវីរិយសម្ពោជ្ឈង្គៈ ដែលនៅមិនទាន់កើត ឬប្រព្រឹត្តទៅដើម្បីសេចក្ដីចម្រើន ចម្រើនបរិបូណ៌ នៃវីរិយសម្ពោជ្ឈង្គៈដែលកើតហើយ ដូច្នេះ ។

## ធម៌ជាហេតុកើត វីរិយសម្ពោជ្ឈង្គៈ

ម្យ៉ាងទៀត ធម៌ ១១ ប្រការ រមែងប្រព្រឹត្តទៅដើម្បីការកើតនៃវីរិយសម្ពោជ្ឈង្គៈ គឺ ៖

១- ការពិចារណាឃើញភ័យក្នុងអបាយ ។

២- ការឃើញអានិសង្ស ។

៣- ការពិចារណាវិថីនៃដំណើរ ។

៤- ការគោរពកោតក្រែងក្នុងបិណ្ឌបាត ។

៥- ការពិចារណាភាពជាធំនៃការទទួលទ្រព្យមត៌ក ។

៦- ការពិចារណា ក្នុងការមានព្រះសាស្តាជាធំ ។

៧- ការពិចារណា ការមានជាតិជាធំ ។

៨- ការពិចារណា ការមានសព្រហ្មចារីជាធំ ។

៩- ការវៀរចាកបុគ្គលខ្ជិលច្រអូស ។

១០- ការគប់រកបុគ្គលអ្នកប្រារព្ធសេចក្តីព្យាយាម ។

១១- ការបង្អោនចិត្តទៅក្នុងវីរិយសម្ពោជ្ឈង្គៈនោះ ។

## ១-ការពិចារណាឃើញភ័យក្នុងអបាយ

បណ្តាធម៌ ១១ ប្រការនោះ កាលភិក្ខុដែលចម្រើនវីរិយសម្ពោជ្ឈង្គៈ សូម្បីពិចារណាឃើញភ័យក្នុងអបាយយ៉ាងនេះថា នរណា ៗ មិនអាចញ៉ាំង វីរិយសម្ពោជ្ឈង្គៈឲ្យកើតបាន ក្នុងវេលាដែលសោយទុក្ខធំ ចាប់ផ្តើមពីត្រូវ

ដាក់ទោសដោយគ្រឿងឃុំឃាំង ៥ ប្រការ ក្នុងនរកក្តី ក្នុងវេលាដែលត្រូវគេចាប់ដោយគ្រឿងចាប់ មានអន្ទាក់ សំណាញ់ និងអួនជាដើមខ្លះ ក្នុងវេលាដេញ កៀង វុក ចាក់ដោយគ្រឿងប្រហារ មានជន្ទួញជាដើម ឲ្យទាញរទេះខ្លះ ក្នុងកំណើតសត្វតិរច្ឆានក្តី ក្នុងវេលាដែលទ្រាំទ្រទុក្ខដោយការស្រេកឃ្លាន ក្តៅក្រហាយ ច្រើនពាន់ឆ្នាំខ្លះ មួយពុទ្ធន្តរខ្លះ ក្នុងប្រេតវិស័យក្តី ក្នុងវេលាដែលត្រូវសោយទុក្ខ ដែលកើតពីខ្យល់ និងកំដៅថ្ងៃជាដើម ដោយផ្ទះដែលខ្ពស់ប្រមាណ ៦០ ហត្ថ ៨០ ហត្ថ នៅសល់តែស្បែកដណ្តប់ឆ្អឹង ក្នុងពួកកាលកញ្ជិកអសុរក្តី ម្នាលភិក្ខុ វេលានេះប៉ុណ្ណោះជាវេលាធ្វើសេចក្តីព្យាយាមរបស់អ្នក ដូច្នេះ វីរិយសម្ពោជ្ឈង្គៈ រមែងកើតឡើងបាន ។

## ២-ការឃើញអានិសង្ស

កាលឃើញអានិសង្សយ៉ាងនេះថា អ្នកខ្ជិលច្រអូស មិនអាចបានលោកុត្តរធម៌ ៩ អ្នកដែលប្រារព្ធសេចក្តីព្យាយាមប៉ុណ្ណោះ ទើបអាច នេះជាអានិសង្សរបស់សេចក្តីព្យាយាម ដូច្នេះ វីរិយសម្ពោជ្ឈង្គៈ ក៏រមែងកើតបាន ។

## ៣-ការពិចារណាវីថិនៃដំណើរ

កាលពិចារណាវីថិនៃដំណើរយ៉ាងនេះថា គួរដើរតាមផ្លូវ ដែលព្រះមានព្រះភាគ ព្រះបច្ចេកពុទ្ធ ព្រះមហាសាវកគ្រប់ព្រះអង្គ ធ្វើដំណើរទៅហើយ ផ្លូវនោះ អ្នកខ្ជិលច្រអូសមិនអាចដើរទៅបាន ដូច្នេះ វីរិយសម្ពោជ្ឈង្គ: ក៏រមែងកើតបាន ។

## ៤-ការគោរពកោតក្រែងចំពោះបិណ្ឌបាត

កាលពិចារណាដល់ការគោរពកោតក្រែងចំពោះបិណ្ឌបាតយ៉ាងនេះថា មនុស្សពួកណាទំនុកបម្រុងលោកដោយបច្ច័យ មានបិណ្ឌបាតជាដើម មនុស្សទាំងនោះ មិនមែនញាតិ មិនមែនទាសៈ និងអ្នកការងាររបស់លោកឡើយ ទាំងមនុស្សទាំងនោះ ក៏មិនមែនថ្វាយបច្ច័យ មានចីវរជាដើមដែលប្រណីតដល់លោក ដោយគិតថា នឹងអាស្រ័យលោកចិញ្ចឹមជីវិតតែដែលពិត គេប្រាថ្នាឲ្យឧបការៈចំពោះខ្លួន ធ្វើហើយមានផលច្រើន ទើបថ្វាយ សូម្បីព្រះសាស្តា ក៏មិនបានទ្រង់ពិចារណាឃើញយ៉ាងនេះថា ភិក្ខុនេះបរិភោគបច្ច័យទាំងនេះហើយ នឹងមានរាងកាយរឹងមាំច្រើន នៅជាសុខ

ដូច្នេះ ហើយទ្រង់អនុញ្ញាតបច្ច័យដល់លោក ដោយពិត ព្រះអង្គទ្រង់ពិចារណាឃើញថា ភិក្ខុបរិភោគបច្ច័យទាំងនេះ បំពេញសមណធម៌ នឹងផុតចាកទុក្ខក្នុងវដ្ដៈបាន ដូច្នេះ ទើបទ្រង់អនុញ្ញាតបច្ច័យទុក ឥឡូវនេះ លោកខ្ជិលច្រអូស មិនគោរពកោតក្រែងក្នុងបិណ្ឌបាតនោះ ដែលឈ្មោះថា ការគោរពកោតក្រែងចំពោះបិណ្ឌបាត រមែងមានដល់អ្នកប្រារព្ធសេចក្ដីព្យាយាមប៉ុណ្ណោះ ដូច្នេះ វីរិយសម្ពោជ្ឈង្គៈក៏កើតបាន ដូចវីរិយសម្ពោ-ជ្ឈង្គៈ កើតដល់ព្រះមហាមិត្តត្ថេរ ដូច្នោះ ។

## រឿងព្រះមហាមិត្តត្ថេរ

បានឮមកថា ព្រះថេរៈអាស្រ័យនៅក្នុងល្អាងឈ្មោះកសកៈ ។ និងមហាឧបាសិកាម្នាក់ក្នុងស្រុក ជាទីគោចររបស់លោក ទំនុកបម្រុងព្រះថេរៈដូចបុត្រ ។ ថ្ងៃមួយ នាងនឹងទៅព្រៃទើបប្រាប់កូនស្រីថា កូន ! អង្ករនៅឯណោះ ទឹកដោះ ទឹកដោះថ្លា ទឹកអំពៅនៅឯណោះ វេលាដែល លោកម្ចាស់មិត្តៈ បងប្រុសរបស់នាងមកហើយ ចូរផ្សំអាហារថ្វាយ ព្រមដោយទឹកដោះ ទឹកដោះថ្លា និងទឹកអំពៅផងណាកូន ។ កូនស្រីសួរថា ក៏ម៉ែនឹងទទួលទានទេចាំ ។ មហាឧបាសិកាឆ្លើយថា កាលថ្ងៃម្សិលមិញ ម៉ែ

ហូបអាហារដែលទុក ១ យប់ ( បារិវាសកភត្ត ) ដែលផ្សំនឹងទឹកដោះជូរនោះហើយ ។ កូនស្រីសួរថា ម៉ែនឹងពិសារពេលថ្ងៃទេ ។ មហាឧបាសិកាប្រាប់ថា នាងចូរដាក់បន្ទៃជ្រក់ ហើយយកកញ្ចុំងអង្ករបបរ មានរសជូរទុកឲ្យម៉ែចុះ ។ ព្រះថេរៈគ្រងចីវរហើយ កំពុងនាំបាត្រចេញ ( ពីស្មោក ) បានឮសំឡេងនោះហើយ ក៏ទូន្មានខ្លួនឯងថា បានឮថា មហាឧបាសិកាហូបតែអាហារដែលទុក ១ យប់ នឹងទឹកដោះជូរ សូម្បីពេលថ្ងៃ ក៏នឹងទទួលទានបបរជូរ ដាក់បន្ទៃជ្រក់ នាងប្រាប់អាហារមានបាយជាដើម ដើម្បីប្រយោជន៍ដល់លោក ក៏មហាឧបាសិកានោះ មិនបានប្រាថ្នាទីស្រែ ទីសួនអាហារ និងសម្ពត់ ព្រោះអាស្រ័យលោកឡើយ តែប្រាថ្នាសម្បត្តិ ៣ ប្រការ ( មនុស្សសម្បត្តិ សួគ៌សម្បត្តិ និព្វានសម្បត្តិ ) ទើបប្រគេន លោកនឹងអាចឲ្យសម្បត្តិទាំងនោះ ដល់មហាឧបាសិកានោះ បានឬទេហ្ន៎ ដូច្នេះលោកគិតថា បិណ្ឌបាតនេះឯង យើងនៅមានរាគៈ ទោសៈ មោហៈ នៅមិនអាចទទួលបាន ដូច្នេះហើយ ក៏ទុកបាត្រក្នុងស្មោក ដោះក្ដុំចីវរ ត្រឡប់ទៅល្អាងកសកៈ រក្សាបាត្រទុកក្រោមគ្រែ ពាក់ចីវរទុកត្រង់ស្នួរចីវរ អង្គុយចុះអធិដ្ឋានសេចក្ដីព្យាយាមថា បើយើងមិនសម្រេចព្រះអរហត្ត នឹងមិនចេញទៅពីល្អាង ដូច្នេះ ។ ភិក្ខុដែលមិនប្រមាទមកអស់កាលជាយូរអង្វែង

ហើយ ចម្រើនវិបស្សនា ក៏សម្រេចព្រះអរហត្ត មុនវេលាអាហារព្រឹក ជាព្រះមហាខីណាស្រព ( អស់អាសវៈហើយ ) អង្គុយញញឹមដូចផ្កាបទុម ដែលកំពុងរីកដូច្នោះ ។ ទេវតាស្ថិតនៅដើមឈើ ជិតទ្វារល្អាង ថ្លែងឧទានថា ៖

នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម
យស្ស តេ អាសវា ខីណា ទក្ខិណេយ្យោសិ មារិស

លោកជាបុរសអាជានេយ្យ ខ្ញុំសូមមនស្ការលោក លោកជាកំពូលបុរស ខ្ញុំសូមនមស្ការលោក ខ្ញុំសូមនមស្ការលោកអ្នកមានអាសវៈអស់ហើយ លោកអ្នកនិរទុក្ខ លោកជាអ្នកគួរដល់ទក្ខិណាទាន ដូច្នេះ ។

ហើយពោលថា លោកម្ចាស់ ពួកស្ត្រីថ្វាយអាហារដល់ព្រះអរហន្តទាំងឡាយ ដូចលោកម្ចាស់អ្នកចូលទៅបិណ្ឌបាត នឹងផុតពីទុក្ខបាន ដូច្នេះ ។

ព្រះថេរៈក្រោកឡើង បើកទ្វារមើលវេលា ជ្រាបថា នៅព្រឹក ទើបកាន់បាត្រ និងចីវរចូលកាន់ស្រុក ចំណែកក្មេងស្រីត្រៀមអាហារសម្រេចហើយ អង្គុយចាំមើលនៅត្រង់ទ្វារ ដោយនឹកថា មួយក្អែតបងប្រុសយើងគង់នឹងមក មួយក្អែតបងប្រុសយើងគង់នឹងមក ។ កាលព្រះថេរៈមកដល់

ទ្វារផ្ទះហើយ ក្មេងស្រីនោះ ក៏ទទួលបាត្រដាក់ពេញដោយអាហារ លាយទឹកដោះ ដែលផ្សំដោយទឹកដោះថ្លា និងទឹកអំពៅហើយ ដាក់លើដៃ ( របស់ព្រះថេរៈ ) ។ ព្រះថេរៈធ្វើអនុមោទនាថា ចូរបានសុខចុះ ហើយក៏ចៀសចេញទៅ ។ ក្មេងស្រីនោះឈរសម្លឹងមើលលោកហើយ ។ សេចក្តីពិតក្នុងគ្រានោះ ពណ៌សម្បុររបស់ព្រះថេរៈ បរិសុទ្ធិក្រៃលែងណាស់ ឥន្ទ្រិយថ្លាផូរផង់ មុខរបស់លោកស្រស់បស់ក្រៃលែងណាស់ ដូចផ្លែត្នោតទុំជ្រុះចាកទង ដូច្នោះ ។ មហាឧបាសិកាត្រឡប់មកពីព្រៃសួរថា បងប្រុសរបស់នាងមកហើយឬកូន ។ ក្មេងស្រីនោះ ក៏ប្រាប់រឿងទាំងអស់ឲ្យមាតាស្តាប់ ។ មហាឧបាសិកាក៏ដឹងបានថា ថ្ងៃនេះ កិច្ចបព្វជិតនៃបុត្ររបស់យើងដល់ទីបំផុតហើយ ទើបពោលថា កូន ! បងប្រុសរបស់នាង ត្រេកអរក្រៃលែងណាស់ក្នុងព្រះពុទ្ធសាសនា មិនអផ្សុក ( ចង់សឹក ) ឡើយ ដូច្នេះ ។

## ៥- ការពិចារណា ការមានទ្រព្យមត៌កជាធំ

កាលពិចារណា ការមានទ្រព្យមត៌កជាធំ យ៉ាងនេះថា ក៏ទ្រព្យ-មត៌ករបស់ព្រះសាស្តាមានច្រើន គឺ អរិយទ្រព្យ ៧ ប្រការ ទ្រព្យមត៌កនោះ អ្នកខ្ជិលច្រអូសមិនអាចទទួលបាន ដូចជា មាតា បិតា រមែង

កាត់កាឡបុត្រអ្នកប្រព្រឹត្តខុស ធ្វើឲ្យជាអ្នកខាងក្រៅថា អ្នកនេះមិនមែនជាកូនរបស់យើង កាលមាតាបិតាស្លាប់ទៅ គេក៏មិនបានទទួលទ្រព្យមត៌កយ៉ាងណា សូម្បីបុគ្គលអ្នកខ្ជិលច្រអូស ក៏ដូច្នោះ រមែងមិនបានមត៌ក គឺអរិយទ្រព្យនេះ អ្នកប្រារព្ធសេចក្ដីព្យាយាមប៉ុណ្ណោះ រមែងបានទទួល ដូច្នេះ វិរិយសម្ពោជ្ឈង្គៈ រមែងកើតបាន ។

## ៦-ការពិចារណា ការមានព្រះសាស្ដាជាធំ

កាលពិចារណា ការមានព្រះសាស្ដាជាធំយ៉ាងនេះថា ព្រះសាស្ដារបស់យើងជាធំ ព្រោះក្នុងវេលាដែលព្រះសាស្ដារបស់យើង ទ្រង់ចាប់បដិសន្ធិ ក្នុងព្រះគភ៌របស់ព្រះមាតាក្ដី វេលាស្ដេចចេញមហាភិនេស្រ្កម៍ក្ដី វេលាត្រាស់ដឹងព្រះអនុត្តរសម្មាសម្ពោធិញាណក្ដី វេលាប្រកាសព្រះធម្មចក្រ សម្ដែងយមកបាដិហារ្យ ស្ដេចចុះចាកពីទេវលោក និងទ្រង់ដាក់អាយុសង្ខារក្ដី វេលាស្ដេចរលត់ខន្ធបរិនិព្វានក្ដី មុឺនលោកធាតុ ក៏ញាប់ញ័រហើយ យើងបួសក្នុងព្រះសាសនារបស់សាស្ដា បែបនេះហើយ ជាអ្នកខ្ជិលច្រអូសគួរឬទេ ដូច្នេះ វិរិយសម្ពោជ្ឈង្គៈ រមែងកើតបាន ។

## ៧-ការពិចារណា ការមានជាតិជាធំ

កាលពិចារណា ការមានជាតិជាធំយ៉ាងនេះថា សូម្បីដោយជាតិឥឡូវនេះ យើងមិនមែនជាអ្នកមានជាតិទន់ទាបនោះទេ យើងឈ្មោះថាកើតហើយក្នុងវង្សរបស់ព្រះបាទឧក្កាកករាជ ដែលបន្តវង្សគ្នាមកដោយមហាសម្មតបវេណី មិនលាយជាមួយនឹងជនជាតិដទៃ ជាព្រះនត្តារបស់ព្រះបាទសុទ្ធោទនមហារាជ និងព្រះនាងមហាមាយាទេវី ជាព្រះអនុជរបស់ព្រះរាហុលពុទ្ធជិនោរស ដែលឈ្មោះថា យើងជាពុទ្ធជិនបុត្រ បែបនេះហើយ នៅជាអ្នកខ្ជិលច្រអូស មិនសមគួរ ដូច្នេះ វីរិយសម្ពោជ្ឈង្គៈ រមែងកើតបាន ។

## ៨-ការពិចារណា ការមានសព្រហ្មចារីជាធំ

កាលពិចារណា ការមានសព្រហ្មចារីជាធំ យ៉ាងនេះថា ព្រះសារីបុត្រ ព្រះមោគ្គល្លាន និងព្រះមហាសាវក ៨០ រូប លោកចាក់ធ្លុះ ( ត្រាស់ដឹង ) លោកុត្តរធម៌ ដោយសេចក្ដីព្យាយាមទាំងនោះ យើងនឹងដើរតាមផ្លូវរបស់សព្រហ្មចារីទាំងនោះ ឬមិនដើរតាមហ្ន៎ ដូច្នេះ វីរិយសម្ពោជ្ឈង្គៈ រមែងកើតបាន ។

## ៩- ការវៀរចាកបុគ្គលអ្នកខ្ជិលច្រអូស

## ១០- ការគប់រកបុគ្គលអ្នកប្រារព្ធសេចក្តីព្យាយាម

## ១១- ការបង្អោនចិត្តទៅក្នុងវីរិយសម្ពោជ្ឈង្គៈនោះ

*កាលវៀរបុគ្គលអ្នកខ្ជិលច្រអូស អ្នកលះបង់សេចក្តីព្យាយាមផ្លូវកាយ និងផ្លូវចិត្ត ដូចជាពោះថ្លាន់ស៊ីពេញពោះហើយ ក៏ឈប់នឹងក្តី គប់រកបុគ្គលអ្នកប្រារព្ធសេចក្តីព្យាយាម អ្នកឧទ្ទិសខ្លួន ប្រាថ្នាបដិបត្តិធម៌ក្តី មានចិត្តបង្អោនទៅដើម្បីឲ្យសេចក្តីព្យាយាមកើតឡើង ក្នុងឥរិយាបថទាំងឡាយ មានឈរ អង្គុយជាដើមក្តី វីរិយសម្ពោជ្ឈង្គៈ រមែងកើតបាន ។ ភិក្ខុរមែងដឹងច្បាស់ថា វីរិយសម្ពោជ្ឈង្គៈនោះ ដែលកើតហើយ ដោយអាការយ៉ាងនេះ រមែងចម្រើនបរិបូណ៌ ដោយអរហត្តមគ្គ ។*

## បីតិសម្ពោជ្ឈង្គៈ

*បីតិសម្ពោជ្ឈង្គៈ រមែងកើត ដោយន័យដែលមកហើយក្នុងបាលី ( សំយុត្តនិកាយ មហាវារវគ្គ ) យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែលជាទីតាំងនៃបីតិសម្ពោជ្ឈង្គៈមាន ការធ្វើឲ្យច្រើននូវយោនិសោមនសិការ*

ក្នុងធម៌ដែលជាទីតាំងនៃបីតិសម្ពោជ្ឈង្គៈ នេះជាអាហារ ដើម្បីការកើតនៃបីតិសម្ពោជ្ឈង្គៈ ដែលនៅមិនទាន់កើត ឬជាផ្លូវដើម្បីសេចក្ដីចម្រើនចម្រើនបរិបូណ៌នៃបីតិសម្ពោជ្ឈង្គៈ ដែលកើតហើយ ដូច្នេះ ។ បីតិនោះឯង ឈ្មោះថា ធម៌ជាទីតាំងនៃបីតិសម្ពោជ្ឈង្គៈ ក្នុងបាលីនោះ ។ មនសិការដែលញ៉ាំងបីតិនោះឲ្យកើត ឈ្មោះថា យោនិសោមនសិការ ។

## ធម៌ជាហេតុកើតបីតិសម្ពោជ្ឈង្គៈ

ម្យ៉ាងទៀត ធម៌ ១១ ប្រការ រមែងជាផ្លូវកើត បីតិសម្ពោជ្ឈង្គៈ គឺ

១- ពុទ្ធានុស្សតិ ។

២- ធម្មានុស្សតិ ។

៣- សង្ឃានុស្សតិ ។

៤- សីលានុស្សតិ ។

៥- ចាគានុស្សតិ ។

៦- ទេវតានុស្សតិ ។

៧- ឧបសមានុស្សតិ ។

៨- វៀរបុគ្គលអ្នកសៅហ្មង ។

៩- គប់រកបុគ្គលអ្នកបរិសុទ្ធិ ។

១០- ការពិចារណាសេចក្តីក្នុងព្រះសូត្រ ដែលជាទីតាំងនៃសេចក្តីជ្រះថ្លា ។

១១- ការបង្អោនចិត្តទៅក្នុងបីតិសម្ពោជ្ឈង្គៈនោះ ។

ពិតណាស់ អ្នកចម្រើនបីតិសម្ពោជ្ឈង្គៈ កាលរឭកដល់ព្រះពុទ្ធគុណ បីតិសម្ពោជ្ឈង្គៈ ផ្សាយជ្រួតជ្រាបទូទៅសរីរៈដរាបដល់ឧបចារសមាធិ រមែងកើតឡើង ។ កាលរឭកដល់គុណព្រះធម៌ និងព្រះសង្ឃក្តី ពិចារណាចតុប្បារិសុទ្ធិសីល ៤ ដែលខ្លួនរក្សា មិនដាច់ធ្លុះធ្លាយ អស់វេលាយូរក្តី សូម្បីជាគ្រហស្ថ ពិចារណាសីល ១០ សីល ៥ ក្តី ពិចារណាចាគៈការបរិច្ចាគថា ក្នុងវេលាប្រសព្វទុព្ភិក្ខភ័យជាដើម យើងថ្វាយភោជនដែលប្រណីតដល់សព្រហ្មចារីទាំងឡាយ ហើយថ្វាយភោជនឈ្មោះយ៉ាងនេះ ដូច្នេះក្តី សូម្បីជាគ្រហស្ថ ពិចារណាដល់ទាន ដែលថ្វាយដល់លោកអ្នកមានសីល ក្នុងវេលាបែបនោះក្តី ពិចារណាដល់គុណ ដូចដែលទេវតាប្រកបហើយដល់ភាពជាទេវតាថា មាននៅក្នុងខ្លួនក្តី ពិចារណាឃើញថាកិលេសដែលគ្របសង្កត់បានហើយ សូម្បីដោយសមាបត្តិ រហូតអស់ ៦០ ឆ្នាំខ្លះ ៧០ ឆ្នាំខ្លះ មិនមានការកម្រើកដូច្នេះក្តី វៀរបុគ្គលសៅហ្មង អ្នក

មានទចិត្តកករល្អក់ដែលសន្សំទុក ព្រោះមិនធ្វើដោយគោរព ក្នុងវេលាឃើញព្រះចេតិយ ឃើញពោធិព្រឹក្ស និងឃើញព្រះថេរៈ ដូចជានឹងល្អងធូលីលើខ្នងលា ព្រោះមិនមានសេចក្ដីជ្រះថ្លា គោរពស្រឡាញ់ក្នុងព្រះរតនត្រ័យ មានព្រះពុទ្ធជាដើមក្ដី សេពបុគ្គលអ្នកបរិសុទ្ធិ អ្នកច្រើនដោយសេចក្ដីជ្រះថ្លា មានចិត្តបង្អោនចុះក្នុងព្រះរតនត្រ័យ មានព្រះពុទ្ធជាដើមក្ដី ពិចារណាសេចក្ដីក្នុងព្រះសូត្រ ដែលជាទីតាំងនៃសេចក្ដីជ្រះថ្លា ដែលសម្ដែងគុណរបស់ព្រះរតនត្រ័យក្ដី មានចិត្តបង្អោនទៅដើម្បីឲ្យកើតបីតិ ក្នុងឥរិយាបថទាំងឡាយ មានឈរ អង្គុយជាដើមក្ដី បីតិសម្ពោជ្ឈង្គៈ រមែងកើតបាន ។ ភិក្ខុរមែងដឹងច្បាស់ថា បីតិសម្ពោជ្ឈង្គៈនោះ ដែលកើតហើយដោយអាការយ៉ាងនេះ រមែងចម្រើនបរិបូណ៌ ដោយអរហត្តមគ្គ ។

## បស្សទ្ធិសម្ពោជ្ឈង្គៈ

បស្សទ្ធិសម្ពោជ្ឈង្គៈ រមែងកើតដោយន័យដែលមកហើយក្នុងបាលី ( សំយុត្តនិកាយ មហាវារវគ្គ ) យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ កាយបស្សទ្ធិ សេចក្ដីស្ងប់កាយ , ចិត្តបស្សទ្ធិ សេចក្ដីស្ងប់ចិត្តមាន ការធ្វើឲ្យច្រើននូវយោនិសោមនសិការក្នុងសេចក្ដីស្ងប់កាយ និងសេចក្ដីស្ងប់ចិត្តនោះ នេះ

ជាអាហារ ( រមែងប្រព្រឹត្តទៅ ) ដើម្បីការកើតឡើងនៃបស្សទ្ធិសម្ពោជ្ឈង្គៈ ដែលមិនទាន់កើត ឬជាផ្លូវដើម្បីសេចក្តីចម្រើន ចម្រើនបរិបូរណ៍ពេញលេញនៃបស្សទ្ធិសម្ពោជ្ឈង្គៈ ដែលកើតហើយ ដូច្នេះ ។

## ធម៌ជាហេតុកើតបស្សទ្ធិសម្ពោជ្ឈង្គ

ម្យ៉ាងទៀត ធម៌ ៧ ប្រការ រមែងជាផ្លូវកើតបស្សទ្ធិសម្ពោជ្ឈង្គ គឺ ៖

១- សេពភោជនដែលប្រណីត ។

២- សេពរដូវជាទីសប្បាយ ។

៣- សេពឥរិយាបថជាទីសប្បាយ ។

៤- ប្រកបភាពជាកណ្តាល ។

៥- វៀរបុគ្គលអ្នកមិនស្ងប់កាយ ។

៦- សេពបុគ្គលអ្នកស្ងប់កាយ ។

៧- បង្អោនចិត្តទៅក្នុងបស្សទ្ធិសម្ពោជ្ឈង្គនោះ ។

ពិតណាស់ អ្នកចម្រើនបស្សទ្ធិសម្ពោជ្ឈង្គៈ កាលបរិភោគភោជនជាទីសប្បាយដែលប្រណីតហ្មត់ចត់ក្តី សេពរដូវជាទីសប្បាយ មិនថា នឹងជារដូវត្រជាក់ រដូវក្តៅ សេពឥរិយាបថជាទីសប្បាយមិនថានឹងជាឥរិយាបថ

ឈរ ជាដើមក្ដី រមែងកើតសេចក្ដីស្ងប់បាន ។ តែពាក្យនោះ លោកមិនបានពោលសំដៅដល់បុគ្គលអ្នកជាមហាបុរស ដែលអត់ធន់ចំពោះរដូវ និងឥរិយាបថជាទីសប្បាយ ។ កាលអ្នកមានរដូវ និងឥរិយាបថដែលត្រូវគ្នា និងមិនត្រូវគ្នា វៀររដូវ និងឥរិយាបថដែលមិនត្រូវគ្នាចេញហើយ សេពរដូវ និងឥរិយាបថដែលត្រូវគ្នា បស្សទ្ធិសម្ពោជ្ឈង្គៈ រមែងកើតបាន ។ ការពិចារណាដល់ភាពដែលខ្លួន និងអ្នកដទៃមានកម្មជារបស់ខ្លួន ហៅថាប្រកបភាពជាកណ្ដាល បស្សទ្ធិសម្ពោជ្ឈង្គៈ រមែងកើតបានដោយប្រកបភាពជាកណ្ដាលយ៉ាងនេះ ។ កាលវៀរបុគ្គលអ្នកមានកាយមិនស្ងប់ ដូចត្រាច់បៀតបៀនសត្វដទៃដោយគ្រឿងប្រហារ មានដុំដី និងកំណាត់ឈើជាដើមក្ដី សេពបុគ្គលអ្នកមានកាយស្ងប់ សង្រួមដៃ ជើងក្ដី មានចិត្តបង្អោន ទោរទន់ទៅដើម្បីឲ្យកើតបស្សទ្ធិសម្ពោជ្ឈង្គៈ ក្នុងឥរិយាបថ មានឈរ អង្គុយជាដើមក្ដី បស្សទ្ធិសម្ពោជ្ឈង្គៈ រមែងកើតបាន ។ ភិក្ខុរមែងដឹងច្បាស់ថា ក៏បស្សទ្ធិសម្ពោជ្ឈង្គៈនោះ ដែលកើតហើយដោយអាការយ៉ាងនេះ រមែងចម្រើនបរិបូណ៌ ដោយអរហត្តមគ្គ ។

## សមាធិសម្ពោជ្ឈង្គ

*សមាធិសម្ពោជ្ឈង្គៈ រមែងកើតបាន ដោយន័យមកហើយក្នុងបាលី (សំយុត្តនិកាយ មហាវារវគ្គ) យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ សមថ-និមិត្ត (បាលីថា សមាធិនិមិត្ត) អព្យគ្គនិមិត្តមាន ការធ្វើឲ្យច្រើននូវយោនិសោមនសិការក្នុងនិមិត្តទាំងពីរនោះ នេះជាអាហារ (រមែងប្រព្រឹត្តទៅ) ដើម្បីការកើតនៃសមាធិសម្ពោជ្ឈង្គៈ ដែលនៅមិនទាន់កើត ឬជាផ្លូវដើម្បីសេចក្ដីចម្រើន ចម្រើនបរិបូណ៌ពេញលេញ នៃសមាធិសម្ពោជ្ឈង្គៈ ដែលកើតហើយ ដូច្នេះ ។*

*ក្នុងនិមិត្តទាំងនេះ សមថៈនុ៎ះឯង ឈ្មោះថា សមថនិមិត្ត និងអព្យគ្គនិមិត្ត ព្រោះអត្ថថា មិនរវើរវាយ ។*

## ធម៌ជាហេតុកើតសមាធិសម្ពោជ្ឈង្គ

*ម្យ៉ាងទៀត ធម៌ ១១ ប្រការ រមែងជាផ្លូវកើតសមាធិសម្ពោជ្ឈង្គ គឺ ៖*

*១- ធ្វើវត្ថុឲ្យស្អាតរៀបរយ ។*

*២- ការធ្វើឥន្ទ្រិយឲ្យស្មើគ្នា ។*

*៣- ឆ្លាតក្នុងនិមិត្ត ។*

៤- ផ្គងចិត្តក្នុងសម័យដែលគួរផ្គង ។

៥- គ្របសង្កត់ចិត្តក្នុងសម័យដែលគួរគ្របសង្កត់ ។

៦- ធ្វើចិត្តឲ្យរីករាយក្នុងសម័យដែលគួរឲ្យរីករាយ ។

៧- ព្រងើយក្នុងសម័យដែលគួរព្រងើយ ។

៨- វៀរបុគ្គលអ្នកមានចិត្តមិនជាសមាធិ ។

៩- គប់រកបុគ្គលអ្នកមានចិត្តជាសមាធិ ។

១០- ពិចារណា និងវិមោក្ខ ។

១១- បង្អោនចិត្តទៅក្នុងសមាធិសម្ពោជ្ឈង្គៈនោះ ។

## អធិប្បាយធម៌ ១១ ប្រការ

ក្នុងធម៌ ១១ ប្រការនោះ ចំពោះការធ្វើវត្ថុឲ្យស្អាតរៀបរយ និងការធ្វើឥន្ទ្រិយឲ្យស្មើ គប្បីជ្រាបតាមន័យដែលពោលមកហើយនុ៎ះឯង ។

សេចក្តីឆ្លាតក្នុងការកំណត់កសិណនិមិត្ត ជាអារម្មណ៍ ឈ្មោះថាឆ្លាតក្នុងនិមិត្ត ។ ការផ្គងចិត្តទុក ដោយការតាំងធម្មវិចយសម្ពោជ្ឈង្គៈ វិរិយសម្ពោជ្ឈង្គៈ និងបីតិសម្ពោជ្ឈង្គៈ ក្នុងសម័យដែលចិត្តរួញរា ព្រោះមានសេចក្តីព្យាយាមធូរថយពេកទៅជាដើម ឈ្មោះថា ផ្គងចិត្តក្នុងសម័យ

ដែលគួរផ្គង ។

ការគ្របសង្កត់ចិត្តទុក ដោយការតាំងបស្សទ្ធិសម្ពោជ្ឈង្គៈ សមាធិ-សម្ពោជ្ឈង្គៈ និងឧបេក្ខាសម្ពោជ្ឈង្គៈ ក្នុងសម័យដែលចិត្តរាយមាយ ព្រោះប្រារព្ធសេចក្តីព្យាយាមខ្លាំងហួសពេកទៅជាដើម ឈ្មោះថា គ្របសង្កត់ចិត្តក្នុងសម័យដែលគួរគ្របសង្កត់ ។

ពាក្យថា ធ្វើចិត្តឲ្យរីករាយក្នុងសម័យដែលគួរឲ្យរីករាយ អធិប្បាយថា សម័យណាចិត្តមិនស្រស់ថ្លា ព្រោះមានបញ្ញា និងសេចក្តីព្យាយាមខ្សោយទៅ ឬព្រោះមិនបានសម្រេចសុខដែលកើតពីសេចក្តីស្ងប់ សម័យនោះ ក៏ធ្វើចិត្តឲ្យសង្វេគ ដោយពិចារណាសំវេគវត្ថុ រឿងដែលជាទីតាំងនៃសេចក្តីសង្វេគ ៨ ប្រការ ។ រឿងដែលជាទីតាំងនៃសេចក្តីសង្វេគ ៨ ប្រការ គឺ ១ ជាតិ , ២ ជរា , ៣ ព្យាធិ , ៤ មរណៈ , ៥ ទុក្ខក្នុងអបាយ , ៦ ទុក្ខក្នុងអតីតមានវដ្តៈជាមូល , ៧ ទុក្ខក្នុងអនាគតមានវដ្តៈជាមូល , ៨ ទុក្ខក្នុងបច្ចុប្បន្នមានការស្វែងរកអាហារជាមូល ។ មួយទៀត ការធ្វើសេចក្តីជ្រះថ្លាឲ្យកើត ដោយមករឭកដល់គុណព្រះរតនត្រ័យ យ៉ាងនេះ ក៏ហៅថា ការធ្វើចិត្តឲ្យរីករាយក្នុងសម័យដែលគួរឲ្យរីករាយ ។

ឈ្មោះថា ព្រងើយកន្តើយក្នុងសម័យដែលគួរព្រងើយកន្តើយ អធិ-

ប្បាយថា សម័យណា ចិត្តអាស្រ័យការបដិបត្តិប្រពៃ មិនរួញរា មិនរវើរវាយ ចិត្តស្រស់ថ្លា ប្រព្រឹត្តទៅស្មើក្នុងអារម្មណ៍ ដំណើរក្នុងសមថវិថី សម័យនោះ មិនត្រូវខ្វល់ខ្វាយក្នុងការផ្គង គ្របសង្កត់ និងធ្វើចិត្តឲ្យរីករាយ ដូចសារថី មិនត្រូវខ្វល់ខ្វាយ ក្នុងកាលសេះរត់ស្មើល្អដូច្នោះ យ៉ាងនេះ ហៅថា ព្រងើយកន្តើយ ក្នុងសម័យដែលគួរព្រងើយកន្តើយ ។

ការវៀរបុគ្គលអ្នកមានចិត្តរវើរវាយ មិនសម្រេចឧបចារៈ ឬអប្បនាឲ្យឆ្ងាយ ឈ្មោះថា វៀរបុគ្គលអ្នកមានចិត្ត មិនជាសមាធិ ។

ការសេព គប់រក ចូលទៅអង្គុយជិតបុគ្គលអ្នកមានចិត្តជាសមាធិ ដោយឧបចារភាវនា ឬអប្បនាភាវនា ឈ្មោះថា គប់រកបុគ្គលអ្នកមានចិត្តជាសមាធិ ។

ភាពជាអ្នកមានចិត្តបង្អោនទោរទន់ទៅ ដើម្បីឲ្យកើតសមាធិ ក្នុងឥរិយាបថទាំងឡាយ មានឈរ អង្គុយជាដើម ឈ្មោះថា បង្អោនចិត្តទៅក្នុងសមាធិសម្ពោជ្ឈង្គៈ ។

សេចក្តីថា កាលបដិបត្តិយ៉ាងនេះ សមាធិសម្ពោជ្ឈង្គៈនោះ រមែងកើតបាន ។ កាលភិក្ខុដឹងច្បាស់ថា ក៏សមាធិសម្ពោជ្ឈង្គៈនោះ ដែលកើតហើយដោយអាការយ៉ាងនេះ រមែងចម្រើនបរិបូណ៌ដោយអរហត្តមគ្គ ។

## ឧបេក្ខាសម្ពោជ្ឈង្គ

ឧបេក្ខាសម្ពោជ្ឈង្គៈ រមែងកើតបាន តាមន័យដែលមកហើយក្នុងបាលី ( សំយុត្តនិកាយ មហាវារវគ្គ ) យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែលជាទីតាំងនៃឧបេក្ខាសម្ពោជ្ឈង្គៈមាន ការធ្វើឲ្យច្រើននូវយោនិសោ-មនសិការក្នុងធម៌ជាទីតាំងនៃឧបេក្ខាសម្ពោជ្ឈង្គៈនោះ នេះជាអាហារ ( រមែងប្រព្រឹត្តទៅ ) ដើម្បីការកើតនៃឧបេក្ខាសម្ពោជ្ឈង្គៈ ដែលនៅមិនទាន់កើតឬជាផ្លូវដើម្បីសេចក្ដីចម្រើន ចម្រើនបរិបូរណ៌ពេញលេញនៃឧបេក្ខាសម្ពោ-ជ្ឈង្គៈដែលកើតហើយ ដូច្នេះ ។ ក៏ក្នុងធម៌ទាំងនោះ ឧបេក្ខានុ៎ះឯង ឈ្មោះថាធម៌ជាទីតាំងនៃឧបេក្ខាសម្ពោជ្ឈង្គៈ ។

## ធម៌ជាហេតុកើតឧបេក្ខាសម្ពោជ្ឈង្គ

មួយ៉ាងទៀត ធម៌ ៥ ប្រការ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃឧបេក្ខាសម្ពោជ្ឈង្គៈ គឺ ៖

១- ដាក់ខ្លួនជាកណ្ដាលក្នុងសត្វ ។

២- ដាក់ខ្លួនជាកណ្ដាលក្នុងសង្ខារ ។

៣- វៀរបុគ្គលអ្នកប្រកាន់សត្វនិងសង្ខារ ។

៤- គប់រកបុគ្គលអ្នកដាក់ខ្លួនជាកណ្ដាលក្នុងសត្វនិងសង្ខារ ។

៥- បង្អោនចិត្តទៅក្នុងឧបេក្ខាសម្ពោជ្ឈង្គនោះ ។

## អធិប្បាយធម៌ ៥ ប្រការ

ក្នុងធម៌ ៥ ប្រការនោះ អ្នកចម្រើនឧបេក្ខាសម្ពោជ្ឈង្គៈ រមែងផ្ដើមការដាក់ខ្លួនជាកណ្ដាលក្នុងសត្វ ដោយអាការ ២ យ៉ាង គឺ ដោយការពិចារណាដល់ភាពដែលខ្លួន និងអ្នកដទៃ មានកម្មជារបស់ខ្លួន យ៉ាងនេះថា លោកមកដោយកម្មរបស់ខ្លួន ក៏នឹងទៅដោយកម្មរបស់ខ្លួន សូម្បីគេក៏មកដោយកម្មរបស់ខ្លួន (គេ) នឹងទៅដោយកម្មរបស់ខ្លួន (គេ) ដូចគ្នា លោកនឹងប្រកាន់អ្វីនឹងគ្នា ដូច្នេះ និងដោយការពិចារណាដល់ការមិនមានសត្វ យ៉ាងនេះថា កាលពោលអំពីបរមត្ថ ដែលថា សត្វ ៗ គឺ មិនមាន លោកនឹងប្រកាន់នឹងគ្នាដូចម្ដេចហ្ន៎ ដូច្នេះ ។

ផ្ដើមការដាក់ខ្លួនជាកណ្ដាលក្នុងសង្ខារ ដោយអាការ ២ យ៉ាង គឺ ដោយការពិចារណាដោយភាពជារបស់មិនមានម្ចាស់ យ៉ាងនេះថា ចីវរនេះ នឹងចូលដល់ការផ្លាស់ប្ដូរពណ៌ និងការចាស់គ្រាំគ្រា ជាសំពត់ជូតជើង ត្រូវគ្រឹះចោលដោយចុងឈើប្រទាត់ បើថា ចីវរនោះ គប្បីមានម្ចាស់សោត

គេក៏មិនគប្បីឲ្យវាវិនាសយ៉ាងនេះ ដូច្នេះ និងដោយការពិចារណា ដោយភាពជារបស់អាក្រក់ យ៉ាងនេះថា ចីវរនេះនៅមិនបានយូរ ជារបស់អាក្រក់ដូច្នេះ ។ សូម្បីក្នុងបរិក្ខារ មានបាត្រជាដើម ក៏គប្បីប្រកបសេចក្តីដូចក្នុងចីវរ ។

ក្នុងប្រការថា វៀរបុគ្គលអ្នកប្រកាន់ក្នុងសត្វ និងសង្ខារ មានវិនិច្ឆ័យដូច្នេះ ៖

បុគ្គលណាជាគ្រហស្ថ ក៏ប្រកាន់បិយជន មានបុត្រ ធីតា ជាដើមរបស់ខ្លួន ឬជាបព្វជិត ក៏ប្រកាន់បព្វជិត មានអន្តេវាសិក និងអ្នករួមឧបជ្ឈាយ៍គ្នាជាដើមរបស់ខ្លួន រវល់តែធ្វើកិច្ចកម្ម មានកោរសក់ ដេរចីវរ ជ្រលក់ចីវរ ដុតបាត្រជាដើម របស់ជនទាំងនោះ ដោយដៃរបស់ខ្លួនតែម្តង កាលមិនឃើញត្រឹមតែមួយភ្លែត ក៏រអ៊ូរទាំថា សាមណេររូបឯណោះ ទៅណា ភិក្ខុកម្លោះរូបឯណោះទៅណា ក្រឡេកមើលឆ្វេងស្តាំ ដូចម្រឹគផ្អើល ដូច្នោះ សូម្បីអ្នកដទៃអង្វរសូមថា មេត្តាបញ្ជូនសាមណេរឈ្មោះឯណោះ ទៅជួយកោរសក់ជាដើម ត្រឹមតែមួយភ្លែតចុះ ដូច្នេះ ក៏មិនព្រមឲ្យ ដោយនិយាយថា ពួកយើងនឹងមិនឲ្យធ្វើកិច្ចកម្មរបស់ខ្លួនខ្លះឬ ពួកលោក នាំលោកទៅនឹងលំបាកដូច្នេះ បុគ្គលនេះឈ្មោះថា ប្រកាន់សត្វ ។

ចំណែកបុគ្គលណា ប្រកាន់បរិក្ខារ មានចីវរ បាត្រ ស្បោកបាត្រ ឈើច្រត់ជាដើម សូម្បីអ្នកដទៃនឹងយកដៃចាប់ក៏មិនឲ្យចាប់ សូម្បីសូមខ្ចី ក៏ឆ្លើយជំទាស់ថា យើងត្រូវការប្រើទ្រព្យក៏មិនទាន់ប្រើ នឹងឲ្យពួកលោកបានយ៉ាងណា ដូច្នេះ បុគ្គលនេះឈ្មោះថា ប្រកាន់សង្ខារ ។

ចំណែកបុគ្គលណា ដាក់ខ្លួនជាកណ្តាល ទៀងត្រង់ក្នុងវត្ថុទាំងពីរនោះ បុគ្គលនេះឈ្មោះថា ដាក់ខ្លួនជាកណ្តាល ក្នុងសត្វ និងសង្ខារ ។

កាលវៀរឆ្ងាយបុគ្គលអ្នកប្រកាន់សត្វ និងសង្ខារបែបនេះក្តី គប់រកបុគ្គលអ្នកដាក់ខ្លួនជាកណ្តាលក្នុងសត្វ និងសង្ខារក្តី មានចិត្តបង្អោនទៅដើម្បីឲ្យកើតឧបេក្ខាសម្ពោជ្ឈង្គៈ ក្នុងឥរិយាបថទាំងឡាយ មានឈរ អង្គុយជាដើមក្តី ឧបេក្ខាសម្ពោជ្ឈង្គៈនេះ រមែងកើតបាន ដោយប្រការដូច្នេះ ។ ភិក្ខុរមែងដឹងច្បាស់ថា ក៏ឧបេក្ខាសម្ពោជ្ឈង្គៈនោះ ដែលកើតហើយ ដោយអាការយ៉ាងនេះ រមែងចម្រើនបរិបូណ៌ ដោយអរហត្តមគ្គ ។

ពាក្យថា ឥតិ អជ្ឈត្តំ វា ឬខាងក្នុងជាដើម សេចក្តីថា ពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយ ព្រោះកំណត់សម្ពោជ្ឈង្គៈ ៧ របស់ខ្លួន ឬរបស់អ្នកដទៃ ឬកំណត់សម្ពោជ្ឈង្គៈ ៧ របស់ខ្លួនតាមកាល ឬរបស់អ្នកដទៃតាមកាល ។ ក៏ការកើត និងការសូន្យទៅ ( នៃឧបេក្ខាសម្ពោជ្ឈង្គៈ )

គប្បីជ្រាប ដោយអំណាចការកើត និងការរលត់នៃសម្ពោជ្ឈង្គៈទាំងឡាយ ក្នុងពោជ្ឈង្គបព្វៈនេះ ។ សេចក្តីតពីនេះ ក៏មានន័យដូចពោលមកហើយ ។

## សតិកំណត់ពោជ្ឈង្គ ជាអរិយសច្ច ៤

តែក្នុងពោជ្ឈង្គបព្វៈនេះ មានសេចក្តីផ្សេងគ្នាតែម្យ៉ាង គឺ គប្បីប្រកបសេចក្តីយ៉ាងនេះថា សតិកំណត់ពោជ្ឈង្គៈជាអារម្មណ៍ ជាទុក្ខសច្ច ជាដើម ហើយគប្បីជ្រាបថា ជាផ្លូវបដិបត្តិនាំចេញចាកទុក្ខ របស់ភិក្ខុដែលកំណត់ពោជ្ឈង្គៈជាអារម្មណ៍ ។ ពាក្យដ៏សេសក៏ដូច្នោះដូចគ្នា ។

" ចប់ ពោជ្ឈង្គបព្វៈ "

## សច្ចបព្វៈ

[១៣២] ព្រះមានព្រះភាគ ត្រាស់ចែកធម្មានុបស្សនា ដោយពោជ្ឈង្គៈ ៧ ប្រការ យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់ចែកសច្ចៈ ៤ ប្រការ ទើបត្រាស់ថា បុន ចបរំ ដូច្នេះ ជាដើម ។

## អរិយសច្ច ៤

ក្នុងពាក្យទាំងនោះ ពាក្យថា **ដឹងច្បាស់តាមសេចក្ដីពិតថា នេះទុក្ខជាដើម** សេចក្ដីថា ដឹងច្បាស់តាមសេចក្ដីពិត នូវធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ វៀរតណ្ហាថា នេះទុក្ខ , ដឹងច្បាស់តាមសេចក្ដីពិតនូវតណ្ហា ដែលមានអំពីមុន ដែលធ្វើទុក្ខនោះឯងឲ្យកើត ឲ្យប្រាកដឡើង នេះទុក្ខសមុទ័យ , ដឹងច្បាស់តាមសេចក្ដីពិតនូវសេចក្ដីរលត់ គឺ មិនមានទុក្ខ និងទុក្ខសមុទ័យទាំងពីរថា នេះទុក្ខនិរោធ , ដឹងច្បាស់តាមសេចក្ដីពិតនូវអរិយមគ្គ ដែលជាហេតុកំណត់ដឹងទុក្ខ ជាហេតុលះសមុទ័យ ជាហេតុធ្វើឲ្យច្បាស់និរោធថា នេះទុក្ខនិរោធគាមិនីបដិបទា ។

កថាពោលអំពីសច្ចៈដ៏សេស វៀរកថា ពោលដោយបទភាជនៈចែកបទនៃទុក្ខ មានជាតិជាដើម លោកពោលទុកពិស្ដារក្នុងគម្ពីរវិសុទ្ធិមគ្គ

ហើយ ។

## អធិប្បាយបទភាជន:

## ជាតិ

[១៣៣] ចំណែកក្នុងបទភាជនៈ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ពាក្យថា កតមា ច ភិក្ខវេ ជាតិ ម្នាលភិក្ខុទាំងឡាយ ជាតិតើដូចម្ដេច សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ ក៏ជាតិដូចម្ដេច ដែលតថាគតពោលយ៉ាងនេះថា សូម្បីជាតិក៏ជាទុក្ខ ជាតិនោះ តើដូចម្ដេច ។ គប្បីជ្រាបអត្ថក្នុងបុច្ឆាទាំងពួង យ៉ាងនេះ ។ ពាក្យថា **របស់សត្វទាំងនោះ យ៉ាងណា** ជាពាក្យកំណត់រួមសត្វទុកទាំងអស់ ដោយមិនមានកំណត់ថា របស់ពួកសត្វឈ្មោះនេះ ។ សូម្បីពាក្យថា **ក្នុងពួកសត្វនោះៗ** នេះ ជាពាក្យកំណត់រួមពួកសត្វទុកទាំងអស់ ។ ការកើត ឈ្មោះថា **ជាតិ** ។ ពាក្យថា ជាតិនេះ ជាឈ្មោះរបស់ខន្ធដែលកើតក្នុងគ្រាដំបូង ព្រមដោយការប្រែប្រួល ។ ពាក្យថា **សញ្ជាតិ** នេះ ជាវេវចនៈ (ជំនួស) របស់ជាតិនុ៎ះឯង តែប្រកបដោយឧបសគ្គ ។ ការកើតនុ៎ះឯង ឈ្មោះថា ឱក្កន្តិ ឈានចុះ ដោយអត្ថថា ឈានចុះដោយអាការ ដែលចូលទៅតាមលំដាប់ ។ ឈ្មោះថា អភិនិព្វត្តិ

**កើតចំពោះ** ដោយអត្ថថា កើតដោយចំពោះ ពោលគឺ កើត ៗ ទាំង ៤ យ៉ាងនេះ ឈ្មោះថា ពោលដោយសម្មតិ ។ ចំណែកបាលី ខន្ធានំ ចាតុភាវោ **ការប្រាកដនៃខន្ធទាំងឡាយ** នេះ ពោលដោយបរមត្ថ ។ ការប្រាកដនៃខន្ធទាំងឡាយនុ៎ះឯង ដែលចែកជាខន្ធមួយ ខន្ធបួន និងខន្ធប្រាំ ក្នុងបណ្ដាពួកសត្វដែលមានខន្ធមួយជាដើម នុ៎ះឯង មិនមែនការប្រាកដនៃបុគ្គល ។ តែកាលការប្រាកដនៃខន្ធនោះមាន ។ ក៏សម្មតិហៅថា បុគ្គលប្រាកដដូច្នេះ ពាក្យថា អាយតនានំ បដិលាភោ **ការបានអាយតនៈទាំងឡាយ** សេចក្ដីថា អាយតនៈទាំងឡាយប្រាកដនុ៎ះឯង ដែលឈ្មោះថា បានមក នោះឈ្មោះថា ការបានមក ដែលពោលបានថា ការប្រាកដនៃអាយតនៈទាំងនោះ ។

## ជរា

សព្ទថា **ជរា** ជាសព្ទសម្ដែងដល់សភាពខ្លួនឯង ។ សព្ទថា ជីរណតា សម្ដែងដល់ភារៈ គឺ អាការ ។ សព្ទថា ខណ្ឌិច្ចំ ជាដើម គឺ សម្ដែងដល់ការៈផ្លាស់ប្ដូរ ពិតណាស់ វេលាជាកម្លោះក្រមុំ ធ្មេញក៏ស ភាពស្មើ ៗ គ្រាចាស់គ្រាំគ្រា ធ្មេញទាំងនោះ ក៏ផ្លាស់ពណ៌ទៅដោយ

លំដាប់ រន្ធើ បាក់ធ្លាក់ទៅក្នុងទីនោះ ៗ ។ មួយទៀត ធ្មេញបាក់ សំដៅដល់ធ្មេញដែលរបូតឫស ចាកទីនៅ ឈ្មោះថា ខណ្ឌិតា ។ ភាវៈនៃធ្មេញដែលបាក់ ហៅថា ខណ្ឌិច្ចំ ។

សក់ និងរោម គ្រាំគ្រាទៅដោយលំដាប់ ឈ្មោះថា សក់ស្កូវ ។ សក់ស្កូវកើតព្រមហើយដល់បុគ្គលនោះ ហេតុនោះ បុគ្គលនោះ ឈ្មោះថា មានសក់ស្កូវ ។ ភាវៈនៃបុគ្គលអ្នកមានសក់ស្កូវ ឈ្មោះថា ផាលិច្ចំ **ប្រការដែលសក់ស្កូវ** ។ សភាពជ្រីវជ្រួញ ត្រង់ស្បែករបស់បុគ្គលនោះ មានប្រាកដ ព្រោះមានសាច់ និងឈាម ស្ងួតទៅដោយត្រូវខ្យល់ គឺ ជរាប្រហារ ហេតុនោះ បុគ្គលនោះ ឈ្មោះថា មានស្បែកជ្រីវជ្រួញ ( ស្វិត ) ។ ភាវៈនៃបុគ្គលមានស្បែកជ្រីវជ្រួញនោះ ឈ្មោះថា វលិត្តចតា **សភាពនៃស្បែកស្វិត** ។ ដោយពាក្យមានប្រមាណត្រឹមប៉ុណ្ណេះ ដែលព្រះមានព្រះភាគទ្រង់សម្តែងថា ជរា គឺ ទ្រង់ត្រាស់បង្ហាញឲ្យប្រាកដច្បាស់ ដោយសម្តែងការផ្លាស់ប្តូរក្នុងធ្មេញ សក់ រោម ស្បែក ។ ផ្លូវទៅរបស់ខ្យល់ ឬភ្លើង នឹងប្រាកដបាន ក៏ព្រោះខ្យល់បក់ត្រូវស្មៅ ឬដើមឈើជាដើម បាក់បែករន្ធោះរន្ធើ ឬភ្លើងឆេះ តែផ្លូវទៅរបស់ខ្យល់ និងភ្លើងនោះ ក៏មិនប្រាកដយ៉ាងណា ផ្លូវទៅនៃជរាក៏ដូច្នោះដែរ នឹងប្រាកដបាន ក៏ដោយភាវៈ មាន

ធ្មេញបាក់ជាដើម នៃអាការ ៣២ មានធ្មេញជាដើម សូម្បីបុគ្គលបើកភ្នែកមើលក៏ចាប់មិនបាន ការគ្រាំគ្រានៃអាការ មានធ្មេញបាក់ជាដើម មិនមែនតួជរាទេ ព្រោះជរានឹងគប្បីដឹងផ្លូវចក្ខុមិនបាន ។ តែព្រោះកាលដល់ជរាអាយុសាបសូន្យទៅដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ដោយផលជិតថា សេចក្តីសាបសូន្យទៅនៃអាយុ ហៅថា **ជរា** ។ មួយទៀត ព្រោះវេលានៅជាកម្លោះក្រមុំ ឥន្ទ្រិយទាំងឡាយ មានចក្ខុជាដើម ស្រស់ថ្លាល្អ អាចទទួលអារម្មណ៍របស់ខ្លួនសូម្បីដែលល្អិតតូចបានដោយងាយ កាលដល់ជរា ក៏ដល់ភាពទ្រុឌទ្រោម កករល្អក់ មិនថ្លាផូរផង់ មិនអាចទទួលអារម្មណ៍របស់ខ្លួនសូម្បីដែលគ្រោតគ្រាតបាន ដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ដោយផលជិតថា ការដល់ភាពទ្រុឌទ្រោមនៃឥន្ទ្រិយទាំងឡាយ ហៅថា **ជរា** ដូច្នេះខ្លះ ។

## មរណៈ

ក្នុងមរណនិទ្ទេស មានវិនិច្ឆ័យដូចតទៅនេះ ៖

សព្ទថា យំ សំដៅដល់ មរណៈ ជាសព្ទសម្តែងនបុំសកលិង្គ (មិនមែនភេទប្រុសភេទស្រី ផ្នែកវេយ្យាករណ៍) ។ ក្នុងពាក្យថា យំ នោះគប្បីប្រកបសេចក្តីដូច្នេះថា មរណៈ លោកហៅថា **ចុតិ** ហៅថា **ចវនតា** ។

ក្នុងសព្ទទាំងនោះ សព្ទថា ចុតិ សម្តែងដល់សភាវៈខ្លួនឯង ។ សព្ទថា ចវនតា សម្តែងដល់ភាវៈ គឺ អាការ ។ កាលបុគ្គលដល់មរណៈហើយ ខន្ធទាំងឡាយរមែងបែក និងបាត់ទៅឯងមិនឃើញ ព្រោះដូច្នោះ មរណៈនោះ ទើបហៅថា ការបែកធ្លាយ ការបាត់ទៅ សេចក្តីស្លាប់ ។ បទថា មច្ចុ មរណំ គឺ មច្ចុមរណៈ មិនមែនខណិកមរណៈ (ស្លាប់មួយខណៈៗ) ។ ការធ្វើកាលៈ គឺ ស្លាប់ ឈ្មោះថា **កាលកិរិយា** ។ សម្បីទាំងអស់នេះ ពោលដោយសម្មតិនោះឯង ។ ចំណែកបាលីថា **ខន្ធានំ** ភេទោ នេះ ជាការពោលដោយបរមត្ថ ។ ការបែកធ្លាយនៃខន្ធទាំងឡាយ ដែលចែកជាខន្ធ ១ ខន្ធ ៤ និងខន្ធ ៥ ក្នុងបណ្តាពួកសត្វ ដែលមានខន្ធមួយជាដើម នុ៎ះឯង មិនមែនការបែកធ្លាយនៃបុគ្គល ។ តែកាលការប្រជុំព្រមនៃខន្ធមានហើយ ក៏សម្មតិហៅថា បុគ្គលស្លាប់ ។ ការលះបង់អត្តភាព ឈ្មោះថា ការលះបង់សាកសព ។ ពិតហើយ កាលបុគ្គលដល់សេចក្តីស្លាប់ អត្តភាពក៏ធ្លាក់ចុះដូចជាកំណាត់ឈើ គ្មានប្រយោជន៍ ដូច្នោះ ព្រោះដូច្នោះ មរណៈនោះ លោកទើបហៅថា **ការលះបង់សាកសព** ។ ចំណែកការដាច់នៃជីវិតិន្ទ្រិយ កាលពោលដោយបរមត្ថ ដោយអាការទាំងពួង ក៏គឺ មរណៈ ។ មរណៈនោះឯង ហៅថា សម្មតិមរណៈ ។ មនុស្សលោកកាន់យកការដាច់

នៃជីវិតិន្ទ្រិយប៉ុណ្ណោះ ទើបនិយាយថា តិស្សៈស្លាប់ ផុស្សៈស្លាប់ ដូច្នេះ ។

សោកៈ

បទថា ញាតិព្យសនេន **ដោយសេចក្ដីវិនាស** សេចក្ដីថា ដោយសេចក្ដីវិនាសយ៉ាងណាមួយ បណ្ដាសេចក្ដីវិនាសទាំងឡាយ មានសេចក្ដីវិនាសញាតិជាដើម ។ បទថា ទុក្ខធម្មេន **ទុក្ខធម៌** សេចក្ដីថា ហេតុនៃទុក្ខ មានការសម្លាប់ និងឃុំឃាំងដើម ។ បទថា ផុដ្ឋស្ស **ពាល់ត្រូវហើយ** បានដល់ ប៉ះខ្ទប់ហើយ គ្របសង្កត់ហើយ ។ ពាក្យថា **សោក** បានដល់ សេចក្ដីសោក ដែលមានសេចក្ដីក្រៀមក្រំចិត្ត ជាលក្ខណៈ រមែងកើតដល់បុគ្គលក្នុងកាលត្រូវសេចក្ដីវិនាស មានការវិនាសចាកញាតិជាដើម ឬហេតុនៃទុក្ខ មានការសម្លាប់ ការឃុំឃាំងជាដើមណាមួយ គ្របសង្កត់ហើយ ។ ភាពជាអ្នកសោកសៅ បានដល់ សេចក្ដីសោកសៅ ។ ក៏សេចក្ដីសោក-សៅនោះ កើតឡើងធ្វើខាងក្នុងឲ្យរីងស្ងួត ឲ្យក្រៀមស្វិត ព្រោះដូច្នោះទើបហៅថា **សេចក្ដីរីងស្ងួតចិត្ត សេចក្ដីក្រៀមក្រំចិត្ត** ដូច្នេះ ។

បរិទេវៈ

ជនទាំងឡាយ ប្រកាន់យ៉ាងនេះថា កូនស្រីរបស់យើង កូនប្រុស

*របស់យើង ដូច្នេះ រមែងទូញយំរៀបរាប់ ដោយសេចក្តីប្រកាន់នោះ ហេតុនោះ សេចក្តីប្រកាន់នោះ ទើបឈ្មោះថា **ជាហេតុយំរៀបរាប់** ។ ជនទាំងឡាយ យំរៀបរាប់ពីគុណនោះ ៗ ដោយហេតុនោះ ព្រោះដូច្នោះ ហេតុនោះ ទើបឈ្មោះថា **ជាហេតុយំរៀបរាប់** ។ សព្ទទាំងពីរ ( អាទេវនា បរិទេវនា ) ក្រៅពីអាទេវៈ បរិទេវៈនោះ ជាសព្ទសម្តែងភាវៈនៃសេចក្តីទូញយំរៀបរាប់ នោះឯង ។*

## ទុក្ខ ទោមនស្ស

*សេចក្តីទុក្ខ ដែលមានកាយបសាទជាទីតាំង (ទីកើត) ព្រោះអត្ថថាទ្រាំបានលំបាក ឈ្មោះថា **សេចក្តីលំបាកកាយ** ។ ពាក្យថា **មិនសប្បាយចិត្ត** គឺ មិនរីករាយចិត្ត ។ ពាក្យថា **ទុក្ខកើតពីកាយសម្ផស្ស** គឺ ទុក្ខដែលកើតពីសម្ផស្សផ្លូវកាយ ។ ពាក្យថា **វេទនាដែលមិនគួរសប្បាយចិត្ត** គឺ វេទនា ដែលមិនគួរពេញចិត្ត ។ ទោមនស្សសម្បយុត្តនឹងចិត្ត ឈ្មោះថា ចេតសិក បានដល់ ទោមនស្សផ្លូវចិត្ត ។ ពាក្យដ៏សេសមានន័យដូចពោលមកហើយ ក្នុងទុក្ខនុ៎ះឯង ។*

## ឧបាយាសៈ

*បទថា អាយាសោ បានដល់ សេចក្តីលំបាកផ្លូវចិត្ត ដែលដល់អាការ គឺ ស្រងាកចិត្ត ខ្វាចចិត្ត ។ សេចក្តីចង្អៀតចិត្ត ដោយភាវៈមាន*

កម្លាំង ឈ្មោះថា **សេចក្តីចង្អៀតចង្អល់ចិត្ត** ។ សព្ទទាំងពីរ ( អាយាសិត្តត្តំ ឧបាយាសិត្តំ ) ក្រៅពីអាយាសៈ និងឧបាយាសៈនោះ ជាធម៌ជាប់នៅក្នុងខ្លួន បំភ្លឺការៈ ចង្អុលការៈ ។

## ការមិនបានតាមសេចក្តីប្រាថ្នាជាទុក្ខ

បទថា ជាតិធម្មានំ **មានការកើតជាធម្មតា** គឺ មានការកើតជាសភាវៈ ។ ពីរបទថា ឥច្ឆា ឧប្បជ្ជតិ **សេចក្តីប្រាថ្នារមែងកើត** គឺ តណ្ហារមែងកើត ។ ពាក្យថា អហោ វត បានដល់ សេចក្តីប្រាថ្នា ។ បទថា ន ខោ បនេតំ ឥច្ឆាយ **សេចក្តីនោះ មិនគប្បីបានដោយការប្រាថ្នានោះឯង** សេចក្តីថា សេចក្តីនោះ គឺ ការមិនត្រូវមកកើត វៀរមគ្គភាវនាចេញ បុគ្គលមិនគប្បីសម្រេចបានតាមប្រាថ្នា ។ ពាក្យថា ឥទំបិ **សូម្បីនោះ** គឺ សូម្បីយ៉ាងនេះ ។ **បិ** អក្សរ ក្នុងពាក្យថា **ឥទម្បិ** សំដៅដល់បទដ៏សេសខាងមុខ ។ បទថា យម្បិច្ឆំ **សេចក្តីប្រាថ្នាណា** សេចក្តីថា បុគ្គលប្រាថ្នាវត្ថុដែលមិនគប្បីបាន រមែងមិនបាន ព្រោះធម៌ណា សេចក្តីប្រាថ្នាក្នុងវត្ថុដែលមិនគប្បីបាននោះ ក៏ជាទុក្ខ ។ គ្រប់ៗ បទ ក៏ន័យនេះដូចគ្នា ។ ក្នុងខន្ធនិទ្ទេសមានវិនិច្ឆ័យដូច្នេះ ។ រូបនោះផង ឧបាទានក្ខន្ធផង ព្រោះហេតុ

នោះ ទើបឈ្មោះថា រូបូបាទានក្ខន្ធ ។ គ្រប់ៗ ខន្ធ ក៏គប្បីជ្រាបយ៉ាងនេះ ។

## សមុទយអរិយសច្ចៈ

[១៣៤] ពាក្យថា យាយំ តណ្ហា កាត់ជា យា អយំ តណ្ហា ប្រែថា **តណ្ហានេះណា** ។ ពាក្យថា ពោនោព្ភវិកា មានវិគ្រោះថា ការធ្វើភពថ្មី ឈ្មោះថា ភពថ្មី , ភពថ្មីនោះ ជាប្រក្រតីនៃតណ្ហានោះ ហេតុនោះ តណ្ហានោះ ទើបឈ្មោះថា ពោនោព្ភវិកា **មានការកើតទៀតជាប្រក្រតី** ។ ពាក្យថា នន្ទិរាគសហគតា បានដល់ តណ្ហាដែលកើតរួមដោយតម្រេក ដោយអំណាចសេចក្ដីត្រេកត្រអាល ។ លោកអធិប្បាយថា ដោយអត្ថ តណ្ហានោះ ក៏ដូចគ្នានឹងនន្ទិរាគៈនុ៎ះឯង ។ ក្នុងពាក្យទាំងនោះ ពាក្យថា តត្រ-តត្រាភិនន្ទិនី **សេចក្ដីត្រេកត្រអាលក្នុងអារម្មណ៍នោះ ៗ** សេចក្ដីថា អត្តភាពកើតឡើងក្នុងទីណា ៗ តណ្ហា ក៏ត្រេកត្រអាលក្នុងទីនោះ ៗ ។ ន័យមួយទៀត តណ្ហាតែងតែត្រេកត្រអាលក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើម ឈ្មោះថា ក្នុងទីនោះ ៗ ។ អធិប្បាយថា ត្រេកត្រអាលក្នុងរូប ត្រេកត្រអាលក្នុងសំឡេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍ ។ សព្ទថា សេយ្យថីទំ ជានិបាតសព្ទ ។ សព្ទថា សេយ្យថីទំ នោះ មានសេចក្ដីថា បើមានពាក្យ

សួរថា តណ្ហានោះ តើដូចម្តេច ? ។ ចំណង់ក្នុងកាម ឈ្មោះថា **កាម-តណ្ហា** ។ ពាក្យថា កាមតណ្ហានោះ ជាឈ្មោះ នៃតម្រេកជាប់ដោយកាមគុណ ៥ ។ ចំណង់ក្នុងភព ឈ្មោះថា **ភវតណ្ហា** ។ ពាក្យថា ភវ-តណ្ហានេះ ជាឈ្មោះរបស់តម្រេកក្នុងរូបភព និងអរូបភព ដែលកើតព្រមដោយសស្សតទិដ្ឋិ ដែលកើតដោយសេចក្តីប្រាថ្នាភព និងសេចក្តីត្រេកអរក្នុងឈាន ។ ចំណង់ក្នុងវិភវៈ ឈ្មោះថា **វិភវតណ្ហា** ។ ពាក្យថា វិភវតណ្ហានេះ ជាឈ្មោះរបស់តម្រេក ដែលកើតព្រមដោយ ឧច្ឆេទទិដ្ឋិ ។

[១៣៥] ឥឡូវនេះ ព្រះមានព្រះភាគដើម្បីនឹងទ្រង់សម្តែងវត្ថុជាទីតាំងពីកើតនៃតណ្ហានោះដោយពិស្តារ ទើបត្រាស់ថា សា ខោ បនេសា **ក៏តណ្ហានោះឯង** ដូច្នេះ ជាដើម ។

បណ្តាពាក្យទាំងនោះ ពាក្យថា ឧប្បជ្ជតិ ប្រែថា **កើត** ។ ពាក្យថា និវិសតិ បានដល់ តាំងនៅដោយការប្រព្រឹត្តទៅរឿយ ៗ ។ ពាក្យថា យំ លោកេ បិយរូបំ សាតរូបំ សេចក្តីថា សភាវៈជាទីស្រឡាញ់ និងសភាវៈដែលពេញចិត្តក្នុងលោក ។ ក្នុងពាក្យថា ចក្ខុំ លោកេ ជាដើម មានអធិប្បាយដូច្នេះ ពិតហើយ សត្វទាំងឡាយ ប្រកាន់មាំក្នុងចក្ខុជាដើម ក្នុងលោកដោយសេចក្តីជារបស់យើង តាំងមាំនៅក្នុងសម្បត្តិ រមែងសម្គាល់

ចក្ខុ (ភ្នែក) របស់ខ្លួន ដែលមានបសាទទាំង ៥ ស្រស់ថ្លា ដូចមុខផ្សេងៗ នៃកែវមណី ដែលផ្សាយឡើងហើយក្នុងវិមានមាស ដោយទំនងកាន់យកនិមិត្តក្នុងកញ្ចក់ជាដើម រមែងសម្គាល់សោតៈ (ត្រចៀក) ដូចបំពង់ឡូតប្រាក់ និងដូចដោយខ្សែសង្វារ រមែងសម្គាល់ឃានៈ (ច្រមុះ) ដែលបានវោហារហៅថា តុង្គនាសា (ច្រមុះស្រួច) ដូចទងហរិតាល ដែលគេពួតតាំងទុក រមែងសម្គាល់ជិវ្ហា (អណ្ដាត) ដែលទន់ស្អាតចាំទទួលរសឆ្ងាញ់ ដូចផ្ទាំងសម្ពត់កម្ពលក្រហម រមែងសម្គាល់កាយ ដូចដើមសាលៈជំទង់ និងដូចសរសរមាស រមែងសម្គាល់មនៈ (ចិត្ត) ដ៏ឧឡារ (របស់ខ្លួន) មិនដូចគ្នានឹងចិត្តរបស់អ្នកដទៃ ៗ រមែងសម្គាល់រូប ដូចជាពណ៌សម្បុរផ្កាកណ្ណិការមាសជាដើម រមែងសម្គាល់សំឡេង ដូចជាសំឡេងសត្វការៈវេកនិងតាវៅ ដែលគួរស្ដាប់ និងសំឡេងរំពងរបស់ប៉ីកែវដែលផ្លុំឡើង រមែងសម្គាល់អារម្មណ៍ មានគន្ធារម្មណ៍ (ក្រអូប) ជាដើម ដែលមានសមុដ្ឋាន ៤ ដែលខ្លួនបានហើយថា អារម្មណ៍បែបនេះ របស់អ្នកដទៃណាហ្ន៎ នឹងមាន ។ កាលសត្វទាំងនោះ សម្គាល់ហើយយ៉ាងនេះ ចក្ខុជាដើមទាំងនោះ ក៏រមែងជាទីស្រឡាញ់ ជាទីរីករាយ ។ កាលបើដូច្នោះ តណ្ហារបស់សត្វទាំងនោះ ដែលនៅមិនទាន់កើត ក៏រមែងកើតក្នុងចក្ខុជាដើមនោះ និង

តណ្ហាដែលកើតហើយ ក៏រមែងតាំងនៅដោយការប្រព្រឹត្តទៅរឿយៗ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ថា ៖

**ចក្ខុជាទីស្រឡាញ់ ជាទីពេញចិត្ត ក្នុងលោក , តណ្ហានោះ កាលនឹងកើតឡើង ក៏កើតឡើងក្នុងចក្ខុនោះ ដូច្នេះជាដើម ។**

ពាក្យថា ឥត្ថ ឧប្បជ្ជមានា ឧប្បជ្ជតិ សេចក្តីថា តណ្ហានោះ កាលកើតក្នុងកាលណា ក៏រមែងកើតត្រង់ចក្ខុនេះ ក្នុងកាលនោះ ។ គ្រប់ៗ បទក៏ន័យនេះ ។

## ទុក្ខនិរោធអរិយសច្ចៈ

[១៣៦] បទទាំងពួង មានបទថា អសេសវិរាគនិរោធោ **ការរលត់ដោយមិនមានសេសសល់** ជាដើម ទាំងអស់ ជាវេវចនៈរបស់ព្រះនិព្វានទាំងឯង ។ ពិតណាស់ តណ្ហាមកដល់ព្រះនិព្វាន រមែងកម្ចាត់ រលត់មិននៅសល់ ព្រោះដូច្នោះ ព្រះនិព្វាននោះ ទើបត្រាស់ហៅថា ការរលត់ដោយកម្ចាត់មិននៅសល់នៃតណ្ហានោះឯង ។ មួយទៀត តណ្ហាមកដល់ព្រះនិព្វាន រមែងលះ លះបង់ បន្សាត់ មិនជាប់ ព្រោះដូច្នោះ ព្រះនិព្វាន

ទើបត្រាស់ហៅថា លះ លះបង់ បន្សាត់ មិនជាប់ ។ ពិតណាស់ព្រះនិព្វាន ក៏មានតែម្យ៉ាងប៉ុណ្ណោះ ។ តែឈ្មោះរបស់ព្រះនិព្វាននោះ មានច្រើន ដោយបដិបក្ខចំពោះឈ្មោះរបស់សង្ខតធម៌ទាំងអស់ ។ គឺយ៉ាងណា គឺ ធម៌ដែលគ្រោតគ្រាតមិននៅសល់ ជាទីរលត់មិននៅសល់ ជាទីលះ ជាទីលះបង់ ជាទីផុត ជាទីមិនជាប់ ជាទីអស់រាគៈ ជាទីអស់ទោសៈ ជាទីអស់មោហៈ ជាទីអស់តណ្ហា ជាទីមិនកើត ជាទីឈប់ មិនមាននិមិត្ត មិនមានទីតាំង មិនមានទីអាស្រ័យ មិនមានបដិសន្ធិ មិនប្រព្រឹត្តទៅ មិនទៅ មិនកើត មិនចាស់ មិនឈឺ មិនស្លាប់ មិនសោក មិនយំរៀបរាប់ មិនចង្អៀតចង្អល់ មិនសៅហ្មង ដូច្នេះជាដើម ។ ឥឡូវនេះ ព្រះមាន-ព្រះភាគ ដើម្បីនឹងទ្រង់សម្តែងការមិនមាននៃតណ្ហាទាំងពួង ដែលមគ្គលះបានហើយ ទើបបញ្ឈប់ ( មិនប្រព្រឹត្តទៅ ) ព្រោះមកដល់ព្រះនិព្វាន ក្នុងវត្ថុដែលព្រះអង្គទ្រង់សម្តែងថា តណ្ហាកើតនុះឯង ទើបត្រាស់ថា សា ខោ បនេសា **ក៏តណ្ហានេះ** ដូច្នេះ ជាដើម ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យនោះ ដូចតទៅនេះ ឧបមាថា បុរសជួបវល្លិ៍បណ្តូលពេជ្រ ដែលកើតក្នុងស្រែហើយ ចាប់ស្រាវពីចុង ស្វែងរកគល់ជួបហើយ កាត់ចេញ វល្លិ៍នោះក៏ស្ងួតទៅដោយលំដាប់ ដល់ភាព

មិនប្រាកដ ពេលនោះ គេក៏ហៅថា វល្លិ៍បណ្តូលពេជ្រក្នុងស្រែនោះ រលត់ហើយ លះហើយ តណ្ហាក្នុងចក្ខុជាដើម ប្រៀបដូចវល្លិ៍បណ្តូលពេជ្រក្នុងស្រែ តណ្ហានោះ កាត់ឫសបានដោយអរហត្តមគ្គ ដល់នូវការឈប់ ( ដុះ ) ព្រោះមកដល់ព្រះនិព្វាន ម្យ៉ាងទៀត តណ្ហាដែលដល់ការឈប់យ៉ាងនោះហើយ រមែងមិនប្រាកដក្នុងវត្ថុទាំងនោះ ដូចវល្លិ៍បណ្តូលពេជ្រ មិនប្រាកដក្នុងស្រែ ដូច្នោះ ។ មួយទៀត ប្រៀបដូចពួកមនុស្សនាំចោរមកពីព្រៃ គប្បីសម្លាប់ត្រង់ទ្វារទិសខាងត្បូងនៃព្រះនគរ តពីនោះ មនុស្សទាំងឡាយនឹងគប្បីនិយាយគ្នាថា ពួកចោរក្នុងព្រៃស្លាប់ហើយ ឬត្រូវសម្លាប់ស្លាប់ហើយដូច្នេះ យ៉ាងណា ក៏ដូច្នោះដូចគ្នា តណ្ហាក្នុងចក្ខុជាដើម ប្រៀបដូចចោរក្នុងព្រៃ តណ្ហានោះ ឈ្មោះថា រលត់ទៅក្នុងព្រះនិព្វានទុំះឯង ព្រោះមកដល់ព្រះនិព្វានហើយ ទើបរលត់ទៅ ដូចចោរត្រូវសម្លាប់ត្រង់ទ្វារទិសខាងត្បូង ដូច្នោះ មួយទៀត តណ្ហាដែលរលត់ហើយយ៉ាងនោះ រមែងមិនប្រាកដក្នុងវត្ថុទាំងនោះ ដូចចោរមិនប្រាកដក្នុងព្រៃដូច្នោះ ។ ព្រោះដូច្នោះព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងការរលត់នៃតណ្ហានោះ ក្នុងចក្ខុជាដើមនោះ ទើបត្រាស់ថា ចក្ខុជាទីស្រឡាញ់ ជាទីរីករាយក្នុងលោក តណ្ហានោះ កាលបុគ្គលនឹងលះ ក៏លះបានក្នុងចក្ខុនោះ កាលនឹងរលត់ ក៏រលត់

ក្នុងចក្ខុនោះ ដូច្នេះជាដើម ។

## ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ

[១៣៧] ពាក្យថា អយមេវ ជាពាក្យកំណត់ពិត ដើម្បីបដិសេធមគ្គដទៃ ។ ពាក្យថា អរិយោ សេចក្ដីថា មគ្គ ឈ្មោះថា អរិយៈ ព្រោះឆ្ងាយចាកកិលេសទាំងឡាយ ដែលមគ្គនោះ ៗ គប្បីសម្លាប់ និងព្រោះធ្វើភាពជាព្រះអរិយៈ ។ ទ្រង់សម្ដែងកម្មដ្ឋានពោលដោយសច្ចៈ ៤ ដោយពាក្យថា ជីងក្នុងទុក្ខជាដើម ។ ក្នុងសច្ចៈ ៤ នោះ , សច្ចៈ ២ ខាងដើម ( ទុក្ខ និងសមុទ័យ ) ជាវដ្ដសច្ចៈ , សច្ចៈ ២ ខាងចុង ( និរោធ និងមគ្គ ) ជាវិវដ្ដសច្ចៈ ។ ក្នុងវដ្ដសច្ចៈ និងវិវដ្ដសច្ចៈទាំងនោះ ការតាំងមាំនៃកម្មដ្ឋានរបស់ភិក្ខុ រមែងមានក្នុងវដ្ដសច្ចៈ មិនមានក្នុងវិវដ្ដសច្ចៈ ។ ព្រះយោគាវចរកំណត់សច្ចៈ ២ ខាងដើម ក្នុងសម្នាក់អាចារ្យដោយសង្ខេប យ៉ាងនេះថា បញ្ចក្ខន្ធជាទុក្ខ តណ្ហាជាសមុទ័យ និងពិស្ដារដោយន័យជាដើមថា បញ្ចក្ខន្ធដូចម្ដេច ? គឺ រូបក្ខន្ធ ដូច្នេះហើយ ស្វាធ្យាយ ( ទន្ទេញ ) ឈ្មោះថាធ្វើកម្មក្នុងសច្ចៈ ២ ទាំងនោះ ។ ចំណែកក្នុងសច្ចៈ ២ ក្រៅពីនេះព្រះយោគាវចររមែងធ្វើកម្ម ដោយការស្ដាប់តែម្យ៉ាង យ៉ាងនេះថា និរោធ-

សច្ច គួរប្រាថ្នា គួរពេញចិត្ត , មគ្គសច្ច គួរប្រាថ្នា គួរពេញចិត្ត ។ ព្រះយោគាវចរនោះ កាលធ្វើយ៉ាងនេះ រមែងចាក់ធ្លុះសច្ចៈទាំង ៤ ដោយបដិវេធញ្ញាណតែម្យ៉ាង រមែងត្រាស់ដឹងដោយអភិសមយញ្ញាណតែម្យ៉ាង គឺ ចាក់ធ្លុះទុក្ខ ដោយបដិវេធ គឺ បរិញ្ញាកិច្ច ចាក់ធ្លុះសមុទ័យ ដោយបហានកិច្ច ចាក់ធ្លុះនិរោធសច្ចៈ ដោយសច្ឆិកិរិយាកិច្ច ចាក់ធ្លុះមគ្គសច្ចៈ ដោយភាវនាកិច្ច ។ រមែងត្រាស់ដឹងទុក្ខសច្ចៈ ដោយអភិសមយញ្ញាណ គឺ បរិញ្ញាកិច្ច ត្រាស់ដឹងសមុទ័យសច្ចៈ ដោយបហានកិច្ច ត្រាស់ដឹងនិរោធ-សច្ចៈ ដោយសច្ឆិកិរិយាកិច្ច ត្រាស់ដឹងមគ្គសច្ចៈ ដោយភាវនាកិច្ច ។ ក្នុងខាងដើម ព្រះយោគាវចរនោះ មានបដិវេធញ្ញាណក្នុងសច្ចៈ ២ ខាងដើម ដោយការកំណត់ ការសាកសួរ ការស្តាប់ ការទ្រទ្រង់ចាំ និងការពិចារណា ចំណែកក្នុងសច្ចៈ ២ ខាងចុង ព្រះយោគាវចរ មានបដិវេធញ្ញាណ ដោយអំណាចការស្តាប់តែម្យ៉ាង ក្នុងខាងក្រោយ ទើបមានបដិវេធញ្ញាណក្នុងសច្ចៈ ៣ ដោយកិច្ច មានបដិវេធញ្ញាណ ក្នុងនិរោធសច្ចៈ ដោយអារម្មណ៍ ។ ចំណែកបច្ចវេក្ខណញ្ញាណ មានដល់ព្រះយោគាវចរអ្នកសម្រេចសច្ចៈហើយ ។ ព្រះយោគាវចរនេះ ជាអ្នកផ្តើមបំពេញសេចក្តីព្យាយាម ព្រោះដូច្នោះ ទើបមិនត្រាស់បច្ចវេក្ខណញ្ញាណនោះ ទុក

ក្នុងទីនេះ ។ មួយទៀត កាលភិក្ខុនេះកំណត់ដឹងក្នុងខាងដើម សេចក្តីរំពឹងរូបរួមចិត្ត ធ្វើទុកក្នុងចិត្ត និងពិចារណាថា យើងកំណត់ដឹងទុក្ខ យើងលះសមុទ័យ យើងធ្វើឲ្យច្បាស់និរោធ យើងចម្រើនមគ្គ ដូច្នេះ មិនទាន់មាននឹងមានបានតាំងពីការកំណត់ទៅ ។ ចំណែកក្នុងវេលាខាងក្រោយ ទុក្ខក៏បានឈ្មោះថា កំណត់ដឹងហើយ សមុទ័យក៏ជាការលះចេញហើយ និរោធក៏ជាការធ្វើឲ្យច្បាស់ហើយ មគ្គក៏ជាការធ្វើឲ្យកើតហើយ ។

ក្នុងសច្ចៈទាំងនោះ សច្ចៈ ២ ខាងដើម ឈ្មោះថា ជ្រាលជ្រៅព្រោះឃើញបានលំបាក , សច្ចៈ ២ ខាងចុង ឈ្មោះថា ឃើញបានលំបាកព្រោះជ្រាលជ្រៅ ។ សេចក្តីពិត ទុក្ខសច្ចៈ ប្រាកដតាំងពីកើតមក សូម្បីនឹងពោលគ្នាថា ទុក្ខហ្ន៎ ក្នុងវេលាដែលប៉ះដង្គត់ និងបន្ទាមុតជាដើម ។ សូម្បីសមុទយសច្ចៈ ក៏ប្រាកដតាំងពីកើតមក ដោយអំណាចចង់ទំពារចង់ស៊ីជាដើម ។ តែសូម្បីសច្ចៈទាំងពីរនោះ ក៏ឈ្មោះថា ជ្រាលជ្រៅដោយលក្ខណៈ និងការចាក់ធ្លុះ ។ សច្ចៈ ២ នោះ ឈ្មោះថា ជ្រាលជ្រៅព្រោះឃើញបានលំបាក ដោយប្រការដូច្នេះ ។ ចំណែកសេចក្តីព្យាយាមដើម្បីឃើញសច្ចៈ ២ ក្រៅពីនេះ ដូចជាលូកដៃចាប់ភវគ្គព្រហ្ម ឈានជើងទៅប៉ះអវិចីនរក និងដូចយកចុងរោមទ្រាយ នឹងចុងរោមទ្រាយ ដែលចែក

ចេញ ៧ ចំណែកមកតជាប់គ្នា ។ សច្ចៈ ២ ខាងចុងទាំងនោះ ឈ្មោះថា ឃើញបានលំបាក ព្រោះជ្រាលជ្រៅ ដោយប្រការដូច្នេះ ។ ព្រះមានព្រះភាគ ត្រាស់ថា នេះសេចក្តីដឹងក្នុងទុក្ខ ដូច្នេះជាដើម ទ្រង់សំដៅដល់ការកើត ញាណដែលជាចំណែកខាងដើម ក្នុងសច្ចៈ ៤ ដែលឈ្មោះថា ជ្រាលជ្រៅ ព្រោះឃើញបានលំបាក និងដែលឈ្មោះថា ឃើញបានលំបាក ព្រោះ ជ្រាលជ្រៅ ដោយអំណាចការកំណត់ជាដើម ដោយប្រការដូច្នេះ ។ ចំណែក ក្នុងខណៈចាក់ធ្លុះ ញាណ (បដិវេធញ្ញាណ) នោះ ក៏មានតែមួយប៉ុណ្ណោះ ។

## សម្មាសង្កប្ប

ការត្រិះរិះ មានការត្រិះរិះចេញចាកកាមជាដើម ផ្សេងគ្នាក្នុងខាង ដើម ព្រោះសញ្ញាក្នុងការវៀរចាកកាម ព្យាបាទ និងវិហិង្សាផ្សេងគ្នា ។ តែក្នុងខណៈនៃមគ្គ ការត្រិះរិះជាចំណែកកុសលតែមួយប៉ុណ្ណោះ កើត ឡើងឲ្យអង្គមគ្គបរិបូណ៌ ដោយសម្រេចការមិនកើតនៃការត្រិះរិះចំណែក អកុសល ដែលកើតហើយក្នុងឋានៈ ៣ ទាំងនេះ ព្រោះកម្ចាត់ផ្លូវនៃការ ត្រិះរិះចំណែកអកុសលនោះបានដាច់ នេះឈ្មោះថា សម្មាសង្កប្បៈ ។

## សម្មាវាចា

សូម្បីកុសលធម៌ មានចេតនាវៀរចាកមុសាវាទជាដើម ក៏ផ្សេងគ្នា

ក្នុងខាងដើម ព្រោះសញ្ញាក្នុងការវៀរចាកមុសាវាទជាដើមផ្សេងគ្នា ។ តែក្នុងខណៈនៃមគ្គ ចេតនាវៀរចាកចំណែកកុសលតែម្យ៉ាងប៉ុណ្ណោះ កើតឡើងឲ្យអង្គមគ្គបរិបូណ៌ ដោយឲ្យសម្រេចសេចក្ដីមិនកើតនៃចេតនាជាគ្រឿងទ្រុស្តសីល ចំណែកអកុសលដែលកើតហើយ ក្នុងឋានៈ ៤ ទាំងនេះ ព្រោះកម្ចាត់ផ្លូវនៃចេតនាជាគ្រឿងទ្រុស្តសីលចំណែកអកុសលនោះ បានដាច់ នេះ ឈ្មោះថា សម្មាវាចា ។

## សម្មាកម្មន្ត

សុប្បីកុសលធម៌ មានចេតនាវៀរចាកបាណាតិបាតជាដើម ក៏ផ្សេងគ្នាក្នុងខាងដើម ព្រោះសញ្ញាក្នុងការវៀរចាកបាណាតិបាតជាដើមផ្សេងគ្នា ។ តែក្នុងខណៈនៃមគ្គ ចេតនាវៀរចាកចំណែកកុសលតែម្យ៉ាងប៉ុណ្ណោះ កើតឡើងឲ្យអង្គនៃមគ្គបរិបូណ៌ ដោយឲ្យសម្រេចការមិនកើតនៃចេតនា ជាគ្រឿងទ្រុស្តសីលចំណែកអកុសលដែលកើតហើយក្នុងឋានៈ ៣ ទាំងនេះ ព្រោះកម្ចាត់ផ្លូវបានដាច់ នេះឈ្មោះថា សម្មាកម្មន្តៈ ។

## សម្មាអាជីវៈ

ពាក្យថា មិច្ឆាអាជីវៈ បានដល់ កាយទុច្ចរិត និងវចីទុច្ចរិត ដែល

ប្រព្រឹត្តទៅដើម្បីត្រូវការរបស់ទំពារ របស់ស៊ីជាដើម ។ ពាក្យថា **លះ** គឺវៀរ ។ ពាក្យថា ដោយសម្មាអាជីវៈ គឺ ដោយអាជីវៈដែលព្រះពុទ្ធទ្រង់សរសើរ ។ ពាក្យថា សម្រេចជីវិត គឺ ដំណើរការចិញ្ចឹមជីវិត ។ ដែលឈ្មោះថា សម្មាអាជីវៈ ផ្សេងគ្នាក្នុងខាងដើម ព្រោះសញ្ញាក្នុងការវៀរចាកទុច្ចរិតមានមុសាវាទជាដើម ផ្សេងគ្នា ។ តែក្នុងខណៈនៃមគ្គ ចេតនាវៀរចាក ចំណែកកុសលតែមួយប៉ុណ្ណោះ កើតឡើង ឲ្យអង្គនៃមគ្គបរិបូណ៌ដោយឲ្យសម្រេចការមិនកើតនៃចេតនាជាគ្រឿងទ្រុស្តសីល ដែលជាមិច្ឆាអាជីវៈ ដែលកើតហើយក្នុងឋានៈ ៧ ( កាយទុច្ចរិត៣ វចីទុច្ចរិត ៤ ) ទាំងនេះឯង ព្រោះកម្មាត់ផ្លូវបានដាច់ នេះឈ្មោះថា សម្មាអាជីវៈ ។

## សម្មាវាយាម

ពាក្យថា **ដែលនៅមិនទាន់កើត** គឺ ដែលនៅមិនកើតដល់ខ្លួនក្នុងភពមួយ ឬក្នុងអារម្មណ៍បែបនោះ ។ តែព្រះយោគាវចរឃើញបាប អកុសលធម៌ ដែលកំពុងកើតដល់អ្នកដទៃ រមែងញុំាងឆន្ទៈឲ្យកើត ប្រារព្ធសេចក្ដីព្យាយាម ផ្គងចិត្តទុក ដើម្បីមិនឲ្យកើតបាបអកុសលដែលនៅមិនកើត ដោយគិតយ៉ាងនេះថា ឱហ្ន៎ បាបអកុសលធម៌ បែបនោះ មិនគប្បី

កើតដល់យើង ដូច្នេះ ។ ពាក្យថា ឆន្ទំ ជនេតិ **រមែងញ៉ាំងឆន្ទៈឲ្យកើត** គឺ ឲ្យកើតសេចក្តីពេញចិត្តក្នុងសេចក្តីព្យាយាម ដែលឲ្យសម្រេចការបដិបត្តិ ដែលមិនឲ្យកើតបាបអកុសលទាំងនោះ ។ ពាក្យថា វាយមតិ **ព្យាយាម** គឺ ធ្វើសេចក្តីព្យាយាម ។ ពាក្យថា វីរិយំ អារភតិ **ប្រារព្ធសេចក្តីព្យាយាម** គឺ ដំណើរសេចក្តីព្យាយាម ។ ពាក្យថា ចិត្តំ បគ្គណ្ហាតិ **ផ្គងចិត្ត** គឺ ធ្វើការផ្គងចិត្តដោយសេចក្តីព្យាយាម ។ ពាក្យថា បទហាតិ **តាំងទុក** គឺ ដំណើរការតាំងសេចក្តីព្យាយាមថា នឹងសល់តែស្បែក សរសៃ ឆ្អឹង ក៏ដោយចុះ ដូច្នេះ ។ ពាក្យថា ឧប្បន្នានំ **ដែលកើតហើយ** គឺ ដែលធ្លាប់កើតហើយដល់ខ្លួន ដោយការកម្រើកឡើង ។ រមែងឲ្យកើតឆន្ទៈ ដើម្បីលះបាបអកុសលទាំងនោះថា ឥឡូវនេះ យើងនឹងមិនឲ្យបាបអកុសល ដូច្នោះកើតឡើងទេ ។

ពាក្យថា អនុប្បន្នានំ កុសលានំ **កុសលដែលនៅមិនទាន់កើត** គឺ កុសលធម៌មាន បឋមជ្ឈានជាដើម ដែលខ្លួនមិនទាន់បាន ។ ពាក្យថា ឧប្បន្នានំ ដែលកើតហើយ គឺ ក្នុងកុសលទាំងនោះឯង ដែលខ្លួនបានហើយ ។ ពាក្យថា ឋិតិយា ដើម្បីតាំង គឺ ដើម្បីតាំងនៅដោយការកើតបន្តគ្នារឿយៗ ។ ពាក្យថា អសម្មោសាយ ការមិនដាច់ខ្សែ គឺ ដើម្បីមិនឲ្យ

សាបសូន្យ ។ ពាក្យថា ភិយ្យោភាវាយ ដើម្បីក្រៃលែងឡើង ៗ គឺ ដើម្បីចម្រើនក្រៃលែងឡើងទៅ ។ ពាក្យថា វេបុល្លាយ គឺ ដើម្បីសេចក្ដីធំទូលាយ ។ ពាក្យថា ភាវនាយ ធារិបូរិយា គឺ ដើម្បីសេចក្ដីបរិបូណ៌ ។ សូម្បីសម្មាវាយាមៈនេះ ក៏ផ្សេងគ្នាក្នុងខាងដើម ព្រោះចិត្តដែលគិតមិនឲ្យកើតអកុសល ដែលនៅមិនទាន់កើតជាដើម ផ្សេងគ្នា ។ តែក្នុងខណៈនៃមគ្គ វីរិយៈចំណែកកុសលតែម្យ៉ាងប៉ុណ្ណោះ កើតឡើងឲ្យអង្គនៃមគ្គបរិបូណ៌ ដោយឲ្យសម្រេចកិច្ចក្នុងឋានៈ ៤ ទាំងនេះ ដូចគ្នា នេះឈ្មោះថា សម្មាវាយាមៈ ។

## សម្មាសតិ

សូម្បីសម្មាសតិ ក៏ផ្សេងគ្នាក្នុងខាងដើម ព្រោះចិត្តដែលកំណត់អារម្មណ៍ មានកាយជាដើមផ្សេងគ្នា តែក្នុងខណៈនៃមគ្គ សតិតែម្យ៉ាងប៉ុណ្ណោះ កើតឡើងឲ្យអង្គនៃមគ្គបរិបូណ៌ ដោយឲ្យសម្រេចកិច្ចក្នុងឋានៈ ៤ នេះឈ្មោះថា សម្មាសតិ ។

## សម្មាសមាធិ

ឈានទាំងឡាយផ្សេងគ្នា ទាំងក្នុងខាងដើម ទាំងក្នុងខណៈនៃមគ្គ ។

ក្នុងខាងដើម ផ្សេងគ្នាដោយសមាបត្តិ ។ ក្នុងខណៈនៃមគ្គ ផ្សេងគ្នាដោយមគ្គ ។ ពិតហើយ មគ្គទី ១ នៃមគ្គខណៈមួយ មានបឋមឈានជាបាទ សូម្បីមគ្គទី ២ ជាដើម មានបឋមឈានជាបាទខ្លះ មានឈានយ៉ាងណាមួយ ក្នុងទុតិយជ្ឈានជាដើមជាបាទខ្លះ ។ មគ្គទី ១ នៃមគ្គខណៈ សូម្បីតែមួយ មានឈានណាមួយនៃទុតិយជ្ឈានជាដើមជាបាទ សូម្បីមគ្គទី ២ ជាដើម ក៏មានឈានណាមួយនៃទុតិយជ្ឈានជាដើម ជាបាទខ្លះ មានបឋមឈានជាបាទខ្លះ ។ មគ្គទាំង ៤ ពោលដោយឈាន ដូចគ្នាក៏មាន ផ្សេងគ្នាក៏មាន ដូចគ្នាកន្លែងខ្លះក៏មាន ដោយប្រការដូច្នេះ ។ នេះជាសេចក្តីផ្សេងគ្នានៃមគ្គនោះ កំណត់ដោយឈានដែលជាបាទ ។ គប្បីជ្រាបការអធិប្បាយ ដោយការកំណត់ដោយឈានជាបាទមុន មគ្គដែលកើតដល់ព្រះយោគាវចរអ្នកបានបឋមជ្ឈាន ចេញចាកបឋមជ្ឈាន ចម្រើនវិបស្សនា ឈ្មោះថា មានបឋមជ្ឈានជាបាទ ។ ក៏អង្គនៃមគ្គ និងពោជ្ឈង្គៈ រមែងបរិបូណ៌ក្នុងបឋមជ្ឈាននេះដោយពិត ។ មគ្គដែលកើតដល់ព្រះយោគាវចរអ្នកបានទុតិយជ្ឈាន ចេញចាកទុតិយជ្ឈានហើយ ចម្រើនវិបស្សនា ឈ្មោះថា មានទុតិយជ្ឈានជាបាទ ។ ចំណែកអង្គមគ្គក្នុងតតិយជ្ឈាននេះ មាន ៧ ប្រការ ។ មគ្គដែលកើតដល់ព្រះយោគាវចរ អ្នកចេញចាកតតិយជ្ឈាន

ហើយ ចម្រើនវិបស្សនា ឈ្មោះថា មានតតិយជ្ឈានជាបាទ ។ ចំណែកអង្គមគ្គក្នុងតតិយជ្ឈាននេះ មាន ៧ តែពោជ្ឈង្គៈ មាន ៦ ប្រការ ។ ចំពោះព្រះយោគាវចរអ្នកចេញចាកចតុត្ថជ្ឈាន ដរាបដល់នេវសញ្ញានាសញ្ញាយ-តនៈ ក៏ន័យនេះដូចគ្នា ។ ឈានពួក ៤ និងពួក ៥ រមែងកើតក្នុងអរូបនិងឈាននោះ លោកពោលថា ជាលោកុត្តរៈ មិនមែនលោកិយៈ ។ សួរថា ក្នុងឈាន មានបឋមជ្ឈានជាដើមនេះ តើដូចម្តេច ។ ឆ្លើយថា ក្នុងឈាន មានបឋមជ្ឈានជាដើមស្ងួម្បីនេះ ព្រះយោគាវចរនោះ ចេញចាកឈានណាហើយ បានសោតាបត្តិមគ្គ ចម្រើនអរូបសមាបត្តិ ហើយកើតក្នុងអរូបភព មគ្គទាំង ៣ មានឈាននោះជាបាទ កើតឡើងដល់ព្រះយោ-គាវចរនោះ ក្នុងអរូបភពនោះ ។ លោកកំណត់មគ្គ ដែលមានឈានជាបាទតែម្យ៉ាង ដោយប្រការដូច្នេះ ។ តែព្រះថេរៈពួកខ្លះពោលថា កំណត់ខន្ធជាអារម្មណ៍នៃវិបស្សនា ។ ពួកខ្លះក៏ថា កំណត់អធ្យាស្រ័យបុគ្គល ។ ពួកខ្លះក៏ថា កំណត់វិបស្សនាដែលជាវុដ្ឋានគាមិនី ។ វិនិច្ឆ័យវាទៈរបស់ព្រះថេរៈទាំងនោះ គប្បីជ្រាបតាមន័យដែលលោកពោលទុក ក្នុងអធិការពោលអំពីវុដ្ឋានគាមិនីវិបស្សនា ក្នុងគម្ពីរវិសុទ្ធិមគ្គ ។ ពាក្យថា អយំ វុច្ចតិ ភិក្ខវេ សម្មាសមាធិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សម្មាសមាធិ សេចក្តី

ថា ធម៌នេះ ខាងដើមជាលោកិយៈ ខាងក្រោយហៅថា លោកុត្តរៈ សម្មា-សមាធិ ។

ពាក្យថា ឥតិ អជ្ឈត្តំ វា ឬក្នុងថាងក្នុងជាដើម សេចក្តីថា ពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយ ព្រោះកំណត់សច្ចៈ ៤ របស់ខ្លួន របស់អ្នកដទៃ ឬព្រោះកំណត់សច្ចៈ ៤ របស់ខ្លួនតាមកាល របស់អ្នកដទៃតាមកាលយ៉ាងនេះ ។ ចំណែកការកើត និងការរលត់ក្នុងសច្ចបព្វៈនេះ គប្បីជ្រាបដោយការកើត និងការសូន្យទៅនៃសច្ចៈ ៤ តាមសេចក្តីពិត ។ ពាក្យដទៃក្រៅពីនេះ មានន័យដូចពោលមកហើយ ។

## សតិកំណត់សច្ចៈ ៤ ជាអរិយសច្ចៈ

តែក្នុងសច្ចបព្វៈនេះ ផ្សេងគ្នាតែម្យ៉ាង គឺ គប្បីប្រកបសេចក្តីយ៉ាងនេះថា សតិកំណត់សច្ចៈ ៤ ជាអារម្មណ៍ ជាទុក្ខសច្ចជាដើម ហើយគប្បីជ្រាបថា ជាផ្លូវបដិបត្តិនាំចេញចាកទុក្ខរបស់ភិក្ខុ ដែលកំណត់សច្ចៈជាអារម្មណ៍ ។ ពាក្យដ៏សេស ក៏ដូចគ្នា ។

" ចប់ សច្ចបព្វៈ "

## សរុបសេចក្ដី

ដោយលំដាប់ពាក្យមានប្រមាណត្រឹមតែប៉ុណ្ណេះ កម្មដ្ឋាន ២១ គឺ អានាបានបព្វៈ ១ ចតុឥរិយាបថបព្វៈ ១ ចតុសម្បជញ្ញបព្វៈ ១ ទ្វត្តិ-សាការ ១ ចតុធាតុវវត្ថានៈ ១ សីវថិកា ៩ វេទនានុបស្សនា ១ ចិត្តានុបស្សនា ១ នីវរណបរិគ្គហៈ ១ខន្ធបរិគ្គហៈ ១ អាយតនបរិគ្គហៈ ១ ពោជ្ឈង្គបរិគ្គហៈ ១ សច្ចបរិគ្គហៈ ១ ។

បណ្ដាកម្មដ្ឋាន ២១ នោះ កម្មដ្ឋាន ១១ គឺ អានាបានៈ ១ ទ្វត្តឹសាការ ១ សីវថិកា ៩ ជាអប្បនាកម្មដ្ឋាន ។ តែព្រះមហាសិវត្ថេរ អ្នករចនាគម្ពីរទីឃនិកាយ ពោលថា ព្រះមានព្រះភាគត្រាស់ សីវថិកា ៩ ដោយអាទីនវានុបស្សនា ។ ព្រោះដូច្នោះ តាមមតិរបស់លោក អានា-បានៈ និង ទ្វត្តឹសាការ ២ ប៉ុណ្ណោះជាអប្បនាកម្មដ្ឋាន ។ ដ៏សេសជា អានាបានៈ និងទ្វត្តឹសាការៈ ២ ប៉ុណ្ណោះ ជាអប្បនាកម្មដ្ឋាន ។ ដ៏សេស ជាឧបចារកម្មដ្ឋាន សួរថា សេចក្ដីតាំងមាំកើតក្នុងកម្មដ្ឋាននោះទាំងអស់ ឬមិនកើត ឆ្លើយថា មិនមែនមិនកើត សេចក្ដីតាំងមាំមិនកើតក្នុងឥរិយា-បថៈ សម្បជញ្ញៈ នីវរណៈ និងពោជ្ឈង្គៈ កើតក្នុងកម្មដ្ឋានដ៏សេស ។ ចំណែកព្រះមហាសិវត្ថេរ ពោលថា សេចក្ដីតាំងមាំ រមែងកើតក្នុងកម្មដ្ឋាន

សម្បជញ្ញៈទាំងនោះ ( ទាំងអស់ ) ព្រោះព្រះយោគាវចរនេះ រមែងកំណត់យ៉ាង នេះថា ឥរិយាបថ ៤ មានដល់យើង ឬមិនមានទេហ្ន៎ សម្បជញ្ញៈ ៤ មាន ដល់យើង ឬមិនមានទេហ្ន៎ នីវរណៈ ៥ មានដល់យើង ឬមិនមានទេហ្ន៎ ពោជ្ឈង្គៈ ៧ មានដល់យើង ឬមិនមានទេហ្ន៎ ដូច្នេះ ព្រោះដូច្នោះ សេចក្តីតាំងមាំ រមែងកើតក្នុងកម្មដ្ឋានទាំងអស់ ។

## អានិសង្ស

[១៣៨] ពាក្យថា យោ ហិ កោចិ ភិក្ខវេ សេចក្តីថា ម្នាលភិក្ខុ ទាំងឡាយ អ្នកណាម្នាក់ មិនថា ភិក្ខុ ឬភិក្ខុនី ឧបាសក ឬឧបាសិកា ។ ពាក្យថា ឯវំ ភាវេយ្យ សេចក្តីថា គប្បីចម្រើនតាមលំដាប់ភាវនា ដែល ពោលមកហើយតាំងពីដើម ។ ពាក្យថា ទាដិកង្ខំ សេចក្តីថា គប្បីសង្ឃឹម បាន គប្បីប្រាថ្នាបានជាពិតប្រាកដ ។ ពាក្យថា អញ្ញា សំដៅដល់ ព្រះ អរហត្ត ។ ពាក្យថា សតិ វា ឧទានិសេសេ សេចក្តីថា កាលឧបាទិសេស-វិបាកក្ខន្ធ ដែលកិលេស មានតណ្ហាជាដើម ចូលទៅប្រកាន់ទុកនៅមាន មិនទាន់អស់ទៅ ។ ពាក្យថា អនាគាមិតា ប្រែថា ភាពជាព្រះអនាគាមី ។ ព្រះមានព្រះភាគ គ្រាទ្រង់ត្រាស់សម្តែងពាក្យប្រៀនប្រដៅ ជាធម៌នាំអ្នក

បដិបត្តិចេញចាកទុក្ខដោយ ៧ ឆ្នាំ យ៉ាងនេះហើយ កាលនឹងទ្រង់សម្ដែង វេលា (បដិបត្តិ) ដែលតិចទៅជាងនោះទៀត ទើបត្រាស់ថា តិដ្ឋន្តុ ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ ៧ ឆ្នាំ ចូរលើកទុក ដូច្នេះជាដើម ។ ក៏ពាក្យនោះ សូម្បីទាំងអស់ ត្រាស់ដោយវេនេយ្យបុគ្គលថ្នាក់កណ្ដាល ។ តែដែលត្រាស់ ថា បុគ្គលទទួលពាក្យប្រៀនប្រដៅវេលាព្រឹក សម្រេចគុណវិសេសវេលា ល្ងាច ទទួលពាក្យប្រៀនប្រដៅវេលាល្ងាច ក៏សម្រេចគុណវិសេសវេលាព្រឹក ដូច្នេះ ទ្រង់សំដៅដល់បុគ្គលដែលមានបញ្ញាវាងវៃ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់សម្ដែងថា ពាក្យប្រៀនប្រដៅរបស់តថាគត នាំអ្នកបដិបត្តិចេញ ចាកទុក្ខយ៉ាងនេះហើយ កាលនឹងទ្រង់ញ៉ាំងទេសនា ដែលទ្រង់សម្ដែង ដោយធម៌ដ៏កំពូល គឺ ព្រះអរហត្ត ឲ្យចប់ស្រេចក្នុងឋានៈ ២១ ប្រការ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ផ្លូវនេះជាផ្លូវឯក ដើម្បីសេចក្ដីបរិសុទ្ធិ នៃសត្វទាំងឡាយ ដើម្បីឈានកន្លងសោកៈ និងបរិទេវៈ ដើម្បីរលត់ទុក្ខ និងទោមនស្ស ដើម្បីសម្រេចញាយធម៌ ដើម្បីធ្វើឲ្យច្បាស់ព្រះនិព្វាន នេះគឺ សតិប្បដ្ឋាន ៤ ដោយប្រការដូច្នេះ ពាក្យណាដែលតថាគតពោល ហើយយ៉ាងនេះ ពាក្យនោះ តថាគតអាស្រ័យផ្លូវឯកនេះ ពោលហើយ ។ ពាក្យដ៏សេស មានអត្ថងាយយល់ទាំងអស់នោះឯង ។

ក្នុងវេលាចប់ទេសនា ភិក្ខុបីម៉ឺនរូប តាំងនៅក្នុងព្រះអរហត្ត ។

*( ចប់ អដ្ឋកថាសតិប្បដ្ឋានសូត្រទី ៩ )*

# អដ្ឋកថា ចាយាសិរាជញ្ញសូត្រ ទី១០

[១៣៩] បាយាសិរាជញ្ញសូត្រ ចាប់ផ្តើមថា ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ។ ក្នុងបាយាសិរាជញ្ញសូត្រនោះ មានពណ៌នាតាមលំដាប់បទដូចតទៅនេះ ។

## ប្រវត្តិព្រះកុមារកស្សបៈ

ពាក្យថា អាយស្មា អ្នកមានអាយុ នេះ ជាពាក្យដែលគួរស្រឡាញ់ ។ ពាក្យថា **កុមារកស្សប** ជាឈ្មោះរបស់លោក ។ ក៏ព្រោះលោកបួសកាលនៅក្មេងជំទង់ ព្រះមានព្រះភាគ ត្រាស់បង្គាប់នឹងភិក្ខុទាំងឡាយថា ពួកអ្នកចូរហៅកស្សបៈមក ចូរឲ្យផ្លែឈើនេះខ្លះ របស់ទំពារនេះខ្លះ ដល់កស្សបៈដូច្នេះ ភិក្ខុទាំងឡាយ សង្ស័យថា កស្សបៈអង្គណា (ព្រោះភិក្ខុដែលឈ្មោះកស្សបៈមានច្រើនអង្គ) ទើបនាំគ្នាដាក់នាមលោកថា កុមារកស្សបៈ ។ តាំងពីនោះមក សូម្បីពេលលោកចាស់ជរា ក៏នៅតែហៅថា កុមារកស្សបៈទុះឯង ។ ន័យមួយទៀត ព្រោះលោកជាបុត្រចិញ្ចឹមរបស់ព្រះបាទបសេនទិកោសល មនុស្សទាំងឡាយ ទើបសំដៅហៅលោកថា កុមារកស្សបៈ ។ នឹងពោលរឿងរបស់លោកឲ្យជាក់ច្បាស់ តាំងពីបុព្វប្រយោគដូចតទៅនេះ ។

បានឮមកថា ព្រះថេរៈ ( កុមារកស្សបៈ ) ជាបុត្រសេដ្ឋី គ្រាព្រះមានព្រះភាគ ព្រះនាមថា បទុមុត្តរៈ ។ តមកថ្ងៃមួយ លោកឃើញព្រះមានព្រះភាគ ទ្រង់តែងតាំងព្រះសាវករបស់ព្រះអង្គមួយរូប ដែលជាអ្នកពោលធម៌បានវិចិត្រទុកក្នុងតំណែង ( ឯតទគ្គ ) ទើបថ្វាយទានចំពោះព្រះមានព្រះភាគ ៧ ថ្ងៃ ធ្វើសេចក្តីប្រាថ្នាថា សូម្បីខ្ញុំអ្នកមានជោគ ក៏នឹងជាព្រះសាវកអ្នកពោលធម៌យ៉ាងវិចិត្រ ដូចព្រះថេរៈអង្គនេះ ក្នុងព្រះពុទ្ធមួយព្រះអង្គនាអនាគតកាល បានធ្វើបុណ្យទាំងឡាយ បួសក្នុងសាសនារបស់ព្រះមានព្រះភាគ ព្រះនាមថា កស្សបៈ មិនអាចធ្វើគុណវិសេសឲ្យកើតបាន ។ ន័យថា គ្រានោះ កាលព្រះមានព្រះភាគ ស្តេចរលត់ខន្ធបរិនិព្វានហើយ ព្រះសាសនាកំពុងសាបសូន្យ ភិក្ខុ ៥ រូប ធ្វើជណ្តើរឡើងទៅកាន់ភ្នំ ធ្វើសមណធម៌ ។ ភិក្ខុដែលជាសង្ឃត្ថេរ ( ប្រធាន ) សម្រេចព្រះអរហត្ត ក្នុងថ្ងៃទី ៣ ។ ភិក្ខុដែលជាអនុត្ថេរ បានជាព្រះអនាគាមីក្នុងថ្ងៃទី ៤ ។ ៣ រូប ទៀត មិនអាចធ្វើគុណវិសេសឲ្យកើត បានក៏ទៅកើតក្នុងទេវលោក ។ បណ្តាភិក្ខុ ៣ រូប ដែលសោយសម្បត្តិក្នុងទេវតានិងមនុស្ស រហូតដល់អស់មួយពុទ្ធន្តរនោះ មួយរូបទៅកើតក្នុងរាជត្រកូលក្នុងក្រុងតក្កសិលា ជាព្រះរាជាព្រះនាមថា **បុក្កុសាតិ** បួសឧទ្ទិសព្រះមាន-

ព្រះភាគ ប្រាថ្នាមកកាន់ក្រុងរាជគ្រឹះ បានស្តាប់ព្រះធម៌ទេសនារបស់ព្រះ-មានព្រះភាគ ត្រង់ពេងស្តូនធ្លាំង ក៏សម្រេចអនាគាមិផល ។ មួយរូបទៅកើតក្នុងផ្ទះរបស់ត្រកូល ត្រង់កំពង់ទូកឈ្មោះ **សុប្បដ្ឋនៈ** ជិតសមុទ្រមួយកន្លែង ដោយសារទូក ៗ លិច ត្រូវយកឈើធ្វើសំពត់ស្លៀក បានលាភសក្ការៈ ( ដែលមនុស្សល្ងង់គិតថា ជាព្រះអរហន្តគួរបូជា ) ខ្លួនឯងក៏កើតការគិតថា ជាព្រះអរហន្ត ទេវតាអ្នកប្រាថ្នាសេចក្តីល្អ បានដាស់តឿនថា អ្នកមិនមែនជាព្រះអរហន្តទេ ចូរទៅគាល់ព្រះសាស្តា ទូលសួរបញ្ហា ក៏ធ្វើតាមទេវតាដាស់តឿន បានសម្រេចព្រះអរហត្តផល ។ មួយរូប ទៅកើតក្នុងគភ៌របស់ត្រកូលស្ត្រីម្នាក់ ក្នុងក្រុងរាជគ្រឹះ ។ ត្រកូលស្ត្រីនោះអង្វរមាតាក៏មិនបានបួស ដរាបមានស្វាមី មិនដឹងខ្លួនថា តាំងគភ៌ យកចិត្តស្វាមី ៗ ក៏អនុញ្ញាត ទើបបួសជាភិក្ខុនីនៅក្នុងសម្នាក់ភិក្ខុនី ។ ភិក្ខុនីទាំងឡាយ ឃើញនាងមានគភ៌ ទើបសួរភិក្ខុទេវទត្ត ។ ភិក្ខុទេវទត្ត ក៏ប្រាប់ថានាងមិនមែនជាសមណៈ ។ ហើយ ( សង្ស័យ ) ក៏ទៅទូលសួរព្រះទស-ពល ។ ព្រះសាស្តា ត្រាស់បង្គាប់ឲ្យព្រះឧបាលិត្ថេរទទួលរឿងទៅវិនិច្ឆ័យ ។ ព្រះថេរៈអញ្ជើញត្រកូលអ្នកក្រុងសាវត្ថី និងនាងវិសាខាឧបាសិកា ឲ្យជួយពិនិត្យមើល (បានដឹងសេចក្តីពិតហើយ) ទើបវិនិច្ឆ័យថា នាងតាំងគភ៌

មកអំពីមុនបព្វជ្ជា ទើបមិនវិនាស ។ ព្រះសាស្តាប្រទានសាធុការ គាំទ្រ ដល់ព្រះថេរៈថា ឧបាលិវិនិច្ឆ័យអធិករណ៍ ប្រពៃហើយ ។ ភិក្ខុនីនោះ ប្រសូតបុត្រ ដូចគ្នានឹងចាក់ពុម្ពដោយជុំមាស ។ ព្រះបាទបសេនទិកោ-សល ប្រោសឲ្យទទួលទារកនោះមកចិញ្ចឹម ។ ព្រះរាជទាននាមថា កស្សបៈ តមកទ្រង់ចិញ្ចឹមកស្សបៈធំធាត់ល្មមហើយ ទើបទ្រង់នាំទៅទុកដាក់ក្នុងសម្នាក់ ព្រះសាស្តា ឲ្យបព្វជ្ជា ។ មនុស្សទាំងឡាយទើបចាំ សម្គាល់ ហៅលោក ថា កុមារកស្សបៈ ព្រោះជាបុត្រចិញ្ចឹមរបស់ព្រះរាជា ដោយប្រការដូច្នេះ ។ ថ្ងៃមួយ លោកធ្វើសមណធម៌នៅត្រង់ព្រៃអន្ធវ័ន ទេវតាអ្នកប្រាថ្នាសេចក្តី ល្អ ទើបឲ្យលោករៀនបញ្ហា ហើយប្រាប់ឲ្យលោកទៅទូលសួរ បញ្ហាទាំង នេះ ចំពោះព្រះមានព្រះភាគ ។ ព្រះថេរៈទូលសួរបញ្ហាហើយ ក៏សម្រេច ព្រះអរហត្ត ពេលចប់ការវិសជ្ជនាបញ្ហា ។ សូម្បីព្រះមានព្រះភាគ ក៏ទ្រង់ ស្ថាបនាលោកទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលនៃភិក្ខុអ្នកពោលធម៌បាន វិចិត្រ ។

ពាក្យថា សេតព្យា ជាឈ្មោះរបស់នគរនោះ ។ ពាក្យថា ឧត្តរេន សេតព្យំ គឺ ទិសខាងជើងនៃសេតព្យនគរ ។ ពាក្យថា រាជញ្ញោ គឺ ស្តេច ដែលមិនបានទទួលមុទ្ធាភិសេក ។ ពាក្យថា ទិដ្ឋិគតំ គឺ ទិដ្ឋិ ការឃើញ

ទុះឯង ។ កាលមានពាក្យដែលពោលមកថា គូថគតំ មុត្តគតំ ដូច្នេះ វត្ថុដទៃក្រៅចាកគូថជាដើម រមែងមិនមានយ៉ាងណា ទិដ្ឋិទុះឯង ក៏គឺ ទិដ្ឋិគតៈដូច្នោះ ។

[១៤០] ពាក្យថា **សូម្បីព្រោះហេតុនេះ ទើបមិនមាន** ដូច្នេះ សេចក្តីថា ស្តេចបាយាសិ ពោលថា សូម្បីនឹងអាងហេតុនោះ ៗ យ៉ាងនេះ លោកដទៃ ។ល។ ក៏មិនមាន ។ ពាក្យថា បុរា ។បេ។ សញ្ញាបេតិ សេចក្តីថា ញុំាងកាតមិនទាន់យល់ត្រឹមណា ។

ពាក្យថា ឥមេ ភោ កស្សប ចន្ទិមសុរិយា សេចក្តីថា ន័យថា ស្តេចបាយាសិនោះ ត្រូវព្រះថេរៈសួរហើយ គិតថា សមណៈនេះ នាំយកព្រះចន្ទព្រះអាទិត្យមកឧបមាមុន ទើបជាអ្នកដែលបុគ្គលដទៃគ្របសង្កត់ទុកមិនបានដោយបញ្ញា ដូចគ្នានឹងព្រះចន្ទព្រះអាទិត្យ ក៏បើយើងនឹងឆ្លើយ ថា ព្រះចន្ទព្រះអាទិត្យមាននៅក្នុងលោកនេះ សមណៈនេះ ក៏នឹងធ្វើឲ្យយើងភ្ញាក់ដោយបញ្ហាកម្មជាដើមថា ព្រះចន្ទព្រះអាទិត្យទាំងនោះ អាស្រ័យអ្វីទទឹងប្រវែងប៉ុនណា កម្ពស់ប៉ុនណា យើងក៏មិនអាចនឹងចងលោកទុកបាននឹងឆ្លើយចំពោះលោកថា មាននៅក្នុងលោកដទៃប៉ុណ្ណោះ ព្រោះដូច្នោះស្តេចបាយាសិ ទើបពោលតបយ៉ាងនោះ ។ ក៏ព្រះមានព្រះភាគ ត្រាស់

សុធាភោជនីយជាតក ក្នុងកាលមិនយូរ មុនបាយាសិរាជញ្ញសូត្រនោះ ។ ក្នុងសុធាភោជនីយជាតកនោះ ព្រះចន្ទ ជាចន្ទទេវបុត្រ ព្រះអាទិត្យ ជាសុរិយទេវបុត្រ ។ ជាតក ឬព្រះសូត្រដែលព្រះមានព្រះភាគ ត្រាស់ទុកប្រាកដ ដឹងទូទៅក្នុងជម្ពូទ្វីប ។ ដោយហេតុនោះ ស្តេចបាយាសិនោះ គិតថា យើងមិនអាចពោលថា ទេវបុត្រទាំងឡាយ ដែលនៅប្រចាំក្នុងព្រះច័ន្ទព្រះអាទិត្យនោះមិនមាន ទើបពោលឆ្លើយថា **ព្រះចន្ទ ព្រះអាទិត្យនោះ ជាទេវតា មិនមែនមនុស្សទេ** ។

[១៤១] ពាក្យថា អត្ថិ បន រាជញ្ញ បរិយាយោ សេចក្តីថា ព្រះថេរៈសួរថា ហេតុនៅមានឬ ។ ពាក្យថា អាពាធិកា គឺ អ្នកប្រកបដោយជម្ងឺ ពោលគឺ អ្នកមានវេទនាដែលមិនត្រូវគ្នា ។ ពាក្យថា ទុក្ខិតា គឺ ដល់ទុក្ខ ។ ពាក្យថា ពាឡ្ហគិលានា គឺ ជាជម្ងឺមានប្រមាណក្រៃលែង ។ ពាក្យថា សទ្ធាយិកា សេចក្តីថា យើងជឿពួកលោក , លោកជាបុគ្គលគួរជឿ មានវាចាដែលយើងជឿតាមបាន ។ ពាក្យថា បច្ចយិកា សេចក្តីថា យើងទុកចិត្តពួកលោក លោកក៏ជាអ្នកដែលគួរទុកចិត្ត ដែលយើងគួរជឿទុកចិត្ត ។

**[១៤២-១៤៣]** ពាក្យថា ឧទ្ទិសិត្វា សេចក្តីថា សម្តែងខ្លួន និងវត្ថុ

ដែលរក្សាទុកដាក់ដល់បុគ្គលទាំងនោះ ឲ្យទទួលទុក ។ ពាក្យថា វិប្បល-
បន្តស្ស គឺ ត្អូញត្អែថា កូនប្រុសរបស់យើង កូនស្រីរបស់យើង ទ្រព្យរបស់
យើង ។ ពាក្យថា និរយបាលេសុ គឺ អ្នកដាក់ទោសសត្វក្នុងនរក ។ ក៏
បុគ្គលពួកណាពោលថា កម្មនុ៎ះឯងដាក់ទោស នាយនិរយបាលមិនមាន
បុគ្គលទាំងនោះ ក៏ជំទាស់ក្នុងទេវទូតសូត្រ ដែលថា ម្នាលភិក្ខុទាំងឡាយ
នាយនិរយបាល ចាប់អ្នកនោះ ដូច្នេះជាដើម ។ នាយនិរយបាលមាន
នៅក្នុងនរក ដូចមនុស្សអ្នកដាក់ទោស ប្រចាំរាជត្រកូលក្នុងមនុស្សលោក
ដូច្នោះ ។

[១៤៤] ពាក្យថា វេឡុទោសិកាយហិ ប្រែថា ដោយបន្ទះឫស្សី ។
ពាក្យថា សុនិម្មជ្ជិតំ សេចក្តីថា **គួរ** ជារបស់បញ្ចេញដោយល្អ ដោយ
ប្រការណា ក៏កោសចេញទៅដោយប្រការនោះ ។ អធិប្បាយថា ចូរកោស
ចេញ នាំចេញទៅដោយប្រការនោះ ។ ពាក្យថា **អសុចិ** គឺ មិនគួរពេញ
ចិត្ត ។ ពាក្យថា អសុចិសំខាតោ គឺ ជាចំណែកមិនស្អាត ឬដែលដឹងថា
ជារបស់មិនស្អាត ។ ពាក្យថា ទុគ្គន្ធោ គឺ ក្លិនស្អុយដូចសាកសព ។
ពាក្យថា ជេគុច្ឆោ គឺ គួរជារបស់គួរខ្ពើម ។ ពាក្យថា បដិក្កូលោ គឺ នាំ
សេចក្តីទាស់ចិត្តមក ដោយការឃើញប៉ុណ្ណោះ ។ ពាក្យថា ឧញ្ញាតនិ សេចក្តី

ថា កុទិនរបស់ពួកមនុស្ស សួម្បីជាស្តេចចក្រពត្តិជាដើម ដែលធ្លួតទឹកមួយថ្ងៃ ២ ដង ផ្លាស់សម្លត់មួយថ្ងៃ ៣ ដង តាក់តែងប្រដាប់កាយហើយក៏នៅស្អុយគគ្រុក ដូចសាកសពដែលព្យួរនឹងក ទេវតាដែលនៅឆ្ងាយដល់មួយរយយោជន៍ ។

[១៨៥] ពាក្យថា តាវតឹសានំ សេចក្តីថា លោកពោលទៀត ដោយអំណាចបុគ្គលអ្នកសមាទានសីល ៥ មានវៀរបាណាតិបាតជាដើម ប្រព្រឹត្តហើយ ។ នឹងពោលអធិប្បាយ ពាក្យពោលរបស់ទេវតាជាន់តាវត្តិង្សថា ទេវតាអ្នកកើតក្នុងទីឆ្ងាយ កុំមកមុន ព្រោះហេតុណា ទេវតាទាំងនេះ ទើបមិនមក ។

[១៨៦] ពាក្យថា ជច្ចន្ធូបមោ មញ្ញេ បដិភាសិ គឺ ប្រាកដដូចជាបុគ្គលខ្វាក់ភ្នែកអំពីកំណើត ។

ពាក្យថា អរញ្ញវនបត្ថានិ អធិប្បាយថា ដែលឈ្មោះថា អរញ្ញព្រោះប្រកបដោយអង្គគុណរបស់អ្នកនៅព្រៃ ដែលឈ្មោះថា **វនព្រៃ** ព្រោះជាដួរព្រៃធំ ។ ពាក្យថា បត្ថានិ គឺ ឆ្ងាយ ។

[១៨៧] ពាក្យថា កល្យាណធម្មោ គឺ មានធម៌ដែលល្អ ព្រោះសីលនោះឯង ។ ពាក្យថា ទុក្ខប្បដិក្កូលេ គឺ អ្នកមិនប្រាថ្នាទុក្ខ ។ ពាក្យថា

សេយ្យោ ភវិស្សតិ អធិប្បាយថា នឹងមានសុគតិសុខ ក្នុងលោកដទៃ ។

[១៤៨] ពាក្យថា ឧបវិជញ្ញា គឺ វេលាប្រសូតជិតចូលមកហើយ គភ៌ចាស់ហើយ ។ អធិប្បាយថា នឹងប្រសូតមិនយូរឡើយ ។ បទថា ឧបភោគ្គា ភវិស្សតិ គឺ នឹងជាស្រីបម្រើ ។ បទថា អនយព្យសនំ បានដល់ ទុក្ខធំ ។ សុខ ឈ្មោះថា អយៈ, មិនមែនអយៈ ឈ្មោះថា អនយៈ គឺ ទុក្ខ ទុក្ខនោះរមែងដេញ គឺ ដេញសុខចេញទៅដោយប្រការទាំងពួង ព្រោះ ហេតុនោះ ទើបឈ្មោះ ព្យសនៈ, ព្យសនៈ គឺ ទុក្ខ ឈ្មោះថា អនព្យសនៈ អធិប្បាយថា **ទុក្ខធំ** ដោយប្រការដូច្នេះ ។ ពាក្យថា អយោនិសោ គឺ ដោយមិនមែនឧបាយ ។ ពាក្យថា អបក្កំ ឧ បរិចាចេន្តិ អធិប្បាយថា មិនបានចូលទៅកាត់អាយុដែលនៅមិនប្រែប្រួល មិនទាន់ អស់ ឲ្យដាច់ក្នុងចន្លោះ ។ ពាក្យថា បរិចាកំ អាគមេន្តិ គឺ រង់ចាំវេលា ដែលអាយុទុំជោរ ។ សូម្បីព្រះធម្មសេនាបតី ក៏ពោលទុកថា ៖

ណាភិនន្ទាមិ មរណំ ណាភិកង្ខាមិ ជីវិតំ
កាលញ្ច បដិកង្ខាមិ និព្វេសំ ភដកោ យថា

**យើងមិនត្រេកអរក្នុងសេចក្តីស្លាប់ មិនប្រាថ្នាក្នុងការរស់**
**នៅ តែយើងរង់ចាំវេលា (បែកធ្លាយ) ដូចកូនឈ្នួលរង់ចាំ**

តម្លៃឈ្នួល ដូច្នោះ ។

[១៤៩] ពាក្យថា ឧត្តិន្ទិត្វា គឺ ផ្ទះជីស្អិតដែលបូកទុក ។ ពាក្យថា រាមណេយ្យកំ គឺ គួររីករាយ ។ ពាក្យថា ចេឡាវិកា គឺ ក្មេងស្រីដែលក្រចខ្លួនដោយការលេង ។ ពាក្យថា កោមារិកា គឺ ក្មេងស្រីតូច ។ ពាក្យថា តុយ្ហំ ជីវំ សេចក្តីថា ស្រីទាំងនោះឯង ឃើញជីវៈដែលចេញទៅ ដែលចូលទៅ ខណៈដែលស្តេចយល់សប្តិឃើញ ខ្លះទេ ។ ព្រះថេរៈពោលថា ជីវៈជាអាការត្រាច់ទៅនៃចិត្ត ទើបពោលទុកក្នុងទីនេះ ។ ក៏លោកមានសេចក្តីយល់ក្នុងអាការត្រាច់ទៅនៃចិត្តនោះថា ជីវៈ ។

[១៥០] ពាក្យថា ឩយាយ សេចក្តីថា ចងជីវៈទុកដោយខ្សែធ្នូ ។ ពាក្យថា បត្ថិន្នតរោ រឹងជាង គឺ រឹងប៉ុង ។ ស្តេចបាយាសិសម្តែងអ្វីដោយពាក្យនេះ ។ ព្រះបាទបាយាសិសម្តែងសេចក្តីនេះថា លោកទាំងឡាយពោលថា វេលានៅរស់ សត្វមានខន្ធ ៥ តែវេលាស្លាប់ នៅសល់នៅត្រឹមតែរូបក្ខន្ធប៉ុណ្ណោះ ខន្ធ ៣ ក៏ប្រព្រឹត្តទៅមិនបាន វិញ្ញាណក្ខន្ធក៏ទៅ រូបក្ខន្ធដែលនៅសល់ គួរនឹងស្រាល តែត្រឡប់ជាធ្ងន់ ព្រោះដូច្នោះ អ្វី ៗ ដែលទៅទីណាមិនបាន ដូច្នេះ ។

[១៥១] ពាក្យថា និព្វុតំ គឺ មានតេជោធាតុ ដែលស្ងប់ហើយ ។

[១៥២] ពាក្យថា អនុបហច្ច គឺ មិនឲ្យវិនាស ។ ពាក្យថា អគ្គមគោហោតិ គឺ ផ្ដើមស្លាប់ជាបណ្ដើរៗ ។ ពាក្យថា ឱដ្ឋនាថ ប្រែថា ទាញមកខាងនេះ ។ ពាក្យថា សន្ធុនាថ ប្រែថា ទាញមកខាងណោះ ។ ពាក្យថា និទ្ធុនាថ ប្រែថា ទាញទៅទាញមក ។ ពាក្យថា តញ្ចាយតនំ ន បដិសំវេទេតិ សេចក្ដីថា រូបាយតនៈនោះ មិនដឹងច្បាស់ដោយចក្ខុនោះ ។ គ្រប់បទក៏ន័យនេះ ។

[១៥៣] ពាក្យថា សន្ទុដមោ គឺ អ្នកផ្ទុំស័ង្ខ ។ ពាក្យថា ឧបធ្មា-សិត្វា គឺ ហើយផ្ទុំ ។

[១៥៥] ពាក្យថា អគ្គិកោ ប្រែថា អ្នកបម្រើភ្លើង ។ ពាក្យថា អាធាតេយ្យំ គឺ គប្បីឲ្យសម្រេច ឬគប្បីដល់អាយុ ពាក្យថា ធោសេយ្យំ គឺ គប្បីចិញ្ចឹមដោយភោជន ជាដើម ។ ពាក្យថា វឌ្ឍេយ្យំ គឺ គប្បីដល់សេចក្ដីជំជាត់ ។ ពាក្យថា អរណីសហិតំ គឺ គូសឈើពួតភ្លើង ។

[១៥៦] ពាក្យថា តិរោរាជានោ ព្រះរាជាខាងក្រៅ សេចក្ដីថា ព្រះរាជាទាំងឡាយក្នុងខាងក្រៅដែន គឺ ក្នុងជនបទដទៃ ក៏ដឹង ។ ពាក្យថា អព្យត្តោ គឺ អ្នកមិនមានបញ្ញាខ្លាំងក្លា អ្នកមិនឆ្លាត ។ ពាក្យថា កោបេនបិ សេចក្ដីថា បុគ្គលពួកណា ពោលទឹងយើងយ៉ាងនេះ ខ្ញុំក៏ទឹងបបួល នឹងនាំ

នឹងនាំគេ ដែលមានទិដ្ឋិយ៉ាងនោះត្រាច់ទៅ ដោយសេចក្ដីក្រោធ ដែលកើតក្នុងបុគ្គលទាំងនោះ ។ ពាក្យថា មក្ខេន ដោយមក្ខៈ គឺ ការមើលងាយ ដែលមានលក្ខណៈមើលងាយ ដូចលោកពោលហើយ ។ ពាក្យថា បលាសេន ដោយបលាសៈ គឺ ការវាយឫកស្មើ ដែលមានលក្ខណៈប្រកាន់ថា ជាគូ ( ជិត ) នឹងលោក ។

[១៥៧] ពាក្យថា ហរីតកបណ្ណំ គឺ ស្លឹកឈើខៀវខ្ចី សម្ប្រភេទណាមួយ ។ អធិប្បាយថា ដោយទីបំផុត សូម្បីស្លឹកស្មៅខ្ចីក៏មិនមាន ។ ពាក្យថា អាសន្នឧទកលាបំ គឺ អ្នកមានបំពង់គ្រាប់ពេញ ដែលចងស៊កទុកហើយ ។ ពាក្យថា អាសិត្តោទកានិ វដុមានិ គឺ ផ្លូវ និងអូរព្រែក មានទឹកបរិបូណ៌ ។ ពាក្យថា យោគ្គានិ គឺ យានទឹមដោយគោប្រើ ។ ពាក្យថា ពហុនិក្ខន្តោ សេចក្ដីថា ចេញទៅច្រើន ចេញទៅយូរហើយ ។ ពាក្យថា យថាភតេន ភណ្ឌេន សេចក្ដីថា វត្ថុ គឺ ស្មៅ ឈើ និងទឹកណា ដែលពួកលោកផ្ទុកមក ក៏ចូរញុំាងពួករទេះឲ្យប្រព្រឹត្តទៅ ដោយវត្ថុដែលលោកផ្ទុកមក នាំមកនោះចុះ ។ ពាក្យថា អប្បសារានិ គឺ មានតម្លៃតិច ។ ពាក្យថា បណិយានិ គឺ វត្ថុទាំងឡាយ ។

[១៥៩-១៦០] ពាក្យថា មម ច សុត្វាភត្តំ សេចក្ដីថា នេះជា

អាហារនៃជ្រូកទាំងឡាយរបស់ខ្ញុំ ។ ពាក្យថា ឧក្ខរេន គឺ ហៀរឡើង ។ ពាក្យថា បក្ខរន្តិ គឺ ហូរចុះ ។ ពាក្យថា តុម្ហេ ខ្វេត្ថ ភណោ ប្រែថា នែវើយ ពួកអ្នករាល់គ្នាទេតើ ជាមនុស្សឆ្កួត ខូចចរឹតក្នុងរឿងនេះ ។ មយ៉ាងទៀត បាលីក៏មានយ៉ាងនេះដូចគ្នា ។ ពាក្យថា តថា ហិ បន មេ សូករភត្តំ ប្រែថា តែសូម្បីយ៉ាងនោះ គូថនេះ ក៏ជាអាហារនៃសូករទាំងឡាយរបស់ខ្ញុំ ។

[១៦១] ពាក្យថា អាគតាគតំ កលឹ ប្រែថា លេបកូនបាសកាដែលចាញ់ ដែលបានមកដល់ខ្លួន ៗ ។ ពាក្យថា បជោហិស្សាមិ សេចក្តីថា ខ្ញុំនឹងធ្វើការសែន នឹងធ្វើការបួងសួង ។ ពាក្យថា អក្ខេហិ ទិព្វិស្សាមិ គឺ លេងដោយកូនបាសាកាទាំងឡាយ គឺ លេងដោយកូនបាសាកាទាំងឡាយ ។

[១៦២-១៦៤] ពាក្យថា លិត្តំ បរមេន តេជសា ប្រែថា ដែលលាបដោយថ្នាំពិស មានកម្លាំងខ្លាំងក្លា ។

[១៦៥] ប្រទេសនៃស្រុកជាទីរស់នៅ លោកហៅ **គាមបជ្ជ:** បាលីថា គាមបទ ក៏មាន ។ សេចក្តីក៏យ៉ាងនេះដូចគ្នា ។ ពាក្យថា **សំបកថ្មៃ** គឺ បាច់សំបកថ្មៃ ។ ពាក្យថា សុសន្នទ្ធោ ប្រែថា ចងទុកល្អហើយ ។ ពាក្យថា

ត្វំ បជានាហិ ប្រែថា លោកចូរដឹង ។ អធិប្បាយថា លោកចូរទទួលទុក បើលោកត្រូវការនឹងកាន់យក ក៏កាន់យកបាន ។ ពាក្យថា ខោមំ ប្រែថា សំបកឈើ ។ ពាក្យថា អយសំ ប្រែថា ដែក ( លោហៈខ្មៅ ) ។ ពាក្យថា លោហំ ប្រែថា ទង់ដែង ( លោហៈក្រហម ) ។ ពាក្យថា សជ្ឈុំ ប្រែថា ប្រាក់ ។ ពាក្យថា សុវណ្ណំ ប្រែថា មាស មាសក: ។ ពាក្យថា អភិឆដ្ឋីសុ ប្រែថា ត្រេកអរហើយ ។

[១៦៦] ពាក្យថា អត្តមនោ ប្រែថា មានចិត្តជារបស់ខ្លួន គឺ មានចិត្តត្រេកអរហើយ ។ ពាក្យថា អភិនន្ទោ គឺ ជ្រះថ្លាក្រៃលែងហើយ ។ ពាក្យថា បញ្ហបដិភាណានិ ប្រែថា ការប្រាកដច្បាស់នៃបញ្ហា ។ ពាក្យថា បច្ចនីកំ កាតព្វំ សេចក្តីថា ធ្វើដូចជាសត្រូវ គឺ ធ្វើខុសៗ គ្នា ។ ពាក្យថា អវមញ្ញិស្សំ សេចក្តីថា ឈរនៅក្រាញ ប្រកាន់ផ្ទុយគ្នា ។

ពាក្យថា សង្ឃាតំ អាបជ្ជន្តិ ប្រែថា សូម្បីពិឃាត វិនាស មរណៈ ។ ពាក្យថា ន មហប្ផលោ សេចក្តីថា មិនមានផលច្រើនដោយផលវិបាក ។ ពាក្យថា ន មហានិសំសោ សេចក្តីថា មិនមានអានិសង្សច្រើន ដោយអានិសង្ស គឺ គុណ ។ ពាក្យថា ន មហាជុតិកោ សេចក្តីថា មិនមានសេចក្តីរុងរឿង ដោយភាពរុងរឿង ដោយអានុភាព ។ ពាក្យថា ន

មហាវិច្ឆរោ សេចក្តីថា មិនមានការផ្សាយទូលំទូលាយ ដោយការផ្សាយទៅនៃវិបាក ។ ពាក្យថា តីជនង្គលំ ប្រែថា ពូជ ( គាប់ពូជ ) និងនង្គ័ល ។ ពាក្យថា ទុក្ខេត្តេ ប្រែថា ក្នុងស្រែអាក្រក់ ស្រែគ្មានសារៈ ។ ពាក្យថា ទុព្ភូមេ ប្រែថា ផ្ទៃដីមិនរាបស្មើ ។ ពាក្យថា បតិដ្ឋាបេយ្យ ប្រែថា គប្បីតាំងទុក ។ ពាក្យថា ខណ្ឌានិ គឺ បាក់បែក ។ ពាក្យថា បូតីន គឺ គ្មានសារៈ ។ ពាក្យថា វាតាតបហតានិ គឺ ត្រូវខ្យល់ និងកម្តៅថ្ងៃ បៀតបៀន ។ ពាក្យថា អសារទានិ គឺ ខៀវស្រស់ ដរាបវៀរការដាក់គាប់ស្រូវបាន ។ ពាក្យថា អសុខសយិតានិ គឺ ពូជពួកណា ដែលគេធ្វើឲ្យស្ងួតហើយ រក្សាទុកក្នុងជង្រុក ពូជទាំងនោះ ឈ្មោះថា ស្ងួតល្អ , តែពូជទាំងនោះមិនដូច្នោះ ។ ពាក្យថា ន អនុប្បវេច្ឆេយ្យ គឺ ភ្លៀងមិនបង្អុរចុះមក សេចក្តីថា មិនធ្លាក់ដោយល្អ ( ត្រឹមត្រូវតាមរដូវកាល ) ។ អធិប្បាយថា មិនធ្លាក់គ្រប់កន្លះខែ គ្រប់ ១០ ថ្ងៃ គ្រប់ ៥ ថ្ងៃ ។ ពាក្យថា អបិ នុ តានិ សេចក្តីថា កាលស្រែមានពូជ និងភ្លៀង ជាទោសយ៉ាងនេះហើយ ពូជទាំងនោះ នឹងគប្បីធំធាត់ខ្ពស់ឡើង លូតលាស់ ចាក់ឫស និងរីកសាយធំទូលាយដោយល្អ ដោយពន្លក ឫស និងស្លឹកជាដើម បានឬ ។ ពាក្យថា ឯវរូបោ ខោ រាជញ្ញ យញ្ញោ សេចក្តីថា មហាបពិត្រ ទាន

បែបនេះ រមែងមិនមានផលច្រើន ព្រោះមិនបរិសុទ្ធិដោយបច្ច័យ ព្រោះការប្រទូសរ៉ាយអ្នកដទៃធ្វើឲ្យកើតឡើងខ្លះ ដោយទាយកខ្លះ ដោយបដិគ្គាហកៈខ្លះ ។ ពាក្យថា ឯវំ ខោ រាជញ្ញ អញ្ញោ សេចក្ដីថា បពិត្ររាជញ្ញៈ ទានបែបនេះ រមែងមានផលច្រើន ដោយបច្ច័យដែលកើតឡើងព្រោះការមិនប្រទូសរ៉ាយអ្នកដទៃខ្លះ ដោយទាយកអ្នកមានសីល ព្រោះមិនប្រទូសរ៉ាយអ្នកដទៃខ្លះ ដោយបដិគ្គាហកៈ អ្នកដល់ព្រមដោយគុណមានសម្មាទិដ្ឋិជាដើមខ្លះ ។ ប្រសិនបើទាន បានបដិគ្គាហកៈអ្នកចេញចាកនិរោធ ក្រៃលែងដោយគុណ ( គុណាតិរេកសម្បទា ) និងចេតនារបស់ទាយក ជំទូលាយសោត ក៏នឹងឲ្យវិបាកទាន់ភ្នែកតែម្ដង ។

[១៦៧] ព្រះបាទបាយាសិ ស្ដាប់ធម្មកថារបស់ព្រះថេរៈ ទ្រង់និមន្តព្រះថេរៈថ្វាយមហាទាន ៧ ថ្ងៃ តាំងទានជាប្រចាំដល់មនុស្សទាំងពួង តាំងពីពេលនោះមក ។ លោកសំដៅដល់ទាននោះ ទើបពោលថា គ្រានោះឯងព្រះបាទបាយាសិ ជាដើម ។

បណ្ដាបទទាំងនោះ បទថា កាណាជិកំ គឺ បាយដែលចម្អិនពីអង្ករបាក់មានកន្ទក់ ។ ពាក្យថា តិលង្គទុតិយំ ប្រែថា មានទឹកម្ជូរជាគម្រប់ពីរ ។ ពាក្យថា ថោរកានិ ច វត្ថានិ ប្រែថា សំពត់ដែលមានសរសៃគ្រោត

គ្រាត ។ ពាក្យថា កុឡុវាលកានិ គឺ សម្ពត់ដែលប្រឡាក់ដោយទឹកអំពៅ អធិប្បាយថា សម្ពត់ផ្ទាំងធំដែលដាក់ទុកជាគំនរ ៗ ។ ពាក្យថា ឯវមនុទ្ធិសតិ គឺ បង្ហាញទុកយ៉ាងនេះ ។ ពាក្យថា ធានាចិ ប្រែថា សូម្បីដោយជើង ។ ពាក្យថា អសក្កច្ចំ គឺ វៀរសទ្ធា ឲ្យទានដោយមិនមានសទ្ធា ។ ពាក្យថា អសហត្ថា ប្រែថា មិនមែនដោយដៃរបស់ខ្លួនឯង ។ ពាក្យថា អចិត្តីកតំ គឺ វៀរការធ្វើដោយការគោរពក្នុងទាន , មិនបានចូលទៅតាំងការធ្វើដោយគោរព ឲ្យទានប្រណីតមិនបាន ។ ពាក្យថា អបវិទ្ធំ គឺ បោះឲ្យធ្លាក់រាត់រាយ ។ ពាក្យថា សុញ្ញំ សេរីសកំ សេចក្តីថា ចូលទៅកាន់វិមានប្រាក់ដែលស្ងាត់មួយ ឈ្មោះ សេរីសកៈ ។ ន័យថា មានដើមឈើធំនៅជិតទ្វារវិមាននោះ ព្រោះហេតុនោះ វិមាននោះ ទើបហៅថា សេរីសកៈ ។

## រឿង ព្រះគវម្បតិ

[១៦៨] បានឮមកថា ព្រះថេរៈ ជាប្រធានក្មេងចិញ្ចឹមគោ ក្នុងមនុស្សលោក ក្នុងជាតិមុន បោសប្រាសសម្អាតគល់ឈើដើមធំ ចាក់រោយដីខ្សាច់ និមន្តព្រះថេរៈអ្នកកាន់បិណ្ឌបាតិកធុតង្គមួយរូប ឲ្យអង្គុយត្រង់គល់ឈើ ថ្វាយអាហារដែលខ្លួនបានមក ចុតិចាកមនុស្សលោកនោះ ទៅ

កើតក្នុងវិមានប្រាក់នោះ ដោយអានុភាពរបស់បុណ្យនោះ ។ ដើមឈើតាំងនៅជិតទ្វារវិមាន ។ ៥០ ឆ្នាំ ដើមឈើនោះទើបមានផ្លែ ។ តពីនោះទេវបុត្រក៏ដល់សេចក្តីតក់ស្លុតថា កន្លងទៅ ៥០ ឆ្នាំហើយ ។ សម័យតមក ទេវបុត្រនោះទៅកើតក្នុងពួកមនុស្ស ក្នុងសម័យរបស់ព្រះមានព្រះភាគរបស់យើង ស្តាប់ធម្មកថារបស់ព្រះសាស្តា ក៏សម្រេចព្រះអរហត្ត ។ តែដោយអំណាចការធ្លាប់នៅ ព្រះថេរៈក៏ទៅកាន់វិមាននោះឯងនៅរឿយ ៗ ដើម្បីសម្រាកពេលថ្ងៃ ។ ន័យថា វិមាននោះ ជាទីនៅជាសុខតាមរដូវកាល របស់ព្រះថេរៈនោះ លោកសំដៅយកហេតុយ៉ាងនោះ ទើបពោលថា សម័យនុ៎ះឯង ព្រះគវម្បតិ ដូច្នេះជាដើម ។

ពាក្យថា សោ សក្កច្ចំ ទានំ ទត្វា សេចក្តីថា ឧត្តរមាណពនោះឲ្យទាន សូម្បីជារបស់អ្នកដទៃ ក៏ដោយគោរព ។ ពាក្យថា ឯវមារោចេហិ សេចក្តីថា សូមលោកម្ចាស់ប្រាប់ ( មនុស្ស ) ដោយន័យជាដើមថា អ្នកទាំងឡាយចូរឲ្យទានដោយគោរព ដូច្នេះ ។ ក៏ឯមហាជនស្តាប់ការប្រាប់របស់ព្រះថេរៈនោះហើយ ក៏ឲ្យទានដោយគោរព ទៅកើតក្នុងទេវលោក ។ ចំណែកស្រីបម្រើ (បរិចារិកា) របស់ស្តេចបាយាសិ សូម្បីឲ្យទានដោយគោរព ក៏ទៅកើតក្នុងសម្នាក់របស់ស្តេចបាយាសិនុ៎ះឯង ដោយ

អំណាចសេចក្តីប្រាថ្នា ន័យថា សេរីសកវិមាននោះ ជាវិមានសម្រាប់ទេព ដែលចារិកមកពីគ្រប់ទិស មាននៅក្នុងព្រៃឈ្មោះ **វត្តនី** ( កំបាំងឯង ) ។ ក៏ក្នុងថ្ងៃមួយ បាយាសិទេវបុត្រ សម្តែងខ្លួនដល់ពួកឈ្មួញទាំងឡាយ ហើយពោលប្រាប់កម្មដែលខ្លួនធ្វើទុកនោះឯង ។

(ចប់ អដ្ឋកថាបាយាសិរាជញ្ញសូត្រទី ១០)

ការពណ៌នាសេចក្តីនៃមហាវគ្គ

ដែលមាន ៧ សូត្រ ក៏ចប់ស្រេចហើយដែរ ។

សុមង្គលវិលាសិនី ទីឃនិកាយ មហាវគ្គ ចតុត្ថភាគ

" ភាគ ១៧ "

រួមព្រះសូត្រដែលមានក្នុងវគ្គនេះគឺ

មហាសុទស្សនសូត្រ ១ ជនវសភសូត្រ ១ មហាគោវិន្ទសូត្រ ១

មហាសមយសូត្រ ១ សក្កបញ្ហសូត្រ ១ មហាសតិប្បដ្ឋានសូត្រ ១

បាយាសិរាជញ្ញសូត្រ ១

រួមជា ៧ សូត្រ ។


ព្រះរាជាណាចក្រកម្ពុជា